★ ★ ★ ★ ★ អត្ថបទនៃសំណើច្បាប់ ★ ★ ★ ★ ★

ការបោះឆ្នោតសាកលរដ្ថ California

ថ្ងៃអង្គារ ទី 3 ខែ វិច្ឆិកា ឆ្នាំ 2020

មណ្ឌលបោះឆ្នោតបើកទ្វារពីម៉ោង 7:00 ព្រឹករហូតដល់ម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត!

បោះឆ្នោតដោយសុវត្ថិភាពនៅរដ្ថ CALIFORNIA

វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ

ខ្ញុំ Alex Padilla រដ្ថលេខាធិការនៃរដ្ថ California សូមបញ្ជាក់ថាវិធានការ ដែលបានដាក់បញ្ចូលនៅទីនេះនឹងត្រូវបានដាក់បញ្ជូន ទៅអ្នកបោះឆ្នោតនៃរដ្ថ California នៅ ក្នុងការបោះឆ្នោតសាកល ដែលនឹងត្រូវធ្វើឡើ ទូទាំងរដ្ថនៅថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020 ហើយថាមគ្គុទ្ទេសក៍នេះត្រូវបានរៀបចំយ៉ាងត្រឹមត្រូវតាមច្បាប់។ ហត្ថលេខានិងត្រារបស់រដ្ថធ្វើនៅ Sacramento រដ្ថ California នៅថ្ងៃទី 10 ខែសីហា ឆ្នាំ 2020។

Alex Padilla, រដ្ថលេខាធិការ

★ អ្នកអាចស្នើសុំច្បាប់ចម្លងបន្ថែមនៃអត្ថបទសំណើច្បាប់នេះដោយទាក់ទងទៅមន្ត្រី រៀបចំការបោះឆ្នោតខោនធីរបស់អ្នក ឬហៅតាមលេខ (888) 345-4917 ★

កម្រងសិទ្ធិ

អ្នកបោះឆ្នោត

អ្នកមានសិទ្ធិដូចខាងក្រោម៖

1. **សិទ្ធិបោះឆ្នោត ប្រសិនបើអ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះ។** អ្នកមានលក្ខណៈសម្បត្តិអាចបោះឆ្នោតបាន ប្រសិនបើអ្នក៖
   - ជាពលរដ្ឋអាមេរិកដែលរស់នៅរដ្ឋ California
   - យ៉ាងហោចណាស់មានអាយុ 18 ឆ្នាំ
   - បានចុះឈ្មោះនៅកន្លែងដែលអ្នកកំពុងរស់នៅបច្ចុប្បន្ន
   - បច្ចុប្បន្នមិនស្ថិតក្នុងពន្ធនាគាររដ្ឋ ឬពន្ធនាគារសហព័ន្ធ ឬត្រូវបានដោះលែងបណ្តោះអាសន្នដោយសារទោសបទឧក្រិដ្ឋណាមួយ
   - បច្ចុប្បន្នតុលាការមិនបានរកឃើញថាអសមត្ថភាពផ្លូវចិត្តក្នុងការបោះឆ្នោត

2. **សិទ្ធិក្នុងការបោះឆ្នោតប្រសិនបើអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះរួចហើយ ទោះបីជាឈ្មោះរបស់អ្នកមិនមាននៅក្នុងបញ្ជី។** អ្នកនឹងបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន។ សន្លឹកឆ្នោតរបស់អ្នកនឹងត្រូវបានរាប់បញ្ចូល ប្រសិនបើមន្ត្រីបោះឆ្នោតកំណត់ថាអ្នកមាន លក្ខណៈសម្បត្តិដើម្បីបោះឆ្នោត។

3. **សិទ្ធិក្នុងការបោះឆ្នោត ប្រសិនបើអ្នកនៅតែស្ថិតនៅក្នុងជួររង់ចាំនៅពេលដែលការិយាល័យបោះឆ្នោតត្រូវបិទ។**

4. **សិទ្ធិបោះឆ្នោតដោយសន្លឹកឆ្នោតសម្ងាត់** ដោយមិនមាននរណារំខានអ្នក ឬប្រាប់អ្នកអំពីរបៀបបោះឆ្នោត។

5. **សិទ្ធិទទួលបានសន្លឹកឆ្នោតថ្មី ប្រសិនបើអ្នកបានបង្កើតកំហុស** ប្រសិនបើអ្នកមិនទាន់បាន បោះឆ្នោតរួច។ អ្នកអាចៈ

   ស្នើសុំមន្ត្រីបោះឆ្នោតនៅកន្លែងបោះឆ្នោតរកសន្លឹកឆ្នោតថ្មី

   ប្តូរ សន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នក រកសន្លឹកឆ្នោតថ្មីមួយនៅការិយាល័យ បោះឆ្នោត ឬកន្លែងបោះឆ្នោតរបស់អ្នក ឬ

   បោះឆ្នោតដោយការប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន។

6. **សិទ្ធិទទួលបានជំនួយក្នុងការបោះសន្លឹកឆ្នោតរបស់អ្នក**ពីនរណាម្នាក់ ដែលអ្នកជ្រើសរើសលើកលែងតែពីនិយោជក ឬ តំណាងសហជីពរបស់អ្នក។

7. **សិទ្ធិទម្លាក់សន្លឹកឆ្នោត បោះតាមសំបុត្ររបស់អ្នកដែលបានបំពេញ រួចនៅកន្លែងបោះឆ្នោតណាមួយ**នៅក្នុងរដ្ឋ California។

8. **សិទ្ធិទទួលបានឯកសារបោះឆ្នោតជាភាសាមួយក្រៅពីភាសាអង់គ្លេស** ប្រសិនបើមានមនុស្សគ្រប់គ្រាន់ នៅក្នុងមណ្ឌលបោះឆ្នោតរបស់អ្នកនិយាយភាសានោះ។

9. **សិទ្ធិក្នុងការសួរសំណួរទៅមន្ត្រីបោះឆ្នោតអំពីនីតិវិធី បោះឆ្នោត** និងមើល ពីដំណើរការបោះឆ្នោត។ ប្រសិនបើមនុស្សដែលអ្នកសួរមិនអាចឆ្លើយតបនឹងសំណួររបស់អ្នកបានពួកគេត្រូវតែបញ្ជូនអ្នកទៅមនុស្សដែលសមស្របដើម្បីទទួលបានចម្លើយ។ ប្រសិនបើអ្នកបង្ករការរំខានពួកគេអាចឈប់ឆ្លើយនឹងអ្នក។

10. **សិទ្ធិរាយការណ៍អំពីសកម្មភាពបោះឆ្នោតខុសច្បាប់ ឬក្លែងបន្លំ**ទៅមន្ត្រីបោះឆ្នោត ឬការិយាល័យរដ្ឋលេខាធិការ។

    នៅលើគេហទំព័រ **www.sos.ca.gov**
    តាមទូរស័ព្ទលេខ **(888) 345-4917**
    តាមអ៊ីម៉ែល **elections@sos.ca.gov**

ប្រសិនបើអ្នកជឿថាអ្នកត្រូវបានបដិសេធ ចំពោះសិទ្ធិណាមួយក្នុងចំណោមសិទ្ធិទាំងនេះ សូមទូរស័ព្ទទៅបណ្តាញទាន់ហេតុការណ៍សម្រាប់អ្នកបោះឆ្នោតដោយសម្ងាត់ឥតគិតថ្លៃរបស់រដ្ឋលេខាធិការ តាមលេខ **(888) 345-4917**

សំណើប្រជាមតិ 15

វិធានការផ្តួចផ្តើមនេះ ត្រូវបានដាក់ជូនប្រជាជនដោយអនុលោមទៅតាមប្រការនៃ ផ្នែក 8 មាត្រា II នៃធម្មនុញ្ញរដ្ឋ California ។

វិធានការផ្តួចផ្តើមនេះបន្ថែមផ្នែកនានាទៅលើធម្មនុញ្ញរដ្ឋ California ហេតុដូច្នេះ ប្រការថ្មីដែលត្រូវបានស្នើអោយបន្ថែមគឺត្រូវបានបោះពុម្ពជា *ប្រភេទអក្សរទ្រេត* ដើម្បីបង្ហាញថាពួកវាជាចំណុចថ្មី។

សំណើច្បាប់

ផ្នែក 1. ចំណងជើង.

វិធានការនេះត្រូវបានស្គាល់ថាជា "ច្បាប់មូលនិធិសាលារៀននិងសហគមន៍ក្នុងមូលដ្ឋានរដ្ឋ Californa ឆ្នាំ 2020 (The California Schools and Local Communities Funding Act of 2020)"។

ផ្នែក 2. លទ្ធផលរកឃើញ។

(a) រដ្ឋ California គឺជាសេដ្ឋកិច្ចធំបំផុតទីប្រាំនៅក្នុងពិភពលោក ប៉ុន្តែប្រសិនបើយើងមិនវិនិយោគលើអនាគតរបស់យើងទេ យើងនឹងរត់ពីក្រោយគេវិញ។ ដើម្បីធ្វើឲ្យរីកលូតលាស់សេដ្ឋកិច្ចរបស់យើង និងផ្តល់គុណភាពកាន់តែល្អសម្រាប់ពេលនេះនិងសម្រាប់ជំនាន់ក្រោយទៀតនៃពលរដ្ឋ California យើងត្រូវធ្វើឲ្យកាន់តែប្រសើរឡើងក្នុងការងារវិនិយោគលើសាលារៀន មហាវិទ្យាល័យសហគមន៍ និងសហគមន៍មូលដ្ឋាន ហើយត្រូវខិតខំថែមទៀតដើម្បីលើកទឹកចិត្តអាជីវកម្មខ្នាតតូចនិងអាជីវកម្មចាប់ផ្តើមថ្មី។

(b) ភាពប្រកួតប្រជែងរបស់យើងចាប់ផ្តើមជាមួយនឹងការធ្វើឲ្យកូនៗ និងការអប់រំ របស់ពួកគេជាអាទិភាព។ ការកាត់មូលនិធិនិងការផ្តល់មូលនិធិមិនគ្រប់គ្រាន់រាប់ទសវត្សបានធ្វើឲ្យអន្តរាយដល់សាលារៀននៅរដ្ឋ California ។ ការសិក្សាថ្មីៗមួយបានដាក់ចំណាត់ថ្នាក់លើលទ្ធផលនៃសាលារៀននៅរដ្ឋ California ស្ថិតនៅពាក់កណ្តាលបាតក្រោមក្នុងចំណោមរដ្ឋទាំងអស់។ រដ្ឋនានាដែលទទួលបានចំណាត់ថ្នាក់ខ្ពស់បំផុតចំណាយប្រាក់រាប់ពាន់ដុល្លារសម្រាប់សិស្សម្នាក់ៗច្រើនជាងនៅរដ្ឋ California ។

(c) កង្វះមូលនិធិរបស់រដ្ឋ California បង្កផលវិបាកដោយផ្ទាល់ដល់កូនៗរបស់យើង៖ យើងនៅចំណាត់ថ្នាក់ចុងក្រោយបង្អស់នៅក្នុងប្រទេសក្នុងសមាមាត្រចំនួនគ្រូនិងសិស្ស ចុងក្រោយគេក្នុងសមាមាត្រចំនួនអ្នកផ្តល់ប្រឹក្សាណែនាំនិងសិស្ស ហើយចុងក្រោយគេក្នុងសមាមាត្រចំនួនបណ្ណារក្សនិងសិស្ស។

(d) គុណភាពជីវិតក្នុងសហគមន៍មូលដ្ឋានរបស់យើងក៏ចាំបាច់ជាទីបំផុតសម្រាប់អនាគតសេដ្ឋកិច្ចរបស់យើង។ វាអាស្រ័យទៅលើផ្លូវថ្នល់ដែលមានសុវត្ថិភាពនិងស្អាត សេវាកម្មសង្គ្រោះបន្ទាន់ដែលយើងពឹងពាក់ សួនច្បារនិងកម្មវិធីកំសាន្តដែលរក្សាយុវជនអោយឆ្ងាយពីបញ្ហា និងផ្លូវថ្នល់ដែលយើងថែទាំបានល្អ។ ទីក្រុង ខោនធី និងទីភ្នាក់ងារក្នុងមូលដ្ឋានរបស់យើងគឺកំពុងនៅជួរមុខ ប្រឈមជាមួយនឹងផលវិបាកនៃការខ្វះលំនៅដ្ឋានដែលមានតម្លៃសមរម្យ និងការកើនឡើងនៃភាពឥតទីជម្រក ព្រមទាំងហានិភ័យកាន់តែអាក្រក់ដោយសារភ្លើងឆេះព្រៃ និងគ្រោះមហន្តរាយផ្សេងៗទៀត។

(e) ពន្ធទ្រព្យសម្បត្តិលើអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្ម គឺជាប្រភពចម្បងនៃមូលនិធិសម្រាប់សាលារៀន និងសហគមន៍មូលដ្ឋានរបស់យើង។ ខណៈដែលគ្រប់រដ្ឋផ្សេងៗទៀតវាយតម្លៃលើអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មដោយផ្អែកលើតម្លៃទីផ្សារត្រឹមត្រូវរបស់ខ្លួន រដ្ឋ California អនុញ្ញាតពន្ធអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្ម អស់រយៈពេលច្រើនឆ្នាំ ឬរហូតដល់រាប់ទសវត្សដោយមិនមានការវាយតម្លៃឡើងវិញ។ ប្រព័ន្ធមិនប្រក្រតីនេះគឺងាយនឹងរងប៉ះពាល់ដោយគ្រោងការណ៍លួចគេចពន្ធ បង្វែរមូលនិធិចេញពីសាលារៀននិងសហគមន៍មូលដ្ឋាន រួមចំណែកដល់កង្វះខាតលំនៅដ្ឋានតម្លៃសមរម្យ ធ្វើឲ្យខូចការប្រកួតប្រជែងផ្នែកអាជីវកម្ម និងធ្វើឲ្យបាត់បង់ប្រយោជន៍ដល់អាជីវកម្មចាប់ផ្តើមថ្មី។

(f) ការប៉ាន់ប្រមាណមិនគ្រប់គ្រាន់របស់រដ្ឋ California ទៅលើអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មគឺជាបញ្ហាកំពុងរីកធំឡើង។ អ្នកវិនិយោគនិងសាជីវកម្មធំៗដែលភាគច្រើនមកពីរដ្ឋ និងខោនធីផ្សេងៗ កំពុងប្រើប្រាស់ផែនការជាច្រើនដើម្បីគេចពីច្បាប់និងទិញ លក់ អចលនទ្រព្យដោយមិនត្រូវបានវាយតម្លៃឡើងវិញ ដែលធ្វើឲ្យបាត់បង់មូលនិធិសម្រាប់សាលារៀន និងសហគមន៍មូលដ្ឋានរបស់យើងរាប់ពាន់លានដុល្លារ។

(g) ការសិក្សានាពេលថ្មីៗនេះមួយដោយសាកលវិទ្យាល័យ ភាគខាងត្បូង California បានរកឃើញថាអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មដែលមិនមានការវាយតម្លៃ អនុញ្ញាតឲ្យម្ចាស់កម្មសិទ្ធិគេចពន្ធអចលនទ្រព្យក្នុងមូលដ្ឋាន ជាង $11 ពាន់លានក្នុងមួយឆ្នាំដែលទឹកប្រាក់នេះគួរតែទៅគាំទ្រដល់សាលារៀន និងសហគមន៍មូលដ្ឋានរបស់យើង។

(h) ប្រព័ន្ធពន្ធអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មមិនប្រក្រតីរបស់រដ្ឋ California រួមចំណែកដល់វិបត្តិលំនៅដ្ឋានតម្លៃសមរម្យនៅរដ្ឋ California។ ការសិក្សាដែលធ្វើឡើងដោយការិយាល័យអ្នកវិភាគនីតិបញ្ញត្តិនិងសាកលវិទ្យាល័យ California បានបង្ហាញថាប្រព័ន្ធពន្ធអចលនទ្រព្យនៅរដ្ឋ California លើកទឹកចិត្តឲ្យម្ចាស់អចលនទ្រព្យរក្សាទុកអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មទំនេរចោល និងមិនប្រើប្រាស់គ្រប់គ្រាន់។ ប្រព័ន្ធមានកំណែទម្រង់ដែលវាយតម្លៃលើអចលនទ្រព្យទាំងអស់ដោយផ្អែកលើតម្លៃទីផ្សារត្រឹមត្រូវរបស់វា នឹងបង្កើតការលើកទឹកចិត្តថ្មីដ៏មានថាមពលដើម្បីសាងសង់លំនៅដ្ឋានថ្មី។

(i) ម្ចាស់អចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មគ្រប់រូបទទួលអត្ថប្រយោជន៍ពីសាលារៀន និងសេវាកម្មក្នុងមូលដ្ឋានដូចជាសុវត្ថិភាពសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ ។ វាមានភាពអយុត្តិធម៌ និងប្រឆាំងការប្រកួតប្រជែងដែលប្រព័ន្ធពន្ធ អចលនទ្រព្យបង្ខំអាជីវកម្មមួយចំនួនឲ្យបង់ពន្ធអចលនទ្រព្យខ្ពស់ជាងដើម្បីគាំទ្រដល់សាលារៀន និងសហគមន៍មូលដ្ឋានរបស់យើង ខណៈពេលដែលគូប្រជែងរបស់ពួកគេបង់ពន្ធអចលនទ្រព្យទាបជាងព្រោះតែអចលនទ្រព្យរបស់ពួកគេត្រូវបានប៉ាន់ប្រមាណក្រោមតម្លៃទីផ្សារត្រឹមត្រូវ ។

(j) ប្រព័ន្ធពន្ធអចលនទ្រព្យមិនប្រក្រតីរបស់រដ្ឋ California មិនត្រឹមតែធ្វើឲ្យខូចការប្រកួតប្រជែងប៉ុណ្ណោះទេ វាក៏បំបាក់ទឹកចិត្តលើការវិនិយោគអាជីវកម្មផងដែរ។ នៅក្រោមប្រព័ន្ធបច្ចុប្បន្ន អាជីវកម្មដែលវិនិយោគលើការកែលម្អ អចលនទ្រព្យរបស់ ពួកគេចង់ឲ្យមានការវាយតម្លៃឡើងវិញ និងពន្ធអចលនទ្រព្យដែលខ្ពស់ជាងមុន។ ប៉ុន្តែ អាជីវកម្មដែលមិនវិនិយោគលើការកែលម្អអចលនទ្រព្យរបស់ពួកគេ បន្តរីករាយនឹងថ្លៃចំណាយតិចនៃការ វាយតម្លៃទាបនេះ។

(k) ការសិក្សាមួយដែលធ្វើនៅសាកលវិទ្យាល័យ California បង្ហាញថាការវាយតម្លៃឡើងវិញលើអចលនទ្រព្យពាណិជ្ជកម្មនឹងមានអត្ថប្រយោជន៍វិជ្ជមានសុទ្ធទៅលើការងារនិងសេដ្ឋកិច្ចរដ្ឋ California ។

(l) ប្រសិនបើយើងបានធ្វើកំណែទម្រង់បញ្ហានៃការវាយតម្លៃមិនគ្រប់គ្រាន់របស់រដ្ឋ California ទៅលើអចនទ្រព្យអាជីវកម្មនោះរដ្ឋ California នឹងនៅតែស្ថិតក្នុងចំណាត់ថ្នាក់ក្នុងចំណោមរដ្ឋទាបជាងគេបំផុតសម្រាប់ពន្ធអចលនទ្រព្យអាជីវកម្មនៅក្នុងប្រទេសដដែល ព្រោះតែប្រការនៃធម្មនុញ្ញរដ្ឋ California ពាក់ព័ន្ធនឹងការកំណត់ដែនត្រឹម 1% នៅលើអត្រាពន្ធ អចលនទ្រព្យ។

(m) អាជីវកម្មខ្នាតតូច និងអាជីវកម្មចាប់ផ្តើមថ្មីដែលរីកចម្រើនគឺជាមូលដ្ឋានគ្រឹះសម្រាប់សេដ្ឋកិច្ចរដ្ឋ California នៅពេលនេះ និង

នៅពេលអនាគតរបស់ យើង។ ពន្ធទ្រព្យសម្បត្តិទៅលើឧបករណ៍ និងគ្រឿងសង្ហារឹមបំបាក់ទឹកចិត្តដល់អាជីវកម្មចាប់ ផ្តើមថ្មី អាជីវកម្មខ្នាតតូច និងអាជីវកម្មធំៗ មិនឲ្យចង់ធ្វើការវិនិយោគផលិតថ្មី។ តាមរយៈការតម្រូវឲ្យអចលនទ្រព្យធំៗដែលត្រូវបានវាយតម្លៃមិនគ្រប់គ្រាន់ ទទួលការប៉ាន់ប្រមាណតាមតម្លៃទីផ្សារត្រឹមត្រូវនោះ អាជីវកម្មខ្នាតតូចអាចនឹងត្រូវបានលើកលែងទាំងស្រុងពីពន្ធទ្រព្យសម្បត្តិលើឧបករណ៍និងគ្រឿងសង្ហារឹម ហើយពន្ធអាចត្រូវបានកាត់បន្ថយយ៉ាងច្រើនសម្រាប់អាជីវកម្មផ្សេងទៀត ដោយការដកចេញកត្តាមិនលើកទឹកចិត្តនេះ ដោយមិនខូចប្រយោជន៍ដល់មូលនិធិសម្រាប់សាលារៀន និងសហគមន៍ក្នុងមូលដ្ឋានរបស់យើង។

(n) ការវាយតម្លៃឡើងវិញលើអចលនទ្រព្យពាណិជ្ជកម្មនិងឧស្សាហកម្ម ដែលមិនមានការវាយតម្លៃគ្រប់គ្រាន់នៅក្នុងរដ្ឋ California នឹងប៉ះពាល់ជាចម្បងលើអចលនទ្រព្យមួយចំនួនតូចដែលជាកម្មសិទ្ធិរបស់សាជីវកម្មធំៗបំផុត និងអ្នកវិនិយោគដែលសម្បូរទ្រព្យធនបំផុត។ ស្មើរតែ 80 ភាគរយនៃអត្ថប្រយោជន៍ពន្ធនៃការវាយតម្លៃមិនគ្រប់គ្រាន់នេះដែល អនុញ្ញាតដោយប្រព័ន្ធបច្ចុប្បន្ន មានត្រឹមតែ 8 ភាគរយនៃអចលនទ្រព្យប៉ុណ្ណោះ។

(o) អត្ថប្រយោជន៍ចំពោះសាលារៀន សហគមន៍មូលដ្ឋាននិងសេដ្ឋកិច្ចរបស់យើងដែលបានមកពីការបញ្ចប់ការវាយតម្លៃមិនគ្រប់គ្រាន់លើអចលនទ្រព្យពាណិជ្ជកម្មនិងឧស្សាហកម្មអាចសម្រេចបាន ខណៈពេលដែលនៅការពារអាជីវកម្មខ្នាតតូចតាមរយៈការលើកលែងនិងពន្យារពេលការវាយតម្លៃឡើងវិញហើយស្របគ្នានេះដែរ ការលើកទឹកចិត្តអាជីវកម្មខ្នាតតូចតាមរយៈការបង្កើតបរិយាកាសប្រកួតប្រជែងដែលស្មើភាពគ្នាជាងមុន និងតាមរយៈការលុបបំបាត់ពន្ធទ្រព្យសម្បត្តិ លើឧបករណ៍ និងគ្រឿងសង្ហារឹមអាជីវកម្ម។

(p) ការកែទម្រង់ការវាយតម្លៃចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មទៅតាមតម្លៃទីផ្សារត្រឹមត្រូវនឹងនាំមកនូវប្រព័ន្ធកាន់តែត្រឹមត្រូវសម្រាប់សាលារៀនរបស់យើង សហគមន៍មូលដ្ឋានរបស់យើង និងអាជីវកម្មរបស់យើង។ អាជីវកម្មទាំងអស់នឹងប្រកួតប្រជែងក្នុងបរិយាកាសស្មើភាពគ្នាដែលនឹងបង្កើតអោយមានប្រាក់រាប់ពាន់លានដុល្លារបន្ថែមសម្រាប់គាំទ្រដល់សាលារៀន និងសហគមន៍មូលដ្ឋានរបស់យើង។

ផ្នែក 3. គោលបំណង និងចេតនា។

វាគឺជាចេតនារបស់ពលរដ្ឋ California ក្នុងការអនុវត្តទាំងអស់ដូចខាងក្រោមនៅក្នុងវិធានការនេះ ៖

(a) រក្សាក្នុងគ្រប់វិធីរបស់សំណើប្រជាមតិ 13 នូវការការពារសម្រាប់ម្ចាស់ផ្ទះ និងសម្រាប់អចលនទ្រព្យជួលជាលំនៅដ្ឋាន ។ វិធានការនេះប៉ះពាល់តែការវាយតម្លៃលើអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មដែលជាប់ពន្ធប៉ុណ្ណោះ។

(b) ផ្តល់ចំណូលដែលកើនឡើង និងមានស្ថេរភាពសម្រាប់សាលារៀន ទីក្រុង ខោនធី និងទីភ្នាក់ងារក្នុងមូលដ្ឋានផ្សេងទៀត ដោយការតម្រូវឲ្យអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មដែលមិនទាន់មានការវាយតម្លៃគ្រប់គ្រាន់ ទទួលបានការវាយតម្លៃតាមតម្លៃទីផ្សារត្រឹមត្រូវ ។

(c) បែងចែកប្រាក់ចំណូលថ្មីដែលបានមកពីវិធានការនេះទៅដល់សាលារៀន និងសហគមន៍មូលដ្ឋាន មិនមែនទៅរដ្ឋទេ។

(d) ធានាថាចំណែកនៃប្រាក់ចំណូលថ្មីណាមួយដែលចូលទៅសាលារៀនក្នុងមូលដ្ឋាននិងមហាវិទ្យាល័យសហគមន៍ ដោយសារលទ្ធផលនៃវិធានការនេះត្រូវបានចាត់ទុកជាប្រាក់ចំណូលថ្មីដែលបន្ថែមពីលើមូលនិធិផ្សេងទៀតសម្រាប់សាលារៀន និងមហាវិទ្យាល័យសហគមន៍ រួមទាំងសំណើប្រជាមតិ 98 ។

(e) ធានាថាមណ្ឌលមានសាលារៀនទាំងអស់ និងមហាវិទ្យាល័យសហគមន៍ នឹងទទួលបានមូលនិធិបន្ថែមពីវិធានការនេះ និងថាមូលនិធិដែលចូលទៅសាលារៀន និង មហាវិទ្យាល័យសហគមន៍ត្រូវបានបែងចែកក្នុងរបៀបដែលស្របទៅតាម រូបមន្តមូលនិធិគ្រប់គ្រងក្នុងមូលដ្ឋានក្នុងចេតនាលើកកម្ពស់សមធម៌។

(f) ធានាថាប្រាក់ចំណូលថ្មីនឹងចូលទៅទីក្រុង ខោនធី និងមណ្ឌលពិសេសដែលជាលទ្ធផលនៃវិធានការណ៍នេះ និងត្រូវបានបែងចែកក្នុងរបៀបដូចគ្នាទៅនឹងចំណូលពន្ធលើអចលនទ្រព្យផ្សេងទៀតដែលស្របនឹងវិធានការណ៍លើសន្លឹកឆ្នោតពីមុនដែលបានអនុម័តដោយអ្នកបោះឆ្នោតដើម្បីកែលម្អគុណភាពជីវិតក្នុងសហគមន៍មូលដ្ឋាននៅគ្រប់ផ្នែកទាំងអស់នៃរដ្ឋ California ។

(g) ធ្វើអោយប្រាកដថាមានតម្លាភាពសាធារណៈពេញលេញតាមរយៈការតម្រូវឲ្យសាលារៀន មហាវិទ្យាល័យសហគមន៍ ទីក្រុង ខោនធី និងមណ្ឌលពិសេសបង្ហាញជាសាធារណៈនូវប្រាក់ចំណូលថ្មីដែលគេបានទទួល និងរបៀបចំណាយប្រាក់ចំណូលទាំងនោះតាមលក្ខណៈដែលទូលំទូលាយ និងងាយយល់។

(h) មានភាពច្បាស់លាស់ថាវិធានការនេះអនុវត្តតែចំពោះអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មដែលជាប់ពន្ធដោយការរួមបញ្ចូលនូវប្រការដែលចែងថា៖

(1) អចលនទ្រព្យលំនៅដ្ឋានទាំងអស់ត្រូវបានលើកលែងដូច្នេះម្ចាស់ផ្ទះ និងអ្នកជួល មិនរងការប៉ះពាល់ដោយវិធានការនេះតាមរបៀបណាមួយឡើយ។

(2) វិធានការនេះមិនផ្លាស់ប្តូរលើច្បាប់ដែលមានស្រាប់ដែលប៉ះពាល់ដល់ពន្ធដារ ឬការការពារដី កសិកម្មឡើយ។

(i) មិនធ្វើការផ្លាស់ប្តូរលើប្រការធម្មនុញ្ញនៃសំណើប្រជាមតិ 13 ដែលទាក់ទងនឹងដែនកំណត់ 1 ភាគរយលើអត្រាពន្ធអចលនទ្រព្យសម្រាប់អចលនទ្រព្យជាប់ពន្ធទាំងអស់ដើម្បីឲ្យពន្ធ អចលនទ្រព្យក្នុងមូលដ្ឋានលើអចលនទ្រព្យពាណិជ្ជកម្មនិងឧស្សាហកម្មនឹងបន្តស្ថិតនៅក្នុងចំណោមអត្រាទាបបំផុតនៅក្នុងប្រទេស បន្ទាប់ពីវិធានការនេះត្រូវបានយល់ព្រមដោយអ្នក បោះឆ្នោត។

(j) ធានាស្ថេរភាពសម្រាប់ម្ចាស់អចលនទ្រព្យអាជីវកម្មខ្នាតតូចដោយការផ្តល់ការមិនរាប់បញ្ចូល សម្រាប់ម្ចាស់អចលនទ្រព្យពាណិជ្ជកម្មនិងឧស្សាហកម្មខ្នាតតូច។ ចេតនានៃប្រការនេះគឺដើម្បីផ្តល់ការមិនរាប់បញ្ចូលដែលអនុវត្តតែលើម្ចាស់ពិតប្រាកដនៃអាជីវកម្មខ្នាតតូច ហើយថាម្ចាស់អចលនទ្រព្យធំៗត្រូវបានបង្ការពីការប្រើប្រាស់ការមិនរាប់បញ្ចូលសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។

(k) ពន្យារពេលការវាយតម្លៃឡើងវិញសម្រាប់អចលនទ្រព្យដែលអាជីវកម្មខ្នាតតូចមានចំនួន 50 ភាគរយ ឬច្រើនជាងនេះនៃទីតាំងដែលមានមនុស្សប្រើប្រាស់ រហូតដល់កាលបរិច្ឆេទវាយតម្លៃឆ្នាំ 2025–26 ដើម្បីផ្តល់ឲ្យអ្នកជួលទីតាំងអាជីវកម្មខ្នាតតូចទាំងនោះនូវពេលវេលាបន្ថែមដើម្បីជ្រើសរើសជម្រើសនៃការជួលដែលមានប្រសិទ្ធភាពសម្រាប់ពួកគេ ដែលទទួលស្គាល់ថាផលប៉ះពាល់នៃវិធានការនេះនឹងខុសគ្នាសម្រាប់អចលនទ្រព្យនីមួយៗអាស្រ័យលើថាតើការវាយតម្លៃបច្ចុប្បន្នវាជិតប៉ុនណាទៅនឹងតម្លៃទីផ្សារត្រឹមត្រូវ ហើយតើវាមានលក្ខណៈសម្បត្តិសម្រាប់ការមិនរាប់បញ្ចូលអចលនទ្រព្យខ្នាតតូចសម្រាប់អចលនទ្រព្យ ដែលមានតម្លៃទីផ្សារត្រឹមត្រូវក្នុងទឹកប្រាក់ចាប់ពី $3 លានចុះក្រោមឬទេ។

(l) លើកទឹកចិត្តអាជីវកម្មថ្មី និងអាជីវកម្មដែលមានស្រាប់អោយធ្វើការវិនិយោគថ្មីដោយការលុបបំបាត់ពន្ធទ្រព្យផ្ទាល់ខ្លួនរបស់អាជីវកម្មលើឧបករណ៍និងគ្រឿងសង្ហារឹមសម្រាប់អាជីវកម្មខ្នាតតូច និងការផ្តល់ការលើកលែងក្នុងទឹកប្រាក់ $500,000 ក្នុងមួយឆ្នាំសម្រាប់អាជីវកម្មផ្សេងទៀត។ រដ្ឋសភាអាចនឹងមិនកាត់បន្ថយការលើកលែងនេះទេ ប៉ុន្តែអាចនឹងបង្កើនវាវិញ។

(m) ផ្តល់សមធម៌កាន់តែច្រើនលើពន្ធដារនៃអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មតាមរយៈការ វាយតម្លៃអចលនទ្រព្យទាំងអស់អាស្រ័យលើតម្លៃទីផ្សារត្រឹមត្រូវជាក់ស្តែងដូចជាអាជីវកម្មចាប់ផ្តើមថ្មីនិងអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មថ្មីដែលកំពុងត្រូវបានវាយតម្លៃផ្អែកលើតម្លៃទីផ្សារត្រឹមត្រូវជាក់ស្តែងរបស់ពួកគេ។ ចេតនានេះគឺដើម្បីអោយអាជីវកម្មទាំងអស់ប្រកួតប្រជែងក្នុងបរិយាកាស កាន់តែស្មើភាពគ្នានិងធ្វើឲ្យប្រាកដថាអាជីវកម្មទាំងអស់បង់ប្រាក់ចំណែករបស់ពួកគេដើម្បីគាំទ្រដល់សាលារៀន និង សហគមន៍មូលដ្ឋានដែលពួកគេទទួលអត្ថប្រយោជន៍។

(n) ក្រោយពីការពិភាក្សាជាមួយក្រុមការងារគ្រប់គ្រងពន្ធអចលនទ្រព្យ តម្រូវឲ្យរដ្ឋសភាផ្តល់តាម លក្ខន្តិកៈសម្រាប់ដំណាក់កាលចាប់ផ្តើមនៃការវាយតម្លៃឡើងវិញលើអចលនទ្រព្យពិត ពាណិជ្ជកម្ម និងឧស្សាហកម្ម ដែលមិនទាន់បានវាយតម្លៃគ្រប់គ្រាន់ដើម្បីអ្នកវាយតម្លៃប្រចាំខោនធីអាចនឹង អនុវត្តច្បាប់ថ្មីប្រកបដោយប្រសិទ្ធភាព។ ជំហានអនុវត្តបែបនេះនឹងចាប់ផ្តើមជាមួយនឹងកាលបរិច្ឆេទ វាយតម្លៃសម្រាប់ឆ្នាំសារពើពន្ធ 2022–23 ហើយនិងកើតឡើងជាច្រើនឆ្នាំក្រោយទៀត។ ម្ចាស់ដែលរងការប៉ះពាល់ត្រូវមានកាតព្វកិច្ចបង់ពន្ធដោយផ្អែកលើ តម្លៃដែលបានវាយតម្លៃថ្មីចាប់ផ្តើម ពីកាលបរិច្ឆេទវាយតម្លៃសម្រាប់ឆ្នាំសារពើពន្ធនោះ នៅពេលដែលអ្នកវាយតម្លៃបានបញ្ចប់ ការ វាយតម្លៃឡើងវិញនោះ។

(o) តម្រូវឲ្យរដ្ឋសភាធានាថាប្រការនៃដំណាក់កាលចាប់ផ្តើមនេះ ផ្តល់ដល់ម្ចាស់អចលនទ្រព្យពិតនៃពាណិជ្ជកម្ម និងឧស្សាហកម្មដែលមិនទទួលបានការវាយតម្លៃត្រឹមត្រូវដែលរងប៉ះពាល់នូវពេលវេលាសមរម្យដើម្បីបង់ប្រាក់ដែលកើនឡើងនៅក្នុងកាតព្វកិច្ចពន្ធរបស់ពួកគេ ដោយសារតែ វិធានការនេះ។

(p) ផ្តល់សម្រាប់ការស្តារឡើងវិញនៃថ្លៃចំណយរដ្ឋបាលផ្ទាល់ ជាក់ស្តែងដែលកើតមាននៅតាមបណ្តាខោនធីដើម្បីអនុវត្តច្បាប់នេះដោយប្រសិទ្ធភាព។

(q) ធានាថាមូលនិធិទូទៅនិងមូលនិធិផ្សេងទៀតរបស់រដ្ឋមិនរងការប៉ះពាល់ដោយសារការទូទាត់សង ទៅរដ្ឋសម្រាប់ការកាត់បន្ថយចំណូលពន្ធដោយសារភាពកាត់បន្ថយបាននៃពន្ធអចលនទ្រព្យ។

(r) រក្សាការគ្រប់គ្រងត្រួតពិនិត្យរបស់ក្រុមប្រឹក្សាសមកម្មរដ្ឋលើប្រព័ន្ធពន្ធអចលនទ្រព្យដើម្បីធានាដល់សាធារណជនថា ការវាយតម្លៃលើអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មនៅក្នុងខោនធីទាំងអស់គឺមានសមធម៌និងដូចៗគ្នាតាមការតម្រូវនៃវិធានការនេះ ហើយត្រូវបន្តធានាថាក្រុមប្រឹក្សាសមកម្មរដ្ឋផ្តល់នូវជំនួយទូទាំងរដ្ឋតាមការចាំបាច់ដើម្បីគាំទ្រដល់ការអនុវត្តប្រកបដោយសមត្ថភាពលើវិធានការនេះ នៅក្នុងខោនធីទាំង 58។

ផ្នែក 4. ផ្នែក 8.7 ត្រូវបានបន្ថែមទៅលើមាត្រា XVI នៃធម្មនុញ្ញរដ្ឋ California ដែលចែងថា៖

ផ្នែក. 8.7. (a) មូលនិធិពន្ធអចលនទ្រព្យសាលារៀនក្នុងមូលដ្ឋាន និងមហាវិទ្យាល័យសហគមន៍ត្រូវបានបង្កើតនៅក្នុងរតនាគាររដ្ឋដើម្បីរក្សាទុកក្នុងមូលនិធិទំនុកចិត្ត ហើយត្រូវលៃបម្រុងជាបន្តដើម្បីគាំទ្រដល់ទីភ្នាក់ងារអប់រំក្នុងមូលដ្ឋាន ដូចដែលលក្ខខណ្ឌនោះត្រូវបានកំណត់ន័យនៅក្នុងផ្នែក 421 នៃច្បាប់អប់រំដូចមានចែងនៅក្នុងលក្ខន្តិកៈកាលពីថ្ងៃទី 1 ខែមករា ឆ្នាំ 2020 និងសម្រាប់ការគាំទ្រមណ្ឌលមហាវិទ្យាល័យសហគមន៍។ ទឹកប្រាក់ដែលបានដាក់ចូលទៅក្នុងមូលនិធិពន្ធអចលនទ្រព្យសាលារៀនក្នុងមូលដ្ឋាន និងមហាវិទ្យាល័យសហគមន៍ត្រូវរក្សាទុកក្នុងមូលនិធិទំនុកចិត្ត សម្រាប់សាលារៀន ហើយត្រូវបែងចែកដូចខាងក្រោម៖

(1) ដប់មួយភាគរយនៃទឹកប្រាក់នេះនឹងត្រូវបានបែងចែកដោយក្រុមប្រឹក្សាភិបាលនៃមហាវិទ្យាល័យសហគមន៍រដ្ឋ California ទៅឲ្យមណ្ឌលមហាវិទ្យាល័យសហគមន៍ក្នុងសមាមាត្រទៅនឹងមូលនិធិដែលបានគណនាសម្រាប់មណ្ឌលនីមួយៗ ស្របទៅតាមរូបមន្តបែងចែកដែលកំពុងប្រតិបត្តិការក្នុងលក្ខន្តិកៈច្បាប់ចុះថ្ងៃទី 1 ខែមករា ឆ្នាំ 2020 ឬ លក្ខន្តិកៈបន្តវេន ណាមួយក្នុងករណីដែលចំណូលពីពន្ធអចលនទ្រព្យត្រូវបានគណនាស្របទៅតាមផ្នែក 84751 នៃច្បាប់អប់រំ ឬលក្ខន្តិកៈបន្តវេនណាមួយដែលលើសពីមូលនិធិសរុបដែលបានគណនាសម្រាប់មណ្ឌលស្របតាមរូបមន្តបែងចែកដែលអនុវត្តនៅពេលនោះ ត្រូវតែបានដកចេញពីចំណែក សមាមាត្ររបស់មណ្ឌលនោះនៃមូលនិធិពន្ធអចលនទ្រព្យសាលារៀនក្នុងមូលដ្ឋាន និង មហាវិទ្យាល័យសហគមន៍។

(2) ទឹកប្រាក់ប៉ែតសិបប្រាំបួនភាគរយត្រូវបែងចែកដោយស្នងការការអប់រំសាធារណៈ ទៅមណ្ឌលនៃសាលារៀន សាលារដ្ឋឯករាជ្យ និងការិយាល័យអប់រំខោនធីដូចតទៅ៖

(A) ទៅមណ្ឌលសាលារៀន និងសាលារដ្ឋឯករាជ្យក្នុងសមាមាត្រទៅតាមមូលនិធិសរុបរបស់មណ្ឌលសាលារៀន ឬសាលារដ្ឋឯករាជ្យដែលបានគណនាអនុលោមតាមផ្នែករង (a) ដល់ (i) រាប់បញ្ចូលទាំងផ្នែក 42238.02 នៃច្បាប់អប់រំដូចមានចែងក្នុងប្រការទាំងនោះចុះថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 2019 ។ មណ្ឌលសាលារៀនណាមួយឬសាលារៀនរដ្ឋឯករាជ្យដែលមាន លក្ខណៈសម្បត្តិជា "មណ្ឌលសាលារៀនជំនួយមូលដ្ឋាន" ឬ "អង្គភាពពន្ធលើស" នៅក្រោមផ្នែករង (o) នៃផ្នែក 42238.02 នៃក្រមអប់រំត្រូវតែបានដកចេញពីចំណែកសមាមាត្ររបស់វានៃមូលនិធិពន្ធអចលនទ្រព្យសាលារៀនក្នុងមូលដ្ឋាន និងមហាវិទ្យាល័យសហគមន៍នូវចំនួនដែលតួលេខសរុប ត្រូវបានគណនានៅក្នុងផ្នែករង (j) នៃផ្នែក 42238.02 នៃច្បាប់អប់រំលើសពីចំនួនដែលត្រូវបានគណនា ទៅតាមផ្នែករង (a) ដល់ (i) រាប់បញ្ចូលទាំងផ្នែក 42238.02 នៃច្បាប់អប់រំដូចមានចែងក្នុងប្រការទាំងនោះចុះថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 2019 ។

(B) ទៅការិយាល័យអប់រំខោនធីក្នុងសមាមាត្រនៃមូលនិធិសរុបរបស់ការិយាល័យនីមួយៗដែលបានគណនាស្របទៅតាមផ្នែក 2574 នៃច្បាប់អប់រំដូចមានចែងក្នុងផ្នែកនោះចុះថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2019 ។

(3) ទោះជាមានកថាខណ្ឌ (1) និង (2) នៃផ្នែករងនេះក៏ដោយ មិនមានមណ្ឌលសាលារៀន ឬសាលារដ្ឋឯករាជ្យណាត្រូវទទួលប្រាក់ពីមូលនិធិពន្ធអចលនទ្រព្យសាលារៀនសម្រាប់ក្នុងមូលដ្ឋាន និងមហាវិទ្យាល័យសហគមន៍ ដែលតិចជាងមួយរយដុល្លារ ($100) ឡើយក្នុងមួយឯកតានៃវត្ថុមានប្រចាំថ្ងៃជាមធ្យមដែលត្រូវបានលៃតម្រូវបន្ថែម ឬបន្ថយប្រចាំឆ្នាំដោយភាគរយដដែល ដែលមូលនិធិពន្ធអចលនទ្រព្យសម្រាប់សាលារៀនក្នុងមូលដ្ឋាននិងមហាវិទ្យាល័យសហគមន៍បានកើនឡើង ឬ ថយចុះពីឆ្នាំមុន ហើយមិនមានមណ្ឌលមហាវិទ្យាល័យ សហគមន៍ណាត្រូវទទួលប្រាក់ពីមូលនិធិពន្ធអចលនទ្រព្យសាលារៀនក្នុងមូលដ្ឋាន តិចជាងមួយរយដុល្លារ ($100) ឡើយក្នុងសិស្សពេញម៉ោងដែលបានចុះឈ្មោះចូលរៀនម្នាក់ ដែលត្រូវបានលៃតម្រូវបន្ថែម ឬបន្ថយប្រចាំឆ្នាំដោយភាគរយដដែល ដែលមូលនិធិពន្ធអចលនទ្រព្យសាលារៀនក្នុងមូលដ្ឋាន និងមហាវិទ្យាល័យសហគមន៍បានកើន ឬបានថយចុះពីឆ្នាំមុន។

(b) លើកលែងតែដូចមានចែងនៅក្នុងកថាខណ្ឌ (2) នៃអនុផ្នែក (d) នៃផ្នែក 8.6 នៃមាត្រានេះ ថ្វីបើមានច្បាប់ណាផ្សេងទៀតក៏ដោយ ទឹកប្រាក់ដែលបានដាក់ចូលទៅក្នុងមូលនិធិពន្ធអចលនទ្រព្យ សាលារៀនក្នុងមូលដ្ឋាន និងមហាវិទ្យាល័យសហគមន៍មិនត្រូវស្ថិតនៅក្រោមការលៃបម្រុង ការដកយកវិញ ឬការផ្ទេរដោយអង្គនីតិបញ្ញត្តិ អភិបាល នាយកហិរញ្ញវត្ថុ ឬ អ្នកត្រួត ពិនិត្យសម្រាប់គោលបំណងផ្សេងក្រៅពីអ្វីដែលបានបញ្ជាក់នៅក្នុងផ្នែកនេះឡើយ ហើយចំណូលទាំងនេះក៏មិនត្រូវប្រើជាប្រាក់កម្ចីទៅកាន់មូលនិធិទូទៅ ឬមូលនិធិផ្សេងទៀតរបស់រដ្ឋ ឬមូលនិធិរដ្ឋាភិបាលក្នុងមូលដ្ឋានឡើយ។

(c) ទឹកប្រាក់ដែលបានលៃទុកសម្រាប់ទីភ្នាក់ងារអប់រំក្នុងមូលដ្ឋានដូចដែលលក្ខខណ្ឌនោះត្រូវបានកំណត់ន័យនៅក្នុងផ្នែក 421 នៃច្បាប់

អប់រំដូចដែលលក្ខន្តិកៈនោះចែងនៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2020 និង មណ្ឌលមហាវិទ្យាល័យសហគមន៍ពីមូលនិធិពន្ធ អចលនទ្រព្យសម្រាប់ សាលារៀនក្នុងមូលដ្ឋាន និងមហាវិទ្យាល័យសហគមន៍ត្រូវបំពេញបង្គ្រប់ មិនមែនជំនួសមូលនិធិផ្សេងទៀតសម្រាប់ការអប់រំទេ។ មូលនិធិដែល បានដាក់ចូលទៅក្នុង ឬដែលបានលៃទុកពីមូលនិធិពន្ធ អចលនទ្រព្យ សាលារៀនក្នុងមូលដ្ឋាន និងមហាវិទ្យាល័យសហគមន៍ត្រូវតែមិនមែន ជាផ្នែកមួយនៃ "ប្រាក់លៃទុកសរុបសម្រាប់សាលារៀនក្នុងមូលដ្ឋាននិង មហាវិទ្យាល័យសហគមន៍ ចេញពីប្រាក់មូលនិធិទូទៅនៃពន្ធ ដែលត្រូវ បានដកយកទេ ដោយអនុលោមទៅតាមមាត្រា XIII B និង ដែលបាន លៃទុកចេញពីប្រាក់ពន្ធក្នុងមូលដ្ឋាន" សម្រាប់គោលបំណងនៅក្នុង កថាខណ្ឌ (2) និង (3) នៃផ្នែករង (b) នៃផ្នែក 8 នៃមាត្រានេះ ឬសម្រាប់ គោលបំណងនៃផ្នែក 21 នៃមាត្រានេះ។ លើកលែងក្នុងករណីនៅក្នុងអនុ ផ្នែក (c) នៃផ្នែក 8.6 របស់មាត្រានេះ ប្រាក់ចំណូលដែលរកបានដោយ ផ្នែក 2.5 នៃមាត្រា XIII A មិនត្រូវបានចាត់ទុកថាជាប្រាក់ចំណូល មូលនិធិទូទៅដែលអាចត្រូវបានដកយកស្របតាមមាត្រា XIII B សម្រាប់ គោលបំណងនៃកថាខណ្ឌ (1) នៃផ្នែករង (b) នៃផ្នែក 8 នៃមាត្រានេះ ឡើយ ហើយក៏មិនត្រូវបានពិចារណានៅក្នុងការកំណត់នៃប្រាក់ចំណូល មូលនិធិទូទៅក្នុងមនុស្សម្នាក់ៗសម្រាប់គោលបំណងនៃផ្នែករង (b) និង (e) នៃផ្នែក 8 នៃមាត្រានេះដែរ។

(d) លើកលែងតែមានផ្តល់នៅក្នុងអនុផ្នែក (c) នៃភាគ 8.6 នៃមាត្រា នេះ ប្រាក់ចំណូលដែលរក បានដោយផ្នែក 2.5 នៃមាត្រា XIII A មិន ត្រូវបានចាត់ទុកថាជាប្រាក់ចំណូលមូលនិធិទូទៅពីពន្ធដែលអាចលៃ បម្រុងទុកបានតាមមាត្រា XIII B សម្រាប់គោលបំណងនៃផ្នែក 20 ឬ ផ្នែក 21 នៃមាត្រានេះ។

ផ្នែក 5. ផ្នែក 8.6 ត្រូវបានបន្ថែមទៅលើមាត្រា XVI នៃធម្មនុញ្ញរដ្ឋ California ដូចមានចែងថា៖

ផ្នែក. 8.6. (a) អង្គនីតិបញ្ញត្តិត្រូវផ្តល់តាមលក្ខន្តិកៈច្បាប់ នូវ វិធីសាស្ត្រដោយផ្អែកលើបទពិសោធន៍នាពេលកន្លងមកសម្រាប់ ការកំណត់ប្រាក់ចំ ណូលបន្ថែមដែលរកបាននៅក្នុងខោនធីនីមួយៗ រៀងរាល់ឆ្នាំសារពើពន្ធដោយសារការអនុវត្តអត្រាពន្ធដែលបានបញ្ជាក់ នៅក្នុងផ្នែករង (a) នៃផ្នែក 1 នៃមាត្រា XIII A និងការអនុវត្តផ្នែក 2.5 នៃមាត្រា XIII A ។ ការកំណត់ចំនួនប្រាក់ចំណូលបន្ថែមនៅក្នុងខោនធីនី មួយៗត្រូវតែត្រូវបានបញ្ជូនទៅសវនករប្រចាំខោនធីរៀងរាល់ឆ្នាំសម្រាប់ ការប្រើប្រាស់លើការគណនាដែលត្រូវបានតម្រូវដោយផ្នែកនេះ។

(b) បន្ទាប់ពីការផ្ទេរមូលនិធិចាំបាច់ ស្របតាមផ្នែករង (c) (d) និង (e) និង អនុកថាខណ្ឌ (B) នៃកថាខណ្ឌ (1) នៃផ្នែករងនេះ ប្រាក់ចំណូលបន្ថែម ទាំងអស់ដែលបានមកពីការអនុវត្តអត្រាពន្ធដែលបានបញ្ជាក់នៅក្នុងផ្នែករង (a) នៃផ្នែក 1 នៃមាត្រា XIII A និងការអនុវត្តផ្នែក 2.5 នៃមាត្រា XIII A ត្រូវតែត្រូវបានបែងចែក និងផ្ទេរដោយសវនករប្រចាំខោនធីដូចខាងក្រោម៖

(1) (A) ទីមួយ បែងចែកទៅមូលនិធិពន្ធអចលនទ្រព្យសាលារៀនក្នុង មូលដ្ឋាន និងមហាវិទ្យាល័យ សហគមន៍ដែលបានបង្កើតឡើង អនុលោម តាមផ្នែក 8.7 នៃមាត្រានេះក្នុងចំនួនទឹកប្រាក់ស្មើនឹងចំណែករបស់អង្គភាព សាលារៀននៃពន្ធលើអចលនទ្រព្យ ដូចបានកំណត់តាមជំពូក 6 (ចាប់ផ្តើម ជាមួយនឹងផ្នែក 95) នៃផ្នែក 0.5 នៃផ្នែក 1 នៃច្បាប់ប្រាក់ចំណូល និងការ ដកពន្ធ ដូចមានចែងក្នុងជំពូកនោះនៅថ្ងៃទី 1 ខែមករាឆ្នាំ 2020។

(B) មុនធ្វើការផ្ទេរ ស្របតាមអនុកថាខណ្ឌ (A) នៃកថាខណ្ឌ (1) នៃ ផ្នែករងនេះ សវនករប្រចាំខោនធីត្រូវដកចំនួនទឹកប្រាក់ស្មើនឹងចំណែក របស់ខោនធីនៃទឹកប្រាក់ដែលកើនឡើងនៅក្នុងប្រាក់លៃបម្រុងនៃពន្ធប្រាក់ មូលនិធិទូទៅសម្រាប់ការគាំទ្រដល់មណ្ឌលសាលារៀន និង មណ្ឌលមហាវិទ្យាល័យសហគមន៍ អនុលោមតាមផ្នែក 8 នៃមាត្រា នេះដោយសារតែការបាត់បង់ប្រាក់ចំណូលដែលបានបណ្តាលមកពី ការលើកលែងពន្ធដូចមានចែងក្នុងផ្នែក 3.1 នៃមាត្រា XIII តាមការកំណត់ ដោយនាយកហិរញ្ញវត្ថុ។ ចំណែកនៃប្រាក់លៃបម្រុងមូលនិធិទូទៅបន្ថែម របស់ខោនធីនឹងត្រូវបានផ្ទេរដោយសវនករខោនធីទៅមូលនិធិទូទៅមុន ការបែងចែកដែលបានបញ្ជាក់នៅក្នុងអនុកថាខណ្ឌ (A) នៃកថាខណ្ឌ (1) នៃអនុផ្នែកនេះ។ ចំនួនទឹកប្រាក់ដែលត្រូវបានកំណត់ដោយនាយកហិរញ្ញវត្ថុ ស្របតាមអនុកថាខណ្ឌនេះត្រូវតែបែងចែកដោយខោនធីសម្រាប់ឆ្នាំ សារពើពន្ធនីមួយៗក្នុងសមាមាត្រទៅនឹងការខាតបង់ប្រាក់ចំណូល ដែល បណ្តាលមកពីការលើកលែងដូចបានចែងក្នុង ផ្នែគ 3.1 នៃមាត្រា XIII ។

(2) ទីពីរ ក្នុងចំណោមទីក្រុង ខោនធី និងមណ្ឌលពិសេស អនុលោម តាមជំពូក 6 (ចាប់ផ្តើមជាមួយ នឹងផ្នែក 95) នៃ ភាគ 0.5 នៃផ្នែក 1 នៃ ច្បាប់ប្រាក់ចំណូលនិងការដកពន្ធ ដូចដែលជំពូកនោះបានចែងនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2020 ។

(c) គណៈកម្មការពន្ធអាជីវកម្មប្រើយីហោត្រូវកំណត់ការកាត់បន្ថយ ទៅលើមូលនិធិទូទៅ និងមូលនិធិរដ្ឋដែលបានប៉ះពាល់ផ្សេងទៀត នៃប្រាក់ចំណូលដែលមានប្រភពមកពីពន្ធតម្រូវដោយច្បាប់ពន្ធលើ ប្រាក់ចំណូលផ្ទាល់ខ្លួន (ភាគ 10 [ចាប់ផ្តើមជាមួយនឹងផ្នែក 17001] នៃផ្នែក 2 នៃច្បាប់ប្រាក់ចំណូល និងការដកពន្ធ) និងច្បាប់ពន្ធសាជីវកម្ម (ភាគ 11 [ចាប់ផ្តើមជាមួយនឹងផ្នែក 23001] នៃផ្នែក 2 នៃច្បាប់ ប្រាក់ចំណូល និងការដកពន្ធ) ដូចដែលច្បាប់ទាំងនោះបានចែងនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2020 ដោយសារតែការកាត់បន្ថយនៃកំណើនសុទ្ធ ណាមួយនៅក្នុងពន្ធអចលនទ្រព្យដែលបណ្តាលមកពីការអនុវត្តផ្នែករង (a) នៃផ្នែក 3.1 នៃមាត្រា XIII និងផ្នែក 2.5 នៃមាត្រា XIII A ។ ចំនួនទឹកប្រាក់នៃការកាត់បន្ថយដូចបានកំណត់ដោយគណៈកម្មការ ពន្ធអាជីវកម្មប្រើយីហោត្រូវតែផ្ទេរដោយសវនករខោនធី ទៅមូលនិធិ ទូទៅ និងមូលនិធិរដ្ឋដែលបានប៉ះពាល់ផ្សេងទៀត មុនការបែងចែកដែល បានបញ្ជាក់នៅក្នុងអនុផ្នែក (b) ។ សម្រាប់គោលបំណងនៃការធ្វើការ កំណត់ដែលតម្រូវដោយផ្នែក 8, 20 និង 21 នៃមាត្រានេះ ចំនួន ទឹកប្រាក់ដែលបានផ្ទេរទៅមូលនិធិទូទៅស្របតាមផ្នែករងនេះ ត្រូវចាត់ទុកថាជាប្រាក់ចំណូលមូលនិធិទូទៅដែលអាចត្រូវបានលៃបម្រុង អនុលោមតាម មាត្រា XIII B និងប្រាក់ពន្ធមូលនិធិទូទៅដែលបានលៃ បម្រុងស្របតាមមាត្រា XIII B ហើយត្រូវតែត្រូវបានរួមបញ្ចូលនៅក្នុង ការគណនាប្រាក់ចំណូលមូលនិធិទូទៅក្នុងមនុស្សម្នាក់ៗ។ ចំនួនទឹកប្រាក់ដែលបានផ្ទេរអនុលោមតាមអនុផ្នែកនេះត្រូវតែបែងចែក ក្នុងចំណោមខោនធី សម្រាប់ ឆ្នាំសារពើពន្ធនីមួយៗក្នុងសមាមាត្រទៅ នឹងការចូលវិភាគទានរបស់ខោនធីនីមួយៗ ទៅក្នុង ប្រាក់ចំណូលបន្ថែម សរុបដែលបានមកពីការអនុវត្តអត្រាពន្ធ ដែលបានបញ្ជាក់នៅក្នុងអនុ ផ្នែក (a) នៃផ្នែក 1 នៃមាត្រា XIII A និងការអនុវត្តផ្នែក 2.5 នៃមាត្រា XIII A ដែលបានកំណត់ សម្រាប់ខោនធីទាំងអស់។

(d) (1) ខោនធី ឬទីក្រុងនីមួយៗ និងខោនធីត្រូវទទួលបានការទូទាត់ ប្រាក់ជារៀងរាល់ឆ្នាំលើថ្លៃចំណាយរដ្ឋបាលផ្ទាល់ជាក់ស្តែងនៃការអនុវត្ត ផ្នែក 3.1 នៃមាត្រា XIII និងផ្នែក 2.5 នៃ មាត្រា XIII A ដូចបានកំណត់ ដោយក្រុមប្រឹក្សាអ្នកត្រួតពិនិត្យខោនធី ឬទីក្រុងនិងខោនធី ស្របតាម លក្ខន្តិកៈច្បាប់ដែលកំណត់ថ្លៃចំណាយទាំងនោះ។ អង្គនីតិបញ្ញត្តិត្រូវ កំណត់ដោយលក្ខន្តិកៈច្បាប់ថាតើអ្វីខ្លះដែលបង្កើតជាថ្លៃចំណាយរដ្ឋបាល

ផ្ទាល់ជាក់ស្តែង សម្រាប់គោលបំណងនៃផ្នែករងនេះ។ ថ្លៃចំណាយ ទាំងនោះយ៉ាងហោចណាស់ត្រូវរួមមាន ថ្លៃចំណាយលើការវាយតម្លៃ បណ្តឹងឧទ្ធរណ៍លើ ការវាយតម្លៃ ការប្រឹក្សាផ្នែកច្បាប់ ការបែងចែក និងការចែកចាយពន្ធ និងការធ្វើសវនកម្ម និងការអនុវត្តប្រការនៃផ្នែក 3.1 នៃមាត្រា XIII និងផ្នែក 2.5 នៃមាត្រា XIII A ។ វាគឺជាចេតនានៃ ផ្នែករងនេះដើម្បីផ្តល់មូលនិធិ ឲ្យបានសមស្របពេញលេញដល់ខោន ធីដើម្បីរ៉ាប់រងថ្លៃចំណាយ ទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងការអនុវត្ត ច្បាប់នេះ។

(2) អង្គនីតិបញ្ញត្តិត្រូវកំណត់ដោយលក្ខន្តិកៈច្បាប់លើថ្លៃចំណាយ ចាប់ផ្តើមដំបូងដែលចាំបាច់សម្រាប់ខោនធី ឬទីក្រុងនិងខោនធីនិមួយៗ និងក្រុមប្រឹក្សាសមកម្មរដ្ឋដើម្បីអនុវត្តច្បាប់ហើយ ត្រូវលៃបម្រុងប្រាក់ មូលនិធិទូទៅដើម្បីបង់ថ្លៃចំណាយចាប់ផ្តើមទាំងនោះ រហូតទាល់តែមាន មូលនិធិគ្រប់គ្រាន់ដើម្បីបង់ថ្លៃចំណាយបន្តទាំងអស់ដើម្បីអនុវត្តច្បាប់ ដែលនៅពេលដែល លក្ខន្តិកៈច្បាប់នឹងផ្តល់ដល់មូលនិធិទូទៅដើម្បី ទូទាត់សង។

(e) ខោនធី និងទីក្រុងនីមួយៗត្រូវទទួលបានការទូទាត់សំណងជា រៀងរាល់ឆ្នាំសម្រាប់ការសងប្រាក់ពន្ធអចលនទ្រព្យជាក់ស្តែងដែលបាន ទូទាត់នៅឆ្នាំសារពើពន្ធមុន ដែលជាលទ្ធផលនៃការកែតម្រូវទៅតាម ការវាយតម្លៃ ស្របតាមផ្នែក 2.5 នៃមាត្រា XIII A ។ ចំនួនទឹកប្រាក់ ទូទាត់សងអនុលោមតាមផ្នែករងនេះសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ត្រូវតែដកចេញពីការចូលរួមវិភាគទានរបស់ខោនធីនីមួយៗទៅក្នុង ប្រាក់ចំណូលបន្ថែមសរុប ដែលបានមកពីការអនុវត្តផ្នែក 2.5 នៃមាត្រា XIII A ដែលជាលទ្ធផលនៃការអនុវត្តអត្រាពន្ធដែលបាន បញ្ជាក់នៅក្នុងផ្នែករង (a) របស់ផ្នែក 1 នៃមាត្រា XIII A។

(f) រាល់ភ្នាក់ងារអប់រំក្នុងមូលដ្ឋាន មហាវិទ្យាល័យសហគមន៍ ខោនធី ទីក្រុង និងមណ្ឌលពិសេស ដែលទទួលមូលនិធិពីប្រាក់ចំណូលដែល បង្កើតឡើងដោយផ្នែក 2.5 នៃមាត្រា XIII A ត្រូវបង្ហាញអោយឃើញ ជាសាធារណៈសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ដែលរួមមានថវិកាប្រចាំឆ្នាំ របស់ខ្លួន ចំនួនប្រាក់ចំណូលពន្ធអចលនទ្រព្យដែលខ្លួនបានទទួលក្នុង ឆ្នាំសារពើពន្ធនោះ ដែលជាលទ្ធផល នៃផ្នែក 2.5 នៃមាត្រា XIII A និង របៀបដែលប្រាក់ចំណូលទាំងនោះត្រូវបានចំណាយ។ ការបង្ហាញអោយ ឃើញនេះត្រូវតែត្រូវបានធ្វើឡើងឱ្យទូលំទូលាយ អោយសាធារណជន ទូទៅបានដឹង ហើយត្រូវបានសរសេរឲ្យងាយយល់។

ផ្នែក 6. ផ្នែក 2.5 ត្រូវបានបន្ថែមទៅលើមាត្រា XIII A នៃធម្មនុញ្ញរដ្ឋ California ដូចមានចែងថា៖

ផ្នែក. 2.5. (A) (1) ថ្វីបើមានផ្នែក 2 នៃមាត្រានេះក៏ដោយ សម្រាប់ កាលបរិច្ឆេទការវាយតម្លៃសម្រាប់ឆ្នាំសារពើពន្ធ 2022–23 និង កាលបរិច្ឆេទក្រោយៗទៀត "តម្លៃសាច់ប្រាក់ពេញ" នៃអចលនទ្រព្យ ពាណិជ្ជកម្ម និងឧស្សាហកម្មដែលមិនត្រូវបានលើកលែងក្រោម រដ្ឋធម្មនុញ្ញគឺជាតម្លៃទីផ្សារដែលត្រឹមត្រូវ សម្រាប់អចលនទ្រព្យនោះគិត មកត្រឹមកាលបរិច្ឆេទដែលបានកំណត់ដោយអ្នកវាយតម្លៃប្រចាំខោនធីនៃ ខោនធីដែលអចលនទ្រព្យនោះស្ថិតនៅ លើកលែងតែត្រូវបានចែងដោយ អង្គនីតិបញ្ញត្តិ យោងតាមអនុផ្នែក (b)។

(2) កថាខណ្ឌ (1) នៃផ្នែករងនេះមិនត្រូវអនុវត្តលើអចលនទ្រព្យ លំនៅ ដ្ឋានដូចដែលបានបញ្ជាក់នៅក្នុងផ្នែកនេះទេ មិនថាវាត្រូវបានកាន់កាប់ ដោយម្ចាស់ផ្ទះ ឬក៏អ្នកជួល។ អចលនទ្រព្យលំនៅដ្ឋានដូចដែលបាន កំណត់ន័យនៅក្នុងផ្នែកនេះ ត្រូវតែមានការវាយតម្លៃតាមការ តម្រូវដោយ ផ្នែក 2 នៃមាត្រានេះ។ កថាខ័ណ្ឌ (1) នៃផ្នែករងនេះក៏មិនត្រូវអនុវត្ត ចំពោះអចលនទ្រព្យដែលបានប្រើប្រាស់សម្រាប់ផលិតកម្មកសិកម្ម ពាណិជ្ជកម្ម ដូចបានកំណត់ នៅក្នុងផ្នែកនេះដែរ។ អចលនទ្រព្យដែល ត្រូវបានប្រើប្រាស់សម្រាប់ផលិតកម្មកសិកម្មពាណិជ្ជកម្មដូចដែលបាន កំណត់នៅ ក្នុងផ្នែកនេះ ត្រូវមានការវាយតម្លៃតាមការតម្រូវដោយផ្នែក 2 នៃមាត្រានេះ។

(b) អង្គនីតិបញ្ញត្តិត្រូវបង្កើតក្រុមការងារមួយផ្នែករដ្ឋបាលពន្ធអចលន ទ្រព្យភ្លាមៗ បន្ទាប់ពីផ្នែកនេះ ត្រូវបានអនុម័ត ដែលរួមមាន អ្នក វាយតម្លៃ ឬអ្នកទទួលបានការចាត់តាំង សមាជិកក្រុមប្រឹក្សាសមកម្មរដ្ឋ ឬអ្នកទទួលបានការចាត់តាំង អ្នកគាំទ្រច្បាប់នេះ ឬអ្នកទទួលបានការ ចាត់តាំង អ្នកតំណាងអ្នកបង់ពន្ធ និងសមាជិកអង្គនីតិបញ្ញត្តិ ឬអ្នកទទួលបានការចាត់តាំង។ ក្រុមការងារត្រូវធ្វើការកោះប្រជុំជាសាធា រណៈភ្លាមៗ បន្ទាប់ពី ការបង្កើតក្រុមការងាររបស់ខ្លួនដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ដល់អង្គនីតិបញ្ញត្តិ រាល់ការផ្លាស់ប្តូរលក្ខន្តិកៈច្បាប់ និងបទបញ្ញត្តិ ដែលចាំបាច់សម្រាប់ការអនុវត្តប្រកបដោយយុត្តិធម៌ នៃវិធានការនេះ ស្របតាមគោលបំណង និង ចេតនារបស់ខ្លួន។ បន្ទាប់ពីកិច្ចពិភាក្សាជាមួយក្រុមការងារ អង្គនីតិបញ្ញត្តិត្រូវផ្តល់ដោយ លក្ខន្តិកៈច្បាប់សម្រាប់ដំណាក់កាលចាប់ផ្តើមការវាយតម្លៃឡើងវិញ លើអចលនទ្រព្យពាណិជ្ជកម្មនិងឧស្សាកម្ម ដូចដែលបានតម្រូវដោយ កថាខណ្ឌ (1) នៃផ្នែករង (a) ។ ការចាប់ផ្តើមណាមួយដូចនេះត្រូវផ្តល់នូវ ការវាយតម្លៃឡើងវិញលើ ភាគរយនៃអចលនទ្រព្យ ពាណិជ្ជកម្ម និងឧស្សាហកម្ម ដែលចាប់ផ្តើមជាមួយនឹងកាលបរិច្ឆេទការវាយតម្លៃ សម្រាប់ឆ្នាំសារពើពន្ធ 2022–23 និងបន្តកាលបរិច្ឆេទវាយតម្លៃពីរ ឬច្រើនដងទៀតក្នុងឆ្នាំសារពើពន្ធនីមួយៗ ក្រោយមក ដើម្បីធានា រយៈពេលបន្ទុកការងារ និងការអនុវត្តដែលសមហេតុផលសម្រាប់អ្នក វាយតម្លៃប្រចាំខោនធី ដែលរួមមានប្រការសម្រាប់ការដំណើរការ និង ការកំណត់ពេលវេលានៃបណ្តឹងឧទ្ធរណ៍លើការវាយតម្លៃ។ ម្ចាស់កម្មសិទ្ធិ ជាដំបូងត្រូវមានកាតព្វកិច្ចក្នុងការបង់ពន្ធដោយផ្អែកលើតម្លៃដែលបាន ប៉ាន់ប្រមាណថ្មី ចាប់ផ្តើមពីកាលបរិច្ឆេទវាយតម្លៃសម្រាប់ឆ្នាំសារពើពន្ធ នោះ នៅពេលដែលអ្នកវាយតម្លៃប្រចាំខោនធីបានបញ្ចប់ការវាយតម្លៃ ឡើងវិញ។ ដំណាក់កាលចាប់ផ្តើមក៏ត្រូវផ្តល់ឲ្យអ្នកបង់ពន្ធដែល ទ្រព្យសម្បត្តិត្រូវបានវាយតម្លៃឡើងវិញ នូវពេលវេលាសមស្របដើម្បីបង់ ថ្លៃកំណើនពន្ធណាមួយផងដែរ។ បន្ទាប់ពីការវាយតម្លៃឡើងវិញដំបូងលើ អចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្ម ស្របតាមផ្នែករងនេះ អចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មនោះ ត្រូវតែមានការវាយតម្លៃ ឡើងវិញយូរៗម្តង មិនញឹកញាប់ជាងរៀងរាល់បីឆ្នាំម្តង ដូចដែលបាន កំណត់ដោយអង្គនីតិបញ្ញត្តិ។ ទោះបីជាមានចែងក្នុងលក្ខន្តិកៈច្បាប់ ជាធរមានក៏ដោយ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកវាយតម្លៃ ប្រចាំខោនធី អង្គនីតិបញ្ញត្តិត្រូវបង្កើតដំណើរការសម្រាប់បណ្តឹងឧទ្ធរណ៍ សវនាការ ដែលបណ្តាលមកពីការវាយតម្លៃឡើងវិញលើអចលទ្រព្យ អនុលោមទៅតាមផ្នែកនេះ ដែលស្របតាមខាងក្រោម៖

(1) ដំណើរការមិនត្រូវរួមបញ្ចូលការទទួលយកដោយស្វ័យប្រវត្តិនូវមតិ របស់អ្នកស្នើសុំ អំពីតម្លៃនៅក្នុង អំឡុងពេលវេលាដែលបានផ្តល់ឲ្យឡើយ។

(2) ដំណើរការត្រូវដាក់បន្ទុកភស្តុតាងទៅលើអ្នកបង់ពន្ធថាអចលនទ្រព្យ នោះមិនត្រូវបានប៉ាន់តម្លៃបានត្រឹមត្រូវ។

(3) ដំណើរការត្រូវតម្រូវឲ្យអ្នកបង់ពន្ធផ្តល់ភស្តុតាងពាក់ព័ន្ធទៅនឹងការ តវ៉ាណាមួយនៅក្នុងការដាក់ ពាក្យសុំដំបូងនៅចំពោះមុខក្រុមប្រឹក្សាតវ៉ា លើការវាយតម្លៃនៅក្នុងមូលដ្ឋាន។

(4) ប្រសិនបើស្ថិតក្រោមការពិនិត្យឡើងវិញដោយតុលាការកំពូល ដំណើរការត្រូវធានាថាសេចក្តីសម្រេចដោយអង្គសវនការរដ្ឋបាលក្នុង

15

មូលដ្ឋានដូចជា ក្រុមប្រឹក្សាបណ្តឹងឧទ្ធរណ៍ការវាយតម្លៃ ត្រូវស្ថិតក្រោមតែការពិនិត្យរឿងក្តីឡើងវិញដោយតុលាការថ្នាក់ក្រោមលើបញ្ហាច្បាប់ប៉ុណ្ណោះ ខណៈដែលបញ្ហានៃអង្គហេតុ ដែលរួមមានការវាយតម្លៃ ត្រូវតែបានត្រួតពិនិត្យក្រោមស្តង់ដារភស្តុតាងដែលត្រឹមត្រូវ។

(c) សម្រាប់គោលបំណងនៃផ្នែកនេះ៖

(1) "អចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្ម" សំដៅលើអចលនទ្រព្យទាំងឡាយណាដែលត្រូវបានប្រើប្រាស់ជាអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្ម ឬក៏ជាដីនៅទំនេរដែលមិនត្រូវបានចែកជាតំបន់សម្រាប់ការប្រើប្រាស់ជាលំនៅដ្ឋាន និងមិនត្រូវបានប្រើប្រាស់ សម្រាប់ផលិតកម្មកសិកម្មពាណិជ្ជកម្ម។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ ដីទំនេរមិនត្រូវរាប់បញ្ចូលជាអចលនទ្រព្យដែលត្រូវបានប្រើប្រាស់ ឬត្រូវបានការពារសម្រាប់ ជាទីធ្លាបើកចំហ ឧទ្យាន ឬការកំណត់ដែលប្រហាក់ប្រហែលគ្នានោះ សម្រាប់ដីដែលជាសំខាន់មិនត្រូវមានរចនាសម្ព័ន្ធ មានលក្ខណៈធម្មជាតិដើម្បីផ្តល់ឱកាសសម្រាប់ការកម្សាន្ត និងការអប់រំ ហើយមានបំណងដើម្បីរក្សាតម្លៃទេសភាព វប្បធម៌ ឬប្រវត្តិសាស្ត្រ។

(2) "អចលនទ្រព្យប្រើប្រាស់ចម្រុះ" សំដៅលើអចលនទ្រព្យដែលត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ជាលំនៅដ្ឋាន និងពាណិជ្ជកម្ម ឬឧស្សាហកម្ម។

(3) "អចលនទ្រព្យប្រើប្រាស់សម្រាប់ផលិតកម្មកសិកម្មពាណិជ្ជកម្ម" សំដៅលើដីដែលបានប្រើប្រាស់សម្រាប់ការផលិតទំនិញកសិកម្មបែបពាណិជ្ជកម្ម។

(4) (A) "អចលនទ្រព្យលំនៅដ្ឋាន" ត្រូវរាប់បញ្ចូលអចលនទ្រព្យ ដែលបានប្រើប្រាស់ជាអចលនទ្រព្យលំនៅដ្ឋាន ដែលរួមមាន សំណង់សម្រាប់គ្រួសារទោល និងសំណង់ច្រើនជាន់ និងដី ដែលរចនាសម្ព័ន្ធទាំងនោះត្រូវបានសាងសង់ ឬដាក់ពីលើ ។

(B) អង្គនីតិបញ្ញត្តិត្រូវផ្តល់ដោយលក្ខន្តិកៈច្បាប់ថា អចលនទ្រព្យណាមួយដែលត្រូវបានបែងចែក តំបន់ជាលក្ខណៈពាណិជ្ជកម្ម ឬឧស្សាហកម្ម ក៏ប៉ុន្តែត្រូវបានប្រើប្រាស់ជាអចលនទ្រព្យ លំនៅដ្ឋានរយៈពេលវែង ត្រូវបានចាត់ថ្នាក់ជាលំនៅដ្ឋានសម្រាប់ គោលបំណងនៃកថាខណ្ឌ (2) នៃផ្នែករង (a)។ សម្រាប់អចលនទ្រព្យប្រើប្រាស់ចម្រុះ អង្គនីតិបញ្ញត្តិត្រូវធានាថា មានតែចំណែកនោះនៃអចលនទ្រព្យប៉ុណ្ណោះដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងពាណិជ្ជកម្ម និងឧស្សាហកម្ម ត្រូវស្ថិតនៅក្រោមការវាយតម្លៃឡើងវិញ ដូចដែលបាន តម្រូវដោយកថាខណ្ឌ (1) នៃផ្នែករង (a)។ អង្គនីតិបញ្ញត្តិក៏ត្រូវកំណត់ និងផ្តល់ដោយលក្ខន្តិកៈច្បាប់ផងដែរថា ការប្រើប្រាស់លក្ខណៈ ពាណិជ្ជកម្មមានដែនកំណត់នៃអចលនទ្រព្យលំនៅដ្ឋានដូចជា ការិយាល័យនៅផ្ទះ អាជីវកម្មនៅផ្ទះ ឬការជួលរយៈពេលខ្លីត្រូវបានចាត់ថ្នាក់ជាលំនៅដ្ឋានសម្រាប់គោលបំណងនៃកថាខណ្ឌ (2) របស់ផ្នែករង (a)។ អង្គនីតិបញ្ញត្តិអាចនឹងផ្តល់ការលើកលែងការវាយតម្លៃ ឡើងវិញសម្រាប់ការប្រើប្រាស់រួមគ្នាលក្ខណៈពាណិជ្ជកម្ម នៃអចលនទ្រព្យប្រើប្រាស់ ចម្រុះ ក្នុងករណីដែល 75 ភាគរយ ឬលើសពីនេះនៃអចលនទ្រព្យនោះ គិតតាមទំហំក្រឡាផ្ទៃ ឬតម្លៃគឺជាលំនៅដ្ឋាន។

(d) (1) ស្ថិតក្រោមកថាខណ្ឌ (2) នៃអនុផ្នែកនេះ បន្ទាប់ពីមានការវាយតម្លៃឡើងវិញ អនុលោមតាម ផ្នែករង (a) និង (b) អចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មនីមួយៗ ដែលមានតម្លៃទីផ្សារត្រឹមត្រូវ ចំនួនបីលានដុល្លារ ($3,000,000) ឬតិចជាងនេះ មិនត្រូវស្ថិតក្រោមការវាយតម្លៃឡើងវិញទេ ស្របតាមកថាខណ្ឌ (1) នៃផ្នែក (a) ហើយត្រូវបានវាយតម្លៃតាមការតម្រូវដោយផ្នែក 2 នៃមាត្រានេះ។ ចំនួនទឹកប្រាក់ដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌនេះត្រូវតែកែតម្រូវសម្រាប់អតិផរណារៀងរាល់ពីរឆ្នាំម្តង ចាប់ផ្តើមពីថ្ងៃទី 1 ខែមករា ឆ្នាំ 2025 តទៅ ដូចបានកំណត់ដោយក្រុមប្រឹក្សាសមកម្មរដ្ឋ។ ក្រុមប្រឹក្សាសមកម្មរដ្ឋត្រូវគណនាការកែតម្រូវដាច់ដោយឡែកសម្រាប់ខោនធីនីមួយៗ ដោយធ្វើការពិចារណាលើភាពខុសៗគ្នាជាមធ្យមលើតម្លៃទីផ្សារពាណិជ្ជកម្ម និងឧស្សាហកម្មក្នុង ចំណោមខោនធីទាំងនោះ។

(2) ទោះបីជាមានចែងក្នុងកថាខណ្ឌ (1) នៃផ្នែករងនេះក៏ដោយ អចលនទ្រព្យដែលនឹងអនុលោមតាមការលើកលែងដូចបានកំណត់ក្នុងកថាខណ្ឌ (1) នៃផ្នែករងនេះ ត្រូវស្ថិតក្រោមការវាយតម្លៃឡើងវិញ ស្របតាមកថាខណ្ឌ (1) នៃផ្នែករង (a) ប្រសិនបើម្ចាស់កម្មសិទ្ធិដែលទទួលបានផលដោយផ្ទាល់ ឬប្រយោលពីអចលនទ្រព្យនោះ មានផលប្រយោជន៍ភាពជាម្ចាស់ទទួលផលផ្ទាល់ ឬប្រយោលនៅក្នុងអចលនទ្រព្យពាណិជ្ជកម្ម និងឧស្សាហកម្មផ្សេងទៀតដែលមានទីតាំងនៅក្នុងរដ្ឋដែលអចលនទ្រព្យនោះស្ថិតនៅក្នុងទ្រព្យសម្បត្តិរួម រួមទាំងទ្រព្យសម្បត្តិដែលកំពុងវាយតម្លៃ មានតម្លៃទីផ្សារត្រឹមត្រូវលើសពីបីលានដុល្លារ ($3,000,000) ។ ចំនួនទឹកប្រាក់ដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌនេះត្រូវតែកែតម្រូវសម្រាប់អតិផរណារៀងរាល់ពីរឆ្នាំម្តង ចាប់ផ្តើមពីថ្ងៃទី 1 ខែមករា ឆ្នាំ 2025 តទៅ ដូចបានកំណត់ដោយក្រុមប្រឹក្សាសមកម្មរដ្ឋ។

(3) រាល់ការកំណត់ទាំងអស់នៃតម្លៃទីផ្សារត្រឹមត្រូវក្រោមផ្នែករងនេះ ត្រូវតែកំណត់ដោយអ្នកវាយតម្លៃប្រចាំខោនធីនៃខោនធីដែលអចលនទ្រព្យនោះស្ថិតនៅ ហើយការកំណត់បែបនោះដោយអ្នកវាយតម្លៃប្រចាំខោនធីត្រូវតែប្រាកដប្រជា ហើយស្ថិតក្រោមការពិនិត្យដោយតុលាការតែមួយគត់សម្រាប់ការបំពានលើសេចក្តីវិនិច្ឆ័យ។

(4) ដើម្បីមានលក្ខណៈសម្បត្តិទទួលបានការលើកលែងដែលបានផ្តល់ដោយកថាខណ្ឌ (1) នៃផ្នែករងនេះ ម្ចាស់អចលនទ្រព្យត្រូវធ្វើការអះអាងនិងបញ្ជាក់ជារៀងរាល់ឆ្នាំដល់អ្នកវាយតម្លៃប្រចាំខោនធីក្រោមទោសបញ្ញត្តិនៃការបំពានសម្បថថាលក្ខខណ្ឌដែលបានតម្រូវដោយកថាខណ្ឌ (1) និង (2) នៃផ្នែករងនេះ សម្រាប់ការលើកលែងពីការវាយតម្លៃឡើងវិញត្រូវបានបំពេញតាម ហើយត្រូវស្ថិតក្រោមសវនកម្មដោយខោនធី ឬរដ្ឋអំពីការបញ្ជាក់នោះ។ ក្រុមប្រឹក្សាសមកម្មរដ្ឋត្រូវមានសិទ្ធិអំណាចក្នុងការធ្វើសវនកម្មណាមួយតំណាងឲ្យរដ្ឋ។

(5) អចលនទ្រព្យណាមួយដែលត្រូវបានលើកលែងពីការវាយតម្លៃឡើងវិញក្រោមកថាខណ្ឌ (1) នៃផ្នែករងនេះត្រូវបានលើកលែងពីការវាយតម្លៃឡើងវិញ ដរាបណាអចលនទ្រព្យនោះបំពេញតាមលក្ខខណ្ឌដែលកំណត់ដោយកថាខណ្ឌ (1) និង (2) នៃផ្នែករងនេះ។ ប្រសិនបើមានការផ្លាស់ប្តូរកម្មសិទ្ធិទទួលផលផ្ទាល់ ឬប្រយោលពីអចលនទ្រព្យនោះ ការអះអាងនិងការបញ្ជាក់ថ្មីត្រូវតែផ្តល់ជូនទៅអ្នកវាយតម្លៃប្រចាំខោនធី។

(6) បណ្តឹងឧទ្ធរណ៍ណាមួយរបស់អ្នកបង់ពន្ធដែលត្រូវបានរកឃើញថា មិនត្រូវបានលើកលែងពីការ វាយតម្លៃឡើងវិញ អនុលោមតាមកថាខណ្ឌ (1) នៃផ្នែករងនេះត្រូវស្ថិតក្រោមដំណើរការ សម្រាប់បណ្តឹងឧទ្ធរណ៍សវនាការ ដូចមានចែងក្នុងផ្នែករង (b) ។

(e) (1) ករណីដែល 50 ភាគរយឡើងទៅនៃប្រវែងផ្ទៃការ៉ែនៃអចលនទ្រព្យឧស្សាហកម្ម ឬពាណិជ្ជកម្មត្រូវបានកាន់កាប់ដោយអាជីវកម្មខ្នាតតូច ដូចបានកំណត់ន័យក្នុងកថាខណ្ឌ (4) នៃផ្នែករងនេះ ប្រការនៃកថាខណ្ឌ (1) នៃផ្នែករង (a) មិនត្រូវចូលជាធរមានមុនកាលបរិច្ឆេទការវាយតម្លៃសម្រាប់ឆ្នាំសារពើពន្ធ 2025-26 ឡើយ។ ទោះយ៉ាងណាក្តី ករណីដែលប្រសិនបើអង្គនីតិបញ្ញត្តិបង្កើតឡើងដោយលក្ខន្តិកៈច្បាប់ អនុលោមតាមផ្នែករង (b) ចែងថាអចលនទ្រព្យដែលមានលក្ខណៈគ្រប់គ្រាន់ក្រោមកថាខណ្ឌនេះ ត្រូវតែមានការវាយតម្លៃឡើងវិញតាមកាលបរិច្ឆេទវាយតម្លៃបន្ទាប់ពីឆ្នាំសារពើពន្ធ 2025-26 នោះ អចលនទ្រព្យបែបនេះនឹងត្រូវបានវាយតម្លៃឡើងវិញ ចាប់ផ្តើមពីកាលបរិច្ឆេទវាយតម្លៃបន្ទាប់នោះទៅ។

(2) ដើម្បីមានសិទ្ធិទទួលបានការពន្យារពេលដែលបានផ្តល់ដោយកថាខណ្ឌ (1) នៃផ្នែករងនេះ កម្មសិទ្ធិករនៃអចលនទ្រព្យត្រូវធ្វើការទាមទារ និងបញ្ជាក់ជារៀងរាល់ឆ្នាំដល់អ្នកវាយតម្លៃខោនធី ក្រោមទោសបញ្ញត្តិនៃការបំពានសម្បថថា លក្ខខណ្ឌដែលតម្រូវដោយកថាខណ្ឌ (1) នៃអនុផ្នែកនេះដើម្បីសុំពន្យាពេលការវាយតម្លៃឡើងវិញត្រូវបានបំពេញ ហើយត្រូវបានធ្វើសវនកម្មដោយខោនធី ឬក្រុមប្រឹក្សាសមកម្មរដ្ឋទាក់ទងនឹងការបញ្ជាក់នោះ។

(3) រាល់អចលនទ្រព្យដែលការវាយតម្លៃឡើងវិញត្រូវបានពន្យាពេលក្រោមកថាខណ្ឌ (1) នៃផ្នែករងនេះ ត្រូវមានសិទ្ធិទទួលបានការពន្យាពេល តែក្នុងដរាបណាដែលខ្លួនបំពេញតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកថាខណ្ឌ (1) នៃផ្នែករងនេះហើយប្រសិនបើមានការផ្លាស់ប្តូរកម្មសិទ្ធិទទួលប្រយោជន៍ដោយផ្ទាល់ ឬប្រយោលនៃអចលនទ្រព្យពិតនោះ ការទាមទារនិងការបញ្ជាក់ថ្មីត្រូវតែបានធ្វើជូនអ្នកវាយតម្លៃខោនធី។ ក្រោយពេលបញ្ចប់ការពន្យារពេល អចលនទ្រព្យនោះត្រូវស្ថិតនៅក្រោមកថាខណ្ឌ (1) នៃផ្នែករង (a)។

(4) សម្រាប់គោលបំណងនៃផ្នែករងនេះ ពាក្យថា "អាជីវកម្មខ្នាតតូច" ត្រូវរាប់បញ្ចូលតែអាជីវកម្មទាំងឡាយណា ដែលបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

(A) អាជីវកម្មមាននិយោជិតពេញម៉ោងប្រចាំឆ្នាំតិចជាង 50 នាក់។

(B) អាជីវកម្មជាកម្មសិទ្ធិ និងដំណើរការដោយឯករាជ្យក្នុងរបៀបដែលផលប្រយោជន៍កម្មសិទ្ធិអាជីវកម្ម ការគ្រប់គ្រង និងប្រតិបត្តិការ មិនស្ថិតនៅក្រោមការគ្រប់គ្រង ការរឹតត្បិត ការកែប្រែ ឬការដាក់កម្រិតដោយប្រភពខាងក្រៅ ដោយបុគ្គល ឬដោយអាជីវកម្មមួយផ្សេងទៀត។

(C) អាជីវកម្មមានកម្មសិទ្ធិអចលនទ្រព្យដែលមានទីតាំងនៅរដ្ឋ California។

(f) សម្រាប់គោលបំណងនៃផ្នែកនេះ ការខកខានក្នុងការទាមទារ ក្នុងឆ្នាំណាមួយតាមរបៀបដែលតម្រូវដោយច្បាប់ជាធរមាន នៅពេលដែលការទាមទារត្រូវបានតម្រូវ ការមិនរាប់ញ្ចូល ឬការធ្វើចំណាត់ថ្នាក់ដែលកាត់បន្ថយ ឬពន្យាពេលការវាយតម្លៃ ឬការវាយតម្លៃឡើងវិញត្រូវបានចាត់ទុកថាជាការលើកលែងនៃការមិនរាប់បញ្ចូល ឬការចាត់ថ្នាក់សម្រាប់ឆ្នាំនោះ។

(g) ការប្រើប្រាស់វិធីសាស្ត្រដែលកំណត់ដោយអង្គនីតិបញ្ញត្តិ អនុលោមតាមផ្នែករង (a) នៃផ្នែក 8.6 នៃមាត្រា XVI ការផ្លាស់ប្តូរភាគរយនៃតម្លៃប៉ាន់ដែលត្រូវបានវាយតម្លៃពន្ធសរុបនៅក្នុងទីក្រុង ខោនធី ឬទីក្រុងនិងខោនធី ដែលត្រូវបានប្រើដើម្បីគណនាចំនួនទឹកប្រាក់នៃការកែតម្រូវថ្លៃសេវាអាជ្ញាប័ណ្ណយានយន្តរបស់អង្គភាព ដែលអនុលោមតាមផ្នែក 97.70 នៃច្បាប់ប្រាក់ចំណូលនិងពន្ធដារ មិនត្រូវរាប់បញ្ចូលតម្លៃប៉ាន់ដែលត្រូវបានវាយតម្លៃបន្ថែម ដែលជាលទ្ធផលនៃការអនុវត្តផ្នែកនេះឡើយ។

(h) ថ្វីបើមានផ្នែក 16 នៃមាត្រា XVI ឬច្បាប់ផ្សេងទៀតណាមួយក៏ដោយ ការវាយតម្លៃបន្ថែមដែលទទួលបានពីការអនុវត្តផ្នែកនេះ មិនត្រូវបានចាត់ចូលក្នុងផ្នែកណាមួយនៃពន្ធ ឬការគណនាកំណើនសម្រាប់ប្រព្រឹត្តកម្មជាការតំលើងថ្លៃពន្ធ នឹងមិនត្រូវបានបង្វែរទិសដៅក្នុងរបៀបណាមួយឡើយ។

ផ្នែកទី 7. ផ្នែក 3.1 ត្រូវបានបន្ថែមទៅក្នុងមាត្រា XIII នៃរធម្មនុញ្ញរដ្ឋ California ដែលចែងថា៖

ផ្នែក 3.1. (a) (1) ចំពោះអ្នកជាប់ពន្ធនីមួយៗដែលបង់ពន្ធលើទ្រព្យសម្បត្តិរូបីផ្ទាល់ខ្លួន រួមទាំងឧបករណ៍ និងគ្រឿងសង្ហារឹមអាជីវកម្ម ដែលត្រូវបានប្រើសម្រាប់គោលបំណងអាជីវកម្ម ចំណុចខាងក្រោមនេះត្រូវអនុវត្ត៖

(A) (i) ចំពោះអ្នកបង់ពន្ធដែលជាអាជីវកម្មខ្នាតតូច ដូចបានកំណត់ន័យក្នុងកថាខណ្ឌ (4) នៃផ្នែករង (e) នៃផ្នែក 2.5 នៃមាត្រា XIIIA រាល់ទ្រព្យរូបីផ្ទាល់ខ្លួនទាំងអស់ដែលបានកាន់កាប់និងប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្ម គឺរួចផុតពីការបង់ពន្ធ។

(ii) អ្នកជាប់ពន្ធត្រូវធ្វើការទាមទារ និងបញ្ជាក់ជារៀងរាល់ឆ្នាំដល់អ្នកវាយតម្លៃខោនធីក្រោមទោសបញ្ញត្តិនៃការបំពានសម្បថថាលក្ខខណ្ឌដែលតម្រូវដោយអនុកថាខណ្ឌនេះសម្រាប់ការលើកលែងត្រូវបានបំពេញ ហើយការទាមទារបែបនេះត្រូវស្ថិតក្រោមការធ្វើសវនកម្មដោយខោនធី ឬរដ្ឋ ទៅលើការបញ្ជាក់នោះ។

(B) លើកលែងតែអ្នកជាប់ពន្ធដែលស្ថិតនៅក្រោមអនុកថាខណ្ឌ (A) នៃកថាខណ្ឌ (1) នៃផ្នែករងនេះ ចំនួនរហូតដល់ប្រាំរយពាន់ដុល្លារអាមេរិក ($500,000) នៃទ្រព្យរូបីផ្ទាល់ខ្លួន និងគ្រឿងសង្ហារឹមរួមបញ្ចូលគ្នា ក្នុងអ្នកជាប់ពន្ធម្នាក់ ត្រូវបានរួចផុតពីការបង់ពន្ធ។

(2) យន្តហោះ និងនាវាមិនត្រូវស្ថិតនៅក្រោមការលើកលែងពន្ធនេះទេ។

(3) អង្គនីតិបញ្ញត្តិមិនត្រូវបន្ថយចំនួនប្រាក់លើកលែងពន្ធដែលផ្តល់ដោយផ្នែករងនេះ ឬផ្លាស់ប្តូរការអនុវត្តរបស់ពួកវាទេ ប៉ុន្តែអាចបង្កើនចំនួនទឹកប្រាក់លើកលែងពន្ធ ដែលត្រូវបានបញ្ជាក់ក្នុងអនុកថាខណ្ឌ (B) នៃកថាខណ្ឌ (1) នៃផ្នែករងនេះ ស្របតាមសិទ្ធិអំណាចដែលបានចែងក្នុងផ្នែក 2 នៃមាត្រានេះ។

(b) អង្គនីតិប្បញ្ញត្តិត្រូវផ្តល់តាមលក្ខន្តិកៈច្បាប់ថារាល់អង្គភាពពាក់ព័ន្ធដែលរួមមានប៉ុន្តែមិនកំណត់តែចំពោះក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនកាន់កាប់ ឬសាជីវកម្មមេ ត្រូវបានចាត់ទុកថាជា " អ្នកជាប់ពន្ធ" តែមួយសម្រាប់គោលបំណងនៃផ្នែកនេះ។

ផ្នែក 8. ផ្នែក 16 ត្រូវបានបន្ថែមទៅក្នុងមាត្រាទី XIIIB នៃរដ្ឋធម្មនុញ្ញរដ្ឋ California ដែលចែងថា៖

ផ្នែក 16. (a) សម្រាប់គោលបំណងនៃមាត្រានេះ "ចំណូលពន្ធ" មិនត្រូវរាប់បញ្ចូលនូវប្រាក់ចំណូលបន្ថែមដែលរកបានដោយផ្នែក 2.5 នៃមាត្រា XIII A ទេ។

(b) សម្រាប់គោលបំណងនៃមាត្រានេះ ប្រាក់លៃបម្រុងដែលស្ថិតនៅក្រោមការកំណត់របស់អង្គភាពរដ្ឋាភិបាលនីមួយៗ មិនត្រូវរាប់បញ្ចូលប្រាក់លៃបម្រុងនៃប្រាក់ចំណូលបន្ថែម ដែលប្រមូលបានពីលទ្ធផលនៃការអនុវត្តផ្នែក 2.5 នៃមាត្រា XIIIA ឡើយ។

ផ្នែក 9. កាលបរិច្ឆេទមានប្រសិទ្ធិភាព។

វិធានការណ៍នេះត្រូវមានសុពលភាពនៅថ្ងៃទី1 ខែមករា ឆ្នាំ 2022 លើកលែងតែផ្នែករង (a) នៃផ្នែក 3.1 នៃមាត្រា XIII ត្រូវមានសុពលភាពនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2024 ហើយផ្នែករង (d) នៃផ្នែក 8.6 នៃមាត្រា XVI និងផ្នែករង (b) នៃផ្នែក 2.5 នៃមាត្រា XIIIA ត្រូវមានសុពលភាពភ្លាមៗ បន្ទាប់ពីការអនុម័តវិធានការនេះរួច។

ផ្នែក 10. ឯករាជ្យភាពនៃប្រការ។

ប្រការទាំងឡាយនៃច្បាប់នេះគឺអាចកាត់ចេញពីគ្នាបាន។ ប្រសិនបើវគ្គ ផ្នែក ផ្នែករង កថាខណ្ឌ អនុប្រយោគ ប្រយោគ ឃ្លា ពាក្យពេចន៍ ឬការអនុវត្តនៃច្បាប់នេះក្នុងហេតុផលណាមួយ ត្រូវបានក្លាយជាមោឃៈ ដោយសេចក្តីសម្រេចរបស់តុលាការដែនសមត្ថកិច្ចយុត្តាធិការ សេចក្តីសម្រេចនោះមិនត្រូវប៉ះពាល់ដល់សុពលភាពនៃផ្នែកផ្សេងទៀតនៃច្បាប់នេះឡើយ។ ប្រជាពលរដ្ឋ California សូមប្រកាសថាពួកគេនឹងធ្វើការអនុម័ត

15

16

17

18

ច្បាប់នេះ ហើយគ្រប់វគ្គ ផ្នែក ផ្នែករង កថាខណ្ឌ អនុប្រយោគ ប្រយោគ ឃ្លា ពាក្យពេចន៍ ឬការអនុវត្តដែលមិនត្រូវបានប្រកាសថាអសុពលភាព ឬផ្ទុយពីរដ្ឋធម្មនុញ្ញដោយមិនគិតថាតើវគ្គនៃច្បាប់ឬការអនុវត្ត នឹងក្រោយមកត្រូវប្រកាសថាអសុពលភាព។ ថ្វីបើមានតមកពីខាងមុខ ផ្នែក 7 នៃច្បាប់នេះមិនអាចកាត់ចេញបានពីផ្នែក 6 នៃច្បាប់នេះទេ។

ផ្នែក 11. ការបកស្រាយលក្ខណៈសេរី។

ច្បាប់នេះ ត្រូវតែបកស្រាយដោយសេរីភាពដើម្បីប្រតិបត្តិតាមគោលបំណងរបស់ខ្លួន ដូចដែលបានចែងច្បាស់នៅក្នុងផ្នែកទី 3 នៃច្បាប់នេះ។

សំណើប្រជាមតិ 16

វិសោធនកម្មនេះដែលបានស្នើដោយវិសោធនកម្មទី 5 នៃធម្មនុញ្ញ សភា នៃសម័យប្រជុំសាមញ្ញ 2019–2020 (សេចក្តីសម្រេចជំពូក 23 លក្ខន្តិកៈច្បាប់ឆ្នាំ 2020) ធ្វើវិសោធនកម្មយ៉ាងច្បាស់លាស់ទៅលើរដ្ឋធម្មនុញ្ញនៃរដ្ឋ California ដោយការលុបចោលផ្នែកមួយ ដូច្នេះប្រការជាធរមានដែលត្រូវបានស្នើសុំឲ្យលុបចោល ត្រូវបានបោះពុម្ពជាប្រភេទអក្សរឆ្ងូតចោល។

សំណើវិសោធនកម្មចំពោះមាត្រា I

ផ្នែក 31 នៃមាត្រា I ត្រូវបានលុបចោល។

~~ផ្នែក 31. (a) រដ្ឋមិនត្រូវរើសអើង ឬផ្តល់ការព្យាបាលតាមចំណូលចិត្ត ចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយដោយផ្អែកទៅលើជាតិសាសន៍ ភេទ ពណ៌សម្បុរ ជាតិពន្ធ ឬសញ្ជាតិដើមនៅក្នុងប្រតិបត្តិការនៃការផ្តល់ការងារសាធារណៈ ការអប់រំសាធារណៈ ឬការម៉ៅការសាធារណៈឡើយ។~~

~~(b) ផ្នែកនេះត្រូវបានអនុវត្តតែចំពោះវិធានការដែលបានចាត់ធ្វើក្រោយកាលបរិច្ឆេទមានប្រសិទ្ធភាពរបស់ផ្នែកនេះប៉ុណ្ណោះ។~~

~~(c) គ្មានអ្វីមួយនៅក្នុងផ្នែកនេះត្រូវបានបកស្រាយថាជាការហាមឃាត់ទៅលើសក្ខណៈសម្បត្តិពិតប្រាកដដោយផ្អែកលើភេទ ដែលមានភាពចាំបាច់សមហេតុសមផលចំពោះប្រតិបត្តិការជាប្រក្រតីនៃការងារសាធារណៈ ការអប់រំសាធារណៈ ឬការម៉ៅការសាធារណៈឡើយ។~~

~~(d) គ្មានអ្វីមួយនៅក្នុងផ្នែកនេះត្រូវបានបកស្រាយថាជាការបញ្ចប់សុពលភាពដីកាតុលាការ ឬវិក្រឹត្យការយល់ព្រមណាមួយ ដែលមានអានុភាពគិតចាប់ពីកាលបរិច្ឆេទប្រសិទ្ធភាពនៃផ្នែកនេះឡើយ។~~

~~(e) គ្មានអ្វីមួយនៅក្នុងផ្នែកនេះត្រូវបានបកស្រាយថាជាការហាមឃាត់ទៅលើវិធានការដែលត្រូវតែចាត់ធ្វើដើម្បីបង្កើត ឬរក្សានូវសិទ្ធិទទួលបានកម្មវិធីសហព័ន្ធឡើយ ដែលភាពគ្មានសិទ្ធិទទួលបាននឹងបណ្តាលឲ្យបាត់បង់នូវមូលនិធិសហព័ន្ធទៅកាន់រដ្ឋ។~~

~~(f) សម្រាប់គោលបំណងនៃផ្នែកនេះ "រដ្ឋ" ត្រូវអាប់បញ្ចូល ប៉ុន្តែមិនចាំបាច់កំណត់តែចំពោះ រដ្ឋខ្លួនឯង ទីក្រុងណាមួយ ខោនធីណាមួយ ទីក្រុងនិងខោនធីណាមួយ ប្រព័ន្ធសាកលវិទ្យាល័យសាធារណៈ រួមទាំងសាកលវិទ្យាល័យ California មណ្ឌលមហាវិទ្យាល័យសហគមន៍ មណ្ឌលសាលារៀន មណ្ឌលពិសេស ឬផ្នែករងនៃនយោបាយ ឬភ្នាក់ងាររដ្ឋាភិបាលណាមួយ ឬនៅក្នុងរដ្ឋនោះ។~~

~~(g) មធ្យោបាយដែលមានសម្រាប់ការអំលោភបំពានលើផ្នែកនេះ ត្រូវតែដូចគ្នាដោយមិនគិតពីជាតិសាសន៍ ភេទ ពណ៌សម្បុរ ជាតិពន្ធ ឬសញ្ជាតិដើមរបស់ភាគីដែលរងរបួសឡើយ ដូចដែលមានសម្រាប់ការបំពានច្បាប់ប្រឆាំងការរើសអើងរបស់រដ្ឋ California ដែលមានជាធរមានពីមុនមកដែរ។~~

~~(h) ផ្នែកនេះត្រូវតែស្វ័យអនុវត្ត។ ប្រសិនបើភាគណាមួយ ឬច្រើននៃផ្នែកនេះត្រូវបានរកឃើញថាមានទំនាស់ជាមួយនឹងច្បាប់សហព័ន្ធ ឬធម្មនុញ្ញនៃសហរដ្ឋនោះ ផ្នែកនេះត្រូវអនុវត្តឲ្យដល់កម្រិតអតិបរិមាដែលច្បាប់សហព័ន្ធ និងរដ្ឋធម្មនុញ្ញសហរដ្ឋអនុញ្ញាត។ រាល់ប្រការដែលគ្មានសុពលភាព ត្រូវតែអាចកាត់ចេញបានពីចំណែកដែលនៅសល់នៃផ្នែកនេះ។~~

សំណើប្រជាមតិ 17

វិសោធនកម្មនេះដែលបានស្នើដោយវិសោធនកម្មទី 6 នៃរដ្ឋធម្មនុញ្ញ សភានៃសម័យប្រជុំសាមញ្ញ 2019–2020 (សេចក្តីសម្រេច ជំពូក 24 លក្ខន្តិកៈឆ្នាំ 2020) ធ្វើវិសោធនកម្មយ៉ាងច្បាស់លាស់ទៅលើរដ្ឋធម្មនុញ្ញនៃរដ្ឋ California ដោយការធ្វើវិសោធនកម្មផ្នែកទាំងឡាយនេះ ដូច្នេះប្រការជាធរមានដែលត្រូវបានស្នើសុំឲ្យលុបចោលត្រូវបានបោះពុម្ពជាប្រភេទ~~អក្សរឆ្ងូតចោល~~ ហើយប្រការថ្មីដែលត្រូវបានស្នើឲ្យបន្ថែមត្រូវបានបោះពុម្ពជា *ប្រភេទអក្សរទ្រេត*ដើម្បីបង្ហាញថាទាំងនោះជាប្រការថ្មី។

សំណើវិសោធនកម្មលើមាត្រា II

ទីមួយ—ដែលផ្នែកទី 2 នៃមាត្រា II ត្រូវបានធ្វើវិសោធនកម្មដូចមានចែងថា៖

ផ្នែក 2. *(a)* ពលរដ្ឋអាមេរិកអាយុ 18 ឆ្នាំ និងមានទីលំនៅក្នុងរដ្ឋនេះអាចបោះឆ្នោតបាន។

(b) អ្នកបោះឆ្នោតដែលបាត់បង់សិទ្ធិបោះឆ្នោតខណៈពេលជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធដូចបានរៀបរាប់នៅក្នុងផ្នែក 4 ត្រូវទទួលបានសិទ្ធិបោះឆ្នោតរបស់ខ្លួនវិញក្រោយពេលបញ្ចប់រយៈពេលជាប់ពន្ធនាគាររបស់ពួកគេ។

ទីពីរ—ដែលផ្នែក 4 នៃមាត្រា II ត្រូវបានធ្វើវិសោធនកម្មដូចមានចែងថា៖

ផ្នែក 4. អង្គនីតិបញ្ញត្តិត្រូវហាមឃាត់ការអនុវត្តពុំត្រឹមត្រូវដែលប៉ះពាល់ដល់ការបោះឆ្នោត ហើយត្រូវផ្តល់ការដកហូតសិទ្ធិអ្នកបោះឆ្នោតខណៈដែលអសមត្ថភាពផ្លូវចិត្ត ឬ~~ជាប់ពន្ធនាគារ ឬកំពុងស្ថិតនៅក្រៅឃុំ ដោយមានលក្ខខណ្ឌ~~ *ដែលកំពុងជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធ* ពីការផ្ទេរទៅសបទឧក្រិដ្ឋ។

សំណើប្រជាមតិ 18

វិសោធនកម្មនេះដែលបានស្នើដោយវិសោធនកម្មទី 4 នៃរដ្ឋធម្មនុញ្ញ សភានៃសម័យប្រជុំសាមញ្ញ 2019–2020 (សេចក្តីសម្រេច ជំពូក 30 លក្ខន្តិកៈឆ្នាំ 2020) ធ្វើវិសោធនកម្មយ៉ាងច្បាស់លាស់ទៅលើរដ្ឋធម្មនុញ្ញនៃរដ្ឋ California ដោយការធ្វើវិសោធនកម្មផ្នែកមួយនេះ ដូច្នេះប្រការថ្មីដែលត្រូវបានស្នើសុំឲ្យបន្ថែមត្រូវបានបោះពុម្ពជា *ប្រភេទអក្សរទ្រេត* ដើម្បីបញ្ជាក់ថាពួកវាជាប្រការថ្មី។

សំណើវិសោធនកម្មចំពោះមាត្រា II

ដែលផ្នែកទី 2 នៃមាត្រា II ត្រូវបានធ្វើវិសោធនកម្មដូចមានចែងថា៖

ផ្នែក 2. *(a)* ពលរដ្ឋអាមេរិក *ដែលមានអាយុយ៉ាងតិច* 18 ឆ្នាំ និងមានលំនៅដ្ឋាន នៅក្នុងរដ្ឋនេះអាចបោះឆ្នោតបាន។

(b) ពលរដ្ឋអាមេរិកដែលមានអាយុ 17 ឆ្នាំ គឺជាអ្នកតាំងទីលំនៅក្នុងរដ្ឋនេះ ហើយនឹងមានអាយុយ៉ាងតិច 18 ឆ្នាំ នៅពេលបោះឆ្នោតសាកលលើកក្រោយ អាចបោះឆ្នោតនៅក្នុងការបោះឆ្នោតបឋម ឬពិសេសណាមួយ

ដែលកើតឡើងមុនការបោះឆ្នោតសាកលលើកក្រោយ ដែលពលរដ្ឋនោះនឹងមានសិទ្ធិបោះឆ្នោតបានប្រសិនបើមានអាយុយ៉ាងតិច 18 ឆ្នាំ។

សំណើប្រជាមតិ 19

វិសោធនកម្មនេះ ដែលបានស្នើដោយវិសោធនកម្មទី 11 នៃរដ្ឋធម្មនុញ្ញសភានៃសម័យប្រជុំសាមញ្ញ 2019–2020 (សេចក្ដីសម្រេច ជំពូក 31 លក្ខន្ដិកៈឆ្នាំ 2020) ធ្វើវិសោធនកម្មយ៉ាងច្បាស់លាស់ទៅលើធម្មនុញ្ញនៃរដ្ឋ California ដោយការបន្ថែមផ្នែកថ្មីនេះ ដូច្នេះប្រការថ្មីដែលត្រូវបានស្នើសុំឲ្យបន្ថែម ត្រូវបានបោះពុម្ពជា *ប្រភេទអក្សរទ្រេត* ដើម្បីបញ្ជាក់ថាពួកវាជាប្រការថ្មី។

សំណើវិសោធនកម្មចំពោះមាត្រា XIII A

ទីមួយ—វិធានការនេះត្រូវបានស្គាល់ ហើយអាចត្រូវបានយោងទៅលើថាជាការការពារផ្ទះសម្រាប់មនុស្សវ័យចំណាស់ ពិការធ្ងន់ធ្ងរ ក្រុមគ្រួសារ និងជនរងគ្រោះពីភ្លើងឆេះព្រៃ ឬច្បាប់នៃគ្រោះធម្មជាតិ។

ទីពីរ—ដែលផ្នែកទី 2.1 ត្រូវបានបន្ថែមទៅលើមាត្រា XIII A ដូចខាងក្រោម៖

ផ្នែកទី 2.1. (a) ការដាក់ដែនកំណត់លើកំណើនពន្ធអចលនទ្រព្យទៅលើទីលំនៅចម្បងសម្រាប់មនុស្សចាស់ ជនពិការធ្ងន់ធ្ងរ ជនរងគ្រោះពីភ្លើងឆេះព្រៃ និងគ្រោះធម្មជាតិ និងក្រុមគ្រួសារ។ វាជាចេតនារបស់អង្គនីតិបញ្ញត្តិនៅក្នុងការស្នើសុំ និងរបស់ពលរដ្ឋ នៅក្នុងការអនុម័តផ្នែកនេះ ដើម្បីធ្វើកិច្ចការទាំងពីរដូចខាងក្រោម៖

(1) កំណត់ព្រំដែនកំណើនពន្ធអចលនទ្រព្យលើទីលំនៅចម្បង ដោយការបំបាត់ចោលនូវការរឹតបន្ដឹងទីតាំងដែលមិនស្មើភាពគ្នាទៅលើម្ចាស់ផ្ទះដែលពិការធ្ងន់ធ្ងរ ជនរងគ្រោះពីភ្លើងឆេះព្រៃ ឬគ្រោះមហន្ដរាយផ្សេងៗ ឬពលរដ្ឋវ័យចំណាស់អាយុចាប់ពី 55 ឆ្នាំឡើងទៅដែលត្រូវការផ្លាស់ទីលំនៅទៅជិតក្រុមគ្រួសារ ឬការថែទាំវេជ្ជសាស្ត្រ បន្ថយទំហំ ស្វែងរកផ្ទះដែលសមស្របនឹងតម្រូវការរបស់ពួកគេ ឬផ្លាស់ប្ដូរផ្ទះដែលខូចខាត និងកំណត់កម្រិតនៃការខូចខាតពីភ្លើងឆេះព្រៃទៅលើផ្ទះ តាមរយៈមូលនិធិដែលត្រូវបានរៀបចំសម្រាប់ការការពារអគ្គីភ័យ និងការឆ្លើយតបគ្រោះអាសន្ន។

(2) កំណត់ព្រំដែនកំណើនពន្ធអចលនទ្រព្យទៅលើផ្ទះគ្រួសារ ដែលប្រើប្រាស់ជាទីលំនៅចម្បងដោយការការពារសិទ្ធិរបស់ឪពុកម្ដាយ និងជីដូនជីតាដើម្បីផ្ទេរកម្មសិទ្ធិផ្ទះគ្រួសាររបស់ពួកគេទៅឲ្យកូនចៅរបស់ពួកគេប្រើប្រាស់បន្ដជាទីលំនៅចម្បង ខណៈពេលដែលមានការលុបបំបាត់ចោលកលល្បិចគេចពន្ធមិនស្មើភាពគ្នា ដែលប្រើប្រាស់ដោយអ្នកវិនិយោគឆ្នេរខាងកើត ជនល្បីល្បាញ អ្នកមានធនធានដែលមិនមានទីលំនៅក្នុង California និងអ្នកទទួលមរតកពីមូលនិធិទំនុកចិត្ត ដើម្បីចៀសវាងការបង់ប្រាក់ចំណែកស្មើគ្នាលើពន្ធអចលនទ្រព្យផ្ទះលំហែ ទ្រព្យប្រាក់ចំណូល និងផ្ទះជួលតាមឆ្នេរសមុទ្រដែលពួកគេមាននៅរដ្ឋ California។

(b) ភាពយុត្ដិធម៌នៃពន្ធអចលនទ្រព្យសម្រាប់ពលរដ្ឋវ័យចំណាស់ ពិការធ្ងន់ធ្ងរ និងជនរងគ្រោះពីភ្លើងឆេះព្រៃ និងគ្រោះមហន្ដរាយធម្មជាតិ។ ទោះបីជាមានប្រការផ្សេងទៀតនៃរដ្ឋធម្មនុញ្ញនេះ ឬច្បាប់ផ្សេងទៀតក៏ដោយ ចាប់ពីថ្ងៃ និងក្រោយថ្ងៃទី 1 ខែមេសា ឆ្នាំ 2021 តទៅ ប្រការខាងក្រោមនេះត្រូវអនុវត្ត៖

(1) ស្ថិតក្រោមនីតិវិធី និងនិយមន័យដែលអាចអនុវត្តបានដែលផ្ដល់ដោយលក្ខន្ដិកៈច្បាប់ ម្ចាស់នៃទីលំនៅចម្បងដែលមានអាយុចាប់ពី 55 ឆ្នាំឡើងទៅ ជនពិការធ្ងន់ធ្ងរ ឬជនរងគ្រោះពីភ្លើងឆេះព្រៃ ឬគ្រោះធម្មជាតិ អាចផ្ទេរតម្លៃជាប់ពន្ធនៃទីលំនៅចម្បងរបស់ខ្លួនទៅកាន់ទីលំនៅចម្បងជំនួសមួយដែលមានទីតាំងនៅកន្លែងណាមួយនៅក្នុងរដ្ឋនេះ ដោយមិនគិតពីទីតាំង ឬតម្លៃនៃទីលំនៅចម្បងជំនួស ដែលបានទិញ ឬបានសាងសង់ថ្មីធ្វើជាទីលំនៅគោលរបស់ជននោះក្នុងរយៈពេលពីរឆ្នាំនៃការលក់ទីលំនៅចម្បងដើម។

(2) សម្រាប់គោលបំណងនៃផ្នែករងនេះ៖

(A) សម្រាប់រាល់ការផ្ទេរតម្លៃជាប់ពន្ធទៅកាន់ទីលំនៅចម្បងជំនួសដែលមានតម្លៃស្មើ ឬតិចជាងទីលំនៅចម្បងដើម តម្លៃជាប់ពន្ធនៃទីលំនៅចម្បងជំនួសត្រូវចាត់ទុកថាជាតម្លៃដែលអាចយកពន្ធបាននៃទីលំនៅចម្បងដើម។

(B) សម្រាប់រាល់ការផ្ទេរតម្លៃជាប់ពន្ធនៃទីលំនៅចម្បងជំនួស ដែលមានតម្លៃខ្ពស់ជាងទីលំនៅចម្បងដើមនោះ តម្លៃជាប់ពន្ធនៃទីលំនៅចម្បងជំនួសត្រូវគណនាដោយការបន្ថែមភាពខុសគ្នារវាងតម្លៃសាច់ប្រាក់ពេញលេញនៃទីលំនៅចម្បងដើម និងតម្លៃសាច់ប្រាក់ពេញលេញនៃទីលំនៅចម្បងជំនួស ទៅនឹងតម្លៃជាប់ពន្ធនៃទីលំនៅចម្បងដើម។

(3) ម្ចាស់នៃទីលំនៅចម្បងដែលមានអាយុលើសពី 55 ឆ្នាំ ឬជាជនពិការធ្ងន់ធ្ងរ មិនត្រូវបានអនុញ្ញាតឲ្យផ្ទេរតម្លៃជាប់ពន្ធនៃទីលំនៅចម្បងលើសពីបីដងឡើយ ដោយអនុលោមតាមផ្នែករងនេះ។

(4) រាល់បុគ្គលដែលស្វែងរកការផ្ទេរតម្លៃជាប់ពន្ធនៃទីលំនៅចម្បងរបស់ខ្លួន ដោយអនុលោមតាមផ្នែករងនេះ ត្រូវដាក់ពាក្យសុំជាមួយនឹងអ្នកវាយតម្លៃប្រចាំខោនធីដែលទីលំនៅចម្បងជំនួសនោះស្ថិតនៅ។ ពាក្យសុំត្រូវដាក់បញ្ចូលជាអប្បបរិមានូវព័ត៌មានដែលអាចប្រៀបធៀបគ្នាបានជាមួយនឹងព័ត៌មានដែលបានកំណត់នៅក្នុងកថាខណ្ឌទី (1) នៃផ្នែករង (f) នៃផ្នែក 69.5 នៃច្បាប់ប្រាក់ចំណូលនិងការដកពន្ធ ដែលផ្នែកនោះបានចែងនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2020។

(c) ភាពយុត្ដិធម៌នៃពន្ធអចលនទ្រព្យសម្រាប់ផ្ទះគ្រួសារ។ ថ្វីបើមានប្រការផ្សេងទៀតនៃរដ្ឋធម្មនុញ្ញនេះ ឬច្បាប់ផ្សេងទៀតក៏ដោយ ចាប់ពីថ្ងៃ និងក្រោយថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ 2021 តទៅ ប្រការខាងក្រោមនេះត្រូវបានអនុវត្ត៖

(1) សម្រាប់គោលបំណងនៃផ្នែករង (a) នៃផ្នែក 2 ពាក្យថា "បានទិញ" និង "ផ្លាស់ប្ដូរម្ចាស់កម្មសិទ្ធិ" មិនរាប់បញ្ចូលនូវការទិញ ឬការផ្ទេរផ្ទះគ្រួសាររបស់អ្នកផ្ទេរនៅក្នុងករណីនៃការផ្ទេរមួយរវាងឪពុកម្ដាយ និងកូនៗរបស់ពួកគេឡើយ ដូចមានចែងដោយអង្គនីតិបញ្ញត្ដិ ប្រសិនបើអចលនទ្រព្យនោះបន្ដនៅជាផ្ទះគ្រួសាររបស់អ្នកទទួលការផ្ទេរ។ ផ្នែករងនេះ ត្រូវបានអនុវត្ដចំពោះការផ្ទេរដោយស្ម័គ្រចិត្ត និងការផ្ទេរដែលជាលទ្ធផលពីដីកាតុលាការ ឬបញ្ញត្ដិតុលាការ។ តម្លៃជាប់ពន្ធថ្មីនៃផ្ទះគ្រួសាររបស់អ្នកទទួលការផ្ទេរ ត្រូវតែជាផលបូកនៃចំនួនទាំងពីរខាងក្រោម៖

(A) តម្លៃជាប់ពន្ធនៃផ្ទះគ្រួសារ ដែលស្ថិតក្រោមការលៃតម្រូវដូចដែលបានអនុញ្ញាតដោយផ្នែករង (b) នៃផ្នែកទី 2 ដែលត្រូវបានកំណត់ចាប់ពីកាលបរិច្ឆេទភ្លាមៗមុនកាលបរិច្ឆេទនៃការទិញដោយ ឬការផ្ទេរទៅឲ្យអ្នកទទួលការផ្ទេរនោះ។

(B) ការអនុវត្ដនៃចំនួនទឹកប្រាក់ខាងក្រោម៖

(i) ប្រសិនបើតម្លៃដែលបានវាយតម្លៃនៃផ្ទះគ្រួសារនៅពេលទិញដោយ ឬផ្ទេរទៅឲ្យអ្នកទទួលការផ្ទេរតិចជាងផលបូកនៃតម្លៃជាប់ពន្ធ ដូចមានរៀបរាប់នៅក្នុងអនុកថាខណ្ឌ (A) បូកនឹងមួយលានដុល្លារ ($1,000,000) បន្ទាប់មកសូន្យដុល្លារ ($0)។

18

19

(ii) ប្រសិនបើតម្លៃដែលបានវាយតម្លៃនៃផ្ទះគ្រួសារនៅពេលទិញដោយ ឬផ្ទេរទៅឲ្យដោយអ្នកទទួលការផ្ទេរស្មើគ្នានឹង ឬច្រើនជាងផលបូកនៃតម្លៃជាប់ពន្ធ ដូចមានរៀបរាប់នៅក្នុងអនុកថាខណ្ឌ (A) បូកនឹងមួយលានដុល្លារ ($1,000,000) ចំនួនទឹកប្រាក់ដែលស្មើនឹងតម្លៃដែលបានវាយតម្លៃនៃផ្ទះគ្រួសារនៅពេលទិញ ឬផ្ទេរទៅឲ្យអ្នកទទួលការផ្ទេរ ដកនឹងផលបូកនៃតម្លៃជាប់ពន្ធ ដូចមានរៀបរាប់នៅក្នុងអនុកថាខណ្ឌ (A) និងមួយលានដុល្លារ ($1,000,000)។

(2) កថាខណ្ឌ (1) ក៏ត្រូវបានអនុវត្តចំពោះការទិញ ឬការផ្ទេរផ្ទះគ្រួសាររវាងជីដូនជីតា និងចៅរបស់ពួកគេផងដែរ ប្រសិនបើឪពុកម្តាយទាំងអស់នៃចៅទាំងនោះដែលមានលក្ខណៈសម្បត្តិជាកូនរបស់ជីដូនជីតានោះបានស្លាប់ចាប់ពីកាលបរិច្ឆេទនៃការទិញ ឬការផ្ទេរនោះ។

(3) កថាខណ្ឌ (1) និង (2) ក៏ត្រូវបានអនុវត្តចំពោះការទិញ ឬការផ្ទេរកសិដ្ឋានគ្រួសារផងដែរ។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ រាល់ការសំដៅទៅលើពាក្យថា "ផ្ទះគ្រួសារ" នៅក្នុងកថាខណ្ឌ (1) ឬ (2) ត្រូវចាត់ទុកថាសំដៅទៅលើ "កសិដ្ឋានគ្រួសារ" ជំនួសវិញ។

(4) ចាប់ពីថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ 2023 តទៅ និងរៀងរាល់ពីរឆ្នាំម្តងថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំបន្ទាប់តទៅ ក្រុមប្រឹក្សាសមកម្មរដ្ឋ ត្រូវលៃតម្រូវចំនួនទឹកប្រាក់មួយលានដុល្លារ ($1,000,000) ដូចមានបរិយាយនៅក្នុងកថាខណ្ឌ (1) សម្រាប់អតិផរណា ដើម្បីឆ្លុះបញ្ចាំងនូវការប្រែប្រួលសន្ទស្សន៍តម្លៃផ្ទះសម្រាប់រដ្ឋ California សម្រាប់ឆ្នាំប្រតិទិនមុនដូចដែលបានកំណត់ដោយទីភ្នាក់ងារហិរញ្ញវត្ថុលំនៅដ្ឋានសហព័ន្ធ។ ក្រុមប្រឹក្សាសមកម្មរដ្ឋត្រូវគណនា និងបោះពុម្ពផ្សាយនូវរាល់ការលៃតម្រូវដែលបានតម្រូវដោយកថាខណ្ឌនេះ។

(5) (A) ស្ថិតក្រោមអនុកថាខណ្ឌ (B) ដើម្បីទទួលអត្ថប្រយោជន៍ពន្ធ អចលនទ្រព្យដែលផ្តល់ជូនដោយផ្នែកនេះសម្រាប់ការទិញ ឬការផ្ទេរផ្ទះគ្រួសារ អ្នកទទួលការផ្ទេរត្រូវទាមទារសុំការលើកលែងសម្រាប់ម្ចាស់ផ្ទះ ឬការលើកលែងសម្រាប់អតីតយុទ្ធជនពិការនៅពេលទិញ ឬផ្ទេរផ្ទះគ្រួសារនោះ។

(B) អ្នកទទួលការផ្ទេរ ដែលខកខានក្នុងការទាមទារសុំការលើកលែងសម្រាប់ម្ចាស់ផ្ទះ ឬការលើកលែងសម្រាប់អតីតយុទ្ធជនពិការនៅពេលទិញ ឬផ្ទេរផ្ទះគ្រួសារទេនោះ អាចនឹងទទួលបានអត្ថប្រយោជន៍ពន្ធ អចលនទ្រព្យដែលផ្តល់ជូនដោយផ្នែកនេះ ដោយការទាមទារសុំការលើកលែងសម្រាប់ម្ចាស់ផ្ទះ ឬការលើកលែងសម្រាប់អតីតយុទ្ធជនពិការ ក្នុងរយៈពេលមួយឆ្នាំនៃការទិញ ឬផ្ទេរផ្ទះគ្រួសារនោះ ហើយត្រូវមានសិទ្ធិទទួលបានប្រាក់បង់ពន្ធវិញ ដែលត្រូវបានជំពាក់ពីមុន ឬត្រូវបានបង់ចន្លោះកាលបរិច្ឆេទនៃការផ្ទេរ និងកាលបរិច្ឆេទដែលអ្នកទទួលការផ្ទេរទាមទារសុំការលើកលែងសម្រាប់ម្ចាស់ផ្ទះ ឬការលើកលែងសម្រាប់អតីតយុទ្ធជនពិការ។

(d) ផ្នែករង (h) នៃផ្នែកទី 2 ត្រូវបានអនុវត្តចំពោះរាល់ការទិញ ឬផ្ទេរណាមួយដែលកើតឡើងនៅថ្ងៃទី ឬមុនថ្ងៃទី 15 ខែកុម្ភៈ ឆ្នាំ 2021 ប៉ុន្តែមិនត្រូវបានអនុវត្តចំពោះការទិញ ឬផ្ទេរណាមួយដែលកើតឡើងក្រោយកាលបរិច្ឆេទនេះឡើយ។ ផ្នែករង (h) នៃផ្នែកទី 2 ត្រូវអស់សុពលភាពត្រឹមថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ 2021។

(e) សម្រាប់គោលបំណងនៃផ្នែកនេះ៖

(1) "ការលើកលែងពន្ធសម្រាប់អតីតយុទ្ធជនពិការ" មានន័យថា ការលើកលែងដែលត្រូវបានអនុញ្ញាតដោយផ្នែករង (a) នៃផ្នែកទី 4 នៃមាត្រា XIII។

(2) "កសិដ្ឋានគ្រួសារ" មានន័យថា អចលនទ្រព្យណាដែលស្ថិតក្រោមការប្រមូលផល ឬកំពុងត្រូវបានប្រើប្រាស់ជាវាលស្មៅ ឬដីសម្រាប់ចិញ្ចឹមគោក្រាបី ឬត្រូវបានប្រើប្រាស់ដើម្បីផលិតនូវផលិតផលកសិកម្ម ដូចដែលពាក្យនោះត្រូវបានកំណត់និយមន័យនៅក្នុងផ្នែក 51201 នៃច្បាប់រដ្ឋាភិបាលដូចដែលផ្នែកនោះបានចែងកាលពីថ្ងៃទី 1 ខែមករា ឆ្នាំ 2020 ។

(3) "ផ្ទះគ្រួសារ" មានអត្ថន័យដូចគ្នានឹងពាក្យថា "ទីលំនៅគោល" ដូចពាក្យដែលត្រូវបានប្រើប្រាស់នៅក្នុងផ្នែករង (k) នៃផ្នែកទី 3 នៃមាត្រា XIII ។

(4) "តម្លៃសាច់ប្រាក់ពេញលេញ" មានអត្ថន័យដូចគ្នានឹងនិយមន័យដែលបានកំណត់នៅក្នុងផ្នែករង (a) នៃផ្នែកទី 2។

(5) "ការលើកលែងពន្ធសម្រាប់ម្ចាស់ផ្ទះ" មានន័យថា ការលើកលែងពន្ធដែលផ្តល់ដោយផ្នែករង (k) នៃផ្នែកទី 3 នៃមាត្រា XIII ។

(6) "គ្រោះធម្មជាតិ" ដូចដែលបានប្រកាសដោយអភិបាល មានន័យថា ការកើតមាននៃលក្ខខណ្ឌនៃគ្រោះមហន្តរាយ ឬគ្រោះភ័យធ្ងន់ធ្ងរចំពោះសុវត្ថិភាពរបស់មនុស្ស ឬទ្រព្យសម្បត្តិនៅក្នុងតំបន់រងផលប៉ះពាល់ដែលបណ្តាលមកពីលក្ខខណ្ឌទាំងឡាយដូចជា អគ្គីភ័យ ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ដីបាក់ រញ្ជួយដី ចលាចលស៊ីវិល ការឈ្លានពានពីបរទេស ឬបន្ទុះភ្នំភ្លើង។

(7) "ទីលំនៅចម្បង" មានន័យថា ទីលំនៅដែលមានលក្ខណៈសម្រាប់ទទួលបានដូចជា៖

(A) ការលើកលែងពន្ធសម្រាប់ម្ចាស់ផ្ទះ។

(B) ការលើកលែងពន្ធសម្រាប់អតីតយុទ្ធជនពិការ។

(8) "ទីលំនៅគោល" ដូចដែលត្រូវបានប្រើប្រាស់នៅក្នុងផ្នែករង (b) មានអត្ថន័យដូចគ្នានឹងពាក្យដែលប្រើប្រាស់នៅក្នុងផ្នែករង (a) នៃផ្នែកទី 2។

(9) "ទីលំនៅចម្បងជំនួស" មានន័យដូចគ្នានឹង "លំនៅជំនួស" ដូចដែលពាក្យនោះត្រូវបានកំណត់និយមន័យនៅក្នុងផ្នែករង (a) នៃផ្នែកទី2។

(10) "តម្លៃជាប់ពន្ធ" មានន័យថា តម្លៃឆ្នាំមូលដ្ឋានដែលត្រូវបានកំណត់ដោយយោងទៅតាមផ្នែករង (a) នៃផ្នែកទី 2 បូកនឹងការលៃតម្រូវណាមួយដែលត្រូវបានអនុញ្ញាតដោយផ្នែករង (b) នៃផ្នែកទី 2។

(11) "ជនរងគ្រោះដោយសារភ្លើងឆេះព្រៃ ឬគ្រោះធម្មជាតិ" សំដៅលើម្ចាស់នៃទីលំនៅចម្បងដែលរងការខូចខាតជាទម្ងន់ ជាលទ្ធផលនៃភ្លើងឆេះព្រៃ ឬគ្រោះមហន្តរាយធម្មជាតិដែលមានចំនួនលើសពី 50 ភាគរយនៃតម្លៃការកែលម្អទីលំនៅចម្បងភ្លាមៗ មុនពេលមានភ្លើងឆេះព្រៃ ឬគ្រោះមហន្តរាយធម្មជាតិ។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ "ការខូចខាត" រាប់បញ្ចូលទាំងការបន្ថយលើតម្លៃនៃទីលំនៅចម្បង ដែលជាលទ្ធផលនៃការរឹតត្បិតការប្រើប្រាស់ ដែលបណ្តាលមកពីភ្លើងឆេះព្រៃ ឬគ្រោះធម្មជាតិ។

(12) "ភ្លើងឆេះព្រៃ" មានអត្ថន័យដូចគ្នានឹងពាក្យដែលត្រូវបានកំណត់និយមន័យនៅក្នុងផ្នែករង (j) នៃផ្នែកទី 51177 នៃច្បាប់រដ្ឋាភិបាលដូចដែលផ្នែកនេះបានចែងនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2020។

ទីបី—ដែលផ្នែកទី 2.2 ត្រូវបានបន្ថែមទៅលើមាត្រា XIIIA ដូចខាងក្រោម៖

ផ្នែក 2.2. (a) កិច្ចការពារសេវាកម្មអគ្គីភ័យ ការឆ្លើយតបគ្រោះអាសន្ន និងសេវាកម្មខោនធី។ វាជាចេតនារបស់អង្គនីតិបញ្ញត្តិ

នៅក្នុងការស្នើសុំ និងរបស់ពលរដ្ឋនៅក្នុងការអនុម័តផ្នែកនេះ និងផ្នែក 2.3 ដើម្បីធ្វើកិច្ចការទាំងពីរដូចខាងក្រោម៖

(1) លះបង់ប្រាក់ចំណូលសម្រាប់កិច្ចការពារអគ្គីភ័យ ការឆ្លើយតបគ្រោះអាសន្ន ដោះស្រាយអសមធម៌នៅក្នុងមណ្ឌលអគ្គីភ័យដែលខ្វះមូលនិធិ ធានាថាសហគមន៍ទាំងអស់ត្រូវបានការពារពីភ្លើងឆេះព្រៃ និងការពារជីវិតរបស់ពលរដ្ឋ California រាប់លាននាក់។

(2) ការពារប្រាក់ចំណូលខោនធី និងសេវាកម្មក្នុងមូលដ្ឋានសំខាន់ៗផ្សេងទៀត។

(b) (1) មូលនិធិឆ្លើយតបអគ្គីភ័យរដ្ឋ California ត្រូវបានបង្កើតឡើងនៅក្នុងរតនាគាររដ្ឋ។

(2) មូលនិធិការពារប្រាក់ចំណូលខោនធី ត្រូវបានបង្កើតឡើងនៅក្នុងរតនាគាររដ្ឋ។ ថវិកានៅក្នុងមូលនិធិការពារប្រាក់ចំណូលខោនធី ត្រូវបានលៃបម្រុងជាបន្ត ដោយមិនគិតពីឆ្នាំសារពើពន្ធ សម្រាប់គោលបំណងនៃការសងប្រាក់ជូនទីភ្នាក់ងារក្នុងមូលដ្ឋានដែលមានសិទ្ធិទទួលបាន ដែលជួបប្រទះចំណូលអវិជ្ជមាន ហើយនិងការបង់ថ្លៃចំណាយរដ្ឋបាលរបស់ក្រសួងពន្ធដារ និងរដ្ឋបាលប្រាក់កម្រៃរដ្ឋ California ដោយអនុលោមតាមផ្នែក 2.3។ ថវិកានៅក្នុងមូលនិធិនេះ ត្រូវប្រើប្រាស់តែទៅតាមការចែងនៅក្នុងផ្នែកទី 2.3 ប៉ុណ្ណោះ។

(c) សម្រាប់គោលបំណងនៃការគណនាដែលតម្រូវដោយផ្នែកទី 8 នៃមាត្រា XVI ថវិកានៅក្នុងមូលនិធិឆ្លើយតបអគ្គីភ័យរដ្ឋ California និងមូលនិធិការពារប្រាក់ចំណូលខោនធី ត្រូវចាត់ទុកថាជាប្រាក់ចំណូលមូលនិធិទូទៅ ដែលអាចត្រូវបានលៃតម្រូវស្របតាមមាត្រា XIII B។

(d) នាយកផ្នែកហិរញ្ញវត្ថុត្រូវធ្វើកិច្ចការជាធរមានដូចតទៅ៖

(1) នៅថ្ងៃទី ឬមុនថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 2022 និងនៅថ្ងៃទី ឬមុនថ្ងៃទី 1 ខែកញ្ញា នៃឆ្នាំបន្ទាប់និមួយៗរហូតដល់ថ្ងៃទី 1 ខែកញ្ញាឆ្នាំ 2027 គណនាប្រាក់ចំណូល និងប្រាក់សន្សំបន្ថែមដែលបានកើនឡើងទៅលើរដ្ឋពីការអនុវត្តនៃផ្នែកទី 21 រួមបញ្ចូលប៉ុន្តែមិនកំណត់តែចំពោះ កំណើនណាមួយក្នុងប្រាក់ចំណូលពន្ធរដ្ឋ និងប្រាក់សន្សំសុទ្ធមកលើរដ្ឋ ដែលកើតឡើងពីរាល់ការកាត់បន្ថយនូវកាតព្វកិច្ចផ្តល់មូលនិធិរបស់រដ្ឋក្រោមផ្នែកទី 8 នៃមាត្រា XVI អំឡុងពេលឆ្នាំសារពើពន្ធមុនដែលបញ្ចប់នៅថ្ងៃទី 30 ខែមិថុនា។ នៅក្នុងការគណនាដែលតម្រូវដោយកថាខណ្ឌនេះ នាយកផ្នែកហិរញ្ញវត្ថុត្រូវប្រើប្រាស់ទិន្នន័យជាក់ស្តែង ឬការប៉ាន់ស្មានល្អបំផុតដែលអាចរកបាន នៅពេលណាដែលពុំអាចរកបានទិន្នន័យជាក់ស្តែង។ ការគណនានេះ ត្រូវតែជាការសម្រេចចុងក្រោយ ហើយមិនត្រូវបានលៃតម្រូវសម្រាប់ការផ្លាស់ប្តូរបន្តបន្ទាប់ទៀត នៅក្នុងទិន្នន័យដែលជាមូលដ្ឋានឡើយ។ នាយកផ្នែកហិរញ្ញវត្ថុ ត្រូវបញ្ជាក់នូវលទ្ធផលនៃការគណនាជូនអង្គនីតិបញ្ញត្តិ និងអ្នកត្រួតពិនិត្យឲ្យបានមុនថ្ងៃទី 1 ខែកញ្ញា ជារៀងរាល់ឆ្នាំ។

(2) នៅថ្ងៃទី ឬមុនថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 2028 និងថ្ងៃទី 1 ខែកញ្ញានៃឆ្នាំបន្តនិមួយៗ ត្រូវគណនាប្រាក់ចំណូល និងប្រាក់សន្សំបន្ថែមដែលបានកើនឡើងទៅលើរដ្ឋពីការអនុវត្តនៃផ្នែក 2.1 រួមបញ្ចូលប៉ុន្តែមិនកំណត់តែចំពោះ រាល់កំណើនប្រាក់ចំណូលពន្ធលើប្រាក់ចំណូលរដ្ឋ និងប្រាក់សន្សំសុទ្ធមកលើរដ្ឋ ដែលកើតឡើងពីរាល់ការកាត់បន្ថយកាតព្វកិច្ចផ្តល់មូលនិធិរបស់រដ្ឋក្រោមផ្នែកទី 8 នៃមាត្រា XVI អំឡុងពេលនៃឆ្នាំសារពើពន្ធមុនដែលបញ្ចប់នៅថ្ងៃទី 30 ខែមិថុនា ដោយការគុណចំនួនទឹកប្រាក់មកពីឆ្នាំសារពើពន្ធមុនដែលបញ្ចប់នៅថ្ងៃទី 30 ខែមិថុនា ជាមួយនឹងអត្រានៃកំណើនប្រាក់ចំណូលពន្ធអចលនទ្រព្យដែលបានលៃទុកសម្រាប់ទីភ្នាក់ងារក្នុងមូលដ្ឋាននៅក្នុងឆ្នាំសារពើពន្ធនោះ។ នៅក្នុងការគណនាដែលតម្រូវដោយកថាខណ្ឌនេះ នាយកផ្នែកហិរញ្ញវត្ថុ ត្រូវប្រើប្រាស់ទិន្នន័យជាក់ស្តែង ឬការប៉ាន់ស្មានល្អបំផុតដែលអាចរកបាន នៅពេលណាមិនមានទិន្នន័យជាក់ស្តែង។ ការគណនានេះ ត្រូវតែជាការសម្រេចចុងក្រោយ ហើយមិនត្រូវបានលៃតម្រូវសម្រាប់ការផ្លាស់ប្តូរបន្ទាប់នៅក្នុងទិន្នន័យដែលជាមូលដ្ឋានឡើយ។ នាយកផ្នែកហិរញ្ញវត្ថុ ត្រូវបញ្ជាក់នូវលទ្ធផលនៃការគណនាជូនអង្គនីតិបញ្ញត្តិ និងអ្នកត្រួតពិនិត្យឲ្យបានមុនថ្ងៃទី 1 ខែកញ្ញា ជារៀងរាល់ឆ្នាំសារពើពន្ធ។

(e) មុនថ្ងៃទី 15 ខែកញ្ញា ឆ្នាំ 2022 និងរាល់ថ្ងៃទី 15 ខែកញ្ញា នៃឆ្នាំបន្តបន្ទាប់ អ្នកត្រួតពិនិត្យត្រូវធ្វើដូចតទៅ៖

(1) ផ្ទេរពីមូលនិធិទូទៅចូលមូលនិធិឆ្លើយតបអគ្គីភ័យរដ្ឋ California នូវចំនួនទឹកប្រាក់ដែលស្មើនឹង 75 ភាគរយនៃចំនួនដែលបានគណនាដោយនាយកផ្នែកហិរញ្ញវត្ថុ ដោយអនុលោមតាមផ្នែករង (d) សម្រាប់ឆ្នាំអាចអនុវត្តបាននោះ។

(2) ផ្ទេរពីមូលនិធិទូទៅចូលទៅកាន់មូលនិធិការពារប្រាក់ចំណូលខោនធី នូវចំនួនទឹកប្រាក់ដែលស្មើនឹង 15 ភាគរយនៃចំនួនទឹកប្រាក់ដែលបានគណនាដោយនាយកផ្នែកហិរញ្ញវត្ថុ ដោយអនុលោមតាមផ្នែករង (d) សម្រាប់ឆ្នាំធរមាននោះ។ ថវិកាដែលបានផ្ទេរទៅកាន់មូលនិធិការពារប្រាក់ចំណូលខោនធី ដែលអនុលោមតាមកថាខណ្ឌនេះ ត្រូវប្រើប្រាស់ដើម្បីសងប្រាក់ជូនទីភ្នាក់ងារក្នុងមូលដ្ឋានដែលមានសិទ្ធិ ដែលជួបប្រទះចំណូលអវិជ្ជមាន ដូចដែលបានចែងនៅក្នុងផ្នែកទី 2.3។

(f) ថវិកានៅក្នុងមូលនិធិឆ្លើយតបអគ្គីភ័យរដ្ឋ California ត្រូវប្រើប្រាស់ដោយអង្គនីតិបញ្ញត្តិនៅក្នុងឆ្នាំសារពើពន្ធនីមួយៗសម្រាប់តែគោលបំណងនៃផ្នែកនេះម្យ៉ាងគត់ ហើយលើកលែងតែមានចែងនៅក្នុងផ្នែករង (g) មិនត្រូវបានលៃបម្រុងសម្រាប់គោលបំណងផ្សេងទៀតឡើយ។ ថវិកានៅក្នុងមូលនិធិឆ្លើយតបអគ្គីភ័យរដ្ឋ California អាចត្រូវបានប្រើប្រាស់ដោយមិនគិតពីឆ្នាំសារពើពន្ធឡើយ ហើយត្រូវប្រើប្រាស់ដើម្បីពង្រីកបុគ្គលិកពន្លត់អគ្គីភ័យ ដូចមានចែងនៅក្នុងកថាខណ្ឌ (1) ដល់ (4) រួមបញ្ចូលទាំង ប៉ុន្តែមិនមែនដើម្បីជំនួសរដ្ឋដែលមានស្រាប់ ឬមូលនិធិក្នុងមូលដ្ឋានដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងទាំងនោះឡើយ។

(1) ម្ភៃភាគរយនៃថវិកានៅក្នុងមូលនិធិឆ្លើយតបអគ្គីភ័យរដ្ឋ California ត្រូវលៃបម្រុងឲ្យក្រសួងការពារព្រៃឈើ និងអគ្គីភ័យ ដើម្បីផ្តល់មូលនិធិដល់បុគ្គលិកពន្លត់អគ្គីភ័យ។

(2) ប៉ែតសិបភាគរយនៃថវិកានៅក្នុងមូលនិធិឆ្លើយតបអគ្គីភ័យរដ្ឋ California ត្រូវដាក់នៅក្នុងមូលនិធិឆ្លើយតបអគ្គីភ័យរបស់មណ្ឌលពិសេស ដែលត្រូវបានបង្កើតជាគណនីរងនៅក្នុងមូលនិធិឆ្លើយតបអគ្គីភ័យរដ្ឋ California និងលៃបម្រុងឲ្យមណ្ឌលពិសេសៗដែលផ្តល់ជូនសេវាកម្មការពារអគ្គីភ័យ ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដូចតទៅ៖

(A) ហាសិបភាគរយនៃចំនួនទឹកប្រាក់ដែលមានរៀបរាប់នៅក្នុងកថាខណ្ឌនេះ ត្រូវប្រើប្រាស់ដើម្បីផ្តល់មូលនិធិដល់បុគ្គលិកពន្លត់អគ្គីភ័យនៅក្នុងមណ្ឌលពិសេសដែលខ្វះមូលនិធិ ដែលផ្តល់សេវាកម្មការពារអគ្គីភ័យ ត្រូវបានបង្កើតឡើងក្រោយថ្ងៃទី 1 ខែកក្កដា ឆ្នាំ 1978 និងជួលបុគ្គលិកពេញម៉ោង ឬស្មើនឹងពេញម៉ោងនៅតាមស្ថានីយ ដែលអាចរកបានភ្លាមៗដើម្បីបង្កើតបានជាយ៉ាងហោចណាស់ហាសិបភាគរយនៃកាតព្វកិច្ចអាសន្នពេញលេញដំបូង។

(B) ម្ភៃប្រាំភាគរយនៃចំនួនទឹកប្រាក់ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌនេះ ត្រូវប្រើប្រាស់ដើម្បីផ្តល់មូលនិធិដល់បុគ្គលិកពន្លត់អគ្គីភ័យនៅក្នុងមណ្ឌលពិសេសៗដែលផ្តល់សេវាការពារអគ្គីភ័យត្រូវបានបង្កើតឡើងមុន

19

ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 1978 មានការខ្វះខាតថវិកាដោយសារតែចំណែកទាបមិនស្មើគ្នានៃប្រាក់ចំណូលពន្ធអចលនទ្រព្យ និងកំណើនតម្រូវការកម្រិតសេវាកម្មចាប់តាំងពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 1978 មក និងជួលបុគ្គលិកពេញម៉ោងឬស្មើនឹងពេញម៉ោងនៅតាមស្ថានីយដែលអាចរកបានភ្លាមៗ ដើម្បីបង្កើតបានយ៉ាងតិច 50 ភាគរយនៃកាតព្វកិច្ចអាសន្នពេញលេញដំបូង។

(C) ម្លៃប្រាំភាគរយនៃចំនួនទឹកប្រាក់ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌនេះ ត្រូវប្រើប្រាស់ដើម្បីផ្តល់មូលនិធិដល់បុគ្គលិកពន្លត់អគ្គីភ័យនៅក្នុងមណ្ឌលពិសេសៗដែលមានការខ្វះខាតថវិកា ដែលផ្តល់សេវាកម្មការពារអគ្គីភ័យ និងជួលបុគ្គលិកពេញម៉ោង ឬស្មើនឹងពេញម៉ោងនៅស្ថានីយដែលអាចរកបានភ្លាមៗ ដើម្បីបង្កើតបានយ៉ាងតិច 30 ភាគរយ ប៉ុន្តែតិចជាង 50 ភាគរយនៃកាតព្វកិច្ចអាសន្នពេញលេញដំបូង។

(3) នៅក្នុងការកំណត់ថាតើមណ្ឌលពិសេសដែលផ្តល់សេវាការពារអគ្គីភ័យមានការខ្វះខាតថវិកាសម្រាប់គោលបំណងនៃកថាខណ្ឌ (2) នោះ អង្គនីតិបញ្ញត្តិ ត្រូវពិចារណាទៅលើកត្តាទាំងឡាយខាងក្រោមតាមលំដាប់នៃអាទិភាព៖

(A) កម្រិតដែលប្រាក់ចំណូលពន្ធអចលនទ្រព្យរបស់មណ្ឌលពិសេសមានការខ្វះខាតថវិកាដើម្បីធានានិរន្តរភាពគ្រប់គ្រាន់នៃការពន្លត់អគ្គីភ័យ ដូចដែលបានវាស់វែងធៀបនឹងដង់ស៊ីតេប្រជាជន ទំហំនៃតំបន់សេវា និងចំនួននៃអ្នកបង់ពន្ធនៅក្នុងព្រំដែននៃមណ្ឌលពិសេស។

(B) ក្រោយពីការបង្កើតរួច ថាតើមណ្ឌលពិសេសនោះបានទទួលការលៃបម្រុងពន្ធអចលនទ្រព្យ ដោយអនុលោមតាមជំពូក 282 នៃលក្ខន្តិកៈឆ្នាំ 1979 ដែរឬទេ។

(C) ភាពចម្រុះផ្នែកភូមិសាស្ត្រ។

(4) ការលៃចែកថវិកាទៅឲ្យមណ្ឌលពិសេសដែលមានលក្ខណៈសម្បត្តិអនុលោមតាមកថាខណ្ឌ (2) ត្រូវស្ថិតក្នុងទម្រង់ជាជំនួយ ដែលមានរយៈពេលមិនតិចជាង 10 ឆ្នាំ ដើម្បីធានាថា មណ្ឌលពិសេសនោះអាចចូលរួមនៅក្នុងការផ្តល់ថវិកាប្រកបដោយការទទួលខុសត្រូវ និងធានានិរន្តរភាពនៃសេវាពន្លត់អគ្គីភ័យបានគ្រប់គ្រាន់ក្នុងរយៈពេលវែង។

(g) ទោះបីជាមានផ្នែករង (f) ក៏ដោយ ប្រសិនបើនៅក្នុងឆ្នាំសារពើពន្ធណាមួយ ក្រោយពីឆ្នាំសារពើពន្ធទីមួយ ដែលថវិកាត្រូវបានផ្ទេរចេញពីមូលនិធិទូទៅចូលក្នុងមូលនិធិឆ្លើយតបអគ្គីភ័យរដ្ឋ California ដោយអនុលោមតាមផ្នែកនេះ ចំនួនទឹកប្រាក់ដែលត្រូវបានផ្ទេរលើសពីចំនួនដែលត្រូវបានផ្ទេរក្នុងឆ្នាំសារពើពន្ធមុន 10 ភាគរយនោះ អ្នកត្រួតពិនិត្យមិនត្រូវផ្ទេរចំនួនទឹកប្រាក់លើសពី 10 ភាគរយនោះឡើយ ដែលត្រូវអាចរកបានសម្រាប់ការលៃបម្រុងពីមូលនិធិទូទៅសម្រាប់គោលបំណងណាមួយ។

ទីបួន—ដែលផ្នែកទី 2.3 ត្រូវបានបន្ថែមទៅលើមាត្រា XIII A ដែលចែងថា៖

ផ្នែកទី 2.3. (a) ជារៀងរាល់ឆ្នាំ មុនកាលបរិច្ឆេទដែលបញ្ជាក់ដោយក្រសួងពន្ធដារ និងរដ្ឋបាលប្រាក់កម្រៃ តាមបទបញ្ជាទាំងឡាយដែលត្រូវបានអនុម័តដោយអនុលោមតាមផ្នែកនេះ ខោនធីនីមួយៗត្រូវកំណត់នូវចំណូលសម្រាប់ខោនធី និងសម្រាប់ទីភ្នាក់ងារក្នុងមូលដ្ឋាននីមួយៗនៅក្នុងខោនធី ដែលជាលទ្ធផលនៃការអនុវត្តផ្នែកទី 2.1 ដោយការបន្ថែមចំនួនទឹកប្រាក់ដូចតទៅ៖

(1) កំណើនប្រាក់ចំណូលដែលជាលទ្ធផលនៃការលក់ និងការវាយតម្លៃឡើងវិញទៅលើទីលំនៅចម្បងដើមសម្រាប់ការផ្ទេររវាងខោនធីចេញទៅក្រៅ ដោយអនុលោមតាមផ្នែករង (b) នៃផ្នែកទី 2.1។

(2) ការថយចុះប្រាក់ចំណូល ដែលត្រូវបញ្ជាក់ថាជាចំនួនអវិជ្ជមានដែលជាលទ្ធផលនៃការផ្ទេរតម្លៃជាប់ពន្ធនៃទីលំនៅចម្បងដើម ដែលមានទីតាំងនៅក្នុងខោនធីផ្សេងទៀតទៅកាន់ទីលំនៅចម្បងជំនួសដែលមានទីតាំងនៅក្នុងខោនធីសម្រាប់ការផ្ទេររវាងខោនធីចូលទៅក្នុង ដោយអនុលោមតាមផ្នែករង (b) នៃផ្នែកទី 2.1។

(3) កំណើនប្រាក់ចំណូលដែលជាលទ្ធផលនៃអនុផ្នែក (c) នៃផ្នែកទី 2.1។

(b) ទីភ្នាក់ងារប្រចាំខោនធី ឬទីភ្នាក់ងារក្នុងមូលដ្ឋានណាមួយនៅក្នុងខោនធីដែលមានចំណូលវិជ្ជមាន ដែលត្រូវបានកំណត់ដោយអនុលោមតាមផ្នែករង (a) មិនត្រូវមានសិទ្ធិទទួលបានការសងប្រាក់ពីមូលនិធិការពារប្រាក់ចំណូលខោនធីឡើយ។ ទីភ្នាក់ងារប្រចាំខោនធី ឬទីភ្នាក់ងារក្នុងមូលដ្ឋានណាមួយនៅក្នុងខោនធី ដែលមានចំណូលអវិជ្ជមាន ដែលត្រូវបានកំណត់ដោយអនុលោមតាមផ្នែករង (a) ត្រូវបានចាត់ទុកថាមានសិទ្ធិជាទីភ្នាក់ងារក្នុងស្រុកសម្រាប់ទទួលបានការសងប្រាក់ពីមូលនិធិការពារប្រាក់ចំណូលខោនធី។

(c) ក្រសួងពន្ធដារ និងរដ្ឋបាលប្រាក់កម្រៃនៃរដ្ឋ California ត្រូវកំណត់នូវចំណូលសរុបរបស់ទីភ្នាក់ងារក្នុងមូលដ្ឋានដែលមានសិទ្ធិ រៀងរាល់បីឆ្នាំម្តងដោយផ្អែកទៅលើចំនួនទឹកប្រាក់ដែលបានកំណត់ដោយអនុលោមតាមផ្នែករង (a) សម្រាប់ឆ្នាំនីមួយៗនៃរយៈពេលបីឆ្នាំនោះ និងផ្តល់សំណងជូនទីភ្នាក់ងារក្នុងស្រុកនីមួយៗដែលមានសិទ្ធិទទួលបាន ដែលមានចំណូលអវិជ្ជមានពីថវិកានៅក្នុងមូលនិធិការពារប្រាក់ចំណូលខោនធី ដែលស្មើនឹងចំនួនទឹកប្រាក់នោះ។ ប្រសិនបើមានកង្វះខាតថវិកានៅក្នុងមូលនិធិនោះដើម្បីរ៉ាប់រងទៅលើចំនួនទឹកប្រាក់សរុបនៃការសងប្រាក់ក្រោមផ្នែកនេះនោះ ក្រសួងពន្ធដារ និងរដ្ឋបាលប្រាក់កម្រៃនៃរដ្ឋ California ត្រូវលៃទុកចំណែកតាមសមាមាត្រនៃថវិកានៅក្នុងមូលនិធិទៅឲ្យទីភ្នាក់ងារក្នុងមូលដ្ឋាននីមួយៗដែលមានសិទ្ធិទទួលបាន ដោយផ្អែកលើចំនួនទឹកប្រាក់នៃប្រាក់សំណងសម្រាប់ទីភ្នាក់ងារក្នុងមូលដ្ឋានដែលមានសិទ្ធិ ចំពោះចំនួនទឹកប្រាក់សរុបនៃប្រាក់សំណងក្រោមផ្នែកនេះ។

(d) នៅចុងបញ្ចប់រយៈពេលបីឆ្នាំនីមួយៗនៅក្នុងផ្នែករង (c) បន្ទាប់ពីក្រសួងពន្ធដារនិងរដ្ឋបាលប្រាក់កម្រៃនៃរដ្ឋ California បានសងប្រាក់ដល់ទីភ្នាក់ងារក្នុងមូលដ្ឋាននីមួយៗដែលមានសិទ្ធិ ដែលបានជួបប្រទះចំណូលអវិជ្ជមានអំឡុងពេលបីឆ្នាំហើយនោះ អ្នកត្រួតពិនិត្យត្រូវផ្ទេរសមតុល្យដែលនៅសេសសល់ ប្រសិនបើមាន នៅក្នុងមូលនិធិការពារប្រាក់ចំណូលខោនធី ចូលទៅកាន់មូលនិធិទូទៅដែលអាចរកបានសម្រាប់លៃបម្រុងដើម្បីគោលបំណងណាមួយ។

(e) ក្រសួងពន្ធដារ និងរដ្ឋបាលប្រាក់កម្រៃរដ្ឋ California ត្រូវប្រកាសដាក់ឲ្យប្រើនូវបទបញ្ញត្តិនានាដើម្បីអនុវត្តផ្នែកនេះ ដោយអនុលោមតាមប្រការតាក់តែងច្បាប់នៃក្រមនីតិវិធីរដ្ឋបាល (Administrative Procedure Act) (ជំពូក 3.5 [ចាប់ផ្តើមជាមួយនឹងផ្នែកទី 11340] នៃវគ្គ 1 នៃផ្នែកទី 3 នៃមាតិកា 2 នៃក្រមរដ្ឋាភិបាល) ដែលអាចត្រូវបានធ្វើវិសោធនកម្មទៅតាមពេលវេលាដោយអង្គនីតិបញ្ញត្តិ ឬអ្នកស្នងប្រការទាំងនោះ។

(f) សម្រាប់គោលបំណងនៃផ្នែកនេះ និងផ្នែកទី 2.2 "ទីភ្នាក់ងារក្នុងមូលដ្ឋានដែលមានសិទ្ធិ" គឺជាខោនធីមួយ ទីក្រុងមួយ ទីក្រុងនិងខោនធីមួយ មណ្ឌលពិសេសមួយ ឬមណ្ឌលសាលារៀន ដូចដែលបានកំណត់ដោយអនុលោមតាមផ្នែករង (o) នៃផ្នែកទី 42238.02 នៃច្បាប់ការអប់រំ ដែលបានចែងនៅថ្ងៃទី 8 ខែមករា ឆ្នាំ 2020 ដែលមានចំណូលអវិជ្ជមាន ដូចដែលបានកំណត់ដោយអនុលោមតាមផ្នែកនេះ។

សំណើប្រជាមតិ 20

វិធានការផ្ទួចផ្តើមនេះបានដាក់ជូនប្រជាជន ដោយអនុលោមទៅតាមមាត្រានៃភាគ 8 មាត្រា II នៃធម្មនុញ្ញរដ្ឋ California។

វិធានការផ្ទួចផ្តើមនេះធ្វើវិសោធនកម្ម និងបន្ថែមភាគទៅលើក្រមព្រហ្មទណ្ឌ ហេតុនេះប្រការដែលបាន ស្នើ ឲ្យលុបចោលត្រូវបានបោះពុម្ពជា ~~អក្សរឆ្លូតចោល~~ ហើយប្រការថ្មីដែលត្រូវស្នើឲ្យ ដាក់ បញ្ចូលត្រូវបានបោះពុម្ពជា *ប្រភេទអក្សរទ្រេត* ដើម្បីបង្ហាញថាវាថ្មី។

សំណើច្បាប់

ភាគ 1. ចំណងជើង។

ច្បាប់នេះត្រូវគេស្គាល់និងអាចត្រូវបានយោងទៅថា ច្បាប់កាត់បន្ថយបទល្មើសនិងរក្សារដ្ឋ California ឲ្យមានសុវត្ថិភាពឆ្នាំ 2018 (Reducing Crime and Keeping California Safe Act of 2018)។

ភាគ 2. គោលបំណង។

វិធានការនេះនឹងដោះស្រាយបញ្ហាពាក់ព័ន្ធបី ដែលបានបង្កើតឡើងដោយច្បាប់ថ្មីៗនេះ ដែលបាន គំរាមកំហែងដល់សុវត្ថិភាពសាធារណៈរបស់ពលរដ្ឋ California និងកូនរបស់ពួកគេ ពីឧក្រិដ្ឋជន ហិង្សា។ វិធានការនេះនឹង៖

(a) កែទម្រង់ប្រព័ន្ធដោះលែងក្រៅឃុំ ដោយមានលក្ខខណ្ឌ ដើម្បីជនល្មើសព្រហ្មទណ្ឌ ហិង្សាមិនត្រូវ បានដោះលែងក្រៅឃុំ មុនកំណត់ពីពន្ធនាគារពង្រឹង ការពិនិត្យមើលលើការត្រួតពិនិត្យ ដោយសហគមន៍ ក្រោយពេលដោះលែងក្រៅឃុំ និង រឹតបន្តឹងទោសសម្រាប់ការរំលោភបំពាន លើលក្ខខណ្ឌពេលមានការត្រួតពិនិត្យ ដោយសហគមន៍ ក្រោយពេលដោះលែងក្រៅឃុំ។

(b) កែទម្រង់ច្បាប់ស្តីពីចោរកម្មដើម្បីស្តារទំនួលខុសត្រូវ សម្រាប់ចោរលួចច្រើនដងនិងក្រុមចោរ ដែលមានអង្គការចាត់តាំង និង

(c) ពង្រីកការប្រមូល DNA ពីជនដែលជាប់ទោសគ្រឿងញៀន ចោរកម្ម និង អំពើហិង្សា ក្នុងគ្រួសារ ពាក់ព័ន្ធ នឹងឧក្រិដ្ឋកម្ម ដើម្បីជួយដោះស្រាយបទល្មើស ហិង្សា និងលើកលែងទោសជនគ្មានកំហុស។

ផ្នែក 3. លទ្ធផលរកឃើញ និងការប្រកាស

(a) បង្ការការដោះលែងជនល្មើសបទឧក្រិដ្ឋ នៃទង្វើហិង្សាមុនកំណត់។

(1) ការការពារមនុស្សគ្រប់រូប នៅក្នុងរដ្ឋរបស់យើង រួមទាំងកុមារងាយរងគ្រោះបំផុត ពីបទល្មើស ហិង្សាគឺជាកិច្ចការដ៏សំខាន់បំផុត។ ឃាតករ អ្នកចាប់រំលោភ អ្នកបៀតបៀនកុមារ និង ជនល្មើសហិង្សាផ្សេងទៀត មិនគួរត្រូវបានដោះលែង មុនកំណត់ពីពន្ធនាគារទេ។

(2) តាំងពីឆ្នាំ 2014 មករដ្ឋ California មានការកើនឡើងនៃបទល្មើសហិង្សាច្រើនជាង រដ្ឋផ្សេងៗទៀត នៅសហរដ្ឋអាមេរិក។ តាំងពីឆ្នាំ 2013 មកបទល្មើសហិង្សានៅ Los Angeles បានកើតឡើង 69.5% ។ បទល្មើសហិង្សា នៅ Sacramento បានកើនឡើងក្នុងរយៈពេលប្រាំមួយខែ ដំបូងនៃឆ្នាំ 2015 លឿនជាងទីក្រុងអាមេរិកធំបំផុតទាំង 25 ដែលត្រូវបានតាមដានដោយ FBI ។

(3) ការផ្លាស់ប្តូរថ្មីៗនេះលើច្បាប់ដោះលែង ដោយមានលក្ខខណ្ឌបានអនុញ្ញាតឲ្យមាន ការដោះលែង មុនកំណត់នៃជនល្មើសគ្រោះថ្នាក់ ដោយសារតែភាពបរាជ័យរបស់ច្បាប់ ក្នុងការកំណត់និយមន័យ បទល្មើសមួយចំនួនថាជាអំពើ "ហិង្សា។" ការផ្លាស់ប្តូរទាំងនេះអនុញ្ញាតឲ្យបុគ្គល ដែលជាប់ទោសពីបទជួញដូរផ្លូវភេទកុមារ ការរំលោភមនុស្ស ដែលមិនដឹងខ្លួន បទឧក្រិដ្ឋ វាយប្រហារដោយអាវុធពិឃាត ការតដៃ មកលើមន្ត្រីប៉ូលិស ឬអ្នកពន្លត់ អគ្គិភ័យ និងបទឧក្រិដ្ឋអំពើហិង្សា ក្នុងគ្រួសារត្រូវបានចាត់ទុកជា "ជនល្មើសអហិង្សា។"

(4) ជាលទ្ធផលជនល្មើសដែលគេហៅថា "អហិង្សា" ទាំងនេះ មាន លក្ខណៈសម្បត្តិទទួលបានការ ដោះលែងមុនកំណត់ពីពន្ធនាគារ ដោយគ្រាន់តែជាប់ពន្ធនាគារមួយភាគនៃទោស ដែលបានសម្រេច ដោយចៅក្រម។

(5) ជនល្មើសហិង្សាក៏កំពុងត្រូវបានអនុញ្ញាតឲ្យមានសេរីភាព នៅក្នុងសហគមន៍របស់យើង ទោះបីជា នៅពេលពួកគេប្រព្រឹត្តបទល្មើសថ្មី និងបំពានលើលក្ខខណ្ឌនៃការត្រួតពិនិត្យ ដោយសហគមន៍ ក្រោយ ពេលដោះលែងរបស់ពួកគេក៏ដោយ ដូចជាសមាជិកជើងកាងដែលត្រូវបានចោទប្រកាន់ពីបទ ឃាតកម្មលើមន្ត្រីប៉ូលិសឈ្មោះ Keith Boyer នៃទីក្រុង Whittier។

(6) ពលរដ្ឋ California ត្រូវការការពារល្អជាងនេះពីជនល្មើសហិង្សាបែបនោះ។

(7) ពលរដ្ឋ California ត្រូវការការពារកាន់តែល្អប្រសើរពី ឧក្រិដ្ឋជនដែលរំលោភបំពាន ម្តងហើយម្តងទៀតលើលក្ខខណ្ឌ នៃការពិនិត្យមើលដោយសហគមន៍ ក្រោយពេលដោះលែងរបស់ពួកគេ។

(8) វិធានការនេះកែទម្រង់ច្បាប់ ដើម្បីឲ្យឧក្រិដ្ឋជនដែលរំលោភបំពានលើលក្ខខណ្ឌនៃការដោះលែង អាចត្រូវបាននាំត្រឡប់មកតុលាការវិញ និងទទួលខុសត្រូវចំពោះការរំលោភបំពានដូច្នោះ។

(9) ពលរដ្ឋ California ត្រូវការការពារល្អជាងនេះពីជនល្មើសហិង្សាបែបនោះ។ វិធានការនេះកែទម្រង់ច្បាប់ ដើម្បីកំណត់និយមន័យលើបទល្មើសទាំងនោះថាជា "បទឧក្រិដ្ឋហិង្សា" ក្នុងគោលបំណងនៃការដោះលែងមុនកំណត់។

(10) មិនមានអ្វីមួយនៅក្នុងច្បាប់នេះមានចេតនា បង្កើតបទល្មើស "វាយប្រហារ" បន្ថែមដែលនឹង បង្កើនចំនួនមនុស្សនៅក្នុងពន្ធនាគាររដ្ឋទេ។

(11) មិនមានអ្វីមួយនៅក្នុងច្បាប់នេះមានចេតនាធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពរបស់នាយកដ្ឋានអប់រំ កែប្រែនិងស្តារនីតិសម្បទាររដ្ឋ California ក្នុងការផ្តល់កិត្តិយសការអប់រំ និងស្នាដៃទេ។

(b) ស្តារឡើងវិញទំនួលខុសត្រូវសម្រាប់ការលួចច្រើនលើកច្រើនសារ និង ក្រុមចោរដែលមានអង្គការចាត់តាំង។

(1) ការផ្លាស់ប្តូរថ្មីៗនេះទៅលើច្បាប់នៃរដ្ឋ California អនុញ្ញាតឲ្យបុគ្គលដែលលួចច្រើនលើកច្រើន សារ ប្រឈមមុខនឹងផលវិបាកមួយចំនួនតូច ដោយមិនគិតអំពីប្រវត្តិបទល្មើសរបស់ពួកគេ ឬ ថាតើពួកគេបានលួចប៉ុន្មានដងហើយទេ។

(2) ជាលទ្ធផលនៅចន្លោះឆ្នាំ 2014 និង 2016 រដ្ឋ California មានការកើនឡើងខ្ពស់បំផុតទីពីរ ក្នុង ករណីចោរកម្មនិងបទល្មើសលើអចលនទ្រព្យ នៅក្នុងសហរដ្ឋអាមេរិកក្នុងពេល ដែលរដ្ឋភាគច្រើនមានការថយចុះជាលំដាប់។ យោងតាមក្រសួងយុត្តិធម៌នៃរដ្ឋ California តម្លៃនៃទ្រព្យសម្បត្តិដែលត្រូវបានលួចកាល ពីឆ្នាំ 2015 មានចំនួន $2.5 ពាន់លាន ហើយបានកើនឡើង 13 ភាគរយតាំងពីឆ្នាំ 2014 ដែលជាការកើនឡើងខ្ពស់ បំផុតក្នុងមួយឆ្នាំ ក្នុងរយៈពេលយ៉ាងតិច 10 ឆ្នាំ។

(3) បុគ្គលដែលលួចច្រើនលើកច្រើនសារ តែងធ្វើដូច្នោះដើម្បី គាំទ្រដល់ ទម្លាប់ ប្រើប្រាស់ គ្រឿង ញៀន របស់ ពួកគេ។ ការផ្លាស់ប្តូរថ្មីៗនេះនៅលើច្បាប់នៃរដ្ឋ California បានកាត់បន្ថយសមត្ថភាពចៅក្រម ក្នុងការចេញ ដីការឲ្យជនជាប់ទោសបទល្មើស ចោរកម្មម្តងហើយម្តងទៀតចូលក្នុងកម្មវិធីព្យាបាលគ្រឿងញៀន ដែលមានប្រសិទ្ធភាព។

(4) រដ្ឋ California ត្រូវការច្បាប់ដែលកាន់តែរឹងមាំ សម្រាប់អ្នកដែលមិនរាងចាល នឹងទោសពីបទល្មើសចោរកម្ម ដែលនឹងលើកទឹកចិត្តឲ្យអ្នកលួចច្រើនលើកច្រើនសារ ដើម្បីគាំទ្រដល់ការប្រើប្រាស់គ្រឿងញៀនចូលមក ក្នុងកម្មវិធីបន្សាបគ្រឿងញៀនដែលមានស្រាប់។ វិធានការនេះអនុម័តលើកំណែទម្រង់ដូច្នោះ។

(c) ស្តារកម្មវិធីប្រមូល DNA ដើម្បីដោះស្រាយបទល្មើសហិង្សា។

(1) ការប្រមូល DNA ពីឧក្រិដ្ឋជនគឺជាការចាំបាច់ ចំពោះការដោះស្រាយឧក្រិដ្ឋកម្មហិង្សា។ ឧក្រិដ្ឋកម្មហិង្សាជាង 450 ករណី រួមមានឃាតកម្ម

20

ការរំលោភសេពសន្ថវៈ និងការប្លន់ មិនបាន ដោះស្រាយរួចរាល់ទេ ដោយសារ DNA កំពុងត្រូវបានប្រមូលយកពីឧក្រិដ្ឋជនចំនួនតិច។

(2) DNA ដែលបានប្រមូលកាលពីឆ្នាំ 2015 ពីទណ្ឌិតបៀតបៀនកុមារ បានដោះស្រាយករណីរំលោភ សំលាប់ក្មេងប្រុសអាយុប្រាំមួយឆ្នាំពីរនាក់ ដែលបានកើតឡើងកាលពីបីទសវត្ស៍កន្លងទៅ នៅខោនធី Los Angeles ។ DNA ដែលបានប្រមូលកាលពីឆ្នាំ 2016 ពីបុគ្គលម្នាក់ ដែលត្រូវបាន ចាប់ខ្លួននៅពេលកំពុងបើកបរ រថយន្តលួច បានដោះស្រាយ ឃាតកម្ម រំលោភនៅតំបន់ ឈូងសមុទ្រ San Francisco កាលពីឆ្នាំ 2012 លើស្ត្រី អាយុ 83 ឆ្នាំ។

(3) ការផ្លាស់ប្តូរថ្មីៗនេះលើច្បាប់នៃរដ្ឋ California បានលុបបំបាត់ ដោយអចេតនាលើ ការប្រមូល DNA សម្រាប់ករណីចោរកម្ម និង ឧក្រិដ្ឋ កម្មគ្រឿងញៀន។ វិធានការនេះស្តារឡើងវិញ ការប្រមូល DNA ពីទណ្ឌិត នៃបទល្មើសបែបនោះ។

(4) ការអនុញ្ញាតឲ្យប្រមូលយកសំណាក DNA ថែមទៀត នឹង ជួយ កំណត់អត្តសញ្ញាណជនសង្ស័យ ជម្រះជនគ្មានទោសចេញ និង ដោះលែងជន ដែលត្រូវបានកាត់ទោសខុស។

(5) វិធានការនេះមិនប៉ះពាល់ដល់ការការពារផ្លូវច្បាប់ ដែលមានស្រាប់ ដែលការពារឯកជនភាពរបស់ បុគ្គល ដោយការអនុញ្ញាតការយកចេញ នូវ ព័ត៌មាន DNA របស់ពួកគេទេ ប្រសិនបើពួកគេមិន ជាប់ចោទ ពីបទឧក្រិដ្ឋ កម្ម ឬ ត្រូវបានសម្រេចឲ្យរួចទោស ឬ ត្រូវបានរកឃើញថាគ្មានទោស។

ផ្នែក 4. ការពិចារណា អំពីការដោះលែងដោយមានលក្ខខណ្ឌ។

ផ្នែគ 4.1. ផ្នែក 3003 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្ម ដែលមានខ្លឹមសារដូចខាងក្រោម៖

3003. (a) លើកលែងតែមានផ្តល់ផ្ទុយពីនេះ នៅក្នុងភាគនេះជន ជាប់ឃុំដែលត្រូវបានដោះលែង ដោយមានលក្ខខណ្ឌ ឬការត្រួតពិនិត្យ ដោយសហគមន៍ ក្រោយពេលដោះលែងដូចមានកំណត់ នៅក្នុង ចំណងជើង 2.05 (ចាប់ផ្តើមជាមួយនឹងភាគ 3450) ត្រូវត្រឡប់ទៅខោន ធី ដែលជាកន្លែងស្នាក់នៅ ស្របច្បាប់ចុងក្រោយ មុនពេលការជាប់ឃុំរបស់ ជនជាប់ឃុំនោះ។ ជនជាប់ឃុំដែលត្រូវបានដោះលែង ដោយមានលក្ខខណ្ឌ ឬ នៅក្រោមការត្រួតពិនិត្យដោយសហគមន៍ ក្រោយពេលដោះលែងដូច មានចែង នៅក្នុងចំណងជើង 2.05 (ចាប់ផ្តើមជាមួយនឹងភាគ 3450) និងអ្នក ដែលត្រូវបានដាក់ឲ្យជាប់ពន្ធនាគារ ពីបទល្មើសផ្លូវភេទ ដែល ត្រូវមានការចុះឈ្មោះអនុលោមតាម ភាគ 290 ត្រូវព្យាយាមឲ្យអស់ពី សមត្ថភាព ដើម្បីយកត្រឡប់មកក្រុងវិញ ដែលជាលំនៅដ្ឋានស្របច្បាប់ ចុងក្រោយរបស់ជនជាប់ឃុំនោះ មុនពេលដាក់ឲ្យជាប់ឃុំ ឬនៅក្នុងទីតាំងភូមិ សាស្ត្រជិតនឹងគ្រួសារ ចំណងសង្គម ឬចំណងសេដ្ឋកិច្ច និង លទ្ធភាពទទួល បានការផ្តល់សេវាកម្មឡើងវិញ លើកលែងតែការ ត្រឡប់ទៅទីតាំង នោះនឹងរំលោភបំពានលើច្បាប់ផ្សេងទៀត ឬ បង្កឲ្យមានហានិភ័យចំពោះជន រង គ្រោះដោយជនជាប់ឃុំនោះ។ សម្រាប់គោលបំណងនៃអនុផ្នែកនេះ ពាក្យថា “លំនៅដ្ឋានស្របច្បាប់ចុងក្រោយ” មិនត្រូវចាត់ទុកថាជា ខោនធី ឬ ក្រុងដែលជនជាប់ឃុំបានប្រព្រឹត្តបទល្មើសទេ នៅពេលកំពុងជាប់ឃុំនៅក្នុង ពន្ធនាគារ ប្រចាំ រដ្ឋឬកន្លែងឃុំឃាំងក្នុងមូលដ្ឋាន ឬនៅពេលកំពុងជាប់ឃុំ សម្រាប់ការព្យាបាល នៅក្នុងមន្ទីរពេទ្យប្រចាំ រដ្ឋ។

(b) ទោះបីជាមានអនុផ្នែក (a), ជនជាប់ឃុំអាចត្រូវបានយកប្រគល់ទៅ ខោនធី ឬ ក្រុងមួយទៀត ប្រសិនបើវានឹងនាំមកនូវឧត្តម ប្រយោជន៍ដល់ សាធារណជន។ ប្រសិនបើក្រុមប្រឹក្សាសវនការដោះលែង ដោយមាន លក្ខខណ្ឌដែលធ្វើការកំណត់លក្ខខណ្ឌនៃការ ដោះលែងជនជាប់ឃុំ ដែល បានកាត់ទោសរួចតាមអនុផ្នែក (b) នៃផ្នែក 1168 ដូចបានកំណត់ដោយ គណៈកម្មការពិចារណាការដោះលែង ដោយមានលក្ខខណ្ឌ ឬនាយកដ្ឋាន អប់រំកែប្រែនិង ស្តារនីតិសម្បទារ ដែលធ្វើការកំណត់លក្ខខណ្ឌ នៃការ ដោះលែងសម្រាប់ជនជាប់ឃុំ ដែលបានកាត់ទោសរួច តាមភាគ 1170 សម្រេចថាបញ្ជូនទៅខោនធី ឬ ក្រុងមួយទៀតគណៈកម្មការត្រូវពន្យល់ មូលហេតុ ជាលាយលក្ខណ៍អក្សរ នៅលើកំណត់ហេតុអចិន្ត្រៃយ៍របស់ជន ដែលត្រូវដោះលែងដោយ មានលក្ខខណ្ឌនោះ ហើយត្រូវរៀបរាប់មូលហេតុ ទាំងនោះ នៅក្នុងសេចក្តីជូនដំណឹងទៅប៉ូលិស ឬ នាយ ប៉ូលិសស្របតាម ភាគ 3058.6 ។ នៅក្នុងការធ្វើការសម្រេចចិត្ត អាជ្ញាធរដោះលែង ដោយមានលក្ខខណ្ឌ ត្រូវពិចារណាក្នុងចំណោមអ្នកដទៃទៀត នូវកត្តា ខាងក្រោមដោយផ្តល់ទម្ងន់ខ្លាំងបំផុត ទៅលើ ការការពារជនរងគ្រោះ និង សុវត្ថិភាពរបស់សហគមន៍៖

(1) សេចក្តីត្រូវការ ដើម្បីការពារជីវិត ឬ សុវត្ថិភាពរបស់ជនរងគ្រោះ អ្នកទទួលការដោះលែង សាក្សី ឬ អ្នកផ្សេងទៀត។

(2) កង្វល់សាធារណៈដែលនឹងកាត់បន្ថយឱកាស ដែលការដោះលែង ដោយមានលក្ខខណ្ឌ នៃ ជនជាប់ឃុំនោះអាចបញ្ចប់ដោយជោគជ័យ។

(3) ការផ្តល់ជូនការងារដែលបានផ្ទៀងផ្ទាត់រួច ឬកម្មវិធីអប់រំ ឬ បណ្តុះបណ្តាលវិជ្ជាជីវៈ។

(4) វត្តមាននៃគ្រួសារនៅក្នុងខោនធីមួយទៀត ដែលជនជាប់ឃុំមាន ចំណងរឹងមាំជាមួយ និងដែល មានការគាំទ្រពីពួកគេនឹងបង្កើនឱកាសឲ្យ ការដោះលែង នឹង បញ្ចប់ដោយជោគជ័យ។

(5) កង្វះកម្មវិធីព្យាបាលអ្នកជំងឺក្រៅដែលចាំបាច់ សម្រាប់ជនដោះលែងក្រៅ ឃុំដោយមានលក្ខខណ្ឌ ដើម្បីទទួលបានការព្យាបាលតាមភាគ 2960 ។

(c) នាយកដ្ឋានអប់រំកែប្រែ និងស្តារនីតិសម្បទារ ដោយមានការកំណត់ ការប្តេជ្ញាចិត្ត ពីខាងក្រៅ ខោនធីត្រូវផ្តល់អាទិភាព ចំពោះសុវត្ថិភាព សហគមន៍ព្រមទាំងសាក្សីនិងជនរងគ្រោះ។

(d) ក្នុងការធ្វើការសម្រេចចិត្តរបស់ខ្លួន អំពីជនជាប់ឃុំ ដែលបានចូលរួមក្នុងកម្មវិធី បុត្រសម្ព័ន្ធ តាមមាត្រា 1.5 (ចាប់ផ្តើម ជាមួយនឹងភាគ 2717.1) នៃជំពូក 5, អាជ្ញាធរដោះលែងក្រៅឃុំ ដោយមាន លក្ខខណ្ឌត្រូវពិចារណា យ៉ាងម៉ឺងម៉ាត់ចំពោះការដោះលែង ជនជាប់ឃុំទៅក្នុងខោនធី ដែលនិយោជក កម្មវិធីបុត្រសម្ព័ន្ធស្ថិតនៅ ប្រសិនបើនិយោជកនោះអះអាងទៅអាជ្ញាធរដោះលែង ដោយមាន លក្ខខណ្ឌថា និយោជកមានចេតនាជួលជន ជាប់ឃុំនៅពេលដោះលែង។

(e) (1) ព័ត៌មានខាងក្រោមប្រសិនបើមានត្រូវផ្សព្វផ្សាយ ដោយ នាយកដ្ឋានអប់រំកែប្រែ និង ស្តារ នីតិសម្បទារទៅទីភ្នាក់ងារអនុវត្តច្បាប់ ក្នុងមូលដ្ឋានពាក់ព័ន្ធ នឹងជនជាប់ឃុំដែលត្រូវបានដោះលែង ដោយមាន លក្ខខណ្ឌ ឬ ជនជាប់ឃុំ ដែលត្រូវបានដាក់នៅក្រោមការត្រួតពិនិត្យ ដោយសហគមន៍ ក្រោយការដោះលែងតាមការទាមទារលេខ 2.05 (ចាប់ផ្តើមជាមួយនឹងភាគ 3450) ដែលត្រូវបាន ដោះលែងនៅក្នុង យុត្តាធិការរបស់ពួកគេ៖

(A) នាមត្រកូល នាមខ្លួន និងនាមកណ្តាល។

(B) ថ្ងៃខែឆ្នាំកំណើត។

(C) ភេទជាតិសាសន៍ កម្ពស់ ទម្ងន់ និង ពណ៌សក់ និង ភ្នែក។

(D) កាលបរិច្ឆេទនៃការដោះលែង ដោយមានលក្ខខណ្ឌ ឬ ការដាក់នៅ ក្រោមការត្រួតពិនិត្យដោយ សហគមន៍ ក្រោយពេលដោះលែងនិងការឲ្យ ចេញពីកន្លែងឃុំ។

(E) ការចុះបញ្ជី អំពីស្ថានភាព ប្រសិនបើជនជាប់ឃុំត្រូវចុះឈ្មោះ ដោយសារ ប្រើប្រាស់សារធាតុ ដែលត្រូវគ្រប់គ្រងភេទ ឬ បទល្មើសនៃ ការបង្ករអគ្គិភ័យ។

(F) លេខព័ត៌មានថ្កោលទោសប្រចាំរដ្ឋ California, លេខ FBI, លេខ សន្តិសុខសង្គម, និងលេខបណ្ណ បើកបរ។

(G) ខោនធីដែលបានប្តេជ្ញាចិត្ត។

(H) បរិយាយអំពីស្លាកស្នាមសញ្ញា និង ស្នាមសាក់នៅលើជនជាប់ឃុំ។

20

(I) បទល្មើសដែលបានចោទឲ្យជាប់ទោស សម្រាប់ជនជាប់ឃុំដែលនាំឲ្យមានការដោះលែង ដោយ មានលក្ខខណ្ឌ ឬការត្រួតពិនិត្យដោយសហគមន៍ ក្រោយពេលដោះលែង នៅក្នុងស្ថានភាពនេះ។

(J) អាសយដ្ឋានរួមទាំងព័ត៌មានទាំងអស់ ដូចខាងក្រោម៖

(i) ឈ្មោះនិងលេខផ្លូវ។ លេខប្រអប់ប្រៃសណីយមិនអាចទទួលយកទេ សម្រាប់គោលបំណងនៃអនុកថាខណ្ឌនេះ។

(ii) ក្រុង និងលេខហ្ស៊ីបកូដ។

(iii) កាលបរិច្ឆេទដែលផ្តល់អាសយដ្ឋាន តាមអនុកថាខណ្ឌនេះត្រូវបានស្នើឲ្យមានប្រសិទ្ធភាព។

(K) មន្ត្រី និងអង្គភាពទំនាក់ទំនង រួមមានព័ត៌មានទាំងអស់ដូចខាងក្រោម៖

(i) ឈ្មោះ និងលេខទូរសព្ទរបស់មន្ត្រីទំនាក់ទំនងម្នាក់ៗ។

(ii) ប្រភេទអង្គភាពទំនាក់ទំនងរបស់មន្ត្រីទំនាក់ទំនងម្នាក់ៗ ដូចជាអង្គភាពទទួលខុសត្រូវលើ ការដោះលែងដោយមានលក្ខខណ្ឌការចុះបញ្ជី ឬ ការដោះលែងសាកល្បងប្រចាំខោនធី។

(L) រូបថតរចនាដោយឌីជីថលនិងយ៉ាងហោចណាស់ ស្នាមក្រយៅដៃឌីជីថលមួយរបស់ជន ដែលត្រូវ ដោះលែងដោយមានលក្ខខណ្ឌ។

(M) កូអរដោនេភូមិសាស្ត្រសម្រាប់ទីតាំងលំនៅដ្ឋានរបស់ជនជាប់ឃុំ សម្រាប់ប្រើប្រាស់ជាមួយប្រព័ន្ធ ព័ត៌មានភូមិសាស្ត្រ (GIS) ឬ កម្មវិធីកុំព្យូទ័រដែលអាចប្រៀបធៀបបាន។

(N) សេចក្ដីចម្លងនៃកំណត់ហេតុត្រួតពិនិត្យ ក្នុងរយៈពេលមុនដោះលែងដោយមានលក្ខខណ្ឌ។

(2) លើកលែងតែមិនអាចរកព័ត៌មានបាន នាយកដ្ឋានអប់រំកែប្រែនិងស្តារនីតិសម្បទារ ត្រូវបញ្ជូនតាម ប្រព័ន្ធអេឡិចត្រូនិកទៅទីភ្នាក់ងារ ប្រចាំខោនធីដែលបានកំណត់នៅក្នុងអនុផ្នែក (a) នៃ ភាគ 3451 នូវស្ថានភាពជំងឺរបេង តម្រូវការព្យាបាលជាក់លាក់សុខភាពផ្លូវចិត្ត និងការព្យាបាលជំងឺក្រៅ ព្រមទាំងកង្វល់វេជ្ជសាស្ត្រ ឬ ពិការភាពណាមួយសម្រាប់ខោនធី ដែលត្រូវពិចារណា នៅពេលដែល ជនល្មើសផ្លាស់ទីចូល ទៅក្នុងការត្រួតពិនិត្យដោយសហគមន៍ ក្រោយពេលដោះលែងតាមភាគ 3450 សម្រាប់គោលបំណងនៃការកំណត់ អត្តសញ្ញាណតម្រូវការព្យាបាល និងសុខភាពផ្លូវចិត្តរបស់បុគ្គលនោះ។ រាល់ការបញ្ជូនទៅទីភ្នាក់ងារប្រចាំខោនធីត្រូវអនុលោម តាមប្រការជាធរមាននៃច្បាប់ស្តីពីការចល័ត និងទំនួលខុសត្រូវផ្នែកធានារ៉ាប់រងសុខភាពសហព័ន្ធឆ្នាំ 1996 (Health Insurance Portability and Accountability Act of 1996, HIPAA) (ច្បាប់សាធារណៈ 104-191) ច្បាប់សហព័ន្ធ ស្តីពីបច្ចេកវិទ្យាព័ត៌មានសុខភាពសម្រាប់សុខាភិបាល សេដ្ឋកិច្ច និង ព្យាបាល (Health Information Technology for Economic and Clinical Health Act, HITECH) (ច្បាប់សាធារណៈ 111-005), និងការអនុវត្តបទបញ្ញត្តិ ស្តីពីឯកជនភាពនិងសន្តិសុខ នៅក្នុង ចំណែក 160 និង 164 នៃ ចំណងជើង 45 នៃក្រមនៃបញ្ញត្តិសហព័ន្ធ។ កថាខណ្ឌនេះមិនត្រូវ ចូលជាធរមានទេ រហូតទាល់តែរដ្ឋមន្ត្រីក្រសួងសុខាភិបាល និង សេវាកម្ម មនុស្ស របស់សហរដ្ឋអាមេរិក ឬអ្នកដែលទទួលការចាត់តាំងជំនួសរដ្ឋមន្ត្រី កំណត់ថា ប្រការនេះមិនត្រូវបាន ប្រគល់សិទ្ធិជាមុនដោយ HIPAA ។

(3) លើកលែងតែព័ត៌មានដែលទាមទារដោយកថាខណ្ឌ (2) ព័ត៌មានដែលទាមទារដោយអនុផ្នែកនេះ ត្រូវមកពីមូលដ្ឋានទិន្នន័យរបស់ជនដែលត្រូវដោះលែងដោយមានលក្ខខណ្ឌប្រចាំរដ្ឋ។ ព័ត៌មានដែលទទួលបានពីប្រភព នីមួយៗត្រូវអាស្រ័យលើរយៈពេលដូចគ្នា។

(4) រាល់ព័ត៌មានដែលទាមទារដោយអនុផ្នែកនេះ ត្រូវបានផ្តល់មកដោយប្រើប្រាស់ការផ្ទេរពីកុំព្យូទ័រ ទៅកុំព្យូទ័រ ក្នុងទម្រង់ដែលអាចប្រើប្រាស់បាន ដោយប្រព័ន្ធកុំព្យូទ័រដេសថប។ ការផ្ទេរព័ត៌មាននេះ ត្រូវអាចប្រើប្រាស់បានជា បន្តបន្ទាប់ដោយទីភ្នាក់ងារអនុវត្តច្បាប់ ក្នុងមូលដ្ឋានតាម សំណើ។

(5) ការផ្សព្វផ្សាយ ឬ ការទទួលព័ត៌មានដោយមិនមានការអនុញ្ញាតដូចមានចែង ក្នុងអនុផ្នែកនេះគឺជា ការបំពានលើភាគ 11143 ។

(f) ទោះជាមានច្បាប់ផ្សេងទៀតក៏ដោយ ប្រសិនបើជនរងគ្រោះ ឬ សាក្សីស្នើសុំចម្ងាយបន្ថែមនៅក្នុង ការដាក់ជនជាប់ឃុំ ដែលត្រូវដោះលែងដោយមានលក្ខខណ្ឌហើយ ប្រសិនបើគណៈកម្មការសវនាការ ដោះលែងដោយមានលក្ខខណ្ឌ ឬ នាយកដ្ឋា អប់រំកែប្រែ និង ស្តារនីតិសម្បទាររកឃើញថា មាន តម្រូវការក្នុងការការពារជីវិតសុវត្ថិភាព ឬ សុខុមាលភាពរបស់ជនរងគ្រោះ ឬ សាក្សីជនជាប់ឃុំ ដែល ត្រូវបានដោះលែងដោយមានលក្ខខណ្ឌ មិនអាចត្រឡប់ទៅទីតាំងដែលមានចម្ងាយតិចជាង 35 ម៉ាយពី លំនៅដ្ឋានជាក់ស្តែងរបស់ជនរងគ្រោះ ឬសាក្សីបានទេ សម្រាប់បទល្មើសណាមួយខាងក្រោម៖

(1) បទព្រហ្មទណ្ឌហិង្សាដូចមានកំណត់និយមន័យ នៅក្នុង ~~កថាខណ្ឌ (1) ទៅ (7) រួមទាំងនិង (11) និង (16) នៃ~~ អនុផ្នែក (c) នៃភាគ 667.5 *ឬ អនុផ្នែក (a) នៃភាគ 3040.1*។

(2) បទព្រហ្មទណ្ឌដែលចុងចោទបង្ករបួសខ្លាំងលើរាងកាយរបស់មនុស្សម្នាក់ ក្រៅពីជាអ្នកចូលដៃ ដែលត្រូវបានចោទនិងមានភស្តុតាងដូចមានចែងនៅក្នុងភាគ 12022.53, 12022.7, ឬ 12022.9។

(3) ការរំលោភបំពានលើកថាខណ្ឌ (1), (3), ឬ (4) នៃអនុផ្នែក (a) នៃ ភាគ 261, អនុផ្នែក (f), (g), ឬ (i) នៃភាគ 286, អនុផ្នែក (f), (g), ឬ (i) នៃភាគ 287 ឬ នៃអតីតភាគ 288a, ឬ អនុផ្នែក (b), (d), ឬ (e) នៃភាគ 289។

(g) ទោះបីជាមានច្បាប់ផ្សេងៗក៏ដោយជនជាប់ឃុំ ដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ សម្រាប់ការរំលោភបំពានលើភាគ 288 ឬ 288.5 ដែល នាយកដ្ឋានអប់រំកែប្រែ និង ស្តារនីតិសម្បទារ កំណត់ថាបង្កហានិភ័យខ្ពស់ ដល់សារធារណជនមិត្រូវដាក់ ឬឲ្យរស់នៅក្នុង ចម្ងាយមួយម៉ាយកន្លះ ពីសាលារៀនរដ្ឋ ឬឯកជន រួមមាន ទាំង សាលាមត្តេយ្យ និងពីថ្នាក់ទី 1 ដល់ទី 12 ឡើយ ក្នុងពេលដោះ លែងដោយ មានលក្ខខណ្ឌ។

(h) ទោះបីជាមានច្បាប់ផ្សេងៗក៏ដោយជនជាប់ឃុំដែល បានត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ឬការត្រួតពិនិត្យដោយសហគមន៍ ក្រោយពីការដោះលែងដោយសារការល្មើសនៃការរំលោភបំពាន មិនត្រូវបានបញ្ជូនទៅទីកន្លែង ដែលមានចម្ងាយតិចជាង 35 ម៉ាយ ពីទីលំនៅជាក់ស្តែងរបស់ជនរងគ្រោះ ឬសាក្សី ឬទីកន្លែងធ្វើការឡើយ ប្រសិនបើជនរងគ្រោះ ឬ សាក្សីបានស្នើសុំចម្ងាយ បន្ថែមទៀតក្នុងការដាក់ជនដែលត្រូវដោះលែងមានលក្ខខណ្ឌ ឬការត្រួតពិនិត្យដោយសហគមន៍ ក្រោយពេលដោះលែង និងប្រសិនបើគណៈកម្មការសវនការដោះលែងដោយមានលក្ខខណ្ឌ ឬនាយកដ្ឋានអប់រំកែប្រែនិងស្តារនីតិសម្បទារ ឬ ទីភ្នាក់ងារត្រួតពិនិត្យប្រចាំខោនធីយល់ឃើញថា មានតម្រូវការសម្រាប់ការពារអាយុ ជីវិត សុវត្ថិភាព ឬសុខុមាលភាពរបស់ជនរងគ្រោះ។ ប្រសិនបើជនជាប់ឃុំដែលត្រូវបានដោះលែង ដោយមានការត្រួតពិនិត្យដោយសហគមន៍ មិនអាច ត្រូវបានដាក់ក្នុងខោនធីដែល ជាទីលំនៅ ស្របច្បាប់ចុងក្រោយរបស់ជនជាប់ឃុំ ដោយអនុលោម តាមអនុផ្នែកនេះទេ ទីភ្នាក់ងារត្រួតពិនិត្យប្រចាំខោនធី អាចផ្ទេរជនជាប់ឃុំនោះទៅខោនធីផ្សេងទៀតបាន ប្រសិនបើមានការអនុញ្ញាតពីខោនធីដែលត្រូវទទួល។

(i) អាជ្ញាធរត្រូវផ្តល់ការពិចារណាដល់ការបែងចែក ប្រកបដោយសមធម៌ នៃជនដែលត្រូវដោះលែង ដោយមានលក្ខខណ្ឌ និងសមាមាត្រនៃការ ប្តេជ្ញាចិត្តពីខាងក្រៅខោនធីមកពី ខោនធីមួយធៀប នឹងចំនួន នៃការ

20

ប្តេជ្ញាចិត្តពីខោនធីនោះ នៅពេលធ្វើការសម្រេចចិត្ត ចំពោះការដោះលែង ដោយមានលក្ខខណ្ឌ។

(j) ជនជាប់ឃុំអាចនឹងត្រូវបានដោះលែង ដោយមានលក្ខខណ្ឌទៅរដ្ឋផ្សេងទៀត ដោយយោងទៅតាម ច្បាប់ផ្សេងទៀត។ នាយកដ្ឋានអប់រំ កែប្រែ និងស្តារនីតិសម្បទារត្រូវសម្របសម្រួល ជាមួយអង្គភាពក្នុងមូលដ្ឋានទាក់ទង នឹងការដាក់ជនជាប់ឃុំ នៅក្រៅរដ្ឋអំពីការត្រួតពិនិត្យ ដោយសហគមន៍ បន្ទាប់ពីការដោះលែង ដោយស្របតាមចំណងជើង 2.05 (ចាប់ផ្តើមជាមួយភាគ 3450)។

(k) (1) លើកលែងតែមានផ្តល់នៅក្នុងកថាខណ្ឌ (2) នាយកដ្ឋានអប់រំ កែប្រែ និង ស្តារនីតិសម្បទារ ត្រូវតែជាភ្នាក់ងារដែលទទួលខុសត្រូវ ជាចម្បង និងមានការគ្រប់គ្រងលើកម្មវិធីធនធាន និងបុគ្គលិកក្នុងការអនុវត្តប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្មនៃ ការអនុវត្តច្បាប់ (LEADS) ស្របទៅតាមអនុផ្នែក (e) ។ ទីភ្នាក់ងារប្រចាំខោនធីដែលធ្វើការឃ្លាំមើលជនជាប់ឃុំ ដែលត្រូវបានដោះលែងដោយនៅក្រោម ការត្រួពិនិត្យដោយសហគមន៍ បន្ទាប់ពីការដោះលែងតាមចំណងជើង 2.05 (ចាប់ផ្តើមជាមួយភាគ 3450) ត្រូវផ្តល់ព័ត៌មានណាមួយ ដែលបានស្នើដោយនាយកដ្ឋាន ដើម្បីធានាថាព័ត៌មានមានភាព ត្រឹមត្រូវទាក់ទងនឹងជនជាប់ឃុំ ដែលបានដោះលែងពីពន្ធនាគារប្រចាំរដ្ឋ។ ព័ត៌មាននេះអាចនឹងរួមមាន *កំណត់ត្រាទាំងអស់នៃការត្រួតពិនិត្យ* ការចេញដីការការដកហូត ឬការបញ្ជាប់ការត្រួតពិនិត្យដោយសហគមន៍ ក្រោយពេលដោះលែង។ នៅថ្ងៃឬ នៅមុនថ្ងៃទី 1 ខែ សីហា ឆ្នាំ 2011 ទីភ្នាក់ងារខោនធីដែលត្រូវបានចាត់តាំង ឲ្យត្រួតពិនិត្យ មើលជនជាប់ឃុំ ដែលបានដោះលែងដោយមានការត្រួតពិនិត្យ ដោយសហគមន៍ក្រោយការដោះលែង ត្រូវជូនដំណឹងនាយកដ្ឋានថា ទីភ្នាក់ងារប្រចាំខោនធីត្រូវបានចាត់តាំងជាអង្គភាពក្នុងមូលដ្ឋាន ដើម្បី ទទួលខុសត្រូវលើការផ្តល់ការត្រួតពិនិត្យនោះ។

(2) ទោះបីជាមានកថាខណ្ឌ (1) នាយកដ្ឋានយុត្តិធម៌ត្រូវតែជាភ្នាក់ងារដែលមានភារកិច្ចចម្បងទទួល ខុសត្រូវសម្រាប់ការផ្តល់ព័ត៌មានត្រឹមត្រូវ នៅក្រោម LEADS ដែលទាក់ទងនឹងប័ណ្ណក្រយៅដៃ។

(*l*) បន្ថែមពីលើលក្ខខណ្ឌតម្រូវនៅក្រោមអនុផ្នែក (k) នាយកដ្ឋានអប់រំ កែប្រែនិង ស្តារ នីតិសម្បទារ ត្រូវផ្តល់ទៅនាយកដ្ឋានយុត្តិធម៌នូវ ទិន្នន័យដែលត្រូវដាក់បញ្ចូល នៅក្នុងឯកសារ ដោះលែង ដែលមានការត្រួតពិនិត្យរបស់ប្រព័ន្ធ ទូរគមនាគមន៍អនុវត្តច្បាប់របស់រដ្ឋ California (CLETS) ដើម្បីឲ្យការអនុវត្តច្បាប់អាចទទួលបានយោបល់ តាមរយៈ CLETS អំពីបុគ្គលទាំងអស់ដែលត្រូវមានការត្រួតពិនិត្យដោយ សហគមន៍ ក្រោយពេលដោះលែងនិងទីភ្នាក់ងារប្រចាំខោនធី ដែលបានការចាត់តាំងអាចផ្តល់ការត្រួតពិនិត្យ។ ទិន្នន័យដែលត្រូវការ ដោយ អនុផ្នែកនេះត្រូវតែបាន ផ្តល់តាមរយៈការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក។

ភាគ 4.2. ភាគ 3040.1 ត្រូវបានបន្ថែមទៅក្នុង ក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

3040.1 (a) សម្រាប់គោលបំណងនៃការដោះលែងមុនកំណត់ ឬ ការពិចារណាអំពីការដោះលែងដោយមានលក្ខខណ្ឌ នៅក្រោយសិទ្ធិអំណាចនៃភាគ 32 នៃមាត្រ I នៃធម្មនុញ្ញ, ភាគ 12838.4 និង 12838.5 នៃក្រមរដ្ឋាភិបាល, ភាគ 3000.1, 3041.5, 3041.7, 3052, 5000, 5054, 5055, 5076.2 នៃក្រមព្រហ្មទណ្ឌ និងការសិទ្ធិអំណាច ក្នុងការបង្កើតវិធានដែលបានផ្តល់ដោយភាគ 5058 នៃ ក្រមព្រហ្មទណ្ឌ ខាងក្រោមនេះគឺជានិយមន័យនៃពាក្យ "បទល្មើសព្រហ្មទណ្ឌហិង្សា"៖

(1) ឃាតកម្ម ឬ មនុស្សឃាតដោយចេតនា។

(2) ការបង្ករបួសស្នាម ព្រៃផ្សៃ។

(3) ការរំលោភសេពសន្ធវៈ ដូចមានកំណត់នៅ ក្នុងកថាខណ្ឌ (2) ឬ (6) នៃអនុផ្នែក (a) នៃភាគ 261 ឬ កថាខណ្ឌ (1) ឬ (4) នៃអនុផ្នែក (a) នៃភាគ 262។

(4) សេពសន្ធវៈ តាមរន្ធគូថដូចមានកំណត់អត្ថន័យ ក្នុងអនុផ្នែក (c) ឬ (d) នៃភាគ 286។

(5) ការរួមសង្វាសតាមមាត់ ដូចមានកំណត់អត្ថន័យ ក្នុងអនុផ្នែក (c) ឬ (d) នៃភាគ 287។

(6) ទង្វើ អាសអាភាស និងស្រើបស្រាល ដូចមានកំណត់អត្ថន័យ ក្នុងអនុផ្នែក (a) ឬ (b) នៃភាគ 288។

(7) បទព្រហ្មទណ្ឌណាមួយ ដែលត្រូវដាក់ទោស ដោយការជាប់ពន្ធនាគារអស់មួយជីវិត ឬ ការជាប់ ពន្ធនាគារប្រចាំរដ្ឋអស់មួយជីវិត។

(8) បទព្រហ្មទណ្ឌដែលចុងចោទបង្ករបួសធ្ងន់ធ្ងរ លើរាងកាយជនណាម្នាក់ក្រៅពីជាអ្នកឃុបឃិត ដែលត្រូវបានចោទ និងមានភស្តុតាងដូចមានចែង នៅក្នុងភាគ 12022.7, 12022.8, ឬ 12022.9 នៅថ្ងៃឬ ក្រោយពីថ្ងៃទី 1 ខែកក្កដាឆ្នាំ 1977, ឬ ដូចបានបញ្ជាក់មុនថ្ងៃទី 1 ខែកក្កដាឆ្នាំ 1977 នៅក្នុងភាគ 213, 264, និង 461, ឬបទព្រហ្មទណ្ឌណាមួយ ដែលចុងចោទប្រើប្រាស់អាវុធត្រូវបានចោទនិងមានភាស្តុតាង ដូចមានចែងនៅក្នុងអនុផ្នែក (a) នៃភាគ 12022.3, ឬភាគ 12022.5 ឬ 12022.55។

(9) ការប្លន់ណាមួយ។

(10) ការបង្កអគ្គិភ័យ ក្នុងការរំលោភបំពានលើអនុផ្នែក (a) ឬ (b) នៃ ភាគ 451។

(11) ការ រួមសង្វាស ដោយការស៊ីកបញ្ចូល ដូចមានកំណត់អត្ថន័យ ក្នុងអនុផ្នែក (a) ឬ (j) នៃភាគ 289។

(12) ឃាតកម្មដោយមានការប៉ុនប៉ង។

(13) ការរំលោភបំពានលើ ឮភាគ 18745, 18750, ឬ 18755។

(14) ការចាប់ជម្រិត។

(15) ការវាយប្រហារដោយមានចេតនា ប្រព្រឹត្តបទព្រហ្មទណ្ឌជាក់លាក់ ក្នុងបំណងរំលោភបំពាននៅ ក្នុងភាគ 220។

(16) ការរំលោភបំពាន ខាងផ្លូវភេទជាបន្តបន្ទាប់លើកុមារ ដោយ រំលោភបំពានលើភាគ 288.5។

(17) ការប្លន់យករថយន្ត ដូចមានកំណត់អត្ថន័យ ក្នុងអនុផ្នែក (a) នៃ ភាគ 215។

(18) ការរំលោភសេពសន្ធវៈ ការរំលោភសេពសន្ធវៈ លើប្តីប្រពន្ធ ឬ ការ រួមសង្វាសដោយការស៊ីក បញ្ចូលដោយមានគ្នាច្រើន ដោយរំលោភបំពាន លើភាគ 264.1។

(19) ការជម្រិតដូចមានកំណត់និយមន័យ នៅក្នុងភាគ 518 ដែល បង្កើតបានជា បទព្រហ្មទណ្ឌរំលោភ លើភាគ 186.22។

(20) ការគំរាមកំហែងលើជនរងគ្រោះ ឬ សាក្សីដូចមានកំណត់អត្ថន័យ ក្នុង អនុផ្នែក (c) នៃភាគ 136.1។

(21) ការគាស់ចូលក្នុងផ្ទះកម្រិតទីមួយណាមួយ ដូចកំណត់នៅក្នុងអនុ ផ្នែក (a) នៃភាគ 460, ដែលត្រូវ បានចោទប្រកាន់ និង មានភស្តុតាងថា មនុស្សម្នាក់ទៀតក្រៅពីអ្នកចូលដៃ មានវត្តមាននៅក្នុង លំនៅដ្ឋាន ក្នុង ពេលប្រព្រឹត្តអំពើគាស់ផ្ទះ។

(22) ការរំលោភបំពានណាមួយលើភាគ 12022.53។

(23) ការរំលោភបំពានលើអនុផ្នែក (b) ឬ (c) នៃភាគ 11418។

(24) ការអូសទាញឲ្យប្រព្រឹត្តឃាតកម្ម។

(25) ការវាយប្រហារបទព្រហ្មទណ្ឌដោយ មានអាវុធដោយរំលោភបំពាន លើកថាខណ្ឌ (2) នៃអនុផ្នែក (a) និងអនុផ្នែក (b) នៃភាគ 245។

(26) ការវាយប្រហារបទព្រហ្មទណ្ឌដោយមានអាវុធពិឃាត ដោយ រំលោភបំពានលើកថាខណ្ឌ (1) នៃ អនុផ្នែកនៃភាគ 245។

(27) ការវាយប្រហារ បទព្រហ្មទណ្ឌដោយមានអាវុធពិឃាតលើមនុស្ស របស់មន្ត្រីស្លូតត្រង់ ឬ អ្នកពន្លត់អគ្គិភ័យ ដោយរំលោភបំពានលើអនុផ្នែក (c) និង (d) នៃភាគ 245។

(28) ការវាយប្រហារបទព្រហ្មទណ្ឌ ដោយមធ្យោបាយប្រើកម្លាំង ដែល នឹងបង្ករបួសធ្ងន់ធ្ងរ លើ រាងកាយដោយរំលោភបំពាន លើកថាខណ្ឌ (4) នៃអនុផ្នែក (a) នៃភាគ 245។

(29) ការវាយប្រហារដោយប្រើ សារធាតុគីមីបង្កហេតុដោយ រំលោភបំពានលើភាគ 244។

(30) ការដាក់ពន្ធនាគារខុសដោយ រំលោភបំពានលើភាគ 210.5។

(31) បទព្រហ្មទណ្ឌដោយការបញ្ចេញអាវុធ ដោយរំលោភបំពានលើ ភាគ 246។

(32) ការបញ្ចេញពីយានយន្ត ដែលរំលោភបំពានទៅលើអនុផ្នែក (c) នៃភាគ 26100 ។

(33) អំពើហិង្សាក្នុងគ្រួសារកម្រិតព្រហ្មទណ្ឌ ដែលបង្កឲ្យមានការ ប៉ះទង្គិចដោយរំលោភបំពានទៅលើភាគ 273.5 ។

(34) បទព្រហ្មទណ្ឌដោយការប្រើកម្លាំង ឬការគំរាមកំហែងទៅលើសាក្សី ឬជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដោយរំលោភបំពានទៅលើភាគ 140 ។

(35) បទព្រហ្មទណ្ឌដែលតតាំង នឹងមន្ត្រីសន្តិភាព ហើយបង្កឲ្យមានការ ស្លាប់ ឬរងរបួសធ្ងន់ធ្ងរ ដែល រំលោភបំពានទៅលើភាគ 148.10 ។

(36) បទព្រហ្មទណ្ឌដោយការស្អប់ខ្ពើមដែល ត្រូវផ្តន្ទាទោសអនុលោម តាមភាគ 422.7 ។

(37) ការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌលើមនុស្សចាស់ ឬការរំលោភបំពានលើ នីតិជននៅក្នុងបន្ទុក ដោយរំលោភបំពាន លើអនុផ្នែក (b) នៃភាគ 368 ។

(38) ការរំលោភសេពសន្ថវៈដោយរំលោភ បំពានលើកថាខណ្ឌ (1) (3) ឬ (4) នៃអនុផ្នែក (a) នៃភាគ 261 ។

(39) ការរំលោភ សេពសន្ថវៈ ដោយរំលោភបំពានលើភាគ 262។

(40) ការរួមសង្វាសដោយការស៊ីកបញ្ជូល ក្នុងការរំលោភបំពានលើអនុ ផ្នែក (b), (d), ឬ (e) នៃភាគ 289។

(41) សេពសន្ថវៈតាមរន្ធគូថ ក្នុងការរំលោភបំពានលើអនុផ្នែក (f), (g), ឬ (i) នៃភាគ 286។

(42) ការរួមសង្វាសតាមមាត់ ក្នុងការរំលោភបំពានលើអនុផ្នែក (f), (g), ឬ (i) នៃភាគ 287។

(43) ការចាប់ជម្រិតអនីតិជនក្នុង គោលបំណង អំពីពេស្យាចារដោយ រំលោភបំពានលើភាគ 267។

(44) ការជួញដូរមនុស្ស ក្នុងការរំលោភបំពានលើអនុផ្នែក (a), (b), ឬ (c) នៃភាគ 236.1។

(45) ការរំលោភបំពានលើកុមារ ដោយរំលោភបំពានលើភាគ 273ab។

(46) ការរក្សាទុកការបំផ្ទុះ ឬ ការបញ្ចេះសារធាតុបំផ្លាញ ដោយ រំលោភបំពានលើភាគ 18740។

(47) ការរំលោភបំពានពីរ ឬ ច្រើនលើអនុផ្នែក (c) នៃភាគ 451។

(48) ការប៉ុនប៉ងណាមួយដើម្បីប្រព្រឹត្តបទល្មើស ដែលបានរៀបរាប់ នៅក្នុងអនុផ្នែកនេះ។

(49) បទព្រហ្មទណ្ឌណាមួយដែលត្រូវបានអះអាង និងមានភស្តុតាងថា ចុងចោទបាន ប្រើប្រាស់អាវុធ គ្រោះថ្នាក់ ឬ ពិឃាតដោយផ្ទាល់។

(50) បទល្មើសណាមួយដែលបណ្តាល ឲ្យមានការចុះឈ្មោះជនល្មើស ខាងផ្លូវភេទ អស់មួយជីវិត ស្រប តាមភាគ 290 ដល់ 290.009 រួម ទាំងអស់។

(51) ការឃុបឃិតណាមួយ ដើម្បីប្រព្រឹត្តបទល្មើស ដែលបានរៀបរាប់ នៅក្នុងភាគនេះ។

(b) ប្រការនៃភាគនេះ ត្រូវអនុវត្តលើជនជាប់ឃុំដែល កំពុងនៅក្នុងការ ឃុំឃាំងនៅពន្ធនាគារនៅត្រឹម ឬ នៅក្រោយ កាលបរិច្ឆេទចូលជាធរមាន នៃភាគនេះដោយមិនគិតអំពី ពេលវេលានៃការកាត់ទោស ឡើយ។

ភាគ 4.3. ភាគ 3040.2 ត្រូវបានបន្ថែមទៅក្នុង ក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

3040.2. (a) នៅពេលធ្វើការពិនិត្យមើល លើការពិចារណាអំពីការ ដោះលែង ដោយមានលក្ខខណ្ឌ សម្រាប់ជនល្មើសអហិង្សាមន្ត្រីសវនាការ សម្រាប់គណៈកម្មការសវនាការ លើកលែងទោសដោយ មានលក្ខខណ្ឌត្រូវ ពិចារណា លើរាល់ព័ត៌មានពាក់ព័ន្ធដែលអាច ទុកចិត្តបានអំពីជនជាប់ឃុំ។

(b) ស្តង់ដារនៃការត្រួតពិនិត្យ ត្រូវពិចារណាថា តើជនជាប់ឃុំ នឹងបង្ក ហានិភ័យដោយមិនសម ហេតុផលនៃការ បង្កើតជនរងគ្រោះ ដោយសារ ទង្វើព្រហ្មទណ្ឌឬទេ ប្រសិនបើដោះលែងចេញពី ពន្ធនាគារ។

(c) ក្នុងការឈានទៅសម្រេចចិត្ត មន្ត្រីសវនការត្រូវពិចារណាលើកត្តា ខាងក្រោម៖

(1) លក្ខខណ្ឌជុំវិញការ កាត់ទោសបច្ចុប្បន្ន។

(2) ប្រវត្តិឧក្រិដ្ឋកម្មរបស់ជនជាប់ឃុំ រួមទាំងការពាក់ព័ន្ធ នឹងទង្វើឧក្រិដ្ឋ កម្មផ្សេងទៀតទាំងអនីតិជន និង នីតិជនដែលបានកត់ត្រាទុកត្រឹមត្រូវ។

(3) អាកប្បកិរិយាស្ថាប័នរបស់ជនជាប់ឃុំ រួមមានការប្រព្រឹត្តខុស ក្នុង កម្មវិធីស្តារនីតិសម្បទារ និងផ្នែក ស្ថាប័ន។

(4) ធាតុចូលណាមួយពីជនជាប់ឃុំ ជនរងគ្រោះណាមួយតើបាន ចុះឈ្មោះនៅពេលបញ្ជូនឬទេ និង ទីភ្នាក់ងារកាត់ទោសនានា។

(5) ស្ថានភាពផ្លូវចិត្តពីមុននិងបច្ចុប្បន្នរបស់ជនជាប់ឃុំ ដែលបាន កត់ត្រាទុកនៅក្នុងកំណត់ហេតុ ដែលរក្សាទុក នៅនាយកដ្ឋានអប់រំកែប្រែ និងស្តារនីតិសម្បទា។

(6) អាកប្បកិរិយាកាលពីមុន និងបច្ចុប្បន្នរបស់ជនជាប់ឃុំអំពីបទល្មើស។

(7) ព័ត៌មានផ្សេងទៀតណាមួយ ដែលឆ្លុះបញ្ចាំងអំពីភាពសាកសម ក្នុង ការដោះលែងជនជាប់ឃុំ។

(d) ស្ថានភាពខាងក្រោមនេះត្រូវតែបានពិចារណា ដោយមន្ត្រីសវនការ ក្នុងការកំណត់ថា តើជនជាប់ឃុំ មិនសាកសមសម្រាប់ការដោះលែងឬទេ៖

(1) ជនរងគ្រោះច្រើននាក់ពាក់ព័ន្ធ នឹងការប្រព្រឹត្តបទល្មើសបច្ចុប្បន្ន។

(2) ជនរងគ្រោះងាយរងគ្រោះយ៉ាងខ្លាំង ដោយសារអាយុឬស្ថានភាព ផ្លូវកាយឬ ផ្លូវចិត្ត។

(3) ជនជាប់ឃុំយកចំណេញពីជំហរ នៃការទុកចិត្តក្នុងការប្រព្រឹត្ត បទឧក្រិដ្ឋ។

(4) ជនជាប់ឃុំមានកាំភ្លើង ឬ អាវុធពិឃាតនៅពេលប្រព្រឹត្តបទឧក្រិដ្ឋ។

(5) ជនរងគ្រោះឈឺចាប់ដោយ របួសធ្ងន់ធ្ងរលើរាងកាយក្នុងពេល ប្រព្រឹត្តបទល្មើស។

(6) ជនជាប់ឃុំបានប្រព្រឹត្តបទឧក្រិដ្ឋ ពាក់ព័ន្ធនឹងជើងកាងឧក្រិដ្ឋកម្ម នៅតាមផ្លូវ។

(7) ជនជាប់ឃុំមានមុខតំណែងជាអ្នកដឹកនាំ ឬគ្រប់គ្រងលើអ្នកចូលរួម ផ្សេងទៀត ក្នុងការប្រព្រឹត្ត បទល្មើស ឬ ជនជាប់ឃុំបានទាក់ទាញអ្នក ផ្សេងទៀតឲ្យចូលរួម ក្នុងការប្រព្រឹត្តបទល្មើស។

(8) ក្នុងពេលប្រព្រឹត្តបទល្មើសជនជាប់ឃុំ មានឱកាសច្បាស់លាស់ ក្នុងការឈប់ប៉ុន្តែខ្លួននៅតែបន្ត។

(9) ជនជាប់ឃុំបានចូលរួមពាក់ព័ន្ធ ក្នុងទង្វើឧក្រិដ្ឋកម្មដែលបានកត់ត្រាទុក ផ្សេងទៀតដែលជាផ្នែកមួយសំខាន់នៃបទឧក្រិដ្ឋ ដែលជាមូលហេតុនៃការជាប់ពន្ធនាគារពេលបច្ចុប្បន្ន។

(10) របៀបនៃការប្រព្រឹត្តបទល្មើសបានបង្កើតសក្តានុពលភាព សម្រាប់ការបង្ករបួសធ្ងន់ធ្ងរផ្សេងទៀត ក្រៅពីជនរងគ្រោះនៃបទល្មើស។

(11) ជនជាប់ឃុំស្ថិតនៅក្នុងការសាកល្បង ការដោះលែងដោយមានលក្ខខណ្ឌការត្រួតពិនិត្យ ដោយ សហគមន៍ក្រោយពេលដោះលែង ឬការត្រួតពិនិត្យជាចាំបាច់ ឬស្ថិតនៅក្នុងការឃុំឃាំង ឬបានគេចពីការឃុំឃាំងនៅពេលប្រព្រឹត្តបទល្មើស។

(12) ជនជាប់ឃុំនៅលើទម្រង់នៃការដោះលែងមុន ឬ ក្រោយកាត់ទោសនៅពេលប្រព្រឹត្តបទល្មើស។

(13) ប្រវត្តិហិង្សាកាលពីមុនរបស់ជនជាប់ឃុំ ទោះជាអនីតិជន ឬ នីតិជន។

(14) ជនជាប់ឃុំបានចូលរួម ក្នុងការប្រព្រឹត្តខុសឆ្គង ពេលនៅក្នុងពន្ធនាគារ ឬ កន្លែងឃុំខ្លួន។

(15) ជនជាប់ឃុំត្រូវបានដាក់ ឲ្យជាប់ឃុំសម្រាប់ច្រើនករណីពីខោនធី ឬ យុត្តាធិការដដែល ឬ ផ្សេងទៀត។

(e) ស្ថានភាពខាងក្រោមនេះ ត្រូវតែបានពិចារណាដោយ មន្ត្រីសវនការ ក្នុងការកំណត់ថា តើជនជាប់ឃុំ សាកសមសម្រាប់ការដោះលែងឬទេ៖

(1) ជនជាប់ឃុំ មិនមានប្រវត្តិវាយប្រហារ លើអនីតិជនផ្សេងទៀត ឬ ការប្រព្រឹត្តបទល្មើសដែលអាច នឹង បង្ករគ្រោះថ្នាក់លើជនរងគ្រោះ។

(2) ជនជាប់ឃុំខ្វះប្រវត្តិបទល្មើសហិង្សា។

(3) ជនជាប់ឃុំបានបង្ហាញការស្តាយក្រោយ។

(4) អាយុបច្ចុប្បន្នរបស់ជនជាប់ ឃុំកាត់បន្ថយ ហានិភ័យនៃការមិនរាងចាល។

(5) ជនជាប់ឃុំមានផែនការសមហេតុផល ប្រសិនបើដោះលែង ឬបានបង្កើតជំនាញដែលមានទីផ្សារ ដែលអាចយកទៅប្រើប្រាស់នៅពេលដោះលែង។

(6) សកម្មភាពស្ថាប័នរបស់ជនជាប់ឃុំ បង្ហាញអំពីសមត្ថភាពកើនឡើងក្នុងប្រើប្រាស់បានដោយ ស្របច្បាប់នៅពេលដោះលែង។

(7) ជនជាប់ឃុំបានចូលរួម ក្នុងបទឧក្រិដ្ឋក្រោមស្ថានភាព ដែលអាចអនុគ្រោះបានមួយផ្នែក ដែលមិន មានចំនួនច្រើនចំពោះការផ្លូវច្បាប់។

(8) ជនជាប់ឃុំមិនមានការប៉ុនប៉ង ដើម្បីប្រព្រឹត្តបទល្មើសប៉ុន្តែ ត្រូវបានអូសទាញដោយអ្នកដទៃឲ្យ ចូលរួមប្រព្រឹត្ត ។

(9) ជនជាប់ឃុំមានប្រវត្តិតិចតួចបំផុត ឬ គ្មានប្រវត្តិបទល្មើស។

(10) ជនជាប់ឃុំគឺជាអ្នក ចូលរួមអកម្ម ឬ ដើរតួនាទីតិចតួច នៅក្នុងការប្រព្រឹត្តបទល្មើស។

(11) បទល្មើសត្រូវបានប្រព្រឹត្តក្នុងពេល ឬ ដោយសារមានស្ថានភាពមិនប្រក្រតីដែលមិនទំនង នឹង កើតឡើងទៀតឡើយ។

ភាគ 4.4. ភាគ 3040.3 ត្រូវបានបន្ថែមទៅក្នុង ក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

3040.3. (a) ជនជាប់ឃុំដែលការប្រព្រឹត្តបច្ចុប្បន្នរបស់ខ្លួន រួមមានទោសបូកទោសបន្ត ឬ ទោសស្នាក់នៅសម្រាប់បទល្មើស ឬ ការចោទប្រកាន់ដូចបានកំណត់និយមន័យថា ជាហិង្សាដោយអនុផ្នែក (c) នៃ ភាគ 667.5 ឬ ភាគ 3040.1 ត្រូវចាត់ទុកថាជាជនល្មើសហិង្សាសម្រាប់គោលបំណងនៃភាគ 32 នៃមាត្រានៃធម្មនុញ្ញ។

(b) អ្នកទោសដែលនៅជាមួយគ្នា ដែលដីកាឃុំខ្លួនបច្ចុប្បន្នមានរាប់បញ្ចូលទាំងទោសគុក ដែលគ្មានពេលជាក់លាក់ផងដែរនោះ ត្រូវចាត់ទុកថាជាជនល្មើសហិង្សា សម្រាប់គោលបំណងនៃផ្នែកទី 32 នៃមាត្រា I នៃរដ្ឋធម្មនុញ្ញ។

(c) អ្នកទោសដែលនៅជាមួយគ្នា ដែលដីកាឃុំខ្លួនបច្ចុប្បន្នមានរាប់បញ្ចូលទាំងការពង្រីកបន្ថែមណាមួយ ដែលធ្វើឲ្យបទល្មើសជាមូលដ្ឋានក្លាយជាហិង្សា ដោយអនុលោមតាមផ្នែករង (c) នៃផ្នែកទី 667.5 ត្រូវចាត់ទុកថាជាជនល្មើសហិង្សាសម្រាប់គោលបំណងនៃផ្នែកទី 32 នៃមាត្រា I នៃរដ្ឋធម្មនុញ្ញ។

(d) សម្រាប់គោលបំណងនៃផ្នែកទី 32 នៃមាត្រា I នៃរដ្ឋធម្មនុញ្ញ "រយៈពេលពេញលេញ" នៃ "បទល្មើសចម្បង" ត្រូវគណនាដោយផ្អែកទៅលើតែចំនួនថ្ងៃជាក់ស្តែង ដែលបានជាប់ទោសពីបទល្មើស ដែលមានដីកាឃុំខ្លួនប៉ុណ្ណោះ។

ផ្នែកទី 4.5. ផ្នែកទី 3040.4 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

3040.4. អនុលោមតាមផ្នែករង (b) នៃផ្នែកទី 28 នៃមាត្រា I នៃរដ្ឋធម្មនុញ្ញ ក្រសួងត្រូវផ្តល់សេចក្តីជូនដំណឹងសមហេតុសមផលមួយ ដល់ជនរងគ្រោះ នៃបទល្មើសព្រហ្មទណ្ឌមុនពេល ដែលអ្នកទោស ដែលនៅជាមួយគ្នាត្រូវបានពិនិត្យឡើងវិញ សម្រាប់ការដោះលែងឲ្យនៅក្រៅឃុំ ដោយមានលក្ខខណ្ឌ និងការដោះលែងជាស្ថាពរមុនពេលកំណត់។ ក្រសួងត្រូវផ្តល់ជូនជនរងគ្រោះជាមួយនឹងសិទ្ធិឲ្យអ្នកដទៃស្តាប់ឮ ទាក់ទងនឹងការពិចារណាដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌមុនពេលកំណត់ និងដើម្បីចូលរួមនៅក្នុងដំណើរការពិនិត្យឡើងវិញ។ ក្រសួងត្រូវពិចារណាអំពីសុវត្ថិភាពនៃជនរងគ្រោះ ក្រុមគ្រួសារជនរងគ្រោះ និងសាធារណជនទូទៅនៅពេលធ្វើការកំណត់ទៅលើការដោះលែងមុនពេលកំណត់។

(a) មុនពេលធ្វើការពិនិត្យឡើងវិញសម្រាប់ការដោះលែងឲ្យនៅក្រៅឃុំ ដោយមានលក្ខខណ្ឌ មុនពេលកំណត់ ក្រសួងត្រូវផ្តល់សេចក្តីជូនដំណឹងដល់ទីភ្នាក់ងារ ឬបណ្តាទីភ្នាក់ងារចោទប្រកាន់ និងដល់ជនរងគ្រោះដែលបានចុះបញ្ជី ហើយត្រូវប្រឹងប្រែងឲ្យអស់ពីលទ្ធភាពដើម្បីរកទីតាំង និងជូនដំណឹងដល់ជនរងគ្រោះ ដែលពុំត្រូវបានចុះបញ្ជី។

(b) ទីភ្នាក់ងារចោទប្រកាន់ ត្រូវមានសិទ្ធិក្នុងការពិនិត្យឡើងវិញ នូវព័ត៌មានទាំងអស់ដែលអាចរកបានចំពោះមន្ត្រីសវនាការ រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ សំណុំឯកសារកណ្តាលរបស់អ្នកទោស ដែលនៅជាមួយគ្នា ប្រវត្តិបទល្មើសព្រហ្មទណ្ឌរបស់នីតិជន និងអនីតិជនដែលបានចងក្រងឯកសារ អាកប្បកិរិយាស្ថាប័ន រួមទាំងកម្មវិធីស្តារលទ្ធភាពពលកម្មឡើងវិញ និងការប្រព្រឹត្តពុំត្រឹមត្រូវផ្នែកស្ថាប័ន រាល់ធាតុចូលមកពីបុគ្គល ឬអង្គភាពណាមួយដែលតស៊ូមតិក្នុងនាមជាអ្នកទោស ដែលនៅជាមួយគ្នា និងរាល់ព័ត៌មានដែលបានដាក់ស្នើជូនដោយសាធារណជន។

(c) ជនរងគ្រោះត្រូវមានសិទ្ធិក្នុងការដាក់ស្នើសេចក្តីថ្លែងការណ៍ សម្រាប់គោលបំណងនៃការពិចារណាដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌមុនពេលកំណត់ រួមទាំងសេចក្តីថ្លែងការណ៍រក្សាការសម្ងាត់។

(d) ទីភ្នាក់ងារចោទប្រកាន់ទាំងអស់ រួមទាំងទីភ្នាក់ងារអនុវត្តច្បាប់ ដែលពាក់ព័ន្ធ និងជនរងគ្រោះទាំងអស់ ទោះបីបានចុះបញ្ជីក្តី ឬមិនបានចុះបញ្ជីក្តី ត្រូវមានសិទ្ធិក្នុងការឆ្លើយតបចំពោះគណៈកម្មការជាលាយលក្ខណ៍អក្សរ។

(e) ការឆ្លើយតបចំពោះគណៈកម្មការដោយបណ្តាទីភ្នាក់ងារចោទប្រកាន់ បណ្តាទីភ្នាក់ងារអនុវត្តច្បាប់ និងជនរងគ្រោះ ត្រូវតែធ្វើឡើងក្នុងរយៈពេល 90 ថ្ងៃនៃកាលបរិច្ឆេទរបស់សេចក្តីជូនដំណឹងអំពីភាពមានសិទ្ធិទទួលបានរបស់អ្នកទោសដែល នៅជាមួយគ្នាសម្រាប់ការពិនិត្យឡើងវិញ ឬការពិចារណាលើការដោះលែងឲ្យ នៅក្រៅឃុំដោយមានលក្ខខណ្ឌមុនពេលកំណត់។

(f) គណៈកម្មការត្រូវជូនដំណឹងដល់បណ្តាទីភ្នាក់ងារចោទប្រកាន់ បណ្តាទីភ្នាក់ងារអនុវត្តច្បាប់ និងជនរងគ្រោះ អំពីសេចក្តីសម្រេចដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌចំពោះជនល្មើសអហិង្សាក្នុងរយៈពេល 10 ថ្ងៃបន្ទាប់ពីបានធ្វើសេចក្តីសម្រេចរួច។

(g) ក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីបានជូនដំណឹងអំពីសេចក្តីសម្រេចស្ថាពរ ដែលពាក់ព័ន្ធនឹងការពិចារណាដោះលែងឲ្យ នៅក្រៅឃុំដោយមានលក្ខខណ្ឌចំពោះជនល្មើសអហិង្សា អ្នកទោសដែលនៅជាមួយគ្នា និងបណ្តាទីភ្នាក់ងារចោទប្រកាន់អាចស្នើសុំការពិនិត្យឡើងវិញ ទៅលើសេចក្តីសម្រេចនោះបាន។

(h) ប្រសិនបើអ្នកទោសដែលនៅជាមួយគ្នាណាម្នាក់ ត្រូវបានបដិសេធការដោះលែងមុនពេលកំណត់ក្រោមបទបញ្ញត្តិដោះលែងឲ្យនៅក្រៅឃុំ ដោយមានលក្ខខណ្ឌចំពោះជនល្មើសអហិង្សានៃផ្នែកទី 32 នៃមាត្រា I នៃរដ្ឋធម្មនុញ្ញនោះ អ្នកទោសដែលនៅជាមួយគ្នានោះ មិនត្រូវមានសិទ្ធិទទួលបានការពិចារណាដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌចំពោះជនល្មើសអហិង្សា សម្រាប់រយៈពេលពីរឆ្នាំប្រតិទិន ដោយគិតចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចស្ថាពរ នៃការបដិសេធលើកមុន។

ផ្នែកទី 4.6. ផ្នែកទី 3041 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្ម ដែលមានខ្លឹមសារដូចខាងក្រោម៖

3041. (a) (1) ករណីដែលអ្នកទោសដែលនៅជាមួយគ្នាដែលត្រូវបានកាត់ទោសដោយអនុលោមតាមច្បាប់ណាមួយក្រៅពីជំពូក 4.5 (ចាប់ផ្តើមពីផ្នែកទី 1170) នៃចំណងជើងទី 7 នៃផ្នែកទី 2 គណៈកម្មការសវនាការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ ត្រូវជួបជាមួយអ្នកទោសដែលនៅជាមួយគ្នាម្នាក់ៗអំឡុងពេលប្រាំមួយឆ្នាំ មុនកាលបរិច្ឆេទដោះលែងឲ្យនៅក្រៅឃុំ ដោយមានលក្ខខណ្ឌដែលមានសិទ្ធិជាអប្បបរមារបស់អ្នកទោស ដែលនៅជាមួយគ្នា សម្រាប់គោលបំណងនៃការពិនិត្យឡើងវិញ និងចងក្រងឯកសារអំពីសកម្មភាព និងអាកប្បកិរិយាដែលទាក់ទងនឹងសិទ្ធិទទួលបានការដោះលែងឲ្យនៅក្រៅឃុំ ដោយមានលក្ខខណ្ឌរបស់អ្នកទោសដែលនៅជាមួយគ្នា។ អំឡុងពេលនៃការពិគ្រោះយោបល់នេះ គណៈកម្មការត្រូវផ្តល់ជូនព័ត៌មានដល់អ្នកទោស ដែលនៅជាមួយគ្នាអំពីដំណើរការសវនាការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ កត្តាច្បាប់ទាំងឡាយដែលពាក់ព័ន្ធនឹងភាពសមស្រប ឬភាពមិនសមស្របរបស់ពួកគេ សម្រាប់ការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌនោះនិងការផ្តល់អនុសាសន៍ជាលក្ខណៈបុគ្គលសម្រាប់អ្នកទោស ដែលនៅជាមួយគ្នា ដែលពាក់ព័ន្ធនឹងការចាត់តាំងការងារកម្មវិធីស្តារលទ្ធភាពពលកម្មឡើងវិញ និងអាកប្បកិរិយាស្ថាប័ន។ ក្នុងរយៈពេល 30 ថ្ងៃ បន្ទាប់ពីកិច្ចពិគ្រោះយោបល់ គណៈកម្មការត្រូវចេញលទ្ធផលវិជ្ជមាន និងអវិជ្ជមានរបស់ខ្លួន ព្រមទាំងអនុសាសន៍ជូនអ្នកទោស ដែលនៅជាមួយគ្នាជាលាយលក្ខណ៍អក្សរ។

(2) រយៈពេលមួយឆ្នាំមុនកាលបរិច្ឆេទដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ ដែលមានសិទ្ធិជាអប្បបរមារបស់អ្នកទោសដែលនៅជាមួយគ្នា គណៈដែលមានសមាសភាពស្នងការ ឬស្នងការរងចាប់ពីពីររូបឡើងទៅ ត្រូវជួបម្តងទៀតជាមួយអ្នកទោសដែលនៅជាមួយគ្នា និងត្រូវផ្តល់ជូនការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌជាធម្មតា ដូចមានចែងនៅក្នុងផ្នែកទី 3041.5។ សមាជិកនៃគណៈដែលជាស្នងការរងមិនត្រូវលើសពីមួយរូបឡើយ។

(3) ករណីបោះឆ្នោតជាក្រុម បញ្ហានោះត្រូវបញ្ជូនទៅពិនិត្យឡើងវិញនៅចំពោះមុខចៅក្រម ទៅលើកំណត់ហេតុពីមុនដែលគណៈនោះបានផ្តល់ជូននូវការបោះឆ្នោតជាក្រុម។ នៅពេលពិនិត្យឡើងវិញនៅចំពោះមុខចៅក្រម គណៈកម្មការត្រូវបោះឆ្នោតថាតើត្រូវផ្តល់ជូន ឬបដិសេធការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ និងផ្តល់ជូននូវសេចក្តីថ្លែងការណ៍ ស្តីពីសេចក្តីសម្រេច។ ការពិនិត្យឡើងវិញនៅចំពោះមុខចៅក្រមត្រូវធ្វើឡើងដោយអនុលោមទៅតាមផ្នែករង (e)។

(4) នៅពេលផ្តល់ជូននូវការដោះលែងឲ្យ នៅក្រៅឃុំដោយមានលក្ខខណ្ឌ អ្នកទោសដែលនៅជាមួយគ្នាត្រូវទទួលបានការដោះលែង ក្រោមរយៈពេលពិនិត្យឡើងវិញជាធរមាន។ ទោះជាយ៉ាងណា អ្នកទោសដែលនៅជាមួយគ្នាមិនត្រូវបានដោះលែង មុនពេលឈានដល់ពេលដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ ដែលមានសិទ្ធិទទួលបានជាអប្បបរមារបស់ខ្លួនដោយអនុលោមតាមផ្នែកទី 3046 ឡើយ លុះត្រាណាតែអ្នកទោសដែលនៅជាមួយគ្នានោះមានសិទ្ធិទទួលបានការដោះលែងឲ្យនៅក្រៅឃុំឲ្យមានលក្ខខណ្ឌ មុនពេលកំណត់ដោយអនុលោមតាមកាលបរិច្ឆេទនៃភាពមានសិទ្ធិទទួលបានការដោះលែងឲ្យ នៅក្រៅឃុំដោយមានលក្ខខណ្ឌចំពោះជនល្មើសជាយុវជន ឬកាលបរិច្ឆេទនៃភាពមានសិទ្ធិទទួលបាន ~~ការដោះលែង~~ *ឲ្យនៅក្រៅឃុំ* ដោយមានលក្ខខណ្ឌចំពោះមនុស្សចាស់។

(5) យ៉ាងហោចណាស់ស្នងការមួយរូបនៃគណៈត្រូវមានវត្តមាននៅក្នុងអង្គប្រជុំ លើកចុងក្រោយលើកលែងតែពុំមានលទ្ធភាពធ្វើដូច្នោះបាន ឬនៅពេលដែលអង្គប្រជុំលើកចុងក្រោយនោះគឺជាអង្គប្រជុំដំបូង។ រាល់បុគ្គលនៅក្នុងគណៈសវនាការអាចស្នើសុំការពិនិត្យឡើងវិញ ទៅលើរាល់សេចក្តីសម្រេចណាមួយដែលទាក់ទងនឹងការដោះលែង ឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌសម្រាប់ សវនការចំពោះមុខចៅក្រមដោយគណៈកម្មការ។ ករណីធ្វើការពិនិត្យឡើងវិញ សន្លឹកឆ្នោតភាគច្រើនដែលគាំទ្រឲ្យមានការដោះលែងឲ្យនៅក្រៅឃុំ ដោយមានលក្ខខណ្ឌ ដោយសមាជិកគណៈកម្មការ ដែលចូលរួមនៅកក្នុងការពិនិត្យឡើងវិញដោយចៅក្រម ត្រូវបានតម្រូវឲ្យផ្តល់ការដោះលែង ឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌជូនអ្នកទោសដែល នៅជាមួយគ្នាណាម្នាក់។

(b) (1) គណៈ ឬគណៈកម្មការ ចៅក្រមប្រចាំការ ត្រូវផ្តល់ការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌជូនអ្នកទោសដែលនៅជាមួយគ្នាណាម្នាក់ លើកលែងតែខ្លួនកំណត់ថាស្ថានទម្ងន់នៃបទល្មើសមួយ ឬបណ្តាបទល្មើសដែលបានផ្តន្ទាទោសបច្ចុប្បន្ន ឬរយៈពេល និងស្ថានទម្ងន់នៃបទល្មើសមួយ ឬបណ្តាបទល្មើសដែលបានផ្តន្ទាទោសពីមុន គឺជាការពិចារណាទៅលើសុវត្ថិភាពសាធារណជនដែលទាមទារឲ្យមានរយៈពេលឃុំខ្លួនយូរជាងមុនសម្រាប់បុគ្គលនេះ។ *គណៈ ឬគណៈកម្មការ ចៅក្រមប្រចាំការ ត្រូវពិចារណាទៅលើប្រវត្តិបទល្មើសព្រហ្មទណ្ឌ ទាំងស្រុងរបស់អ្នកទោសដែលនៅជាមួយគ្នា រួមទាំងបទល្មើសដែលបានផ្តន្ទាទោសបច្ចុប្បន្ន ឬពីមុនមក នៅក្នុងការធ្វើការកំណត់នេះ។*

(2) ក្រោយថ្ងៃទី 30 ខែកក្កដា ឆ្នាំ 2001 រាល់សេចក្តីសម្រេចរបស់គណៈកម្មការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌយល់ឃើញថាអ្នកទោសដែលនៅជាមួយគ្នាណាម្នាក់មានលក្ខណៈសមស្រប សម្រាប់ការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ ត្រូវតែជាសេចក្តីសម្រេចស្ថាពរក្នុងរយៈពេល 120 ថ្ងៃបន្ទាប់ពីថ្ងៃសវនាការ។ ក្នុងអំឡុងពេលនោះ គណៈកម្មការអាចពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចរបស់គណៈកម្មការបាន។ សេចក្តីសម្រេចរបស់គណៈ ត្រូវតែជាសេចក្តីសម្រេចស្ថាពរដោយអនុលោមតាមផ្នែករងនេះ លើកលែងតែគណៈកម្មការយល់ឃើញថាគណៈនោះមានកំហុសផ្នែកច្បាប់ ឬសេចក្តីសម្រេចរបស់គណៈនោះផ្អែកទៅលើកំហុសនៃអង្គហេតុណាមួយ ឬព័ត៌មានថ្មីនោះគួរត្រូវបានបង្ហាញជូនគណៈកម្មការ ដែលពេលកែតម្រូវ ឬពិចារណាដោយគណៈកម្មការ មានលទ្ធភាពជាច្រើនដែលបណ្តាលឲ្យមានសេចក្តីសម្រេចខុសគ្នាជាច្រើន នៅពេលបើកសវនាការឡើងវិញ។ នៅក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយនេះ គណៈកម្មការត្រូវពិគ្រោះយោបល់ជាមួយបណ្តាស្នងការដែលបានធ្វើសវនាការពិចារណាលើការដោះលែង ឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ។

(3) សេចក្តីសម្រេចរបស់គណៈមិនត្រូវទទួលបានការមិនអនុម័ត និងបញ្ជូនទៅកាន់សវនាការឡើងវិញឡើយ លើកលែងតែមានសំឡេងឆ្នោតភាគច្រើនរបស់ក្រុមប្រឹក្សា ចៅក្រមប្រចាំការនៅក្រោយអង្គប្រជុំជាសាធារណៈ។

(c) សម្រាប់គោលបំណងនៃការពិនិត្យឡើងវិញ ទៅលើភាពសមស្របសម្រាប់ការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌរបស់អ្នកទោសដែលនៅជាមួយគ្នា ដែលមានសិទ្ធិទទួលបានការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌក្រោមច្បាប់ពីមុន នៅកាលបរិច្ឆេទមួយមុនពេលដែលត្រូវបានគណនាក្រោមផ្នែកទី 1170.2 គណៈកម្មការត្រូវចាត់តាំងគណៈនានា ដែលមានសមាជិកយ៉ាងតិចពីររូប ដើម្បីជួបជាប្រចាំឆ្នាំជាមួយអ្នកទោសដែលនៅជាមួយគ្នាម្នាក់ៗ រហូតដល់ពេលដែលជននោះត្រូវបានដោះលែងដោយអនុលោមតាមនីតិវិធីរឿងក្តី ឬឈានដល់ពេលផុតកំណត់នៃរយៈពេលរបស់ខ្លួន ដូចដែលបានគណនាក្រោមផ្នែកទី 1170.2។

(d) វាគឺជាចេតនារបស់រដ្ឋសភាដែលថា អំឡុងពេលដែលគ្មានអ្នកទោសដែលនៅជាមួយគ្នាច្រើនលើសលប់កំពុងរង់ចាំសវនាការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ សវនាការពិចារណាដោះលែងឲ្យនៅក្រៅឃុំ ដោយមានលក្ខខណ្ឌមួយជីវិត ឬសវនាការរំលាយចោលកិច្ចសន្យាមួយ

20

ជីវិត សវនាការទាំងឡាយនឹងត្រូវបានធ្វើឡើងដោយគណៈដែលមានសមាជិកចាប់ពីបីរូបឡើងទៅ ដែលភាគច្រើននៃពួកគេត្រូវតែជាស្នងការ។ គណៈកម្មការត្រូវរាយការណ៍ប្រចាំខែអំពីចំនួននៃរឿងក្តី នៅពេលអ្នកទោសដែលនៅជាមួយគ្នានៅពុំទាន់បានទទួលបានសវនាការពិចារណាដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌលើកដំបូង ឬបន្តបន្ទាប់ចប់ជាស្ថាពរ ក្នុងរយៈពេល 30 ថ្ងៃ ក្រោយកាលបរិច្ឆេទនៃសវនាការដែលបានតម្រូវដោយផ្នែករង (a) នៃផ្នែកទី 3041.5 ឬកថាខណ្ឌ (2) នៃផ្នែករង (b) នៃផ្នែកទី 3041.5 លើកលែងតែអ្នកទោសដែលនៅជាមួយគ្នានោះបានបោះបង់ សិទ្ធិចំពោះក្របខណ្ឌពេលវេលាទាំងនោះ។ របាយការណ៍នោះ ត្រូវទទួលបានការពិចារណាទៅលើភាពលើសលប់នៃរឿងក្តីសម្រាប់គោលបំណងនៃផ្នែកនេះ ហើយត្រូវបញ្ជូលនូវព័ត៌មានអំពីភាពរីកចម្រើនឆ្ពោះទៅរកការលុបបំបាត់ចោលនូវភាពលើសលប់ និងអំពីចំនួននៃអ្នកទោសដែលនៅជាមួយគ្នា ដែលបានបោះបង់សិទ្ធិរបស់ពួកគេចំពោះរយៈពេលកំណត់ខាងលើ។ របាយការណ៍នេះត្រូវធ្វើជាសាធារណៈនៅឯអង្គប្រជុំដែលបានគ្រោងពេលជាទៀងទាត់របស់គណៈកម្មការ ហើយរបាយការណ៍ជាលាយលក្ខណ៍អក្សរមួយអោយសាធារណជនអាចចូលប្រើប្រាស់បាន និងបញ្ជូនទៅកាន់រដ្ឋសភាប្រចាំត្រីមាស។

(e) សម្រាប់គោលបំណងនៃផ្នែកនេះ ការពិនិត្យឡើងវិញចំពោះមុខចៅក្រមដោយគណៈកម្មការមានន័យថា ការពិនិត្យឡើងវិញដែលធ្វើឡើងដោយសំឡេងភាគច្រើននៃស្នងការកាន់តំណែងនៅថ្ងៃដែលបញ្ហានោះត្រូវបានធ្វើសវនាការដោយគណៈកម្មការ។ ការពិនិត្យឡើងវិញចំពោះមុខចៅក្រម ត្រូវធ្វើឡើងដោយអនុលោមទៅតាមខាងក្រោម៖

(1) ស្នងការដែលធ្វើការពិនិត្យឡើងវិញ ត្រូវពិចារណាទៅលើកំណត់ហេតុទាំងស្រុងនៃសវនាការដែលបណ្តាលឲ្យមានការបោះឆ្នោតជាក្រុម។

(2) ការពិនិត្យឡើងវិញត្រូវកំណត់ព្រំដែនចំពោះកំណត់ហេតុនៃសវនាការ។ កំណត់ហេតុត្រូវមានជាអត្ថបទ ឬការថតសំឡេងនៃសវនាការ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ឬបានថតទុកជាអេឡិចត្រូនិច ដែលត្រូវបានពិចារណាជាក់ស្តែងដោយគណៈដែលបានបង្កើតនូវការបោះឆ្នោតជាក្រុម និងរាល់ឯកសារផ្សេងៗទៀតដែលត្រូវបានពិចារណាជាក់ស្តែងដោយគណៈ។ ភ័ស្តុតាង ឬមតិយោបល់ថ្មីៗ មិនត្រូវពិចារណានៅក្នុងនីតិវិធីរឿងក្តីចំពោះមុខចៅក្រមឡើយ។

(3) គណៈកម្មការត្រូវថ្លែងការណ៍ដាច់ដោយឡែកនូវហេតុផលសម្រាប់សេចក្តីសម្រេចរបស់ខ្លួនដើម្បីផ្តល់ជូន ឬបដិសេធការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ។

(4) ស្នងការដែលពាក់ព័ន្ធនឹងការបោះឆ្នោតជាក្រុម ត្រូវបានបដិសេធពីការពិចារណាទៅលើបញ្ហា នៅ ក្នុងការពិនិត្យឡើងវិញចំពោះមុខចៅក្រម។

ផ្នែកទី 4.7. ផ្នែកទី 3454 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្ម ដែលមានខ្លឹមសារដូចខាងក្រោម៖

3454. (a) ទីភ្នាក់ងារត្រួតពិនិត្យប្រចាំខោនធីនីមួយៗ ដូចដែលបានបង្កើតឡើងដោយគណៈកម្មការ អ្នកត្រួតពិនិត្យប្រចាំខោនធី ដោយអនុលោមតាមផ្នែករង (a) នៃផ្នែកទី 3451 ត្រូវបង្កើតនូវដំណើរការពិនិត្យឡើងវិញសម្រាប់វាយតម្លៃ និងធ្វើឲ្យប្រសើរឡើងនូវកម្មវិធីត្រួតពិនិត្យក្រោយពេលដោះលែងសម្រាប់ជននោះ។ រាល់លក្ខខណ្ឌនៃការត្រួតពិនិត្យក្រោយការដោះលែងបន្ថែមត្រូវមានការពាក់ព័ន្ធ សមហេតុសមផលជាមួយនឹងបទល្មើសដែលជាមូលដ្ឋាន សម្រាប់ឲ្យជនល្មើសចំណាយពេលវេលានៅក្នុងពន្ធនាគារ ឬចំពោះហានិភ័យមិនរាងចាលរបស់ជនល្មើស និងប្រវត្តិបទល្មើសព្រហ្មទណ្ឌរបស់ជនល្មើស និងស្របជាមួយនឹងច្បាប់។

(b) ទីភ្នាក់ងារប្រចាំខោនធីនីមួយៗ ដែលទទួលខុសត្រូវចំពោះការត្រួតពិនិត្យក្រោយពេលដោះលែង ដូចដែលបានបង្កើតឡើងដោយគណៈកម្មការអ្នកត្រួតពិនិត្យប្រចាំខោនធី ដោយអនុលោមតាមផ្នែករង (a) នៃផ្នែកទី 3451 អាចកំណត់លក្ខខណ្ឌនៃការត្រួតពិនិត្យសមរម្យបន្ថែមទៀត ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី 3453 ដែលស្របជាមួយនឹងសុវត្ថិភាពសាធារណៈ រួមទាំងការប្រើប្រាស់នូវការត្រួតពិនិត្យ បែបអេឡិចត្រូនិចជាបន្តបន្ទាប់ ដូចដែលបានកំណត់នៅក្នុង ផ្នែកទី 1210.7 បង្គាប់បញ្ជាឲ្យមានការផ្តល់សេវាស្តារលទ្ធភាពពលកម្មឡើងវិញ និងសេវាព្យាបាលសមរម្យ កំណត់គ្រឿងលើកទឹកចិត្តសមរម្យ និងកំណត់ និងបង្គាប់បញ្ជាឲ្យមានការឆ្លើយតបសមរម្យចំពោះការរំលោភបំពាន ដែលបានចោទប្រកាន់ ដែលអាចរួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះការដាក់ទណ្ឌកម្មភ្លាមៗ មានរចនាសម្ព័ន្ធ និងពាក់កណ្តាលសម្រេច រហូតដល់ និងរួមបញ្ចូលទាំងការបញ្ជូនទៅកាន់តុលាការចូលកាន់កាប់វិញ ដោយអនុលោមតាមផ្នែកទី 3015 ឬការឃុំខ្លួនភ្លាមៗ នៅក្នុងពន្ធនាគារប្រចាំទីក្រុង ឬខោនធី។ រយៈពេលនៃការឃុំខ្លួនភ្លាមៗ ត្រូវបានលើកទឹកចិត្ត ថា ជាវិធីសាស្ត្រនៃការដាក់ទោសមួយសម្រាប់ការរំលោភបំពានទៅលើលក្ខខណ្ឌនៃការត្រួតពិនិត្យ ក្រោយការដោះលែងសម្រាប់ជនល្មើស។

(c) ដូចដែលបានប្រើប្រាស់នៅក្នុងចំណងជើងនេះ “ការឃុំខ្លួនភ្លាមៗ” គឺជារយៈពេលនៃការឃុំខ្លួន នៅក្នុងពន្ធនាគារប្រចាំទីក្រុង ឬខោនធី ដោយសារតែការរំលោភបំពានទៅលើលក្ខខណ្ឌនៃការត្រួតពិនិត្យក្រោយការដោះលែងសម្រាប់ជនល្មើស។ រយៈពេលនៃការឃុំខ្លួន អាចមានលំដាប់ចន្លោះពីមួយ ទៅនឹង 10 ថ្ងៃ ជាប់ៗគ្នា។ ការឃុំខ្លួនភ្លាមៗ គឺជាឧបករណ៍មួយដែលអាចត្រូវបានប្រើប្រាស់ដោយទីភ្នាក់ងារប្រចាំខោនធីនីមួយៗ ដែលទទួលខុសត្រូវចំពោះការត្រួតពិនិត្យក្រោយការដោះលែង។ រយៈពេលនៃការឃុំខ្លួនដែលកាន់តែខ្លីជាងមុន ប៉ុន្តែមិនចាំបាច់ត្រូវតែញឹកញាប់ជាងមុនសម្រាប់ការរំលោភបំពានរបស់ជនល្មើស ទៅលើលក្ខខណ្ឌនៃការត្រួតពិនិត្យក្រោយការដោះលែង ត្រូវដាក់ទោសឲ្យបានសមរម្យទៅលើជនល្មើស ដោយទប់ស្កាត់ការរំខាន នៅក្នុងគ្រឹះស្ថានការងារ ឬផ្ទះ ដែលជាទូទៅបណ្តាលមកពីការដកហូតរយៈពេលវែង។

(d) នៅពេលសម្រេចដើម្បីដាក់បង្ខំរយៈពេលនៃការឃុំខ្លួនភ្លាមៗ ក្រសួងដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ ត្រូវជូនដំណឹងដល់តុលាការ មេធាវីរដ្ឋ មេធាវីមណ្ឌល និងនគរបាល ដាក់បង្ខំឲ្យមានការឃុំខ្លួនភ្លាមៗនីមួយៗ។

ផ្នែកទី 4.8. ផ្នែកទី 3455 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្ម ដែលមានខ្លឹមសារដូចខាងក្រោម៖

3455. (a) ប្រសិនបើទីភ្នាក់ងារត្រួតពិនិត្យប្រចាំខោនធីបានកំណត់ក្រោយពីការអនុវត្តដំណើរការវាយតម្លៃរបស់ខ្លួនថា ការដាក់ទណ្ឌកម្ម ពាក់កណ្តាលសម្រេចដូចដែលបានអនុញ្ញាត ក្នុងផ្នែករង (b) នៃផ្នែកទី 3454 ពុំសមរម្យឡើយ *ឬ ប្រសិនបើជនដែលស្ថិតក្រោមការត្រួតពិនិត្យនោះ បានរំលោភបំពានទៅលើលក្ខខណ្ឌនៃការដោះលែងជន ដែលស្ថិតក្រោមការត្រួតពិនិត្យជាលើកទីបីនោះ* ទីភ្នាក់ងារត្រួតពិនិត្យប្រចាំខោនធី ត្រូវធ្វើញត្តិទាមទារ ទៅកាន់តុលាការដោយអនុលោមតាមផ្នែកទី 1203.2 ដើម្បីដកហូតកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យនៅក្នុងសហគមន៍ក្រោយការដោះលែង។ នៅចំណុចណាមួយអំឡុងពេល ដែលដំណើរការបានចាប់ផ្តើម ដោយអនុលោមតាមផ្នែកនេះ ជនណាម្នាក់អាចបោះបង់ជាលាយលក្ខណ៍អក្សរនូវសិទ្ធិរបស់ខ្លួន ក្នុងការពិគ្រោះយោបល់ សារភាពអំពីការរំលោភបំពានរបស់ខ្លួន ទៅលើការត្រួតពិនិត្យនៅក្នុងសហគមន៍ក្រោយការដោះលែង បោះបង់សិទ្ធិចូលសវនាការនៅតុលាការ និងទទួលយកការកែប្រែដែលបានស្នើសុំទៅលើការត្រួតពិនិត្យ នៅក្នុង សហគមន៍ក្រោយការដោះលែងរបស់ខ្លួន។ បណ្តឹងទាមទារត្រូវដាក់បញ្ចូលនូវរបាយការណ៍ជាលាយលក្ខណ៍អក្សរមួយ ដែលមានព័ត៌មានបន្ថែមពាក់ព័ន្ធនឹងញត្តិ រួមទាំងរយៈពេល និងលក្ខខណ្ឌពាក់ព័ន្ធនៃការត្រួតពិនិត្យ នៅក្នុងសហគមន៍ក្រោយការដោះលែង កាលៈទេសៈនៃការរំលោភបំពានជាមូលដ្ឋាន ដែលបានចោទប្រកាន់ប្រវត្តិ និងសាវតានៃអ្នករំលោភបំពាន និងរាល់អនុសាសន៍ផ្សេងៗ។ ក្រុមប្រឹក្សាយុត្តិធម៌ត្រូវជ្រើសយកទម្រង់ និងវិធានៃតុលាការក្នុងការបង្កើតនីតិវិធីឯកសណ្ឋានទូទាំងរដ្ឋ ដើម្បីអនុវត្តផ្នែករងនេះ រួមទាំងខ្លឹមសារអប្បបរិមានៃរបាយការណ៍របស់ទីភ្នាក់ងារត្រួតពិនិត្យ។ នៅពេលរកឃើញថា មានជនណាម្នាក់បានរំលោភបំពានទៅលើលក្ខខ័ណ្ឌនៃការត្រួតពិនិត្យនៅក្នុងសហគមន៍ក្រោយការដោះលែង មន្ត្រីសវនាការដកហូតសិទ្ធិ ត្រូវមានសិទ្ធិអំណាចក្នុងការធ្វើនូវកិច្ចការទាំងអស់ដូចតទៅ៖

(1) បញ្ជូនជននោះទៅកាន់ការត្រួតពិនិត្យក្នុងសហគមន៍ក្រោយការដោះលែង ដោយមានការកែប្រែលក្ខខណ្ឌទាំងឡាយ តាមការសមរម្យ រួមទាំងរយៈពេលនៃការឃុំខ្លួននៅក្នុងពន្ធនាគារប្រចាំខោនធីផងដែរ។

(2) ដកហូតសិទ្ធិ និងបញ្ចប់ការត្រួតពិនិត្យក្នុងសហគមន៍ក្រោយការដោះលែង និងបង្គាប់បញ្ជាឲ្យជននោះទទួលទោសនៅក្នុងពន្ធនាគារប្រចាំខោនធី។

(3) បញ្ជូនជននោះទៅកាន់តុលាការចូលកាន់កាប់វិញ ដោយអនុលោមតាមផ្នែកទី 3015 ឬកម្មវិធីផ្នែកលើភ័ស្តុតាងផ្សេងៗតាមឆន្ទានុសិទ្ធិរបស់តុលាការ។

(b) (1) នៅពេលណាក៏ដោយ អំឡុងពេលនៃការត្រួតពិនិត្យក្នុងសហគមន៍ក្រោយការដោះលែង ប្រសិនបើមន្ត្រីសន្តិភាពណាម្នាក់*រួមទាំងមន្ត្រីគ្រប់គ្រងការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ* មានមូលហេតុប្រហាក់ប្រហែលក្នុងការជឿជាក់ថា ជនដែលស្ថិតក្រោមការត្រួតពិនិត្យក្នុងសហគមន៍ក្រោយការដោះលែង កំពុងតែរំលោភបំពានទៅលើរយៈពេល ឬលក្ខខណ្ឌណាមួយនៃការដោះលែងរបស់ខ្លួន *ឬ ខកខានពុំបានមកបង្ហាញខ្លួននៅឯសវនាការ ដោយអនុលោមតាមផ្នែកទី 1203.2 ដើម្បីដកហូតសិទ្ធិ កែប្រែ ឬបញ្ចប់ការត្រួតពិនិត្យក្នុងសហគមន៍ក្រោយការដោះលែង* ដោយពុំចាំបាច់មានដីកា ឬដំណើរការផ្សេងៗ មន្ត្រីនោះអាចឃាត់ខ្លួនជននោះ ហើយនាំខ្លួនគាត់នៅចំពោះមុខទីភ្នាក់ងារត្រួតពិនិត្យប្រចាំខោនធី ដែលបានបង្កើតឡើងដោយគណៈកម្មការអ្នកត្រួតពិនិត្យប្រចាំខោនធី ដោយអនុលោមតាមផ្នែករង (a) នៃផ្នែកទី 3451។ បន្ថែមពីលើនេះទៀត មន្ត្រីណាម្នាក់ដែលបានជួលដោយទីភ្នាក់ងារត្រួតពិនិត្យប្រចាំខោនធី អាចស្វែងរកដីកា និងតុលាការណាមួយ ឬមន្ត្រីសវនាការដែលបានចាត់តាំង ដែលត្រូវបានតែងតាំងដោយអនុលោមតាមផ្នែកទី 71622.5 នៃក្រមរដ្ឋាភិបាល ត្រូវមានសិទ្ធិក្នុងការចេញដីកាសម្រាប់ការចាប់ខ្លួនជនល្មើសនោះ។

(2) តុលាការ ឬមន្ត្រីសវនាការដែលបានចាត់តាំង ត្រូវមានសិទ្ធិអំណាចក្នុងការចេញដីកាសម្រាប់ជនល្មើសដែលស្ថិតក្រោមបណ្តឹងទាមទារមួយដែលបានដាក់ក្រោមផ្នែកនេះ ដែលបានខកខានមិនមកបង្ហាញខ្លួនសម្រាប់សវនាការទៅលើបណ្តឹងទាមទារ ឬដោយសារមូលហេតុអ្វីមួយដែលជាប្រយោជន៍នៃភាពយុត្តិធម៌ ឬដើម្បីបញ្ជូនត្រឡប់ទៅឲ្យគ្រប់គ្រងជនល្មើសដែលបានបង្ហាញខ្លួននៅឯសវនាការតាមបណ្តឹងទាមទារស្រាប់មូលហេតុអ្វីមួយដើម្បីជាប្រយោជន៍នៃភាពយុត្តិធម៌។

(3) ប្រសិនបើជនល្មើសដែលស្ថិតក្រោមការត្រួតពិនិត្យក្នុងសហគមន៍ក្រោយការដោះលែងកំពុងស្ថិតក្រោមរយៈពេលនៃការឃុំខ្លួនភ្លាមៗ នៅពេលដែលជនណាម្នាក់ដែលស្ថិតក្រោមផ្នែកនេះត្រូវបានចាប់ខ្លួនដោយមាន ឬគ្មានដីកា ឬការដាក់ បណ្តឹងទាមទារសុំការដកហូតសិទ្ធិនោះ តុលាការអាចបង្គាប់បញ្ជាឲ្យដោះលែងជននោះក្រោមការត្រួតពិនិត្យពីការគ្រប់គ្រងក្រោមរយៈពេល និងលក្ខខណ្ឌទាំងឡាយដែលតុលាការចាត់ទុកថាសមរម្យ។

(c) សវនាការដកហូតសិទ្ធិ ត្រូវធ្វើឡើងនៅក្នុងរយៈពេលសមរម្យមួយក្រោយពីបានដាក់ញត្តិដកហូតសិទ្ធិ។ លើកលែងតែដូចមានចែងនៅក្នុងកថាខណ្ឌទី (3) នៃផ្នែករង (b) ដោយផ្អែកទៅលើការបង្ហាញភាពលុបលើគេឯងនៃភ័ស្តុតាងដែលថា ជនល្មើសដែលស្ថិតក្រោមការត្រួតពិនិត្យបង្ករនូវហានិភ័យមិនសមហេតុផលចំពោះសុវត្ថិភាពសាធារណជន ឬដែលថា ជនល្មើសនោះអាចជានឹងមិនបង្ហាញខ្លួន ប្រសិនបើត្រូវបានដោះលែងចេញពីការគ្រប់គ្រង ឬដោយសារហេតុផលណាមួយដែលជាប្រយោជន៍នៃភាពយុត្តិធម៌នោះ ទីភ្នាក់ងារត្រួតពិនិត្យប្រចាំខោនធីត្រូវមានសិទ្ធិអំណាចក្នុងការធ្វើការកំណត់ថាតើជននោះគួរនៅតែស្ថិតនៅក្នុងការគ្រប់គ្រងដែលមិនទាន់បានបង្ហាញខ្លួននៅតុលាការលើកទីមួយទៅលើញត្តិមួយ ដើម្បីដកហូតសិទ្ធិការត្រួតពិនិត្យក្នុងសហគមន៍ក្រោយការដោះលែង ហើយនៅពេលកំណត់នោះ អាចបង្គាប់បញ្ជាឲ្យជនល្មើសដែលត្រូវបានឃុំឃាំងនៅមិនទាន់បានបង្ហាញខ្លួននៅតុលាការលើកទីមួយ។

(d) ការឃុំឃាំងដោយអនុលោមតាមកថាខណ្ឌទី (1) និង (2) នៃផ្នែករង (a) មិនត្រូវលើសពីរយៈពេល 180 ថ្ងៃនៅក្នុងពន្ធនាគារប្រចាំខោនធីសម្រាប់ការដាក់ក្នុងពន្ធនាគារមួយលើកៗ។

(e) ជនណាម្នាក់មិនត្រូវនៅតែស្ថិតក្រោមការត្រួតពិនិត្យ ឬស្ថិតក្រោមការគ្រប់គ្រងដោយអនុលោមតាមការទាមទារដ៏ត្រឹមត្រូវនេះនៅពេលឬក្រោយពេលបីឆ្នាំ ដោយគិតចាប់ពីថ្ងៃចូលទៅក្នុងការត្រួតពិនិត្យក្នុងសហគមន៍ក្រោយការដោះលែងដំបូងសម្រាប់ជនល្មើសឡើយ លើកលែងតែនៅពេលដែលការត្រួតពិនិត្យរបស់ជននោះត្រូវបានប្រកាសឲ្យដឹងដោយអនុលោមតាមផ្នែកទី 1203.2 ឬផ្នែករង (b) នៃផ្នែកទី 3456។

ផ្នែកទី 5. ការប្រមូល DNA.

ផ្នែកទី 5.1. ផ្នែកទី 296 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្ម ដែលមានខ្លឹមសារដូចខាងក្រោម៖

296. (a) ជនទាំងឡាយខាងក្រោមនេះ ត្រូវផ្តល់សំណាកពីជញ្ជាំងថ្ពាល់ មេដៃស្តាំ និងផ្ទិតស្នាមបាតដៃទាំងសងខាង និងសំណាកឈាម ឬសំណាកជីវសាស្ត្រផ្សេងៗដែលត្រូវបានតម្រូវដោយអនុលោមតាមជំពូកនេះ សម្រាប់ការវិភាគកំណត់អត្តសញ្ញាណដោយទីភ្នាក់ងារអនុវត្តច្បាប់៖

(1) ជនណាម្នាក់ រួមទាំងអនីតិជន ដែលត្រូវបានផ្តន្ទាទោសពីបទ ឬរកឃើញទោសកំហុស ឬ គ្មានការជំទាស់ទៅនឹងបទឧក្រិដ្ឋណាមួយ ឬត្រូវបានរកឃើញថាគ្មានកំហុសដោយសារមូលហេតុឆ្គួតវង្វេងនឹងបទឧក្រិដ្ឋ ឬអនីតិជនណាម្នាក់ដែលត្រូវបានកាត់សេចក្តីក្រោមផ្នែកទី 602 នៃក្រមសុខុមាលភាព និងស្ថាប័នសម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋ។

(2) នីតិជនណាម្នាក់ដែលត្រូវបានចាប់ខ្លួនដោយសារ ឬត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយដូចខាងក្រោម៖

(A) រាល់បទឧក្រិដ្ឋដែលបានបញ្ជាក់នៅក្នុងផ្នែកទី 290 ឬប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋណាមួយដែលមានរៀបរាប់នៅក្នុងផ្នែកទី 290 ឬបទឧក្រិដ្ឋណាមួយដែលដាក់បង្ខំឲ្យជនល្មើសនូវកាតព្វកិច្ចក្នុងការចុះឈ្មោះនៅរដ្ឋ California ថាជាជនល្មើសផ្លូវភេទក្រោមផ្នែកទី 290។

(B) អំពើឃាតកម្ម ឬចេតនាធ្វើឃាតដោយស្ម័គ្រចិត្ត ឬការប៉ុនប៉ងប្រព្រឹត្តអំពើឃាតកម្ម ឬចេតនាធ្វើឃាតដោយស្ម័គ្រចិត្ត។

(C) ចាប់ពីថ្ងៃទី ~~1 ខែមករា នៃឆ្នាំទីប្រាំ ដោយពីបានអនុម័តច្បាប់ដែលបានបន្ថែមកថាខណ្ឌរងនេះ ដូចដែលបានធ្វើវិសោធនកម្ម~~ *ថ្ងៃទី 1 ឆ្នាំ 2009* រាល់នីតិជនណាម្នាក់ដែលត្រូវបានចាប់ខ្លួន ឬចោទប្រកាន់ពីបទឧក្រិដ្ឋអ្វីមួយ។

(3) ជនណាម្នាក់ រួមទាំងអនីតិជនណាម្នាក់ ដែលត្រូវបានតម្រូវឲ្យចុះឈ្មោះក្រោមផ្នែកទី 290 *ដល់ 290.009 ដែលបានរាប់បញ្ចូល* ឬ *ផ្នែកទី* 457.1 ដោយសារតែការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈឹម ឬជនណាម្នាក់ រួមទាំងអនីតិជនដែលសម្រាកនៅក្នុងមន្ទីរថែទាំសុខភាពផ្លូវចិត្ត ឬកម្មវិធីព្យាបាលជនល្មើសផ្លូវភេទ បន្ទាប់ពីត្រូវបានបញ្ជូនទៅកាន់មន្ទីរថែទាំ ឬកម្មវិធីនោះដោយតុលាការ បន្ទាប់ពីត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ។

(4) ជនណាម្នាក់ ដោយមិនរាប់បញ្ចូលទាំងអនីតិជន ដែលត្រូវបានផ្តន្ទាទោស ឬរកឃើញទោសកំហុស ឬ គ្មានការជំទាស់ទៅនឹងបទឧក្រិដ្ឋណាមួយ បទឧក្រិដ្ឋណាមួយដូចខាងក្រោម៖

(A) ការរំលោភបំពានបទមជ្ឈឹមនៃផ្នែកទី 459.5។

(B) ការរំលោភបំពានផ្នែករង (a) នៃផ្នែកទី 473 ដែលអាចផ្តន្ទាទោសបានថាជាបទមជ្ឈឹមដោយអនុលោមតាមផ្នែករង (b) នៃផ្នែកទី 473។

20

(C) ការរំលោភបំពានផ្នែករង (a) នៃផ្នែកទី 476a ដែលអាចផ្តន្ទាទោសបានថាជាបទមជ្ឈឹមដោយអនុលោមតាមផ្នែករង (b) នៃផ្នែកទី 476a។

(D) ការរំលោភបំពានទៅលើផ្នែកទី 487 ដែលអាចផ្តន្ទាទោសបានថាជាបទមជ្ឈឹមដោយអនុលោមតាមផ្នែកទី 490.2។

(E) ការរំលោភបំពានទៅលើផ្នែកទី 496 ដែលអាចផ្តន្ទាទោសបានថាជាបទមជ្ឈឹម។

(F) ការរំលោភបំពានបទមជ្ឈឹមទៅលើផ្នែករង (a) នៃផ្នែកទី 11350 នៃក្រមស្តីពីសុខភាព និងសុវត្ថិភាព។

(G) ការរំលោភបំពានបទមជ្ឈឹមទៅលើផ្នែករង (a) នៃផ្នែកទី 11377 នៃក្រមស្តីពីសុខភាព និងសុវត្ថិភាព។

(H) ការរំលោភបំពានបទមជ្ឈឹមទៅលើកថាខណ្ឌទី (1) នៃផ្នែករង (e) នៃផ្នែកទី 243។

(I) ការរំលោភបំពានបទមជ្ឈឹមទៅលើផ្នែកទី 273.5។

(J) ការរំលោភបំពានបទមជ្ឈឹមទៅលើកថាខណ្ឌទី (1) នៃផ្នែករង (b) នៃផ្នែកទី 368។

(K) ការរំលោភបំពានបទមជ្ឈឹម នៅពេលដែលជនរងគ្រោះត្រូវបានបដិសេធ ដូចមានចែងនៅក្នុងផ្នែកទី 6211 នៃក្រមគ្រួសារ។

(L) ការរំលោភបំពានបទមជ្ឈឹមទៅលើកថាខណ្ឌទី (3) នៃផ្នែករង (b) នៃផ្នែកទី 647។

~~(4)~~ *(5)* ពាក្យថា "បទឧក្រិដ្ឋ" ដូចដែលត្រូវបានប្រើប្រាស់នៅក្នុងផ្នែករងនេះ រួមបញ្ចូលទាំងការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ។

~~(5)~~ *(6)* គ្មានអ្វីមួយនៅក្នុងជំពូកនេះត្រូវបានបកស្រាយថា ជាការហាមឃាត់នូវការប្រមូល និងការវិភាគសំណាក គំរូ ឬការផ្ទិតម្រាមដៃថាជាលក្ខខណ្ឌមួយនៃ ចម្លើយថាទទួល ឬមិនទទួលបទល្មើសដែលគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

20

(b) បទបញ្ញត្តិទាំងឡាយនៃជំពូកនេះ និងលក្ខខណ្ឌតម្រូវរបស់វាសម្រាប់ការដាក់ស្នើសំណាក គំរូ និងស្នាមម្រាមដៃឲ្យបានឆាប់តាមដែលអាចអនុវត្តបានតាមក្បួនរដ្ឋបាល ត្រូវអនុវត្តទៅលើជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងអស់ ដោយមិនគិតពីទោសដែលត្រូវបានដាក់បង្ខំ រួមទាំងការកាត់ទោសរហូតដល់ស្លាប់ អស់មួយជីវិតដោយគ្មានលទ្ធភាពនៃការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ ឬរយៈពេលមួយជីវិត ឬពាក់កណ្តាលសម្រេច ឬការចាត់របៀបដែលបានផ្តល់ឲ្យ ករណីជានីតិជន ឬអនីតិជនដែលត្រូវបានជំនុំជម្រះទោសដូចនីតិជន ឬថាតើជននោះ ត្រូវបានបន្ទំ ពិន័យ ឬបញ្ជូនទៅឲ្យធ្វើការវាយតម្លៃ និងដោយមិនគិតពីការចាត់របៀបដែលបានផ្តល់ឲ្យ ឬការដាក់ជំនួសដែលបានធ្វើឡើងករណី *ជា* អនីតិជនដែលត្រូវបានរកឃើញថាបានប្រព្រឹត្តបទឧក្រិដ្ឋ ឬត្រូវបានកាត់សេចក្តីក្រោមផ្នែកទី 602 នៃក្រមស្តីពីសុខុមាលភាព និងស្ថាប័ន។

(c) បទបញ្ញត្តិទាំងឡាយនៃជំពូកនេះ និងលក្ខខណ្ឌតម្រូវរបស់វាសម្រាប់ការដាក់ស្នើភិនភាគ សំណាក និងស្នាមម្រាមដៃឲ្យបានឆាប់តាមដែលអាចអនុវត្តបានតាមក្បួនរដ្ឋបាល ដោយជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានរៀបរាប់នៅក្នុងផ្នែករង (a) ត្រូវបានអនុវត្តដោយមិនគិតពីការដាក់ជំនួស ឬការឃុំឃាំងនៅក្នុងមន្ទីរពេទ្យផ្លូវចិត្ត ឬមន្ទីរព្យាបាលសាធារណៈ ឬឯកជនណាមួយ ហើយត្រូវរួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះជនទាំងឡាយខាងក្រោម រួមទាំងអនីតិជន៖

(1) ជនណាម្នាក់ដែលត្រូវបានបង្ខាំងនៅក្នុងមន្ទីរពេទ្យរដ្ឋ ឬមន្ទីរព្យាបាលផ្សេងទៀតក្នុងនាមជាជនល្មើសផ្លូវចិត្តដែលមានវិបត្តិផ្លូវចិត្ត ក្រោមមាត្រា 1 (ចាប់ផ្តើមជាមួយនឹងផ្នែកទី 6300) នៃជំពូកទី 2 នៃផ្នែកទី 2 នៃចំណែកទី 6 នៃក្រមស្តីពីសុខុមាលភាព និងស្ថាប័ន។

(2) ជនណាម្នាក់ដែលមានវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរដូចមានចែងនៅក្នុងបទបញ្ញត្តិទាំងឡាយនៃមាត្រា 4 (ចាប់ផ្តើមជាមួយនឹងផ្នែកទី 2960) នៃជំពូកទី 7 នៃចំណងជើងទី 1 នៃផ្នែកទី 3 នៃក្រមព្រហ្មទណ្ឌ។

(3) ជនណាម្នាក់ដែលត្រូវបានរកឃើញថាជាអ្នកប្រព្រឹត្តអំពើហិង្សាផ្លូវភេទដោយអនុលោមតាមមាត្រា 4 (ចាប់ផ្តើមជាមួយនឹងផ្នែកទី 6600) នៃជំពូកទី 2 នៃផ្នែកទី 2 នៃចំណែកទី 6 នៃក្រមស្តីពីសុខុមាលភាព និងស្ថាប័ន។

(d) បទបញ្ញត្តិទាំងឡាយនៃជំពូកនេះមានលក្ខណៈចាំបាច់ ហើយត្រូវបានអនុវត្ត ទោះបីជាតុលាការបានជូនដំណឹងដល់ជនល្មើសណាម្នាក់ក៏ដោយ រួមទាំងអនីតិជនផងដែរ ដែលពួកគេត្រូវតែផ្តល់នូវធនាគារទិន្នន័យ និងភិនភាគ សំណាក និងស្នាមម្រាមដៃពីមូលដ្ឋានទិន្នន័យថាជាលក្ខខណ្ឌនៃការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ ឬការឆ្លើយតបនឹងបទចោទប្រកាន់ថាមានទោស គ្មានការជំទាស់ ឬគ្មានទោសដោយហេតុផលឆ្គួតវង្វេង ឬការសារភាពណាមួយចំពោះបទល្មើសដែលមានរៀបរាប់នៅក្នុងផ្នែករង (a)។

(e) ប្រសិនបើនៅដំណាក់កាលណាមួយនៃដំណើរការរឿងក្តីតុលាការ មេធាវីចោទប្រកាន់កំណត់ថា ភិនភាគ សំណាក និងស្នាមម្រាមដៃដែលត្រូវបានតម្រូវដោយជំពូកនេះ ពុំត្រូវបានយកពីជនល្មើសណាម្នាក់ ដូចមានកំណត់ក្រោមផ្នែករង (a) នៃផ្នែកទី 296 នោះ មេធាវីចោទប្រកាន់ត្រូវជូនដំណឹងដល់តុលាការដោយផ្ទាល់មាត់នៅលើកំណត់ហេតុ ឬជាលាយលក្ខណ៍អក្សរ និងស្នើសុំថា តុលាការត្រូវបង្គាប់បញ្ជាឲ្យប្រមូលសំណាក គំរូ និងស្នាមម្រាមដៃតាមការតម្រូវដោយច្បាប់។ ទោះជាយ៉ាងណា ការខកខានដោយមេធាវីចោទប្រកាន់ ឬទីភ្នាក់ងារអនុវត្តច្បាប់ក្នុងការជូនដំណឹងដល់តុលាការ មិនត្រូវដោះលែងជនល្មើសដែលជាប់កាតព្វកិច្ចត្រូវផ្តល់ភិនភាគ សំណាក និងស្នាមម្រាមដៃដោយអនុលោមតាមជំពូកនេះ។

(f) មុនពេលការចាត់របៀប ឬកាត់ទោសជាស្ថាពរនៅក្នុងករណីដែលតុលាការត្រូវសើបសួរ និងផ្ទៀងផ្ទាត់ថា ភិនភាគ សំណាក និងស្នាមម្រាមដៃដែលត្រូវបានតម្រូវដោយជំពូកនេះត្រូវបានទទួលហើយនោះ ហើយអង្គហេតុនេះត្រូវបានដាក់បញ្ចូលនៅក្នុងសម្រង់សាលក្រម ឬដីកាចាត់របៀប ករណីជាអនីតិជន។ សម្រង់សាលក្រមដែលបានចេញដោយតុលាការ ត្រូវបញ្ជាក់ថា តុលាការបានបង្គាប់បញ្ជាឲ្យជនល្មើសនោះអនុលោមតាមលក្ខខណ្ឌតម្រូវនៃជំពូកនេះ ហើយជនល្មើសនោះត្រូវដាក់បញ្ចូលនៅក្នុងកម្មវិធីមូលដ្ឋានទិន្នន័យកំណត់អត្តសញ្ញាណ DNA និងទាក់ទងនឹងច្បាប់ និងកម្មវិធីធនាគារទិន្នន័យ ហើយត្រូវស្ថិតក្រោមជំពូកនេះ។

ទោះជាយ៉ាងណា ការខកខានដោយតុលាការក្នុងការផ្ទៀងផ្ទាត់ការប្រមូលភិនភាគ សំណាក និងស្នាមម្រាមដៃ ឬបញ្ចូលអង្គហេតុទាំងនេះទៅក្នុងសម្រង់សាលក្រម ឬដីកាចាត់របៀប ករណីជាអនីតិជន មិនត្រូវធ្វើជាមោឃៈនូវការចាប់ខ្លួន ការឆ្លើយតបចំពោះបទចោទប្រកាន់ថាមានទោស ការផ្តន្ទាទោស ឬការចាត់របៀប ឬបន្ធូរបន្ថយដល់ជនល្មើសណាម្នាក់ពីលក្ខខណ្ឌតម្រូវនៃជំពូកនេះ។

ផ្នែកទី 6. ការលួចឥវ៉ាន់តាមហាង។

ផ្នែកទី 6.1. ផ្នែកទី 459.5 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្ម ដែលមានខ្លឹមសារដូចខាងក្រោម៖

459.5. (a) ថ្មីបើមានផ្នែកទី 459 ក៏ដោយ ការលួចឥវ៉ាន់តាមហាងត្រូវបានកំណត់ថាជាការចូលទៅក្នុងគ្រឹះស្ថានពាណិជ្ជកម្មណាមួយ ដោយមានចេតនា ~~ប្រព្រឹត្តអំពើចោរកម្ម~~ *លួចយកទ្រព្យសម្បត្តិ ឬទំនិញលក់រាយ* ខណៈដែលគ្រឹះស្ថាននោះកំពុងបើកទ្វារដំណើរការអំឡុងម៉ោងអាជីវកម្មជាធម្មតា ដែលតម្លៃនៃទ្រព្យសម្បត្តិដែលបានលួចយក ឬមានចេតនាលួចយក មិនលើសពីប្រាំបួនរយហាសិបដុល្លារ ($950)។ ការចូលទៅក្នុងគ្រឹះស្ថានពាណិជ្ជកម្មណាមួយផ្សេងទៀត ដោយមានចេតនាប្រព្រឹត្តអំពើចោរកម្ម គឺជាការលបចូលលួច។ ការលួចឥវ៉ាន់តាមហាងត្រូវផ្តន្ទាទោសពីបទមជ្ឈឹម លើកលែងតែជនល្មើសនោះ ដែលមានការកាត់ទោសពីបទល្មើសពីមុនមកចាប់ពីមួយឡើងទៅ ដូចមានបញ្ជាក់នៅក្នុង ខទី (iv) នៃកថាខណ្ឌរង (C) នៃកថាខណ្ឌទី (2) នៃផ្នែករង (e) នៃផ្នែកទី 667 ឬសម្រាប់បទល្មើសដែលតម្រូវឲ្យមានការចុះបញ្ជីដោយ

អនុលោមតាមផ្នែករង (c) នៃផ្នែកទី 290 អាចត្រូវបានផ្តន្ទាទោសដោយអនុលោមតាមផ្នែករង (h) នៃផ្នែកទី 1170។

(b) រាល់អំពើលួចឥវ៉ាន់តាមហាងដូចដែលបានកំណត់នៅក្នុងផ្នែករង (a) ត្រូវចោទប្រកាន់ថាជាការលួចឥវ៉ាន់តាមហាង។ គ្មានជនល្មើសណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទលួចឥវ៉ាន់តាមហាងអាចត្រូវបានចោទប្រកាន់ផងដែរពីបទលបចូលលួច ឬចោរកម្មទៅលើទ្រព្យសម្បត្តិដូចគ្នានោះឡើយ។

(c) "ទ្រព្យសម្បត្តិ ឬទំនិញរាយ" មានន័យថា រាល់ទំនិញ ផលិតផល របស់ប្រើប្រាស់ សម្ភារ ឬសមាសភាពដែលមានបំណងចង់ដាក់លក់នៅក្នុងគ្រឹះស្ថានពាណិជ្ជកម្មលក់រាយ។

(d) "តម្លៃ" មានន័យថា តម្លៃរាយនៃសម្ភារណាមួយ ដែលត្រូវបានផ្សាយពាណិជ្ជកម្មលក់ដោយគ្រឹះស្ថានលក់រាយដែលរងការប៉ះពាល់ រួមទាំងពន្ធជាធរមានផងដែរ។

(e) ផ្នែកនេះ មិនត្រូវបានអនុវត្តចំពោះអំពើចោរកម្មកាំភ្លើង ការក្លែងបន្លំ ការលក់ខុសច្បាប់ ការផ្ទេរ ឬការផ្តល់នូវកាតចូលដំណើរការដោយអនុលោមតាមផ្នែកទី 484e ការក្លែងបន្លំកាតចូលដំណើរការដោយអនុលោមតាមផ្នែកទី 484f ការប្រើប្រាស់ដោយខុសច្បាប់នូវកាតចូលដំណើរការដោយអនុលោមតាមផ្នែកទី 484g អំពើចោរកម្មពីមនុស្សចាស់ជរាដោយអនុលោមតាមផ្នែករង (e) នៃផ្នែកទី 368 ការទទួលទ្រព្យដែលបានលួច ការបន្លំលួចយកប្រាក់ ឬការលួចអត្តសញ្ញាណដោយអនុលោមតាមផ្នែកទី 530.5 ឬអំពើចោរកម្ម ឬការប្រើប្រាស់យានយន្តដោយគ្មានការអនុញ្ញាត ដោយអនុលោមតាមផ្នែកទី 10851 នៃក្រមស្តីពីយានយន្ត។

ផ្នែកទី 6.2. ផ្នែកទី 490.2 នៃក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្ម ដែលមានខ្លឹមសារដូចខាងក្រោម៖

490.2. (a) ថ្មីបើមានផ្នែកទី 487 ឬបទបញ្ញត្តិផ្សេងទៀតនៃច្បាប់ដែលកំណត់នូវអំពើចោរកម្មធំៗក็ដោយ ការទទួលទ្រព្យដោយអំពើចោរកម្ម នៅពេលដែលតម្លៃនៃលុយ ពលកម្ម អចលនទ្រព្យ ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលត្រូវបានលួចយកទៅមិនលើសពីប្រាំបួនរយហាសិបដុល្លារ ($950) ត្រូវចាត់ទុកថាជាអំពើចោរកម្មតូចតាច ហើយត្រូវផ្តន្ទាទោសជាបទមជ្ឈឹម លើកលែងតែជនល្មើសនោះអាចត្រូវបានកាត់ទោសជំនួសដោយអនុលោមតាមផ្នែករង (h) នៃផ្នែកទី 1170 ប្រសិនបើជនល្មើសនោះមានការកាត់ទោសពីបទល្មើសពីមុនមកចាប់ពីមួយឡើងទៅ ដូចមានបញ្ជាក់នៅក្នុង ខទី (iv) នៃកថាខណ្ឌរង (C) នៃកថាខណ្ឌទី (2) នៃផ្នែករង (e) នៃផ្នែកទី 667 ឬសម្រាប់បទល្មើសដែលតម្រូវឲ្យមានការចុះបញ្ជីដោយអនុលោមតាមផ្នែករង (c) នៃផ្នែកទី 290។

(b) ផ្នែកនេះមិនត្រូវបានអនុវត្តចំពោះអំពើរចោរកម្មណាមួយដែលអាចត្រូវបានចោទប្រកាន់ជាបទល្មើសមួយដែលអនុលោមតាមបទបញ្ញត្តិច្បាប់ណាមួយផ្សេងទៀតឡើយ។

(c) ផ្នែកនេះ មិនត្រូវបានអនុវត្តចំពោះអំពើរចោរកម្មប្រដាប់អាវុធ*ការក្លែងបន្លំ ការលក់ខុសច្បាប់ ការផ្ទេរ ឬការផ្តល់នូវកាតចូលដំណើរការដោយអនុលោមតាមផ្នែកទី 484e ការក្លែងបន្លំកាតចូលដំណើរការដោយអនុលោមតាមផ្នែកទី 484f ការប្រើប្រាស់ដោយខុសច្បាប់នូវកាតចូលដំណើរការដោយអនុលោមតាមផ្នែកទី 484g អំពើរចោរកម្មពីមនុស្សចាស់ជរាដោយអនុលោមតាមផ្នែករង (e) នៃផ្នែកទី 368 ការទទួលទ្រព្យដែលបានលួច ការបន្លំលួចយកប្រាក់ ឬការលួចអត្តសញ្ញាណដោយអនុលោមតាមផ្នែកទី 530.5 ឬអំពើរចោរកម្ម ឬការប្រើប្រាស់យានយន្តដោយគ្មានការអនុញ្ញាត ដោយអនុលោមតាមផ្នែកទី 10851 នៃក្រមស្តីពីយានយន្ត។*

ផ្នែកទី 7. ចោរកម្មជាស៊េរី

ផ្នែកទី 7.1. ផ្នែកទី 490.3 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌដែលមានខ្លឹមសារដូចខាងក្រោម៖

490.3. (a) ផ្នែកនេះត្រូវបានអនុវត្តចំពោះបទល្មើសព្រហ្មទណ្ឌដូចខាងក្រោម៖

(1) ចោរកម្មខ្នាតតូច។

(2) ការលួចឥវ៉ាន់ក្នុងហាង។

(3) ចោរកម្មខ្នាតធំ។

(4) ការលបចូលលួច។

(5) ការប្លន់ឡាន។

(6) ការប្លន់។

(7) បទល្មើសព្រហ្មទណ្ឌចំពោះមនុស្សចាស់ជរា ឬនីតិជនក្នុងបន្ទុកនៅក្នុងអត្ថន័យផ្នែករង (d) ឬ (e) នៃផ្នែករងទី 368។

(8) រាល់ការរំលោភបំពានណាមួយទៅលើផ្នែកទី 496។

(9) ការយក ឬការបើកបរដោយខុសច្បាប់នូវយានយន្តណាមួយនៅក្នុងអត្ថន័យនៃផ្នែកទី 10851 នៃក្រមស្តីពីយានយន្ត។

(10) ការក្លែងបន្លំ។

(11) ការលក់ ការផ្ទេរ ឬការផ្តល់នូវកាតចូលដំណើរការដោយខុសច្បាប់ដោយអនុលោមតាមផ្នែកទី 484e។

(12) ការក្លែងបន្លំកាតចូលដំណើរការដោយអនុលោមតាមផ្នែកទី 484f។

(13) ការប្រើប្រាស់ដោយខុសច្បាប់នូវកាតចូលដំណើរការដោយអនុលោមតាមផ្នែកទី 484g។

(14) ការលួចអត្តសញ្ញាណដោយអនុលោមតាមផ្នែកទី 530.5។

(15) អំពើរចោរកម្ម ឬការប្រើប្រាស់ដោយគ្មានការអនុញ្ញាតនូវយានយន្ត ដោយអនុលោមតាមផ្នែកទី 10851 នៃក្រមស្តីពីយានយន្ត។

(b) ថ្មីបើមានកថាខណ្ឌទី (3) នៃផ្នែករង (h) នៃផ្នែកទី 1170, កថាខណ្ឌទី (2) និង (4) នៃផ្នែករង (a) នៃផ្នែកទី 1170.12, កថាខណ្ឌទី (2) និង (4) នៃផ្នែករង (c) នៃផ្នែកទី 667 រាល់ជនល្មើសទាំងឡាយដែល កន្លងមកត្រូវបានផ្តន្ទាទោសពីបទល្មើសពីរ ឬច្រើនដូចមានបញ្ជាក់នៅក្នុងផ្នែករង (a) ដែលបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តនៅឱកាសដាច់ដោយឡែកពីគ្នា ហើយជាអ្នកដែលត្រូវបានផ្តន្ទាទោសជាបន្តបន្ទាប់ពីបទអំពើរចោរកម្មខ្នាតតូច ឬការលួចឥវ៉ាន់ក្នុងហាង នៅពេលដែលតម្លៃនៃលុយ ពលកម្ម អចលនទ្រព្យ ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលត្រូវបានលួចយកទៅលើសពីពីررយហាសិបដុល្លារ ($250) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមិនលើសពីមួយឆ្នាំ ឬដាក់ពន្ធនាគារដោយអនុលោមតាមផ្នែករង (h) នៃផ្នែកទី 1170។

(c) ផ្នែកនេះមិនហាមឃាត់ជនល្មើសណាម្នាក់ ឬច្រើននាក់ពីការចោទប្រកាន់ពីការរំលោភបំពានច្បាប់ដែលកើតចេញពីប្រតិបត្តិការបទល្មើសព្រហ្មទណ្ឌដូចគ្នា ដែលរំលោភបំពានទៅលើផ្នែកនេះឡើយ។

ផ្នែកទី 8. ចោរកម្មនៅហាងលក់រាយដោយមានការរៀបចំ។

ផ្នែកទី 8.1. ផ្នែកទី 490.4 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌដែលមានខ្លឹមសារដូចខាងក្រោម៖

490.4. (a) "ទ្រព្យសម្បត្តិ ឬទំនិញរាយ" មានន័យថា រាល់ទំនិញ ផលិតផល របស់ប្រើប្រាស់ សម្ភារ ឬសមាសភាពដែលមានបំណងចង់ដាក់លក់នៅក្នុងគ្រឹះស្ថានពាណិជ្ជកម្មលក់រាយ។

(b) "តម្លៃ" មានន័យថា តម្លៃរាយនៃសម្ភារណាមួយ ដែលត្រូវបានផ្សាយពាណិជ្ជកម្មលក់ដោយគ្រឹះស្ថានលក់រាយដែលរងការប៉ះពាល់ រួមទាំងពន្ធជាធរមានផងដែរ។

(c) ជនណាម្នាក់ដែលប្រព្រឹត្តជាមួយជនដទៃទៀត ម្នាក់ ឬច្រើននាក់ ដែលប្រព្រឹត្តអំពើចោរកម្មពីررដង ឬច្រើនជាងនេះ ដោយអនុលោមតាម

20

ផ្នែកទី 459.5 ឬ 490.2 នូវទ្រព្យសម្បត្តិ ឬទំនិញរាយ ដែលមានតម្លៃសរុបលើសពីពីរយហាសិបដុល្លារ ($250) និងយកទ្រព្យសម្បត្តិនេះដោយខុសច្បាប់ក្នុងរយៈពេល 180 ត្រូវបានចោទប្រកាន់ពីបទចោរកម្ម នៅហាងលក់រាយដោយមានការរៀបចំ។

(d) ថ្វីបើមានកថាខណ្ឌទី (3) នៃផ្នែករង (h) នៃផ្នែកទី 1170, កថាខណ្ឌទី (2) និង (4) នៃផ្នែករង (a) នៃផ្នែកទី 1170.12, កថាខណ្ឌទី (2) និង (4) នៃផ្នែករង (c) នៃផ្នែកទី 667 ចោរកម្មនៅហាងលក់រាយដោយមានការរៀបចំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមិនលើសពីមួយឆ្នាំ ឬដាក់ពន្ធនាគារដោយអនុលោមតាមផ្នែករង (h) នៃផ្នែកទី 1170។

(e) សម្រាប់គោលបំណងនៃផ្នែកនេះ តម្លៃនៃទ្រព្យសម្បត្តិរាយដែលបានលួចយកទៅដោយជនល្មើសទាំងឡាយណាដែលប្រព្រឹត្តជាក្រុម អាចត្រូវបានសរុបទៅជាចំនួន ឬបទចោទប្រកាន់តែមួយ ដែលមានចំនួនសរុបតម្លៃស្មើនឹងទំនិញរាយទាំងអស់ដែលជាតម្លៃដែលត្រូវបានពិចារណានៅក្នុងការកំណត់អំពីកម្រិតនៃអំពើចោរកម្ម។

(f) បទល្មើសក្រោមផ្នែកនេះ អាចត្រូវបានកាត់ទោសនៅក្នុងខោនធីណាមួយដែលអំពើរចោរកម្មជាមូលដ្ឋានអាចត្រូវបានកាត់ទោសជាបទល្មើសដាច់ដោយឡែកពីគ្នា។

(g) ផ្នែកនេះមិនហាមឃាត់ជនល្មើសណាម្នាក់ ឬច្រើននាក់ពីការចោទប្រកាន់ពីការរំលោភបំពានច្បាប់ដែលកើតចេញពីប្រតិបត្តិការបទល្មើសព្រហ្មទណ្ឌដូចគ្នា ដែលរំលោភបំពានទៅលើផ្នែកនេះឡើយ។

ផ្នែកទី 9. វិសោធនកម្ម។

ច្បាប់នេះមិនត្រូវធ្វើវិសោធនកម្មដោយរដ្ឋសភាឡើយ លើកលែងតែដោយលក្ខន្តិក:អ្វីមួយ ដែលពង្រីកបន្ថែមនូវគោលបំណង លទ្ធផល និងសេចក្តីថ្លែងការណ៍នៃច្បាប់នេះ ហើយត្រូវបានឆ្លងនៅក្នុងសភានីមួយៗដោយការបោះឆ្នោតដោយហៅឈ្មោះដែលបានបញ្ជូលនៅក្នុងទិន្នានុប្បវត្តិ បីភាគបួននៃសមាជិកភាពនៃសភានីមួយៗដំណាលគ្នា ឬដោយលក្ខន្តិក:ណាមួយដែលចូលជាធរមាននៅពេលដែលត្រូវបានអនុម័ត ដោយអ្នកបោះឆ្នោតតែប៉ុណ្ណោះ។

ផ្នែកទី 10. វិច្ឆិន្នភាព។

ប្រសិនបើបទបញ្ញត្តិណាមួយនៃច្បាប់នេះ ឬផ្នែកណាមួយនៃបទបញ្ញត្តិនេះ ឬការអនុវត្តរបស់វាទៅលើជនណាម្នាក់ ឬកាលៈទេសៈណាមួយគឺ ដោយសារហេតុផលអ្វីមួយដែលចាត់ទុកជាមោឃៈ ឬផ្ទុយពីរដ្ឋធម្មនុញ្ញនោះ បទបញ្ញត្តិដែលនៅសេសសល់ និងការអនុវត្តដែលអាចត្រូវបានផ្តល់សុពលភាពដោយគ្មានបទបញ្ញត្តិ ឬការអនុវត្តដែលចាត់ទុកជាមោឃៈ ឬផ្ទុយពីរដ្ឋធម្មនុញ្ញមិនត្រូវរងការប៉ះពាល់ឡើយ ប៉ុន្តែត្រូវនៅតែមានប្រសិទ្ធភាពពេញលេញ ហើយសរុបមក បទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ គឺជាប្រការសេសសល់។

ផ្នែកទី 11. គំនិតផ្តួចផ្តើមដែលមានទំនាស់។

(a) ក្នុងករណីដែលវិធានការនេះ និងវិធានការមួយផ្សេងទៀតដែលដោះស្រាយការពិចារណាលើការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ ដោយអនុលោមតាមផ្នែកទី 32 នៃមាត្រា I នៃរដ្ឋធម្មនុញ្ញ ការដកហូតសិទ្ធិដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ និងការត្រួតពិនិត្យក្នុងសហគមន៍ក្រោយការដោះលែង ការប្រមូល DNA ឬបទល្មើសចោរកម្មត្រូវមាននៅលើសន្លឹកឆ្នោតទូទាំងរដ្ឋដូចគ្នានោះ បទបញ្ញត្តិនៃវិធានការ ឬបណ្តាវិធានការផ្សេងទៀតត្រូវចាត់ទុកថាមានទំនាស់ជាមួយនឹងវិធានការនេះ។ ក្នុងករណីដែលគំនិតផ្តួចផ្តើមនេះទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាង វិធានការមួយដែលចាត់ទុកថាមានទំនាស់ជាមួយវា ប្រការនៃគំនិតផ្តួចផ្តើមនេះនឹងត្រូវឈ្នះទាំងស្រុង ហើយវិធានការ ឬបណ្តាវិធានការផ្សេងទៀតត្រូវចាត់ទុកជាមោឃៈ។

(b) ប្រសិនបើវិធានការនេះត្រូវបានអនុម័តដោយអ្នកបោះឆ្នោត ប៉ុន្តែត្រូវបានជំនួសដោយច្បាប់ដោយមានវិធានការទំនាស់ផ្សេងទៀតដែលអនុម័តដោយអ្នកបោះឆ្នោតនៅពេលបោះឆ្នោតតែមួយ ហើយវិធានការសន្លឹកឆ្នោតដែលមានទំនាស់ត្រូវបានចាត់ទុកជាមោឃៈនាពេលក្រោយមកទៀតនោះ វិធានការនេះត្រូវតែស្វ័យអនុវត្ត និងទទួលបានប្រសិទ្ធភាពពេញលេញ។

សំណើ ប្រជា មតិ 21

វិធានការផ្តួចផ្តើមនេះ បានដាក់ជូន ប្រជាជន ដោយអនុលោម ទៅតាមមាត្រានៃភាគ 8 មាត្រា II នៃធម្មនុញ្ញរដ្ឋ California។

វិធានការផ្តួចផ្តើមនេះ ធ្វើវិសោធនកម្មទៅលើផ្នែកទាំងឡាយនៃក្រមរដ្ឋប្បវេណី ដូច្នេះបទបញ្ញត្តិជាធរមានដែលត្រូវបានដាក់បង្ខំឲ្យលុបចោល ត្រូវបានបោះពុម្ពជា ~~ប្រភេទឆ្ងាត់ចោល~~ បទបញ្ញត្តិថ្មីដែលត្រូវបានស្នើឲ្យបន្ថែម ត្រូវបានបោះពុម្ពជា *ប្រភេទអក្សរទ្រេត* ដើម្បីបញ្ជាក់ថា វាជាបទបញ្ញត្តិថ្មី។

សំណើច្បាប់

ច្បាប់ស្តីពីលទ្ធភាពជួល

ប្រជាពលរដ្ឋ California សម្រេចដូចខាងក្រោម៖

ភាគ 1. ចំណងជើង.

ច្បាប់នេះ ត្រូវមានគេដឹងឮ ហើយអាចត្រូវបានដកស្រង់ជា “ច្បាប់នៃលទ្ធភាពជួល (Rental Affordability Act)”។

ផ្នែកទី 2. ការរកឃើញ និងសេចក្តីប្រកាស។

ប្រជាជននៃរដ្ឋ California រកឃើញ និងប្រកាសដូចខាងក្រោម៖

(a) ពលរដ្ឋ California កាន់តែច្រើន (ជាង 17 លាននាក់) កំពុងតែជួលផ្ទះច្រើនជាងពីមុន។ យោងតាមតួលេខរបស់រដ្ឋ’អត្រាកម្មសិទ្ធិលើផ្ទះសម្បែងនៅរដ្ឋ California បានធ្លាក់ចុះដល់កម្រិតទាបបំផុតរបស់វាចាប់តាំងពីទសវត្សរ៍ឆ្នាំ 1940 មក។ មួយភាគបួននៃមនុស្សធំពេញវ័យរាប់លាននាក់ (អាយុ 25–34 ឆ្នាំ) នៅតែរស់នៅជាមួយឪពុកម្តាយរបស់ពួកគេ (ការិយាល័យជំរឿនសហរដ្ឋអាមេរិក)។

(b) តម្លៃផ្ទះជួល បានឡើងខ្ពស់កប់ពពកក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ការជួលថ្នាក់កណ្តាលគឺមានកម្រិតខ្ពស់នៅក្នុងរដ្ឋ California លើពីរដ្ឋផ្សេងៗទៀតនៅក្នុងប្រទេស ហើយនៅក្នុងចំណោម 50 រដ្ឋ, រដ្ឋ California មានកម្រិតការជួលខ្ពស់លំដាប់ទីបួន។

(c) ជាលទ្ធផលនៃតម្លៃផ្ទះជួលដែលកើនឡើងនេះ ភាគច្រើននៃអ្នកជួលផ្ទះនៅរដ្ឋ California ត្រូវទទួលរងបន្ទុកលើសលប់ដោយសារចំណាយលើផ្ទះ ដោយត្រូវចំណាយលើសពី 30 ភាគរយនៃចំណូលរបស់ពួកគេទៅលើថ្លៃឈ្នួលផ្ទះ។ មួយភាគបីនៃគ្រួសារអ្នកជួលផ្ទះ ចំណាយលើសពី 50 ភាគរយនៃចំណូលរបស់ពួកគេទៅលើថ្លៃឈ្នួលផ្ទះ។

(d) យោងតាមសម្ព័ន្ធផ្ទះសម្បែងអ្នកមានចំណូលទាបថ្នាក់ជាតិ ពលរដ្ឋ California ម្នាក់ដែលរកប្រាក់ឈ្នួលអប្បបរិមា នឹងត្រូវធ្វើការ 92 ម៉ោងក្នុងមួយសប្តាហ៍ដើម្បីមានលទ្ធភាពបង់ថ្លៃឈ្នួលផ្ទះល្វែងដែលជាមធ្យមមានបន្ទប់គេងមួយ។

(e) ក្រុមគ្រួសារដែលប្រឈមនឹងអសន្តិសុខផ្ទះសម្បែង ជារឿយៗត្រូវបានបង្ខំឲ្យសម្រេចចិត្តរវាងការបង់ថ្លៃឈ្នួលផ្ទះរបស់ពួកគេ និងការបំពេញសេចក្តីត្រូវការមូលដ្ឋានផ្សេងៗទៀត ដែលមានផលអវិជ្ជមានទៅលើលទ្ធផលសុខភាពរបស់ពួកគេ។ កម្មករ និយោជិកដែលរងការឈឺចាប់ពីផ្ទះសម្បែងគ្មានស្ថេរភាព និងការចុះខ្សោយសុខភាពរបស់

ពួកគេ ត្រូវតស៊ូរក្សាការងារ ដែលរុញច្រានពួកគេឲ្យចូលទៅក្នុងភាពក្រីក្រ និងគ្មានផ្ទះសម្បែង។

(f) សហជីពការងារ ដូចជាសមាគមគ្រូបង្រៀនរដ្ឋ California សមាគមគិលានុប្បដ្ឋាករដ្ឋ California និងសហជីពនិយោជិកផ្តល់សេវាអន្តរជាតិ (SEIU) បានធ្វើឲ្យផ្ទះសម្បែងដែលមានលទ្ធភាពអាចបង់បានក្លាយជាអាទិភាពសម្រាប់សមាជិករបស់ខ្លួន។ គ្រូបង្រៀននៅតាមមជ្ឈមណ្ឌលទីក្រុងរបស់រដ្ឋ California កំពុងតែចំណាយប្រាក់ 40 ភាគរយដល់ 70 ភាគរយនៃប្រាក់ខែរបស់ខ្លួនទៅលើផ្ទះសម្បែង ហើយភាគច្រើនត្រូវបានបង្ខំឲ្យដកយកមួយម៉ោង ឬច្រើនម៉ោងពីការងាររបស់ពួកគេដើម្បីមានលទ្ធភាពបង់ថ្លៃឈ្នួលផ្ទះមួយ។

(g) ទោះបីជារដ្ឋនេះតំណាងឲ្យត្រឹមតែ 12 ភាគរយនៃចំនួនប្រជាជនទូទាំងសហរដ្ឋក៏ដោយ រដ្ឋ California ផ្តល់ទីលំនៅដល់ប្រជាជនដែលគ្មានផ្ទះសម្បែងទូទាំងប្រទេសរហូតដល់ 22 ភាគរយ។ (ក្រសួងអភិវឌ្ឍផ្ទះសម្បែង និងសហគមន៍រដ្ឋ California)

(h) យោងតាមការសិក្សាមួយកាលពីឆ្នាំ 2018 នៅក្នុង UCLA Anderson Forecast មានទំនាក់ទំនងយ៉ាងរឹងមំារវាងថ្លៃឈ្នួលមធ្យមដែលខ្ពស់ជាង ជាមួយនឹងចំនួននៃប្រជាជនដែលរស់នៅតាមដងផ្លូវ ឬទីជម្រកបណ្តោះអាសន្ន។ នៅពេលផ្សំគ្នាជាមួយនឹងកត្តាមានហានិភ័យនីមួយៗ ទីផ្សារផ្ទះសម្បែងដែលមានលទ្ធភាពអាចបង់បាន រួមចំណែកបង្កើតបានជាកំណើនអ្នកគ្មានផ្ទះសម្បែង។

(i) បញ្ហាគ្មានលំនៅដ្ឋានគឺជាបញ្ហាសុខភាពសាធារណៈដ៏ចម្បង។ ប្រជាជនដែលគ្មានផ្ទះសម្បែង ទំនងជានឹងត្រូវស្លាប់មុនអាយុបីទៅបួនដង ហើយទំនងជាប្រឈមនឹងជំងឺឆ្លង នេះបើយោងតាមក្រុមប្រឹក្សាជាតិថែទាំសុខភាពសម្រាប់អ្នកគ្មានផ្ទះសម្បែង។

(j) មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ បានព្រមានថា ប្រជាជនងាយរងគ្រោះប្រឈមនឹងអាយុរស់នៅមធ្យមទាបជាង មានអត្រាជំងឺមហារីកខ្ពស់ជាង និងកើតមកមានខ្ទោះច្រើន នៅពេលពួកគេផ្លាស់ទីលំនៅចេញពីផ្ទះរបស់ពួកគេដោយសារតែការប្រែប្រួលសេដ្ឋកិច្ចនៅតំបន់ជិតខាងរបស់ពួកគេ។

(k) កំណើនបន្ទុកចំណាយទៅលើផ្ទះសម្បែង ធ្វើឲ្យការកកស្ទះចរាចរណ៍កាន់តែអាក្រក់ថែមទៀត និងបង្កគ្រោះภัយដល់បរិស្ថាន ដោយបង្ខំឲ្យអ្នកធ្វើដំណើរពីផ្ទះទៅកន្លែងធ្វើការត្រូវរស់នៅកាន់តែឆ្ងាយពីកន្លែងធ្វើការរបស់ខ្លួន ដែលធ្វើឲ្យរយៈពេលធ្វើដំណើរពីផ្ទះទៅកន្លែងធ្វើការមានការកើនឡើង។ របាយការណ៍ដោយ Pew Charitable Trusts បានកត់សម្គាល់ថា ចំនួននៃពលរដ្ឋ California ដែលធ្វើដំណើរពីផ្ទះទៅកន្លែងធ្វើការលើសពី 90 នាទី នៅតាមផ្លូវនីមួយៗ មានការកើនឡើង 40 ភាគរយ ចន្លោះពីឆ្នាំ 2010 ដល់ឆ្នាំ 2015។ កំណើននេះគឺជាលទ្ធផលដោយផ្ទាល់នៃកង្វះខាតផ្ទះសម្បែងដែលមានលទ្ធភាពបង់ថ្លៃឈ្នួលបាននៅជិតកន្លែងធ្វើការ។

(l) បន្ទុកនៃภัยស្ពុតតាងដែលកើនឡើង បានផ្តល់ជាយោបល់ថា ការធ្វើឲ្យមានស្ថេរภาพថ្លៃឈ្នួលផ្ទះ អាចនាំមកនូវអត្ថប្រយោជន៍ទូលំទូលាយដល់អ្នកជួលផ្ទះ សេដ្ឋកិច្ចរបស់រដ្ឋ បរិស្ថាន និងសេវាសាធារណៈរបស់រដ្ឋផងដែរ។

ផ្នែកទី 3. គោលបំណង និងចេតនា

ប្រជាពលរដ្ឋនៃរដ្ឋ California តទៅនេះប្រកាសនូវគោលបំណងនិងគោលដៅដែលបានអនុម័តដោយច្បាប់នេះដូចខាងក្រោម៖

(a) ដើម្បីអនុញ្ញាតឲ្យទីក្រុង និងខោនធីនានារបស់រដ្ឋ California អភិវឌ្ឍន៍ និងអនុវត្តគោលនយោបាយគ្រប់គ្រងថ្លៃឈ្នួលផ្ទះដែលធានាថា អ្នកជួលផ្ទះអាចស្វែងរក និងមានលទ្ធภาពបង់ថ្លៃឈ្នួលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

(b) ពង្រឹងគុណภาពនៃការរស់នៅរបស់អ្នកជួលផ្ទះរាប់លាននាក់ក្នុងរដ្ឋ California និងកាត់បន្ថយចំនួននៃប្រជាពលរដ្ឋនៃរដ្ឋ California ដែលប្រឈមនឹងបញ្ហាលំនៅដ្ឋានធ្ងន់ធ្ងរនិងគ្មានផ្ទះសំបែង។

(c) ដើម្បីបញ្ឈប់ការកើនឡើងនៃការបណ្តេញចេញ និងការផ្លាស់ទីជម្រកដែលប៉ះពាល់ដល់សហគមន៍នានាទូទាំងរដ្ឋ California។

(d) ដើម្បីអនុញ្ញាតឲ្យទីក្រុង ខោនធី ឬទីក្រុង និងខោនធី អនុវត្តច្បាប់ក្នុងមូលដ្ឋានណាមួយដែលគ្រប់គ្រងទៅលើអត្រាថ្លៃឈ្នួលផ្ទះសម្រាប់អចលនទ្រព្យលំនៅដ្ឋាន ដរាបណាវាមានអាយុកាលយ៉ាងតិច 15 ឆ្នាំ ចាប់តាំងពីអចលនទ្រព្យនោះបានទទួលលិខិតបញ្ជាក់ការកាន់កាប់របស់ខ្លួន។

(e) ដើម្បីអនុញ្ញាតឲ្យច្បាប់ក្នុងស្រុកគ្រប់គ្រងអត្រាថ្លៃឈ្នួលបន្ទាប់ពីមានផ្ទះទំនេរ ដោយអនុញ្ញាតឲ្យម្ចាស់ផ្ទះបង្កើនថ្លៃឈ្នួលបន្ទប់ដែលទំនេរ មិនលើសពី 15 ភាគរយក្នុងរយៈពេលបីឆ្នាំបន្តបន្ទាប់បន្ថែមពីលើកំណើនណាមួយដែលត្រូវបានអនុញ្ញាតក្រោមបទបញ្ជាក្នុងមូលដ្ឋាន។

(f) ដើម្បីលើកលែងម្ចាស់ផ្ទះដែលមានលំនៅដ្ឋានមួយ ឬពីរ ចេញពីច្បាប់គ្រប់គ្រងថ្លៃឈ្នួលក្នុងមូលដ្ឋាន។

ផ្នែកទី 4. ផ្នែកទី 1954.50 នៃក្រមរដ្ឋប្បវេណី ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម៖

1954.50. ជំពូកនេះ ត្រូវមានគេដឹងឮ ហើយអាចត្រូវបានដកស្រង់ជាច្បាប់ *ภาពមានលទ្ធภาព* បង់ថ្លៃឈ្នួល ~~ផ្ទះ Costa-Hawkins~~។

ផ្នែកទី 5. ផ្នែកទី 1954.52 នៃក្រមរដ្ឋប្បវេណី ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម៖

1954.52. (a) ~~ទ្ធើបើមានបទបញ្ញត្តិនៃច្បាប់ណាមួយផ្សេងទៀតក៏~~ ដោយ ម្ចាស់នៃអចលនទ្រព្យលំនៅដ្ឋានអាចបង្កើតនូវអត្រាថ្លៃឈ្នួលផ្ទះដំបូង និងបន្តបន្ទាប់ទាំងអស់ សម្រាប់លំនៅដ្ឋាន ឬបន្ទប់អំពីអ្វីមួយ ~~ដូច~~ *ខាងក្រោមនេះ* គឺជាការពិត៖

(1) ~~ភាមាន លិខិតមញ្ជាក់ការកាន់កាប់ដែលចេញនៅក្រោយថ្ងៃទី 1 ខែកុម្ភៈ ឆ្នាំ 1995~~ *ដែលបានចេញលិខិតបញ្ជាក់ការកាន់កាប់លំនៅដ្ឋានលើកទីមួយក្នុងរយៈពេល 15 ឆ្នាំ បន្ទាប់ពីថ្ងៃដែលម្ចាស់ផ្ទះស្វែងរកការបង្កើតអត្រាថ្លៃឈ្នួលផ្ទះដំបូង ឬជាបន្តបន្ទាប់។*

(2) ~~ភាត្រូវបានលើកលែងរួចមកហើយពីមទមញ្ជាគ្រប់គ្រងថ្លៃឈ្នួលលំនៅដ្ឋានរបស់អង្គภาពសាធារណៈនៅថ្ងៃទី ឬមុនថ្ងៃទី 1 ខែកុម្ភៈ ឆ្នាំ 1995 ដោយអនុលោមតាមការលើកលែងថ្នាក់មូលដ្ឋានសម្រាប់មន្ទ~~ ~~ដែលទើបតែបានសាងសង់រួចថ្មីៗ៖~~

~~(3)~~ (A) ~~ភា~~អាចផ្លាស់ប្តូរដាច់ដោយឡែកពីគ្នាពីចំណងជើងចំពោះបន្ទប់ស្នាក់នៅ ឬផលប្រយោជន៍រងនៅក្នុងផ្នែករង ដូចមានបញ្ជាក់នៅក្នុងផ្នែករង (b), (d), ឬ (f) នៃផ្នែកទី 11004.5 នៃក្រមស្តីពីអាជីវកម្ម និងវិជ្ជាជីវៈ, *ហើយម្ចាស់គឺជារូបវន្តបុគ្គលដែលកាន់កាប់លំនៅដ្ឋាន ឬបន្ទប់ផ្ទះមិនលើសពីពីរបន្ទប់។*

(B) កថាខណ្ឌនេះមិនយកទៅអនុវត្តក្នុងករណីណាមួយដូចខាងក្រោមឡើយ៖

(i) បន្ទាប់ស្នាក់នៅឬបន្ទប់ដែលការជួលមុនត្រូវបានបញ្ចប់ដោយម្ចាស់ផ្ទះដោយការជូនដំណឹងអនុលោមតាមវគ្គ 1946.1 ឬត្រូវបានបញ្ចប់ដោយការផ្លាស់ប្តូរលក្ខខណ្ឌនៃការជួលដែលបានជូនដំណឹងអនុលោមតាមវគ្គ 827។

(ii) បន្ទប់គេងឬបន្ទប់ខុនដូដែលមិនទាន់ត្រូវបានលក់ដាច់ដោយឡែកដោយអ្នកបែងចែកបន្តដល់អ្នកទិញត្រឹមត្រូវស្មោះត្រង់។ ចំនួនទឹកប្រាក់នៃថ្លៃឈ្នួលដំបូងរបស់បន្ទប់ស្នាក់នៅ សម្រាប់គោលបំណងនៃជំពូកនេះ គឺជាថ្លៃឈ្នួលស្របច្បាប់ដែលចូលជាធរមានកាលពីថ្ងៃទី 7 ខែឧសភា

21

ឆ្នាំ 2001 លើកលែងតែចំនួនទឹកប្រាក់នៃថ្លៃឈ្នួលនោះត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិខុសៗគ្នានៃជំពូកនេះ។ ទោះជាយ៉ាងណា ប្រសិនបើលំនៅដ្ឋាន ឬបន្ទប់ផ្ទះល្វែងបំពេញតាមលក្ខណៈវិនិច្ឆ័យនៃកថាខណ្ឌទី (1) ~~ឬ (2) នៃផ្នែករង (a)~~ ឬ ប្រសិនបើលំនៅដ្ឋាន ឬបន្ទប់ទាំងអស់ លើកលែងតែមួយ ត្រូវបានលក់ចេញដាច់ដោយឡែកពីគ្នា ដោយអ្នកបែងចែកបន្តទៅឲ្យអ្នកទិញដោយសុចរិតក្នុងតម្លៃណាមួយ ហើយអ្នកបែងចែកបន្តនោះបានកាន់កាប់លំនៅដ្ឋាន ឬបន្ទប់ផ្ទះល្វែងដែលនៅសេសសល់មិនទាន់បានលក់នោះជាលំនៅដ្ឋានគោលរបស់ខ្លួនក្នុងរយៈពេលយ៉ាងតិចមួយឆ្នាំ បន្ទាប់ពីការបែងចែកបន្តបានកើតឡើងនោះ កថាខណ្ឌរង (A) ~~នៃកថាខណ្ឌទី (3)~~ ត្រូវបានអនុវត្តចំពោះលំនៅដ្ឋាន ឬបន្ទប់ផ្ទះល្វែងដែលនៅសេសសល់មិនទាន់បានលក់នោះ។

~~(C) ក្នុងករណីដែលបន្ទប់ស្នាក់នៅឬបន្ទប់ដែលអត្រាជួលដំបូងឬបន្តបន្ទាប់ត្រូវបានត្រួតពិនិត្យដោយដីកា ឬបទបញ្ញត្តិនៃជំពូកនេះមានអនុភាពនៅថ្ងៃទី 1 ខែមករា ឆ្នាំ 1995 លក្ខខណ្ឌដូចខាងក្រោមត្រូវអនុវត្ត៖~~

~~(i) ម្ចាស់អចលនវត្ថុដូចបានរៀបរាប់ក្នុងកថាខណ្ឌនេះអាចបង្កើតអត្រាជួលដំបូងនិងបន្តបន្ទាប់ទាំងអស់សម្រាប់ការជួលដែលមានឬការជួលថ្មីៗមានអានុភាពនៅឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 1999 ប្រសិនបើការជួលមានអានុភាពនៅឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 1999 ត្រូវបានបង្កើតចន្លោះថ្ងៃទី 1 ខែមករា ឆ្នាំ 1996 និងថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1998។~~

~~(ii) ដោយចាប់ផ្តើមនៅថ្ងៃទី 1 ខែមករា ឆ្នាំ 1999 ម្ចាស់អចលនវត្ថុដូចបានរៀបរាប់នៅក្នុងកថាខណ្ឌនេះអាចបង្កើតអត្រាជួលដំបូងនិងបន្តបន្ទាប់ទាំងអស់ចំពោះការជួលថ្មីៗ ប្រសិនបើការជួលពីមុនត្រូវមានអានុភាពនៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1995។~~

~~(iii) អត្រាជួលដំបូងសម្រាប់បន្ទប់ស្នាក់នៅឬបន្ទប់ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌនេះ ដែលអត្រាជួលដំបូងត្រូវគ្រប់គ្រងដោយដីកា ឬបទបញ្ញត្តិនៃជំពូកដែលចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 1995 រហូតដល់ថ្ងៃទី 1 ខែមករា ឆ្នាំ 1999 មិនអាចលើសចំនួនដែលត្រូវបានគណនាអនុលោមតាមអនុផ្នែក (c) នៃវគ្គ 1954.53។ ម្ចាស់អចលនវត្ថុដូចបានរៀបរាប់នៅក្នុងកថាខណ្ឌនេះ រហូតដល់ថ្ងៃទី 1 ខែមករា ឆ្នាំ 1999 អាចបង្កើតអត្រាជួលដំបូងសម្រាប់បន្ទាប់ស្នាក់នៅ ឬបន្ទប់ ក្នុងករណីដែលអ្នកជួលបានមោយៈ ចោះបង់ចោល ឬកែប្រែដោយស្ម័គ្រចិត្តអនុលោមតាមកថាខណ្ឌទី (2) នៃវគ្គ 1161 នៃក្រមនីតិវិធីរដ្ឋប្បវេណី។~~

(b) អនុផ្នែក (a) មិនយកមកអនុវត្តទេ ក្នុងករណីដែលម្ចាស់អចលនវត្ថុបានយល់ព្រមផ្សេងតារយៈកិច្ចសន្យាជាមួយអង្គភាពសាធារណៈដោយពិចារណារលើការផ្តល់ហិរញ្ញវត្ថុដោយផ្ទាល់ ឬទម្រង់ផ្សេងទៀតនៃជំនួយដូចកំណត់ក្នុងជំពូក 4.3 (ចាប់ផ្តើមជាមួយវគ្គ 65915) នៃផ្នែកទី 1 នៃចំណងជើង 7 នៃក្រមរដ្ឋាភិបាល។

(c) គ្មានអ្វីមួយនៅក្នុងវគ្គនេះត្រូវបានបកស្រាយឱ្យប៉ះពាល់ដល់អំណាចនៃអង្គភាពសាធារណៈ ដែលអាចមានក្នុងការធ្វើនិយ័តឬគ្រប់គ្រងមូលដ្ឋានសម្រាប់ការកែប្រែផ្សេង។

(d) វគ្គនេះមិនយកមកអនុវត្តចំពោះបន្ទប់ស្នាក់នៅឬបន្ទប់ណាមួយដែលមានបញ្ហាសុខភាពធ្ងន់ធ្ងរ សុវត្ថិភាព អគ្គីភ័យ ឬបង្កើតឱ្យមានការរំលោភច្បាប់ លើកលែងតែអ្វីទាំងឡាយដែលបណ្តាលមកពីគ្រោះមហន្តរាយសម្រាប់ការលើកឡើងត្រូវបានចេញដោយភ្នាក់ងាររដ្ឋាភិបាលសមស្របហើយដែលនៅមិនបញ្ចុះតម្លៃសម្រាប់រយៈពេលប្រាំមួយខែឬលើសពេលទំនេរមុន។

(e) អនុលោមតាមច្បាប់រដ្ឋ California សិទ្ធិរបស់ម្ចាស់ផ្ទះក្នុងការទទួលបានអត្រាយុត្តិធម៌នៃការតបស្នងពីអចលនទ្រព្យ មិនត្រូវសង្កេបឲ្យខ្លីដោយបទបញ្ញត្តិធម្មនុញ្ញ បទបញ្ញា ឬនីយ័តកម្មក្នុងមូលដ្ឋានណាមួយ ដែលត្រូវបានអនុម័តដោយទីក្រុងមួយ ខោនធីមួយ ឬទីក្រុង និងខោនធីមួយឡើយ។

ផ្នែកទី 6. ផ្នែកទី 1954.53 នៃក្រមរដ្ឋប្បវេណី ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម៖

1954.53. (a) ~~ថ្វីបើមានបទបញ្ញត្តិនៃច្បាប់ណាមួយផ្សេងទៀតក៏ដោយ~~ *ហើយលើកលែងតែមានចែងនៅក្នុងផ្នែកទី 1954.52 និងផ្នែករង (b) នៃផ្នែកនេះ ទីក្រុងមួយ ខោនធីមួយ ឬទីក្រុង និងខោនធីមួយ តាមរយៈបទបញ្ញត្តិ បទបញ្ជា ឬនីយ័តកម្មក្នុងមូលដ្ឋាន អាចគ្រប់គ្រងអត្រាថ្លៃឈ្នួលពីដំបូង និងបន្តបន្ទាប់ទាំងអស់សម្រាប់អចលនទ្រព្យលំនៅដ្ឋាន*~~។ ~~ម្ចាស់នៃអចលនទ្រព្យលំនៅដ្ឋាន អាចបង្កើតនូវអត្រាថ្លៃឈ្នួលដំបូងសម្រាប់លំនៅដ្ឋាន ឬបន្ទប់ លើកលែងតែបទបញ្ញត្តិណាមួយខាងក្រោមនេះត្រូវបានអនុវត្ត៖~~

~~(1) ការជួលមុនត្រូវបានបញ្ចប់ដោយម្ចាស់ផ្ទះដោយការជូនដំណឹងអនុលោមតាមវគ្គ 1946.1 ឬត្រូវបានបញ្ចប់ដោយការផ្លាស់ប្តូរលក្ខខណ្ឌនៃការជួលដែលបានជូនដំណឹងអនុលោមតាមវគ្គ 827 លើកលែងតែការកែប្រែត្រូវបានអនុញ្ញាតដោយច្បាប់ក្នុងចំនួននៃការជួលឬថ្លៃឈ្នួល។ សម្រាបគោលបំណងនៃកថាខណ្ឌនេះ ការបញ្ចប់ឬមិនបន្តជាថ្មីនៃកិច្ចសន្យាឬកិច្ចព្រមព្រៀងរបស់ម្ចាស់អចលនវត្ថុជាមួយនឹងភ្នាក់ងាររដ្ឋាភិបាលកំណត់កម្រិតការជួលចំពោះអ្នកជួលមានគុណវុឌ្ឍិ ត្រូវបកស្រាយថាជាការកែប្រែលក្ខខណ្ឌនៃការជួលអនុលោមតាមវគ្គ 827។~~

~~(A) នៅក្នុងយុត្តាធិការមួយដែលគ្រប់គ្រងដោយដីកាឬបទបញ្ញត្តិនៃជំពូកស្តីពីអត្រាជួលសម្រាប់បន្ទប់ស្នាក់នៅឬបន្ទប់ ម្ចាស់អចលនវត្ថុដែលបញ្ចប់ឬខកខានការពិនិត្យមើលកិច្ចសន្យាឬកិច្ចព្រមព្រៀងជាមួយភ្នាក់ងាររដ្ឋាភិបាលដែលកំណត់សម្រាប់កម្រិតជួលដល់គុណវុឌ្ឍិអ្នកជួលអាចមិនកំណត់ការជួលដំបូងសម្រាប់រយៈពេលបីឆ្នាំបន្ទាប់ពីកាលបរិច្ឆេទបញ្ចប់ឬមិនបន្តជាថ្មីនៃកិច្ចសន្យាឬកិច្ចព្រមព្រៀង។ សម្រាប់ការជួលថ្មីណាមួយដែលបានបង្កើតក្នុងរយៈពេលនៃរយៈពេលបីឆ្នាំ អត្រាជួលសម្រាប់ការជួលថ្មីដែលបានបង្កើតចំពោះបន្ទប់ស្នាក់នៅឬបន្ទប់ទំនេរត្រូវកំណត់អត្រាដូចគ្នាដូចការជួលដែលបានបញ្ចប់ឬមិនបន្តជាថ្មីកិច្ចសន្យាឬកិច្ចព្រមព្រៀងជាមួយភ្នាក់ងាររដ្ឋាភិបាលដែលកំណត់ពីការកំណត់ការជួលចំពោះអ្នកជួលមានគុណវុឌ្ឍ បន្ថែមជាមួយនឹងការការកើនឡើងនូវអំណាយក្រោយការបញ្ចប់ឬសុបចោលកិច្ចសន្យាឬកិច្ចព្រមព្រៀង។~~

~~(B) អនុកថាខណ្ឌ (A) មិនយកមកអនុវត្តចំពោះការជួលថ្មីណាមួយក្នុងរយៈ 12 ខែឬរយៈពេលលើសពីនេះដែលត្រូវបានបង្កើតឡើងក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2000 អនុលោមតាមកិច្ចសន្យាឬកិច្ចព្រមព្រៀងរបស់ម្ចាស់ជាមួយភ្នាក់ងាររដ្ឋាភិបាល ដែលកំណត់កម្រិតការជួលចំពោះអ្នកជួលមានគុណវុឌ្ឍិ លើកលែងតែការទំនេរមុននៃបន្ទប់ស្នាក់នៅ ឬបន្ទប់ស្រេបទៅនឹងការមិនបន្តជាថ្មីឬការសុបចោលកិច្ចសន្យាឬកិច្ចព្រមព្រៀងជាមួយភ្នាក់ងាររដ្ឋាភិបាល ដែលកំណត់កម្រិតការជួលចំពោះអ្នកមានមានគុណវុឌ្ឍិដូខកំណត់នៅក្នុងអនុកថាខណ្ឌនេះ។~~

~~(2) ម្ចាស់អចលនវត្ថុបានយល់ព្រមផ្សេងតារយៈកិច្ចសន្យាជាមួយអង្គភាពសាធារណៈដោយពិចារណារលើការផ្តល់ហិរញ្ញវត្ថុដោយផ្ទាល់ ឬទម្រង់ផ្សេងទៀតនៃជំនួយដូចកំណត់ក្នុងជំពូក 4.3 (ចាប់ផ្តើមជាមួយវគ្គ 65915) នៃផ្នែកទី 1 នៃចំណងជើង 7 នៃក្រមរដ្ឋាភិបាល។~~

~~(3) អត្រាជួលដំបូងសម្រាប់បន្ទប់ស្នាក់នៅឬបន្ទប់ដែលអត្រាជួលដំបូងត្រូវគ្រប់គ្រងដោយដីកា ឬបទបញ្ញត្តិនៃជំពូកដែលចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 1995 រហូតដល់ថ្ងៃទី 1 ខែមករា ឆ្នាំ 1999 មិនអាចលើសចំនួនដែលត្រូវបានគណនាអនុលោមតាមអនុផ្នែក (c)។~~

~~(b) អនុផ្នែក (a) ដោយបន្ថែម អនុវត្តចំពោះការបន្តសាជាថ្មីនៃការជួលដំបូងដោយអ្នកជួល អ្នកទទួលជួល ការជួលបន្តដែលបានអនុញ្ញាត~~

~~ឬអ្នកជួលបន្តដែលបានអនុញ្ញាតសម្រាប់រយៈពេលទាំងស្រុងនៃការកាន់កាប់របស់ខ្លួននូវអត្រាជួលដែលបានបង្កើតសម្រាប់ការជួលដំបូង។~~

~~(e)~~

(b) នៅក្នុងដែនសមត្ថកិច្ចណាមួយដែលគ្រប់គ្រងដោយធម្មនុញ្ញ បទបញ្ញត្តិ បទបញ្ជា ឬនីយ៉ូតកម្មអត្រាថ្លៃឈ្នួលដំបូងនៃ លំនៅដ្ឋានឬបន្ទប់ ~~ដែលអត្រាថ្លៃឈ្នួលដំបូងត្រូវបានគ្រប់គ្រងដោយមបទបញ្ញត្តិនៃមបទបញ្ជា ឬធម្មនុញ្ញដែលចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 1995 រហូតដល់ថ្ងៃទី 1 ខែមករា ឆ្នាំ 1999 ត្រូវបង្កើតឡើងដោយអនុលោមតាមផ្នែករងនេះ។ នៅកន្លែងណាមួយ~~ *ប្រសិនបើ* ~~អ្នកជួលផ្ទះគេ~~ ~~ពីមុនបានចាកចេញ~~ ~~បោះបង់ដោយស្ម័គ្រចិត្ត~~ ~~ឬត្រូវបានបណ្តេញចេញ~~ ~~ដោយអនុលោមតាមកថាខណ្ឌទី (2) នៃផ្នែកទី 1161 នៃ~~ *ក្រម* ~~នីតិវិធីរដ្ឋប្បវេណី~~ *នៃ* ~~ម្ចាស់~~ *លំនៅដ្ឋាន ឬបន្ទប់នោះ ដែលត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុង* ~~អចលនទ្រព្យលំនៅដ្ឋានអាចមង្កើតមិនលើសពីពីរដង~~ នូវ~~ អត្រាថ្លៃឈ្នួលដំបូង~~ ~~សម្រាប់~~ *លំនៅដ្ឋាន* ~~ឬបន្ទប់ដែលទំនេរ~~ ~~ឬបោះបង់ក្នុងចំនួនទឹកប្រាក់~~ *ដរាបណាអត្រាដំបូងដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមផ្នែករងនេះ រួមជាមួយនឹងរាល់ការបង្កើនអត្រាថ្លៃឈ្នួលអំឡុងពេលបីឆ្នាំបន្តបន្ទាប់* ~~មិនលើសពី 15 ភាគរយ លើសពីអត្រាថ្លៃឈ្នួលជាធរមានសម្រាប់ការជួលពីមុនភ្លាមៗ ~~ ~~ឬក្នុងចំនួនទឹកប្រាក់មួយដែលស្មើនឹង 70 ភាគរយនៃថ្លៃឈ្នួលលើទីផ្សារទូទៅសម្រាប់បន្ទប់ដែលអាចប្រៀបធៀបគ្នាបាន ដែលចំនួនទឹកប្រាក់មានច្រើនជាង~~

~~រាល់~~ *ការបង្កើន* ~~អត្រាថ្លៃឈ្នួលដំបូង~~ *ដែលត្រូវបានអនុញ្ញាតដោយ និង* ~~បង្កើតឡើងដោយអនុលោមតាមផ្នែករងនេះ~~ *អាចជាការបន្ថែមទៅលើអត្រាណាមួយ* ~~មិនអាចជំនួសឲ្យ~~ ~~ការបង្កើនអត្រាថ្លៃឈ្នួលផ្សេងពីនេះ~~ ~~ដែលត្រូវបានអនុញ្ញាតដោយអនុលោមតាម~~ *ច្បាប់* ~~ក្នុងមូលដ្ឋានឡើយ~~

~~(d) (1) គ្មានអ្វីនៅក្នុងវគ្គនេះ ឬបទបញ្ញត្តិផ្សេងណាមួយនៃច្បាប់នេះ ត្រូវបកស្រាយដើម្បីបញ្ជូលការបង្កើតយ៉ាងជាក់ច្បាស់ក្នុងកិច្ចសន្យាជួល ឬកិច្ចព្រមព្រៀងនូវអត្រាជួលដែលអនុវត្តក្នុងការណីដែលបន្ទប់ជួលជាកម្មវត្ថុនៃការអនុញ្ញាតបន្ត។ គ្មានអ្វីនៅក្នុងវគ្គនេះ ត្រូវបានបកស្រាយដោយលំអៀងនូវកាតព្វកិច្ចនៃកិច្ចសន្យាដែលបានចូលជាធរមាននៅមុនថ្ងៃទី 1 ខែមករា ឆ្នាំ 1996។~~

~~(2) ប្រសិនបើអ្នកកាន់កាប់ដើមឬអ្នកកាន់កាប់ដែលមានភោគៈលើបន្ទប់ស្នាក់នៅ ~~ ~~ឬបន្ទប់អនុលោមតាមកិច្ចសន្យាជួលជាមួយម្ចាស់អចលនវត្ថុ ~~ ~~ដែលមិនស្នាក់នៅជាអចិន្ត្រៃយ៍ទីនេះទៀតទេ ~~ ~~ម្ចាស់អាចមង្កើនការជួលដោយចំនួនណាក៏បានដែលអនុញ្ញាតដោយវគ្គនេះដល់អ្នកជួលបន្ត ~~ ~~ស្របច្បាប់នៅ~~ ~~ឬបន្ទប់ស្នាក់នៅ~~ ~~ឬបន្ទប់មុនថ្ងៃទី 1 ខែមករា ឆ្នាំ 1996។~~

~~(3) ផ្នែករងនេះ ពុំត្រូវបានអនុវត្តចំពោះការផ្លាស់ប្តូរដោយផ្នែកនៃការកាន់កាប់លំនៅដ្ឋាន ~~ ~~ឬបន្ទប់ណាមួយ ~~ ~~ដែលនៅពេលដែលអ្នកកាន់កាប់ណាម្នាក់ ~~ ~~ឬច្រើននាក់ទៅលើបរិវេណ ~~ ~~ដោយអនុលោមតាមកិច្ចព្រមព្រៀងជាមួយម្ចាស់ដូចមានចែងខាងលើនេះ ~~ ~~នៅតែជាអ្នកកាន់កាប់ស្របច្បាប់ ~~ ~~ទៅលើលំនៅដ្ឋាន ~~ ~~ឬបន្ទប់ ~~ ~~ឬនៅពេលដែលអ្នកជួលបន្ត ~~ ~~ឬអនុឬទានិកស្របច្បាប់ណាម្នាក់ ~~ ~~ដែលបានស្នាក់នៅ~~ ~~ឬលំនៅដ្ឋាន ~~ ~~ឬបន្ទប់នោះ~~ ~~មុនថ្ងៃទី 1 ខែមករា ឆ្នាំ 1996 ~~ ~~នៅតែជាម្ចាស់កម្មសិទ្ធិនៃ~~ ~~លំនៅដ្ឋាន ~~ ~~ឬបន្ទប់នោះ។ គ្មានអ្វីនៅក្នុងវគ្គនេះ ~~ ~~ត្រូវបានបកស្រាយ~~ ~~ដើម្បីពង្រីក~~ ~~ឬលុបចោលនូវ~~ ~~សិទ្ធិ~~ ~~របស់ម្ចាស់~~ ~~ក្នុងការ~~ ~~ដកយកនូវ~~ ~~ការយល់ព្រមចំពោះ~~ ~~ការជួលបន្ត~~ ~~ឬ~~ ~~ការតំណាងបានឡើយ។~~

~~(4) ការយល់ព្រមការជួលដោយម្ចាស់~~ ~~មិនដំណើរការ~~ ~~ការ~~ ~~ការ~~ ~~ឡើយ~~ ~~ឬ~~ ~~ការ~~ ~~ពារ~~ ~~ការ~~ ~~អនុវ~~ ~~ត្ត~~ ~~កិ~~ ~~ច្ច~~ ~~ព្រ~~ ~~ម~~ ~~ព្រ~~ ~~ៀ~~ ~~ង~~ ~~ហាម~~ ~~ឃាត~~ ~~ការ~~ ~~ជួ~~ ~~ល~~ ~~ប~~ ~~ន្ត~~ ~~ឬ~~ ~~ការ~~ ~~ចាត~~ ~~ត~~ ~~ាំ~~ ~~ង~~ ~~ឬ~~ ~~ការ~~ ~~ប~~ ~~ោ~~ ~~ះ~~ ~~ប~~ ~~ង~~ ~~ស~~ ~~ិ~~ ~~ទ~~ ~~ិ~~ ~~ទ~~ ~~ិ~~ ~~ម~~ ~~ស~~ ~~់~~ ~~ម~~ ~~្ច~~ ~~ាស~~ ~~់~~ ~~ក~~ ~~្ន~~ ~~ុ~~ ~~ង~~ ~~ការ~~ ~~ប~~ ~~ង~~ ~~្ក~~ ~~ើ~~ ~~ត~~ ~~អ~~ ~~ត្រា~~ ~~ជួ~~ ~~ល~~ ~~ដ~~ ~~ំ~~ ~~ប~~ ~~ូ~~ ~~ង~~

~~លើកលែងតែម្ចាស់បានទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរពីអ្នកជួលថាវគ្គនៃកិច្ចព្រមព្រៀងទទួលយកការជួល។~~

~~(e)~~ *(c)* គ្មានអ្វីមួយនៅក្នុងផ្នែកនេះ ~~ត្រូវ~~ ~~ប~~ ~~ន~~ ~~ប~~ ~~ក~~ ~~ស្រ~~ ~~ាយ~~ ~~ដ~~ ~~ែ~~ ~~ល~~ ~~ធ្វ~~ ~~ើ~~ ~~ឲ~~ ~~យ~~ ~~ប~~ ~~ះ~~ ~~ពាល់~~ ~~ដ~~ ~~ល~~ ~~ស~~ ~~ិ~~ ~~ទ~~ ~~ិ~~ ~~អ~~ ~~ំ~~ ~~ណ~~ ~~ាច~~ ~~ណ~~ ~~ាមួ~~ ~~យ~~ ~~រ~~ ~~ប~~ ~~ស~~ ~~់~~ ~~អ~~ ~~ង~~ ~~្គ~~ ~~ភ~~ ~~ាព~~ ~~ស~~ ~~ា~~ ~~ធ~~ ~~ារ~~ ~~ណ~~ ~~៖~~ ~~ដ~~ ~~ែ~~ ~~ល~~ ~~អ~~ ~~ាច~~ ~~ម~~ ~~ាន~~ ~~អ~~ ~~ត្ថ~~ ~~ិ~~ ~~ភ~~ ~~ាព~~ ~~ផ្ទ~~ ~~ង~~ ~~ផ~~ ~~ង~~ ~~ពី~~ ~~នេ~~ ~~ះ~~ ~~ក~~ ~~្នុ~~ ~~ង~~ ~~ការ~~ ~~ក~~ ~~ំ~~ ~~ណ~~ ~~ត់~~ ~~និ~~ ~~យ~~ ~~ត~~ ~~ក~~ ~~ម~~ ~~ឬ~~ ~~ត្រ~~ ~~ូ~~ ~~ត~~ ~~ព~~ ~~ិ~~ ~~ន~~ ~~ិ~~ ~~ត្យ~~ ~~អ~~ ~~ង~~ ~~្គ~~ ~~ហ~~ ~~េ~~ ~~ត~~ ~~ុ~~ ~~ស~~ ~~ម្រ~~ ~~ាប~~ ~~់~~ ~~ការ~~ ~~ប~~ ~~ណ~~ ~~្ត~~ ~~េ~~ ~~ញ~~ ~~ចេ~~ ~~ញ~~ ~~ឡ~~ ~~ើ~~ ~~យ~~

~~(f) ផ្នែកនេះ~~ *(d) ផ្នែករង (b)* ~~d~~ ~~ពុ~~ ~~ំ~~ ~~ត្រ~~ ~~ូ~~ ~~ប~~ ~~ាន~~ ~~អ~~ ~~ន~~ ~~ុ~~ ~~វ~~ ~~ត្ត~~ ~~ចំ~~ ~~ពោ~~ ~~ះ~~ ~~រ~~ ~~ាល់~~ ~~លំ~~ ~~នៅ~~ ~~ដ~~ ~~ាន~~ ~~ឬ~~ ~~ប~~ ~~ន្ទ~~ ~~ប~~ ~~់ណ~~ ~~ាមួ~~ ~~យ~~ ~~ឡ~~ ~~ើ~~ ~~យ~~ ~~ប្រ~~ ~~សិ~~ ~~ន~~ ~~ប~~ ~~ើ~~ ~~ល~~ ~~ក~~ ~~្ខ~~ ~~ខ~~ ~~ណ~~ ~~្ឌ~~ ~~ទ~~ ~~ាំ~~ ~~ង~~ ~~អ~~ ~~ស~~ ~~់~~ ~~ខ~~ ~~ាង~~ ~~ក្រ~~ ~~ោ~~ ~~ម~~ ~~នេ~~ ~~ះ~~ ~~ត្រ~~ ~~ូ~~ ~~ว~~ ~~ប~~ ~~ាន~~ ~~ប~~ ~~ំ~~ ~~ពេ~~ ~~ញ~~ ~~៖~~

(1) ~~បន្ទ~~ ~~ប~~ ~~ស្ន~~ ~~ាក~~ ~~នៅ~~ ~~ឬ~~ ~~ប~~ ~~ន្ទ~~ ~~ប~~ ~~ត្រ~~ ~~ូ~~ ~~ប~~ ~~ាន~~ ~~លើ~~ ~~ក~~ ~~យ~~ ~~ក~~ ~~ម~~ ~~ក~~ ~~ដ~~ ~~ាក~~ ~~នៅ~~ ~~ក~~ ~~្នុ~~ ~~ង~~ ~~រ~~ ~~ប~~ ~~ាយ~~ ~~ការ~~ ~~ណ~~ ~~៍~~ ~~អ~~ ~~ធ~~ ~~ិ~~ ~~ការ~~ ~~ក~~ ~~ិ~~ ~~ច្ចោ~~ ~~យ~~ ~~ភ្នា~~ ~~ក~~ ~~ង~~ ~~ារ~~ ~~រ~~ ~~ដ~~ ~~្ឋ~~ ~~ាភ~~ ~~ិ~~ ~~ប~~ ~~ាល~~ ~~ស~~ ~~ម~~ ~~ស្រ~~ ~~ប~~ ~~ដ~~ ~~ោ~~ ~~យ~~ ~~ម~~ ~~ាន~~ ~~ប~~ ~~ញ្ហ~~ ~~ាសុ~~ ~~ខ~~ ~~ភ~~ ~~ាព~~ ~~ធ~~ ~~ន់~~ ~~ធ~~ ~~រ~~ ~~សុ~~ ~~វ~~ ~~ត្ថ~~ ~~ិ~~ ~~ភ~~ ~~ាព~~ ~~អ~~ ~~គ្គ~~ ~~ី~~ ~~ភ~~ ~~័យ~~ ~~ឬ~~ ~~រ~~ ~~ំ~~ ~~លោ~~ ~~ភ~~ ~~ប~~ ~~ំ~~ ~~ព~~ ~~ាន~~ ~~ក្រ~~ ~~ម~~ ~~ដ~~ ~~ូ~~ ~~ច~~ ~~ត្រ~~ ~~ូ~~ ~~ប~~ ~~ាន~~ ~~ក~~ ~~ំ~~ ~~ណ~~ ~~ត់~~ ~~ដោ~~ ~~យ~~ ~~វ~~ ~~គ្គ~~ ~~17920.3~~ ~~នៃ~~ ~~ក្រ~~ ~~ម~~ ~~សុ~~ ~~វ~~ ~~ត្ថ~~ ~~ិ~~ ~~ភ~~ ~~ាព~~ ~~និ~~ ~~ង~~ ~~សុ~~ ~~ខ~~ ~~ភ~~ ~~ាព~~ ~~លើ~~ ~~ក~~ ~~លែ~~ ~~ង~~ ~~តែ~~ ~~ការ~~ ~~ប~~ ~~ំ~~ ~~ព~~ ~~ាន~~ ~~ដែ~~ ~~ល~~ ~~ប~~ ~~ណ~~ ~~្ត~~ ~~ាល~~ ~~ម~~ ~~ក~~ ~~ពី~~ ~~គ្រោ~~ ~~ះ~~ ~~ម~~ ~~ហ~~ ~~ន្ត~~ ~~រ~~ ~~ាយ~~ ~~។~~

(2) ~~ការ~~ ~~លើ~~ ~~ក~~ ~~យ~~ ~~ក~~ ~~ម~~ ~~ក~~ ~~នេ~~ ~~ះ~~ ~~ត្រ~~ ~~ូ~~ ~~ប~~ ~~ាន~~ ~~ចេ~~ ~~ញ~~ ~~យ~~ ~~ាង~~ ~~តិ~~ ~~ច~~ ~~ណ~~ ~~ាស់~~ 60 ~~ថ្ងៃ~~ ~~មុ~~ ~~ន~~ ~~ កាលបរិ~~ ~~ច~~ ~~ឆេ~~ ~~ទ~~ ~~នៅ~~ ~~ទ~~ ~~ំ~~ ~~នេ~~ ~~រ~~ ~~។~~

(3) ~~ការ~~ ~~លើ~~ ~~ក~~ ~~ឡើ~~ ~~ង~~ ~~ពី~~ ~~ការ~~ ~~ប~~ ~~ំ~~ ~~ព~~ ~~ាន~~ ~~មិ~~ ~~ន~~ ~~ត្រ~~ ~~ូ~~ ~~ប~~ ~~ាន~~ ~~ពិ~~ ~~និ~~ ~~ត្យ~~ ~~មើ~~ ~~ល~~ ~~នៅ~~ ~~មុ~~ ~~ន~~ ~~ពេ~~ ~~ល~~ ~~អ~~ ~~្នក~~ ~~ជួ~~ ~~ល~~ ~~លុ~~ ~~ប~~ ~~និ~~ ~~ង~~ ~~មិ~~ ~~ន~~ ~~ដ~~ ~~ាក~~ ~~ជួ~~ ~~ល~~ ~~ក~~ ~~្នុ~~ ~~ង~~ ~~រ~~ ~~យ~~ ~~៖~~ ~~ពេ~~ ~~ល~~ 60 ~~ថ្ងៃ~~ ~~ឬ~~ ~~រ~~ ~~យ~~ ~~៖~~ ~~ពេ~~ ~~ល~~ ~~លើ~~ ~~ស~~ ~~នេ~~ ~~ះ~~ ~~។~~ ~~ប~~ ~~ុ~~ ~~ន្តែ~~ ~~ រ~~ ~~យ~~ ~~៖~~ ~~ពេ~~ ~~ល~~ 60 ~~ថ្ងៃ~~ ~~អ~~ ~~ាច~~ ~~ត្រ~~ ~~ូ~~ ~~ប~~ ~~ាន~~ ~~ព~~ ~~ន្យ~~ ~~ដោ~~ ~~យ~~ ~~ភ្នា~~ ~~ក~~ ~~ង~~ ~~ារ~~ ~~រ~~ ~~ដ~~ ~~្ឋ~~ ~~ាភ~~ ~~ិ~~ ~~ប~~ ~~ាល~~ ~~ស~~ ~~ម~~ ~~ស្រ~~ ~~ប~~ ~~ដ~~ ~~ែ~~ ~~ល~~ ~~ប~~ ~~ាន~~ ~~ចេ~~ ~~ញ~~ ~~ការ~~ ~~លើ~~ ~~ក~~ ~~ឡើ~~ ~~ង~~ ~~នេ~~ ~~ះ~~ ~~។~~

ផ្នែកទី 7. សំណង់សេរីភាព។

ច្បាប់នេះ ~~ត្រូ~~ ~~ូ~~ ~~ប~~ ~~ាន~~ ~~ប~~ ~~ក~~ ~~ស្រ~~ ~~ាយ~~ ~~ដោ~~ ~~យ~~ ~~ទ~~ ~~ូ~~ ~~ល~~ ~~ំ~~ ~~ទ~~ ~~ូ~~ ~~ល~~ ~~ាយ~~ ~~ស្រ~~ ~~ប~~ ~~តា~~ ~~ម~~ ~~គោ~~ ~~ល~~ ~~ប~~ ~~ំ~~ ~~ណ~~ ~~ង~~ ~~ រ~~ ~~ប~~ ~~ស~~ ~~់~~ ~~វ~~ ~~ា~~ ~~។~~

ផ្នែកទី 8. វិសោធនកម្ម និងនិរាករណ៍។

អនុលោមតាមផ្នែករង (c) នៃផ្នែកទី 10 នៃមាត្រា II នៃរដ្ឋធម្មនុញ្ញ California ~~ រ~~ ~~ដ~~ ~~ ~~

ជាមួយវា បទបញ្ញត្តិនៃច្បាប់នេះនឹងត្រូវឈ្នះទាំងស្រុង ហើយវិធានការ ឬ បណ្តាវិធានការផ្សេងទៀត ត្រូវចាត់ទុកជាមោឃៈ។

សំណើ ប្រជា មតិ 22

វិធានការផ្តួចផ្តើមនេះ បានដាក់ជូន ប្រជាជន ដោយអនុលោម ទៅតាម មាត្រានៃភាគ 8 មាត្រា II នៃធម្មនុញ្ញរដ្ឋ California។

វិធានការផ្តួចផ្តើមនេះបន្ថែមផ្នែកទាំងឡាយទៅលើក្រមស្តីពីអាជីវកម្ម និងវិជ្ជាជីវៈ ហើយធ្វើវិសោធនកម្មផ្នែកមួយនៃក្រមស្តីពីប្រាក់ចំណូល និងពន្ធដារ។ ដូច្នេះ បទបញ្ញត្តិថ្មីៗដែលត្រូវបានស្នើឲ្យបន្ថែមចូល ត្រូវបានបោះពុម្ពជា *ប្រភេទអក្សរ ទ្រេត* ដើម្បីបញ្ជាក់ថាវាជាបទបញ្ញត្តិថ្មី។

សំណើច្បាប់

ផ្នែកទី 1. ជំពូកទី 10.5 (ចាប់ផ្តើមជាមួយនឹងផ្នែកទី 7448) ត្រូវបានបន្ថែមទៅលើចំណែកទី 3 នៃក្រមស្តីពីអាជីវកម្ម និងវិជ្ជាជីវៈដូចខាងក្រោម៖

ជំពូកទី 10.5. អ្នកបើកបរ និងសេវាផ្អែកលើកម្មវិធី

មាត្រា 1. ចំណងជើង ការរកឃើញ សេចក្តីប្រកាស និងសេចក្តីថ្លែងការណ៍ពីគោលបំណង

7448. ចំណងជើង ជំពូកនេះត្រូវមានគេដឹងឮ ហើយអាចត្រូវបានដកស្រង់ជា ច្បាប់ការពារអ្នកបើកបរ និងសេវាផ្អែកលើកម្មវិធី (Protect App-Based Drivers and Services Act)។

7449. ការរកឃើញ និងសេចក្តីប្រកាស។ ប្រជាជននៃរដ្ឋ California រកឃើញ និងប្រកាសដូចខាងក្រោម៖

(a) ពលរដ្ឋ California រាប់រយពាន់នាក់ កំពុងជ្រើសរើសធ្វើការជាអ្នកម៉ៅការឯករាជ្យនៅក្នុងសេដ្ឋកិច្ចទំនើប ដោយប្រើអ្នកបើកបររបស់ក្រុមហ៊ុនដឹកជញ្ជូន និងវេទិកាចែកចាយផ្អែកលើកម្មវិធី ដើម្បីដឹកជញ្ជូនអ្នកដំណើរ និងចែកចាយម្ហូបអាហារ គ្រឿងទេស និងទំនិញផ្សេងៗទៀត ជាមធ្យោបាយក្នុងការរកប្រាក់ចំណូល ដោយរក្សានូវភាពបត់បែនក្នុងការសម្រេចចិត្តអំពីពេលវេលា ទីកន្លែង និងរបៀបដែលពួកគេធ្វើការ។

(b) អ្នកបើកបររបស់ក្រុមហ៊ុនដឹកជញ្ជូន និងចែកចាយផ្អែកលើកម្មវិធីទាំងនេះ រួមមានជាអាទិ៍ដូចជា ឪពុកម្តាយដែលចង់ធ្វើការតាមគម្រោងពេលមានភាពបត់បែន ខណៈពេលដែលកូនៗរបស់ពួកគេនៅសាលា សិស្សនិស្សិតដែលចង់រកលុយនៅចន្លោះម៉ោងសិក្សា និវត្តជនដែលបើកបរឲ្យក្រុមហ៊ុនដឹកជញ្ជូន ឬចែកចាយពីរ ឬបីម៉ោងក្នុងមួយសប្តាហ៍ ដើម្បីបំពេញបន្ថែមប្រាក់ចំណូលថេរ និងសម្រាប់អន្តរអំពើរជាមួយសង្គម ប្តី ឬប្រពន្ធកងទ័ព និងដៃគូរដែលតែងតែផ្លាស់ទីលំនៅជាញឹកញាប់ និងក្រុមគ្រួសារដែលតស៊ូជាមួយនឹងបន្ទុកចំណាយខ្ពស់ក្នុងការរស់នៅរដ្ឋ California ដែលត្រូវការរកចំណូលបន្ថែម។

(c) អ្នកប្រើប្រាស់ និងអាជីវកម្មនៅរដ្ឋ California រាប់លាននាក់ និងសេដ្ឋកិច្ចរបស់រដ្ឋយើងទាំងមូល ក៏ទទួលអត្ថប្រយោជន៍មកពីសេវាកម្មរបស់អ្នកដែលធ្វើការជាអ្នកម៉ៅការឯករាជ្យ ដោយប្រើអ្នកបើកបរ និងវេទិការបស់ក្រុមហ៊ុនដឹកជញ្ជូន និងចែកចាយដោយផ្អែកលើកម្មវិធី។ អ្នកបើកបររបស់ក្រុមហ៊ុនដឹកជញ្ជូន និងចែកចាយដោយផ្អែកលើកម្មវិធីកំពុងតែ ផ្តល់ជូននូវការដឹកជញ្ជូនដែលមានភាពងាយស្រួល និងមានលទ្ធភាពចំណាយបានសម្រាប់សាធារណជន ដោយកាត់បន្ថយនូវការបើកបរដោយមានកំហុស និងដោយស្រវឹង ធ្វើឲ្យប្រសើរឡើងនូវចល័តភាពសម្រាប់ជនវ័យចាស់ជរា និងបុគ្គលដែលមានពិការភាព ផ្តល់ជូននូវជម្រើសក្នុងការដឹកជញ្ជូនថ្មីសម្រាប់ក្រុមគ្រួសារដែលពុំមានលទ្ធភាពចំណាយទៅលើយានយន្ត និងផ្តល់ជូននូវជម្រើសក្នុងការចែកចាយថ្មីដែលមានលទ្ធភាពចំណាយ និងងាយស្រួលសម្រាប់ហាងលក់គ្រឿងទេស ភោជនីយដ្ឋាន អ្នកលក់រាយ និងអាជីវកម្មក្នុងមូលដ្ឋាន និងភ្ញៀវរបស់ពួកគេ។

(d) ទោះជាយ៉ាងណា ច្បាប់ថ្មីៗនេះបានគំរាមកំហែងបំបាត់ចោលនូវឱកាសការងារដែលអាចបត់បែនបានរបស់ពលរដ្ឋ California រាប់រយពាន់នាក់ ដោយមានសក្តានុពលបង្ខំឲ្យពួកគេធ្វើការតាមវេនដែលបានកំណត់ និងម៉ោងដែលចាំបាច់ខានមិនបាន បំបាត់ចោលនូវសមត្ថភាពរបស់ពួកគេក្នុងការសម្រេចចិត្តដោយខ្លួនឯងអំពីការងារដែលពួកគេទទួលយក និងម៉ោងដែលពួកគេធ្វើការងារ។

(e) កិច្ចការពារសមត្ថភាពរបស់ពលរដ្ឋ California ឲ្យធ្វើការជាអ្នកម៉ៅការឯករាជ្យទូទាំងរដ្ឋ ដោយប្រើអ្នកបើកបរ និងវេទិការបស់ក្រុមហ៊ុនដឹកជញ្ជូន និងចែកចាយដោយផ្អែកលើកម្មវិធី មានភាពចាំបាច់ណាស់សម្រាប់ធ្វើឲ្យប្រជាពលរដ្ឋអាចបន្តជ្រើសរើសការងារណាមួយដែលពួកគេទទួលយក ធ្វើការញឹកញាប់ ឬតិចតួចតាមការចូលចិត្តរបស់ពួកគេ និងធ្វើការជាមួយវេទិកា ឬក្រុមហ៊ុនច្រើន ដែលទាំងអស់នេះរក្សានូវលទ្ធភាពប្រើប្រាស់អ្នកបើកបរ និងសេវារបស់ក្រុមហ៊ុនដឹកជញ្ជូន និងចែកចាយដោយផ្អែកលើកម្មវិធី ដែលមានសារប្រយោជន៍ចំពោះអ្នកប្រើប្រាស់ អាជីវកម្មខ្នាតតូច និងសេដ្ឋកិច្ចរដ្ឋ California ។

(f) អ្នកបើកបររបស់ក្រុមហ៊ុនដឹកជញ្ជូន និងចែកចាយដោយផ្អែកលើកម្មវិធី សមតែនឹងទទួលបានសុវត្ថិភាពសេដ្ឋកិច្ចថេរ។ ជំពូកនេះមានភាពចាំបាច់សម្រាប់ការពារនូវសិទ្ធិសេរីភាពរបស់ពួកគេក្នុងការធ្វើការដោយឯករាជ្យ ដោយផ្តល់ជូនកម្មករ និយោជិតទាំងនេះនូវអត្ថប្រយោជន៍ និងកិច្ចការពារថ្មីៗក្រោមច្បាប់បច្ចុប្បន្ននេះ។ អត្ថប្រយោជន៍ និងកិច្ចការពារទាំងនេះ រួមមានជាអាទិ៍ ជំនួយផ្នែកថែទាំសុខភាពដែលស្របគ្នាជាមួយនឹងការរួមចំណែកជាមធ្យមដែលត្រូវបានតម្រូវក្រោមច្បាប់ស្តីពីការថែទាំដែលមានលទ្ធភាពចំណាយ (Affordable Care Act, ACA) ការធានានូវប្រាក់ចំណូលអប្បបរិមាថ្មីដែលស្មើនឹង 120 ភាគរយនៃប្រាក់ឈ្នួលអប្បបរិមា ដោយគ្មានអតិបរិមា ប្រាក់សំណងសម្រាប់ចំណាយទៅលើយានយន្ត ការធានារ៉ាប់រងលើគ្រោះថ្នាក់ដោយសារការងារ ដើម្បីរ៉ាប់រងទៅលើរបួសស្នាមនៅកន្លែងធ្វើការ និងកិច្ចការពារប្រឆាំងនឹងការរើសអើង និងការបំពានផ្លូវភេទ។

(g) ច្បាប់រដ្ឋ California និងក្រុមហ៊ុនបណ្តាញអ្នកដឹកជញ្ជូន និងចែកចាយ គួរការពារសុវត្ថិភាពរបស់អ្នកបើកបរ និងអ្នកប្រើប្រាស់ដោយពុំមានការប៉ះពាល់ទៅលើសិទ្ធិរបស់អ្នកបើកបររបស់ក្រុមហ៊ុនដឹកជញ្ជូន និងចែកចាយដោយផ្អែកលើកម្មវិធី ដើម្បីធ្វើការជាអ្នកម៉ៅការឯករាជ្យ។ កិច្ចការពារនេះ គួរដាក់បញ្ចូលជាអប្បបរិមានូវការត្រួតពិនិត្យសាវតាបទល្មើសព្រហ្មទណ្ឌរបស់អ្នកបើកបរ គោលនយោបាយគ្មានការយោគយល់សម្រាប់បទល្មើសដែលពាក់ព័ន្ធនឹងគ្រឿងញៀន និងគ្រឿងស្រវឹង និងការបណ្តុះបណ្តាលអំពីសុវត្ថិភាពអ្នកបើកបរ។

7450. សេចក្តីថ្លែងការណ៍ស្តីពីគោលបំណង។ គោលបំណងនៃជំពូកនេះមានដូចតទៅ៖

(a) ការពារសិទ្ធិស្របច្បាប់ជាមូលដ្ឋានរបស់ពលរដ្ឋ California ក្នុងការជ្រើសរើសការងារជាអ្នកម៉ៅការឯករាជ្យជាមួយក្រុមហ៊ុនបណ្តាញអ្នកបើកបរ និងដឹកជញ្ជូន និងចែកចាយទូទាំងរដ្ឋ។

(b) ការពារសិទ្ធិបុគ្គលរបស់អ្នកបើកបររបស់ក្រុមហ៊ុនដឹកជញ្ជូន និងចែកចាយដោយផ្អែកលើកម្មវិធី ក្នុងការមានភាពបត់បែនសម្រាប់កំណត់ម៉ោង ពេលវេលា ទីកន្លែង និងរបៀបធ្វើការរបស់ពួកគេ។

(c) តម្រូវឲ្យក្រុមហ៊ុនបណ្តាញអ្នកដឹកជញ្ជូន និងចែកចាយផ្តល់ជូននូវកិច្ចការពារ និងអត្ថប្រយោជន៍ថ្មីសម្រាប់អ្នកបើកបររបស់ក្រុមហ៊ុនដឹកជញ្ជូន និងចែកចាយដោយផ្អែកលើកម្មវិធី រួមមានជាអាទិ៍ កម្រិតនៃប្រាក់សំណងអប្បបរិមា ការធានារ៉ាប់រងដើម្បីរ៉ាប់រងទៅលើរបួសស្នាម

21

22

នៅកន្លែងធ្វើការ ការធានារ៉ាប់រងគ្រោះថ្នាក់ដោយរថយន្ត ជំនួយផ្នែកថែទាំសុខភាពសម្រាប់អ្នកបើកបរដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ កិច្ចការពារប្រឆាំងនឹងការបំពាន និងការរើសអើង និងសិទ្ធិកិច្ចសន្យាដែលចាំបាច់ខានមិនបាន និងដំណើរការប្តឹងខទ្ទរណ៍។

(d) ធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាពសាធារណៈ ដោយតម្រូវឲ្យមានការត្រួតពិនិត្យសាវតាបទល្មើសព្រហ្មទណ្ឌរបស់អ្នកបើកបរ ការបណ្តុះបណ្តាលសុវត្ថិភាពអ្នកបើកបរ និងបទបញ្ញត្តិសុវត្ថិភាពផ្សេងៗដើម្បីជួយធានាថាអ្នកបើកបររបស់ក្រុមហ៊ុនដឹកជញ្ជូន និងចែកចាយដោយផ្អែកលើកម្មវិធីមិនបង្ការគំរាមកំហែងដល់អ្នកប្រើប្រាស់ ឬសាធារណជន។

មាត្រា 2. ឯករាជ្យភាពរបស់អ្នកបើកបរដោយផ្អែកលើកម្មវិធី

7451. កិច្ចការពារឯករាជ្យភាព។ ថ្វីបើមានបទបញ្ញត្តិនៃច្បាប់ណាមួយផ្សេងទៀតក៏ដោយ រួមមានជាអាទិ៍ ក្រមស្តីពីការងារ ក្រមស្តីពីការធានារ៉ាប់រងភាពគ្មានការងារធ្វើ និងរាល់បទបញ្ជា នីយ័តកម្ម ឬជម្រើសទាំងឡាយរបស់ក្រសួងទំនាក់ទំនងឧស្សាហកម្ម ឬគណៈកម្មការអង្គភាព ឬគណៈកម្មាធិការណាមួយនៅក្នុង ក្រសួងទំនាក់ទំនងឧស្សាហកម្ម អ្នកបើកបរដោយផ្អែកលើកម្មវិធី គឺជាអ្នកម៉ៅការឯករាជ្យម្នាក់ ហើយពុំមែនជានិយោជិក ឬទីភ្នាក់ងារដែលពាក់ព័ន្ធនឹងទំនាក់ទំនងរបស់អ្នកបើកបរដោយផ្អែកលើកម្មវិធីជាមួយនឹងក្រុមហ៊ុនបណ្តាញ ប្រសិនបើលក្ខខណ្ឌទាំងឡាយខាងក្រោមត្រូវបានបំពេញ៖

(a) ក្រុមហ៊ុនបណ្តាញ មិនបញ្ជាក់ច្បាស់ជាឯកតោភាគីនូវកាលបរិច្ឆេទ ម៉ោងនៃថ្ងៃ ចំនួនអប្បបរិមានៃម៉ោង ដែលក្នុងនោះអ្នកបើកបរដោយផ្អែកលើកម្មវិធី ត្រូវតែចូលទៅក្នុងកម្មវិធី ឬវេទិកាដែលអនុញ្ញាតតាមអនឡានរបស់ក្រុមហ៊ុនបណ្តាញឡើយ។

(b) ក្រុមហ៊ុនបណ្តាញមិនតម្រូវឲ្យអ្នកបើកបរដោយផ្អែកលើបណ្តាញទទួលយកសំណើសុំសេវាដឹកជញ្ជូន និងចែកចាយជាក់លាក់ណាមួយ ថាជាលក្ខខណ្ឌមួយនៃការរក្សានូវសិទ្ធិចូលដំណើរការកម្មវិធី ឬវេទិកាដែលអនុញ្ញាតតាមអនឡានរបស់ក្រុមហ៊ុនបណ្តាញឡើយ។

(c) ក្រុមហ៊ុនបណ្តាញ មិនរឹតត្បិតអ្នកបើកបរដោយផ្អែកលើកម្មវិធីពីការផ្តល់សេវាដឹកជញ្ជូន ឬចែកចាយតាមរយៈក្រុមហ៊ុនបណ្តាញផ្សេងទៀតឡើយ លើកលែងតែអំឡុងពេលដែលជាប់ពាក់ព័ន្ធប៉ុណ្ណោះ។

(d) ក្រុមហ៊ុនបណ្តាញមិនរឹតត្បិតអ្នកបើកបរដោយផ្អែកលើកម្មវិធីពីការធ្វើការនៅក្នុងការងារ ឬអាជីវកម្មស្របច្បាប់ណាមួយផ្សេងទៀតឡើយ។

7452. បទបញ្ញត្តិនៃកិច្ចសន្យា និងការរំលាយកិច្ចសន្យា។ (a) ក្រុមហ៊ុនបណ្តាញ និងអ្នកបើកបរដោយផ្អែកលើកម្មវិធីត្រូវចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ មុនពេលដែលអ្នកបើកបរទទួលបានសិទ្ធិចូលទៅដំណើរការកម្មវិធី ឬវេទិកាដែលអនុញ្ញាតតាមអនឡានរបស់ក្រុមហ៊ុនបណ្តាញ។

(b) ក្រុមហ៊ុនបណ្តាញ មិនត្រូវរំលាយចោលកិច្ចសន្យាជាមួយអ្នកបើកបរដោយផ្អែកលើកម្មវិធីឡើយ លុះត្រាតែផ្អែកទៅលើអង្គហេតុអ្វីមួយដែលមានបញ្ជាក់ច្បាស់នៅក្នុងកិច្ចសន្យានោះ។

(c) ក្រុមហ៊ុនបណ្តាញត្រូវផ្តល់ដំណើរការតវ៉ា សម្រាប់អ្នកបើកបរដែលប្រើប្រាស់កម្មវិធី ដែល កិច្ចសន្យារបស់ពួកគេត្រូវបានបញ្ចប់ដោយក្រុមហ៊ុនបណ្តាញ។

7452.5. មិនប៉ះពាល់ឯករាជ្យភាព មិនមានអ្វីមួយនៅក្នុងមាត្រា 3 (ចាប់ផ្តើមជាមួយនឹងភាគ 7453) ដល់មាត្រា 11 (ចាប់ផ្តើមជាមួយ នឹងភាគ 7467), រួមបញ្ចូលគ្នា, នៃជំពូកនេះត្រូវបានបកស្រាយ តាមរបៀបដែលកែប្រែទំនាក់ទំនងរវាង ក្រុមហ៊ុនបណ្តាញ និងអ្នកបើកបរដែលប្រើកម្មវិធី ក្នុងគោលបំណងបំពេញលក្ខខណ្ឌ ដែលមានចែង នៅក្នុងភាគ 7451 ឡើយ។

មាត្រា 3. ការទូទាត់ប្រាក់

7453. ការធានាលើការរកប្រាក់ (a) ក្រុមហ៊ុនបណ្តាញត្រូវធានាថាសម្រាប់រយៈពេលរកប្រាក់ នីមួយៗ អ្នកបើកបរដែលប្រើប្រាស់កម្មវិធីត្រូវបានទូទាត់ប្រាក់ មិនតិចជាងទឹកប្រាក់អប្បបរមា ដូចមាន ចែងក្នុងភាគនេះឡើយ។ ទឹកប្រាក់ចំណូលអប្បបរមាបង្កើតជាការធានា នូវកម្រិតទូទាត់ប្រាក់អប្បបរមាសម្រាប់អ្នកបើកបរដែល ប្រើកម្មវិធី ដែលមិនអាចកាត់បន្ថយបានឡើយ។ ទឹកប្រាក់ចំណូលអប្បបរមានេះមិនអាចហាមឃាត់អ្នកបើកបរ ដែលប្រើកម្មវិធី ពីការរកប្រាក់ បានកាន់តែច្រើនឡើយ។

(b) សម្រាប់រយៈពេលរកប្រាក់ចូលនីមួយៗ ក្រុមហ៊ុនបណ្តាញត្រូវប្រៀបធៀបចំណូលសុទ្ធរបស់អ្នក បើកបរ ដែលប្រើកម្មវិធីទៅនឹងប្រាក់ចំណូលអប្បបរមា សម្រាប់អ្នកបើកបរដដែលនេះ ក្នុងរយៈពេលរកប្រាក់។ ក្នុងករណីដែលចំណូលសុទ្ធរបស់អ្នកបើកបរ ដែលប្រើកម្មវិធីគឺតិចជាងប្រាក់ចំណូលអប្បបរមា សម្រាប់រយៈពេលរកប្រាក់នោះ ក្រុមហ៊ុនបណ្តាញត្រូវរួមបញ្ចូលប្រាក់បន្ថែមដើម្បីបង្ក្រប់លើចំណូលរបស់អ្នកបើកបរ ដែលប្រើកម្មវិធីមិនហួសពីរយៈពេលរកប្រាក់បន្ទាប់។

(c) ក្រុមហ៊ុនបណ្តាញ ឬភ្នាក់ងារមិនត្រូវយក ទទួល ឬរក្សាទុកប្រាក់ទឹកតែ ឬផ្នែកណាមួយនៃប្រាក់ ដែលត្រូវបានបង់ ប្រគល់ឲ្យ ឬទុកឲ្យអ្នកបើកបរដែលប្រើកម្មវិធីពីអតិថិជន ឬកាត់យក ទឹកប្រាក់ណាមួយពីប្រាក់ចំណូលដែលត្រូវបង់ឲ្យអ្នកបើកបរប្រើកម្មវិធី សម្រាប់ការដឹកអ្នកដំណើរ ឬដឹកជញ្ជូននៅលើគណនីនៃប្រាក់ទឹកតែដែលបានបង់ពាក់ព័ន្ធនឹងការដឹក ឬការដឹកជញ្ជូនឡើយ។ ក្រុមហ៊ុនបណ្តាញដែលអនុញ្ញាតឲ្យអតិថិជនបង់ប្រាក់ទឹកតែតាមប័ណ្ណឥណទានត្រូវបង់ទឹកប្រាក់ទឹកតែទាំងអស់ទៅអ្នកបើកបរដែលប្រើកម្មវិធី ដែលអតិថិជនបានបង្ហាញនៅលើបង្ការ៉ាន់ដៃប័ណ្ណឥណទានដោយមិនមានការកាត់យកសម្រាប់ថ្លៃសេវា ឬការចំណាយលើការដំណើរការការ ទូទាត់តាមប័ណ្ណឥណទានដែលអាចគិតថ្លៃមកលើក្រុមហ៊ុនបណ្តាញដោយក្រុមហ៊ុនកាតក្រេឌីត។

(d) សម្រាប់គោលបំណងនៃជំពូកនេះ និយមន័យខាងក្រោមអនុវត្ត៖

(1) "ប្រាក់ឈ្នួល អប្បបរមា ដែលអាច អនុវត្តបាន" សំដៅលើប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ដោយរដ្ឋសម្រាប់គ្រប់វិស័យទាំងអស់ ឬ ប្រសិនបើអ្នកដំណើរ ឬទំនិញត្រូវបានទៅយកនៅក្នុងព្រំដែននៃរដ្ឋាភិបាលក្នុងមូលដ្ឋាន ដែលមានប្រាក់ឈ្នួលអប្បបរមាខ្ពស់ជាងដែលជាទូទៅអាចអនុវត្តបានចំពោះឧស្សាហកម្មទាំងអស់ ប្រាក់ឈ្នួលអប្បបរមាក្នុងមូលដ្ឋាននៃ រដ្ឋាភិបាលក្នុងមូលដ្ឋាននោះ។ ប្រាក់ឈ្នួលអប្បបរមាដែលអាចអនុវត្តបានត្រូវបានកំណត់តាមទីតាំងដែលអ្នកដំណើរ ឬទំនិញត្រូវ បានទៅយក ហើយត្រូវអនុវត្តសម្រាប់ពេលវេលាដែលបានចំណាយក្នុងការបំពេញសំណើការដឹកអ្នកដំណើរ ឬការដឹកជញ្ជូននោះ។

(2) "រយៈពេលរកប្រាក់ចំណូល" សំដៅលើរយៈពេលទូទាត់ប្រាក់ដែលបានកំណត់ដោយក្រុមហ៊ុនបណ្តាញ ដែលមិនលើសពីថ្ងៃប្រតិទិនជាប់គ្នា 14 ថ្ងៃ។

(3) "ប្រាក់ចំណូលសុទ្ធ" សំដៅលើរាល់ចំណូលដែលទទួលបានដោយអ្នកបើកបរដែលប្រើកម្មវិធី ក្នុងរយៈពេលនៃការរកប្រាក់ចំណូល ករណីដែលចំនួនទឹកប្រាក់គឺស្របទៅតាមស្តង់ដារ ទាំងពីរខាងក្រោម៖

(A) ចំនួនទឹកប្រាក់នោះមិនរួមបញ្ចូលប្រាក់ទឹកតែ ថ្លៃផ្លូវ ថ្លៃសម្អាត ថ្លៃព្រលានយន្តហោះ ឬការឆ្លងកាត់ទៅអតិថិជនទេ។

(B) ទឹកប្រាក់អាចរួមបញ្ចូលប្រាក់លើកទឹកចិត្ត ឬប្រាក់រង្វាន់ផ្សេងទៀត។

22

(4) "កម្រិតអប្បបរមានៃចំណូលសុទ្ធ" សំដៅលើ ទឹកប្រាក់សរុបសម្រាប់ រយៈពេលរកប្រាក់ណាមួយដែលរួមមាន៖

(A) សម្រាប់រយៈពេលពាក់ព័ន្ធទឹកប្រាក់សរុប 120 ភាគរយនៃ ប្រាក់ឈ្នួលអប្បបរមាជាធរមានសម្រាប់រយៈពេលពាក់ព័ន្ធនោះ។

(B) (i) ការទូទាត់ប្រាក់ក្នុងមួយម៉ែលសម្រាប់ការចំណាយលើរថយន្ត ដែលបានកំណត់នៅក្នុងអនុកថាខណ្ឌនេះ គុណនឹងចំនួនម៉ែលសរុប ជាក់ស្តែង។

(ii) បន្ទាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃជំពូកនេះនិងសម្រាប់ឆ្នាំ ប្រតិទិន 2021 ការទូទាត់ប្រាក់ក្នុងមួយម៉ែលសម្រាប់ការចំណាយលើ រថយន្ត ត្រូវមានតម្លៃសាបសិបសេន ($0.30) ក្នុងមួយម៉ែលបើកបរ។ សម្រាប់ឆ្នាំប្រតិទិនក្រោយពីឆ្នាំ 2021 ចំនួនទឹកប្រាក់បើកបរក្នុងមួយម៉ែ លត្រូវកែតម្រូវស្របតាមប្រការ (iii)។

(iii) សម្រាប់ឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំ 2021 ការទូទាត់ប្រាក់ក្នុងមួ យម៉ែលសម្រាប់ការចំណាយលើរថយន្តដែលមានរៀបរាប់នៅក្នុងប្រការ (ii) ត្រូវកែតម្រូវជាប្រចាំឆ្នាំដើម្បីឆ្លុះបញ្ចាំងពីកំណើនអតិផរណាដូចបាន វាស់វែងដោយ សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់សម្រាប់អ្នកប្រើប្រាស់នៅ ទីប្រជុំជនទាំងអស់ (CPI-U) ដែលបោះពុម្ពផ្សាយដោយការិយាល័យ ស្ថិតិការងារសហរដ្ឋ អាមេរិក។ ការិយាល័យរតនាគារត្រូវគណនា និង បោះពុម្ពផ្សាយអំពីការកែតម្រូវដែលបានតម្រូវតាមអនុកថាខណ្ឌនេះ។

(e) មិនមានអ្វីមួយនៅក្នុងភាគនេះត្រូវបានបកស្រាយដើម្បីតម្រូវ ឲ្យ ក្រុមហ៊ុនបណ្តាញផ្តល់ចំនួនទឹកប្រាក់ជាក់លាក់នៃការទូទាត់ប្រាក់ ទៅអ្នកបើកបរ ដែលប្រើកម្មវិធីសម្រាប់សំណើដឹកអ្នកដំណើរ ឬការ ដឹកជញ្ជូនដែលបានកំណត់ណាមួយ ករណីដែលប្រាក់ចំណូលសុទ្ធរបស់ អ្នកបើកបរដែលប្រើកម្មវិធីសម្រាប់ រយៈពេលរកប្រាក់នីមួយៗស្មើនឹង ឬលើសពីកម្រិតអប្បបរមា នៃចំណូលសុទ្ធរបស់អ្នកបើកបរប្រើកម្មវិធី សម្រាប់រយៈពេលរកប្រាក់នោះ ដូចមានចែងនៅក្នុងផ្នែករង (b)។ ដើម្បី ភាពច្បាស់លាស់ កម្រិតអប្បបរមានៃប្រាក់ចំណូលសរុបផ្នែកនេះ អាច នឹងត្រូវបានគណនាជាមធ្យមភាគសម្រាប់រយៈពេលរកប្រាក់នីមួយៗ។

មាត្រា 4. អត្ថប្រយោជន៍

7454. ការឧបត្ថម្ភសម្រាប់ការថែទាំសុខភាព។ (a) ស្របតាមការរួម ចំណែកជាមធ្យមដែលត្រូវបានតម្រូវនៅក្រោមច្បាប់ស្តីពីការថែទាំ មានតម្លៃសមរម្យ (ACA) ក្រុមហ៊ុនបណ្តាញត្រូវផ្តល់ប្រាក់ឧបត្ថម្ភ ការថែទាំសុខភាពប្រចាំត្រីមាសសម្រាប់អ្នកបើកបរដែលប្រើកម្មវិធីដែល មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានកំណត់នៅក្នុងផ្នែកនេះ។ អ្នកបើកបរដែលប្រើប្រាស់កម្មវិធីដែលមានទឹកប្រាក់មធ្យមសម្រាប់ម៉ោង បើកបរក្នុងមួយសប្តាហ៍នៅលើប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញក្នុងត្រីមាស ប្រតិទិនត្រូវទទួលបានការឧបត្ថម្ភ ដូចខាងក្រោមពីក្រុមហ៊ុនបណ្តាញ៖

(1) សម្រាប់មធ្យមភាគនៃម៉ោងបើកបរចំនួន 25 ម៉ោង ឬច្រើនជាងនេះ ក្នុងមួយសប្តាហ៍ ក្នុងត្រីមាសប្រតិទិន ការទូទាត់ប្រាក់ដែលច្រើនជាង ឬ ស្មើនឹង 100 ភាគរយនៃការរួមចំណែក ACA ជាមធ្យមសម្រាប់ប្រាក់ បុព្វលាភ Covered California ប្រចាំខែជាមធ្យមដែលអាចអនុវត្តបាន សម្រាប់ខែនីមួយៗនៅក្នុងត្រីមាស។

(2) សម្រាប់មធ្យមភាគនៃម៉ោងបើកបរយ៉ាងហោចណាស់ចំនួន 15 ម៉ោង ប៉ុន្តែតិចជាង 25 ម៉ោង ក្នុងមួយសប្តាហ៍ក្នុងត្រីមាសប្រតិទិន ការ ទូទាត់ប្រាក់ដែលច្រើនជាង ឬស្មើនឹង 50 ភាគរយ នៃការរួមចំណែក ACA ជាមធ្យមសម្រាប់ប្រាក់បុព្វលាភ Covered California ប្រចាំខែ ជាមធ្យម ដែលអាចអនុវត្តបានសម្រាប់ខែនីមួយៗនៅក្នុងត្រីមាស។

(b) នៅដំណាច់រយៈពេលរកប្រាក់នីមួយៗ ក្រុមហ៊ុនបណ្តាញត្រូវផ្តល់ ដល់អ្នកបើកបរដែលប្រើកម្មវិធីនូវព័ត៌មានខាងក្រោម៖

(1) ចំនួនម៉ោងដែលអ្នកបើកបរប្រើកម្មវិធីបានបើកបរសរុបនៅលើកម្មវិធី ឬប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញនៅក្នុងរយៈពេលនៃការរកប្រាក់នោះ។

(2) ចំនួនម៉ោងដែលអ្នកបើកបរដោយប្រើកម្មវិធីបានបើកបរសរុបនៅ លើកម្មវិធី ឬប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញនៅក្នុងអំឡុងពេលត្រីមាស ប្រតិទិនបច្ចុប្បន្នរហូតដល់ចំណុចនោះ។

(c) Covered California អាចនឹងអនុម័ត ឬធ្វើវិសោធនកម្មលើ បទបញ្ញត្តិ ប្រសិនបើវាជាការសមរម្យក្នុងការអនុញ្ញាតឲ្យ អ្នកបើកបរ ដែលប្រើកម្មវិធីដែលទទួលប្រាក់ឧបត្ថម្ភអនុលោមតាមផ្នែកនេះ ចុះឈ្មោះ នៅក្នុងផែនការសុខភាពតាមរយៈ Covered California ។

(d) (1) ដូចមានចែងក្នុងលក្ខខណ្ឌនៃការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ ការថែទាំសុខភាពដែលចែងក្នុង ផ្នែករង (a) ក្រុមហ៊ុនបណ្តាញអាច តម្រូវឲ្យអ្នកបើកបរដែលប្រើកម្មវិធីអោយដាក់បញ្ជូន ភស្តុតាងនៃការ ចុះឈ្មោះបច្ចុប្បន្ននៅក្នុងផែនការសុខភាព ដែលមានសិទ្ធិទទួល។ ភស្តុតាងនៃការចុះឈ្មោះបច្ចុប្បន្នអាចរួមមាន ប៉ុន្តែមិនកំណត់ចំពោះ សមាជិកភាពការធានារ៉ាប់រងសុខភាព ឬអត្តសញ្ញាណប័ណ្ណ ភស្តុតាងនៃ ការធានារ៉ាប់រង និងទម្រង់បែបបទការបង្ហាញអោយឃើញមកពីគម្រោង សុខភាព ឬទម្រង់បែបបទការទាមទារ និងឯកសារចាំបាច់ផ្សេងទៀត ដែលចាំបាច់សម្រាប់ដាក់បញ្ជូនការទាមទារ។

(2) អ្នកបើកបរដែលប្រើកម្មវិធីត្រូវមានយ៉ាងតិច 15 ថ្ងៃប្រតិទិនពី ដំណាច់ត្រីមាសប្រតិទិនដើម្បីផ្តល់ភស្តុតាងនៃការចុះឈ្មោះ ដូចមានចែង នៅក្នុងកថាខណ្ឌ (1)។

(3) ក្រុមហ៊ុនបណ្តាញត្រូវផ្តល់ប្រាក់ឧបត្ថម្ភការថែទាំសុខភាពដែល ផុតកំណត់នៅក្នុងត្រីមាស ប្រតិទិននៅក្រោមផ្នែករង (a) ក្នុងរយៈពេល 15 ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាសប្រតិទិន ឬក្នុង រយៈពេល 15 ថ្ងៃក្រោយ ការផ្តល់ភស្តុតាងនៃការចុះឈ្មោះរបស់អ្នកបើកបរដែលប្រើកម្មវិធីដូចមាន ចែងនៅក្នុង កថាខណ្ឌ (1) ឬ មួយណាដែលយូរជាង។

(e) សម្រាប់គោលបំណងនៃផ្នែកនេះ ត្រីមាសប្រតិទិនសំដៅលើអំឡុង រយៈពេលបួនខាងក្រោម៖

(1) ថ្ងៃទី 1 ខែមករា រហូតដល់ ថ្ងៃទី 31 ខែមីនា។

(2) ថ្ងៃទី 1 ខែមេសា រហូតដល់ ថ្ងៃទី 30 ខែមិថុនា។

(3) ថ្ងៃទី 1 ខែកក្កដា រហូតដល់ ថ្ងៃទី 30 ខែកញ្ញា។

(4) ថ្ងៃទី 1 ខែ តុលា រហូតដល់ ថ្ងៃទី 31 ខែធ្នូ។

(f) មិនមានអ្វីនៅក្នុងផ្នែកនេះត្រូវបានបកស្រាយដើម្បីបង្ការអ្នកបើកបរ ពីការទទួលបានប្រាក់ឧបត្ថម្ភ ការថែទាំសុខភាពពីក្រុមហ៊ុនបណ្តាញ ច្រើនជាងមួយសម្រាប់ត្រីមាសប្រតិទិនដដែលឡើយ។

(g) នៅថ្ងៃ ឬនៅមុនថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020 នៅថ្ងៃ ឬនៅមុនថ្ងៃ ទី 1 ខែកញ្ញា Covered California ត្រូវបោះពុម្ពផ្សាយប្រាក់បុព្វលាភ ប្រចាំខែទូទាំងរដ្ឋជាមធ្យម សម្រាប់បុគ្គលម្នាក់ៗសម្រាប់ឆ្នាំប្រតិទិន បន្ទាប់ សម្រាប់ផែនការធានារ៉ាប់រងសុខភាពប្រភេទប្រូនស៍របស់ Covered California ។

(h) ផ្នែកនេះនឹងលែងអនុវត្ត នៅក្នុងព្រឹត្តិការណ៍ដែលសហរដ្ឋអាមេរិក ឬរដ្ឋ California អនុវត្ត ប្រព័ន្ធថែទាំសុខភាពជាសាកល ឬប្រព័ន្ធ ស្រដៀងគ្នានេះខ្លាំងដែលពង្រីកការរ៉ាប់រងទៅដល់អ្នកទទួលការឧបត្ថម្ភ នៅក្រោមផ្នែកនេះ។

22

7455. ការការពារការបាត់បង់ និងការទទួលខុសត្រូវ មិនមានក្រុមហ៊ុនបណ្តាញណាត្រូវប្រតិបត្តិការនៅក្នុងរដ្ឋ California លើសពីរយៈពេល 90 ថ្ងៃបាន ទេ លើកលែងតែក្រុមហ៊ុនបណ្តាញមាន ផ្តល់ ឬ បង្កើតការធានារ៉ាប់រងដូចខាងក្រោម៖

(a) សម្រាប់ជាអត្ថប្រយោជន៍របស់អ្នកបើកបរដែលប្រើកម្មវិធី ការធានារ៉ាប់រងគ្រោះថ្នាក់ការងារ ដើម្បីរ៉ាប់រងលើការចំណាយថ្លៃព្យាបាល និងការបាត់បង់ប្រាក់ចំណូលដោយសាររបួស ដែលកើតមានខណៈពេលអ្នកបើកបរដែលប្រើកម្មវិធីកំពុងអនឡាញ នៅលើកម្មវិធី ឬប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញ។ គោលការណ៍ត្រូវយ៉ាងហោចណាស់ផ្តល់ដូចខាងក្រោម៖

(1) ការរ៉ាប់រងសម្រាប់ការចំណាយថ្លៃព្យាបាលដែលកើតមាន រហូតដល់យ៉ាងតិចមួយលានដុល្លារ ($1,000,000) ។

(2) (A) ការទូទាត់លើពិការភាពស្មើនឹង 66 ភាគរយនៃប្រាក់ចំណូលមធ្យមប្រចាំសប្តាហ៍របស់អ្នក បើកបរដែលប្រើកម្មវិធី ពីក្រុមហ៊ុនបណ្តាញទាំងអស់ គិតត្រឹមថ្ងៃមានរបួសក្នុងអត្រាទូទាត់ ប្រចាំសប្តាហ៍អតិបរមា និងអប្បបរមាដែលនឹងត្រូវកំណត់ ស្របតាមផ្នែករង (a) នៃផ្នែក 4453 នៃក្រមច្បាប់ការងារសម្រាប់រយៈពេលរហូតដល់ 104 សប្តាហ៍ដំបូងក្រោយពីរងរបួស។

(B) "ប្រាក់ចំណូលជាមធ្យមប្រចាំសប្តាហ៍" សំដៅលើទឹកប្រាក់រកបានសរុបរបស់អ្នកបើកបរដែលប្រើកម្មវិធីពីក្រុមហ៊ុនបណ្តាញទាំងអស់ ក្នុងអំឡុងពេល 28 ថ្ងៃមុនគ្រោះថ្នាក់ដែលមានការធានារ៉ាប់រង ចែកនឹងបួន។

(b) សម្រាប់ជាអត្ថប្រយោជន៍របស់ប្តីប្រពន្ធ កូន និងអ្នកក្នុងបន្ទុកផ្សេងទៀតរបស់អ្នកបើកបរដែលប្រើកម្មវិធី ការធានារ៉ាប់រងលើការស្លាប់ដោយគ្រោះថ្នាក់សម្រាប់របួសដែលបង្កដោយអ្នកបើកបរដែលប្រើប្រាស់កម្មវិធី ខណៈពេលដែលអ្នកបើកបរនោះកំពុងអនឡាញជាមួយកម្មវិធី ឬប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញ ដែលបណ្តាលឲ្យមានការស្លាប់។ សម្រាប់គោលបំណងនៃផ្នែករងនេះ ការចំណាយលើការបញ្ចុះសព និងអត្ថប្រយោជន៍ពីការស្លាប់នឹងត្រូវកំណត់ស្របតាមផ្នែក 4701 និងផ្នែក 4702 នៃ ក្រមច្បាប់ការងារ។

(c) សម្រាប់គោលបំណងនៃផ្នែកនេះ ពាក្យថា "អនឡាញ" សំដៅលើពេលវេលាដែលអ្នកបើកបរដោយប្រើកម្មវិធីកំពុងប្រើប្រាស់កម្មវិធី ឬ ប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញនិងអាចទទួលសំណើសម្រាប់សេវាដឹកអ្នកដំណើរ ឬដឹកជញ្ជូនពីក្រុមហ៊ុនបណ្តាញ ឬក្នុងពេលផ្តល់សេវាកម្ម។

(d) ការធានារ៉ាប់រងលើគ្រោះថ្នាក់ការងារ ឬការធានារ៉ាប់រងលើ ការស្លាប់ដោយសារគ្រោះថ្នាក់ នៅក្រោមផ្នែករង (a) និង (b) មិនត្រូវបានទាមទារឲ្យរ៉ាប់រងលើគ្រោះថ្នាក់ដែលកើតឡើង ខណៈពេលអនឡាញប៉ុន្តែក្រៅម៉ោងផ្តល់សេវាកម្មដែលអ្នកបើកបរមានរបួសកំពុងស្ថិតនៅក្នុងម៉ោងផ្តល់សេវាកម្មនៅលើប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញមួយ ឬ ច្រើន ឬដែលអ្នកបើកបរដែលប្រើកម្មវិធីចូលរួមក្នុងសកម្មភាពផ្ទាល់ខ្លួន។ ប្រសិនបើគ្រោះថ្នាក់ត្រូវបានរ៉ាប់រងដោយការធានារ៉ាប់រងលើគ្រោះថ្នាក់ការងារ ឬការធានារ៉ាប់រងការស្លាប់ដោយគ្រោះថ្នាក់ត្រូវបានផ្តល់ដោយក្រុមហ៊ុនបណ្តាញលើសពីមួយនោះ អ្នកធានារ៉ាប់រងនៃក្រុមហ៊ុនបណ្តាញដែលទទួលការដាក់បណ្តឹងទាមទារត្រូវចូលរួមវិភាគទានមួយចំណែកនៃការរ៉ាប់រងរបស់ក្រុមហ៊ុនមួយ ឬច្រើនទាំងនោះរហូតដល់គ្រប់ការធានារ៉ាប់រង និងដែនកំណត់នៅក្នុងផ្នែករង (a) និង (b)។

(e) អត្ថប្រយោជន៍ដែលបានផ្តល់ដល់អ្នកបើកបរដែលប្រើកម្មវិធីនៅក្រោមផ្នែករង (a) ឬ (b) នៃផ្នែកនេះត្រូវចាត់ទុកថាជាទឹកប្រាក់ដែលត្រូវបង់នៅក្រោមច្បាប់សំណងរបស់កម្មករ ឬអត្ថប្រយោជន៍ពិការភាពសម្រាប់គោលបំណងនៃការកំណត់ទឹកប្រាក់ត្រូវបង់នៅក្រោមការធានារ៉ាប់រង ដែលបានផ្តល់នៅក្រោមមាត្រា 2 (ចាប់ផ្តើមជាមួយនឹងផ្នែក 11580) នៃជំពូក 1 នៃភាគ 3 នៃផ្នែក 2 នៃ ក្រមធានារ៉ាប់រង។

(f) (1) សម្រាប់អត្ថប្រយោជន៍សាធារណៈ DNC ដូចមានកំណត់និយមន័យនៅក្នុងផ្នែក 7463 ត្រូវទទួលបានការធានារ៉ាប់រងការទទួលខុសត្រូវរថយន្តយ៉ាងហោចណាស់មួយលានដុល្លារ ($1,000,000) ក្នុងមួយករណី ដើម្បីទូទាត់ដល់ភាគីទីបីសម្រាប់ របួស ឬការបាត់បង់ដែលបង្កឡើងដោយប្រតិបត្តិការនៃរថយន្តដោយអ្នកបើកបរដែលប្រើកម្មវិធីក្នុងម៉ោងផ្តល់សេវាកម្ម ក្នុងការកើតមានដែលរថយន្តមិនត្រូវបានរ៉ាប់រងដោយគោលការណ៍ដែលអនុលោមតាមផ្នែករង (b) នៃ ផ្នែក 11580.1 នៃក្រមធានារ៉ាប់រង។

(2) សម្រាប់ជាប្រយោជន៍សាធារណៈ TNC ដូចដែលបានកំណត់និយមន័យនៅក្នុងផ្នែក 7463 ត្រូវរក្សាគោលការណ៍ធានារ៉ាប់រងទទួលខុសត្រូវដូចបានតម្រូវដោយមាត្រា 7 (ចាប់ផ្តើមជាមួយនឹងផ្នែក 5430) នៃជំពូក 8 នៃផ្នែក 2 នៃក្រមសេវាកម្មសាធារណៈ។

(3) សម្រាប់ជាប្រយោជន៍សាធារណៈ TCP ដូចដែលបានកំណត់និយមន័យនៅក្នុងផ្នែក 7463 ត្រូវរក្សាគោលការណ៍ធានារ៉ាប់រងទទួលខុសត្រូវដូចបានតម្រូវដោយមាត្រា 4 (ចាប់ផ្តើមជាមួយនឹងផ្នែក 5391) នៃជំពូក 8 នៃផ្នែក 2 នៃក្រមសេវាកម្មសាធារណៈ។

មាត្រា 5. ការប្រឆាំងនឹងការរើសអើងនិងសុវត្ថិភាពសាធារណៈ

7456. ការប្រឆាំងនឹងការរើសអើង។ (a) វាជាការអនុវត្តដែលខុសច្បាប់ លើកលែងតែផ្អែកលើលក្ខណៈសម្បត្តិវិជ្ជាជីវៈត្រឹមត្រូវ ឬតម្រូវការសុវត្ថិភាពសាធារណៈ ឬអ្នកបើកបរដែលប្រើ កម្មវិធីសម្រាប់ក្រុមហ៊ុនបណ្តាញក្នុងការបដិសេធការចុះកិច្ចសន្យាជាមួយ បញ្ចប់កិច្ចសន្យា ឬបិទដំណើរការពីកម្មវិធី ឬប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញ អ្នកបើកបរដែលប្រើកម្មវិធី ឬអ្នកដែលត្រៀមនឹងក្លាយជាអ្នកបើកបរប្រើកម្មវិធី ដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ បុព្វការី ប្រភពកំណើត សាសនា ពូជអម្បូរ អាយុ ពិការភាពផ្លូវកាយឬផ្លូវចិត្ត ភេទ យេនឌ័រ និន្នាការផ្លូវភេទ អត្តសញ្ញាណយេនឌ័រឬការបង្ហាញអំពីយេនឌ័រ ស្ថានភាពវេជ្ជសាស្ត្រ ព័ត៌មានហ្សែន ស្ថានភាពអាពាហ៍ពិពាហ៍ ឬស្ថានភាពយោធា ឬអតីតយុទ្ធជន។

(b) ការទាមទារនានាដែលធ្វើឡើងស្របតាមផ្នែកនេះ ត្រូវធ្វើឡើងដោយអនុលោមតាមតែនីតិវិធីដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសិទ្ធិពលរដ្ឋ Unruh (Unruh Civil Rights Act) (ផ្នែក 51 នៃក្រមរដ្ឋប្បវេណី) ហើយនឹងត្រូវបានគ្រប់គ្រងដោយលក្ខខណ្ឌតម្រូវ និងដំណោះស្រាយរបស់ច្បាប់នេះ។

7457. ការបង្ការការបៀតបៀនផ្លូវភេទ (a) ក្រុមហ៊ុនបណ្តាញ ត្រូវបង្កើតគោលការណ៍ស្តីពីការបៀតបៀនផ្លូវភេទដើម្បីការពារអ្នកបើកបរដែលប្រើកម្មវិធី និងសាធារណជនដែលប្រើប្រាស់សេវាដឹកអ្នកដំណើរ ឬដឹកជញ្ជូន។ គោលការណ៍នេះត្រូវតែអាចរកបាននៅលើគេហទំព័រអ៊ីនធើណែតរបស់ក្រុមហ៊ុនបណ្តាញ។ គោលនយោបាយយ៉ាងហោចណាស់ត្រូវធ្វើទាំងអស់ដូចខាងក្រោម៖

(1) កំណត់ពីឥរិយាបថដែលអាចបង្កើតជាការបៀតបៀនផ្លូវភេទដែលរួមមានឥរិយាបថដូចខាង ក្រោម៖ កាយវិការទាក់ទាញផ្លូវភេទ ការមើលចុងភ្នែកដោយពេញចិត្ត កាយវិការ ឬការបង្ហាញឧបករណ៍ដែលបង្ហើបចំណង់ផ្លូវភេទ រូបភាព គំនូរជីវចល ឬផ្ទាំងរូបភាព មតិ គុណស័ព្ទ ការបង្ខូច ឬនិយាយកំប្លែងដែលអសុរោះ មតិបែបក្រាហ្វិច ពាក្យសំដីបន្ទោកផ្លូវភេទ ឬសារបង្ហើប ឬសារអាសអាភាស ឬការអូសទាញ និង

22

ការប៉ះពាល់ឬការរំលោភបំពានលើរូបរាងកាយ ព្រមទាំងចលនារារាំងឬទប់ស្កាត់។

(2) បង្ហាញថាក្រុមហ៊ុនបណ្តាញ និងនៅក្នុងឧទាហរណ៍ជាច្រើន ច្បាប់ហាមឃាត់អ្នកបើកបរដែលប្រើកម្មវិធី និងអតិថិជនដែលប្រើប្រាស់សេវាដឹកអ្នកដំណើរ ឬដឹកជញ្ជូនមិនឱ្យប្រព្រឹត្តការបៀតបៀនដែលត្រូវបានហាមឃាត់។

(3) បង្កើតដំណើរការមួយសម្រាប់អ្នកបើកបរដែលប្រើកម្មវិធី អតិថិជន និងអ្នកដំណើរតាមសេវាដឹក ដើម្បីដាក់បញ្ជូនពាក្យបណ្តឹងដែលធានានូវការសម្ងាត់តាមដែលអាចធ្វើបាន ការស៊ើបអង្កេត ដែលគ្មានភាពលម្អៀង និងទាន់ពេលវេលា និងសកម្មភាពដោះស្រាយនិងសេចក្តីសម្រេចដោយផ្អែកលើព័ត៌មានដែលប្រមូលបានក្នុងអំឡុងពេលដំណើរការស៊ើបអង្កេត។

(4) ផ្តល់ឱកាសដល់អ្នកបើកបរដែលប្រើកម្មវិធី និងអតិថិជនដែលប្រើប្រាស់សេវាដឹកអ្នកដំណើរ ឬដឹកជញ្ជូនឱ្យដាក់ពាក្យបណ្តឹងតាមអេឡិចត្រូនិច ដើម្បីឱ្យបណ្តឹងអាចត្រូវបានដោះ ស្រាយបានឆាប់រហ័ស។

(5) បង្ហាញថានៅពេលដែលក្រុមហ៊ុនបណ្តាញទទួលបានការចោទប្រកាន់អំពីការប្រព្រឹត្តខុស ក្រុមហ៊ុននឹងធ្វើការស៊ើបអង្កេតដែលត្រឹមត្រូវ ទាន់ពេលវេលា និងម៉ត់ចត់ដើម្បីឈានដល់សេចក្តីសម្រេចសមហេតុផល ដោយផ្អែកលើព័ត៌មានដែលប្រមូលបាន។

(6) ធ្វើឱ្យមានភាពច្បាស់លាស់ថា ទាំងអ្នកបើកបរប្រើកម្មវិធី និងអតិថិជនដែលប្រើប្រាស់សេវាដឹក ឬដឹកជញ្ជូនមិនត្រូវបានសងសឹកវិញដោយសារតែលទ្ធផលនៃពាក្យបណ្តឹងស្មោះត្រង់មួយ ឬដោយសារការចូលរួមក្នុងការស៊ើបអង្កេតប្រឆាំងនឹងអ្នកបើកបរ ដែលប្រើកម្មវិធីអតិថិជន ឬអ្នកដំណើររបស់សេវាកម្មដឹកឡើយ។

(b) មុនពេលផ្តល់សេវាកម្មដឹកអ្នកដំណើរ ឬដឹកជញ្ជូនតាមរយៈកម្មវិធី ឬប្រព័ន្ធរបស់ក្រុមហ៊ុន បណ្តាញ អ្នកបើកបរដែលប្រើកម្មវិធី ត្រូវធ្វើទាំងពីរដូចខាងក្រោម៖

(1) ពិនិត្យមើលគោលការណ៍ស្តីពីការបៀតបៀនផ្លូវភេទរបស់ក្រុមហ៊ុនបណ្តាញ។

(2) ដែលការអះអាងតាមអេឡិចត្រូនិចត្រូវតែគ្រប់គ្រាន់នោះ ត្រូវអះអាងទៅកាន់ក្រុមហ៊ុនបណ្តាញថា អ្នកបើកបរដែលប្រើកម្មវិធីបានពិនិត្យមើលគោលការណ៍ស្តីពីការបៀតបៀនផ្លូវភេទរបស់ក្រុមហ៊ុនបណ្តាញរួចហើយ។

(c) ការទាមទារនានាដែលអនុលោមតាមផ្នែកនេះ ត្រូវធ្វើឡើងតែក្រោមនីតិវិធីដែលត្រូវបានបង្កើតឡើងដោយច្បាប់ ស្តីពីសិទ្ធិពលរដ្ឋ Unruh (ផ្នែក 51 នៃក្រមរដ្ឋប្បវេណី) ហើយនឹង ត្រូវបានគ្រប់គ្រងដោយលក្ខខណ្ឌតម្រូវ និងដំណោះស្រាយ របស់ច្បាប់នេះ។

7458. ការពិនិត្យប្រវត្តិបទល្មើស (a) ក្រុមហ៊ុនបណ្តាញត្រូវអនុវត្ត ឬឱ្យភាគីទីបីអនុវត្តការពិនិត្យ ប្រវត្តិបទឧក្រិដ្ឋថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិបឋម ចំពោះអ្នកបើកបរដែលប្រើកម្មវិធី ឬប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញ ដើម្បីផ្តល់សេវាដឹកអ្នកដំណើរ ឬដឹកជញ្ជូន។ ការពិនិត្យប្រវត្តិត្រូវមានភាពស៊ីគ្នាទៅនឹងស្តង់ដារដែលមានក្នុងផ្នែករង (a) នៃផ្នែក 5445.2 នៃក្រម សេវាកម្មសាធារណៈ។ ទោះជាមានបទញ្ញត្តិផ្សេងទៀតណាមួយនៃច្បាប់ ដែលផ្ទុយពីនេះក្តី បន្ទាប់ពីក្រុមហ៊ុនបណ្តាញទទួល បានការយល់ព្រមពីអ្នកបើកបរដែលប្រើកម្មវិធី ឱ្យពិនិត្យប្រវត្តិបទឧក្រិដ្ឋហើយនោះ មិនមានការយល់ព្រមបន្ថែមទៀតដែលត្រូវបានតម្រូវសម្រាប់ការពិនិត្យជាបន្តលើប្រវត្តិបទឧក្រិដ្ឋរបស់អ្នកបើកបរដែលប្រើកម្មវិធីឡើយ ប្រសិនបើក្រុមហ៊ុនបណ្តាញជ្រើសរើសយកការអនុវត្តការពិនិត្យជាបន្តបែបនោះ។

(b) ក្រុមហ៊ុនបណ្តាញមួយត្រូវបំពេញការពិនិត្យប្រវត្តិបទឧក្រិដ្ឋបឋមដូចដែលត្រូវបានតម្រូវដោយផ្នែករង (a) មុនពេលអនុញ្ញាត ឱ្យអ្នកបើកបរប្រើប្រាស់កម្មវិធី ឬប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញ។ ក្រុមហ៊ុនបណ្តាញត្រូវផ្តល់សេចក្តីចម្លង ឬសេចក្តីសង្ខេបអំពីការពិនិត្យប្រវត្តិបទឧក្រិដ្ឋបឋមជាលក្ខណៈអេឡិចត្រូនិច ឬជារូបវន្តទៅឱ្យអ្នកបើកបរដែលប្រើកម្មវិធី។

(c) អ្នកបើកបរដែលប្រើកម្មវិធី មិនត្រូវទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់កម្មវិធី ឬប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញឡើយ ប្រសិនបើមានការប្រព្រឹត្តបទល្មើសណាមួយខាងក្រោម៖

(1) អ្នកបើកបរធ្លាប់ត្រូវបានផ្តន្ទាទោស ពីបទឧក្រិដ្ឋណាមួយ ដែលមានចែងក្នុងអនុកថាខណ្ឌ (B) នៃ កថាខណ្ឌ (2) នៃផ្នែករង (a) នៃផ្នែក 5445.2 នៃក្រមសេវាកម្មសាធារណៈ បទឧក្រិដ្ឋធ្ងន់ធ្ងរណាមួយដូចដែលបានកំណត់ន័យដោយផ្នែករង (c) នៃផ្នែក 1192.7 នៃក្រមព្រហ្មទណ្ឌ ឬ បទឧក្រិដ្ឋស្តីពីការស្អប់ខ្ពើមណាមួយដូចដែលមានចែងដោយផ្នែក 422.55 នៃក្រមព្រហ្មទណ្ឌ។

(2) អ្នកបើកបរត្រូវបានផ្តន្ទាទោសក្នុងរយៈពេលប្រាំពីរឆ្នាំចុងក្រោយពីបទឧក្រិដ្ឋណាមួយ ដែលមាន ចុះក្នុងកថាខណ្ឌ (3) នៃផ្នែករង (a) នៃផ្នែក 5445.2 នៃក្រមសេវាកម្មសាធារណៈ។

(d) (1) សមត្ថភាពរបស់អ្នកបើកបរដែលប្រើកម្មវិធីឬប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញ អាចត្រូវបានពិនិត្យ ប្រសិនបើក្រុមហ៊ុនបណ្តាញដឹងថាអ្នកបើកបររូបនោះត្រូវបានចាប់ខ្លួនពីបទឧក្រិដ្ឋណាមួយដែលមានចែងដូចខាងក្រោម៖

(A) អនុកថាខណ្ឌ (B) នៃកថាខណ្ឌ (2) ឬកថាខណ្ឌ (3) នៃផ្នែករង (a) នៃផ្នែក 5445.2 នៃក្រមសេវាកម្មសាធារណៈ។

(B) ផ្នែករង (C) នៃផ្នែកនេះ។

(2) ការពិនិត្យដែលត្រូវបានពិពណ៌នាក្នុងកថាខណ្ឌ (1) អាចត្រូវបានដកចេញក្រោយពីសេចក្តីសម្រេចចុងក្រោយនៃការចាប់ខ្លួនពីបទឧក្រិដ្ឋណាមួយដែលមានចុះក្នុងអនុកថាខណ្ឌ (B) នៃកថាខណ្ឌ (2) ឬកថាខណ្ឌ (3) នៃផ្នែករង (a) នៃផ្នែក 5445.2 នៃក្រមសេវាកម្មសាធារណៈ ដែលមិនបង្ករឱ្យមានការផ្តន្ទាទោស។ សេចក្តីសម្រេចចុងក្រោយបែបនេះរួមមានការរកឃើញភាពគ្មានកំហុសយ៉ាងពិតប្រាកដពីការចោទ ប្រកាន់ដែលពាក់ព័ន្ធណាមួយ ការសម្រេចឱ្យរួចទោសនៅឯការជំនុំជម្រះ លិខិតភស្តុតាងដែល បង្ហាញថាមេធាវីវិនិច្ឆ័យដោយមានអំណាចលើបទល្មើសដែលត្រូវបានចោទប្រកាន់បានបដិសេធក្នុងការដាក់ពាក្យបណ្តឹងបទឧក្រិដ្ឋ ឬលិខិតភស្តុតាងដែលបង្ហាញថាកំឡុងរយៈពេលដែលពាក់ព័ន្ធទាំងអស់ដែលត្រូវបានពិពណ៌នាក្នុងជំពូក 2 (ដោយចាប់ផ្តើមជាមួយផ្នែក 799) ចំណងជើង 3 នៃភាគ 2 នៃក្រមព្រហ្មទណ្ឌបានផុតកំណត់។

(e) គ្មានអ្វីនៅក្នុងភាគនេះត្រូវបានបកស្រាយដើម្បីបង្ការក្រុមហ៊ុនបណ្តាញ ពីការដាក់ស្តង់ដារ បន្ថែមដែលទាក់ទងនឹងប្រវត្តិឧក្រិដ្ឋកម្ម ឡើយ។

(f) ថ្វីបើមានចែងក្នុងផ្នែក 1786.12 នៃក្រមរដ្ឋប្បវេណីក៏ដោយ ទីភ្នាក់ងាររាយការណ៍ស៊ើបអង្កេតអ្នកប្រើប្រាស់អាចផ្តល់របាយការណ៍ ស៊ើបអង្កេតអ្នកប្រើប្រាស់ទៅកាន់ក្រុមហ៊ុនបណ្តាញអំពីអ្នក ដែលចង់ក្លាយជាអ្នកបើកបរដែលប្រើកម្មវិធី ដោយមិនគិតថាតើ អ្នកបើកបរដែលប្រើកម្មវិធីនោះ គឺនឹងត្រូវជាបុគ្គលិក ឬជាអ្នកម៉ៅការឯករាជ្យនៃក្រុមហ៊ុនបណ្តាញនោះទេ ។

22

7459. ការបណ្តុះបណ្តាលអំពីសុវត្ថិភាព (a) ក្រុមហ៊ុនបណ្តាញតម្រូវឲ្យអ្នកបើកបរដែលប្រើកម្មវិធីបំពេញបញ្ចប់ការបណ្តុះបណ្តាលដែលមានរៀបរាប់នៅក្នុងផ្នែកនេះ មុនពេលអនុញ្ញាតឲ្យអ្នកបើកបរដែលប្រើកម្មវិធីនោះអាចប្រើប្រាស់ប្រព័ន្ធ ឬកម្មវិធីអនឡាញរបស់ក្រុមហ៊ុនបណ្តាញ ។

(b) ក្រុមហ៊ុនបណ្តាញនឹងផ្តល់ឲ្យអ្នកបើកបរដែលប្រើកម្មវិធីម្នាក់ៗនូវការបណ្តុះបណ្តាលអំពីសុវត្ថិភាព ។ ការបណ្តុះបណ្តាលអំពីសុវត្ថិភាពដែលតម្រូវដោយផ្នែកនេះ រួមមានប្រធានបទដូចខាងក្រោម៖

(1) ការបញ្ជៀសការប៉ះទង្គិច និងបច្ចេកទេសបើកបរការពារ។

(2) អត្តសញ្ញាណកម្មនៃកត្តាដែលបណ្តាលឲ្យមានការប៉ះទង្គិច ដូចជាការបើកបរហួសល្បឿនកំណត់ ការបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹងឬគ្រឿងញៀន (DUI) និងការបើកបរដោយមិនយកចិត្តទុកដាក់។

(3) ការទទួលស្គាល់និងការរាយការណ៍អំពីការបៀតបៀនផ្លូវភេទ និងការប្រព្រឹត្តមិនត្រឹមត្រូវ ។

(4) សម្រាប់អ្នកបើកបរដែលប្រើកម្មវិធីក្នុងការដឹកជញ្ជូនម្ហូបអាហារ ឬគ្រឿងទេសដែលបានរៀបចំរួច ព័ត៌មានសុវត្ថិភាពចំណីអាហារ ទាក់ទងនឹងការដឹកជញ្ជូនម្ហូបអាហារ ដែលរួមមានការគ្រប់គ្រងសីតុណ្ហភាពជាដើម ។

(c) ការបណ្តុះបណ្តាលអាចត្រូវបានផ្តល់អាស្រ័យលើឆន្ទានុសិទ្ធិរបស់ក្រុមហ៊ុនបណ្តាញ ជាការបណ្តុះបណ្តាលតាមអនឡាញ ជាវីដេអូ ឬជួបផ្ទាល់ ។

(d) ថ្វីបើមានចែងក្នុងផ្នែករង (a) ក៏ដោយ រាល់អ្នកបើកបរដែលប្រើកម្មវិធីដែលបានចុះ កិច្ចសន្យាជាមួយក្រុមហ៊ុនបណ្តាញមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2021 ដើម្បីផ្តល់សេវាកម្មដឹកអ្នកដំណើរ ឬសេវាដឹកជញ្ជូនត្រូវមានរហូតដល់ថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 2021 ដើម្បីបញ្ចប់ការបណ្តុះបណ្តាលសុវត្ថិភាពដែលតម្រូវដោយផ្នែកនេះ ហើយអាចបន្តផ្តល់សេវាកម្មដឹកអ្នកដំណើរ ឬសេវាកម្មដឹកជញ្ជូនតាមរយៈកម្មវិធី ឬប្រព័ន្ធរហូតដល់កាលបរិច្ឆេទនោះ។ នៅថ្ងៃ និងក្រោយពីថ្ងៃ ទី 1 ខែកក្កដា ឆ្នាំ 2021 តទៅ អ្នកបើកបរដែលប្រើកម្មវិធីដែលបាន រៀបរាប់នៅក្នុងផ្នែករងនេះ ត្រូវតែបញ្ចប់ ការបណ្តុះបណ្តាលដែលតម្រូវដោយផ្នែកនេះដើម្បីបន្តផ្តល់សេវាកម្មដឹកអ្នកដំណើរ និងសេវាកម្មដឹកជញ្ជូនបន្តទៀតបាន ។

(e) រាល់ផលិតផលសុវត្ថិភាព លក្ខណៈពិសេស នីតិវិធី គោលការណ៍ស្តង់ដារ ឬកិច្ចខិតខំប្រឹងប្រែង ផ្សេងទៀតដែលត្រូវបានអនុវត្តដោយក្រុមហ៊ុនបណ្តាញ ឬការផ្តល់នូវឧបករណ៍ដោយក្រុមហ៊ុន បណ្តាញ ដើម្បីបន្ថែមសុវត្ថិភាពសាធារណៈគឺមិនមែនជាការបង្ហាញពីការងារ ឬទំនាក់ទំនង នៃទីភ្នាក់ងារជាមួយនឹងអ្នកបើកបរដែលប្រើកម្មវិធីទេ។

7460. គោលការណ៍គ្មានការយោគយល់ (a) ក្រុមហ៊ុនបណ្តាញនឹងបង្កើត "គោលការណ៍គ្មានការយោគយល់" ដែលតម្រូវឲ្យមានការផ្អាកជាបន្ទាន់នូវសិទ្ធិរបស់អ្នកបើកបរដែលប្រើកម្មវិធីក្នុងការចូលទៅកាន់កម្មវិធី ឬប្រព័ន្ធអនឡាញរបស់ក្រុមហ៊ុនបណ្តាញ នៅរាល់ពេល ដែលក្រុមហ៊ុនបណ្តាញទទួលរបាយការណ៍តាមរយៈកម្មវិធី ឬប្រព័ន្ធអនឡាញរបស់ខ្លួន ឬដោយវិធីផ្សេងទៀតដែលបានអនុញ្ញាតដោយក្រុមហ៊ុន ឬពីបុគ្គលណាម្នាក់ដែលសង្ស័យថា អ្នកបើកបរដែលប្រើកម្មវិធីគឺស្ថិតនៅក្រោមឥទ្ធិពលនៃថ្នាំញៀន ឬគ្រឿងស្រវឹង ខណៈពេលផ្តល់សេវាកម្មដឹកអ្នកដំណើរ ឬដឹកជញ្ជូន ។

(b) នៅពេលទទួលបានរបាយការណ៍ដូចបានរៀបរាប់នៅក្នុងផ្នែករង (a) ក្រុមហ៊ុនបណ្តាញនឹងផ្អាកអ្នកបើកបរដែលប្រើកម្មវិធីនោះជាបន្ទាន់ពីកម្មវិធី ឬប្រព័ន្ធរបស់ក្រុមហ៊ុនបណ្តាញសម្រាប់ការស៊ើបអង្កេតបន្តទៀត ។

(c) ក្រុមហ៊ុនបណ្តាញអាចនឹងផ្អាកការចូលប្រើកម្មវិធី ឬប្រព័ន្ធអនឡាញរបស់ក្រុមហ៊ុនបណ្តាញ សម្រាប់អ្នកបើកបរដែលប្រើកម្មវិធី ឬអតិថិជនណាដែលត្រូវបានរកឃើញថាបានរំលោភបំពានលើគោលការណ៍មិនលើកលែងដូចបានចែងក្នុងផ្នែករង (a) ដែលអ្នកបើកបរ ឬអតិថិជនដឹងថារបាយការណ៍នេះមិនសមហេតុផល ឬផ្អែកលើរបាយការណ៍ដែលមានចេតនាបដិសេធដោយមិនសមរម្យនូវការចូលប្រើរបស់អ្នកបើកបរក្នុងកម្មវិធី ឬប្រព័ន្ធអនឡាញនោះ។

7460.5. ក្រុមហ៊ុនបណ្តាញត្រូវដាក់ឲ្យមានជាបន្ត និងជាពិសេសដល់ការអនុវត្តច្បាប់នូវយន្តការ ក្នុងការដាក់ជូនសំណើសុំពត៌មានដើម្បីជួយដល់ការស៊ើបអង្កេតដែលទាក់ទងទៅនឹងស្ថានភាព អាសន្ន កាលៈទេសៈបន្ទាន់ និងឧប្បត្តិហេតុសំខាន់ៗ ។

7461. ការសម្រាករបស់អ្នកបើកបរដែលប្រើកម្មវិធី អ្នកបើកបរដែលប្រើកម្មវិធី មិនត្រូវបានដាក់ឲ្យចូលក្នុងកម្មវិធី និងបើកបរ ដោយប្រើកម្មវិធីឬប្រព័ន្ធអនឡាញរបស់ក្រុមហ៊ុនបណ្តាញលើសពី រយៈពេលសរុប 12 ម៉ោងក្នុងរាល់ពេល 24 ម៉ោងឡើយ លើកលែងតែអ្នកបើកបរបានចាកចេញពីកម្មវិធីក្នុងរយៈពេល 6 ម៉ោងដោយគ្មានការរំខាន ។ ប្រសិនបើអ្នកបើកបរដែលប្រើកម្មវិធីត្រូវបានដាក់ឲ្យចូលកម្មវិធី និងបើកបរ លើសពីរយៈពេលសរុប 12 ម៉ោងក្នុងរាល់ពេល 24 ម៉ោងដោយគ្មានការចាកចេញពីកម្មវិធីសម្រាប់រយៈពេល 6 ម៉ោងដោយគ្មានការរំខាននោះ អ្នកបើកបរនឹងត្រូវបានហាមឃាត់មិនឲ្យចូលបើកកម្មវិធី ឬប្រព័ន្ធអនឡាញរបស់ក្រុមហ៊ុនបណ្តាញ ក្នុងរយៈពេលយ៉ាងតិច 6 ម៉ោងដោយគ្មានការរំខាន ។

7462. ការក្លែងបន្លំជាអ្នកបើកបរដែលប្រើកម្មវិធី (a) ជនណាដែលក្លែងបន្លំបោកប្រាស់ធ្វើជាអ្នកបើកបរដែលប្រើកម្មវិធីខណៈពេលកំពុងផ្តល់ ឬប៉ុនប៉ងផ្តល់សេវាកម្មដឹកអ្នកដំណើរ ឬដឹកជញ្ជូន ត្រូវមានទោសបទមជ្ឈឹម ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ក្នុងខោនធីរយៈពេលរហូតដល់ប្រាំមួយខែ ឬពិន័យជាប្រាក់រហូតដល់មួយម៉ឺនដុល្លារ ($10,000) ឬទាំងពីរតែម្តង។ គ្មានអ្វីនៅក្នុងផ្នែករងនេះរារាំងដល់ការកាត់ទោស នៅក្រោមច្បាប់ផ្សេងទៀតទេ ។

(b) បន្ថែមលើការពិន័យផ្សេងទៀតដែលបានផ្តល់ឲ្យដោយច្បាប់ បុគ្គលណាម្នាក់ដែលក្លែងបន្លំធ្វើជាអ្នកបើកបរដោយប្រើកម្មវិធី ខណៈពេលដែលកំពុងផ្តល់ ឬប៉ុនប៉ងផ្តល់សេវាកម្មដឹកអ្នកដំណើរ ឬដឹកជញ្ជូនដោយការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសដូចបានរៀបរាប់ក្នុងផ្នែក 207, 209, 220, 261, 264.1, 286, 287, 288, ឬ 289 នៃក្រមព្រហ្មទណ្ឌត្រូវផ្តន្ទាទោសរយៈពេល ប្រាំឆ្នាំបន្ថែម។

(c) បន្ថែមលើការពិន័យផ្សេងទៀតដែលបានផ្តល់ឲ្យដោយច្បាប់ បុគ្គលណាម្នាក់ដែលក្លែងបន្លំធ្វើជាអ្នកបើកបរដោយប្រើកម្មវិធី ខណៈពេលដែលកំពុងផ្តល់ ឬប៉ុនប៉ងផ្តល់សេវាកម្មដឹកអ្នកដំណើរ ឬដឹកជញ្ជូនដោយការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬប៉ុនប៉ងបទឧក្រិដ្ឋ ហើយនៅក្នុងការប្រព្រឹត្តដូចនោះបង្ករអោយមានរបួសលើរាងកាយធ្ងន់ធ្ងរដល់បុគ្គលម្នាក់ទៀត ក្រៅពីអ្នកឃុបឃិត ត្រូវផ្តន្ទាទោសរយៈពេលប្រាំឆ្នាំបន្ថែម។

(d) បន្ថែមលើការពិន័យផ្សេងទៀតដែលបានផ្តល់ឲ្យដោយច្បាប់ បុគ្គលណាម្នាក់ដែលក្លែងបន្លំធ្វើជាអ្នកបើកបរដោយប្រើកម្មវិធី ខណៈពេលដែលកំពុងផ្តល់ ឬប៉ុនប៉ងផ្តល់សេវាកម្មដឹកអ្នកដំណើរ ឬដឹកជញ្ជូនដោយការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬប៉ុនប៉ងបទឧក្រិដ្ឋ ហើយនៅក្នុងការប្រព្រឹត្តដូចនោះបង្ករអោយមានការស្លាប់នៃបុគ្គលម្នាក់ទៀតក្រៅពីអ្នកឃុបឃិត ត្រូវផ្តន្ទាទោសរយៈពេល 10 ឆ្នាំបន្ថែម។

មាត្រា 6. និយមន័យ

7463. សម្រាប់គោលបំណងនៃជំពូកនេះ និយមន័យខាងក្រោមនឹងត្រូវប្រើប្រាស់៖

(a) "អ្នកបើកបរដែលប្រើកម្មវិធី" សំដៅលើបុគ្គលដែលជាអ្នកដឹកជញ្ជូន DNC អ្នកបើកបរ TNC ឬអ្នកបើកបរ ឬអ្នកកាន់លិខិតអនុញ្ញាត TCP និងបុគ្គលដូចក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងផ្នែករង (a) ដល់ (d) រួមបញ្ចូលទាំងផ្នែក 7451។

(b) "ការរួមចំណែក ACA មធ្យម" សំដៅលើ 82 ភាគរយនៃទឹកប្រាក់ដុល្លារនៃប្រាក់បុព្វលាភរដ្ឋ California ដែលត្រូវបានរ៉ាប់រងប្រចាំខែជាមធ្យម។

(c) "ប្រាក់បុព្វលាភរដ្ឋ California ដែលត្រូវបានរ៉ាប់រងប្រចាំខែជាមធ្យម" ស្មើនឹងទឹកប្រាក់ដុល្លារដែលបានបោះផ្សាយតាមផ្នែករង (g) នៃផ្នែក 7454។

(d) "Covered California" សំដៅលើការផ្លាស់ប្តូរអត្ថប្រយោជន៍សុខភាពរដ្ឋ California ដូចបានបកស្រាយនៅក្នុងចំណងជើង 22 (ចាប់ផ្តើមជាមួយនឹងផ្នែក 100500) នៃក្រម រដ្ឋាភិបាល។

(e) "អតិថិជន" សំដៅលើរូបវន្តបុគ្គល ឬ នីតិបុគ្គលមួយ ឬច្រើន។

(f) "ក្រុមហ៊ុនបណ្តាញដឹកជញ្ជូន" (DNC) សំដៅលើនីតិបុគ្គលដែលមានកម្មវិធី ឬប្រព័ន្ធដែលប្រើប្រាស់សម្រាប់សម្របសម្រួលសេវាកម្មដឹកជញ្ជូននៅក្នុងរដ្ឋ California តាមតម្រូវការជាក់ស្តែង និង រក្សាកំណត់ត្រានៃចំនួនម៉ោង ចូលរួមក្នុងសេវាកម្មគិតជាម៉ែលប្រមូលផ្តុំដោយអ្នកដឹកជញ្ជូន DNC ។ ការដឹកជញ្ជូនត្រូវបានសម្របសម្រួលតាមតម្រូវការជាក់ស្តែង ប្រសិនបើអ្នកដឹកជញ្ជូន DNC ត្រូវបានផ្តល់នូវជម្រើសដើម្បីទទួល ឬមិនទទួល សំណើសុំដឹកជញ្ជូនហើយ DNC មិនតម្រូវឲ្យអ្នកដឹកជញ្ជូន DNC ទទួលយកសំណើដឹកជញ្ជូនជាក់លាក់ជាលក្ខខណ្ឌនៃការរក្សាសិទ្ធិ ប្រើប្រាស់កម្មវិធី ឬប្រព័ន្ធរបស់ DNC ឡើយ។

(g) "អ្នកដឹកជញ្ជូនក្នុងក្រុមហ៊ុនបណ្តាញដឹកជញ្ជូន" (អ្នកដឹកជញ្ជូន DNC) សំដៅលើបុគ្គលដែលផ្តល់ សេវាកម្មដឹកជញ្ជូនតាមរយៈកម្មវិធី ឬប្រព័ន្ធរបស់ DNC។

(h) "សេវាកម្មដឹកជញ្ជូន" សំដៅលើការបំពេញសំណើសុំដឹកជញ្ជូនមានន័យថា ការមកទទួលពីទីតាំងណាមួយនូវវត្ថុ ឬវត្ថុនានា និងការដឹកជញ្ជូនវត្ថុទាំងនោះដោយប្រើរថយន្តអ្នកដំណើរ កង់ ស្ពីន ការដើរ ការដឹកជញ្ជូនសាធារណៈ ឬមធ្យោបាយស្រដៀងគ្នានេះ ទៅកាន់ទីតាំងដែលបាន ជ្រើសរើសដោយអតិថិជនដែលស្ថិតនៅក្នុងចម្ងាយ 50 ម៉ែលពីទីតាំងទទួលយក។ សំណើដឹកជញ្ជូនអាចរួមមានការបញ្ជាទិញផ្សេងៗគ្នាលើសពីមួយដង ប៉ុន្តែមិនលើសពី 12 ដងដែលបានស្នើដោយអតិថិជន។ សេវាកម្មដឹកជញ្ជូនអាចរួមមានការជ្រើសរើស ការប្រមូលផ្តុំ ឬការទិញទំនិញ ដោយអ្នកដឹកជញ្ជូន DNC ករណីដែលកិច្ចការទាំងនោះត្រូវបានធ្វើដោយពាក់ព័ន្ធនឹងការដឹកជញ្ជូនដែលអ្នកដឹកជញ្ជូន DNC បានយល់ព្រមដឹកជញ្ជូន។ សេវាកម្មដឹកជញ្ជូនមិនរាប់បញ្ចូលនូវការដឹកជញ្ជូនទាំងឡាយណាដែលស្ថិតក្រោមផ្នែកទី 26090 ឡើយ ដូចដែលផ្នែកនោះបានចែងកាលពីថ្ងៃទី 29 ខែតុលា ឆ្នាំ 2019។

(i) "ម៉ែលដែលចូលរួម" មានន័យថាចម្ងាយគិតជាម៉ែលទាំងអស់ដែលបានបើកបរអំឡុងម៉ោងពាក់ព័ន្ធនៅក្នុងយានយន្តដឹកអ្នកដំណើរ ដែលមិនត្រូវបានកាន់កាប់ ឬជួលដោយក្រុមហ៊ុនបណ្តាញ។

(j) (1) "ម៉ោងដែលចូលរួម" មានន័យថា ស្ថិតក្រោមលក្ខខណ្ឌទាំងឡាយដែលមានចែងនៅក្នុងកថាខណ្ឌទី (2) អំឡុងពេល ដូចបានកត់ត្រានៅក្នុងកម្មវិធី ឬប្រព័ន្ធអនឡានរបស់ក្រុមហ៊ុនបណ្តាញ ចាប់ពីពេលដែលអ្នកបើកបរដែលប្រើកម្មវិធីទទួលយកសំណើដឹកជញ្ជូនរហូតដល់ពេលដែលអ្នកបើកបរដែលប្រើកម្មវិធីបញ្ចប់នូវសំណើដឹកជញ្ជូន ឬដឹកអ្នកដំណើរនោះ។

(2) (A) ម៉ោងដែលចូលរួមមិនត្រូវរាប់បញ្ចូលខាងក្រោមនេះឡើយ៖

(i) រាល់ម៉ោងដែលបានចំណាយដើម្បីផ្តល់សេវាដឹកអ្នកដំណើរ ឬដឹកជញ្ជូន ក្រោយពីសំណើនោះត្រូវបានលុបចោលដោយអតិថិជន។

(ii) រាល់ម៉ោងដែលបានចំណាយទៅលើសេវាដឹកអ្នកដំណើរ ឬដឹកជញ្ជូន ដែលអ្នកបើកបរប្រើកម្មវិធីបានបោះបង់ចោលការផ្តល់សេវាមុនពេលការបញ្ចប់ ។

(B) ក្រុមហ៊ុនបណ្តាញក៏អាចនឹងដកម៉ោងចេញផងដែរ ប្រសិនបើការធ្វើដូច្នោះមានភាពចាំបាច់សមហេតុសមផលក្នុងការដោះស្រាយ ឬបង្ការនូវការប្រើប្រាស់ដោយទុចរិតនូវកម្មវិធី ឬប្រព័ន្ធអនឡានរបស់ក្រុមហ៊ុនបណ្តាញ។

(k) "រដ្ឋាភិបាលថ្នាក់មូលដ្ឋាន" មានន័យថា ទីក្រុង ខោនធី ទីក្រុងនិងខោនធី ទីក្រុងស្វយ័ត ឬខោនធីស្វយ័ត។

(l) "ក្រុមហ៊ុនបណ្តាញ" មានន័យថាអង្គភាពអាជីវកម្មដែលជា DNC ឬ TNC ។

(m) "យានជំនិះដឹកអ្នកដំណើរ" មានន័យថារថយន្តដឹកអ្នកដំណើរ ដូចមានកំណត់នៅក្នុងផ្នែកទី 465 នៃក្រមស្តីពីយានជំនិះ។

(n) "ផែនការសុខភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" មានន័យថាផែនការធានារ៉ាប់រងសុខភាពដែលក្នុងនោះអ្នកបើកបរដែលប្រើកម្មវិធីគឺជាអ្នកជាវដែលមិនត្រូវបានឧបត្ថម្ភដោយនិយោជក និងដែលមិនមែនជាផែនការ Medicare ឬ Medicaid ។

(o) "សេវាកម្មដឹកអ្នកដំណើរ" មានន័យថាការដឹកជញ្ជូនមនុស្សម្នាក់ ឬច្រើននាក់។

(p) "ក្រុមហ៊ុនបណ្តាញដឹកជញ្ជូន" (TNC) មានអត្ថន័យដូចគ្នានឹងនិយមន័យដែលមាននៅក្នុងផ្នែករង (c) នៃផ្នែកទី 5431 នៃក្រមស្តីពីសេវាកម្មសាធារណៈ។

(q) "អ្នកបើកបរក្រុមហ៊ុនបណ្តាញដឹកជញ្ជូន" (អ្នកបើកបរ TNC) មានអត្ថន័យដូចគ្នានឹងនិយមន័យដែលមាននៅក្នុងផ្នែករង (a) នៃផ្នែកទី 5431 នៃក្រមស្តីពីសេវាកម្មសាធារណៈ។

(r) "អ្នកដឹកជញ្ជូនអ្នកដំណើរភាគីស្វយ័ត" (TCP) មានអត្ថន័យដូចគ្នានឹងនិយមន័យដែលមាននៅក្នុងផ្នែករង 5360 នៃក្រមស្តីពីសេវាកម្មសាធារណៈដែលចែងថា អ្នកបើកបរជាអ្នកផ្តល់សេវាដឹកជញ្ជូនដោយប្រើយានយន្តដឹកអ្នកដំណើរតាមរយៈកម្មវិធី ឬប្រព័ន្ធអនឡានរបស់ក្រុមហ៊ុនបណ្តាញ។

មាត្រា 7. ស្តង់ដារការងារតែមួយ

7464. (a) ការផ្តល់សេវាកម្មដឹកអ្នកដំណើរឬដឹកជញ្ជូនតែមួយ ជារឿយៗតម្រូវឲ្យអ្នកបើកបរដែលប្រើកម្មវិធីត្រូវធ្វើដំណើរឆ្លងកាត់ព្រំដែនសមត្ថកិច្ចរបស់រដ្ឋាភិបាលថ្នាក់មូលដ្ឋានជាច្រើន។ រដ្ឋ California មានទីក្រុងនិងខោនធីជាង 500 ដែលអាចបណ្តាលឲ្យមាននិយ័តកម្មក្នុងមូលដ្ឋានដែលត្រួតគ្នា មិនស៊ីសង្វាក់គ្នា និងប្រឆាំងគ្នាសម្រាប់សេវាកម្មឆ្លងដែនយុត្តាធិការ។

22

(b) ទាក់ទងនឹងលក្ខណៈនៃការឆ្លងដែនយុត្តាធិការនៃសេវាដឹកអ្នកដំណើរ និងដឹកជញ្ជូន និងបន្ថែមទៅលើលក្ខខណ្ឌតម្រូវនិងស្តង់ដារទាំងឡាយដែលបានបង្កើតឡើងដោយជំពូកនេះ រដ្ឋកាន់កាប់ទៅលើផ្នែកទាំងឡាយដូចខាងក្រោម៖

(1) ការផ្តល់ប្រាក់សំណង និងប្រាក់ឧបត្ថម្ភដល់អ្នកបើកបរដែលប្រើកម្មវិធី លើកលែងតែដូចមានចែងនៅក្នុងផ្នែកទី 7453។

(2) ការគ្រោងពេល ការសុំច្បាប់ និងប្រាក់ជំនួយថែទាំសុខភាពសម្រាប់អ្នកបើកបរដែលប្រើកម្មវិធី ព្រមទាំងប្រាក់ខែ ប្រាក់ជំនួយ ឬអត្ថប្រយោជន៍ផ្សេងទៀតដែលទាក់ទងនឹងការងារ ។

(3) លក្ខខណ្ឌតម្រូវនៃការផ្តល់អាជ្ញាប័ណ្ណ និងការធានារ៉ាប់រងសម្រាប់អ្នកបើកបរដែលប្រើកម្មវិធី។

(4) សិទ្ធិរបស់អ្នកបើកបរដែលប្រើកម្មវិធី ដែលទាក់ទងនឹងការរំលាយកិច្ចសន្យាអ្នកបើកបរប្រើកម្មវិធីរបស់ក្រុមហ៊ុនបណ្តាញ។

(c) ថ្វីបើមានផ្នែករង (b) ក៏ដោយ គ្មានអ្វីមួយនៅក្នុងផ្នែកនេះត្រូវកំណត់ព្រំដែនសមត្ថភាពរបស់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន ក្នុងការអនុម័តបទបញ្ជាក្នុងមូលដ្ឋាន ដែលចាំបាច់ក្នុងការដាក់ទោសការប្រព្រឹត្តបទមជ្ឈឹម និងបទឧក្រិដ្ឋ ឬក្នុងការអនុវត្តបទបញ្ជា និងនិយ័តកម្មក្នុងមូលដ្ឋានដែលបានអនុម័តមុនថ្ងៃទី 29 ខែតុលា ឆ្នាំ 2019 ។

មាត្រា 8. ការរាយការណ៍ប្រាក់ចំណូល

7464.5 (a) ក្រុមហ៊ុនបណ្តាញដែលដើរតួជាអង្គភាពដោះស្រាយភាគីទីបី ត្រូវរៀបចំការបញ្ជូនព័ត៌មានត្រឡប់ទៅវិញសម្រាប់អ្នកបង់ប្រាក់ដែលចូលរួមដែលជាអ្នកបើកបរដែលប្រើកម្មវិធីដោយមានអាសយដ្ឋានរដ្ឋ California ដែលមានចំនួនទឹកប្រាក់សរុបនៃប្រតិបត្តិការទូទាត់ប្រាក់ដែលអាចរាយការណ៍បានស្មើនឹង ឬច្រើនជាងប្រាំមួយរយដុល្លារ ($600) ក្នុងមួយឆ្នាំប្រតិទិនដោយមិនគិតពីចំនួននៃប្រតិបត្តិការរវាងអង្គភាពដោះស្រាយភាគីទីបី និងអ្នកបង់ប្រាក់។ អង្គភាពដោះស្រាយភាគីទីបីត្រូវតែរាយការណ៍ចំនួនទឹកប្រាក់នេះទៅកាន់គណៈកម្មការពន្ធដារលើសិទ្ធិប្រើយីហោ និងផ្តល់ជូនអ្នកបង់ប្រាក់មួយច្បាប់ ទោះបីជាខ្លួនពុំមានកាតព្វកិច្ចរាយការណ៍ជូនសហព័ន្ធក៏ដោយ។ ការបញ្ជូនព័ត៌មានត្រឡប់ទៅវិញត្រូវកំណត់អត្តសញ្ញាណដូចខាងក្រោម៖

(1) ឈ្មោះ អាសយដ្ឋាន និងលេខសម្គាល់ពន្ធរបស់អ្នកបង់ប្រាក់ដែលចូលរួម។

(2) ចំនួនទឹកប្រាក់សរុបនៃប្រតិបត្តិការទូទាត់ប្រាក់ដែលអាចរាយការណ៍បាន ដែលទាក់ទងនឹងអ្នកបង់ប្រាក់ដែលចូលរួម។

(b) ក្នុងរយៈពេល 30 ថ្ងៃ ក្រោយកាលបរិច្ឆេទដែលការបញ្ជូនព័ត៌មានត្រលប់វិញនេះត្រូវដល់ពេលបង់ទៅផ្នែកសេវាប្រាក់ចំណូលផ្ទៃក្នុង ក្រុមហ៊ុនបណ្តាញត្រូវរៀបចំដាក់ការបញ្ជូនព័ត៌មានត្រឡប់ទៅវិញមួយច្បាប់ ដែលតម្រូវដោយផ្នែករង (a) ជាមួយនឹងគណៈកម្មការពន្ធដារសិទ្ធិប្រើយីហោ ហើយត្រូវផ្តល់ជូនអ្នកបង់ប្រាក់ដែលចូលរួមមួយច្បាប់។

(c) ក្រុមហ៊ុនបណ្តាញអាចបំពេញលក្ខខណ្ឌតម្រូវនេះដោយការដាក់ជូននូវទម្រង់ប៉ែបបទសេវាប្រាក់ចំណូលផ្ទៃក្នុង 1099-K មួយច្បាប់ ឬដោយដាក់ជូននូវទម្រង់មួយដែលផ្តល់ដោយគណៈកម្មការពន្ធដារលើសិទ្ធិប្រើយីហោ ដែលរួមបញ្ចូលនូវព័ត៌មានដូចគ្នានៅលើ Cal-1099-K។

(d) សម្រាប់គោលបំណងនៃផ្នែកនេះ៖

(1) "អ្នកបង់ប្រាក់ដែលចូលរួម" មានអត្ថន័យដូចគ្នានឹងអ្វីដែលមានចែងនៅក្នុងផ្នែកទី 6050W(d)(1)(A)(ii) នៃចំណងជើងទី 26 នៃក្រមសហរដ្ឋអាមេរិច។

(2) "ប្រតិបត្តិការទូទាត់ប្រាក់ដែលអាចរាយការណ៍បាន" មានអត្ថន័យដូចគ្នានឹងអ្វីដែលមានចែងនៅក្នុងផ្នែកទី 6050W(c)(1) នៃចំណងជើងទី 26 នៃក្រមសហរដ្ឋអាមេរិច។

(3) "អង្គភាពដោះស្រាយភាគីទីបី" មានអត្ថន័យដូចគ្នានឹងអ្វីដែលមានចែងនៅក្នុងផ្នែកទី 6050W(b)(3) នៃចំណងជើងទី 26 នៃក្រមសហរដ្ឋអាមេរិច។

(e) ផ្នែកនេះមិនត្រូវបានអនុវត្តនៅក្នុងស្ថានភាពដែលចំនួនទឹកប្រាក់សរុបនៃប្រតិបត្តិការទូទាត់ប្រាក់ដែលអាចរាយការណ៍បានសម្រាប់អ្នកបង់ប្រាក់ដែលចូលរួមនៅក្នុងឆ្នាំប្រតិទិនតិចជាងប្រាំមួយរយដុល្លារ ($600) ឬដែលអ្នកបង់ប្រាក់ដែលចូលរួមនោះមិនមែនជាអ្នកបើកបរប្រើកម្មវិធីឡើយ។

(f) ផ្នែកនេះត្រូវអនុវត្តចំពោះប្រតិបត្តិការទូទាត់ប្រាក់ដែលអាចរាយការណ៍បាន ដែលកើតឡើងនៅថ្ងៃទី ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2021។

មាត្រា 9. វិសោធនកម្ម

7465. (a) ក្រោយកាលបរិច្ឆេទប្រសិទ្ធភាពនៃជំពូកនេះ អង្គនីតិបញ្ញត្តិអាចនឹងធ្វើវិសោធនកម្មជំពូកនេះដោយលក្ខខន្តិកៈដែលបានអនុម័តនៅក្នុងសភានីមួយៗ ដោយការបោះឆ្នោតហៅឈ្មោះដែលបានបញ្ចូលនៅក្នុងទិន្នានុប្បវត្តិ ប្រាំពីរភាគប្រាំបីនៃសមាជិកភាពដំណាលគ្នា ករណីដែលលក្ខន្តិកៈនោះស៊ីសង្វាក់គ្នាជាមួយនឹង និងពង្រីកបន្ថែមគោលបំណងនៃជំពូកនេះ។ គ្មានសេចក្តីព្រាងច្បាប់ណាមួយដែលស្វែងរកការធ្វើវិសោធនកម្មជំពូកនេះ ក្រោយកាលបរិច្ឆេទប្រសិទ្ធភាពនៃជំពូកនេះ អាចត្រូវបានអនុម័តឬក្លាយជាលក្ខន្តិកៈពិតប្រាកដឡើយ លើកលែងតែសេចក្តីព្រាងច្បាប់នោះ ត្រូវបានបោះពុម្ព និងចែកចាយទៅឲ្យសមាជិករួច និងប្រកាសផ្សាយនៅលើអ៊ីនធើណិតជាទម្រង់សម្រេចចុងក្រោយរបស់វា ក្នុងរយៈពេលយ៉ាងតិច 12 ថ្ងៃនៃថ្ងៃធ្វើការ មុនការអនុម័តរបស់វានៅក្នុងសភាណាមួយនៃអង្គនីតិបញ្ញត្តិ។

(b) គ្មានលក្ខន្តិកៈណាមួយដែលត្រូវបានអនុម័តក្រោយថ្ងៃទី 29 ខែតុលា ឆ្នាំ 2019 ប៉ុន្តែមុនកាលបរិច្ឆេទប្រសិទ្ធភាពនៃជំពូកនេះ ដែលនឹងបង្កើតវិសោធនកម្មនៃជំពូកនេះ ត្រូវដំណើរការក្រោយកាលបរិច្ឆេទប្រសិទ្ធភាពនៃជំពូកនេះឡើយ លើកលែងតែលក្ខន្តិកៈនោះត្រូវបានអនុម័តដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃផ្នែករង (a)។

(c) (1) គោលបំណងនៃជំពូកនេះមានរៀបរាប់នៅក្នុងមាត្រា 1 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 7448)។

(2) រាល់លក្ខន្តិ:ដែលធ្វើវិសោធនកម្មផ្នែកទី 7451 មិនពង្រីកបន្ថែមគោលបំណងនៃជំពូកនេះឡើយ។

(3) រាល់លក្ខន្តិកៈដែលហាមឃាត់អ្នកបើកបរដែលប្រើកម្មវិធីពីការផ្តល់សេវាដឹកអ្នកដំណើរ ឬដឹកជញ្ជូនជាក់លាក់ណាមួយ ខណៈពេលអនុញ្ញាតឲ្យបុគ្គល ឬអង្គភាពផ្សេងៗផ្តល់សេវាដឹកអ្នកដំណើរ ឬដឹកជញ្ជូនដូចគ្នានេះ ឬដាក់បន្ទុកបទបញ្ជាដែលមិនស្មើគ្នាទៅលើអ្នកបើកបរដែលប្រើកម្មវិធី ដោយផ្អែកទៅលើស្ថានភាពចំណាត់ថ្នាក់របស់ពួកគេ បង្កើតបានជាវិសោធនកម្មនៃជំពូកនេះ ហើយត្រូវតែអនុម័តដោយអនុលោមតាមនីតិវិធីទាំងឡាយដែលគ្រប់គ្រងលើវិសោធនកម្មដែលស៊ីសង្វាក់គ្នាជាមួយនឹងគោលបំណងនៃជំពូកនេះដូចមានចែងនៅក្នុងផ្នែករង (a) និង (b)។

(4) រាល់លក្ខន្តិកៈដែលអនុញ្ញាតឲ្យអង្គភាព ឬអង្គការណាមួយតំណាងឲ្យផលប្រយោជន៍របស់អ្នកបើកបរដែលប្រើកម្មវិធីដែលពាក់ព័ន្ធនឹងទំនាក់ទំនងកិច្ចសន្យារបស់អ្នកបើកបរជាមួយក្រុមហ៊ុនបណ្តាញ ឬប្រាក់សំណង អត្ថប្រយោជន៍ ឬលក្ខខណ្ឌការងាររបស់អ្នកបើកបរ បង្កើតបានជាវិសោធនកម្មនៃជំពូកនេះ ហើយត្រូវតែអនុម័តដោយអនុលោម

22

តាមនីតិវិធីទាំងឡាយដែលគ្រប់គ្រងលើវិសោធនកម្មដែលស៊ីសង្វាក់គ្នាជាមួយនឹងគោលបំណងនៃជំពូកនេះដូចមានចែងនៅក្នុងផ្នែករង (a) និង (b)។

(d) រាល់លក្ខន្តិកៈដែលដាក់ទោសបញ្ញត្តិបទមជ្ឈឹម ឬបទឧក្រិដ្ឋបន្ថែមដើម្បីផ្តល់កិច្ចការពារកាន់តែច្រើនប្រឆាំងនឹងសកម្មភាពឧក្រិដ្ឋសម្រាប់អ្នកបើកបរដោយផ្អែកលើកម្មវិធី និងបុគ្គលដែលប្រើសេវាដឹកអ្នកដំណើរ ឬដឹកជញ្ជូនអាចត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិដោយការបោះឆ្នោតហៅឈ្មោះដែលបានបញ្ជូលនៅក្នុងទិន្នានុប្បវត្តិសំឡេងភាគច្រើននៃសមាជិកភាពដំណាលគ្នារបស់សភានីមួយៗដោយមិនចាំបាច់អនុលោមតាមផ្នែករង (a) និង (b)។

មាត្រា 10. និយ័តកម្ម

7466. (a) និយ័តកម្មគ្រាមានអាសន្នអាចត្រូវបានអនុម័តដោយ Covered California ដើម្បីអនុវត្តនិងគ្រប់គ្រងផ្នែករង (c) និង (g) នៃផ្នែកទី 7454។

(b) និយ័តកម្មគ្រាអាសន្នដែលត្រូវបានអនុម័តដោយអនុលោមតាមផ្នែកនេះ ត្រូវអនុលោមតាមជំពូកទី 3.5 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 11340) នៃភាគទី 1 នៃចំណែកទី 3 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល និងសម្រាប់គោលបំណងនៃជំពូកនោះ រួមទាំងផ្នែកទី 11349.6 នៃក្រមរដ្ឋាភិបាល ការអនុម័តនិយ័តកម្មនេះគឺជាការបន្ទាន់មួយ ហើយត្រូវពិចារណាដោយការិយាល័យច្បាប់រដ្ឋបាលតាមការចាំបាច់សម្រាប់ការរក្សាសន្តិភាព សុខភាព និងសុវត្ថិភាពសាធារណៈ និងសុខុមាលភាពទូទៅភ្លាមៗ។ ថ្វីបើមានប្រការនៃច្បាប់ផ្សេងទៀតក៏ដោយ និយ័តកម្មគ្រាអាសន្នដែលត្រូវបានអនុម័តដោយ Covered California អាចនៅតែមានប្រសិទ្ធភាពរយៈពេលពីរឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការអនុម័ត។

មាត្រា 11. ភាពដាច់ចេញពីគ្នា

7467. (a) ស្ថិតក្រោមផ្នែករង (b) ប្រការទាំងឡាយនៃជំពូកនេះ គឺដាច់ដោយឡែកពីគ្នា។ ប្រសិនបើចំណែក ផ្នែក ផ្នែករង កថាខណ្ឌ អនុប្រយោគ ប្រយោគ ឃ្លា ពាក្យ ឬការអនុវត្តនៃជំពូកនេះគឺដោយសារហេតុផលណាមួយដែលត្រូវបានចាត់ទុកជាមោឃៈដោយសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច សេចក្តីសម្រេចនោះមិនត្រូវប៉ះពាល់ទៅលើចំណែកដែលនៅសេសសល់នៃជំពូកនេះឡើយ។ ប្រជាជននៃរដ្ឋ California សូមប្រកាសថាពួកគេនឹងបានអនុម័តជំពូកនេះ ហើយរាល់ចំណែក ផ្នែក ផ្នែករង កថាខណ្ឌ អនុប្រយោគ ប្រយោគ ឃ្លា ពាក្យ និងការអនុវត្តដែលមិនត្រូវបានប្រកាសជាមោឃៈ ឬផ្ទុយពីរដ្ឋធម្មនុញ្ញ ដោយមិនគិតថាតើចំណែកផ្សេងទៀតនៃជំពូកនេះ ឬការអនុវត្តនៃជំពូកនេះនឹងត្រូវបានប្រកាសជាបន្តបន្ទាប់ថាជាមោឃៈ។

(b) ថ្វីបើមានផ្នែករង (a) ក៏ដោយ ប្រសិនបើចំណែក ផ្នែក ផ្នែករង កថាខណ្ឌ អនុប្រយោគ ប្រយោគ ឃ្លា ពាក្យ ឬការអនុវត្តណាមួយនៃផ្នែកទី 7451 នៃមាត្រា 2 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 7451) ដូចដែលបានបន្ថែមដោយអ្នកបោះឆ្នោត ដោយសារហេតុផលណាមួយដែលត្រូវបានចាត់ទុកជាមោឃៈដោយសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច សេចក្តីសម្រេចនោះត្រូវអនុវត្តទៅលើប្រការដែលនៅសេសសល់ទាំងស្រុងនៃជំពូកនេះ ហើយគ្មានបទបញ្ញត្តិណាមួយនៃជំពូកនេះត្រូវបានចាត់ទុកថាមានសុពលភាព ឬត្រូវបានផ្តល់អនុភាពនៃច្បាប់ឡើយ។

ផ្នែកទី 2. ផ្នែកទី 17037 នៃក្រមស្តីពីប្រាក់ចំណូលនិងពន្ធដារ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម៖

17037. ប្រការទាំងឡាយនៅក្នុងក្រម ឬលក្ខន្តិកៈច្បាប់ទូទៅផ្សេងៗដែលពាក់ព័ន្ធនឹងភាគនេះ ដាក់បញ្ចូលនូវចំណុចទាំងអស់ដូចខាងក្រោម៖

(a) ជំពូក 20.6 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 9891) នៃចំណែកទី 3 នៃក្រមស្តីពីអាជីវកម្មនិងវិជ្ជាជីវៈ ដែលទាក់ទងនឹងអ្នករៀបចំពន្ធដារ។

(b) ភាគទី 10.2 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 18401) ដែលទាក់ទងនឹងការគ្រប់គ្រងច្បាប់ស្តីពីសិទ្ធិប្រើយីហោ និងពន្ធលើប្រាក់ចំណូល។

(c) ភាគទី 10.5 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 20501) ដែលទាក់ទងនឹងច្បាប់ស្តីពីជំនួយ និងការពន្យារពេលពន្ធលើអចលនទ្រព្យ។

(d) ភាគទី 10.7 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 21001) ដែលទាក់ទងនឹងសេចក្តីព្រៀងច្បាប់នៃសិទ្ធិរបស់អ្នកបង់ពន្ធ។

(e) ភាគទី 11 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 23001) ដែលទាក់ទងនឹងច្បាប់ស្តីពីពន្ធលើសាជីវកម្ម។

(f) ផ្នែកទី 15700 ដល់ 15702.1 ដោយរាប់បញ្ចូលក្រមរដ្ឋាភិបាលដែលទាក់ទងនឹងគណៈកម្មការពន្ធលើសិទ្ធិប្រើយីហោ។

(g) មាត្រា 8 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 7464.5) នៃជំពូកទី 10.5 នៃចំណែកទី 3 នៃក្រមស្តីពីអាជីវកម្ម និងវិជ្ជាជីវៈ។

ផ្នែក 3. ទំនាស់វិធានការ។

(a) ករណីដែលវិធានការគំនិតផ្ដួចផ្ដើមនេះនិងវិធានការសន្លឹកឆ្នោតផ្សេងទៀត ឬវិធានការទាំងឡាយដែលពាក់ព័ន្ធដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីជាមួយនឹងចំណាត់ថ្នាក់បុគ្គលិក ការផ្តល់ប្រាក់សំណង ឬអត្ថប្រយោជន៍របស់អ្នកបើកបរដែលប្រើកម្មវិធី ត្រូវមាននៅលើសន្លឹកឆ្នោតទូទាំងរដ្ឋដូចគ្នានោះ វិធានការសន្លឹកឆ្នោត ឬវិធានការនានាត្រូវបានចាត់ទុកថាមានទំនាស់ជាមួយនឹងវិធានការនេះ។ ក្នុងករណីដែលគំនិតផ្ដួចផ្ដើមនេះទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាង ប្រការទាំងឡាយនៃវិធានការនេះត្រូវមានជ័យជំនះទាំងស្រុង ហើយប្រការនៃវិធានការ ឬបណ្តាវិធានការសន្លឹកឆ្នោតផ្សេងទៀតត្រូវចាត់ទុកជាមោឃៈ។

(b) ប្រសិនបើវិធានការនេះត្រូវបានអនុម័តដោយអ្នកបោះឆ្នោត ប៉ុន្តែត្រូវបានជំនួសទាំងស្រុង ឬដោយផ្នែកដោយវិធានការសន្លឹកឆ្នោតមានទំនាស់ផ្សេងទៀតដែលអនុម័តដោយអ្នកបោះឆ្នោតនៅពេលបោះឆ្នោតតែមួយ ហើយវិធានការសន្លឹកឆ្នោតដែលមានទំនាស់ត្រូវបានចាត់ទុកជាមោឃៈនាពេលក្រោយមកទៀតនោះ វិធានការនេះត្រូវតែស្វ័យអនុវត្ត និងទទួលបានប្រសិទ្ធិភាព និងចូលជាធរមានពេញលេញ។

ផ្នែកទី 4. ការការពារផ្លូវច្បាប់។

គោលបំណងនៃផ្នែកនេះគឺដើម្បីធានាថាសិទ្ធិដ៏មានតម្លៃរបស់ប្រជាពលរដ្ឋក្នុងការទទួលបាននូវគំនិតផ្ដួចផ្ដើមនេះ មិនអាចត្រូវបានចាត់ទុកជាមោឃៈដោយមិនត្រឹមត្រូវដោយអ្នកនយោបាយរដ្ឋ ដែលបដិសេធមិនការពារឆន្ទៈអ្នកបោះឆ្នោតបានឡើយ។ ដូច្នេះ ប្រសិនបើច្បាប់នេះត្រូវបានអនុម័តដោយអ្នកបោះឆ្នោតនៃរដ្ឋ California ហើយក្រោយមកទៀតស្ថិតក្រោមបញ្ហាប្រឈមផ្នែកច្បាប់ដែលប៉ុនប៉ងកំណត់វិសាលភាព
ឬការអនុវត្តនៃច្បាប់នេះតាមរបៀបណាមួយ ឬចោទប្រកាន់ថាច្បាប់នេះរំលោភបំពានទៅលើច្បាប់ក្នុងមូលដ្ឋាន រដ្ឋ ឬសហព័ន្ធទាំងស្រុង ឬដោយផ្នែក ហើយអភិបាល និងអគ្គមេធាវីបដិសេធមិនការពារច្បាប់នេះ នោះត្រូវចាត់ការដូចតទៅ៖

(a) ថ្វីបើមានអ្វីដែលផ្ទុយទៅនឹងប្រការនៅក្នុងជំពូកទី 6 ក៏ដោយ (ចាប់ផ្តើមពីផ្នែក 12500) នៃភាគទី 2 នៃផ្នែកទី 3 នៃចំណងជើងទី 2

នៃក្រមរដ្ឋាភិបាល ឬច្បាប់ផ្សេងទៀតណាមួយ អគ្គមេធាវី នឹងតែងតាំងទីប្រឹក្សាឯករាជ្យដើម្បីការពារច្បាប់នេះក្នុងនាមរដ្ឋ California។

(b) មុនពេលតែងតាំងឬក្រោយពីបង្កើតទីប្រឹក្សាឯករាជ្យ អគ្គមេធាវីត្រូវអនុវត្តដោយគ្មានធ្វេសប្រហែសក្នុងការកំណត់គុណសម្បត្តិនៃទីប្រឹក្សាឯករាជ្យ ហើយត្រូវទទួលនូវការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីទីប្រឹក្សាឯករាជ្យថាទីប្រឹក្សាឯករាជ្យនឹងអនុវត្តការការពារច្បាប់នេះដោយស្មោះត្រង់។ ការបញ្ជាក់ជាលាយលក្ខណ៍អក្សរត្រូវបង្ហាញជាសាធារណៈទៅតាមការស្នើសុំ។

(c) ដើម្បីគាំទ្រដល់ការការពារច្បាប់នេះនៅក្នុងស្ថានភាពទាំងឡាយដែលអភិបាលនិងអគ្គមេធាវីខកខានពុំបានធ្វើដូច្នោះ ទោះបីជាមានឆន្ទៈរបស់អ្នកបោះឆ្នោតក៏ដោយនោះ ត្រូវមានការបម្រុងទុកជាបន្តពីមូលនិធិទូទៅដល់អ្នកគ្រប់គ្រងដោយមិនគិតពីឆ្នាំសារពើពន្ធ ក្នុងចំនួនទឹកប្រាក់មួយដែលចាំបាច់ដើម្បីរ៉ាប់រងទៅលើបន្ទុកចំណាយនៃការរក្សាឲ្យក្រុមប្រឹក្សាឯករាជ្យការពារច្បាប់នេះដោយស្មោះស្ម័គ្រ និងរឹងមាំក្នុងនាមរដ្ឋ California។

ផ្នែកទី 5. ការបកស្រាយដោយសេរី។

ច្បាប់នេះត្រូវបានបកស្រាយដោយសេរីដើម្បីទទួលបានប្រសិទ្ធភាពតាមគោលបំណងរបស់ខ្លួន។

សំណើប្រជាមតិ23

វិធានការផ្តួចផ្តើមនេះបានដាក់ជូនប្រជាជនដោយអនុលោមទៅតាមប្រការនៃផ្នែក 8 មាត្រា II នៃធម្មនុញ្ញរដ្ឋ California។

វិធានការផ្តួចផ្តើមនេះបន្ថែមផ្នែកខ្លះទៅក្នុងក្រមស្តីពីសុវត្ថិភាព និងសុខភាព។ ដូចនេះ ប្រការថ្មីដែលបានស្នើបន្ថែមត្រូវបានបោះពុម្ពជា *ប្រភេទអក្សរទ្រេត* ដើម្បីបង្ហាញថាជាបទបញ្ញត្តិថ្មី។

សំណើច្បាប់

ផ្នែក 1. ឈ្មោះ។

ច្បាប់នេះត្រូវមានឈ្មោះថា "ច្បាប់ការពារអាយុជីវិតអ្នកជំងឺលាងឈាម (Protect the Lives of Dialysis Patients Act)"។

ផ្នែក 2. ការរកឃើញនិងគោលបំណង។

ច្បាប់នេះ ដែលត្រូវបានអនុម័តដោយប្រជាពលរដ្ឋ California ធ្វើការរកឃើញនិងមានគោលបំណងដូចខាងក្រោម៖

(a) ប្រជាពលរដ្ឋធ្វើការរកឃើញដូចខាងក្រោម៖

(1) ការលាងឈាម គឺជាដំណើរការសង្គ្រោះជីវិតមួយ ដែលឈាមត្រូវបានយកចេញពីរាងកាយរបស់មនុស្សម្នាក់ សម្អាតជាតិពុលចេញ រួចហើយបញ្ជូនត្រឡប់ទៅកាន់អ្នកជំងឺវិញ។ វាត្រូវតែធ្វើឡើងយ៉ាងហោចណាស់បីដងក្នុងមួយសប្តាហ៍ ជាច្រើនម៉ោងក្នុងមួយលើក ហើយអ្នកជំងឺត្រូវតែបន្តការព្យាបាលអស់មួយជីវិត ឬរហូតទាល់តែពួកគេទទួលបានប្តូរតម្រងនោម។

(2) នៅរដ្ឋ California មនុស្សយ៉ាងហោចណាស់ 70,000 នាក់ទទួលការព្យាបាលលាងឈាម។

(3) មានសាជីវកម្មស្វែងរកប្រាក់ចំណេញពហុជាតិចំនួនពីរប៉ុណ្ណោះ ដែលប្រតិបត្តិការ ឬចាត់ចែងគ្លីនិកលាងឈាមបីភាគបួននៅរដ្ឋ California ហើយព្យាបាលអ្នកជំងឺលាងឈាមជាង 75 ភាគរយនៅក្នុងរដ្ឋនេះ។ សាជីវកម្មពហុជាតិទាំងពីរនេះរកប្រាក់ប្រចាំឆ្នាំបានរាប់ពាន់លានដុល្លារពីប្រតិបត្តិការលាងឈាមរបស់ពួកគេ រួមទាំងច្រើនជាង $350 លានក្នុងមួយឆ្នាំគ្រាន់តែនៅក្នុងរដ្ឋ California មួយ។

(4) នីតិវិធីលាងឈាម និងផលប៉ះពាល់ពីការព្យាបាលបង្ហាញឲ្យឃើញនូវគ្រោះថ្នាក់ជាច្រើនចំពោះអ្នកជំងឺ ហើយគ្លីនិកលាងឈាមជាច្រើននៅរដ្ឋ California ត្រូវបានលើកឡើងពីភាពបរាជ័យក្នុងការរក្សាស្តង់ដារនៃការថែទាំឲ្យបានត្រឹមត្រូវ។ ភាពបរាជ័យក្នុងការរក្សាស្តង់ដារឲ្យបានត្រឹមត្រូវអាចបណ្តាលឲ្យមានគ្រោះថ្នាក់ចំពោះអ្នកជំងឺ ការសម្រាកនៅមន្ទីរពេទ្យ ហើយថែមទាំងឈានដល់ការស្លាប់ទៀតផង។

(5) គ្លីនិកលាងឈាមបច្ចុប្បន្ននេះ មិនត្រូវបានតម្រូវឲ្យមានវេជ្ជបណ្ឌិតនៅនឹងកន្លែងដើម្បីត្រួតពិនិត្យគុណភាព ធានាថាមានការគោរពតាមផែនការថែទាំអ្នកជំងឺត្រឹមត្រូវ និងត្រួតពិនិត្យពិធីការសុវត្ថិភាពឡើយ។ អ្នកជំងឺគួរតែមានលទ្ធភាពទទួលបានគ្រូពេទ្យនៅនឹងកន្លែង នៅពេលណាដែលការព្យាបាលលាងឈាមកំពុងត្រូវបានផ្តល់ជូន។

(6) ការព្យាបាលលាងឈាមពាក់ព័ន្ធនឹងការចូលទៅកាន់សរសៃឈាមដោយផ្ទាល់ ដែលដាក់អ្នកជំងឺនៅក្នុងហានិភ័យខ្ពស់ពីការឆ្លងជំងឺផ្សេងៗ។ ការរាយការណ៍ឲ្យបានត្រឹមត្រូវ និងតម្លាភាពនៃអត្រាឆ្លងជំងឺ លើកទឹកចិត្តឲ្យគ្លីនិកកែលម្អគុណភាព និងជួយដល់អ្នកជំងឺក្នុងការជ្រើសរើសការថែទាំរបស់ខ្លួនឲ្យបានល្អបំផុត។

(7) នៅពេលមន្ទីរថែទាំសុខភាពដូចជា មន្ទីរពេទ្យ និងមន្ទីរថែទាំមនុស្សចាស់បិទទ្វារ និយ័តករនៃរដ្ឋ California អាចចាត់វិធានការដើម្បីការពារអ្នកជំងឺពីគ្រោះថ្នាក់។ ដូចគ្នានេះដែរ កិច្ចការពារដ៏រឹងមាំគួរត្រូវបានផ្តល់ជូនដល់អ្នកជំងឺងាយរងគ្រោះ នៅពេលគ្លីនិកលាងឈាមបិទទ្វារ។

(8) សាជីវកម្មលាងឈាម បានបញ្ចុះបញ្ចូលប្រឆាំងនឹងកិច្ចប្រឹងប្រែងក្នុងការអនុម័តការការពារសម្រាប់អ្នកជំងឺលាងឈាមនៅរដ្ឋ California ដោយចំណាយជាង $100 លានកាលពីឆ្នាំ 2018 និង 2019 ដើម្បីមានឥទ្ធិពលលើអ្នកបោះឆ្នោត និងអង្គនីតិបញ្ញត្តិ។

(b) គោលបំណង៖

(1) វាគឺជាគោលបំណងនៃច្បាប់នេះ ដើម្បីធានាថា គ្លីនិកលាងឈាមអ្នកជំងឺមិនសម្រាកពេទ្យ ផ្តល់នូវការថែទាំអ្នកជំងឺប្រកបដោយគុណភាពនិងតម្លៃសមរម្យជូនប្រជាពលរដ្ឋដែលមានជំងឺតម្រងនោមដំណាក់កាលចុងក្រោយ។

(2) ច្បាប់នេះមានបំណងធ្វើជាថវិកាអព្យាក្រិតមួយសម្រាប់រដ្ឋក្នុងការអនុវត្តនិងគ្រប់គ្រង។

ផ្នែក 3. ផ្នែក 1226.7 ត្រូវបានបន្ថែមទៅក្នុងក្រមស្តីពីសុវត្ថិភាព និងសុខភាពដូចមានចែង៖

1226.7. (a) គ្លីនិកលាងឈាមរ៉ាំរ៉ៃ ត្រូវផ្តល់ការថែទាំប្រកបដោយគុណភាពដូចគ្នាជូនអ្នកជំងឺរបស់ខ្លួន ដោយពុំមានការរើសអើងផ្អែកទៅលើថាតើនរណាជាអ្នកទទួលខុសត្រូវបង់ប្រាក់សម្រាប់ការព្យាបាលរបស់អ្នកជំងឺ។ លើសពីនេះ គ្លីនិកលាងឈាមរ៉ាំរ៉ៃ មិនត្រូវបដិសេធមិនផ្តល់ការថែទាំដោយផ្អែកលើមូលដ្ឋានថាតើនរណាជាអ្នកទទួលខុសត្រូវបង់ប្រាក់សម្រាប់ការព្យាបាលរបស់អ្នកជំងឺឡើយ។ ការរើសអើងដែលត្រូវបានហាមឃាត់នេះរួមមានប៉ុន្តែមិនកំណត់ចំពោះ ការរើសអើងផ្អែកលើមូលដ្ឋានថាអ្នកបង់ប្រាក់គឺជាអ្នកជំងឺ អង្គភាពឯកជន អ្នកធានារ៉ាប់រង Medi-Cal Medicaid ឬ Medicare ។ ផ្នែកនេះក៏ត្រូវអនុវត្តផងដែរចំពោះអង្គភាពគ្រប់គ្រងសម្រាប់គ្លីនិកលាងឈាមរ៉ាំរ៉ៃដែលត្រូវធានាថាគ្មានការរើសអើងដែលត្រូវបានហាមឃាត់ដោយផ្នែកនេះកើតឡើងនៅឯ

22

23

ឬក្នុងចំណោមគ្លីនិកដែលកាន់កាប់ ឬប្រតិបត្តិការដោយអង្គភាពគ្រប់គ្រងឡើយ។

(b) និយមន័យ៖

(1) "គ្លីនិកលាងឈាមរ៉ាំរ៉ៃ" មានអត្ថន័យដូចគ្នានឹងនិយមន័យក្នុងផ្នែកទី 1204។

(2) "អង្គភាពគ្រប់គ្រង" សំដៅដល់បុគ្គល ក្រុមហ៊ុន សមាគម ដៃគូសាជីវកម្ម ឬអង្គភាពផ្សេងទៀតដែលជាម្ចាស់កម្មសិទ្ធិឬធ្វើប្រតិបត្តិការគ្លីនិកលាងឈាមរ៉ាំរ៉ៃដែលមានអាជ្ញាប័ណ្ណ ដោយមិនពាក់ព័ន្ធថាតើបុគ្គល ឬអង្គភាពនោះគ្រប់គ្រងអាជ្ញាបណ្ណដោយផ្ទាល់ឬទេ។

វគ្គ 4. វគ្គ 1226.8 ត្រូវបានបន្ថែមទៅក្នុងក្រមសុវត្ថិភាពនិងសុខភាព ដែលចែងថា៖

1226.8. (a) រាល់គ្លីនិកលាងឈាមរ៉ាំរ៉ៃ ដោយការចំណាយផ្ទាល់របស់គ្លីនិកលាងឈាមរ៉ាំរ៉ៃ ត្រូវតែរក្សាឲ្យមានវត្តមានគ្រូពេទ្យមានអាជ្ញាប័ណ្ណយ៉ាងតិចមួយរូបនៅនឹងកន្លែងគ្រប់ពេលវេលាដែលអ្នកជំងឺលាងឈាមនៅក្នុងមជ្ឈមណ្ឌលកំពុងទទួលការព្យាបាល។ គ្រូពេទ្យនេះត្រូវមានសិទ្ធិអំណាច និងការទទួលខុសត្រូវលើសុវត្ថិភាពអ្នកជំងឺ និងណែនាំលើការផ្តល់ និងគុណភាពការថែទាំវេជ្ជសាស្ត្រ។

(1) គ្លីនិកលាងឈាមរ៉ាំរ៉ៃ អាចដាក់ពាក្យសុំទៅកាន់ក្រសួងដើម្បីសុំការលើកលែងចំពោះលក្ខខណ្ឌតម្រូវនេះនៅក្នុងផ្នែករង (a) ដោយឈរលើហេតុផលស្មោះត្រង់ថាកង្វះខាតគ្រូពេទ្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រារាំងគ្លីនិកពុំអោយបំពេញតាមលក្ខខណ្ឌតម្រូវបាន។ នៅពេលបង្ហាញហេតុផលនេះ ក្រសួងអាចផ្តល់ការលើកលែងមួយដែលអនុញ្ញាតឲ្យគ្លីនិកបំពេញតាមលក្ខខណ្ឌតម្រូវនៅក្នុងផ្នែករង (a) ដោយត្រូវមានយ៉ាងហោចណាស់មួយក្នុងចំណោមខាងក្រោមនៅនឹងកន្លែងគ្រប់ពេលវេលាដែលអ្នកជំងឺលាងឈាមកំពុងទទួលការព្យាបាលនៅក្នុងមជ្ឈមណ្ឌលដូចជា៖ គ្រូពេទ្យមានអាជ្ញាប័ណ្ណ អ្នកអនុវត្តវិជ្ជាជីវៈគិលានុប្បដ្ឋាក ឬជំនួយការគ្រូពេទ្យ។

(2) ចេរវេលានៃការលើកលែងដែលផ្តល់ដោយក្រសួងដែលអនុលោមតាមកថាខណ្ឌទី (1) គឺមួយឆ្នាំប្រតិទិន ដោយគិតចាប់ពីកាលបរិច្ឆេទដែលគ្លីនិកទទួលដំណឹងអំពីការសម្រេចចិត្តរបស់ក្រសួង។

(b) សម្រាប់គ្លីនិកលាងឈាមរ៉ាំរ៉ៃនីមួយៗ គ្លីនិក ឬអង្គភាពគ្រប់គ្រង ត្រូវរាយការណ៍ប្រចាំត្រីមាសជូនក្រសួងអំពីទម្រង់ និងគម្រោងកាលវិភាគដែលបានចេញដោយក្រសួង ទិន្នន័យអំពីការឆ្លងជំងឺដែលពាក់ព័ន្ធនឹងការថែទាំសុខភាពរបស់គ្លីនិកលាងឈាម ("HAI របស់ គ្លីនិកលាងឈាម") រួមទាំងការកើតឡើងនិងប្រភេទនៃ HAI របស់គ្លីនិកលាងឈាមនៅតាមគ្លីនិកលាងឈាមរ៉ាំរ៉ៃនីមួយៗនៅរដ្ឋ California និងព័ត៌មានផ្សេងទៀតដែលក្រសួងចាត់ទុកថាសមរម្យក្នុងការផ្តល់តម្លាភាពលើអត្រា HAI របស់គ្លីនិកលាងឈាម និងលើកកម្ពស់សុវត្ថិភាពអ្នកជំងឺ។ មន្ត្រីប្រធានប្រតិបត្តិ ឬមន្ត្រីនាយកនៃគ្លីនិក ឬអង្គភាពគ្រប់គ្រង ត្រូវបញ្ជាក់ក្រោមទោសបញ្ញត្តិនៃការភូតភរថា មន្ត្រីនោះមានការពេញចិត្តក្រោយការពិនិត្យឡើងវិញរួច ថារបាយការណ៍ HAI របស់គ្លីនិកលាងឈាមដែលបានដាក់ជូនក្រសួងមានលក្ខណៈត្រឹមត្រូវ និងពេញលេញ។ ក្រសួងត្រូវប្រកាសផ្សាយនៅលើគេហទំព័រអ៊ីនធើណិតរបស់ខ្លួន អំពីទិន្នន័យ HAI របស់គ្លីនិកលាងតំរងនោមពីរបាយការណ៍នេះ នៅកម្រិតលម្អិតដូចគ្នានឹងកម្រិតដែលបានផ្តល់ជូននៅក្នុងរបាយការណ៍។ ព័ត៌មានដែលបានប្រកាសផ្សាយត្រូវដាក់បញ្ចូលនូវព័ត៌មានដែលកំណត់អត្តសញ្ញាណអង្គភាពគ្រប់គ្រងនៃគ្លីនិកលាងឈាមរ៉ាំរ៉ៃនីមួយៗ។

(1) បន្ថែមពីលើការរាយការណ៍ទៅកាន់ក្រសួងដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃផ្នែករងនេះ គ្លីនិកលាងតំរងនោមរ៉ាំរ៉ៃត្រូវរាយការណ៍អំពី HAI របស់គ្លីនិកលាងឈាមជូនបណ្តាញសុវត្ថិភាពថែទាំសុខភាពជាតិ យោងតាមលក្ខខណ្ឌតម្រូវ និងនីតិវិធីរបស់បណ្តាញសុវត្ថិភាពថែទាំសុខភាពជាតិ។

(2) ករណីក្រសួងកំណត់ថា គ្លីនិកលាងឈាមរ៉ាំរ៉ៃ ឬអង្គភាពគ្រប់គ្រងបានខកខានក្នុងការរក្សាព័ត៌មាន ឬដាក់ជូនរបាយការណ៍បានទាន់ពេលវេលាដូចដែលបានតម្រូវក្រោមផ្នែករងនេះ ឬដែលរបាយការណ៍ដែលបានដាក់ជូននោះពុំត្រឹមត្រូវ ឬមិនពេញលេញនោះក្រសួងត្រូវវាយតម្លៃទោសបញ្ញត្តិប្រឆាំងនឹងគ្លីនិកលាងឈាមរ៉ាំរ៉ៃ ឬអង្គភាពគ្រប់គ្រងមិនលើសពី មួយរយពាន់ដុល្លារ ($100,000)។ ក្រសួងត្រូវកំណត់ចំនួនទឹកប្រាក់ពិន័យដោយផ្អែកលើភាពធ្ងន់ធ្ងរនៃការបំពានស្ថានភាពនៃភាពមិនត្រឹមត្រូវ ឬខ្វះចន្លោះព័ត៌មាន និងគុណភាពនៃការបកស្រាយ ប្រសិនបើមាន ចំពោះការរំលោភបំពាននេះ។ ប្រាក់ពិន័យដែលប្រមូលបានដោយអនុលោមតាមកថាខណ្ឌនេះត្រូវបានប្រើប្រាស់ដោយក្រសួងក្នុងការអនុវត្តនិងពង្រឹងច្បាប់គ្រប់គ្រងគ្លីនិកព្យាបាលលាងឈាមរ៉ាំរ៉ៃ។

(c) និយមន័យ។ សម្រាប់គោលបំណងនៃផ្នែកនេះ៖

(1) "គ្លីនិកលាងឈាមរ៉ាំរ៉ៃ" មានអត្ថន័យដូចគ្នានឹងនិយមន័យក្នុងផ្នែកទី 1204។

(2) " HAI របស់គ្លីនិកលាងឈាម" មានន័យថា ការឆ្លងជំងឺតាមការហូរឈាម ការឆ្លងជំងឺតាមការប្រើប្រាស់ទីតាំងក្នុងមូលដ្ឋាន ឬការឆ្លងតាមសរសៃឈាម ដែលទាក់ទងនឹងការលាងឈាម ដូចដែលបានកំណត់ដោយបណ្តាញសុវត្ថិភាពថែទាំសុខភាពជាតិនៃមជ្ឈមណ្ឌលសហព័ន្ធទទួលបន្ទុកគ្រប់គ្រងនិងបង្ការជំងឺ ឬនិយមន័យបន្ថែម ឬជំនួសណាមួយដែលសមរម្យ ដែលក្រសួងកំណត់ដោយនិយ័តកម្ម។

(3) "អង្គភាពគ្រប់គ្រង" មានអត្ថន័យដូចគ្នានឹងនិយមន័យនៅក្នុងផ្នែកទី 1226.7។

(4) "គ្រូពេទ្យមានអាជ្ញាប័ណ្ណ" មានន័យថាគ្រូពេទ្យតម្រងនោម ឬគ្រូពេទ្យផ្សេងទៀតដែលផ្តល់អាជ្ញាប័ណ្ណដោយរដ្ឋ ដោយអនុលោមតាមជំពូកទី 5 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 2000) នៃចំណែកទី 2 នៃក្រមស្តីពីអាជីវកម្ម និងវិជ្ជាជីវៈ ។

(5) "បណ្តាញសុវត្ថិភាពថែទាំសុខភាពជាតិ" មានន័យថាប្រព័ន្ធតាមអ៊ីនធើណិតមានសន្តិសុខដែលបង្កើតឡើងនិងគ្រប់គ្រងដោយមជ្ឈមណ្ឌលសហព័ន្ធទទួលបន្ទុកគ្រប់គ្រងនិងបង្ការជំងឺដែលប្រមូល វិភាគ និងរាយការណ៍អំពីទិន្នន័យ HAI របស់គ្លីនិកលាងឈាមដែលលៃតម្រូវតាមហានិភ័យ ដែលពាក់ព័ន្ធនឹងការកើតឡើងនៃ HAI និងដំណើរការដែលវិធានការទាំងឡាយត្រូវបានអនុវត្តដើម្បីបង្ការការឆ្លងជំងឺទាំងនេះឬប្រព័ន្ធប្រមូលទិន្នន័យអ្នកស្នងតំណែងណាមួយ ដែលបម្រើឲ្យគោលបំណងដូចគ្នាបានយ៉ាងច្រើន។

(6) "អ្នកអនុវត្តវិជ្ជាជីវៈគិលានុប្បដ្ឋាក" មានន័យថាគិលានុប្បដ្ឋាកចុះបញ្ជីដែលមានអាជ្ញាប័ណ្ណដោយអនុលោមតាមជំពូកទី 6 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 2700) នៃផ្នែកទី 2 នៃក្រមស្តីពីអាជីវកម្ម និងវិជ្ជាជីវៈ និងបញ្ជាក់ទទួលស្គាល់ថាជាអ្នកអនុវត្តវិជ្ជាជីវៈគិលានុប្បដ្ឋាកដោយគណៈកម្មការគិលានុប្បដ្ឋាកចុះបញ្ជី។

(7) "ជំនួយការគ្រូពេទ្យ" មានន័យថា ជំនួយការគ្រូពេទ្យដែលមានអាជ្ញាប័ណ្ណដោយអនុលោមតាមជំពូកទី 7.7 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 3500) នៃចំណែកទី 2 នៃក្រមស្តីពីអាជីវកម្មនិងវិជ្ជាជីវៈ។

ផ្នែកទី 5. ផ្នែកទី 1226.9 ត្រូវបានបន្ថែមទៅលើក្រមស្តីពីសុខភាពនិងសុវត្ថិភាពដែលចែងថា៖

23

1226.9. (a) មុនពេលបិទទ្វារគ្លីនិកលាងឈាមរ៉ាំរ៉ៃ ឬកាត់បន្ថយ ឬលុបបំបាត់យ៉ាងច្រើននូវកម្រិតនៃសេវាកម្មដែលផ្តល់ជូនដោយគ្លីនិកលាងឈាមរ៉ាំរ៉ៃ គ្លីនិក ឬអង្គភាពគ្រប់គ្រង ត្រូវតែផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ និងទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រសួង។

(b) ក្រសួងត្រូវមានឆន្ទានុសិទ្ធិក្នុងការយល់ព្រម ផ្តល់ការយល់ព្រមដោយមានលក្ខខណ្ឌ ឬមិនយល់ព្រមចំពោះសំណើបិទទ្វារណាមួយ ឬការកាត់បន្ថយ ឬលុបបំបាត់យ៉ាងច្រើននូវសេវាកម្ម។ នៅក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន ក្រសួងអាចពិចារណាទៅលើព័ត៌មានដែលបានដាក់ស្នើដោយគ្លីនិក អង្គភាពគ្រប់គ្រង និងរាស្ត្រភាគីដែលចាប់អារម្មណ៍ដទៃទៀត និងត្រូវពិចារណានូវកត្តាទាំងឡាយណាដែលក្រសួងយល់ថាពាក់ព័ន្ធ រួមមានជាអាទិ៍ប៉ុន្តែមិនកំណត់ចំពោះខាងក្រោមនេះ៖

(1) ផលប៉ះពាល់ទៅលើលទ្ធភាពប្រើប្រាស់ និងលទ្ធភាពទទួលបាននៃសេវាថែទាំសុខភាពទៅលើសហគមន៍ដែលរងការប៉ះពាល់ រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ ផែនការលម្អិតរបស់គ្លីនិកសម្រាប់ធានាថាអ្នកជំងឺនឹងមានលទ្ធភាពទទួលបានការថែទាំដោយគ្មានការរំខាន។

(2) ភស្តុតាងនៃកិច្ចប្រឹងប្រែងដោយស្មោះត្រង់របស់គ្លីនិក ឬអង្គភាពគ្រប់គ្រងក្នុងការលក់ ជួល ឬផ្ទេរកម្មសិទ្ធិ ឬប្រតិបត្តិការរបស់គ្លីនិកទៅឲ្យអង្គភាពមួយផ្សេងទៀតដែលនឹងផ្តល់ការថែទាំលាងឈាមរ៉ាំរ៉ៃ។

(3) ធនធានហិរញ្ញវត្ថុរបស់គ្លីនិកនិងអង្គភាពគ្រប់គ្រងរបស់ខ្លួន។

(c) និយមន័យ៖

(1) "គ្លីនិកលាងឈាមរ៉ាំរ៉ៃ" មានអត្ថន័យដូចគ្នានឹងនិយមន័យក្នុងផ្នែកទី 1204។

(2) "អង្គភាពគ្រប់គ្រង" មានអត្ថន័យដូចគ្នានឹងនិយមន័យនៅក្នុងផ្នែកទី 1226.7។

ផ្នែកទី 6. ផ្នែកទី 1226.10 ត្រូវបានបន្ថែមទៅលើក្រមស្តីពីសុខភាពនិងសុវត្ថិភាពដែលចែងថា៖

1226.10. (a) ប្រសិនបើគ្លីនិកលាងឈាមរ៉ាំរ៉ៃ ឬអង្គភាពគ្រប់គ្រងជំទាស់នឹងសេចក្តីសម្រេចដោយក្រសួងដោយអនុលោមតាមផ្នែកទី 1226.8 ឬ 1226.9 គ្លីនិកលាងឈាមរ៉ាំរ៉ៃ ឬអង្គភាពគ្រប់គ្រងក្នុងរយៈពេល 10 ថ្ងៃធ្វើការអាចស្នើសុំសវនាការដោយអនុលោមតាមផ្នែកទី 131071។ គ្លីនិកលាងឈាមរ៉ាំរ៉ៃ ឬអង្គភាពគ្រប់គ្រងត្រូវបង់ប្រាក់ពិន័យទោសបញ្ញត្តិរដ្ឋបាលទាំងអស់ នៅពេលបណ្តឹងឧទ្ធរណ៍ទាំងអស់ត្រូវបានបញ្ចប់ ប្រសិនបើគោលជំហររបស់ក្រសួងត្រូវបានប្រកាន់ខ្ជាប់ ។

(b) និយមន័យ៖

(1) "គ្លីនិកលាងឈាមរ៉ាំរ៉ៃ" មានអត្ថន័យដូចគ្នានឹងនិយមន័យក្នុងផ្នែកទី 1204។

(2) "អង្គភាពគ្រប់គ្រង" មានអត្ថន័យដូចគ្នានឹងនិយមន័យនៅក្នុងផ្នែកទី 1226.7។

ផ្នែកទី 7. ផ្នែកទី 1266.3 ត្រូវបានបន្ថែមទៅលើក្រមស្តីពីសុខភាពនិងសុវត្ថិភាពដូចខាងក្រោម៖

1266.3. វាគឺជាចេតនារបស់ប្រជាពលរដ្ឋដែលថាអ្នកបង់ពន្ធរដ្ឋ California មិនទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ចំពោះការអនុវត្តនិងការប្រតិបត្តិនៃច្បាប់ការពារ អាយុជីវិតអ្នកជំងឺលាងឈាម។ ដើម្បីប្រតិបត្តិនូវចេតនានោះ នៅពេលគណនា វាយតម្លៃ និងប្រមូលកម្រៃសេវាដែលដាក់ដោយគ្លីនិកលាងឈាមរ៉ាំរ៉ៃ ដោយអនុលោមតាមផ្នែកទី 1266 ក្រសួងត្រូវពិចារណាទៅលើរាល់បន្ទុកចំណាយទាំងអស់ដែលពាក់ព័ន្ធនឹងការអនុវត្ត និងពង្រឹងផ្នែកទី 1226.7 ដល់ 1226.10 ដែលរាប់បញ្ចូល។

ផ្នែកទី 8. គ្មានអ្វីមួយនៅក្នុងច្បាប់នេះមានចេតនាប៉ះពាល់ដល់មន្ទីរថែទាំសុខភាពមានអាជ្ញាប័ណ្ណដោយអនុលោមតាមផ្នែករង (a), (b) ឬ (f) នៃផ្នែកទី 1250 នៃក្រមស្តីពីសុខភាពនិងសុវត្ថិភាពឡើយ។

ផ្នែកទី 9. (a) ក្នុងរយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទចូលជាធរមានរបស់ច្បាប់ ក្រសួងសុខភាពសាធារណៈរដ្ឋ ត្រូវបានអនុញ្ញាតហើយត្រូវអនុម័តបទបញ្ជាទាំងឡាយដែលអនុវត្តផ្នែកទី 1226.8 និង 1226.9 នៃក្រមស្តីពីសុខភាព និងសុវត្ថិភាពដើម្បីពង្រីកបន្ថែមគោលបំណងនៃច្បាប់នេះ។

(b) ប្រសិនបើក្រសួងមិនអាចអនុម័តបទបញ្ជាសម្រេចតាមការតម្រូវក្នុងរយៈពេលមួយឆ្នាំក្រោយកាលបរិច្ឆេទរបស់ច្បាប់នេះទេនោះការអនុម័តបទបញ្ជាអនុវត្តគ្រាមានអាសន្ន ត្រូវចាត់ទុកថាជាការបន្ទាន់ និងចាំបាច់សម្រាប់ការរក្សាសន្តិភាព សុខភាព សុវត្ថិភាព ឬសុខុមាលភាពទូទៅភ្លាមៗ ដែលក្នុងករណីនេះ ក្រសួងត្រូវអនុម័តបទបញ្ជាអនុវត្តគ្រាមានអាសន្នដំបូងមិនលើសពីមួយឆ្នាំ ក្រោយកាលបរិច្ឆេទចូលជាធរមានរបស់ច្បាប់នេះឬភ្លាមៗក្រោយពេលអាចអនុវត្តបាន។ ប្រសិនបើបទបញ្ជាគ្រាមានអាសន្ននេះត្រូវបានអនុម័ត ក្រសួងត្រូវអនុម័តបទបញ្ជាសម្រេចតាមការតម្រូវនៅត្រឹមពេលដែលបទបញ្ជាគ្រាមានអាសន្នផុតកំណត់។

ផ្នែកទី 10. អនុលោមតាមផ្នែករង (c) នៃផ្នែកទី 10 នៃមាត្រា II នៃរដ្ឋធម្មនុញ្ញរដ្ឋ California ច្បាប់នេះ អាចត្រូវបានធ្វើវិសោធនកម្មដោយវិធានការបន្ទាប់ដែលដាក់ស្នើសម្រាប់ការបោះឆ្នោតរបស់ប្រជាពលរដ្ឋនៅពេលបោះឆ្នោតទូទាំងរដ្ឋ ឬដោយលក្ខន្តិកៈដែលត្រូវបានអនុម័តដោយសុពលភាពដោយរដ្ឋសភា និងចុះហត្ថលេខាដោយអភិបាល ប៉ុន្តែសម្រាប់តែពង្រីកបន្ថែមគោលបំណងនៃច្បាប់នេះប៉ុណ្ណោះ។

ផ្នែកទី 11. (a) ករណីដែលវិធានការគំនិតផ្តួចផ្តើមនេះនិងវិធានការ ឬបណ្តាវិធានការគំនិតផ្តួចផ្តើមទាំងឡាយដែលពាក់ព័ន្ធនឹងការលាងឈាម (រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះបទបញ្ជានៃគ្លីនិកលាងឈាមរ៉ាំរ៉ៃ ឬការព្យាបាលនិងថែទាំអ្នកជំងឺលាងឈាម) ត្រូវមាននៅលើសន្លឹកឆ្នោតទូទាំងរដ្ឋដូចគ្នានោះ វិធានការ ឬបណ្តាវិធានការគំនិតផ្តួចផ្តើមផ្សេងទៀត ត្រូវបានចាត់ទុកថាមានទំនាស់ជាមួយនឹងវិធានការនេះ។ ក្នុងករណីដែលវិធានការផ្តួចផ្តើមនេះទទួលបានចំនួនខ្ពស់បំផុតនៃការបោះឆ្នោតគាំទ្រ ប្រការនៃវិធានការនេះត្រូវមានជ័យជំនះទាំងស្រុង ហើយប្រការនៃវិធានការផ្តួចផ្តើមផ្សេងទៀតនឹងត្រូវចាត់ទុកជាមោឃៈ។

(b) ប្រសិនបើការផ្តួចផ្តើមនេះត្រូវបានអនុម័តដោយអ្នកបោះឆ្នោត ប៉ុន្តែត្រូវជំនួស ទាំងមូលឬដោយផ្នែកដោយសារវិធានការសន្លឹកឆ្នោតដែលមានទំនាស់ផ្សេងទៀត ដែលបានអនុម័តដោយអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតដដែល ហើយវិធានការដែលមានទំនាស់នោះក្រោយមកត្រូវគេរកឃើញថាមិនត្រឹមត្រូវ វិធានការ នេះត្រូវតែស្វ័យប្រតិបត្តិ ហើយនិងមានអនុភាពនិងឥទ្ធិពលពេញលេញ។

ផ្នែក 12. ប្រការនៃក្រមច្បាប់នេះគឺអាចអនុវត្តដោយឯករាជ្យពីគ្នា។ ប្រសិនបើប្រការណាមួយនៃក្រមច្បាប់នេះ ឬការអនុវត្តនៃប្រការនេះត្រូវបានរកឃើញថាមិនត្រឹមត្រូវ ភាពជាមោឃៈនោះ មិនប៉ះពាល់ដល់ចំណែកដែលនៅសល់នៃក្រមច្បាប់នេះ ឬការអនុវត្តដែលអាចចូលជាធរមានដោយមិនប៉ះពាល់ដោយប្រការ ឬការអនុវត្តដែលទុកជាមោឃៈនោះឡើយ។ ប្រជាពលរដ្ឋ California តទៅនេះសូមប្រកាសថាពួកគេធ្វើការអនុម័តក្រមច្បាប់នេះ ហើយគ្រប់ភាគ ផ្នែក ផ្នែករង កថាខណ្ឌ អនុប្រយោគ ប្រយោគ ឃ្លា ពាក្យ និងការអនុវត្ត

23

ណាមួយ ដែលមិនត្រូវបានប្រកាសថាអសុពលភាព ឬផ្ទុយពីរដ្ឋធម្មនុញ្ញ ដោយមិនគិតថាតើភាគនៃក្រមច្បាប់នេះ ឬការអនុវត្តវា នឹងត្រូវប្រកាសនៅពេលក្រោយថាជាមោឃៈ។

សំណើប្រជាមតិ 24

វិធានការផ្តួចផ្តើមនេះបានដាក់ជូនប្រជាជនដោយអនុលោម ទៅតាមប្រការនៃផ្នែក 8 មាត្រា II នៃធម្មនុញ្ញរដ្ឋ California។

វិធានការផ្តួចផ្តើមនេះធ្វើវិសោធនកម្មនិងបន្ថែមផ្នែកនានាទៅលើ ក្រមរដ្ឋប្បវេណី ហេតុនេះ ប្រការដែលបានស្នើឲ្យលុបចោលត្រូវបានបោះពុម្ពជា ~~អក្សរឆូត ចោល~~ ហើយប្រការថ្មីដែលត្រូវស្នើឲ្យដាក់បញ្ចូលត្រូវបានបោះពុម្ពជា *ប្រភេទអក្សរទ្រេត* ដើម្បីបង្ហាញថាវាថ្មី។

សំណើច្បាប់

ក្រមច្បាប់សិទ្ធិឯកជនភាពរដ្ឋ California ឆ្នាំ 2020

ផ្នែកក 0.5 ៖ តារាងមាតិកា

ផ្នែក 1 ៖ ចំណងជើង ៖ ក្រមច្បាប់សិទ្ធិឯកជនភាពរដ្ឋ California ឆ្នាំ 2020

ផ្នែក 2 ៖ សេចក្តីសម្រេចរបស់តុលាការ និង ការប្រកាស

ភាគ 3 ៖ គោលបំណង និង ចេតនា

A. សិទ្ធិអ្នកប្រើប្រាស់

B. ទំនួលខុសត្រូវរបស់អាជីវកម្ម

C. ការអនុវត្តនៃច្បាប់

ផ្នែក 4 ៖ កាតព្វកិច្ចទូទៅនៃអាជីវកម្មដែលប្រមូលព័ត៌មានផ្ទាល់ខ្លួន

ផ្នែក 5 ៖ សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការលុបចោលព័ត៌មានផ្ទាល់ខ្លួន

ផ្នែក 6 ៖ សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការកែប្រែព័ត៌មានផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវ

ផ្នែក 7 ៖ សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការដឹងថាព័ត៌មានអ្វីខ្លះដែលកំពុងប្រមូល។ សិទ្ធិចូលមើលព័ត៌មានផ្ទាល់ខ្លួន

ផ្នែក 8 ៖ សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការដឹងថាព័ត៌មានផ្ទាល់ខ្លួនអ្វីខ្លះត្រូវបានលក់ ឬចែកចាយ និងទៅកាន់នរណា

ផ្នែក 9 ៖ សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការជ្រើសរើសមិនចូលរួមការលក់ ឬ ចែកចាយព័ត៌មានផ្ទាល់ខ្លួន

ផ្នែក 10 ៖ សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការកំណត់កម្រិតនៃការប្រើប្រាស់ និងការ បង្ហាញអោយឃើញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់

ផ្នែក 11 ៖ សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការមិនមានការសងសឹកបន្ទាប់ពី ការជ្រើសរើសចាកចេញ ឬប្រើប្រាស់សិទ្ធិផ្សេងទៀត

ផ្នែក 12 ៖ លក្ខខណ្ឌតម្រូវអំពីការជូនដំណឹង ការបង្ហាញអោយឃើញ ការកែតម្រូវ និងការលុប

ផ្នែក 13 ៖ វិធីសាស្ត្រនៃការកំណត់កម្រិតលើការលក់ ការចែកចាយ និងការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន និងការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់

ផ្នែក 14 ៖ និយមន័យ

ផ្នែក 15 ៖ ការលើកលែង

ផ្នែក 16 ៖ ការរំលោភបំពានសន្តិសុខព័ត៌មានផ្ទាល់ខ្លួន

ផ្នែក 17 ៖ ការអនុវត្តផ្នែករដ្ឋបាល

ផ្នែក 18 ៖ មូលនិធិឯកជនភាពអ្នកប្រើប្រាស់

ផ្នែក 19 ៖ ប្រការដែលមានទំនាស់

ផ្នែក 20 ៖ សិទ្ធិទិញមុនគេ

ផ្នែក 21 ៖ បទបញ្ជា

ផ្នែក 22 ៖ ការប្រឆាំងនឹងការគេចវេស

ផ្នែក 23 ៖ ការបោះបង់សិទ្ធិ

ផ្នែក 24 ៖ ការបង្កើតទីភ្នាក់ងារការពារឯកជនភាពរដ្ឋ California

ផ្នែក 25 ៖ វិសោធនកម្ម

ផ្នែក 26 ៖ ឯករាជ្យភាពនៃប្រការ

ផ្នែក 27 ៖ គំនិតផ្តួចផ្តើមដែលមានទំនាស់

ផ្នែក 28 ៖ សិទ្ធិប្តឹង

ផ្នែក 29 ៖ ការបកស្រាយ

ផ្នែក 30 ៖ សេចក្តីព្រមាន

ផ្នែក 31 ៖ កាលបរិច្ឆេទចូលជាធរមាន និងប្រតិបត្តិ

ផ្នែក 1. ចំណងជើង

វិធានការនេះត្រូវគេស្គាល់និងអាចត្រូវបានហៅថាជា "ក្រមច្បាប់ស្តីពីសិទ្ធិឯកជនភាពរដ្ឋ California ឆ្នាំ 2020 (California Privacy Rights Act of 2020)"។

ផ្នែក 2. សេចក្តីសម្រេចរបស់តុលាការ និងការប្រកាស។

ប្រជាពលរដ្ឋ California រកឃើញ និងប្រកាសដូចខាងក្រោម៖

A. កាលពីឆ្នាំ 1972 អ្នកបោះឆ្នោតនៃរដ្ឋ California បានធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញរដ្ឋ California ដើម្បីដាក់បញ្ចូលសិទ្ធិឯកជនភាពក្នុងចំណោមសិទ្ធិ "មិនអាចដកបាន" របស់មនុស្សគ្រប់រូប។ អ្នកបោះឆ្នោតបានធ្វើសកម្មភាពក្នុងការឆ្លើយតបទៅការរំលោភបំពានកាន់តែច្រើនឡើងលើសេរីភាពផ្ទាល់ខ្លួននិងសន្តិសុខបង្ករដោយការប្រមូលនិងការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនកាន់តែកើនឡើងនៅក្នុងសង្គមបច្ចុប្បន្ន ។ វិសោធនកម្មបានបង្កើតសិទ្ធិធម្មនុញ្ញស្របច្បាប់និងដែលអាចអនុវត្តបាន ចំពោះឯកជនភាពសម្រាប់ ពលរដ្ឋ California គ្រប់រូប ។ មូលដ្ឋានគ្រឹះចំពោះសិទ្ធិឯកជនភាពនេះគឺជាសមត្ថភាពរបស់បុគ្គលក្នុងការគ្រប់គ្រងការប្រើប្រាស់រួមទាំងការលក់ព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ។

B. ចាប់តាំងពីអ្នកបោះឆ្នោតនៃរដ្ឋ California បានអនុម័តលើសិទ្ធិធម្មនុញ្ញស្តីពី ឯកជនភាពមកអង្គនីតិបញ្ញត្តិនៃរដ្ឋ California បានអនុម័តយន្តការជាក់លាក់ដើម្បី ការពារឯកជនភាពរបស់ពលរដ្ឋ California រួមទាំងក្រមច្បាប់ការពារឯកជនភាពលើបណ្តាញអ៊ីនធើណែត (Online Privacy Protection Act) សិទ្ធិឯកជនភាពសម្រាប់អនីតិជនរដ្ឋ California ក្នុងក្រមច្បាប់ពិភពឌីជីថល (Privacy Rights for California Minors in the Digital World Act) និងច្បាប់បញ្ចេញពន្លឺ (Shine the Light) ប៉ុន្តែអ្នកប្រើប្រាស់មិនបាន មានសិទ្ធិស្វែងយល់ថាព័ត៌មានផ្ទាល់ខ្លួនអ្វីខ្លះដែលអាជីវកម្ម បានប្រមូលអំពីពួកគេ ហើយអាជីវកម្មប្រើព័ត៌មាននោះតាមរបៀបណា ឬណែនាំអាជីវកម្មមិនឲ្យលក់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ឡើយ។

C. នោះបានផ្លាស់ប្តូរហើយកាលពីឆ្នាំ 2018 នៅពេលដែលអ្នកបោះឆ្នោតជាង 629,000 នាក់នៅរដ្ឋ California បានដាក់ញត្តិដើម្បីផ្តល់លក្ខណៈសម្បត្តិសម្រាប់ក្រមច្បាប់ឯកជនភាពអ្នកប្រើប្រាស់រដ្ឋ California ឆ្នាំ 2018 (California Consumer Privacy Act of 2018) ដើម្បីដាក់លើសន្លឹកឆ្នោត។ ក្នុងការឆ្លើយតបទៅនឹងការផ្តល់លក្ខណៈសម្បត្តិនៃវិធានការនេះ អង្គនីតិបញ្ញត្តិបាន អនុម័តក្រមច្បាប់ឯកជនភាពអ្នកប្រើប្រាស់រដ្ឋ California ឆ្នាំ 2018 (CCPA) ទៅជាច្បាប់។

23

24

CCPA ផ្តល់អ្នកប្រើប្រាស់ក្នុងរដ្ឋ California នូវសិទ្ធិក្នុងការស្វែងយល់អំពីព័ត៌មានអ្វីដែលអាជីវកម្មបានប្រមូលយកអំពីពួកគេ លុបព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ បញ្ឈប់ អាជីវកម្មពីការលក់ព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេរួមទាំងការប្រើប្រាស់ ព័ត៌មានផ្ទាល់ខ្លួនដើម្បីកំណត់គោលដៅលើពួកគេសម្រាប់ការផ្សាយពាណិជ្ជកម្ម បន្ទាប់ពីពួកគេរកមើលលើអ៊ីនធឺណិតពីគេហទំព័រមួយទៅគេហទំព័រមួយទៀត និងឲ្យ អាជីវកម្មទទួលខុសត្រូវប្រសិនបើពួកគេមិនចាត់វិធានការសមហេតុផលដើម្បីការពារព័ត៌មានផ្ទាល់ខ្លួន។

D. ទោះបីជាមុនពេលដែល CCPA បានចូលជាធរមានអង្គនីតិបញ្ញត្តិបានពិចារណាលើសេចក្តីព្រាងច្បាប់ជាច្រើនកាលពីឆ្នាំ 2019 ដើម្បីធ្វើវិសោធនកម្ម ច្បាប់នោះ ដែលសេចក្តីព្រាងច្បាប់ខ្លះនឹងធ្វើឲ្យច្បាប់ចុះខ្សោយយ៉ាងខ្លាំង។ ប្រសិនបើអ្នកបោះឆ្នោតរដ្ឋ California មិនចាត់វិធានការទេសិទ្ធិដែលត្រូវបានខំតស៊ូប្រយុទ្ធយ៉ាងលំបាកដែលអ្នកប្រើប្រាស់ បានទទួលជ័យជំនះអាចនឹងត្រូវបានធ្វើឲ្យខូចដោយច្បាប់នៅពេលអនាគត។

E. ជាជាងការពង្រាវសិទ្ធិឯកជនភាព រដ្ឋ California គួរពង្រឹងជាបន្តទៅទៀត។ អាជីវកម្មជាច្រើនប្រមូលនិងប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ពេលខ្លះ ដោយអ្នកប្រើប្រាស់មិនដឹងខ្លួនថាអាជីវកម្មនោះប្រើប្រាស់អ្វី រក្សាទុកអ្វីខ្លះនៃព័ត៌មាន ផ្ទាល់ខ្លួនរបស់ពួកគេ។ ក្នុងការអនុវត្តជាក់ស្តែង អ្នកប្រើប្រាស់ជារឿយៗចូលទៅក្នុងទម្រង់រៀបចំកិច្ចសន្យាមួយខណៈដែលពួកគេមិនបង់ប្រាក់សម្រាប់ទំនិញ ឬសេវាកម្ម ពួកគេដោះដូរលទ្ធភាពចូលប្រើទំនិញ ឬសេវាកម្មនោះជាមួយនឹងការទទួលបានចំណាប់អារម្មណ៍ ឬព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ។ ដោយសារតែតម្លៃនៃព័ត៌មានផ្ទាល់ខ្លួនដែលពួកគេដោះដូរសម្រាប់ទំនិញ ឬសេវាកម្ម តែងតែគ្មានតម្លាភាព អាស្រ័យលើការអនុវត្តរបស់អាជីវកម្មនោះ អ្នកប្រើប្រាស់ជាញឹកញាប់ មិនមានវិធីល្អដើម្បីឲ្យតម្លៃលើប្រតិបត្តិការទេ។ លើសពីនេះ លក្ខខណ្ឌនៃកិច្ចសន្យា ឬគោលការណ៍ដែលបានសរសេរនោះមានភាពស្មុគស្មាញនិងមិនច្បាស់លាស់ ហើយជាលទ្ធផលអ្នកប្រើប្រាស់ភាគច្រើនមិនដែលមានពេលអាន ឬយល់វាទេ។

F. ភាពមិនឆ្លុះគ្នានៃព័ត៌មាននេះធ្វើឲ្យអ្នកប្រើប្រាស់ពិបាកយល់ ថាពួកគេកំពុងដោះដូរ អ្វីនិងមិនអាចចរចាដោយមានប្រសិទ្ធភាពជាមួយអាជីវកម្ម។ មិនដូចជាក្នុងតំបន់សេដ្ឋកិច្ចផ្សេងទៀតដែលអ្នកប្រើប្រាស់អាចទិញដោយធ្វើការប្រៀបធៀប ឬអាចយល់បានភ្លាម ប្រសិនបើទំនិញ ឬសេវាកម្មគឺថ្លៃ ឬមានតម្លៃសមរម្យទេ អ្នកប្រើប្រាស់ពិបាកដឹងថាតើព័ត៌មានអ្នកប្រើប្រាស់របស់ពួកគេមានតម្លៃប៉ុន្មានចំពោះអាជីវកម្មមួយ នៅពេលដែលការអនុវត្តនៃការប្រើប្រាស់ទិន្នន័យគឺ ខុសគ្នាយ៉ាងខ្លាំងពីអាជីវកម្មមួយទៅអាជីវកម្មមួយ។

G. អាស្រ័យហេតុនេះ រ ដ្ឋមានចំណាប់អារម្មណ៍ក្នុងការកំណត់អណ្ណត្តិច្បាប់ដែលនឹងអនុញ្ញាតឲ្យអ្នកប្រើប្រាស់យល់កាន់តែពេញលេញអំពីរបៀបដែលព័ត៌មានរបស់ពួកគេត្រូវបានប្រើប្រាស់ និងក្នុងគោលបំណងអ្វី។ ដូចគ្នានឹងវិធីដែលស្លាកសញ្ញាគ្រឿងផ្សំនៅលើម្ហូបអាហារជួយអ្នកប្រើប្រាស់ឲ្យទិញកាន់តែមានប្រសិទ្ធភាព ការបង្ហាញអោយឃើញជុំវិញការគ្រប់គ្រងទិន្នន័យនឹងជួយឲ្យ អ្នកប្រើប្រាស់ក្លាយទៅជាគូភាគីកាន់តែមានការជ្រួតជ្រាបលើសេដ្ឋកិច្ចទិន្នន័យ និងលើកកម្ពស់ការប្រកួតប្រជែង។ បន្ថែមពីនេះ ប្រសិនបើអ្នកប្រើប្រាស់អាចប្រាប់ទៅអាជីវកម្ម មិនឲ្យលក់ទិន្នន័យអ្នក ប្រើប្រាស់ នោះអ្នកប្រើប្រាស់នឹងមិនចាំបាច់ត្រូវស្វែងរកគោលការណ៍ឯកជនភាពដើម្បីមើលថាតើអាជីវកម្មលក់ទិន្នន័យនោះដែរឬទេ ដែលការចំណេញពេលវេលានេះជាសរុបគឺមានតម្លៃស្មើនឹងចំនួនប្រាក់យ៉ាងច្រើន។

H. អ្នកប្រើប្រាស់ត្រូវការច្បាប់ដែលរឹងមាំដើម្បីធ្វើឲ្យពួកគេឈរនៅលើទីតាំងស្មើគ្នាជាងមុន នៅពេលចរចាជាមួយអាជីវកម្មដើម្បីការពារសិទ្ធិរបស់ពួកគេ។ អ្នកប្រើប្រាស់គួរតែមានសិទ្ធិទទួលបានការពន្យល់ច្បាស់លាស់អំពីការប្រើប្រាស់ ទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេនិងអាចគ្រប់គ្រង កែតម្រូវ ឬ លុបវាចោលបាន រួមទាំង ការអនុញ្ញាតឲ្យអ្នកប្រើប្រាស់អាចកំណត់ព្រំដែននៃការប្រើប្រាស់របស់អាជីវកម្មលើព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់ពួកគេដើម្បីការពារប្រឆាំងនឹងការលួចអត្តសញ្ញាណ ជ្រើសរើសការមិនចូលរួមការលក់និងការចែកចាយ ព័ត៌មានផ្ទាល់ខ្លួន របស់ពួកគេ និងអាចស្នើសុំឲ្យអាជីវកម្មកែតម្រូវ ព័ត៌មានមិនត្រឹមត្រូវអំពីពួកគេ។

I. រដ្ឋ California គឺជាអ្នកនាំមុខគេក្នុងពិភពលោកលើបច្ចេកវិទ្យាថ្មីៗ ជាច្រើនដែលធ្វើឲ្យមានការផ្លាស់ប្តូរមុខមាត់សង្គមរបស់យើង។ ពិភពលោកបច្ចុប្បន្នមិនអាចនឹងស្រមៃដល់ទេ ប្រសិនបើមិនមានអ៊ីនធឺណិតដែលជា មួយក្នុងចំណោមការបង្កើតថ្មីដ៏អស្ចារ្យបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ រួមទាំងសេវាកម្ម និងអាជីវកម្មថ្មីៗដែលបានលូតលាស់ឡើងដោយសារអ៊ីនធឺណិត ដែលការបង្កើតថ្មីជាច្រើនទាំងនោះគឺមកពីរដ្ឋ California ។ គំរូអាជីវកម្មជោគជ័យបំផុតមួយសម្រាប់អ៊ីនធឺណិតគឺជាសេវាកម្មដែលពឹងផ្អែកលើការ ផ្សាយពាណិជ្ជកម្មដើម្បីរកប្រាក់ដែលខុសគ្នាពីការគិតកម្រៃសេវាពីអ្នកប្រើប្រាស់។ សេវាកម្មគាំទ្រដោយការផ្សាយពាណិជ្ជកម្មមានច្រើនជំនាន់មកហើយ និងអាចជាគំរូ ដ៏អស្ចារ្យសម្រាប់អ្នកប្រើប្រាស់និងអាជីវកម្មដូចគ្នា។ ទោះយ៉ាងណាអាជីវកម្មផ្សាយពាណិជ្ជកម្មខ្លះបច្ចុប្បន្នប្រើប្រាស់បច្ចេកវិទ្យា និងឧបករណ៍ដែលមិនមានតម្លាភាពចំពោះអ្នកប្រើប្រាស់ក្នុងបំណងប្រមូលនិងជួញដូរព័ត៌មានយ៉ាងច្រើន តាមដានពួកគេនៅលើអ៊ីនធឺណិត និងបង្កើតទម្រង់ព័ត៌មានលម្អិតទៅតាមចំណាប់អារម្មណ៍របស់បុគ្គលម្នាក់ៗ។ ក្រុមហ៊ុនមួយចំនួនដែលមិនគិតថ្លៃពីអ្នកប្រើប្រាស់ ឧបត្ថម្ភសេវាកម្មទាំងនេះតាមរយៈការរកប្រាក់ពីព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។ អ្នកប្រើប្រាស់គួរមានព័ត៌មាននិងឧបករណ៍ចាំបាច់ដើម្បីកំណត់ព្រំដែននៃការប្រើប្រាស់ព័ត៌មានរបស់ពួកគេចំពោះការផ្សាយពាណិជ្ជកម្មដែលគោរពដល់ឯកជនភាព ដែលមិនលុកលុយខ្លាំង ហើយព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេគឺមិនត្រូវបាន លក់ ឬចែកចាយជាមួយអាជីវកម្មរាប់រយដែលពួកគេមិនដែលបានឮ ប្រសិនបើពួកគេ ជ្រើសរើសធ្វើដូច្នោះ។ ក្នុងអវត្តមាននៃឧបករណ៍ទាំងនេះ វាស្ទើរតែមិនអាចទៅរួចនោះទេ សម្រាប់អ្នកប្រើប្រាស់ដើម្បីយល់ច្បាស់អំពីកិច្ចសន្យាទាំងនេះ ដែលពួកគេនឹងចូលទៅកាន់ នៅពេល ដែលពួកគេធ្វើអន្តរកម្មជាមួយអាជីវកម្មផ្សេងៗ។

J. កុមារងាយរងគ្រោះយ៉ាងខ្លាំងពីទស្សនៈការចរចាពាក់ព័ន្ធនឹងសិទ្ធិឯកជនភាពរបស់ពួកគេ។ ឪពុកម្តាយគួរតែអាចគ្រប់គ្រងព័ត៌មានអ្វីដែលត្រូវបានប្រមូលនិងលក់ ឬចែកចាយអំពីកូនតូចៗរបស់ពួកគេ និងគួរមានសិទ្ធិដើម្បីទាមទារអោយក្រុមហ៊ុននោះធ្វើការលុបព័ត៌មានដែលបានប្រមូលអំពីកូនៗរបស់ពួកគេ។

K. អាជីវកម្មក៏គួរមានការទទួលខុសត្រូវដោយផ្ទាល់ចំពោះអ្នកប្រើប្រាស់ផងដែរសម្រាប់ការរំលោភបំពានសុវត្ថិភាពទិន្នន័យ និងជូនដំណឹងដល់អ្នកប្រើប្រាស់នៅពេលដែលព័ត៌មានសម្ងាត់បំផុតរបស់ពួកគេត្រូវបានបែកធ្លាយ ។

L. អ្នកឃ្លាំមើលឯករាជ្យដែលមានបេសកកម្មដើម្បីការពារ ឯកជនភាពអ្នកប្រើប្រាស់គួរធានាថាអាជីវកម្មនិងអ្នកប្រើប្រាស់ គឺបានជ្រួតជ្រាបយ៉ាងច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ ហើយគួរអនុវត្តច្បាប់យ៉ាងតឹងរ៉ឹងប្រឆាំងនឹងអាជីវកម្មដែលរំលោភបំពានដល់សិទ្ធិឯកជនភាពរបស់អ្នកប្រើប្រាស់។

ផ្នែក 3. គោលបំណងនិងចេតនា។

ក្នុងការអនុម័តច្បាប់នេះ វាគឺជាគោលបំណងនិងចេតនារបស់ប្រជាជន California ដើម្បីបន្តការពារសិទ្ធិអ្នកប្រើប្រាស់ រួមមានសិទ្ធិឯកជនភាព

ដែលចែងក្នុងរដ្ឋធម្មនុញ្ញ។ ការអនុវត្តក្រមច្បាប់នេះត្រូវបានណែនាំដោយគោលការណ៍ដូចខាងក្រោម៖

A. សិទ្ធិអ្នកប្រើប្រាស់

1. អ្នកប្រើប្រាស់គួរតែដឹងថានរណាដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ និងកូនៗរបស់ពួកគេ របៀបដែលព័ត៌មាននោះត្រូវបានប្រើប្រាស់ ហើយព័ត៌មាននោះ ត្រូវបានបង្ហាញដល់នរណាដើម្បីឲ្យពួកគេមានព័ត៌មានចាំបាច់ដើម្បីអនុវត្ត ការគ្រប់គ្រងដ៏សំខាន់លើការប្រើប្រាស់របស់អាជីវកម្ម ទាំងនោះចំពោះព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ និងកូនៗរបស់ពួកគេ។

2. អ្នកប្រើប្រាស់គួរតែអាចគ្រប់គ្រងការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ រួមមានការដាក់កម្រិតលើការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ ការប្រើប្រាស់ ឬការបង្ហាញព័ត៌មានដោយគ្មានការអនុញ្ញាតដែលបង្កើតហានិភ័យគ្រោះថ្នាក់កម្រិតខ្ពស់ដល់អ្នកប្រើប្រាស់ ហើយអ្នកប្រើប្រាស់គួរតែមានជម្រើសដ៏សំខាន់ លើរបៀបដែលព័ត៌មានត្រូវបានប្រមូល ប្រើប្រាស់ និងបង្ហាញ។

3. អ្នកប្រើប្រាស់គួរតែមានសិទ្ធិប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ហើយគួរតែ អាចកែ លុប និងយកព័ត៌មាននោះមកជាមួយពួកគេពីអាជីវកម្មមួយទៅអាជីវកម្មមួយទៀត។

4. អ្នកប្រើប្រាស់ ឬភ្នាក់ងារដែលមានសិទ្ធិរបស់ពួកគេគួរតែអាចប្រើប្រាស់ជម្រើសទាំងនេះតាមរយៈឧបករណ៍ងាយប្រើប្រាស់ដោយខ្លួនឯង។

5. អ្នកប្រើប្រាស់គួរតែអាចអនុវត្តសិទ្ធិទាំងនេះបានដោយមិនមានការដាក់ពិន័យពីការធ្វើដូច្នោះឡើយ។

6. អ្នកប្រើប្រាស់គួរតែអាចធ្វើឲ្យអាជីវកម្មទទួលខុសត្រូវចំពោះការមិនអនុវត្តការ ប្រុងប្រយ័ត្នដែលសមហេតុផលដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនសម្ងាត់បំផុតរបស់ពួកគេពីអ្នកលួចទិន្នន័យ និងការបំពានសន្តិសុខ។

7. អ្នកប្រើប្រាស់គួរតែទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់របស់អាជីវកម្មចំពោះព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ។

8. គួរតែមានការការពារលើផលប្រយោជន៍ឯកជនភាពរបស់និយោជិក និងអ្នកម៉ៅការឯករាជ្យដោយពិចារណាទៅលើភាពខុសៗគ្នានៅក្នុងទំនាក់ទំនងរវាងនិយោជិក ឬអ្នកម៉ៅការឯករាជ្យជាមួយនិងអាជីវកម្ម ធៀបនឹងទំនាក់ទំនងរវាងអ្នកប្រើប្រាស់និងអាជីវកម្ម។ លើសពីនេះ ច្បាប់នេះមិនមានចេតនាក្នុងការរារាំងដល់សិទ្ធិក្នុងការរៀបចំនិងការតវ៉ា ជាសមូហភាពក្រោមក្រមច្បាប់ទំនាក់ទំនងការងារជាតិឡើយ (National Labor Relations Act)។ វាគឺជាគោលបំណងនិងចេតនានៃក្រមច្បាប់នេះដើម្បីបន្តការលើកលែងនៅក្នុងចំណងជើងនេះសម្រាប់និយោជិក និងអាជីវកម្ម ចំពោះទំនាក់ទំនងអាជីវកម្មរហូតដល់ថ្ងៃទី 1 ខែមករា ឆ្នាំ 2023 ។

B. ទំនួលខុសត្រូវរបស់អាជីវកម្ម

1. អាជីវកម្មគួរតែជូនដំណឹងដល់អ្នកប្រើប្រាស់យ៉ាងជាក់លាក់ និងច្បាស់លាស់អំពីរបៀបដែលអាជីវកម្មប្រមូល និងប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួននិងរបៀបដែលអាជីវកម្ម ប្រើប្រាស់សិទ្ធិ និងជម្រើសរបស់ពួកគេ។

2. អាជីវកម្មគួរប្រមូលតែព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ សម្រាប់តែគោលបំណងបង្ហាញដែលជាក់លាក់ ជាក់ស្តែង និងស្របច្បាប់ប៉ុណ្ណោះ ហើយមិនគួរ បន្តប្រមូល ប្រើប្រាស់ ឬបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ សម្រាប់មូលហេតុដែលផ្ទុយនឹងគោលបំណងទាំងនោះឡើយ។

3. អាជីវកម្មគួរតែប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ តែក្នុងករណីដែលព័ត៌មាននោះមានភាពពាក់ព័ន្ធប៉ុណ្ណោះ ហើយដាក់កម្រិតចំពោះអ្វីដែលចាំបាច់ដែលទាក់ទងនឹងគោលបំណងដែលព័ត៌មាននោះ ត្រូវបានប្រមូល ប្រើប្រាស់ និង ចែកចាយ។

4. អាជីវកម្មគួរតែផ្តល់មធ្យោបាយចូលប្រើប្រាស់យ៉ាងងាយស្រួលដល់អ្នកប្រើប្រាស់ ឬភ្នាក់ងារដែលទទួលបានការអនុញ្ញាតពីពួកគេដើម្បីអនុញ្ញាតឲ្យអ្នកប្រើប្រាស់ និងកូនៗរបស់ពួកគេអាចលុប ឬកែព័ត៌មាននោះ ជ្រើសរើសមិនចូលរួមការលក់ និងការចែកចាយព័ត៌មាននោះទូទាំងប្រព័ន្ធអាជីវកម្ម សេវាកម្ម អាជីវកម្ម និងឧបករណ៍នានា និងដាក់កម្រិតលើការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន សម្ងាត់របស់ពួកគេ។

5. អាជីវកម្មមិនគួរដាក់ពិន័យដល់អ្នកប្រើប្រាស់ចំពោះការអនុវត្តសិទ្ធិទាំងនេះឡើយ។

6. អាជីវកម្មគួរតែអនុវត្តការប្រុងប្រយ័ត្នដែលសមហេតុផល ដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ពីការបំពានសន្តិសុខ។

7. អាជីវកម្មគួរតែអោយទទួលខុសត្រូវ នៅពេលពួកគេបំពានសិទ្ធិឯកជនភាពរបស់អ្នកប្រើប្រាស់ ហើយការដាក់ពិន័យគួរតែធ្ងន់ធ្ងរជាងនៅពេលដែលការបំពាននោះប៉ះពាល់ដល់កុមារ។

C. ការអនុវត្តនៃច្បាប់

1. សិទ្ធិរបស់អ្នកប្រើប្រាស់ និងការទទួលខុសត្រូវរបស់ អាជីវកម្មគួរតែត្រូវបានអនុវត្តជាមួយនឹងគោលដៅពង្រឹងឯកជនភាពអ្នកប្រើប្រាស់ ខណៈដែលផ្តល់ការយកចិត្តទុកដាក់ចំពោះផលប៉ះពាល់លើអាជីវកម្មនិងការច្នៃប្រឌិត។ ឯកជនភាពអ្នកប្រើប្រាស់និងការបង្កើតផលិតផលនិងសេវាកម្មថ្មីដែលមានគុណប្រយោជន៍មិនចាំបាច់ជាគោលដៅដែលមិនស៊ីគ្នានោះទេ។ សិទ្ធិឯកជនភាព អ្នកប្រើប្រាស់ដែលរឹងមាំ បង្កើតបានជាការលើកទឹកចិត្តដើម្បីច្នៃប្រឌិត និងបង្កើតផលិតផលថ្មីដែលមានការការពារឯកជនភាព។

2. អាជីវកម្ម និងអ្នកប្រើប្រាស់គួរតែត្រូវបានផ្តល់នូវការណែនាំច្បាស់លាស់អំពីការទទួលខុសត្រូវ និងសិទ្ធិរបស់ពួកគេ។

3. ច្បាប់គួរដាក់អ្នកប្រើប្រាស់នៅក្នុងទីតាំងមួយដើម្បីចរចារ ដោយដឹងច្បាស់និង ដោយសេរីជាមួយអាជីវកម្មអំពីការប្រើប្រាស់របស់អាជីវកម្មនូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។

4. ច្បាប់គួរតែកែតម្រូវទៅតាមការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យា ជួយអ្នកប្រើប្រាស់អនុវត្តសិទ្ធិរបស់ពួកគេ និងជួយដល់អាជីវកម្មជាមួយនឹងការអនុលោមតាមគោលដៅបន្តនៃការពង្រឹងឯកជនភាពអ្នកប្រើប្រាស់។

5. ច្បាប់គួរអនុញ្ញាតឲ្យមានការគាំទ្រដល់ផលិតផល និងសេវាកម្មថ្មីៗ របស់អ្នកប្រើប្រាស់ និងបង្កើនប្រសិទ្ធិភាពនៃការអនុវត្តសម្រាប់អាជីវកម្ម ក្នុងករណីដែលការធ្វើវិសោធនកម្មមិនធ្វើឱ្យខូចខាត ឬចុះខ្សោយនូវ ឯកជនភាព របស់អ្នកប្រើប្រាស់។

6. ច្បាប់គួរតែត្រូវបានធ្វើវិសោធនកម្មប្រសិនបើចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់ខ្លួនក្នុងករណីដែលការធ្វើវិសោធនកម្ម មិនធ្វើឱ្យខូចខាត ឬចុះខ្សោយ ឯកជនភាពរបស់អ្នកប្រើប្រាស់ ខណៈពេលកំពុងផ្តល់ការយក ចិត្តទុកដាក់ដល់ផលប៉ះពាល់លើអាជីវកម្មនិងនវានុវត្តន៍។

7. អាជីវកម្មគួរមានការទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់ តាមរយៈការអនុវត្តកិច្ចការរដ្ឋបាលនិងស៊ីវិលយ៉ាងរឹងមាំ។

8. ដើម្បីលើកកម្ពស់ឯកជនភាពរបស់អ្នកប្រើប្រាស់របស់ខ្លួន និងអនុលោមភាពនៃអាជីវកម្ម ច្បាប់នេះគួរតែស្របគ្នាជាមួយច្បាប់ឯកជនភាពនៅក្នុងយុត្តាធិការផ្សេងទៀត។

ផ្នែក 4. ផ្នែក 1798.100 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្ម ដែលចែងថា៖

1798.100. កាតព្វកិច្ចទៅនៃអាជីវកម្មដែលប្រមូលព័ត៌មានផ្ទាល់ខ្លួន

~~1798.100. (a) អ្នកប្រើប្រាស់ត្រូវមានសិទ្ធិស្នើសុំអោយអាជីវកម្ម ដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ បង្ហាញអ្នកប្រើប្រាស់ នោះនូវប្រភេទនិង បំណែកជាក់លាក់ នៃព័ត៌មានផ្ទាល់ខ្លួនដែលអាជីវកម្ម នោះបានប្រមូល។~~

~~(b)~~ *(a) អាជីវកម្មដែលគ្រប់គ្រងការប្រមូល ព័ត៌មានផ្ទាល់ខ្លួនរបស់* អ្នកប្រើប្រាស់ត្រូវជូនដំណឹងដល់អ្នកប្រើប្រាស់ នៅពេល ឬនៅមុនពេល ~~ប្រមូល នូវចំណុច~~ *ដូចខាងក្រោម៖*

*(1) ប្រភេទ*នៃព័ត៌មានផ្ទាល់ខ្លួនដែលត្រូវប្រមូលនិងគោលបំណងដែល ប្រភេទនៃព័ត៌មានផ្ទាល់ខ្លួន*នោះត្រូវបានប្រមូល ឬប្រើប្រាស់*~~ត្រូវបាន ប្រើប្រាស់~~ *ហើយថាតើព័ត៌មាននោះត្រូវបានលក់ ឬចែកចាយដែរឬទេ។* អាជីវកម្មមិនត្រូវប្រមូលប្រភេទព័ត៌មានផ្ទាល់ខ្លួនបន្ថែមឬប្រើប្រាស់ ព័ត៌មានផ្ទាល់ ខ្លួនដែលបានប្រមូលសម្រាប់គោលបំណងបន្ថែម *ដែលផ្ទុយពីគោលបំណងដែលបានបង្ហាញដែលព័ត៌មានផ្ទាល់ខ្លួននោះត្រូវ*បានប្រមូលសម្រាប់ដោយមិនមានការជូនដំណឹងស្របជាមួយផ្នែកនេះ ដល់អ្នកប្រើប្រាស់។

(2) ប្រសិនបើអាជីវកម្មប្រមូលព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ ប្រភេទនៃ ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ដែលត្រូវប្រមូលនិងគោលបំណងដែលប្រភេទ នៃព័ត៌មានផ្ទាល់ខ្លួនសម្ងាត់នោះត្រូវបានប្រមូល ឬប្រើប្រាស់សម្រាប់ ហើយថាតើព័ត៌មាននោះត្រូវបានលក់ ឬចែកចាយដែរឬទេ។ អាជីវកម្ម មិនត្រូវប្រមូលប្រភេទព័ត៌មានផ្ទាល់ខ្លួនសម្ងាត់បន្ថែម ឬប្រើប្រាស់ ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ដែលបានប្រមូល សម្រាប់គោលបំណងបន្ថែម ដែលផ្ទុយពីគោលបំណងបានបង្ហាញ ដែលព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ត្រូវ បានប្រមូលសម្រាប់ដោយមិនមានការជូនដំណឹងស្របគ្នាជាមួយផ្នែកនេះ *ដល់អ្នកប្រើប្រាស់។*

(3) រយៈពេលដែលអាជីវកម្មមានបំណងរក្សាទុកនូវប្រភេទព័ត៌មាន ផ្ទាល់ខ្លួន រួមទាំង ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ ឬប្រសិនមិនអាចធ្វើបាន លក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់រយៈពេលនោះ ករណីដែលអាជីវកម្មមិនត្រូវរក្សាទុកព័ត៌មានផ្ទាល់ខ្លួន ឬព័ត៌មានផ្ទាល់ខ្លួន សម្ងាត់របស់អ្នកប្រើប្រាស់ សម្រាប់គោលបំណងដែលបានបង្ហាញនីមួយ ៗដែលព័ត៌មានផ្ទាល់ខ្លួនត្រូវបានប្រមូលរយៈ ពេលយូរជាងអ្វីដែលចាំបាច់ សមហេតុផលសម្រាប់គោលបំណងដែលបានបង្ហាញនោះ។

(b) អាជីវកម្មមួយដែលដើរតួជាភាគីទីបី គ្រប់គ្រងការប្រមូល ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ អាចបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រោមផ្នែករង (a) ដោយការផ្តល់ព័ត៌មានចាំបាច់ដែលលេចធ្លោនិង ច្បាស់លាស់នៅលើ ទំព័រដើមរបស់ គេហទំព័រអ៊ីនធឺណិតរបស់ខ្លួន។ លើសពីនេះ ប្រសិនបើអាជីវកម្មដែលដើរតួជាភាគីទីបីគ្រប់គ្រងការ ប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នៅលើបរិវេណរបស់ខ្លួន រួម ទាំងនៅក្នុងរថយន្តនោះ អាជីវកម្មត្រូវ នៅពេលឬមុនពេលប្រមូល ត្រូវ ជូនដំណឹងដល់អ្នកប្រើប្រាស់ អំពីព័ត៌មានផ្ទាល់ខ្លួនដែលត្រូវប្រមូលនិង គោលបំណងដែល ប្រភេទនៃព័ត៌មានផ្ទាល់ខ្លួនត្រូវបានប្រើប្រាស់សម្រាប់ និងថាតើព័ត៌មានផ្ទាល់ខ្លួនត្រូវបានលក់ក្នុងលក្ខណៈ ច្បាស់លាស់ និង សមហេតុផលនៅទីកន្លែងនោះឬទេ។

(c) ការប្រមូល ការប្រើប្រាស់ ការរក្សាទុក និង ការចែកចាយព័ត៌មាន ផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដោយអាជីវកម្មត្រូវតែជាការចាំបាច់យ៉ាង សមហេតុផលនិងទៅតាមសមាមាត្រដើម្បីសម្រេចគោលបំណងដែល ព័ត៌មាននោះត្រូវបានប្រមូលឬដំណើរការ ឬសម្រាប់គោលបំណងដែល បានបង្ហាញផ្សេងទៀត ដែលស្របគ្នាជាមួយនឹងបរិបទដែលព័ត៌មាន ផ្ទាល់ខ្លួនត្រូវបានប្រមូល និងមិនមែនដំណើរការបន្ថែម ក្នុងរបៀបដែល ផ្ទុយនឹងគោលបំណងទាំងនោះ។

(d) អាជីវកម្មដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ និងដែល លក់ព័ត៌មាន ផ្ទាល់ខ្លួនទៅ ឬចែកចាយវាជាមួយភាគីទីបី ឬដែលបង្ហាញ វាទៅអ្នកផ្តល់សេវា ឬអ្នកម៉ៅការសម្រាប់គោលបំណងអាជីវកម្ម ត្រូវចុះ កិច្ចព្រមព្រៀងជាមួយភាគីទីបី អ្នកផ្តល់សេវា ឬអ្នកម៉ៅការដែល៖

(1) បញ្ជាក់ថាព័ត៌មានផ្ទាល់ខ្លួនត្រូវបានលក់ ឬត្រូវបានបញ្ចេញឱ្យដឹង ដោយអាជីវកម្ម សម្រាប់តែគោលបំណងដែលបានកំណត់ និងបញ្ជាក់ ប៉ុណ្ណោះ ។

(2) តម្រូវឲ្យភាគីទីបី អ្នកផ្តល់សេវា ឬ អ្នកម៉ៅការអនុលោមតាម កាតព្វកិច្ចដែលត្រូវ អនុវត្តស្ថិតក្រោមចំណងជើងនេះ ហើយតម្រូវឲ្យ បុគ្គលទាំងនោះផ្តល់ការការពារ ឯកជនភាពក្នុងកម្រិតដូចគ្នាដូចដែល បានតម្រូវដោយចំណងជើងនេះ ។

(3) ផ្តល់សិទ្ធិអាជីវកម្មដើម្បីចាត់វិធានការដែលសមហេតុផលនិង សមរម្យដើម្បីជួយធានាថាភាគីទីបី អ្នកផ្តល់សេវា ឬអ្នកម៉ៅការប្រើប្រាស់ ព័ត៌មានផ្ទាល់ខ្លួនដែលបានផ្ទេរក្នុងលក្ខណៈដែលស្របតាមកាតព្វកិច្ច របស់អាជីវកម្មស្ថិតក្រោមចំណងជើងនេះ។

(4) តម្រូវឲ្យភាគីទីបី អ្នកផ្តល់សេវាកម្ម ឬអ្នកម៉ៅការជូនដំណឹងដល់ អាជីវកម្ម ប្រសិនបើខ្លួនធ្វើការសម្រេចចិត្តថាលែងអាចបំពេញបានតាម កាតព្វកិច្ចរបស់ខ្លួនក្រោមចំណងជើងនេះ ។

(5) ផ្តល់សិទ្ធិដល់អាជីវកម្មនោះ បន្ទាប់ពីការជូនដំណឹង រួមទាំងនៅ ក្រោមកថាខណ្ឌ (4) ដើម្បីចាត់វិធានការដែលសមហេតុផល និង សមស្របដើម្បីបញ្ឈប់ និងលុបបំបាត់ការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន ដោយគ្មានការអនុញ្ញាត ។

(e) អាជីវកម្មដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ត្រូវ អនុវត្តនីតិវិធី និងការអនុវត្តសន្តិសុខដែលសមហេតុផល ដែលសមស្រប តាមលក្ខណៈនៃព័ត៌មានផ្ទាល់ខ្លួនដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនពីការ ចូល ការប្រើប្រាស់ ការបំផ្លិចបំផ្លាញ ការកែសម្រួល ឬការបញ្ចេញឱ្យដឹង ដោយគ្មានការអនុញ្ញាត ឬខុសច្បាប់អនុលោមតាមផ្នែក 1798.81.5 ។

(f) មិនមានអ្វីនៅក្នុងផ្នែកនេះត្រូវតម្រូវឲ្យអាជីវកម្មបង្ហាញអោយឃើញ អាថ៌កំបាំងពាណិជ្ជកម្មទេ ដូចបានបញ្ជាក់នៅក្នុងបទបញ្ជាដែលបាន អនុម័ត ស្របតាមកថាខណ្ឌ (3) នៃផ្នែករង (a) នៃផ្នែក 1798.185 ។

~~(c) អាជីវកម្មត្រូវផ្តល់ព័ត៌មានដែលបានបញ្ជាក់នៅក្នុងផ្នែករង (a) ដល់ អ្នកប្រើប្រាស់ តែនៅពេលដែលបានទទួលសំណើរបស់អ្នកប្រើប្រាស់ ដែលអាចផ្ទៀងផ្ទាត់បាន ។~~

~~(d) អាជីវកម្មដែលទទួលការស្នើសុំដែលអាចផ្ទៀងផ្ទាត់បានពីអ្នកប្រើ ប្រាស់ដើម្បីចូលប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន ត្រូវចាត់វិធានការភ្លាម ៗ ដើម្បីបង្ហាញ និងចែកចាយព័ត៌មានផ្ទាល់ខ្លួននោះដល់អ្នកប្រើប្រាស់ ដោយឥតគិតថ្លៃ ដូចដែលបានតម្រូវដោយផ្នែកនេះ ។ ព័ត៌មានអាចត្រូវ បានចែកចាយតាមសំបុត្រ ឬតាមប្រព័ន្ធអេឡិចត្រូនិច ហើយប្រសិនបើ ត្រូវបានផ្តល់ជាអេឡិចត្រូនិច ព័ត៌មាននោះត្រូវស្ថិតនៅក្នុងឧបករណ៍ ចល័ត និងទម្រង់ដែលអាចធ្វើទៅបានតាមបច្ចេកទេសដែល អាចប្រើបាន យ៉ាងងាយស្រួល ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់បញ្ជូនព័ត៌មាននេះ ទៅ អង្គភាពដទៃទៀតបានដោយគ្មានឧបសគ្គ ។ អាជីវកម្មអាចផ្តល់ព័ត៌មាន~~

24

~~ផ្ទាល់ខ្លួនដល់អ្នកប្រើប្រាស់គ្រប់ពេលវេលា ប៉ុន្តែមិនត្រូវបានតម្រូវអោយផ្តល់ព័ត៌មានផ្ទាល់ខ្លួនដល់អ្នកប្រើប្រាស់លើសពីពីរដងក្នុងរយៈពេល 12 ខែឡើយ ។~~

~~(e) ផ្នែកនេះមិនតម្រូវឲ្យអាជីវកម្មរក្សាទុកព័ត៌មានផ្ទាល់ខ្លួនណាមួយដែលប្រមូលបានសម្រាប់ប្រតិបត្តិការតែមួយដងទេ ប្រសិនបើព័ត៌មានមែមនោះមិនត្រូវបានលក់ ឬរក្សាទុកដោយអាជីវកម្មដើម្បីកំណត់អត្តសញ្ញាណឡើងវិញ ឬបើមិនដូច្នោះទេ ភ្ជាប់ព័ត៌មានដែលមិនត្រូវបានរក្សាទុកនៅក្នុងរបៀបដែលត្រូវបាន ពិចារណាថាជាព័ត៌មានផ្ទាល់ខ្លួន។~~

ផ្នែក 5. ផ្នែក 1798.105 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្ម ដែលចែងថា៖

1798.105. សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការលុបចោលព័ត៌មានផ្ទាល់ខ្លួន

~~1798.105.~~ (a) អ្នកប្រើប្រាស់ត្រូវមានសិទ្ធិស្នើសុំឱ្យអាជីវកម្ម លុបព័ត៌មានផ្ទាល់ខ្លួនណាមួយអំពីអ្នកប្រើប្រាស់ ដែលអាជីវកម្មបានប្រមូលពីអ្នកប្រើប្រាស់នោះ។

(b) អាជីវកម្មដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ ត្រូវបង្ហាញអោយដឹងពីសិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការស្នើសុំលុបព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ស្របតាមផ្នែក 1798.130។

(c) *(1)* អាជីវកម្មដែលទទួលបានសំណើរបស់អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បានពីអ្នកប្រើប្រាស់ដើម្បីសុំឱ្យលុបព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នោះ ស្របតាមផ្នែករង (a) នៃផ្នែកនេះ ត្រូវលុបព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នោះពីកំណត់ត្រារបស់ខ្លួន ហើយ*ជូនដំណឹង*ដោយផ្ទាល់ទៅកាន់អ្នកផ្តល់សេវា *ឬអ្នកម៉ៅការណាមួយ* ឱ្យលុបព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ពីកំណត់ត្រារបស់ពួកគេ*និងជូនដំណឹងដល់ភាគីទីបី ទាំងអស់ដែលអាជីវកម្មបានលក់ ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួននោះទៅ *ឱ្យពួកគេលុបចោល* ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ លើកលែងតែមានការបង្ហាញថាការលុបនេះមិនអាចធ្វើទៅបាន ឬមានការលំបាកខ្លាំង។

(2) អាជីវកម្មអាចនឹងរក្សាទុកកំណត់ត្រាជាការសម្ងាត់នៃសំណើសុំការលុបទាំងឡាយសម្រាប់តែគោលបំណងតែមួយដើម្បីបង្ការមិនឱ្យមានការលក់ព័ត៌មាន ផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដែលបានដាក់សំណើសុំការលុប ដើម្បីអនុលោមតាមច្បាប់ ឬគោលបំណងផ្សេងៗរហូតដល់កម្រិតដែលអនុញ្ញាតបានក្រោមចំណងជើងនេះ។

*(3) អ្នកផ្តល់សេវាកម្ម ឬអ្នកម៉ៅការត្រូវសហការជាមួយអាជីវកម្មក្នុងការឆ្លើយតបទៅនឹងសំណើសុំរបស់អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បាន ហើយទៅតាមការចង្អុលបង្ហាញរបស់អាជីវកម្ម ត្រូវលុប ឬអនុញ្ញាតឱ្យអាជីវកម្មលុប ហើយត្រូវជូនដំណឹងដល់អ្នកផ្តល់សេវា ឬអ្នកម៉ៅការផ្ទាល់របស់ខ្លួនឱ្យលុបព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ដែលត្រូវបានប្រមូល ប្រើប្រាស់ ដំណើរការ ឬរក្សាទុកដោយអ្នកផ្តល់សេវា ឬអ្នកម៉ៅការនោះ។ អ្នកផ្តល់សេវា ឬអ្នកម៉ៅការនោះត្រូវជូនដំណឹងដល់អ្នកផ្តល់សេវា អ្នកម៉ៅការ ឬភាគីទីបីណាមួយដែលអាចធ្លាប់ចូលប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនពី ឬតាមរយៈអ្នកផ្តល់ សេវា ឬអ្នកម៉ៅការ ឱ្យលុបចោលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ លើកលែងតែព័ត៌មាននោះត្រូវបានចូលប្រើតាមការចង្អុលបង្ហាញរបស់ អាជីវកម្ម និងលើកលែងតែមានការបង្ហាញថាមិនអាចធ្វើទៅបាន ឬពាក់ព័ន្ធនឹងការប្រឹងប្រែងដែលមិនស៊ីគ្នា។ អ្នកផ្តល់សេវា ឬអ្នកម៉ៅការមិនត្រូវតម្រូវឱ្យអនុលោមតាមសំណើសុំលុបចោលដែល ត្រូវបានដាក់ជូនដោយអ្នកប្រើប្រាស់ដោយ*ផ្ទាល់ទៅកាន់អ្នកផ្តល់សេវា ឬអ្នកម៉ៅការដល់កម្រិតមួយដែលអ្នកផ្តល់សេវា ឬ អ្នកម៉ៅការបានប្រមូល ប្រើប្រាស់ ដំណើរការ ឬរក្សាទុកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់តាមតួនាទីរបស់ខ្លួនក្នុងនាមជាអ្នកផ្តល់សេវា ឬអ្នកម៉ៅការចំពោះអាជីវកម្មនោះ។*

(d) អាជីវកម្ម ឬអ្នកផ្តល់សេវា *ឬអ្នកម៉ៅការដែលអនុវត្តស្របតាមកិច្ចសន្យារបស់ខ្លួនជាមួយអាជីវកម្ម អ្នកផ្តល់សេវា ឬអ្នកម៉ៅការផ្សេងទៀត* មិនត្រូវតម្រូវឱ្យអនុលោមតាមសំណើរបស់អ្នកប្រើប្រាស់ក្នុងការសុំលុប ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នោះទេ ប្រសិនបើវាជាភាពចាំបាច់*ដែលសមហេតុផល*សម្រាប់អាជីវកម្ម ម្ចអ្នកផ្តល់សេវាឬ*អ្នកម៉ៅការ* ក្នុងការរក្សាទុកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដើម្បី៖

(1) បញ្ចប់ប្រតិបត្តិការដែលព័ត៌មានផ្ទាល់ខ្លួននោះត្រូវបានប្រមូល បំពេញតាមលក្ខខណ្ឌធានាជាលាយលក្ខណ៍អក្សរ ឬការប្រមូលផលិតផលមកវិញដែលបានធ្វើឡើង អនុលោមតាមច្បាប់សហព័ន្ធ ផ្តល់ទំនិញ ឬសេវាកម្មដែលបានស្នើសុំដោយអ្នកប្រើប្រាស់ ឬត្រូវបានគ្រោងទុកមុនយ៉ាងសមហេតុផលស*ដោយអ្នកប្រើប្រាស*់នៅក្នុងបរិបទទំនាក់ទំនងអាជីវកម្មដែលកំពុងបន្តរបស់អាជីវកម្ម ជាមួយអ្នកប្រើប្រាស់ ឬបើមិនដូច្នេះទេ អនុវត្តកិច្ចសន្យារវាងអាជីវកម្ម និងអ្នកប្រើប្រាស់។

(2) ~~រុករកឧម្បត្តិហេតុសន្តិសុខ ការពារប្រឆាំងនឹងសកម្មភាពព្យាបាទ-ចោកប្រាស់ ចោកបន្លំ ឬខុសច្បាប់ ឬដាក់ទោសអ្នកដែលទទួលខុសត្រូវលើសកម្មភាពនោះ។~~ *ជួយធានាសន្តិសុខ និងសេចក្តីសុចរិតដល់កម្រិតមួយដែលការប្រើប្រាស់ព័ត៌មាន ផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់មានភាពចាំបាច់យ៉ាងសមហេតុផល និងសមស្រប សម្រាប់គោលបំណងទាំងនោះ។*

(3) កែតម្រូវដើម្បីកំណត់ និងជួសជុលកំហុសឆ្គងដែលប៉ះពាល់ដល់មុខងារជាគោលបំណងដែលមានស្រាប់។

(4) ប្រើប្រាស់សេរីភាពបញ្ចេញមតិ ធានានូវសិទ្ធិរបស់អ្នកប្រើប្រាស់ផ្សេងទៀតក្នុងការប្រើប្រាស់សិទ្ធិនៃសេរីភាពបញ្ចេញមតិរបស់អ្នកប្រើប្រាស់ ឬប្រើប្រាស់សិទ្ធិផ្សេងទៀតដែលផ្តល់ដោយច្បាប់។

(5) អនុលោមតាមច្បាប់ស្តីពីឯកជនភាពការទំនាក់ទំនងតាមអេឡិចត្រូនិចរដ្ឋ California (California Electronic Communications Privacy Act) ស្របតាមជំពូក 3.6 (ចាប់ផ្តើមជាមួយនឹងផ្នែក 1546) នៃចំណងជើង 12 នៃភាគ 2 នៃក្រមព្រហ្មទណ្ឌ។

(6) ចូលរួមក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ ឬស្ថិតិជាសាធារណៈ ឬដោយមានការត្រួតពិនិត្យដោយក្រុមការងារ ~~ដើម្បីជាផលប្រយោជន៍ សាធារណៈ~~ដែល*អនុលោមតាម* ឬប្រកាន់ខ្ជាប់ទៅនឹងក្រមសីលធម៌ និង ច្បាប់ឯកជនភាពដែលអាចអនុវត្តបានផ្សេងទៀតទាំងអស់ នៅពេលការលុបព័ត៌មានរបស់អាជីវកម្មទំនងជាមិនអាចធ្វើទៅបាន ឬប៉ះពាល់ធ្ងន់ធ្ងរទៅលើ ~~សមិទ្ធផលនៃ~~*លទ្ធភាពក្នុងការបំពេញ*ការស្រាវជ្រាវនោះ ប្រសិន បើអ្នកប្រើប្រាស់បានផ្តល់ការយល់ព្រមដែលបានជូនដំណឹង។

(7) ដើម្បីបើកឱ្យមានការប្រើប្រាស់សម្រាប់តែផ្នែកក្នុងដែលសមស្របទៅនឹងការរំពឹងទុករបស់អ្នកប្រើប្រាស់ដែលអាស្រ័យលើទំនាក់ទំនងរបស់អ្នកប្រើប្រាស់ជាមួយ នឹងអាជីវកម្ម *ហើយស៊ីគ្នាជាមួយនឹងបរិបទដែលអ្នកប្រើប្រាស់បានផ្តល់ព័ត៌មាន* នោះ។

(8) អនុលោមតាមកាតព្វកិច្ចផ្លូវច្បាប់។

~~(9) បើមិនដូច្នេះទេ ប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ សម្រាប់ផ្នែកក្នុង តាមលក្ខណៈផ្លូវច្បាប់ដែលស្រមគ្នាជាមួយនឹងមរិមទ ដែលអ្នកប្រើប្រាស់បានផ្តល់ ព័ត៌មាននោះ។~~

ផ្នែក 6. ផ្នែក 1798.106 ត្រូវបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌ ដែលចែងថា៖

1798.106. សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការកែប្រែព័ត៌មានផ្ទាល់ខ្លួន ដែលមិនត្រឹមត្រូវ

(a) អ្នកប្រើប្រាស់ត្រូវមានសិទ្ធិស្នើសុំអាជីវកម្មដែលរក្សាទុកព័ត៌មាន ផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវអំពីអតិថិជន ឲ្យកែប្រែព័ត៌មានផ្ទាល់ខ្លួនមិន ត្រឹមត្រូវនោះដោយពិចារណាលើលក្ខណៈរបស់ព័ត៌មានផ្ទាល់ខ្លួននោះ និងគោលបំណងនៃការដំណើរការព័ត៌មានផ្ទាល់ខ្លួននោះ។

(b) អាជីវកម្មដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ ត្រូវបង្ហាញ អោយឃើញ ស្របតាមផ្នែក 1798.130 នូវសិទ្ធិរបស់អ្នកប្រើប្រាស់ក្នុង ការស្នើឲ្យកែតម្រូវ ព័ត៌មានផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវ ។

(c) អាជីវកម្មដែលទទួលសំណើសុំរបស់អ្នកប្រើប្រាស់ដែលអាច ផ្ទៀងផ្ទាត់បាន ដើម្បីកែតម្រូវព័ត៌មានផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវ ត្រូវ ប្រើប្រាស់លទ្ធផលដែលសមហេតុផលលក្ខណៈពាណិជ្ជកម្ម ក្នុងការ កែតម្រូវព័ត៌មានផ្ទាល់ដែលមិនត្រឹម ត្រូវនោះតាមការណែនាំរបស់អ្នកប្រើ ប្រាស់ អនុលោមតាមផ្នែក 1798.130 និងបទបញ្ជាដែលអនុម័តស្រប ទៅតាមកថាខណ្ឌ (8) នៃផ្នែករង (a) នៃផ្នែក 1798.185 ។

ផ្នែក 7. ផ្នែក 1798.110 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្ម ដែលចែងថា៖

1798.110. សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការដឹងថាព័ត៌មានអ្វីខ្លះដែល កំពុងប្រមូល។ សិទ្ធិចូលមើលព័ត៌មានផ្ទាល់ខ្លួន

~~1798.110.~~ (a) អ្នកប្រើប្រាស់ត្រូវមានសិទ្ធិស្នើសុំឲ្យអាជីវកម្ម ដែល ប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ បង្ហាញដល់អ្នកប្រើប្រាស់នូវ ព័ត៌មានដូចខាងក្រោម ៖

(1) ប្រភេទនៃព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូលអំពីអ្នកប្រើប្រាស់នោះ ។

(2) ប្រភេទនៃប្រភពដែលបានប្រមូលព័ត៌មានផ្ទាល់ខ្លួនមកពី។

(3) គោលបំណងអាជីវកម្ម ឬពាណិជ្ជកម្មនៃការប្រមូល ម្ការលក់ *ឬ ការចែកចាយ*ព័ត៌មានផ្ទាល់ខ្លួន ។

(4) ប្រភេទនៃភាគីទីបីដែ~~ល~~*អាជីវកម្ម~~ចែកចាយ~~ បង្ហាញ*ព័ត៌មាន ផ្ទាល់ខ្លួនជាមួយ។

(5) ចំណែកជាក់លាក់នៃព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូលអំពីអ្នកប្រើ ប្រាស់នោះ ។

(b) អាជីវកម្មដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ត្រូវបង្ហាញ ដល់អ្នកប្រើប្រាស់ដោយអនុលោមតាម *អនុកថាខណ្ឌ (B) នៃ* កថាខណ្ឌ (3) នៃផ្នែករង (a) នៃផ្នែក 1798.130 នូវព័ត៌មានដែលបាន បញ្ជាក់នៅក្នុង ផ្នែករង (a) បន្ទាប់ពីបានទទួលសំណើសុំពីអ្នកប្រើប្រាស់ ដែលអាចផ្ទៀងផ្ទាត់បានពីអ្នកប្រើប្រាស់នោះ *ករណីដែលអាជីវកម្មត្រូវ ចាត់ទុកថាអនុលោមតាមកថាខណ្ឌ (1) ដល់ (4) ដែលរួមបញ្ចូលផ្នែករង (a) ទៅតាមប្រភេទព័ត៌មាននិងគោលបំណងអាជីវកម្ម ឬពាណិជ្ជកម្ម សម្រាប់ការប្រមូល ការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួនដែល វា នឹងត្រូវបានតម្រូវឲ្យបង្ហាញដល់អ្នកប្រើប្រាស់ដោយស្របតាមកថាខណ្ឌ (1) ដល់ (4) ដែលរួមបញ្ចូលផ្នែករង (a) គឺដូចគ្នានឹងព័ត៌មានដែលវាបាន បង្ហាញអនុលោមតាមកថាខណ្ឌ (1) ដល់ (4) រួមបញ្ចូលផ្នែករង (c) ។*

(c) អាជីវកម្មដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ ត្រូវបង្ហាញ អោយឃើញដោយអនុលោមតាមកថាខណ្ឌរង (B) នៃកថាខណ្ឌ (5) នៃ ផ្នែករង (a) នៃផ្នែក 1798.130 នូវ ៖

(1) ប្រភេទនៃព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូលអំពីអ្នកប្រើប្រាស់ ។

(2) ប្រភេទនៃប្រភពដែលបានប្រមូលព័ត៌មានផ្ទាល់ខ្លួនមកពី។

(3) គោលបំណងអាជីវកម្ម ឬពាណិជ្ជកម្មនៃការប្រមូល ម្ការលក់ *ឬ ការចែកចាយ*ព័ត៌មានផ្ទាល់ខ្លួន ។

(4) ប្រភេទនៃភាគីទីបីដែ~~ល~~*អាជីវកម្ម~~ចែកចាយ~~ បង្ហាញ*ព័ត៌មាន ផ្ទាល់ខ្លួនជាមួយ។

(5) ថាអ្នកប្រើប្រាស់មានសិទ្ធិស្នើសុំចំណែកជាក់លាក់នៃព័ត៌មាន ផ្ទាល់ខ្លួនដែលអាជីវកម្មបានប្រមូលអំពីអ្នកប្រើប្រាស់នោះ ។

~~(d) ផ្នែកនេះមិនតម្រូវឲ្យអាជីវកម្មធ្វើដូចខាងក្រោមទេ ៖~~

~~(1) រក្សាទុកព័ត៌មានផ្ទាល់ខ្លួនណាមួយអំពីអ្នកប្រើប្រាស់ ដែលត្រូវបាន ប្រមូលសម្រាប់ប្រតិបត្តិការតែមួយដង ប្រសិនបើស្ថិតនៅក្នុងដំណើ ការធម្មតានៃអាជីវកម្ម ដែលព័ត៌មានអំពីអ្នកប្រើប្រាស់នោះមិនត្រូវបាន រក្សាទុក។~~

~~(2) កំណត់អត្តសញ្ញាណឡើងវិញ ឬភ្ជាប់ទៅទិន្នន័យណាមួយ ដែល ក្នុងដំណើរការធម្មតានៃអាជីវកម្មគឺមិនត្រូវបានរក្សាទុកតាមរបៀបដែល នឹងចាត់ទុកជាព័ត៌មានផ្ទាល់ខ្លួន ។~~

ផ្នែក 8. ផ្នែក 1798.115 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្ម ដែលចែងថា៖

1798.115. សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការដឹងថាព័ត៌មានផ្ទាល់ខ្លួន អ្វីខ្លះដែលត្រូវបានលក់ និងចែកចាយ និងទៅនរណា

~~1798.115.~~ (a) អ្នកប្រើប្រាស់ត្រូវមានសិទ្ធិស្នើសុំឲ្យអាជីវកម្ម ដែល លក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ឬដែលបង្ហាញ ព័ត៌មាននោះសម្រាប់គោលបំណងអាជីវកម្ម បង្ហាញទៅអ្នកប្រើប្រាស់ នោះនូវ៖

(1) ប្រភេទនៃព័ត៌មានផ្ទាល់ខ្លួនដែលអាជីវកម្មបានប្រមូលអំពីអ្នកប្រើ ប្រាស់។

(2) ប្រភេទនៃព័ត៌មានផ្ទាល់ខ្លួនដែលអាជីវកម្មបានលក់ *ឬបាន ចែកចាយ* អំពីអ្នកប្រើប្រាស់និងប្រភេទនៃភាគីទីបីដែលព័ត៌មានផ្ទាល់ខ្លួន បានលក់ទៅឲ្យ *ឬ ចែកចាយទៅ*ឲ្យតាមប្រភេទនៃព័ត៌មានផ្ទាល់ខ្លួន សម្រាប់ប្រភេទនីមួយៗនៃភាគីទីបី ដែលព័ត៌មានផ្ទាល់ខ្លួនត្រូវបានលក់ ទៅឲ្យ *ឬចែកចាយ*។

(3) ប្រភេទនៃព័ត៌មានផ្ទាល់ខ្លួនដែលអាជីវកម្មបានបង្ហាញអោយឃើញ អំពីអ្នកប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្ម *និងប្រភេទនៃបុគ្គល ដែលព័ត៌មានត្រូវបាន* បង្ហាញទៅ*សម្រាប់គោលបំណងអាជីវកម្ម ។*

(b) អាជីវកម្មដែលលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ ឬដែលបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់សម្រាប់គោលបំណង អាជីវកម្មត្រូវតែបង្ហាញអោយដឹង ដោយអនុលោមតាមកថាខណ្ឌ (4) នៃ ផ្នែករង (a) នៃផ្នែក 1798.130 នូវព័ត៌មានដែលបានបញ្ជាក់នៅក្នុង

24

ផ្នែករង (a) ទៅកាន់អ្នកប្រើប្រាស់នៅពេលទទួលបានការស្នើសុំពីអ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បានពីអ្នកប្រើប្រាស់នោះ ។

(c) អាជីវកម្មដែលលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ឬដែលបង្ហាញអោយឃើញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ក្នុងគោលបំណងអាជីវកម្ម ត្រូវតែបង្ហាញអោយឃើញដោយអនុលោមតាមកថាខណ្ឌរង (C) នៃកថាខណ្ឌ (5) នៃផ្នែករង (a) នៃផ្នែក 1798.130 ៖

(1) ប្រភេទនៃព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដែលអាជីវកម្មបានលក់ *ឬបានចែកចាយ* ឬប្រសិនបើអាជីវកម្មនោះមិនបានលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ទេ អាជីវកម្មត្រូវបង្ហាញឲ្យឃើញការពិតនោះ ។

(2) ប្រភេទនៃព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដែលវាបានបង្ហាញអោយឃើញ ក្នុងគោលបំណងអាជីវកម្ម ឬប្រសិនបើអាជីវកម្មមិនបានបង្ហាញអោយឃើញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ទេ អាជីវកម្មត្រូវបង្ហាញការពិតនោះ ។

(d) ភាគីទីបីមិនត្រូវលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ដែលត្រូវបានលក់*ឬចែកចាយទៅ*ភាគីទីបីដោយអាជីវកម្មទេ លើកលែងតែអ្នកប្រើប្រាស់បានទទួលការជូនដំណឹងជាក់លាក់ ហើយត្រូវបានផ្តល់ឱកាសក្នុងការប្រើសិទ្ធិក្នុងការបដិសេធមិនចូលរួមដោយអនុលោមតាមផ្នែក 1798.120 ។

ផ្នែក 9. ផ្នែក 1798.120 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្ម ដែលចែងថា៖

1798.120. សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការជ្រើសរើសមិនចូលរួមការលក់ឬចែកចាយព័ត៌មានផ្ទាល់ខ្លួន

~~1798.120.~~ (a) នៅគ្រប់ពេល អ្នកប្រើប្រាស់ត្រូវមានសិទ្ធិក្នុងការណែនាំឱ្យអាជីវកម្មដែលលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ទៅឱ្យភាគីទីបី មិនឱ្យលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ។ សិទ្ធិនេះអាចត្រូវបានហៅថាសិទ្ធិក្នុងការជ្រើសរើសមិនចូលរួ*មការលក់ ឬចែកចាយ*។

(b) ស្របតាមផ្នែករង (a) នៃផ្នែក 1798.135 អាជីវកម្មដែលលក់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ទៅឱ្យ*ឬចែកចាយវាជាមួយ*ភាគីទីបីត្រូវផ្តល់ការជូនដំណឹងដល់អ្នកប្រើប្រាស់ថាព័ត៌មាននេះអាចនឹងត្រូវបានលក់ *ឬចែកចាយ* ហើយអ្នកប្រើប្រាស់មាន “សិទ្ធិក្នុងការជ្រើសរើសមិនចូលរួម” ការលក់ *ឬ ការចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ។

(c) បើទោះជាមានផ្នែករង (a) ក្តី អាជីវកម្មមិនត្រូវលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ឡើយ ប្រសិនបើអាជីវកម្មដឹងច្បាស់ថាអ្នកប្រើប្រាស់នោះមានអាយុតិចជាង 16 ឆ្នាំ លើកលែងតែអ្នកប្រើប្រាស់ ក្នុងករណីដែលអ្នកប្រើប្រាស់ដែលមានអាយុយ៉ាងហោចណាស់ 13 ឆ្នាំ និងក្រោម 16 ឆ្នាំ ឪពុកម្តាយឬអាណាព្យាបាលរបស់អ្នកប្រើប្រាស់ក្នុងករណីដែលអ្នកប្រើប្រាស់មានអាយុក្រោម 13 ឆ្នាំបានអនុញ្ញាតជាវិជ្ជមានដល់ការលក់ *ឬការចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។ អាជីវកម្មដែលមិនខ្វល់ពីអាយុរបស់អ្នកប្រើប្រាស់តាមដោយចេតនាត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីអាយុរបស់អ្នកប្រើប្រាស់នោះ។ ~~សិទ្ធិនេះអាចនឹងត្រូវបានហៅថា “សិទ្ធិក្នុងការជ្រើសរើសចូលរួម”~~។

(d) អាជីវកម្មដែលបានទទួលការណែនាំពីអ្នកប្រើប្រាស់មិនឱ្យលក់ *ឬចែកចាយ* ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នោះ ឬក្នុងករណីព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ជាអនីតិជន មិនបានទទួលការយល់ព្រមឱ្យលក់*ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ជាអនីតិជនរូបនោះ ត្រូវបានហាមឃាត់ស្របតាមកថាខណ្ឌ (4) នៃផ្នែករង ~~(a)~~ *(c)* នៃផ្នែក 1798.135 ពីការលក់ *ឬចែកចាយ* ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នោះ បន្ទាប់ពីអាជីវកម្មបានទទួលការណែនាំពីអ្នកប្រើប្រាស់ លើកលែងតែនាពេលក្រោយមក អ្នកប្រើប្រាស់ផ្តល់ ~~ការយល់ព្រមអនុញ្ញាត~~ *ជាក់លាក់សម្រាប់*ការលក់ *ឬការចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ។

ផ្នែក 10. ផ្នែក 1798.121 ត្រូវបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌដែលចែងថា៖

1798.121. សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការកំណត់កម្រិតនៃការប្រើប្រាស់ និងការ បង្ហាញអោយឃើញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់

~~1798.121.~~ *(a) នៅគ្រប់ពេល អ្នកប្រើប្រាស់ត្រូវមានសិទ្ធិណែនាំអាជីវកម្មដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនសម្ងាត់អំពីអ្នកប្រើប្រាស់ ឱ្យដាក់កម្រិតការប្រើប្រាស់របស់អាជីវកម្មនូវព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់នោះនៅត្រឹមការប្រើប្រាស់ដែលមានភាពចាំបាច់ក្នុងការអនុវត្តសេវាកម្ម ឬផ្តល់ទំនិញដែលត្រូវបានរំពឹងថាសមហេតុផលដោយអ្នកប្រើប្រាស់ជាមធ្យម ដែលស្នើសុំទំនិញឬសេវាកម្មទាំងនោះ ឱ្យអនុវត្តសេវាកម្មដែលមានចែងក្នុងកថាខណ្ឌ (2), (4), (5) និង (8) នៃផ្នែករង (e) នៃផ្នែក 1798.140 និងដូចបានអនុញ្ញាតដោយបទបញ្ជាដែលបានអនុម័តស្របតាមអនុកថាខណ្ឌ (C) នៃកថាខណ្ឌ (19) នៃផ្នែករង (a) នៃផ្នែក 1798.185 ។ អាជីវកម្មដែលប្រើប្រាស់ ឬបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់ក្នុងគោលបំណងក្រៅពីអ្វីដែលមានចែងក្នុងផ្នែករងនេះត្រូវផ្តល់ការជូនដំណឹងដល់អ្នកប្រើប្រាស់ស្របតាមផ្នែករង (a) នៃផ្នែក 1798.135 ថាព័ត៌មាននេះអាចនឹងត្រូវបានប្រើប្រាស់ ឬបង្ហាញទៅកាន់អ្នកផ្តល់សេវា ឬអ្នកម៉ៅការសម្រាប់គោលបំណងបន្ថែមជាក់លាក់ ហើយអ្នកប្រើប្រាស់មានសិទ្ធិដាក់កម្រិតលើការប្រើប្រាស់ ឬការបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់ពួកគេ។*

(b) អាជីវកម្មដែលបានទទួលការណែនាំពីអ្នកប្រើប្រាស់មិនឱ្យប្រើប្រាស់ ឬបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់នោះ លើកលែងតែត្រូវបានអនុញ្ញាតដោយផ្នែករង (a) ស្រមតាមកថាខណ្ឌ (4) នៃអនុផ្នែក (c) នៃផ្នែក 1798.135 ត្រូវបានហាមឃាត់ពីការប្រើប្រាស់ ឬការបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់រូបនោះ សម្រាប់គោលបំណងផ្សេងទៀតបន្ទាប់ពីអាជីវកម្មបានទទួលការណែនាំពីអ្នកប្រើប្រាស់ លុះត្រាតែនៅពេលក្រោយមកអ្នកប្រើប្រាស់ផ្តល់ការយល់ព្រមសម្រាប់ការប្រើប្រាស់ ឬការបង្ហាញព័ត៌មានសម្ងាត់ផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់រូបនោះសម្រាប់គោលបំណងបន្ថែមនានា។

(c) អ្នកផ្តល់សេវាកម្ម ឬ អ្នកម៉ៅការដែលជួយដល់អាជីវកម្មក្នុងការអនុវត្តគោលបំណងដែលបានអនុញ្ញាតដោយផ្នែករង (a) មិនអាចនឹងប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់បានឡើយ បន្ទាប់ពីខ្លួនបានទទួលការណែនាំពីអាជីវកម្ម និងក្នុងកម្រិតដែលខ្លួនដឹងច្បាស់ថាព័ត៌មានផ្ទាល់ខ្លួន នោះគឺជាព័ត៌មានផ្ទាល់ខ្លួនសម្ងាត់សម្រាប់គោលបំណងណាមួយផ្សេងទៀត។ អ្នកផ្តល់សេវាកម្ម ឬអ្នកម៉ៅការត្រូវបានតម្រូវឱ្យតែដាក់កម្រិតការប្រើប្រាស់ ព័ត៌មានផ្ទាល់ខ្លួនរសើបដែលបានទទួលរបស់ខ្លួនស្របតាមកិច្ចសន្យា ជាលាយលក្ខណ៍អក្សរជាមួយអាជីវកម្មដែលជាការឆ្លើយតបទៅនឹងការណែនាំពីអាជីវកម្មហើយពាក់ព័ន្ធតែជាមួយនឹងទំនាក់ទំនងរបស់ខ្លួនជាមួយអាជីវកម្មនោះប៉ុណ្ណោះ។

(d) ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ដែលត្រូវបានប្រមូល ឬដំណើរការដោយគ្មានគោលបំណងទាញផលពីចរិកលក្ខណៈអំពីអ្នកប្រើប្រាស់ គឺមិនស្ថិតក្រោមផ្នែកនេះទេ ដូចដែលមានចែងបន្ថែមក្នុងបទបញ្ញត្តិដែលបានអនុម័ត ស្របតាមអនុកថាខណ្ឌ (C) នៃកថាខណ្ឌ (19) នៃផ្នែករង (a) នៃផ្នែក 1798.185 ហើយត្រូវបានចាត់ទុកថាជាព័ត៌មានផ្ទាល់ខ្លួនសម្រាប់គោលបំណងនៃផ្នែកផ្សេងទៀតទាំងអស់នៃក្រមច្បាប់នេះ រួមទាំងផ្នែក 1798.100 ។

ផ្នែក 11. ផ្នែក 1798.125 នៃ ក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.125. សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការមិនមានការសងសឹកបន្ទាប់ពី ការជ្រើសរើសមិនចូលរួម ឬប្រើប្រាស់សិទ្ធិផ្សេងទៀត

~~1798.125.~~ (a) (1) អាជីវកម្មមិនត្រូវរើសអើងនឹងអ្នកប្រើប្រាស់ ដោយសារតែអ្នកប្រើប្រាស់បានអនុវត្តសិទ្ធិណាមួយនៃសិទ្ធិរបស់អ្នកប្រើប្រាស់ស្ថិតក្រោមចំណងជើងនេះ ដែលរួមមានប៉ុន្តែមិនកំណត់តែចំពោះដោយ៖

(A) ការបដិសេធទំនិញឬសេវាកម្មដល់អ្នកប្រើប្រាស់ ។

(B) ការគិតប្រាក់ក្នុងតម្លៃ ឬអត្រាផ្សេងៗគ្នាសម្រាប់ទំនិញឬសេវាកម្ម រួមទាំងតាមរយៈការប្រើប្រាស់ការបញ្ចុះតម្លៃ ឬអត្ថប្រយោជន៍ផ្សេងទៀត ឬ ការដាក់ពិន័យ។

(C) ការផ្តល់ជូនកម្រិតឬគុណភាពផ្សេងៗគ្នានៃទំនិញឬសេវាកម្មទៅឱ្យអ្នកប្រើប្រាស់។

(D) ការឲ្យយោបល់ថា អ្នកប្រើប្រាស់នឹងទទួលបានតម្លៃ ឬអត្រាផ្សេងៗគ្នាសម្រាប់ទំនិញ ឬសេវាកម្ម ឬកម្រិតឬគុណភាពផ្សេងៗគ្នានៃទំនិញ ឬ សេវាកម្ម។

(E) ការសងសឹកប្រឆាំងនឹងនិយោជិត អ្នកដាក់ពាក្យសុំធ្វើការងារ ឬអ្នកម៉ៅការឯករាជ្យដូចដែលមានចែងក្នុងអនុកថាខណ្ឌ (A) នៃកថាខណ្ឌ (2) នៃ ផ្នែករង (m) នៃផ្នែក 1798.145 សម្រាប់ការអនុវត្តសិទ្ធិរបស់ពួកគេស្ថិតក្រោមចំណងជើងនេះ។

(2) *ស្របតាមអនុផ្នែក (b)* មិនមានអ្វីនៅក្នុងផ្នែករងនេះ ហាមឃាត់អាជីវកម្មពីការគិតប្រាក់ពីអ្នកប្រើប្រាស់ក្នុងតម្លៃ ឬអត្រាតម្លៃផ្សេងៗគ្នា ឬពីការផ្តល់កម្រិតឬគុណភាពផ្សេងៗគ្នារបស់ទំនិញ ឬ សេវាកម្មដល់អ្នកប្រើប្រាស់នោះទេ ប្រសិនបើភាពខុសគ្នានោះមានការពាក់ព័ន្ធសមហេតុផលទៅនឹងតម្លៃដែលបានផ្តល់ជូនអាជីវកម្មដោយទិន្នន័យរបស់អ្នកប្រើប្រាស់។

(3) ផ្នែករងនេះមិនហាមឃាត់អាជីវកម្មពីការផ្តល់ជូនកម្មវិធីភក្តីភាព កម្មវិធីរង្វាន់ កម្មវិធីលក្ខណៈពិសេសបុព្វលាភ កម្មវិធីបញ្ចុះតម្លៃ ឬ កម្មវិធីប័ណ្ណក្លឹប ដែលស្របតាមចំណងជើងនេះឡើយ។

(b) (1) អាជីវកម្មអាចនឹងផ្តល់ជូនប្រាក់លើកទឹកចិត្ត រួមទាំងការទូទាត់ជូនអ្នកប្រើប្រាស់ជាសំណងសម្រាប់ការប្រមូលព័ត៌មានផ្ទាល់ខ្លួន ការលក់ *ឬការចែកចាយ*ព័ត៌មានផ្ទាល់ខ្លួន ឬ~~ការសុំមិនចោល~~ *ការរក្សាទុក*ព័ត៌មានផ្ទាល់ខ្លួន ។ អាជីវកម្មក៏អាចនឹងផ្តល់ជូនផងដែរនូវតម្លៃ អត្រាកម្រិត ឬគុណភាពផ្សេងៗគ្នានៃទំនិញ ឬសេវាកម្មជូនអ្នកប្រើប្រាស់ ប្រសិនបើតម្លៃ ឬភាពខុសគ្នានោះ~~មានការពាក់ព័ន្ធ~~ *សមហេតុផល* ដោយផ្ទាល់ទៅនឹងតម្លៃដែលត្រូវបានផ្តល់ជូនអាជីវកម្មដោយទិន្នន័យរបស់អ្នកប្រើប្រាស់។

(2) អាជីវកម្មដែលផ្តល់ជូនប្រាក់លើកទឹកចិត្តណាមួយដោយអនុលោមតាមផ្នែករងនេះ ត្រូវជូនដំណឹងដល់អ្នកប្រើប្រាស់អំពីប្រាក់លើកទឹកចិត្តនេះ ស្របតាមផ្នែក 1798.130។

(3) អាជីវកម្មអាចបង្កើតកម្មវិធីលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុបានលុះត្រាតែអ្នកប្រើប្រាស់ផ្តល់ជូនអាជីវកម្មនោះនូវការយល់ព្រមជ្រើសរើសចូលរួមជាមុន ស្របតាមផ្នែក 1798.130 ដែលពិពណ៌នាយ៉ាងច្បាស់លាស់អំពីលក្ខខណ្ឌចាំបាច់នៃកម្មវិធីលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុនោះ ហើយអាចត្រូវបានលុបចោលដោយអ្នកប្រើប្រាស់បានគ្រប់ពេល។ *ប្រសិនបើអ្នកប្រើប្រាស់បដិសេធផ្តល់ការយល់ព្រមចូលរួម នោះអាជីវកម្មត្រូវរង់ចាំ យ៉ាងហោចណាស់រយៈ ពេល 12 ខែ មុនពេលមានការស្នើសុំបន្ទាប់ ឱ្យអ្នកប្រើប្រាស់ផ្តល់ជូនការយល់ព្រមចូលរួម ឬដូចមានចែងក្នុងបទបញ្ញត្តិដែលបានអនុម័ត ស្របតាមផ្នែក1798.185 ។*

(4) អាជីវកម្មមិនត្រូវប្រើប្រាស់ការអនុវត្តប្រាក់លើកទឹកចិត្តដែលមានលក្ខណៈ អយុត្តិធម៌ មិនសមហេតុផល ដោយបង្ខំ ឬ ដោយយកអត្រាការប្រាក់ហួសប្រមាណឡើយ។

ផ្នែក 12. ផ្នែក 1798.130 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.130. លក្ខខណ្ឌតម្រូវអំពីការជូនដំណឹង ការបង្ហាញអោយឃើញ ការកែតម្រូវ និងការលុប

~~1798.130~~ (a) ដើម្បីអនុលោមតាមផ្នែក 1798.100, 1798.105, *1798.106,* 1798.110, 1798.115, និង 1798.125 ក្នុងទម្រង់ដែលអ្នកប្រើប្រាស់អាចចូលប្រើបានដោយសមហេតុផល អាជីវកម្មត្រូវ៖

(1) (A) ផ្តល់វិធីសាស្ត្រដែលត្រូវបានកំណត់ទុកជាមុនយ៉ាងតិចពីរដល់អ្នកប្រើប្រាស់សម្រាប់ការ ដាក់បញ្ជូនសំណើសុំព័ត៌មានដែលចាំបាច់ត្រូវបង្ហាញឲ្យឃើញ ស្របតាមផ្នែក 1798.110 និង 1798.115 *ឬ សំណើសម្រាប់ការលុប ឬការកែតម្រូវស្របតាមផ្នែក 1798.105 និង 1798.106 រៀងៗខ្លួន* ដោយរួមមានយ៉ាងហោចណាស់លេខទូរស័ព្ទ ឥតគិតថ្លៃមួយ។ អាជីវកម្មដែលប្រតិបត្តិការតែលើអ៊ីនធឺណិតនិងមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកប្រើប្រាស់ដែលខ្លួនប្រមូលព័ត៌មានផ្ទាល់ខ្លួនអាចតម្រូវឲ្យផ្តល់អាសយដ្ឋាន អ៊ីមែលតែប៉ុណ្ណោះសម្រាប់ការដាក់ជូនការសំណើសុំព័ត៌មានដែលចាំបាច់ត្រូវបង្ហាញដូចមានចែងនៅក្នុងផ្នែក 1798.110 និង 1798.115 *ឬសម្រាប់ការស្នើសុំលុប ឬកែតម្រូវ ស្របតាមផ្នែក 1798.105 និង 1798.106 នីមួយៗ*។

(B) ប្រសិនបើអាជីវកម្មមានគេហទំព័រធឺណិត ត្រូវធ្វើឲ្យគេហទំព័រអ៊ីនធឺណិតនោះអាចប្រើបានចំពោះអ្នកប្រើប្រាស់ដើម្បីដាក់បញ្ជូនសំណើសុំព័ត៌មានដែលត្រូវបង្ហាញស្របតាមផ្នែក 1798.110 និង 1798.115 *ឬសំណើសុំការលុប ឬការកែតម្រូវស្របតាមផ្នែក 1798.105 និង 1798.106 នីមួយៗ*។

(2) *(A)* បង្ហាញឲ្យឃើញនិងផ្តល់ព័ត៌មានចាំបាច់ដល់អ្នកប្រើប្រាស់ ដោយឥត គិតថ្លៃ *កែតម្រូវព័ត៌មានផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវ ឬលុបព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់តាមសំណើរបស់អ្នកប្រើប្រាស់* ក្នុងរយៈពេល 45 ថ្ងៃ ក្រោយទទួលបានសំណើពី អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បានពីអ្នកប្រើប្រាស់។ អាជីវកម្មត្រូវចាត់វិធានការភ្លាមៗដើម្បីកំណត់ថាតើសំណើគឺជាសំណើអ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បានឬទេ ប៉ុន្តែមិនត្រូវពង្រីកតួនាទីអាជីវកម្មដើម្បីបង្ហាញនិងផ្តល់ព័ត៌មាន

កែតម្រូវព័ត៌មានផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវ ឬលុបព័ត៌មានផ្ទាល់ខ្លួន ក្នុងរយៈពេល 45 ថ្ងៃ បន្ទាប់ពីបានទទួលសំណើរបស់អ្នកប្រើប្រាស់ឡើយ។ កំឡុងរយៈពេលក្នុងការផ្តល់ព័ត៌មានដែលត្រូវបានតម្រូវ *ដើម្បីកែព័ត៌មានផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវ ឬដើម្បីលុបព័ត៌មានផ្ទាល់ខ្លួន* អាចនឹងត្រូវបានពន្យារពេលម្តងដោយរយៈពេល 45 ថ្ងៃបន្ថែមនៅពេលចាំបាច់ដែលសមហេតុផល ក្នុងករណីដែលអ្នកប្រើប្រាស់ត្រូវបានផ្តល់ការជូនដំណឹងអំពីការពន្យារពេលក្នុងរយៈពេល 45 ថ្ងៃដំបូង ។ ការ*បង្ហាញព័ត៌មានដែលចាំបាច់* ~~ត្រូវគ្រប់ដណ្តប់រយៈពេល 12 ខែ មុនពេលការទទួលសំណើ របស់អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បានរបស់អាជីវកម្ម~~ ~~ហើយ~~ *ត្រូវ*បាន ~~ធ្វើ~~ *ធ្វើ*ឡើងជាលាយលក្ខណ៍អក្សរ*និ*ងចែកចាយ*តាមរយៈ*គណនីរបស់អ្នកប្រើប្រាស់ជាមួយអាជីវកម្ម ប្រសិនបើអ្នកប្រើប្រាស់*រក្សាទុ*ក*គ*ណ*នីជ*ាមួ*យ*អ*ាជ*ីវ*ក*ម្ម ឬ*តាម*រ*យ*ៈ*សំ*ប*ុ*ត្រ ឬ*ប្រ*ព*ន*្ធ*
*អ*ឡ*ិ*ច*ត្រ*ូ*ន*ិ*ក*តា*ម*ជ*ម្រ*ើ*ស*រ*ប*ស*់*អ*្ន*ក*ប*្រ*ើ*ប*្រ*ា*ស*់ ប*្រ*ស*ិ*ន*ប*ើ*អ*្ន*ក*ប*្រ*ើ*ប*្រ*ា*ស*់
មិ*ន*រ*ក*្ស*ា*ទ*ុ*ក*គ*ណ*នីជ*ាមួ*យ*អ*ាជ*ីវ*ក*ម្ম*ក*ុ*ង*ទ*ម្រ*ង*់ដ*ែ*ល*អ*ាច*ប*្រ*ើ*ប*្រ*ា*ស*់*ប*ាន
យា*ង*ង*ា*យ*ស*្រ*ួ*ល*ដ*ែ*ល អ*ន*ុ*ញ*្ញ*ា*ត*ឱ*ម*្ម*ក*ប*្រ*ើ*ប*្រ*ា*ស*់*ប*ញ*្ជ*ូ*ន*ព*ត*ម*ាន*ន*េ*ះ*ព*ី
*អ*ង*្ក*ភ*ា*ព*ម*ួ*យ*ទ*ៅ*អ*ង*្ក*ភ*ា*ព*ម*ួ*យ*ទ*ៀ*ត*ដ*ោ*យ*ម*ិ*ន*ម*ាន*ឧ*ប*ស*គ*្គ។ *អ*ាជ*ីវ*ក*ម្ম
អាច*ន*ឹ*ង*ត*ម*្រ*ូ*ว*ឲ*ម*ាន*ការ*ផ*្ទ*ៀ*ង*ផ*្ទ*ា*ត*់*ភ*ា*ព*ត*្រ*ឹ*ម*ត*្រ*ូ*ว*ร*ប*ស*ម*ាជ*ិ*ក*ប*ី*ប*ី*ប*ី*ដ*ែ*ล
*ส*ม*ห*ต*ุ*ผ*ล*ผ*ล*ิ*ต*ก*ล*ง*ก*ว*ด*ล*ว*ม*ค*ว*า*ม*ป*ร*ะ*ก*อ*บ*ข*อ*ง*ข*อ*ม*ู*ล*ส*ว*น*บ*ุ*ค*ค*ล*ข*อ*ง

ដោយយោងទៅតាមប្រភេទដែលមានចែងក្នុងផ្នែករង (c) ដែលរៀបរាប់ស្រដៀងបំផុតនូវព័ត៌មានផ្ទាល់ខ្លួនដែលត្រូវបានលក់ *ឬចែកចាយ*។ អាជីវកម្មត្រូវបង្ហាញព័ត៌មានជាបញ្ជីដែលដាច់ដោយឡែកពីបញ្ជី ដែលបង្កើតឡើងសម្រាប់គោលបំណងនៃអនុកថាខណ្ឌ (C) ។

(C) កំណត់ប្រភេទ ឬប្រភេទនានាអំពីព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដែលអាជីវកម្ម បានបង្ហាញសម្រាប់គោលបំណងអាជីវកម្ម ~~នៅក្នុងអំឡុងពេល 12 ខែមុន~~*នៅអំឡុង ពេលដែលអាចអនុវត្តបាន* ដោយយោងតាមប្រភេទ ឬប្រភេទនានាដែលមានចែងក្នុងផ្នែករង (c) ដែលរៀបរាប់ស្រដៀងបំផុតអំពីព័ត៌មានផ្ទាល់ខ្លួនហើយផ្តល់ប្រភេទនៃ*បុគ្គល*~~ភាគីទីមី~~ ដែលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ត្រូវបានបង្ហាញទៅកាន់ សម្រាប់គោលបំណងអាជីវកម្ម ~~នៅក្នុងរយៈពេល 12 ខែមុន~~ *នៅអំឡុងពេលដែលអាចអនុវត្តបាន* ដោយយោងតាមប្រភេទឬប្រភេទនានាដែលមានចែងក្នុងផ្នែករង (c) ដែលរៀបរាប់ស្រដៀងបំផុតអំពីព័ត៌មានផ្ទាល់ខ្លួនដែលត្រូវបានបង្ហាញអោយឃើញ។ អាជីវកម្មត្រូវបង្ហាញព័ត៌មានជាបញ្ជីដែលដាច់ដោយឡែកពីបញ្ជីដែលបង្កើតឡើងសម្រាប់ គោលបំណងនៃអនុកថាខណ្ឌ (B) ។

(5) បង្ហាញឲ្យឃើញព័ត៌មានដូចខាងក្រោមនៅក្នុងគោលការណ៍ ឬគោលការណ៍នានានៃឯកជនភាព លើអ៊ីនធឺណិតរបស់ខ្លួន ប្រសិនបើអាជីវកម្មនោះមានគោលការណ៍ ឬគោលការណ៍នានាអំពីឯកជនភាពលើ អ៊ីនធឺណិត ហើយនៅក្នុងការពិពណ៌នាជាក់លាក់របស់ រដ្ឋ California នៃសិទ្ធិឯកជនភាព របស់អ្នកប្រើប្រាស់ ឬប្រសិនបើអាជីវកម្មនោះមិនរក្សាទុកគោលការណ៍ទាំងនោះលើគេហទំព័រ អ៊ីនធឺណិតរបស់ខ្លួន និងមិនធ្វើបច្ចុប្បន្នភាពព័ត៌មាន នោះយ៉ាងហោចណាស់រៀងរាល់ 12 ខែម្តង៖

(A) ការពិពណ៌នាអំពីសិទ្ធិអ្នកប្រើប្រាស់ស្របតាមផ្នែក 1798.100, 1798.105, *1798.106,* 1798.110, 1798.115, និង 1798.125 ព្រមទាំងវិធីដែលបានកំណត់មួយ *ពីរ* ឬ ច្រើន សម្រាប់ការដាក់បញ្ជូនសំណើ*លើកលែងតែមានចែងក្នុងអនុកថាខណ្ឌ (A) នៃកថាខណ្ឌ (1) នៃផ្នែករង (a) ។*

(B) សម្រាប់គោលបំណងនៃផ្នែករង (c) នៃផ្នែក 1798.110~~,~~៖

(i) a បញ្ជីនៃប្រភេទព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ដែលខ្លួនបានប្រមូលក្នុងអំឡុងពេល 12 ខែមុនដោយយោងតាមប្រភេទ ឬប្រភេទនានាដែលមានចែងក្នុងផ្នែករង (c) ដែលរៀបរាប់ស្រដៀងបំផុតនូវ ព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូល។

(ii) ប្រភេទនៃប្រភពដែលបានប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។

(iii) គោលបំណងអាជីវកម្ម ឬពាណិជ្ជកម្មនៃការប្រមូល ឬការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ។

(iv) ប្រភេទនៃភាគីទីបីដែលអាជីវកម្មបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ទៅកាន់ ។

(C) សម្រាប់គោលបំណងនៃកថាខណ្ឌ (1) និង (2) នៃផ្នែករង (c) នៃផ្នែក1798.115 បញ្ជីពីរដាច់ដោយ ឡែកពីគ្នា៖

(i) បញ្ជីនៃប្រភេទព័ត៌មានផ្ទាល់ខ្លួនដែលខ្លួនបានលក់ *ឬចែកចាយ*អំពីអ្នកប្រើប្រាស់មុនរយៈពេល 12 ខែ ដោយយោងទៅតាមប្រភេទ ឬប្រភេទនានាដែលបានចែងនៅក្នុងផ្នែករង (c) ដែលរៀបរាប់យ៉ាងច្បាស់អំពីព័ត៌មានផ្ទាល់ខ្លួន ដែលបានលក់*ឬបានចែកចាយ* ឬប្រសិនបើអាជីវកម្មនោះមិនបានលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នៅមុនរយៈពេល 12 ខែទេនោះ អាជីវកម្មត្រូ*វបង្ហាញឲ្យឃើញ អង្គហេតុនោះនៅក្នុងគោលការណ៍ ឯកជនភាពរបស់ខ្លួន*។

(ii) បញ្ជីនៃប្រភេទព័ត៌មានផ្ទាល់ខ្លួនដែលខ្លួនបានបង្ហាញអំពីអ្នកប្រើប្រាស់សម្រាប់ គោលបំណងអាជីវកម្មនៅមុនរយៈពេល 12 ខែ ដោយយោងទៅតាមប្រភេទ ដែលមានចែងនៅក្នុងផ្នែករង (c) ដែល*ស~~រៀមអាម~~រៀបរាប់*យ៉ាងច្បាស់អំពីព័ត៌មាន ផ្ទាល់ខ្លួនដែលត្រូវបានបង្ហាញឬប្រសិនបើអាជីវកម្មនោះមិនបាន បង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្ម នៅមុនរយៈពេល 12 ខែទេ អាជីវកម្មនោះត្រូវបង្ហាញអង្គហេតុនោះ។

(6) ធានាថារាល់បុគ្គលដែលទទួលខុសត្រូវចំពោះការដោះស្រាយ សំណួររបស់អ្នកប្រើប្រាស់អំពីការអនុវត្តឯកជនភាពរបស់អាជីវកម្ម ឬ ការអនុលោមតាម ចំណងជើងនេះរបស់អាជីវកម្ម ត្រូវបានជូនដំណឹងពីរាល់លក្ខខណ្ឌតម្រូវក្នុងផ្នែក 1798.100, 1798.105, *1798.106,* 1798.110, 1798.115, 1798.125 និង ផ្នែកនេះ និង របៀបក្នុងការណែនាំអ្នកប្រើប្រាស់ឱ្យអនុវត្តសិទ្ធិរបស់ពួកគេ ស្ថិតក្រោមផ្នែកទាំងនេះ។

(7) ប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនណាមួយដែលបានប្រមូលពីអ្នកប្រើប្រាស់ដែលពាក់ព័ន្ធ ជាមួយការផ្ទៀងផ្ទាត់របស់អាជីវកម្មលើសំណើរបស់អ្នកប្រើប្រាស់សម្រាប់តែគោលបំណងនៃការផ្ទៀងផ្ទាត់ប៉ុណ្ណោះ *ហើយមិនត្រូវបន្តបង្ហាញព័ត៌មានផ្ទាល់ខ្លួន ឬរក្សាទុកវាយូរជាងការចាំបាច់ សម្រាប់គោលបំណងនៃការផ្ទៀងផ្ទាត់ ឬប្រើប្រាស់វាសម្រាប់គោលបំណងដែលមិនជាប់ពាក់ព័ន្ធឡើយ* ។

(b) អាជីវកម្មមិនមានកាតព្វកិច្ចផ្តល់ព័ត៌មានដែលតម្រូវដោយផ្នែក 1798.110 និង 1798.115 ដល់អ្នកប្រើប្រាស់ដូចគ្នាច្រើនជាងពីរដងនៅក្នុងរយៈពេល 12 ខែ នោះទេ។

(c) ប្រភេទព័ត៌មានផ្ទាល់ខ្លួនដែលត្រូវបង្ហាញស្របតាមផ្នែក *1798.100,* 1798.110, និង 1798.115 ត្រូវអនុវត្តតាម~~និយមន័យ~~ *ឬនិយមន័យនានា*នៃព័ត៌មានផ្ទាល់ខ្លួន *និងព័ត៌មានផ្ទាល់ខ្លួនសម្ងាត់*នៅក្នុងផ្នែក 1798.140 *តាមរយៈការពណ៌នាប្រភេទព័ត៌មានផ្ទាល់ខ្លួនដោយការប្រើប្រាស់ វាក្យសព្ទជាក់លាក់ដែលមានចែងក្នុងអនុកថាខណ្ឌ (A) ដល់ (K) រួមទាំងកថាខណ្ឌ (1) នៃផ្នែករង (v) នៃផ្នែក 1798.140 និងតាមរយៈការពណ៌នាប្រភេទនៃព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ ដោយការប្រើប្រាស់វាក្យសព្ទជាក់លាក់ដែលមានចែងក្នុងកថាខណ្ឌ (1) ដល់ (9) រួមទាំងផ្នែករង (ae) នៃផ្នែក 1798.140 ។*

ផ្នែក 13. ផ្នែក 1798.135 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្ម ដែលមានខ្លឹមសារ៖

1798.135. វិធីសាស្ត្រនៃការកំណត់កម្រិតលើការលក់ ការចែកចាយ និងការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន និងការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់

~~1798.135~~ (a) អាជីវកម្មដែល ~~បានតម្រូវឱ្យអនុលោម តាមផ្នែក 1798.120~~ *ដែលលក់ ឬចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ឬប្រើប្រាស់ ឬបង្ហាញព័ត៌មាន ផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀត ក្រៅពីការអនុញ្ញាតទាំងនោះ ដោយផ្នែករង (a) នៃផ្នែក 1798.121* ត្រូវស្ថិតក្នុង ទម្រង់មួយដែលអាចប្រើប្រាស់បានយ៉ាងសមរម្យដល់អ្នកប្រើប្រាស់៖

(1) ផ្តល់តំណភ្ជាប់ដែលច្បាស់លាស់ និងជាក់ស្តែងលើ ~~គេហទំព័រលើអ៊ីនធឺណិត~~ *គេហទំព័រនានាលើអ៊ីនធឺណិត* ដែលមានចំណងជើងថា "ហាមលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់ខ្ញុំ" នៅលើ ~~ទំព័រអ៊ីមលើ~~

~~អ៊ីនធឺណិត~~ *ឬទំព័រវិបនានាលើអ៊ីនធឺណិត*ដែលបើកឲ្យអ្នកប្រើប្រាស់ ឬបុគ្គលដែលទទួលបានការអនុញ្ញាតពីអ្នកប្រើប្រាស់ក្នុងការជ្រើសរើសចាកចេញពីការលក់ឬចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។

(2) ផ្តល់តំណភ្ជាប់ច្បាស់លាស់ និងជាក់ស្តែងលើគេហទំព័រលើអ៊ីនធឺណិតរបស់អាជីវកម្មដែលមាន ចំណងជើងថា "ដាក់កម្រិតលើការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់ខ្ញុំ" ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ឬបុគ្គលដែលទទួលបានការអនុញ្ញាតពីអ្នកប្រើប្រាស់ដាក់កម្រិតលើការប្រើប្រាស់ ឬការបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់ទៅលើការប្រើប្រាស់ ទាំងនោះដែលអនុញ្ញាតដោយផ្នែករង (a) នៃផ្នែក 1798.121 ។

(3) តាមឆន្ទានុសិទ្ធិរបស់អាជីវកម្ម ត្រូវប្រើប្រាស់តំណភ្ជាប់ដែលមានស្លាកសញ្ញាតែមួយ និងច្បាស់លាស់លើគេហទំព័រលើអ៊ីនធឺណិតរបស់អាជីវកម្មជំនួសឲ្យការអនុលោមតាមកថាខណ្ឌ (1) និង (2) ប្រសិនបើតំណភ្ជាប់នោះអនុញ្ញាតឲ្យអ្នកប្រើប្រាស់ជ្រើសរើសចាកចេញពីការលក់ ឬចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់និងដាក់កម្រិតលើការប្រើប្រាស់ ឬការបង្ហាញ ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់យ៉ាងងាយស្រួលនោះ។

(4) ករណីដែលអាជីវកម្មមួយឆ្លើយតបទៅនឹងសំណើជ្រើសរើសចាកចេញដែលបានទទួលដោយអនុលោមតាមកថាខណ្ឌទី (1), (2), ឬ (3) ដោយការជូនដំណឹងដល់អ្នកប្រើប្រាស់អំពីការគិតថ្លៃសម្រាប់ការប្រើប្រាស់ផលិតផល ឬសេវាកម្មណាមួយ ត្រូវបង្ហាញនូវលក្ខខណ្ឌនៃការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ដែលផ្តល់ជូនដោយអនុលោមតាមផ្នែករង (b) នៃផ្នែកទី 1798.125 សម្រាប់ការរក្សាទុក ការប្រើប្រាស់ ការលក់ ឬការចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។

(b) (1) អាជីវកម្មមួយមិនត្រូវបានតម្រូវឲ្យអនុលោមតាមផ្នែករង (a) ឡើយ ប្រសិនបើអាជីវកម្មនោះអនុញ្ញាតឲ្យអ្នកប្រើប្រាស់ សម្រេចចិត្តមិនចូលរួមក្នុងការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួន និងកំណត់ព្រំដែននៃការប្រាស់ព័ត៌មានសម្ងាត់ផ្ទាល់ខ្លួន របស់ពួកគេតាមរយៈសញ្ញាចំណូលចិត្តជ្រើសរើសមិនចូលរួមដែលបានធ្វើជាមួយនឹងសេចក្តីយល់ព្រមរបស់អ្នកប្រើប្រាស់ ដោយវេទិកា បច្ចេកវិទ្យា ឬយន្តការមួយ ដោយផ្អែកលើលក្ខណៈបច្ចេកទេសដែលមានចែងនៅក្នុងនិយ័តកម្មទាំងឡាយ ដែលបានអនុម័ត ដោយអនុលោមតាមកថាខណ្ឌទី (20) នៃផ្នែករង (a) នៃផ្នែកទី 1798.185 ចំពោះអាជីវកម្មដោយបញ្ជាក់អំពីចេតនារបស់អ្នកប្រើប្រាស់ក្នុងការសម្រេចចិត្តមិនចូលរួមនៅក្នុងការលក់របស់អាជីវកម្ម ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ឬកំណត់ព្រំដែនការប្រើប្រាស់ ឬការបង្ហាញឲ្យឃើញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់ ឬទាំងពីរ។

(2) អាជីវកម្មដែលអនុញ្ញាតអ្នកប្រើប្រាស់ឲ្យជ្រើសរើសការមិនចូលរួមការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ និងកំណត់ព្រំដែនការប្រើប្រាស់ព័ត៌មានសម្ងាត់ផ្ទាល់ខ្លួនរបស់ពួកគេ និងកំណត់ព្រំដែនការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់ពួកគេ ដោយអនុលោមតាមកថាខណ្ឌទី (1) អាចផ្តល់តំណភ្ជាប់ទៅកាន់គេហទំព័រណាមួយដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ផ្តល់ការយល់ព្រមដល់ក្រុមហ៊ុនដែលមិនអើពើចំពោះសញ្ញាចំណូលចិត្តជ្រើសរើសមិនចូលរួម ដែលពាក់ព័ន្ធនឹងការលក់របស់អាជីវកម្ម ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ឬការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់សម្រាប់គោលបំណងបន្ថែម ក្នុងករណីដែល៖

(A) គេហទំព័រយល់ព្រមក៏អនុញ្ញាតឲ្យអ្នកប្រើប្រាស់ ឬបុគ្គលដែលត្រូវបានអនុញ្ញាតដោយអ្នកប្រើប្រាស់ដកហូតការយល់ព្រមវិញបានយ៉ាងងាយស្រួល ដូចដែលមានការផ្តល់ជូនដែលបានបញ្ជាក់ផងដែរ។

(B) តំណភ្ជាប់ទៅកាន់គេហទំព័រមិនធ្វើឲ្យខូចខាតដល់បទពិសោធន៍របស់អ្នកប្រើប្រាស់នៅលើគេហទំព័រដែលអ្នកប្រើប្រាស់មានចេតនាចង់ចូលមើលឡើយ ហើយមានរូបរាង អារម្មណ៍ និងទំហំដែលទាក់ទងនឹងតំណភ្ជាប់ផ្សេងទៀតនៅលើគេហទំព័រតែមួយនេះដែរ។

(C) គេហទំព័រយល់ព្រម អនុលោមជាមួយនឹងលក្ខណៈបច្ចេកទេសទាំងឡាយដែលមានចែងនៅក្នុងនិយ័តកម្មដែលត្រូវបានអនុម័តដោយអនុលោមតាមកថាខណ្ឌទី (20) នៃផ្នែករង (a) នៃផ្នែកទី 1798.185។

(3) អាជីវកម្មដែលអនុលោមតាមផ្នែករង (a) មិនត្រូវបានតម្រូវឲ្យអនុលោមតាមផ្នែករង (b) ឡើយ។ សម្រាប់គោលបំណងនៃភាពច្បាស់លាស់ អាជីវកម្មមួយអាចជ្រើសរើសថាតើត្រូវអនុលោមតាមផ្នែករង (a) ឬផ្នែករង (b) ដែរឬទេ។

(c) *អាជីវកម្មមួយដែលស្ថិតក្រោមផ្នែកនេះ* នឹង*៖*

*(1) ~~មិន~~ត្រូវ*តម្រូវឲ្យអ្នកប្រើប្រាស់បង្កើតនូវគណនីមួយ ~~ឬ~~ *ឬផ្តល់ព័ត៌មានបន្ថែមដែលលើសពីអ្វីដែលចាំបាច់* ដើម្បីបង្គាប់ឲ្យអាជីវកម្មមួយមិនលក់ *ឬចែកចាយ* ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ *ឬកំណត់ព្រំដែនការប្រើប្រាស់ ~~ឬ~~ ~~ឬ~~ ~~ឬ~~

(5) សម្រាប់ ~~អ្នកប្រើប្រាស់ណាម្នាក់ដែលបានជ្រើសយកការមិនចូលរួមការលក់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ គោរពការសម្រេចចិត្តរបស់អ្នកប្រើប្រាស់ក្នុងការសម្រេចចិត្តមិនចូលរួមរយៈពេលយ៉ាងតិច 12 ខែ មុនពេលស្នើសុំឲ្យអ្នកប្រើប្រាស់អនុញ្ញាតការលក់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់~~ *អ្នកប្រើប្រាស់អាយុក្រោម 16 ឆ្នាំ ដែលមិនយល់ព្រមជាមួយនឹងការលក់ ឬការចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ហាមឃាត់ការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់អាយុក្រោម 16 ឆ្នាំ និងរង់ចាំយ៉ាងតិច 12 ខែ មុនពេលស្នើសុំការយល់ព្រមរបស់អ្នកប្រើប្រាស់ម្តងទៀត ឬតាមការអនុញ្ញាតដោយនិយ័តកម្ម ឬរហូតទាល់តែអ្នកប្រើប្រាស់ឈានចូលដល់អាយុ 16 ឆ្នាំ។*

(6) ប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនណាមួយដែលបានប្រមូលពីអ្នកប្រើប្រាស់ ទាក់ទងនឹងការដាក់ជូនសំណើជ្រើសរើសការមិនចូលរួមរបស់អ្នកប្រើប្រាស់ សម្រាប់គោលបំណងម្យ៉ាងគត់នៃការការអនុលោមតាមសំណើសុំជ្រើសរើសការមិនចូលរួម។

~~(b)~~ *(d)* គ្មានអ្វីមួយនៅក្នុងចំណងជើងនេះត្រូវបានបកស្រាយដើម្បីតម្រូវឲ្យអាជីវកម្មអនុលោមតាមចំណងជើងនេះ ដោយការដាក់បញ្ចូលនូវតំណភ្ជាប់ និងអត្ថបទដែលបានតម្រូវនៅលើគេហទំព័រដែលអាជីវកម្មនោះដាក់ឲ្យប្រើប្រាស់សម្រាប់សាធារណជនទូទៅឡើយ ប្រសិនបើអាជីវកម្មនោះរក្សាឲ្យមាននូវគេហទំព័រដាច់ដោយឡែក និងបន្ថែមមួយដែលទុកសម្រាប់តែអ្នកប្រើប្រាស់នៅរដ្ឋ California ហើយដែលដាក់បញ្ចូលនូវតំណភ្ជាប់ និងអត្ថបទដែលបានតម្រូវ ហើយអាជីវកម្មនោះចាត់វិធានការសមរម្យដើម្បីធានាថា អ្នកប្រើប្រាស់នៅរដ្ឋ California ត្រូវបាននាំទៅកាន់គេហទំព័រនោះសម្រាប់អ្នកប្រើប្រាស់នៅរដ្ឋ California និងមិនមែនជាគេហទំព័រដែលត្រូវបានដាក់ឲ្យប្រើប្រាស់សម្រាប់សាធារណជនទូទៅទេ។

~~(c)~~ *(e)* អ្នកប្រើប្រាស់ម្នាក់អាចអនុញ្ញាតឲ្យបុគ្គលម្នាក់ផ្សេងទៀត ~~តែម្យ៉ាងគត់~~ ដើម្បីជ្រើសរើសមិនចូលរួមការលក់ *ឬការចែកចាយ* ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ *និងកំណត់ព្រំដែនការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់* ក្នុងនាមជាអ្នកប្រើប្រាស់ *រួមទាំងតាមរយៈ សញ្ញាចំណូលចិត្តជ្រើសរើសការមិនចូលរួមដូចមានកំណត់នៅក្នុងកថាខណ្ឌទី (1) នៃផ្នែករង (b) ដែលបញ្ជាក់អំពីចេតនារបស់អ្នកប្រើប្រាស់ដែលសម្រេចចិត្តមិនចូលរួម* ហើយអាជីវកម្មត្រូវអនុលោមតាមសំណើសម្រេចចិត្តមិនចូលរួមដែលបានទទួលពីបុគ្គលណាម្នាក់ ដែលត្រូវបានអនុញ្ញាតដោយអ្នកប្រើប្រាស់ ដើម្បីធ្វើក្នុងនាមជាអ្នកប្រើប្រាស់ ដោយអនុលោមតាមនិយ័តកម្មទាំងឡាយដែលអនុម័តដោយអគ្គមេធាវី *ដោយមិនគិតថាតើអាជីវកម្មនោះបានជ្រើសរើសអនុលោមតាមផ្នែករង (a) ឬ (b) ឬអត់ឡើយ។ សម្រាប់គោលបំណងនៃភាពច្បាស់លាស់ អាជីវកម្មដែលជ្រើសរើសអនុលោមតាមផ្នែករង (a) អាចឆ្លើយតបទៅនឹងការសម្រេចចិត្តមិនចូលរួមរបស់អ្នកប្រើប្រាស់ដែលស្របគ្នាជាមួយនឹងផ្នែកទី 1798.125។*

(f) ប្រសិនបើអាជីវកម្មជូនដំណឹងអំពីសំណើសម្រេចចិត្តមិនចូលរួមរបស់អ្នកប្រើប្រាស់ដល់បុគ្គលណាម្នាក់ដែលត្រូវបានអនុញ្ញាតដោយអាជីវកម្មដើម្បីប្រមូលព័ត៌មានផ្ទាល់ខ្លួន នៅពេលក្រោយមកទៀត បុគ្គលនោះត្រូវប្រើប្រាស់តែព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នោះសម្រាប់តែគោលបំណងអាជីវកម្មមួយដែលបានបញ្ជាក់ដោយអាជីវកម្មប៉ុណ្ណោះ ឬទៅតាមការអនុញ្ញាតដោយចំណងជើងនេះ ហើយត្រូវបានហាមឃាត់ពី៖

(1) ការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួន។

(2) ការរក្សាទុក ការប្រើប្រាស់ ឬការអនុញ្ញាតអោយឃើញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។

(A) សម្រាប់គោលបំណងក្រៅពីសម្រាប់គោលបំណងជាក់លាក់នៃការផ្តល់សេវាកម្មទាំងឡាយដែលផ្តល់ជូនដល់អាជីវកម្មនោះ។

(B) នៅក្រៅទំនាក់ទំនងអាជីវកម្មដោយផ្ទាល់រវាងបុគ្គល និងអាជីវកម្ម។

(C) សម្រាប់គោលបំណងពាណិជ្ជកម្មក្រៅពីការផ្តល់សេវាជូនអាជីវកម្មនោះ។

(g) អាជីវកម្មដែលជូនដំណឹងអំពីសំណើសម្រេចចិត្តមិនចូលរួមរបស់អ្នកប្រើប្រាស់ទៅឲ្យបុគ្គលណាម្នាក់ ដោយអនុលោមតាមផ្នែករង (f) មិនត្រូវទទួលខុសត្រូវក្រោមចំណងជើងនេះឡើយ ប្រសិនបើបុគ្គលនោះដែលទទួលបានសំណើសម្រេចចិត្តមិនចូលរួមបានរំលោភបំពានលើការរឹតត្បិតទាំងឡាយដែលមានចែងនៅក្នុងចំណងជើងនេះ នៅពេលនៃការជូនដំណឹងអំពីសំណើជ្រើសរើសការមិនចូលរួម ក្នុងករណីដែលអាជីវកម្មនោះមិនមានដំណឹងជាក់ស្តែង ឬហេតុផលដែលត្រូវជឿថា បុគ្គលនោះមានចេតនាប្រព្រឹត្តការរំលោភបំពាននោះ។ ប្រការណាមួយនៃកិច្ចសន្យា ឬកិច្ចព្រមព្រៀងប្រភេទណាមួយដែលអះអាងអំពីការលះបង់សិទ្ធិ ឬកំណត់ព្រំដែនដោយវិធីណាមួយទៅលើផ្នែករងនេះ ត្រូវចាត់ទុកជាមោឃៈ និងមិនអាចអនុវត្តបាន។

ផ្នែកទី 14. ផ្នែកទី 1798.140 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.140. និយមន័យ

~~1798.140.~~ សម្រាប់គោលបំណងនៃផ្នែកនេះ៖

(A) "ការផ្សាយពាណិជ្ជកម្ម និងការធ្វើទីផ្សារ" មានន័យថា ការប្រាស្រ័យទាក់ទងដោយអាជីវកម្ម ឬបុគ្គលណាម្នាក់ក្នុងនាមជាអាជីវកម្មនៅក្នុងមធ្យោបាយណាមួយដើម្បីជម្រុញឲ្យអ្នកប្រើប្រាស់ទទួលបានទំនិញ សេវាកម្ម ឬការងារ។

~~(a)~~ *(b)* "ព័ត៌មានអ្នកប្រើប្រាស់ប្រមូលផ្តុំ" មានន័យថា ព័ត៌មានដែលពាក់ព័ន្ធនឹងក្រុម ឬប្រភេទនៃអ្នកប្រើប្រាស់ ដែលអត្តសញ្ញាណអ្នកប្រើប្រាស់ម្នាក់ៗត្រូវបានយកចេញ ដែលមិនត្រូវបានតភ្ជាប់ ឬអាចតភ្ជាប់ដោយសមហេតុផលជាមួយអ្នកប្រើប្រាស់ ឬគ្រួសារ រួមទាំងតាមរយៈ ឧបករណ៍ណាមួយ។ "ព័ត៌មានអ្នកប្រើប្រាស់ប្រមូលផ្តុំ" មិនមានន័យថា កំណត់ហេតុអ្នកប្រើប្រាស់ម្នាក់ ឬច្រើននាក់ដែលត្រូវបានបិទបាំងអត្តសញ្ញាណទេ។

~~(b)~~ *(c)* "ព័ត៌មានជីវមាត្រ" មានន័យថាលក្ខណៈសរីរសាស្ត្រ ជីវសាស្ត្រ ឬអាកប្បកិរិយារបស់បុគ្គលម្នាក់ រួមមានជាអាទិ៍ *ព័ត៌មានដែលទាក់ទងនឹង* អាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិច (DNA) របស់បុគ្គលម្នាក់ដែល~~អាច~~*ត្រូវបានប្រើប្រាស់ ឬមានចេតនាប្រើប្រាស់* តែឯង ឬរួមគ្នាជាមួយព័ត៌មានផ្សេងទៀត ឬជាមួយព័ត៌មានអត្តសញ្ញាណផ្សេងទៀត ដើម្បីបង្កើតបានជាអត្តសញ្ញាណរបស់បុគ្គលម្នាក់។ ព័ត៌មានជីវមាត្ររួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់តែចំពោះការប្រៀបធៀបប្រស្រីភ្នែក រ៉ែទីន ស្នាមក្រយៅដៃ មុខ ប្រអប់ដៃ បាតដៃ គំរូសរសៃរ៉ែន និងការថតសំឡេង ដែលប្រដាប់វាស់អត្តសញ្ញាណណាមួយដូចជាពុម្ពមុខ គំរូស្នាមក្រយៅដៃ ឬ សំឡេង អាចត្រូវបានយកចេញមកពី ព្រមទាំងគំរូសង្កត់គ្រាប់ចុចឬសម្លេងគំរូដំណើរ ឬសម្លេង ឬទិន្នន័យដំណេក សុខភាព ឬការហាត់ប្រាណដែលមានព័ត៌មានអត្តសញ្ញាណ។

~~(c)~~ *(d)* "អាជីវកម្ម" មានន័យថា៖

(1) ក្រុមហ៊ុនឯកកម្មសិទ្ធិ ក្រុមហ៊ុនដៃគូ ក្រុមហ៊ុនទទួលខុសត្រូវមានកំណត់ សាជីវកម្ម សមាគម ឬអង្គភាពផ្សេងទៀតដែលត្រូវបានរៀបចំ ឬប្រតិបត្តិការដើម្បីស្វែងរកប្រាក់ចំណេញ ឬអត្ថប្រយោជន៍ហិរញ្ញវត្ថុនៃម្ចាស់ភាគហ៊ុនរបស់ខ្លួន ឬម្ចាស់ដទៃទៀត ដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ឬក្នុងនាមអ្នកប្រើប្រាស់ ដែលព័ត៌មាននោះត្រូវបានប្រមូល ហើយដែលអ្នកប្រើប្រាស់តែម្នាក់ឯង ឬរួមគ្នាជាមួយអ្នកដទៃ កំណត់នូវគោលបំណងនិងមធ្យោបាយនៃការដំណើរការព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដែល

24

ធ្វើអាជីវកម្មនៅក្នុងរដ្ឋ California ហើយដែលបំពេញតាមកម្រិតចាប់ផ្តើមមួយឬច្រើនដូចខាងក្រោម៖

(A) ~~ចាប់ពី~~ *ថ្ងៃទី 1 ខែមករា នៃឆ្នាំប្រតិទិនតទៅមាន* ប្រាក់ចំណូលដុលប្រចាំឆ្នាំក្នុងចំនួនលើសម្រៃប្រាំលានដុល្លារ ($25,000,000) *នៅក្នុងឆ្នាំប្រតិទិនមុន* ដូចដែលបានលៃតម្រូវដោយអនុលោមតាមកថាខណ្ឌទី (5) នៃផ្នែករង (a) នៃផ្នែកទី 1798.185។

(B) តែម្នាក់ឯង ឬរួមគ្នាជាប្រចាំឆ្នាំបានទិញ ~~ទទួលសម្រាប់គោលបំណងពាណិជ្ជកម្មរបស់អាជីវកម្ម~~ លក់ ឬចែកចាយ~~សម្រាប់គោលបំណងពាណិជ្ជកម្ម តែម្នាក់ឯង ឬរួមគ្នា~~ នូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ~~50,000~~ *100,000* នាក់ ឬច្រើនជាងនេះ *ឬ* គ្រួសារ ~~ឬឧបករណ៍~~។

(C) ទទួលបាន 50 ភាគរយឬច្រើនជាងនេះនៃប្រាក់ចំណូលប្រចាំឆ្នាំពីការលក់ *ឬចែកចាយ* ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។

(2) អង្គភាពណាមួយដែលគ្រប់គ្រង ឬត្រូវបានគ្រប់គ្រងដោយអាជីវកម្មមួយ*ដូច*មានកំណត់នៅក្នុងកថាខណ្ឌទី (1)*និង* ប្រើប្រាស់ម៉ាកយីហោ*រួ*មជាមួយអាជីវកម្មនោះ *និងជាមួយអ្នកដែលអាជីវកម្មនោះចែករំលែកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់*។ "គ្រប់គ្រង" ឬ "ត្រូវបានគ្រប់គ្រង" មានន័យថា ភាពជាម្ចាស់កម្មសិទ្ធិនៃ ឬសិទ្ធិអំណាចក្នុងការបោះឆ្នោតលើសពី 50 ភាគរយនៃភាគហ៊ុនទាំងអស់នៃចំណាត់ថ្នាក់ណាមួយនៃសន្តិសុខបោះឆ្នោតរបស់អាជីវកម្មមួយ គ្រប់គ្រងនៅក្នុងរបៀបណាមួយទៅលើការបោះឆ្នោតរបស់សំឡេងភាគច្រើនរបស់នាយក ឬរបស់បុគ្គលទាំងឡាយណាដែលអនុវត្តមុខងារស្រដៀងគ្នានេះ ឬសិទ្ធិអំណាចក្នុងការអនុវត្តការជះឥទ្ធិពលគ្រប់គ្រងទៅលើការគ្រប់គ្រងក្រុមហ៊ុនណាមួយ។ "ម៉ាកយីហោ*រួ*ម" មានន័យថា ឈ្មោះ*រួ*ម ម៉ាកសេវា ម៉ាកពាណិជ្ជកម្មណាមួយ *ដែលអ្នកប្រើប្រាស់ជាមធ្យមនឹងយល់ថា អង្គភាពពីរ ឬច្រើនត្រូវបានកាន់កាប់រួមគ្នា*។

(3) គម្រោងវិនិយោគចម្រុះ ឬភាពជាដៃគូដែលមានសមាសភាពអាជីវកម្មទាំងឡាយ ដែលក្នុងអាជីវកម្មនីមួយៗមានមានផលប្រយោជន៍យ៉ាងតិច 40 ភាគរយ។ សម្រាប់គោលបំណងនៃចំណងជើងនេះ គម្រោងវិនិយោគចម្រុះ ឬភាពជាដៃគូនិងអាជីវកម្មនីមួយៗដែលមានសមាសភាពគម្រោងវិនិយោគចម្រុះ ឬភាពជាដៃគូត្រូវបានចាត់ទុកដោយឡែកថាជាអាជីវកម្មតែមួយ លើកលែងតែព័ត៌មានផ្ទាល់ខ្លួនដែលជាកម្មសិទ្ធិរបស់អាជីវកម្មនីមួយៗត្រូវបានប្រកាសផ្សាយដល់គម្រោងវិនិយោគចម្រុះ ឬដៃគូ មិនត្រូវចែករំលែកជាមួយអាជីវកម្មផ្សេងទៀតឡើយ។

(4) បុគ្គលម្នាក់ដែលធ្វើអាជីវកម្មនៅរដ្ឋ California ដែលមិនត្រូវបានគ្របដណ្តប់ដោយកថាខណ្ឌទី (1), (2) ឬ (3) និងដែលបញ្ជាក់ដោយស្ម័គ្រចិត្តជូនទីភ្នាក់ងារការពារឯកជនភាពនៃរដ្ឋ California ថាខ្លួនអនុលោមតាម និងយល់ព្រមភ្ជាប់កាតព្វកិច្ចអនុវត្តតាមចំណងជើងនេះ។

~~(d)~~ *(e)* "គោលបំណងអាជីវកម្ម" មានន័យថា ការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្រាប់គោលបំណងប្រតិបត្តិការរបស់អាជីវកម្ម ~~ឬសម្រាប់អ្នកផ្តល់សេវា~~ ឬគោលបំណងផ្សេងទៀតដែលបានជូនដំណឹង *ឬ សម្រាប់គោលបំណងប្រតិបត្តិការរបស់អ្នកផ្តល់សេវា ឬអ្នកម៉ៅការ ដូចបានកំណត់ដោយនិយ័តកម្មដែលត្រូវបានអនុម័តដោយអនុលោមតាមកថាខណ្ឌទី (11) នៃផ្នែករង (a) នៃផ្នែកទី 1798.185* ឲ្យតែការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួននោះ មានភាពចាំបាច់សមហេតុសមផល និងតាមសមាមាត្រដើម្បីសម្រេចនូវគោលបំណង ~~ប្រតិបត្តិការ~~ សម្រាប់ព័ត៌មាន ផ្ទាល់ខ្លួន ដែលត្រូវបានប្រមូល ឬដំណើរការ ឬសម្រាប់គោលបំណង ~~ប្រតិបត្តិការ~~ផ្សេងទៀត ដែលស៊ីគ្នាជាមួយនឹងបរិបទនៃព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូលនោះ។ គោលបំណងអាជីវកម្មគឺជា៖

(1) ការធ្វើសវនកម្មដែលទាក់ទងនឹង~~អន្តរកម្មបច្ចុប្បន្នជាមួយនឹងអ្នកប្រើប្រាស់ និងប្រតិបត្តិការដំណាលគ្នា រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ~~ ការរាប់ចំណាប់អារម្មណ៍ពាណិជ្ជកម្មចំពោះអ្នកទស្សនាដែលខុសប្លែកពីគេ ការផ្ទៀងផ្ទាត់ទីតាំង និងគុណភាពនៃចំណាប់អារម្មណ៍ពាណិជ្ជកម្ម និងការធ្វើសវនកម្មអនុលោមភាពជាមួយនឹងលក្ខណៈពិសេសនេះ និងស្តង់ដារផ្សេងទៀត។

(2) ~~ការស្រាវជ្រាវរកហេតុការណ៍ផ្នែកសន្តិសុខ ការការពារប្រឆាំងនឹងសកម្មភាពព្យាបាទ ឆបោក ក្លែងបន្លំ ឬសកម្មភាពខុសច្បាប់ និងការកាត់ទោសបុគ្គលដែលទទួលខុសត្រូវចំពោះសកម្មភាពនោះ។~~ *ការជួយដើម្បីធានាថាសន្តិសុខ និងភាពសុចរិតនៃការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់មានភាពចាំបាច់សមហេតុសមផល និងសមាមាត្រសម្រាប់គោលបំណងទាំងនេះ*។

(3) ការបំបាត់កំហុសដើម្បីកំណត់អត្តសញ្ញាណ និងជួសជុលកំហុសដែលធ្វើឲ្យខូចដល់មុខងារគ្រោងទុកដែលមានស្រាប់។

(4) ការប្រើប្រាស់រយៈពេលខ្លីបណ្តោះអាសន្ន *ដែលរួមមានប៉ុន្តែមិនកំណត់ចំពោះការផ្សាយពាណិជ្ជកម្មដែលគ្មានលក្ខណៈផ្ទាល់ខ្លួនដែលបង្ហាញជាផ្នែកមួយនៃអន្តរអំពើបច្ចុប្បន្នរបស់អ្នកប្រើប្រាស់ជាមួយអាជីវកម្ម* ករណីដែល*ព័ត៌មាន*ផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នោះមិនត្រូវបានប្រកាសដល់ភាគីទីបីមួយផ្សេងទៀត ហើយមិនត្រូវបានប្រើប្រាស់ដើម្បីបង្កើតប្រវត្តិរូប ~~អំពីអ្នកប្រើប្រាស់ ឬកែប្រែបុគ្គលណាម្នាក់~~ *នូ*វបទពិសោធន៍របស់អ្នកប្រើប្រាស់នៅក្រៅអន្តរអំពើបច្ចុប្បន្ន *ជាមួយអាជីវកម្ម*។~~រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ ការតម្រូវតាមបរិបទនៃពាណិជ្ជកម្មដែលបានបង្ហាញជាផ្នែកមួយនៃអន្តរអំពើតែមួយនោះ។~~

(5) ការផ្តល់សេវាកម្មក្នុងនាមអាជីវកម្ម*ឬ* ~~អ្នកផ្តល់សេវា~~ *រួ*មទាំងការរក្សា ឬផ្តល់សេវាដល់គណនី ការផ្តល់សេវាអតិថិជន ការដំណើរការ ឬការបំពេញការបញ្ជាទិញនិងប្រតិបត្តិការ ការផ្ទៀងផ្ទាត់ព័ត៌មានអតិថិជន ការដំណើរការទូទាត់ ការផ្តល់ហិរញ្ញប្បទាន ~~ការផ្តល់សេវាផ្សាយពាណិជ្ជកម្ម ឬការធ្វើទីផ្សារ~~ ការផ្តល់សេវាវិភាគ *ការផ្តល់កន្លែងស្នុកទុក* ឬការផ្តល់សេវាស្រដៀងគ្នានេះក្នុងនាមអាជីវកម្ម ~~ឬអ្នកផ្តល់សេវា~~។

(6) ការផ្តល់សេវាផ្សាយពាណិជ្ជកម្ម និងការធ្វើទីផ្សារ លើកលែងតែការផ្សាយពាណិជ្ជកម្មអាកប្បកិរិយាឆ្លងបរិបទដល់អ្នកប្រើប្រាស់ ករណីដែលសម្រាប់គោលបំណងនៃការផ្សាយពាណិជ្ជកម្ម និងការធ្វើទីផ្សារ អ្នកផ្តល់សេវា ឬអ្នកម៉ៅការ មិនត្រូវរួមបញ្ចូលគ្នានូវព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់ដែលបានជ្រើសរើសការមិនចូលរួមដែលអ្នកផ្តល់សេវា ឬអ្នកម៉ៅការនោះបានទទួល ក្នុងនាមអាជីវកម្មជាមួយព័ត៌មានផ្ទាល់ខ្លួនដែលអ្នកផ្តល់សេវា ឬអ្នកម៉ៅការបានទទួល ឬក្នុងនាមបុគ្គលម្នាក់ ឬច្រើននាក់ផ្សេងទៀត ឬប្រមូលពីអន្តរអំពើរបស់ខ្លួនជាមួយអ្នកប្រើប្រាស់។

~~(6)~~ *(7)* ការធ្វើការស្រាវជ្រាវផ្ទៃក្នុងសម្រាប់ការអភិវឌ្ឍ និងការបង្ហាញការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា។

~~(7)~~ *(8)* ការធ្វើសកម្មភាពដើម្បីផ្ទៀងផ្ទាត់ ឬរក្សាគុណភាព ឬសុវត្ថិភាពនៃសេវាកម្ម ឬឧបករណ៍អ្វីមួយដែលត្រូវបានកាន់កាប់ ផលិត ផលិតសម្រាប់ ឬគ្រប់គ្រងដោយអាជីវកម្ម និងដើម្បីកែលម្អ ដំឡើងជំនាន់ ឬពង្រឹងសេវាកម្ម ឬឧបករណ៍ដែលត្រូវបានកាន់កាប់ ផលិត ផលិតសម្រាប់ ឬគ្រប់គ្រងដោយអាជីវកម្ម។

~~(e)~~ *(f)* "ប្រមូល" "ត្រូវបានប្រមូល" ឬ "ការប្រមូល" មានន័យថា ការទិញ ការជួល ការប្រមូល ការទទួលបាន ការទទួល ឬការចូលប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនណាមួយដែលទាក់ទងនឹងអ្នកប្រើប្រាស់តាមមធ្យោបាយណាមួយ។ នេះ*រួ*មបញ្ចូលទាំងការទទួលព័ត៌មានពី

24

អ្នកប្រើប្រាស់ ដោយសកម្មក្តី ឬអកម្មក្តី ឬដោយការសង្កេតមើលអាកប្ប កិរិយារបស់អ្នកប្រើប្រាស់ក្តី។

~~(f)~~ *(g)* "គោលបំណងពាណិជ្ជកម្ម" មានន័យថា ធ្វើឲ្យរីកចម្រើនផលប្រយោជន៍ផ្នែកពាណិជ្ជកម្ម ឬសេដ្ឋកិច្ចរបស់បុគ្គលណាម្នាក់ ដូចជាដោយការជម្រុញឲ្យបុគ្គលម្នាក់ផ្សេងទៀតទិញ ជួល ចូលរួម ជាវ ផ្តល់ ឬផ្លាស់ប្តូរផលិតផល ទំនិញ ទ្រព្យសម្បត្តិ ព័ត៌មាន ឬសេវាកម្ম ឬការអនុញ្ញាត ឬការជិះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលនូវប្រតិបត្តិការពាណិជ្ជកម្មមួយ។ ~~"គោលបំណងពាណិជ្ជកម្ম" មិនរាប់បញ្ចូលសម្រាប់គោលបំណងនៃការចូលរួមជាសន្ទរកថាដែលតុលាការរដ្ឋ ឬសមាព័ន្ធបានទទួលស្គាល់ថាជាសន្ទរកថាមិនមែនពាណិជ្ជកម្ম រួមទាំងសន្ទរកថានយោបាយ និងសារព័ត៌មាន។~~

(h) "ការយល់ព្រម" មានន័យថា ការបញ្ជាក់ដោយសេរី ជាក់លាក់ ជ្រួតជ្រាប និងមានន័យច្បាស់លាស់អំពីបំណងរបស់អ្នកប្រើប្រាស់ ដែលអ្នកប្រើប្រាស់ឬអាណាព្យាបាលស្របច្បាប់របស់អ្នកប្រើប្រាស់ បុគ្គលម្នាក់ដែលមានសិទ្ធិអំណាចមេធាវី ឬបុគ្គលម្នាក់ដែលដើរតួជាអ្នកអភិរក្សសម្រាប់អ្នកប្រើប្រាស់ រួមទាំងដោយសេចក្តីថ្លែងការណ៍ ឬដោយចំណាត់ការវិជ្ជមានច្បាស់លាស់ ធ្វើសញ្ញាប្រាប់ការព្រមព្រៀងក្នុងការដំណើការព័ត៌មានផ្ទាល់ខ្លួនដែលទាក់ទងនឹងអ្នកប្រើប្រាស់សម្រាប់គោលបំណង ជាក់លាក់ដែលបានកំណត់យ៉ាងតូចមួយ។ ការទទួលលក្ខខណ្ឌនៃការប្រើប្រាស់ទូទៅ ឬទូលំទូលាយ ឬឯកសារស្រដៀងគ្នាដែលមានការបរិយាយអំពីព័ត៌មានផ្ទាល់ខ្លួនដែលដំណើរការរួមគ្នាជាមួយព័ត៌មានដែលមិនពាក់ព័ន្ធ មិនបង្កើតបានជាការយល់ព្រមឡើយ។ ការពន្យាពេល ការបង្អន់ ការផ្អាក ឬការបិទចំណែកណាមួយនៃមាតិកា មិនបង្កើតបានជាការយល់ព្រមឡើយ។ ដូចគ្នានេះដែរ ការព្រមព្រៀងដែលទទួលបានតាមរយៈការប្រើប្រាស់ឧបាយកលងងឹត មិនបង្កើតបានជាការយល់ព្រមឡើយ។

~~(g)~~ *(i)* "អ្នកប្រើប្រាស់" មានន័យថា បុគ្គលរូបវន្តដែលជាពលរដ្ឋ California ដូចមានកំណត់នៅក្នុងផ្នែកទី 17014 នៃចំណងជើង 18 នៃក្រមនិយ័តកម្មរដ្ឋ California ដូចដែលផ្នែកនោះចែងនៅថ្ងៃទី 1 ខែកញ្ញាឆ្នាំ 2017 ទោះជាយ៉ាងណា ត្រូវបានកំណត់អត្តសញ្ញាណ រួមទាំងលក្ខណៈកំណត់អត្តសញ្ញាណណាមួយខុសប្លែកពីគេ។

(j) (1) "អ្នកម៉ៅការ" មានន័យថា បុគ្គលម្នាក់ដែលត្រូវបានអាជីវកម្ম ផ្តល់លទ្ធភាពប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្ম ដោយអនុលោមតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយអាជីវកម្ম ករណីដែលកិច្ចសន្យានោះ៖

(A) ហាមឃាត់អ្នកម៉ៅការពី៖

(i) ការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួន។

(ii) ការរក្សា ការប្រើប្រាស់ ឬការប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួនសម្រាប់គោលបំណងអាជីវកម្ম ក្រៅពីសម្រាប់គោលបំណងអាជីវកម្ম ដែលមានបញ្ជាក់នៅក្នុងកិច្ចសន្យា រួមមានជាអាទិ៍ ការរក្សា ការប្រើប្រាស់ ឬការប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួនសម្រាប់គោលបំណងពាណិជ្ជកម្ম ក្រៅពីគោលបំណងអាជីវកម្ম ដែលមានបញ្ជាក់នៅក្នុងកិច្ចសន្យា ឬ អនុញ្ញាតដោយចំណងជើងនេះ។

(iii) ការរក្សា ការប្រើប្រាស់ ឬការប្រកាសផ្សាយព័ត៌មាននៅក្រៅ ទំនាក់ទំនងអាជីវកម្ম ផ្ទាល់រវាងអ្នកម៉ៅការ និងអាជីវកម្ম។

(iv) ការដាក់បញ្ចូលគ្នានូវព័ត៌មានផ្ទាល់ខ្លួនដែលអ្នកម៉ៅការទទួលបានដោយអនុលោមតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយអាជីវកម្ম ជាមួយនឹងព័ត៌មានផ្ទាល់ខ្លួនដែលខ្លួនទទួលបានពី ឬក្នុងនាមបុគ្គលម្នាក់ ឬបណ្តាបុគ្គលផ្សេងទៀត ឬប្រមូលពីអន្តរអំពើររបស់ខ្លួនជាមួយអ្នកប្រើប្រាស់ ករណីដែលអ្នកម៉ៅការអាចដាក់បញ្ចូលព័ត៌មានផ្ទាល់ខ្លួនដើម្បីអនុវត្តគោលបំណងអាជីវកម្ম ណាមួយដូចមានកំណត់នៅក្នុងនិយ័តកម្ম ទាំងឡាយដែលត្រូវបានអនុម័តដោយអនុលោមតាមកថាខណ្ឌទី (10) នៃផ្នែករង (a) នៃផ្នែកទី 1798.185 លើកលែងតែមានចែងសម្រាប់ កថាខណ្ឌទី (6) នៃផ្នែករង (e) និងនៅក្នុងនិយ័តកម្ম ទាំងឡាយដែលអនុម័តដោយទីភ្នាក់ងារការពារឯកជនភាពនៃរដ្ឋ California ។

(B) ដាក់បញ្ចូលការបញ្ជាក់មួយដែលធ្វើដោយអ្នកម៉ៅការ ដែលអ្នកម៉ៅការនោះយល់អំពីការរឹតត្បិតទាំងឡាយនៅក្នុងកថាខណ្ឌរង (A) ហើយនឹងអនុលោមតាមវា។

(C) អនុញ្ញាត ក្រោមកិច្ចព្រមព្រៀងជាមួយអ្នកម៉ៅការអាជីវកម្ম ដើម្បីត្រួតពិនិត្យអនុលោមភាពរបស់អ្នកម៉ៅការជាមួយនឹងកិច្ចសន្យាតាមរយៈ វិធានការទាំងឡាយ រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ ការពិនិត្យ ឡើងវិញដោយដៃជាបន្តបន្ទាប់ និងការស្កេនស្វ័យប្រវត្តិនិងការវាយតម្លៃ ជាទៀងទាត់ សវនកម្ম ឬការធ្វើតេស្តបច្ចេកទេស និងប្រតិបត្តិការ យ៉ាងហោចណាស់រៀងរាល់ 12 ខែម្តង។

(2) ប្រសិនបើអ្នកម៉ៅការនាំឲ្យអ្នកដទៃទៀតជួយនៅក្នុងការដំណើរការ ព័ត៌មានផ្ទាល់ខ្លួនសម្រាប់គោលបំណងអាជីវកម្ম ក្នុងនាមអាជីវកម្ম ឬ ប្រសិនបើបុគ្គលណាម្នាក់ផ្សេងទៀតដែលនាំដោយអ្នកម៉ៅការ បាន នាំឲ្យបុគ្គលម្នាក់ផ្សេងទៀតជួយនៅក្នុងការដំណើរការព័ត៌មានផ្ទាល់ខ្លួន សម្រាប់គោលបំណងអាជីវកម្ম នោះ ត្រូវជូនដំណឹងដល់អាជីវកម្ম អំពី ការនាំឲ្យចូលរួមនោះ ហើយការចូលរួមនោះត្រូវអនុលោមតាមកិច្ចសន្យា ជាលាយលក្ខណ៍អក្សរដែលចងភ្ជាប់កាតព្វកិច្ចអនុវត្តទៅលើបុគ្គល ផ្សេងទៀត ដើម្បីប្រតិបត្តិលក្ខខណ្ឌតម្រូវទាំងអស់ដែលមានចែងនៅក្នុង កថាខណ្ឌទី (1)។

(k) "ការផ្សាយពាណិជ្ជកម្ম អាកប្ប កិរិយា ឆ្លងបរិបទ" មានន័យថា ការកំណត់គោលដៅនៃការផ្សាយពាណិជ្ជកម្ম ទៅកាន់អ្នកប្រើប្រាស់ណា ម្នាក់ ដោយផ្អែកលើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដែលទទួល បានពីសកម្ম ភាពរបស់អ្នកប្រើប្រាស់ ទូទាំងអាជីវកម្ম គេហទំព័រមានម៉ាក យីហោ ច្បាស់លាស់ កម្ম វិធី ឬ សេវាកម្ম ទាំងឡាយ ក្រៅពីអាជីវកម្ম គេហទំព័រ មានម៉ាកយីហោ ច្បាស់លាស់ កម្ম វិធី ឬ សេវាកម្ম ដែលអ្នកប្រើ ប្រាស់ មានអន្តរ អំ ពើ ជាមួយ ដោយ ចេតនា។

(l) "ឧបាយកលងងឹត" មានន័យថា ចំណុចប្រទាក់អ្នកប្រើប្រាស់ដែល ត្រូវ បានរចនា ឬ សម្រ ប សម្រ ួ ល ជាមួ យ នឹ ង ឥ ទ្ធ ិ ព ល យ៉ា ង ខ្លាំ ង នៃ ការ ប ង្វ ែ ร ឬ ការ ធ្ វ ើ ឲ្ យ អ ន់ ថ យ ន ូ ว ส ្ ว ย ภ า ព ការ ធ ្ ว ើ ស េ ច ក ្ ត ี ส ម ្ ร ច ច ិ ต ្ ត ឬ ជ ម ្ ម ើ ส ร ប ស ់ អ ្ ន ก ป ្ ร ើ ป ្ ร า ส ់ ដ ូ ច ដ ែ ล ป ា ន ก ำ ณ ត ់ ป ន ្ ថ ែ ม ទ ៀ ត ដ ោ យ ន ិ យ ័ ต ก ម ្ ม ។

~~(h)~~ *(m)* "បិទបាំងអត្តសញ្ញាណ" មានន័យថា ព័ត៌មានដែលមិនអាចត្រូវ បាន ប្រើ ប្រាស់ ដោ យ ស ម ហ េ ត ុ ផ ល ដើ ម ្ ប ី ส ន ្ ท ิ ฐ า น ព ័ ต ์ ม า น អ ំ ព ี ឬ ត ្ ร ូ ว ป า น ต ภ ั ท ป ់ ท ว ี ก า ล ់ ณ า ม ្ ห า ก ់ ก ร ณ ี ដ ែ ล អ า ជ ี ว ก ม ្ ม น ោ ះ ม า น ก ม ្ ม ส ิ ท ธ ิ ព ័ ต ์ ม า น ន ោ ះ ៖

(1) ចាត់វិធានការសមហេតុផលដើម្បីធានាថា ព័ត៌មាននោះមិនអាចពាក់ព័ន្ធជាមួយនឹងអ្នកប្រើប្រាស់ ឬគ្រួសារណាមួយ។

(2) ប្រព្រឹត្តជាសាធារណៈដើម្បីរក្សា និងប្រើប្រាស់ព័ត៌មាននៅក្នុងទម្រង់ ដែលបិទបាំងអត្តសញ្ញាណ និងមិនប៉ុនប៉ងកំណត់អត្តសញ្ញាណព័ត៌មាន ឡើងវិញ លើកលែងតែអាជីវកម្ম នោះ ប៉ុនប៉ងកំណត់អត្តសញ្ញាណ ព័ត៌ មានឡើ ងវិ ញ សម្ រ ាប ់ គោ ល ប ំ ណ ង ត ែ ម ្ យ ា ង ค ต ่ ค ื ก ำ ณ ต ់ ต ว า ต ื ด ำ ณ ิ ก า ร ป ิ ท ป ั ป ิ ท อ ส ญ ญ า ณ ร ป ส ่ ว น ป ำ ณ ต ป ร ะ ท ศ ต ร ม ล ก ข ข ณ ฑ ต ร ว ส ร ป ข อ ง ผ ล ิ ต ภ ั ณ ฑ ์ ห ร ื อ บ ร ิ ก า ร ห ร ื อ ป ร ะ ส ท ธ ิ ภ า พ ข อ ง ก า ร ด ำ ณ ิ ก า ร ต า ม ก ฎ ห ม า ย ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ อ ง ส ิ ท ธ ิ ต า ม ก ฎ ห ม า ย ห ร ื อ ส ิ ท ธ ิ ต า ม ส ั ญ ญ า ห ร ื อ ก า ร ป ก ป ้ អ ត ្ ถ ប ท ន ៃ ស ំ ណ ើ ច ្ ប ា ប ់ | 55

(3) តម្រូវតាមកិច្ចសន្យាឲ្យអ្នកទទួលព័ត៌មានអនុលោមតាមបទបញ្ញត្តិ ទាំងអស់នៃផ្នែករងនេះ។ ~~កំណត់អត្តសញ្ញាណ ភ្ជាប់ទៅនឹង បរិយាយ អាចពាក់ព័ន្ធជាមួយនឹង ឬភ្ជាប់ដោយផ្ទាល់ ឬដោយប្រយោលទៅ~~

~~នឹងអ្នកប្រើប្រាស់ដាក់លាក់ម្នាក់ ករណីដែលអាជីវកម្មដែលប្រើប្រាស់ព័ត៌មានមិនចាំងអត្តសញ្ញាណនោះ៖~~

~~(1) បានអនុវត្តកិច្ចការពារបច្ចេកទេសដែលហាមឃាត់ការកំណត់អត្តសញ្ញាណឡើងវិញរបស់អ្នកប្រើប្រាស់ ដែលព័ត៌មាននោះអាចនឹងពាក់ព័ន្ធជាមួយ។~~

~~(2) បានអនុវត្តដំណើរការអាជីវកម្មដែលហាមឃាត់យ៉ាងច្បាស់នូវព័ត៌មាននោះ។~~

~~(3) បានអនុវត្តដំណើរការអាជីវកម្មដើម្បីបង្ការនូវការបញ្ចេញដោយធ្វេសប្រហែសនូវព័ត៌មានមិនចាំងអត្តសញ្ញាណ។~~

~~(4) មិនប៉ុនប៉ងក្នុងការកំណត់អត្តសញ្ញាណព័ត៌មាននោះឡើងវិញ។~~

~~(i)~~ *(n)* *"*វិធីសាស្ត្រដែលបានកំណត់សម្រាប់ដាក់ជូនសំណើ" មានន័យថា អាសយដ្ឋានផ្ញើសំបុត្រ អាសយដ្ឋានអ៊ីម៉ែល គេហទំព័រ អ៊ីនធឺណិត រ៉ូបផតថលអ៊ីនធឺណិត លេខទូរស័ព្ទហៅគិតថ្លៃ ឬព័ត៌មានទំនាក់ទំនងដែលអាចអនុវត្តបានផ្សេងទៀត ដែលអ្នកប្រើប្រាស់អាចដាក់ជូនសំណើ ឬសេចក្ដីណែនាំក្រោមចំណងជើងនេះ និងរាល់មធ្យោបាយថ្មីណាមួយដែលងាយស្រួលសម្រាប់អ្នកប្រើប្រាស់ក្នុងការទាក់ទងទៅអាជីវកម្ម ដូចដែលបានអនុម័តដោយអគ្គមេធាវីដោយអនុលោមតាមផ្នែកទី 1798.185។

~~(j)~~ *(o)* "ឧបករណ៍" មានន័យថា វត្ថុជារូបវន្តដែលអាចមានសមត្ថភាពទាក់ទងទៅកាន់អ៊ីនធឺណិតដោយផ្ទាល់ ឬដោយប្រយោល ឬទៅកាន់ឧបករណ៍មួយផ្សេងទៀត។

~~(k) "ព័ត៌មានធានារ៉ាប់រងសុខភាព" មានន័យថា លេខគោលការណ៍ធានារ៉ាប់រងសម្រាប់អ្នកប្រើប្រាស់ ឬលេខអត្តសញ្ញាណអ្នកជាវ លក្ខណៈកំណត់អត្តសញ្ញាណខុសប្លែកគេណាមួយដែលត្រូវបានប្រើប្រាស់ដោយអ្នកធានារ៉ាប់រងសុខភាពដើម្បីកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ ឬព័ត៌មានណាមួយនៅក្នុងពាក្យសុំ និងប្រវត្តិទាមទាររបស់អ្នកប្រើប្រាស់ រួមទាំងកំណត់ត្រាមណ្ដើងឧទ្ធរណ៍ ប្រសិនបើព័ត៌មាននោះត្រូវបានតភ្ជាប់ ឬអាចតភ្ជាប់បានដោយសមហេតុផលទៅនឹងអ្នកប្រើប្រាស់ ឬគ្រួសារណាមួយ រួមទាំងតាមរយៈឧបករណ៍មួយ ដោយអាជីវកម្ម ឬអ្នកផ្ដល់សេវា។~~

~~(l)~~ *(p)* "គេហទំព័រ" មានន័យថា ទំព័រផ្ដើមដំបូងនៃគេហទំព័រអ៊ីនធើណិត និងរាល់គេហទំព័រអ៊ីនធើណិតណាមួយដែលព័ត៌មានផ្ទាល់ខ្លួនត្រូវបានប្រមូល។ ករណីជាសេវាតាមអនឡាញ ដូចជាកម្មវិធីទូរស័ព្ទក្នុងចល័ត ទំព័រដើមមានន័យថា ទំព័រវេទិការបស់កម្មវិធី ឬទំព័រទាញយក តំណភ្ជាប់នៅក្នុងកម្មវិធី ដូចជា ពីការកំណត់រចនាសម្ព័ន្ធកម្មវិធី "អំពី" "ព័ត៌មាន" ឬទំព័រការកំណត់ និងរាល់ទីតាំងផ្សេងទៀតដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់ពិនិត្យមើល ~~សេចក្ដីជូនដំណឹង~~ *សេចក្ដីជូនដំណឹងនានា* ដែលតម្រូវដោយ~~ផ្នែករង (a) នៃផ្នែកទី 1798.135~~ *ចំណងជើងនេះ* រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ មុនពេលការទាញយកកម្មវិធីនោះទេ។

(q) "គ្រួសារ" មានន័យថា ក្រុមមួយ ទោះជាយ៉ាងណាមានអត្តសញ្ញាណនៃអ្នកប្រើប្រាស់ដែលរស់នៅរួមជាមួយគ្នានៅអាសយដ្ឋានលំនៅដ្ឋានតែមួយ និងប្រើប្រាស់ឧបករណ៍ ឬសេវារួមគ្នា។

~~(m)~~ *(r)* "សន្និដ្ឋាន" ឬ "ការសន្និដ្ឋាន" មានន័យថា ការទាញយកព័ត៌មាន ទិន្នន័យ ការសន្ទត់ ឬសេចក្ដីសន្និដ្ឋានពីអង្គហេតុ ភ័ស្ដុតាង ឬប្រភពព័ត៌មាន ឬទិន្នន័យផ្សេងទៀត។

(s) "មានអន្តរអំពើដោយចេតនា" មានន័យថា នៅពេលដែលអ្នកប្រើប្រាស់មានចេតនាមានអន្តរអំពើជាមួយបុគ្គលណាម្នាក់ ឬប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួនទៅឲ្យបុគ្គលម្នាក់ តាមរយៈអន្តរអំពើមួយ ឬច្រើនដែលមានលក្ខណៈគិតទុកជាមុន រួមទាំងការចូលទៅគេហទំព័ររបស់បុគ្គលនោះ ឬការជាវទំនិញ ឬសេវាកម្មពីបុគ្គលម្នាក់នោះ។ ការពន្យាពេល ការបង្អន់ ការផ្អាក ឬការបិទចំណែកណាមួយនៃមាតិកា មិនបង្កើតជាចេតនារបស់អ្នកប្រើប្រាស់ក្នុងការមានអន្តរអំពើ ជាមួយបុគ្គលម្នាក់ឡើយ។

(t) "ការផ្សាយពាណិជ្ជកម្មដែលគ្មានលក្ខណៈផ្ទាល់ខ្លួន" មានន័យថា ការផ្សាយពាណិជ្ជកម្ម និងការធ្វើទីផ្សារដែលផ្អែកតែម្យ៉ាងទៅលើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ដែលទទួលបានពីអន្តរអំពើបច្ចុប្បន្នរបស់អ្នកប្រើប្រាស់ជាមួយអាជីវកម្មនោះ ដោយមានការលើកលែងទៅលើទីតាំងភូមិសាស្ត្រជាក់លាក់របស់អ្នកប្រើប្រាស់។

~~(n)~~ *(u)* "បុគ្គល" មានន័យថា បុគ្គលម្នាក់ កម្មសិទ្ធិ សហគ្រាស ដៃគូគម្រោងវិនិយោគចម្រុះ អង្គការចាត់តាំងឡើងដើម្បីប្រយោជន៍រួម មរតក អាជីវកម្ម ក្រុមហ៊ុន សាជីវកម្ម ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត សមាគម គណៈកម្មាធិការ និងអង្គភាព ឬក្រុមនៃបុគ្គលផ្សេងទៀតដែលធ្វើសកម្មភាពជាក្រុម។

~~(o)~~ *(v)* (1) "ព័ត៌មានផ្ទាល់ខ្លួន" មានន័យថា ព័ត៌មានដែលកំណត់អត្តសញ្ញាណ ពាក់ព័ន្ធនឹង បរិយាយ មានសមត្ថភាព *សមហេតុផល* ក្នុងការពាក់ព័ន្ធជាមួយ ឬអាចត្រូវបានតភ្ជាប់ដោយសមហេតុផល ដោយផ្ទាល់ ឬដោយប្រយោល ជាមួយនឹងអ្នកប្រើប្រាស់ ឬគ្រួសារជាក់លាក់មួយ។ ព័ត៌មានផ្ទាល់ខ្លួនរួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះខាងក្រោមនេះ ប្រសិនបើវាកំណត់អត្តសញ្ញាណ ពាក់ព័ន្ធនឹង បរិយាយ មានសមត្ថភាព *សមហេតុផល* ក្នុងការពាក់ព័ន្ធជាមួយ ឬអាចត្រូវបានតភ្ជាប់ដោយសមហេតុផល ដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងអ្នកប្រើប្រាស់ ឬគ្រួសារជាក់លាក់មួយ៖

(A) លក្ខខណ្ឌកំណត់អត្តសញ្ញាណដូចជា ឈ្មោះពិត ឈ្មោះហៅក្រៅ អាសយដ្ឋានប្រៃសណីយ៍ លេខកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនខុសប្លែកពីគេ លេខកំណត់អត្តសញ្ញាណតាមអនឡាញ អាសយដ្ឋានពិធីការអ៊ីនធើណិត អាសយដ្ឋានអ៊ីមែល ឈ្មោះគណនី លេខសន្តិសុខសង្គម លេខប័ណ្ណបើកបរ លេខលិខិតឆ្លងដែន ឬលេខកំណត់អត្តសញ្ញាណស្រដៀងគ្នាផ្សេងទៀត។

(B) រាល់ ~~ប្រភេទទាំងឡាយនៃ~~ ព័ត៌មានផ្ទាល់ខ្លួនដែលមានបរិយាយនៅក្នុងផ្នែករង (e) នៃផ្នែកទី 1798.80។

(C) លក្ខណៈនៃចំណាត់ថ្នាក់ដែលត្រូវបានការពារក្រោមច្បាប់រដ្ឋ California ឬច្បាប់សហព័ន្ធ។

(D) ព័ត៌មានពាណិជ្ជកម្ម រួមមានជាអាទិ៍ដូចជា កំណត់ត្រាអំពីទ្រព្យសម្បត្តិផ្ទាល់ខ្លួន ផលិតផល ឬសេវាកម្មដែលបានជាវ បានទទួល ឬបានពិចារណា ឬប្រវត្តិ ឬនិន្នាការនៃការជាវ ឬការប្រើប្រាស់ផ្សេងទៀត។

(E) ព័ត៌មានជីវមាត្រ។

(F) ព័ត៌មានសកម្មភាពតាមអ៊ីនធឺណិត ឬតាមអេឡិចត្រូនិកផ្សេងទៀត រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ ប្រវត្តិរុករក ប្រវត្តិស្រាវជ្រាវ និងព័ត៌មានដែលទាក់ទងនឹងអន្តរអំពើរបស់អ្នកប្រើប្រាស់ជាមួយនឹងកម្មវិធីគេហទំព័រអ៊ីនធឺណិត ឬការផ្សាយពាណិជ្ជកម្ម។

(G) ទិន្នន័យទីតាំងភូមិសាស្ត្រ។

(H) ព័ត៌មានជាសំឡេង អេឡិចត្រូនិក សោទស្សន៍ នៃកំដៅ នៃឃានវិញ្ញាណ ឬព័ត៌មានស្រដៀងគ្នានេះ។

(I) ព័ត៌មានដែលទាក់ទងនឹងវិជ្ជាជីវៈ ឬការងារ។

(J) ព័ត៌មានអប់រំ ត្រូវបានកំណត់ថាជាព័ត៌មានដែលមិនអាចរកបានជាព័ត៌មានកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនដែលមិនអាចរកបានជាសាធារណៈ ដូចមានកំណត់នៅក្នុងច្បាប់ស្ដីពីសិទ្ធិ និងឯកជនភាពក្នុងការអប់រំរបស់គ្រួសារ (Family Educational Rights and Privacy Act) (20 U.S.C. Sec. 1232g; 34 C.F.R. ភាគទី 99)។

(K) ការសន្និដ្ឋានដែលទាញចេញពីព័ត៌មានណាមួយខាងក្រោមនេះ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងផ្នែករងនេះដើម្បីបង្កើតបាន

24

ជាប្រវត្តិរូបអំពីអ្នកប្រើប្រាស់ ដែលឆ្លុះបញ្ចាំងអំពីចំណង់ចំណូលចិត្ត អត្តចរិក និន្នាការចិត្តសាស្ត្រ ការជម្រុញចិត្ត អាកប្បកិរិយា ឥរិយាបថ បញ្ញា សមត្ថភាព និងសម្បទារបស់អ្នកប្រើប្រាស់។

(L) ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់។

(2) "ព័ត៌មានផ្ទាល់ខ្លួន" មិនរាប់បញ្ចូលនូវព័ត៌មានដែលអាចរកបានជាសាធារណៈ *ឬទទួលបានដោយស្របច្បាប់ ព័ត៌មានពិត ដែលជាបញ្ហាក្តីកង្វល់ជាសាធារណៈ*ទេ។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ "ដែលអាចរកបានជាសាធារណៈ" មានន័យថា៖ ព័ត៌មានដែលត្រូវបានដាក់ឲ្យប្រើប្រាស់ដោយស្របច្បាប់ពីកំណត់ត្រារបស់សហព័ន្ធ រដ្ឋ ឬរដ្ឋាភិបាលថ្នាក់មូលដ្ឋាន*ឬព័ត៌មានដែលអាជីវកម្មមួយមានមូលដ្ឋានសមហេតុផលក្នុងការជឿជាក់ថា ត្រូវបានដាក់ឲ្យប្រើប្រាស់បានដោយស្របច្បាប់ចំពោះសាធារណជនទូទៅដោយអ្នកប្រើប្រាស់ ឬពីប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានចែកចាយយ៉ាងទូលំទូលាយ ឬដោយអ្នកប្រើប្រាស់ ឬព័ត៌មានដែលត្រូវបានដាក់ឲ្យប្រើប្រាស់បានដោយបុគ្គលម្នាក់ដែលអ្នកប្រើប្រាស់នោះបានប្រកាសផ្សាយព័ត៌មាននោះប្រាប់ ប្រសិនបើអ្នកប្រើប្រាស់នោះពុំបានរឹតត្បិតព័ត៌មានចំពោះទស្សនិកជនជាក់លាក់មួយទេនោះ*។ "ដែលអាចរកបានជាសាធារណៈ" ពុំមានន័យថា ព័ត៌មានជីវមាត្រដែលត្រូវបានប្រមូលដោយអាជីវកម្មមួយ អំពីអ្នកប្រើប្រាស់ដោយអ្នកប្រើប្រាស់ពុំបានដឹងខ្លួនទេ។

(3) "ព័ត៌មានផ្ទាល់ខ្លួន" ពុំរាប់បញ្ចូលនូវព័ត៌មានអ្នកប្រើប្រាស់ដែលត្រូវបានបិទបាំងអត្តសញ្ញាណ ឬព័ត៌មានអ្នកប្រើប្រាស់ប្រមូលផ្តុំទេ។

(w) "ទីតាំងភូមិសាស្ត្រជាក់លាក់" មានន័យថា ទិន្នន័យណាមួយដែលទទួលបានពីឧបករណ៍មួយ ហើយដែលត្រូវបានប្រើប្រាស់ ឬមានចេតនាប្រើប្រាស់ដើម្បីកំណត់ទីតាំងអ្នកប្រើប្រាស់នៅក្នុងតំបន់ភូមិសាស្ត្រមួយដែលស្មើនឹង ឬតិចជាងតំបន់នៃរង្វង់មួយដែលមានកាំប្រវែង 1,850 ហ្វីត លើកលែងតែមានចែងដោយនិយ័តកម្មផ្សេងពីនេះ។

~~(p)~~ *(x)* "ព័ត៌មានកំណត់អត្តសញ្ញាណប្លេបាប៊ីលីតេ" គឺជាអត្តសញ្ញាណកម្ម នៃអ្នកប្រើប្រាស់ ឬឧបករណ៍របស់*អ្នកប្រើប្រាស់*រហូតដល់ក្នុងកម្រិតនៃភាពជាក់លាក់ដែល អាចកើតមានច្រើនជាង ការដែលមិនផ្អែកលើប្រភេទណាមួយនៃព័ត៌មានផ្ទាល់ខ្លួន ដែលត្រូវបានរួមបញ្ចូល ឬស្រដៀងនឹងប្រភេទដែលបានរាយនាមនៅក្នុងនិយមន័យនៃព័ត៌មានផ្ទាល់ខ្លួន។

~~(q)~~ *(y)* "ការដំណើរការ" សំដៅលើប្រតិបត្តិការ ឬបណ្តុំនៃប្រតិបត្តិការ ដែលត្រូវបានធ្វើឡើងទៅលើ~~ព័ត៌មាន~~ទិន្នន័យ*ផ្ទាល់ខ្លួន* ឬបណ្តុំនៃ~~ព័ត៌មាន~~ទិន្នន័យ*ផ្ទាល់ខ្លួន*មិនថាតាមឬមិនតាមរយៈមធ្យោបាយស្វ័យប្រវត្តិនោះទេ។

(z) "ជីវប្រវត្តិសាស្ត្រ" សំដៅលើទម្រង់ណាមួយនៃការដំណើរការលើព័ត៌មានផ្ទាល់ខ្លួនដែលបានកំណត់និយមន័យបន្ថែមតាមបទបញ្ញត្តិស្របតាមកថាខណ្ឌ (16) នៃផ្នែករង (a) នៃផ្នែក 1798.185 ដើម្បីវាយតម្លៃទិដ្ឋភាពបុគ្គលជាក់លាក់ទាក់ទងនឹងរូបវន្តបុគ្គល និងជាពិសេសដើម្បីវិភាគ ឬ ព្យាករណ៍ទិដ្ឋភាពពាក់ព័ន្ធនឹងការប្រតិបត្តិរបស់រូបវន្តបុគ្គលនោះនៅកន្លែងធ្វើការ ស្ថានភាពសេដ្ឋកិច្ច សុខភាព ចំណូលចិត្តផ្ទាល់ខ្លួន ចំណាប់អារម្មណ៍ ភាពដែលអាចជឿទុកចិត្តបាន អាកប្បកិរិយា ទីតាំង ឬ បម្លាស់ទី។

~~(r)~~ *(aa)* "ក្លែងអត្តសញ្ញាណ" ឬ "ការក្លែងអត្តសញ្ញាណ" សំដៅលើដំណើរការ នៃព័ត៌មានផ្ទាល់ខ្លួនក្នុងរបៀបមួយដែលធ្វើឲ្យព័ត៌មានផ្ទាល់ខ្លួន លែងអាចដឹងបានថាជារបស់អ្នកប្រើប្រាស់ជាក់លាក់ម្នាក់ ប្រសិនបើមិនប្រើប្រាស់ព័ត៌មានបន្ថែម ករណីដែលព័ត៌មានបន្ថែមនោះត្រូវបានរក្សាទុកដាច់ដោយឡែកហើយត្រូវស្ថិតនៅក្រោមវិធានការបច្ចេកទេសនិងស្ថាប័ន ដើម្បីធានាថាព័ត៌មានផ្ទាល់ខ្លួនមិនត្រូវបានធ្វើឲ្យគេស្គាល់ថាជារបស់អ្នកប្រើប្រាស់ ដែលមានអត្តសញ្ញាណ ឬដែលអាចកំណត់អត្តសញ្ញាណបាន។

~~(s)~~ *(ab)* "ការស្រាវជ្រាវ " សំដៅលើ *ការវិភាគ*លក្ខណៈវិទ្យាសាស្ត្រ ការសិក្សានិងការអង្កេតលក្ខណៈជាប្រព័ន្ធ រួមមានទាំងការស្រាវជ្រាវជាមូលដ្ឋាន ឬការស្រាវជ្រាវអនុវត្តដែលត្រូវបាន*កំណត់ដើម្បីអភិវឌ្ឍ ឬ រួមចំណែកដល់ចំណេះដឹងសាធារណៈ ឬវិទ្យាសាស្ត្រ*ក្នុង~~ផល ប្រយោជន៍សាធារណៈ~~ និងដែលប្រកាន់ខ្ជាប់នូវ *ឬគោរពតាម*ក្រមសីលធម៌ដែលអាចអនុវត្តបាន ទាំងអស់ផ្សេងទៀត និងច្បាប់ឯកជនភាព ម្ន*ជាអាទិ៍ រួមមាន*ការសិក្សាដែលបានធ្វើឡើងក្នុងផលប្រយោជន៍សាធារណៈក្នុងវិស័យសុខភាពសាធារណៈ។ ការស្រាវជ្រាវជាមួយនឹងព័ត៌មានផ្ទាល់ខ្លួនដែលអាចនឹងត្រូវបានប្រមូលយក ពីអ្នកប្រើប្រាស់នៅពេលអ្នកប្រើប្រាស់ធ្វើអន្តរកម្មជាមួយសេវាកម្ម*ឬ*ឧបករណ៍របស់អាជីវកម្មសម្រាប់គោលបំណងផ្សេងទៀតត្រូវ៖

(1) ស្របគ្នាជាមួយនឹងគោលបំណងអាជីវកម្មដែលព័ត៌មានផ្ទាល់ខ្លួននោះត្រូវបានប្រមូលសម្រាប់។

(2) ក្រោយពីត្រូវបានក្លែងអត្តសញ្ញាណ និងបិទបាំងអត្តសញ្ញាណ ឬបិទបាំងអត្តសញ្ញាណទាំងមូល ព័ត៌មាន ទាំងនោះមិនអាចកំណត់អត្តសញ្ញាណ ផ្សារភ្ជាប់ រៀបរាប់ ឬ អាចបង្កើតទំនាក់ទំនង ឬតភ្ជាប់គ្នាដោយសមហេតុផល ដោយផ្ទាល់ ឬដោយប្រយោលទៅនឹងអ្នកប្រើប្រាស់ជាក់លាក់*ដោយ អាជីវកម្ម*បានទេ។

(3) ដាក់ឲ្យស្ថិតនៅក្រោមការការពារផ្នែកបច្ចេកទេសដែលហាមឃាត់អត្តសញ្ញាណកម្មឡើងវិញលើអ្នកប្រើប្រាស់ដែលបានផ្តល់ព័ត៌មាន*ក្រៅពីការចាំបាច់សម្រាប់គាំទ្រដល់ការស្រាវជ្រាវ*។

(4) ស្ថិតនៅក្រោមដំណើរការអាជីវកម្មដែលហាមឃាត់យ៉ាងជាក់លាក់លើអត្តសញ្ញាណកម្មឡើងវិញនៃ ព័ត៌មាន*ក្រៅពីការចាំបាច់ដើម្បី គាំទ្រដល់ការស្រាវជ្រាវ*។

(5) ដាក់ឲ្យស្ថិតនៅក្រោមដំណើរការអាជីវកម្មដើម្បីបង្ការការបែកធ្លាយដោយធ្វេសប្រហែសនៃព័ត៌មានដែលបានបិទបាំងអត្តសញ្ញាណ។

(6) ត្រូវបានការពារពីការប៉ុនប៉ងអត្តសញ្ញាណកម្មឡើងវិញណាមួយ។

(7) ប្រើប្រាស់តែក្នុងគោលបំណងស្រាវជ្រាវដែលត្រូវគ្នានឹងបរិបទ នៃការប្រមូលព័ត៌មានផ្ទាល់ខ្លួន។

(8) ~~មិនត្រូវបានប្រើប្រាស់សម្រាប់គោលបំណងពាណិជ្ជកម្មណាមួយ។~~

~~(9)~~ ត្រូវបានដាក់ដោយអាជីវកម្មដែលធ្វើការស្រាវជ្រាវឲ្យស្ថិតក្រោមការគ្រប់គ្រងសន្តិសុខបន្ថែម ដែលកំណត់ព្រំដែនលើការចូលប្រើទិន្នន័យស្រាវជ្រាវ សម្រាប់តែបុគ្គលិកដែលត្រូ~~វមំពេញ~~ការ~~ កិ~~ច្ចតាមការចាំបាច់ដើម្បីអនុវត្តគោលបំណងនៃការស្រាវជ្រាវតែប៉ុណ្ណោះ។

(ac) "សន្តិសុខនិងភាពសុចរឹត" សំដៅលើសមត្ថភាពរបស់៖

(1) បណ្តាញឬប្រព័ន្ធព័ត៌មានក្នុងការរុករកឧបទ្ទវហេតុសន្តិសុខដែលធ្វើឲ្យខូចភាពដែលអាចប្រើប្រាស់បាន ភាពត្រឹមត្រូវ ភាពសុចរឹត និងភាពសម្ងាត់នៃព័ត៌មានផ្ទាល់ខ្លួនដែលបានរក្សាទុក ឬដែលបានបញ្ជូន។

(2) អាជីវកម្មក្នុងការរុករកឧបទ្ទវហេតុសន្តិសុខ ទប់ទល់ជាមួយសកម្មភាពព្យាបាទ បំភាន់ បន្លំ ឬ ខុសច្បាប់ និងជួយដាក់ទោសជនដែលត្រូវទទួលទោសចំពោះសកម្មភាពទាំងនោះ។

(3) អាជីវកម្មក្នុងការធានានូវសុវត្ថិភាពផ្នែករាងកាយរបស់រូបវន្តបុគ្គល។

~~(t)~~ *(ad)* (1) "លក់" "ការលក់" "ការលក់ដូរ" ឬ "ត្រូវបានលក់" សំដៅលើការលក់ ការជួល ការបញ្ចេញ ការបង្ហាញអោយឃើញ ការផ្សព្វផ្សាយ ការដាក់ឲ្យរកបាន ការផ្ទេរ ឬការប្រាស្រ័យទាក់ទង ដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬដោយប្រព័ន្ធអេឡិចត្រូនិក ឬមធ្យោបាយផ្សេងទៀតលើព័ត៌មានផ្ទាល់ខ្លួនរបស់ អ្នកប្រើប្រាស់ ដោយអាជីវកម្ម

24

ទៅកាន់~~អាជីវកម្មមួយទៀត ~~ ~~ឬ~~ ~~ភាគីទីបីដើម្បីប្រាក់ ~~ ~~ឬ~~ ~~ការពិចារណាដែលមានតម្លៃផ្សេងទៀត~~។

(2) សម្រាប់គោលបំណងនៃចំណងជើងនេះ អាជីវកម្មមិនលក់ព័ត៌មានផ្ទាល់ខ្លួនទេនៅពេល៖

(A) អ្នកប្រើប្រាស់ប្រើប្រាស់ ~~ឬ~~ ~~ណែនាំ~~អាជីវកម្មដោយចេតនាឲ្យ៖

(i) បង្ហាញឲ្យឃើញព័ត៌មានផ្ទាល់ខ្លួន។

(ii) ~~ប្រើប្រាស់~~~~អាជីវកម្ម~~~~ដើម្បី~~~~ធ្វើ~~~~អន្តរកម្ម~~~~ជាមួយ~~~~ភាគីទីបីមួយ ~~ ~~ឬ~~ ~~ច្រើនដោយចេតនា~~។ ~~ករណីដែលភាគីទីបីក៏មិនលក់ព័ត៌មានផ្ទាល់ខ្លួនដែរ លើកលែងតែការបង្ហាញព័ត៌មាននោះនឹងស្របជាមួយនឹងប្រការនៃចំណងជើងនេះ។ អន្តរកម្មដោយចេតនាកើតឡើងនៅពេលដែលអ្នកប្រើប្រាស់មានចេតនាធ្វើអន្តរកម្មជាមួយ~~~~ភាគីទីបីតាមរយៈ~~~~អន្តរកម្ម~~~~ជាក់លាក់មួយ ~~ ~~ឬ~~ ~~ច្រើន។ ~~~~ការ~~~~ពន្យាពេល ~~ ~~ការ~~~~បង្អ~~~~ន់ ~~ ~~ការ~~~~ផ្អាក ~~ ~~ឬ~~ ~~ការ~~~~មិនចំណែកមួយ~~~~នៃ~~~~មាតិកា ~~ ~~មិ~~~~នបង្កើ~~~~ត~~~~ជាចេ~~~~ត~~~~នារ~~~~ប~~~~ស~~~~ស~~~~ អ~~~~ ~~ ~~

(D) ការរួមបញ្ចូលគ្នានូវព័ត៌មានផ្ទាល់ខ្លួនដែលក្រុមហ៊ុនផ្តល់សេវាកម្ម ទទួលបានពី ឬក្នុងនាមអាជីវកម្មជាមួយ ព័ត៌មានផ្ទាល់ខ្លួនដែលខ្លួនទទួលបានពី ឬក្នុងនាមមនុស្សផ្សេងទៀត ឬដែលប្រមូលបានពីទំនាក់ទំនងផ្ទាល់របស់ខ្លួនជាមួយអ្នកប្រើប្រាស់ ករណីដែលក្រុមហ៊ុនផ្តល់សេវាកម្ម អាចរួមបញ្ចូលព័ត៌មានផ្ទាល់ខ្លួនដើម្បីប្រតិបត្តិគោលបំណងអាជីវកម្ម ណាមួយដូចដែលមានចែងក្នុងបទបញ្ញត្តិ ដែលត្រូវបានអនុម័តស្របតាមកថាខណ្ឌ (10) នៃផ្នែករង (a) នៃផ្នែក 1798.185 លើកលែងតែមានការចែងក្នុងកថាខណ្ឌ (6) នៃផ្នែករង (e) នៃផ្នែកនេះ និងក្នុងបទបញ្ញត្តិដែលត្រូវបានអនុម័ត ដោយទីភ្នាក់ងារការពារឯកជនភាពរដ្ឋ California ។ ជាកម្មវត្ថុចំពោះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនផ្តល់សេវាកម្ម កិច្ចសន្យាអាចអនុញ្ញាតឱ្យអាជីវកម្មពិនិត្យ តាមដានលើអនុលោមភាពរបស់ក្រុមហ៊ុនផ្តល់សេវាកម្មទៅនឹងកិច្ចសន្យាតាមរយៈការវាស់វែងនានា ជាអាទិ៍រួមមានការពិនិត្យមើលដោយដៃដែលកំពុងបន្ត និងការស្ទង់ដោយ ស្វ័យប្រវត្តិ និងការវាយតម្លៃជាប្រចាំ សវនកម្ម ឬការធ្វើតេស្តបច្ចេកទេសនិងប្រតិបត្តិការផ្សេងៗ យ៉ាងហោច ណាស់ម្តងក្នុងរយៈពេល 12 ខែ។

(2) ប្រសិនបើក្រុមហ៊ុនផ្តល់សេវាកម្មចូលរួមជាមួយបុគ្គលផ្សេងទៀតណាម្នាក់ឱ្យជួយខ្លួនក្នុងការដំណើរការព័ត៌មានផ្ទាល់ខ្លួនសម្រាប់គោលបំណងអាជីវកម្មក្នុងនាមអាជីវកម្ម ឬប្រសិនបើបុគ្គលផ្សេងទៀតណាម្នាក់ដែលត្រូវបានអនុញ្ញាតឱ្យចូលរួមដោយក្រុមហ៊ុនផ្តល់សេវាចូលរួម ជាមួយបុគ្គលម្នាក់ផ្សេងទៀតឱ្យជួយក្នុងការដំណើរការព័ត៌មានផ្ទាល់ខ្លួនសម្រាប់គោលបំណង អាជីវកម្មនោះ ក្រុមហ៊ុនផ្តល់សេវាកម្មត្រូវជូនដំណឹងដល់អាជីវកម្មអំពីការចូលរួម ពាក់ព័ន្ធនោះហើយ ការចូលរួមពាក់ព័ន្ធនោះត្រូវធ្វើឡើងដោយ អនុលោមតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សរដែលចងភ្ជាប់ កាតព្វកិច្ចបុគ្គលផ្សេងនោះឱ្យគោរពតាមលក្ខខណ្ឌតម្រូវទាំងអស់ដែលមានចែងក្នុងកថាខណ្ឌ (1)។

(ah) (1) "ចែកចាយ" "ត្រូវបានចែកចាយ" ឬ "ការចែកចាយ" មានន័យថាការចែកចាយ ការជួល ការបញ្ចេញ ការបង្ហាញ ការផ្សព្វផ្សាយ ការធ្វើឱ្យអាចរកបាន ការផ្ទេរ ឬបើមិនដូច្នោះទេការប្រាប់ដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬតាមរយៈអេឡិចត្រូនិច ឬមធ្យោបាយផ្សេងៗនូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដោយអាជីវកម្មទៅកាន់ភាគីទីបី សម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្មអាកប្បកិរិយាឆ្លងបរិបទ មិនថាដើម្បីប្រាក់ ឬតម្លៃផ្សេងទៀត រួមទាំងប្រតិបត្តិការរវាងអាជីវកម្មនិងភាគីទីបីសម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្មអាកប្បកិរិយាឆ្លងបរិបទ ដើម្បីជាប្រយោជន៍របស់អាជីវកម្មដែលមិនមានការដោះដូរប្រាក់។

(2) សម្រាប់គោលបំណងនៃចំណងជើងនេះ អាជីវកម្មមិនចែកចាយ ព័ត៌មានផ្ទាល់ខ្លួនទេនៅពេល៖

(A) អ្នកប្រើប្រាស់ ប្រើប្រាស់ឬណែនាំឱ្យអាជីវកម្មបង្ហាញអោយឃើញ ព័ត៌មានផ្ទាល់ខ្លួន ដោយចេតនា ឬទាក់ទងដោយចេតនាជាមួយភាគីទីបីមួយ ឬច្រើន។

(B) អាជីវកម្មប្រើប្រាស់ឬចែកចាយព័ត៌មានកំណត់អត្តសញ្ញាណ សម្រាប់អ្នកប្រើប្រាស់ដែលបានជ្រើសរើសមិនចូលរួមការចែករំលែក ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ឬបានកំណត់ព្រំដែនការប្រើប្រាស់ ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់សម្រាប់ គោលបំណងនៃការ រំលឹកបុគ្គលដែលអ្នកប្រើប្រាស់បានជ្រើសរើសមិនចូលរួមការចែក រំលែក ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ឬបានកំណត់ព្រំដែនការប្រើប្រាស់ ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់។

(C) អាជីវកម្មផ្ទេរទៅភាគីទីបីនូវព័ត៌មានរបស់អ្នកប្រើប្រាស់ក្នុងនាមជាទ្រព្យសម្បត្តិដែលជាផ្នែកមួយនៃការដាក់បញ្ចូលគ្នាការទទួលយកការ ក្ស័យធន ឬប្រតិបត្តិការផ្សេងទៀតដែលភាគីទីបីទទួលបន្ទុកគ្រប់គ្រងទាំងស្រុង ឬមួយផ្នែកលើអាជីវកម្ម ករណីដែលព័ត៌មានត្រូវបានប្រើប្រាស់ ឬចែកចាយស្របតាមចំណងជើងនេះ។ ប្រសិនបើភាគីទីបីផ្ទាស់ប្តូរយ៉ាងច្រើនលើរបៀបដែលខ្លួនប្រើប្រាស់ ឬចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ក្នុងលក្ខណៈដែលមិនស្របគ្នាយ៉ាងខ្លាំងជាមួយនឹងការសន្យាដែលបានធ្វើនៅពេល ប្រមូលនោះ ភាគីនោះត្រូវផ្តល់ការជូនដំណឹងជាមុនអំពីការអនុវត្តថ្មី ឬការអនុវត្តដែលបានផ្ទាស់ប្តូរជូន ដល់អ្នកប្រើប្រាស់។ ការជូនដំណឹងត្រូវមានភាពច្បាស់លាស់និងម៉ត់ចត់គ្រប់គ្រាន់ដើម្បីធានាថា អ្នកប្រើប្រាស់ដែលមានងាយប្រើប្រាស់ ជម្រើសរបស់ពួកគេស្របតាមចំណងជើងនេះ។ អនុកថាខណ្ឌនេះមិនអនុញ្ញាតឲ្យអាជីវកម្មធ្វើការផ្ទាស់ប្តូរគោលការណ៍ឯកជនភាពដ៏ច្រើន និងប្រតិសកម្ម ឬធ្វើការផ្ទាស់ប្តូរផ្សេងទៀតនៅក្នុងគោលការណ៍ឯកជនភាព របស់ពួកគេក្នុងរបៀបដែលនឹងរំលោភបំពានលើក្រមច្បាប់ ស្តីពីការអនុវត្តមិនត្រឹមត្រូវនិងបំភាន់ឡើយ (ជំពូក 5 [ចាប់ផ្តើមជាមួយនឹងផ្នែក 17200] នៃភាគ 2 នៃផ្នែក 7 នៃក្រមអាជីវកម្ម និងវិជ្ជាជីវៈ)។

~~(w)~~ *(ai)* "ភាគីទីបី" សំដៅលើបុគ្គលដែលមិនមែនណាមួយដូចខាងក្រោម៖

(1) អាជីវកម្ម*ដែលអ្នកប្រើប្រាស់ធ្វើអន្តរកម្មដោយចេតនាជាមួយ*ហើយ*ដែលប្រមូលព័ត៌មានផ្ទាល់ខ្លួនពីអ្នកប្រើប្រាស់ជាផ្នែកនៃអន្តរកម្ម*ជាមួយ*~~អ្នកប្រើ~~ប្រាស់*អាជីវកម្ម*ក្រោមចំណងជើងនេះ។

(2) *អ្នកផ្តល់សេវាកម្ម*ឱ្យ*អាជីវកម្ម*។

(3) អ្នកម៉ៅការ។

~~(A) បុគ្គលដែលអាជីវកម្មបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ សម្រាប់គោលបំណងអាជីវកម្មស្របតាម កិច្ចសន្យាជាលាយលក្ខណ៍អក្សរ ក្នុងករណីដែលកិច្ចសន្យា៖~~

~~(i) ហាមឃាត់បុគ្គលពីការទទួលព័ត៌មានផ្ទាល់ខ្លួនពី៖~~

~~(I) ការលក់ព័ត៌មានផ្ទាល់ខ្លួន។~~

~~(ii) ការរក្សា ការប្រើប្រាស់ ឬការប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួនសម្រាប់គោលបំណងណាមួយក្រៅពីគោលបំណងជាក់លាក់នៃការអនុវត្ត សេវាកម្មដែលមានបញ្ជាក់នៅក្នុងកិច្ចសន្យា រួមមានជាអាទិ៍ ការរក្សា ការប្រើប្រាស់ ឬការប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួនសម្រាប់គោលបំណងពាណិជ្ជកម្មក្រៅពីការផ្តល់សេវាកម្មដែលមានបញ្ជាក់នៅក្នុងកិច្ចសន្យា។~~

~~(III) ការរក្សាទុក ការប្រើប្រាស់ ឬការបង្ហាញព័ត៌មានទៅខាងក្រៅនៃ ទំនាក់ទំនងអាជីវកម្មផ្ទាល់ រវាងបុគ្គលនិងអាជីវកម្ម។~~

~~(ii) រួមបញ្ចូលការបញ្ជាក់ដោយបុគ្គលិកដែលទទួលព័ត៌មានផ្ទាល់ខ្លួន ថាបុគ្គលនោះយល់អំពីការរឹតបន្តឹងនៅក្នុង អនុកថាខណ្ឌ (A) ហើយនឹងគោរពតាមការរឹតបន្តឹងនោះ។~~

~~(B) បុគ្គលដែលត្រូវបានគ្របដណ្តប់នៅក្នុងកថាខណ្ឌនេះ ដែលរំលោភបំពានលើការរឹតបន្តឹងណាមួយដែលបានចែង នៅក្នុងចំណងជើងនេះត្រូវទទួលខុសត្រូវចំពោះការរំលោភបំពាននោះ។ អាជីវកម្មដែលប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួនទៅកាន់បុគ្គលម្នាក់ ដែលត្រូវបានគ្របដណ្តប់ដោយកថាខណ្ឌនេះអនុលោមតាមកថាខណ្ឌនេះ មិនត្រូវទទួលខុសត្រូវក្រោមចំណងជើងនេះឡើយ ប្រសិនបើអ្នកបុគ្គលដែលទទួលព័ត៌មានផ្ទាល់ខ្លួននោះប្រើប្រាស់វាដោយរំលោភបំពានទៅលើការរឹតត្បិតទាំងឡាយដូចមានចែងនៅក្នុងចំណងជើងនេះ ករណីដែលនៅពេលនៃប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួននោះ អាជីវកម្មមិនបានដឹងជាក់ស្តែង ឬពុំមានហេតុផលដែលត្រូវជឿថា បុគ្គលនោះមានចេតនាប្រព្រឹត្តការរំលោភបំពាននេះ។~~

~~(x)~~ *(aj)* "ព័ត៌មានសម្គាល់អត្តសញ្ញាណតែមួយគត់" ឬ "ព័ត៌មានសម្គាល់អត្តសញ្ញាណផ្ទាល់ខ្លួនតែមួយគត់" សំដៅលើព័ត៌មានកំណត់អត្តសញ្ញាណជាប់លាប់ដែលអាចត្រូវបាន ប្រើប្រាស់ដើម្បីស្គាល់អ្នកប្រើប្រាស់ គ្រួសារ ឬឧបករណ៍ដែលត្រូវបានតភ្ជាប់ទៅអ្នកប្រើប្រាស់ ឬគ្រួសារនៅរយៈពេលមួយ និងទូទាំងសេវាកម្មផ្សេងៗគ្នាជាអាទិ៍រួមមានព័ត៌មានកំណត់អត្តសញ្ញាណ ឧបករណ៍ អាសយដ្ឋានពិធីការអ៊ីនធឺណិត ឃុកឃី ប៊ីខន់ ស្លាកភ្ជាប់ភីកសែល ព័ត៌មានសម្គាល់អត្តសញ្ញាណពាណិជ្ជកម្មចល័ត ឬបច្ចេកវិទ្យាស្រដៀងគ្នានេះ លេខសម្គាល់អតិថិជន ឈ្មោះក្លែងក្លាយតែមួយគត់ ឬឈ្មោះហៅក្រៅអ្នកប្រើប្រាស់ លេខទូរស័ព្ទ ឬទម្រង់ផ្សេងទៀតនៃព័ត៌មានសម្គាល់អត្តសញ្ញាណជាប់លាប់ ឬអាចនឹងមាន ដែលអាចត្រូវបានប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ជាក់លាក់ឬ ឧបករណ៍ជាក់លាក់*ដែលត្រូវបានតភ្ជាប់ទៅអ្នកប្រើប្រាស់ ឬគ្រួសារ*។ សម្រាប់គោលបំណងនៃអនុផ្នែកនេះ "គ្រួសារ" សំដៅលើឪពុកម្តាយដែលថែទាំ ឬអាណាព្យាបាល និង~~កុមារ ជាអនីតិជន~~ *អាយុក្រោម 18 ឆ្នាំ* ដែលនៅក្រោមបន្ទុករបស់ឪពុកម្តាយ ឬ អាណាព្យាបាល។

~~(y)~~ *(ak)* "សំណើរបស់អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បាន" សំដៅលើ សំណើដែល ធ្វើដោយដោយអ្នកប្រើប្រាស់ ដោយអ្នកប្រើប្រាស់ជំនួសឲ្យកុមារអនីតិជនរបស់អ្នកប្រើប្រាស់ ឬដោយរូបវន្តបុគ្គល ឬបុគ្គលដែលបានចុះឈ្មោះជាមួយរដ្ឋលេខាធិការ ដែលបានប្រគល់សិទ្ធិដោយអ្នកប្រើប្រាស់ដើម្បីធ្វើសកម្មភាពជំនួសអ្នកប្រើប្រាស់ *ឬដោយបុគ្គលដែលមានអំណាចមេធាវី ឬដើរតួជាអ្នកអភិរក្សសម្រាប់អ្នកប្រើប្រាស់* និងថាអាជីវកម្មអាច~~ដោយសមហេតុផល~~ ផ្ទៀងផ្ទាត់*ដោយប្រើប្រាស់វិធីសាស្ត្រសមហេតុផលតាមលក្ខណៈពាណិជ្ជកម្ម*ស្របតាមបទបញ្ញត្តិដែលបានអនុម័តដោយ អគ្គមេធាវីស្របតាមកថាខណ្ឌ (7) នៃផ្នែករង (a) នៃផ្នែក 1798.185 ថាជាអ្នកប្រើប្រាស់ដែលត្រូវបានអាជីវកម្មប្រមូលព័ត៌មានផ្ទាល់ខ្លួន។ អាជីវកម្មមិនមានកាតព្វកិច្ចផ្តល់ព័ត៌មានទៅអ្នកប្រើប្រាស់ស្របតាមផ្នែក 1798.110 និង 1798.115 *ដើម្បីលុបព័ត៌មានផ្ទាល់ខ្លួនស្របតាមផ្នែក 1798.105 ឬកែតម្រូវព័ត៌មានផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវស្របតាមផ្នែក 1798.106* ទេ ប្រសិនបើអាជីវកម្មមិនអាចផ្ទៀងផ្ទាត់ស្របតាមផ្នែករងនេះ និងបទបញ្ញត្តិដែលបានអនុម័តដោយ អគ្គមេធាវីស្របតាមកថាខណ្ឌ (7) នៃ ផ្នែករង (a) នៃផ្នែក 1798.185 ដែលអ្នកប្រើប្រាស់កំពុងធ្វើការស្នើសុំគឺជាអ្នកប្រើប្រាស់ដែលអាជីវកម្មបានប្រមូលព័ត៌មានផ្ទាល់ខ្លួន ឬជាបុគ្គលិកដែលត្រូវបានប្រគល់សិទ្ធិដោយអ្នកប្រើប្រាស់ដើម្បីធ្វើកិច្ចការនេះ ជំនួសអ្នកប្រើប្រាស់នោះ។

ផ្នែក 15. ផ្នែក 1798.145 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដូចមានចែង៖

1798.145. ការលើកលែង

~~1798.145.~~ (a) កាតព្វកិច្ចដែលបានដាក់ទៅលើអាជីវកម្មដោយចំណងជើងនេះ មិនត្រូវរឹតបន្តឹងសមត្ថភាពរបស់អាជីវកម្មក្នុងការ៖

(1) គោរពតាមច្បាប់សហព័ន្ធ ច្បាប់រដ្ឋ ឬច្បាប់មូលដ្ឋាន *ឬគោរពតាមដីការបស់តុលាការ ឬដីការ កោះហៅដើម្បីផ្តល់ព័ត៌មាន*។

(2) អនុលោមតាមការសាកសួរ ការស៊ើបអង្កេត ដីការ ការកោះហៅ ឬការកោះអញ្ជើញដោយសហព័ន្ធ រដ្ឋ ឬអាជ្ញាធរមូលដ្ឋានរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬបញ្ញត្តិកម្ម ។ *ទីភ្នាក់ងារអនុវត្តច្បាប់ដែលរួមមាននាយកដ្ឋានប៉ូលីសនិងនគរបាល អាចណែនាំអាជីវកម្មដោយអនុលោមតាមការស៊ើបអង្កេត ដែលបានអនុម័តដោយទីភ្នាក់ងារអនុវត្តច្បាប់ដែលមានលេខសំណុំរឿងសកម្ម មិនឱ្យលុបព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ហើយបន្ទាប់ពីបានទទួលការណែនាំនោះ អាជីវកម្ម មិនត្រូវលុបព័ត៌មានផ្ទាល់ខ្លួនក្នុងរយៈពេល 90 ថ្ងៃ ដើម្បីអនុញ្ញាតឱ្យទីភ្នាក់ងារអនុវត្តច្បាប់ទទួលបានដីការ ការកោះហៅ ឬភស្តុតាងដែលចេញដោយតុលាការ ដើម្បីទទួលបានព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។ សម្រាប់បុព្វហេតុ ល្អ និងទៅតាមកម្រិតដែលចាំបាច់សម្រាប់គោលបំណងស៊ើបអង្កេត ទីភ្នាក់ងារ អនុវត្តច្បាប់អាចណែនាំអាជីវកម្មមិនឱ្យលុបព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់សម្រាប់រយៈពេល 90 ថ្ងៃបន្ថែមទៀត។ អាជីវកម្មដែលបានទទួលការណែនាំពីទីភ្នាក់ងារអនុវត្តច្បាប់មិនឱ្យលុបព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដែលបានស្នើសុំការលុបព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់មិនត្រូវប្រើព័ត៌មានផ្ទាល់ខ្លួន របស់អ្នកប្រើប្រាស់ សម្រាប់គោលបំណងណាមួយក្រៅពីការរក្សាទុកវាដើម្បីបង្កើតការ អនុវត្តច្បាប់ជាការឆ្លើយតបទៅនឹងដីការ ការកោះហៅ ឬភស្តុតាងដែលចេញដោយតុលាការឡើយ លើកលែងតែសំណើសុំលុបរបស់អ្នកប្រើប្រាស់ស្ថិតក្រោមការលើកលែងពីការលុបក្រោមចំណងជើងនេះ។*

(3) សហប្រតិបត្តិការជាមួយភ្នាក់ងារអនុវត្តច្បាប់ទាក់ទងនឹងការអនុវត្ត ឬ សកម្មភាពដែលអាជីវកម្ម អ្នកផ្តល់សេវា ឬភាគីទីបី ដោយសមហេតុផល និងជឿដោយក្តីទុកចិត្តថា អាចរំលោភបំពានច្បាប់សហព័ន្ធ រដ្ឋ ឬមូលដ្ឋាន។

(4) សហប្រតិបត្តិការជាមួយស្នើសុំរបស់ភ្នាក់ងាររដ្ឋាភិបាលសម្រាប់ការចូលដំណើរការព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ក្នុងគ្រាអាសន្ន ប្រសិនបើរូបវន្តបុគ្គលកំពុងមានហានិភ័យ ឬគ្រោះថ្នាក់ដល់អាយុជីវិត ឬ រងរបួសផ្នែករាងកាយធ្ងន់ធ្ងរ ករណីដែល៖

(A) សំណើត្រូវបានអនុម័តដោយមន្ត្រីទីភ្នាក់ងារជាន់ខ្ពស់សម្រាប់ ការចូលដំណើរការជាបន្ទាន់លើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់។

(B) សំណើគឺផ្អែកលើការប្តេជ្ញាចិត្តស្មោះត្រង់របស់ភ្នាក់ងារថាវាមានមូលដ្ឋានស្របច្បាប់ដើម្បីចូលប្រើប្រាស់ព័ត៌មានលើមូលដ្ឋានដែលមិនបន្ទាន់។

(C) ទីភ្នាក់ងារយល់ព្រមក្នុងការដាក់ញត្តិទៅតុលាការសម្រាប់ដីកាដែលសមរម្យក្នុងរយៈពេលបីថ្ងៃ និងបំផ្លាញព័ត៌មានចោលប្រសិនបើដីកានោះមិនត្រូវបានផ្តល់អោយ។

~~(4)~~ *(5)* អនុវត្ត ឬការពារការអះអាងតាមផ្លូវច្បាប់។

~~(5)~~ *(6)* ប្រមូល ប្រើប្រាស់ ទទួលបាន លក់ *ចែកចាយ* ឬបង្ហាញ~~អ្នកប្រើប្រាស់ នូវព័ត៌មាន~~ *ផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់* ដែលត្រូវបានបិទបាំងអត្តសញ្ញាណ ឬ~~នៅ~~ក្នុងព័ត៌មានអ្នកប្រើប្រាស់រួម។

~~(6)~~ *(7)* ប្រមូល ឬលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួន របស់ អ្នកប្រើប្រាស់ ប្រសិនបើគ្រប់ទិដ្ឋភាពនៃទង្វើពាណិជ្ជកម្ម កើតឡើងទាំងស្រុងនៅខាងក្រៅរដ្ឋ California។ សម្រាប់គោលបំណងនៃចំណងជើងនេះ ប្រតិបត្តិការពាណិជ្ជកម្មកើតឡើងនៅក្រៅរដ្ឋ California ទាំងស្រុង ប្រសិនបើអាជីវកម្មបានប្រមូលព័ត៌មាននោះ ខណៈពេលអ្នកប្រើប្រាស់ស្ថិតនៅក្រៅរដ្ឋ California គ្មានផ្នែកណាមួយនៃការលក់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់កើតឡើងនៅរដ្ឋ California ឡើយហើយក៏គ្មានព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូល ខណៈដែលអ្នកប្រើប្រាស់ស្ថិតនៅក្នុងរដ្ឋ California ត្រូវបានលក់ផងដែរ។ កថាខណ្ឌនេះមិនត្រូវ~~អនុញ្ញាត~~ *ហាមឃាត់* អាជីវកម្ម ពីការរក្សាទុកដែលរួមមាន ព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកប្រើប្រាស់នៅលើ ឧបករណ៍ ពេលដែលអ្នកប្រើប្រាស់ស្ថិតក្នុងរដ្ឋ California ហើយ បន្ទាប់មកការប្រមូលព័ត៌មានផ្ទាល់ខ្លួននោះ ពេលដែលអ្នកប្រើប្រាស់ និង ព័ត៌មានផ្ទាល់ខ្លួន ដែលបានរក្សាទុក ស្ថិតនៅក្រៅរដ្ឋ California ឡើយ។

(b) កាតព្វកិច្ចដែលតម្រូវលើអាជីវកម្មដោយផ្នែក 1798.110, *1798.115, 1798.120, 1798.121, 1798.130, និង* ~~ដល់~~ 1798.135 ~~រួមបញ្ចូលគ្នា~~ មិនត្រូវអនុវត្តនៅកន្លែងដែលអនុលោមភាពដោយអាជីវកម្មក្រោមចំណងជើងនេះអាចរំលោភបំពានឯកសិទ្ធិភស្តុតាងស្ថិតក្រោមច្បាប់រដ្ឋ California ហើយមិនត្រូវរារាំងអាជីវកម្មពីការផ្តល់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ប្រើប្រាស់ទៅកាន់បុគ្គលដែលត្រូវបានគ្រប

ដណ្តប់ដោយឯកសិទ្ធិភស្តុតាង ស្ថិតក្រោមច្បាប់រដ្ឋ California ជាផ្នែកនៃទំនាក់ទំនងដែលមានឯកសិទ្ធិ។

(c) (1) ចំណងជើងនេះមិនអនុវត្តលើករណីដូចខាងក្រោម៖

(A) ព័ត៌មានវេជ្ជសាស្ត្រដែលត្រូវបានគ្រប់គ្រងដោយក្រមច្បាប់ស្តីពីកាសម្ងាត់ព័ត៌មានវេជ្ជសាស្ត្រ (Confidentiality of Medical Information Act) សាស្ត្រ [ភាគ 2.6 (ចាប់ផ្តើមជាមួយនឹងផ្នែក 56] នៃផ្នែក 1) ឬ ព័ត៌មានសុខភាពដែលបានការពារដែលត្រូវបានប្រមូលដោយអង្គភាពដែលត្រូវបានការពារ ឬដៃគូអាជីវកម្មដែលគ្រប់គ្រងដោយច្បាប់ជូនដំណឹង ពីឯកជនភាព សុវត្ថិភាព និង ការបែកធ្លាយដែលចេញដោយក្រសួងសុខាភិបាលនិង សេវាកម្មមនុស្សជាតិសហរដ្ឋអាមេរិក ភាគ 160 និង 164 នៃចំណងជើង 45 ក្នុងក្រមច្បាប់នៃបទ បញ្ញត្តិសហព័ន្ធដែលបានបង្កើតឡើងស្របតាមក្រមច្បាប់ស្តីពីការចល័តនិងការទទួលខុសត្រូវការធានារ៉ាប់រងសុខភាព ឆ្នាំ 1996 (ច្បាប់សាធារណៈ 104-191) និងក្រមច្បាប់ស្តីពី បច្ចេកវិទ្យាព័ត៌មានសុខភាពសម្រាប់សេដ្ឋកិច្ចនិងសុខភាពគ្លីនិក (Health Information Technology for Economic and Clinical Health Act) (ច្បាប់សាធារណៈ 111-5)។

(B) អ្នកផ្តល់សេវាកម្មថែទាំសុខភាពដែលគ្រប់គ្រងដោយក្រមច្បាប់ស្តីពីការសម្ងាត់នៃព័ត៌មានវេជ្ជសាស្ត្រ (ផ្នែក 2.6 [ចាប់ផ្តើមជាមួយនឹងផ្នែក 56] នៃផ្នែក 1) ឬអង្គភាពគ្របដណ្តប់ដែលបានគ្រប់គ្រងដោយច្បាប់ជូនដំណឹងឯកជនភាព សុវត្ថិភាព និងការបែកធ្លាយដែលចេញដោយក្រសួងសុខាភិបាលនិងសេវាកម្មមនុស្សជាតិសហរដ្ឋអាមេរិក ភាគ 160 និង 164 នៃ ចំណងជើង 45 ក្នុងក្រមច្បាប់នៃបទបញ្ញត្តិសហព័ន្ធដែលបានបង្កើតឡើងស្របតាមក្រមច្បាប់ស្តីពីការចល័ត និងការទទួលខុសត្រូវការធានារ៉ាប់រងសុខភាពឆ្នាំ 1996 (ច្បាប់សាធារណៈ 104-191) ទៅដល់ កម្រិតដែលអ្នកផ្តល់សេវា ឬអង្គភាពដែលបានគ្របដណ្តប់ រក្សាទុកនូវព័ត៌មានរបស់អ្នកជំងឺតាមរបៀបដូចគ្នានឹងព័ត៌មានវេជ្ជសាស្ត្រ ឬព័ត៌មានសុខភាពដែលបានការពារដូចដែលបានរៀបរាប់ ក្នុងអនុកថា ខណ្ឌ (A) នៃផ្នែកនេះ។

(C) *ព័ត៌មានផ្ទាល់ខ្លួន ~~ផ្ទាល់ខ្លួន~~ ព័ត៌មាន* ដែលបានប្រមូលជាផ្នែកនៃការព្យាបាលសាកល្បង *ឬការសិក្សាស្រាវជ្រាវជីវវេជ្ជសាស្ត្រផ្សេងទៀត*ដែលស្ថិតនៅក្រោម *ឬបានអនុវត្តស្របតាម*គោលនយោបាយសហព័ន្ធសម្រាប់ការការពារអ្នកស្ម័គ្រចិត្តដែលត្រូវបាន គេស្គាល់ផងដែរថាជាបទបញ្ជាទូទៅស្របតាមគោលការណ៍ណែនាំការអនុវត្តគ្លីនិកល្អដែលបានចេញដោយក្រុមប្រឹក្សាអន្តរជាតិសម្រាប់ភាពសុខដុមនីយកម្ម ឬស្របតាមលក្ខខណ្ឌតម្រូវការការពារអ្នកស្ម័គ្រចិត្តរបស់រដ្ឋបាលចំណីអាហារនិងឱសថសហរដ្ឋអាមេរិក *ករណីដែលព័ត៌មាននោះមិនត្រូវបានលក់ ឬចែកចាយក្នុងរបៀបដែលមិនត្រូវបានអនុញ្ញាតដោយអនុកថា ខណ្ឌនេះ ហើយប្រសិនបើវាមិនស្របគ្នា នោះអ្នកចូលរួមនឹងត្រូវបានជូនដំណឹងអំពីការប្រើប្រាស់ និងផ្តល់ការអនុញ្ញាតនោះ។*

(2) សម្រាប់គោលបំណងនៃផ្នែករងនេះ និយមន័យនៃពាក្យ "ព័ត៌មានវេជ្ជសាស្ត្រ" និង "អ្នកផ្តល់ សេវាថែទាំសុខភាព" នៅក្នុងផ្នែក 56.05 ត្រូវអនុវត្ត ហើយនិយមន័យនៃពាក្យ "ដៃគូអាជីវកម្ម" "អង្គភាពគ្របដណ្តប់" និង "ព័ត៌មានសុខភាពដែលត្រូវបានការពារ" នៅក្នុងផ្នែក 160.103 នៃ ចំណងជើង 45 នៃក្រមបទបញ្ញត្តិសហព័ន្ធត្រូវអនុវត្តផងដែរ។

(d) *(1)* ចំណងជើងនេះមិនត្រូវអនុវត្តលើសកម្មភាពដែលពាក់ព័ន្ធនឹងការប្រមូល ការថែរក្សា ការបង្ហាញ ការលក់ ការប្រាស្រ័យទាក់ទង ឬការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនណាមួយ ទាក់ទងនឹងភាពគួរបានទទួលឥណទាន ស្ថានភាពឥណទាន លទ្ធភាពឥណទាន ចរិកលក្ខណៈ កិត្តិយសទូទៅ បុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ឬបែបបទនៃការរស់នៅដោយទីភ្នាក់ងាររាយការណ៍ពីអ្នកប្រើប្រាស់ ដូចបានចែងនៅក្នុងផ្នែករង (f) នៃ ផ្នែក 1681a នៃចំណងជើង 15 នៃ ក្រមច្បាប់សហរដ្ឋអាមេរិក ដោយអ្នកផ្តល់ព័ត៌មានដូចមានចែងនៅក្នុងផ្នែក 1681s-2 នៃចំណងជើង 15 នៃក្រមច្បាប់សហរដ្ឋអាមេរិក ដែលផ្តល់ព័ត៌មានសម្រាប់ការប្រើប្រាស់នៅក្នុងរបាយការណ៍អ្នកប្រើប្រាស់ដូចបានកំណត់នៅក្នុងផ្នែករង (d) នៃផ្នែក 1681a នៃចំណងជើង 15 នៃក្រមច្បាប់សហរដ្ឋអាមេរិច និងដោយអ្នកប្រើប្រាស់នៃរបាយការណ៍អ្នកប្រើប្រាស់ដូចមានចែងនៅក្នុងផ្នែគ 1681b នៃចំណងជើង 15 នៃក្រមច្បាប់សហរដ្ឋអាមេរិក។

(2) កថាខណ្ឌ (1) ត្រូវអនុវត្តតែត្រឹមកម្រិតដែលសកម្មភាពនោះពាក់ព័ន្ធនឹងការប្រមូល ការថែរក្សា ការបង្ហាញ ការលក់ ការប្រាស្រ័យទាក់ទង ឬការប្រើប្រាស់ព័ត៌មានបែបនោះដោយ ទីភ្នាក់ងារនោះ អ្នកផ្តល់ ឬអ្នកប្រើប្រាស់ស្ថិតក្រោមបទបញ្ញត្តិ នៅក្រោមក្រមច្បាប់ស្តីពីការរាយការណ៍ឥណទានត្រឹមត្រូវ (Fair Credit Reporting Act) ផ្នែក 1681 et seq. ចំណងជើង 15 នៃក្រមច្បាប់សហរដ្ឋអាមេរិក ហើយ ព័ត៌មានមិនត្រូវបាន*ប្រមូល ~~ថែរក្សា~~* ប្រើប្រាស់ ប្រាស្រ័យទាក់ទង បង្ហាញ ឬលក់ឡើយ លើកលែងតែត្រូវបានប្រគល់សិទ្ធិដោយក្រមច្បាប់ស្តីពីការរាយការណ៍ឥណទានត្រឹមត្រូវ។

(3) ផ្នែករងនេះមិនត្រូវអនុវត្តលើផ្នែក 1798.150 ទេ។

(e) ចំណងជើងនេះមិនអនុវត្តលើព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូលដំណើរការលក់ ឬបង្ហាញ~~ស្រេម ~~ ~~ទៅតាម~~*ស្ថិតនៅក្រោម*តកក្រមច្បាប់ទំនើបភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុសហព័ន្ធ (Gramm-Leach-Bliley Act) (ច្បាប់សាធារណៈ 106-102) និងបទបញ្ញត្តិអនុវត្ត ឬក្រមច្បាប់ឯកជនភាពព័ត៌មានហិរញ្ញវត្ថុរដ្ឋ California (California Financial Information Privacy Act) (ផ្នែក 1.4 [ចាប់ផ្តើមជាមួយនឹងផ្នែក 4050] នៃក្រមហិរញ្ញវត្ថុ)*ឬ ក្រមច្បាប់ឥណទានកសិដ្ឋានសហព័ន្ធឆ្នាំ 1971 (Farm Credit Act of 1971) (ដូចបានធ្វើវិសោធនកម្មក្នុង 12 U.S.C. 2001-2279cc និង បទបញ្ញត្តិអនុវត្ត 12 C.F.R. 600 et seq.)*។ ផ្នែករងនេះមិនត្រូវអនុវត្តលើផ្នែក 1798.150 ទេ។

(f) ចំណងជើងនេះមិនអនុវត្តលើព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូលដំណើរការ លក់ ឬបង្ហាញស្របតាមក្រមច្បាប់ការពារឯកជនភាពអ្នកបើកបរ ឆ្នាំ 1994 (Driver's Privacy Protection Act of 1994) (18 U.S.C. Sec. 2721 et seq.) ទេ។ ផ្នែករងនេះមិនត្រូវអនុវត្តលើផ្នែក 1798.150 ទេ។

(g) (1) ផ្នែក 1798.120 មិនត្រូវអនុវត្តលើព័ត៌មានយានជំនិះ ឬ ព័ត៌មានកម្មសិទ្ធិដែលបានរក្សាទុក ឬ ដែលបានចែកចាយរវាងឈ្មួញលក់រថយន្តថ្មីឡើយ ដូចបានកំណត់នៅក្នុងផ្នែក 426 នៃក្រមច្បាប់យានជំនិះនិងអ្នកផលិតយានជំនិះដូចមានកំណត់នៅក្នុងផ្នែក 672 នៃ ក្រមច្បាប់យានជំនិះ ប្រសិនបើព័ត៌មានរថយន្ត ឬព័ត៌មានកម្មសិទ្ធិត្រូវបានចែកចាយក្នុងគោលបំណងបំពេញចិត្ត ឬក្នុងការរំពឹងទុកថានឹងបំពេញចិត្ត ការជួសជុលរថយន្តដែលបានរ៉ាប់រងដោយការធានារថយន្ត ឬការហៅប្រមូលរថយន្តមកវិញដែលធ្វើឡើងដោយស្របទៅតាមផ្នែក 30118 ដល់ 30120 រួមបញ្ចូលទាំងចំណងជើង 49 នៃក្រមសហរដ្ឋអាមេរិក ករណីដែលឈ្មួញលក់រថយន្ត ថ្មី ឬអ្នកផលិតរថយន្ត ដែលព័ត៌មានរថយន្ត ឬព័ត៌មានកម្មសិទ្ធិត្រូវបានចែកចាយជាមួយនោះ មិនលក់ ចែកចាយ ឬ ប្រើប្រាស់ព័ត៌មាននោះក្នុងគោលបំណងផ្សេង។

(2) សម្រាប់គោលបំណងនៃផ្នែករងនេះ៖

(A) "ព័ត៌មានរថយន្ត" សំដៅលើលេខព័ត៌មានរថយន្ត ម៉ាក សេរី ឆ្នាំ និងកុងទ័រវាស់ចម្ងាយ។

(B) "ព័ត៌មានកម្មសិទ្ធិ" សំដៅលើឈ្មោះ ឬបណ្តាឈ្មោះម្ចាស់ ឬបណ្តាម្ចាស់ ដែលបានចុះបញ្ជី និងព័ត៌មាន ទំនាក់ទំនងសម្រាប់ម្ចាស់ ឬបណ្តាម្ចាស់។

~~(h) (1) ចំណងជើងនេះមិនអនុវត្តលើករណីដូចខាងក្រោម៖~~

~~(A) ព័ត៌មានផ្ទាល់ខ្លួនដែលត្រូវបានប្រមូលដោយអាជីវកម្មអំពីរូបវន្តបុគ្គល ក្នុងអំឡុងពេលដែលរូបវន្តបុគ្គលធ្វើជាអ្នកដាក់ពាក្យសុំការងារ បុគ្គលិក ម្ចាស់ នាយក មន្ត្រី សមាជិកបុគ្គលិកវេជ្ជសាស្ត្រ ឬអ្នកម៉ៅការនៃអាជីវកម្មនោះ ទៅដល់កម្រិតដែលព័ត៌មានរូបវន្តបុគ្គលនោះត្រូវបានប្រមូលនិងប្រើប្រាស់ ដោយអាជីវកម្មសម្រាប់តែក្នុងបរិបទនៃតួនាទីរបស់រូបវន្តបុគ្គលឬ អតីតតួនាទីក្នុងនាមជាអ្នកដាក់ពាក្យ សុំការងារ បុគ្គលិក ម្ចាស់ នាយក មន្ត្រី សមាជិកបុគ្គលិកវេជ្ជសាស្ត្រ ឬអ្នកម៉ៅការនៃអាជីវកម្មប៉ុណ្ណោះ។~~

~~(B) ព័ត៌មានផ្ទាល់ខ្លួនដែលត្រូវបានប្រមូលដោយអាជីវកម្មដែលជាព័ត៌មានទំនាក់ទំនងគ្រាមានអាសន្នរបស់រូបវន្តបុគ្គលនោះដែលធ្វើជាអ្នកដាក់ពាក្យសុំបម្រើការងារ និយោជិក ម្ចាស់ នាយក មន្ត្រី សមាជិកបុគ្គលិកវេជ្ជសាស្ត្រ ឬអ្នកម៉ៅការនៃអាជីវកម្មនោះ ក្នុងកម្រិតមួយដែលថាព័ត៌មានផ្ទាល់ខ្លួននោះត្រូវបានប្រមូល និងប្រើប្រាស់តែម្យ៉ាងគត់ក្នុងបរិបទនៃការមានទំនាក់ទំនងគ្រាមានអាសន្ននៅលើសំណុំឯកសារ។~~

~~(C) ព័ត៌មានផ្ទាល់ខ្លួនដែលចាំបាច់សម្រាប់អាជីវកម្មដើម្បីអនុវត្តដើម្បីគ្រប់គ្រងអត្ថប្រយោជន៍ សម្រាប់រូបវន្តបុគ្គលផ្សេងទៀតដែលទាក់ទងនឹងរូបវន្តបុគ្គលនោះ ដែលធ្វើជាអ្នកដាក់ពាក្យសុំបម្រើការងារ និយោជិក ម្ចាស់ នាយក មន្ត្រី សមាជិកបុគ្គលិកវេជ្ជសាស្ត្រ ឬអ្នកម៉ៅការនៃអាជីវកម្មនោះ ក្នុងកម្រិតមួយដែលថា ព័ត៌មានផ្ទាល់ខ្លួននោះត្រូវបានប្រមូលនិងប្រើប្រាស់តែម្យ៉ាងគត់ក្នុងបរិបទនៃការគ្រប់គ្រងអត្ថប្រយោជន៍ទាំងនោះ។~~

~~(2) សម្រាប់គោលបំណងនៃផ្នែករងនេះ៖~~

~~(A) "អ្នកម៉ៅការ" មានន័យថា រូបវន្តបុគ្គលដែលផ្តល់សេវាកម្មអ្វីមួយជូនអាជីវកម្មដោយអនុលោមតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។~~

~~(B) "នាយក" មានន័យថា រូបវន្តបុគ្គលដែលត្រូវបានចាត់តាំងនៅក្នុងលក្ខន្តិ:សាជីវកម្មនោះ ឬត្រូវបានបោះឆ្នោតជ្រើសរើសដោយសាជីវករ និងរូបវន្តបុគ្គលទាំងឡាយដែលត្រូវបានចាត់តាំង បោះឆ្នោតជ្រើសរើស ឬតែងតាំងដោយឈ្មោះឬមុខងារផ្សេងទៀត ដើម្បីធ្វើជានាយក និងអ្នកស្នងរបស់ពួកគេ។~~

~~(C) "សមាជិកបុគ្គលិកវេជ្ជសាស្ត្រ" មានន័យថាគ្រូពេទ្យ និងគ្រូពេទ្យវះកាត់ ទន្តពេទ្យ ឬគ្រូពេទ្យបាលគ្រេចជើងដែលទទួលបានអាជ្ញាប័ណ្ណដោយអនុលោមតាមផ្នែកទី 2 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 500) នៃក្រមស្តីពីអាជីវកម្ម និងវិជ្ជាជីវៈ និងគ្រូពេទ្យចិត្តសាស្ត្រមែបគ្លីនិក ដូចមានកំណត់នៅក្នុងផ្នែកទី 1316.5 នៃក្រមស្តីពីសុខភាព និងសុវត្ថិភាព។~~

~~(D) "មន្ត្រី" មានន័យថា រូបវន្តបុគ្គលដែលត្រូវបានបោះឆ្នោតជ្រើសរើស ឬតែងតាំងដោយក្រុមប្រឹក្សាភិបាលដើម្បីចាត់ចែងប្រតិបត្តិការប្រចាំថ្ងៃរបស់សាជីវកម្មមួយដូចជានាយកប្រតិបត្តិ ប្រធាន លេខាធិការ ឬហិរញ្ញិក។~~

~~(E) "ម្ចាស់កម្មសិទ្ធិ" មានន័យថា រូបវន្តបុគ្គលម្នាក់ដែលបំពេញតាមលក្ខខណ្ឌខាងក្រោម៖~~

~~(i) មានកម្មសិទ្ធិនៃ ឬសិទ្ធិអំណាចក្នុងការបោះឆ្នោតលើសពី 50 ភាគរយនៃភាគហ៊ុនសរុបនៃថ្នាក់ណាមួយនៃមូលប័ត្របោះឆ្នោតរបស់អាជីវកម្ម។~~

~~(ii) មានការគ្រប់គ្រងនៅក្នុងរបៀបណាមួយទៅលើការបោះឆ្នោតនៃភាគច្រើននៃនាយក ឬបុគ្គលទាំងឡាយដែលប្រើប្រាស់មុខងារស្រដៀងគ្នានេះ។~~

~~(iii) មានសិទ្ធិអំណាចក្នុងការប្រើឥទ្ធិពលគ្រប់គ្រងទៅលើការចាត់ចែងរបស់ក្រុមហ៊ុន។~~

~~(3) ផ្នែករងនេះមិនត្រូវអនុវត្តទៅលើផ្នែករង (b) នៃផ្នែកទី 1798.100 ឬផ្នែកទី 1798.150 ឡើយ។~~

~~(4) ផ្នែករងនេះត្រូវមានប្រសិទ្ធភាពនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2021។~~

~~(i)~~ *(h)* ថ្វីបើមានកាតព្វកិច្ចរបស់អាជីវកម្មក្នុងការឆ្លើយតប និងគោរពសិទ្ធិស្នើសុំរបស់អ្នកប្រើប្រាស់ដោយអនុលោមតាមចំណងជើងនេះក៏ដោយ៖

(1) កំឡុងពេលសម្រាប់អាជីវកម្មមួយក្នុងការឆ្លើយតបទៅនឹង*អ្នកប្រើប្រាស់សម្រាប់* រាល់ ~~សំណើសុំរបស់អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បាន~~ *ដែលត្រូវបានផ្ទៀងផ្ទាត់* អាចត្រូវបានពន្យារបន្ថែមរហូតដល់ *សរុបចំនួន* 90 ~~ថ្ងៃមន្ថែមទៀត~~ តាមការចាំបាច់ ដោយពិចារណាទៅលើភាពស្មុគ្រស្មាញ និងចំនួននៃសំណើ។ អាជីវកម្មត្រូវជូនដំណឹងដល់អ្នកប្រើប្រាស់អំពីការពន្យារពេលបន្ថែមនេះ ក្នុងរយៈពេល 45 ថ្ងៃបន្ទាប់ពីបានទទួលសំណើ រួមជាមួយហេតុផលសម្រាប់ការពន្យារពេលនោះផងដែរ។

(2) ប្រសិនបើអាជីវកម្មនោះមិនចាត់វិធានការទៅលើសំណើរបស់អ្នកប្រើប្រាស់ទេនោះ អាជីវកម្មត្រូវជូនដំណឹងដល់អ្នកប្រើប្រាស់ដោយគ្មានការពន្យារពេល ហើយយ៉ាងហោចណាស់ក្នុងរង្វង់កំឡុងពេលដែលត្រូវបានអនុញ្ញាតសម្រាប់ការឆ្លើយតបដោយផ្នែកនេះ អំពីហេតុផលសម្រាប់ការមិនបានចាត់វិធានការ និងសិទ្ធិទាំងឡាយដែលអ្នកប្រើប្រាស់អាចនឹងមាន ក្នុងការប្តឹងឧទ្ធរណ៍ទៅលើសេចក្តីសម្រេចរបស់អាជីវកម្ម។

(3) ប្រសិនបើសំណើពីអ្នកប្រើប្រាស់ត្រូវបានរកឃើញយ៉ាងច្បាស់ថាមិនសមហេតុផល ឬហួសហេតុ ជាពិសេសដោយសារតែលក្ខណៈច្រំដែលរបស់វានោះ អាជីវកម្មអាចគិតកម្រៃសេវាសមរម្យមួយដោយពិចារណាទៅលើបន្ទុកចំណាយរដ្ឋបាលនៃការផ្តល់ព័ត៌មាន ឬការប្រាស្រ័យទាក់ទង ឬការចាត់វិធានការតាមការស្នើសុំ ឬបដិសេធមិនចាត់វិធានការលើសំណើ និងជូនដំណឹងដល់អ្នកប្រើប្រាស់អំពីហេតុផលសម្រាប់ការបដិសេធសំណើនោះ។ អាជីវកម្មត្រូវទទួលបន្ទុកនៃការបង្ហាញថាសំណើរបស់អ្នកប្រើប្រាស់ណាមួយ ~~ដែលត្រូវបានផ្ទៀងផ្ទាត់~~ *ដែលអាចផ្ទៀងផ្ទាត់បាន* ត្រូវបានរកឃើញយ៉ាងច្បាស់ថាមិនសមហេតុផល ឬហួសហេតុ។

~~(j)~~ *(i) (1)* អាជីវកម្មដែលប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួនទៅកាន់អ្នកផ្តល់សេវា *ឬអ្នកម៉ៅការណាម្នាក់ ដោយអនុលោមតាមចំណងជើងនេះ* មិនត្រូវទទួលខុសត្រូវក្រោមចំណងជើងនេះឡើយ ប្រសិនបើអ្នកផ្តល់សេវា *ឬអ្នកម៉ៅការ* ដែលទទួលព័ត៌មានផ្ទាល់ខ្លួននោះប្រើប្រាស់វាដោយរំលោភបំពានទៅលើការរឹតត្បិតទាំងឡាយដូចមានចែងនៅក្នុងចំណងជើងនេះ ក្នុងករណីដែលនៅពេលនៃប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួននោះ អាជីវកម្មមិនបានដឹងជាក់ស្តែង ឬពុំមានហេតុផលដែលត្រូវជឿថាអ្នកផ្តល់សេវា *ឬអ្នកម៉ៅការនោះ*មានចេតនាប្រព្រឹត្តការរំលោភបំពាននេះ។ ដូចគ្នានេះដែរ អ្នកផ្តល់សេវា *ឬអ្នកម៉ៅការ* មិនត្រូវទទួលខុសត្រូវក្រោមចំណងជើងនេះចំពោះកាតព្វកិច្ចទាំងឡាយរបស់អាជីវកម្មដែលខ្លួនបានផ្តល់សេវាជូនដូចមានចែងនៅក្នុងចំណងជើងនេះ *ករណីដែលអ្នកផ្តល់សេវា ឬអ្នកម៉ៅការនោះត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានរបស់ខ្លួនលើចំណងជើងនេះ។*

(2) អាជីវកម្មដែលប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដោយលើកលែងចំពោះអ្នកប្រើប្រាស់ទាំងឡាយដែលបានប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការសម្រេចចិត្តមិនចូលរួមការលក់ ឬការចែកចាយព័ត៌មាន

24

ផ្ទាល់ខ្លួនរបស់ពួកគេ អ្នកប្រើប្រាស់ដែលបានកំណត់ព្រំដែនការប្រើប្រាស់ ឬការប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់ពួកគេ និងអ្នកប្រើប្រាស់ដែលជាអនីតិជន ដែលពុំបានជ្រើសរើសការមិនចូលរួមក្នុងការប្រមូល ឬការលក់ព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេទៅឲ្យភាគីទីបី ដោយអនុលោមតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សរដែលតម្រូវឲ្យភាគីទីបីផ្តល់ជូនកិច្ចការពារកម្រិតដូចគ្នានឹងសិទ្ធិរបស់អ្នកប្រើប្រាស់ ដែលស្ថិតក្រោមចំណងជើងនេះ ដូចដែលបានផ្តល់ជូនដោយអាជីវកម្ម មិនត្រូវទទួលខុសត្រូវក្រោមចំណងជើងនេះឡើយ ប្រសិនបើភាគីទីបីដែលបានទទួលព័ត៌មានផ្ទាល់ខ្លួននោះប្រើប្រាស់វាដោយរំលោភបំពានទៅលើការរឹតត្បិតទាំងឡាយដែលមានចែងនៅក្នុងចំណងជើងនេះ ករណីដែលនៅពេលនៃការប្រកាសផ្សាយព័ត៌មានផ្ទាល់ខ្លួននោះ អាជីវកម្មមិនបានដឹងជាក់ស្តែង ឬពុំមានហេតុផលដែលត្រូវជឿថា ភាគីទីបីនោះមានចេតនាប្រព្រឹត្តការរំលោភបំពាននេះ។

~~(k)~~ *(j)* ចំណងជើងនេះមិនត្រូវបកស្រាយដើម្បីតម្រូវឲ្យអាជីវកម្មមួយ~~ប្រមូលព័ត៌មានផ្ទាល់ខ្លួនដែលវានឹងមិនប្រមូលនៅក្នុងដំណើការធម្មតានៃអាជីវកម្មរបស់ខ្លួន រក្សាទុកព័ត៌មានផ្ទាល់ខ្លួនក្នុងរយៈពេលវែងជាងការដែលខ្លួនត្រូវរក្សាទុកព័ត៌មានបែបនោះនៅក្នុងដំណើការធម្មតានៃអាជីវកម្មរបស់ខ្លួន~~ ~~ឬ~~*អ្នកផ្តល់សេវា ឬអ្នកម៉ៅការ* ~~ដើម្បី~~*៖*

(1) កំណត់អត្តសញ្ញាណឡើងវិញ ~~ឬ~~ បើមិនដូច្នោះទេតភ្ជាប់ព័ត៌មានដែ~~ល~~*ន*នៅ~~ក្នុ~~ង~~ដ~~ំ~~ណ~~ើ~~ការ~~ធ~~ម~~ម~~ត~~ា~~ន~~ៃ~~អ~~ាជ~~ីវ~~ក~~ម~~ម~~ន~~ុ~~ង~~ ~~ពុ~~ំ~~ត្រ~~ូ~~ូ~~ វ~~ា~~ ~~ត~~ូ~~ ~~ ~~

(i) មានកម្មសិទ្ធិ ឬសិទ្ធិអំណាចក្នុងការបោះឆ្នោតលើសពី 50 ភាគរយនៃភាគហ៊ុនសរុបនៃថ្នាក់ណាមួយនៃមូលប័ត្របោះឆ្នោតរបស់អាជីវកម្ម។

(ii) មានការគ្រប់គ្រងនៅក្នុងរបៀបណាមួយទៅលើការបោះឆ្នោតនៃភាគច្រើននៃនាយក ឬបុគ្គលទាំងឡាយដែលប្រើប្រាស់មុខងារស្រដៀងគ្នានេះ។

(iii) មានសិទ្ធិអំណាចក្នុងការប្រើឥទ្ធិពលគ្រប់គ្រងទៅលើការចាត់ចែងរបស់ក្រុមហ៊ុន។

(3) ផ្នែករងនេះមិនត្រូវអនុវត្តទៅលើផ្នែករង (a) នៃផ្នែកទី 1798.100 ឬផ្នែកទី 1798.150 ឡើយ។

(4) ផ្នែករងនេះនឹងឈប់មានប្រសិទ្ធភាពថ្ងៃទី 1 ខែមករា ឆ្នាំ 2023។

(n) (1) កាតព្វកិច្ចទាំងឡាយដែលដាក់ទៅលើអាជីវកម្មទាំងឡាយដោយផ្នែកទី 1798.100, 1798.105, *1798.106,* 1798.110, 1798.115, *1798.121,* 1798.130, និង 1798.135 មិនត្រូវអនុវត្តចំពោះព័ត៌មានផ្ទាល់ខ្លួនដែលឆ្លុះបញ្ចាំងអំពីការប្រាស្រ័យទាក់ទង ឬប្រតិបត្តិការជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់រវាងអាជីវកម្ម និងអ្នកប្រើប្រាស់ ដែលអ្នកប្រើប្រាស់នោះគឺជារូបវន្តបុគ្គលដែល *បានដើរតួ* ឬកំពុងដើរតួជានិយោជិក ម្ចាស់កម្មសិទ្ធិ នាយក មន្ត្រី ឬ*អ្នកម៉ៅការឯករាជ្យ* នៃក្រុមហ៊ុន ក្រុមហ៊ុនដៃគូ ក្រុមហ៊ុនឯកកម្មសិទ្ធិ ទីភ្នាក់ងារមិនស្វែងរកប្រាក់ចំណេញ ឬទីភ្នាក់ងាររដ្ឋាភិបាល និងដែលការប្រាស្រ័យទាក់ទងនិងប្រតិបត្តិការជាមួយអាជីវកម្មនោះកើតឡើងតែម្យ៉ាងគត់ក្នុងបរិបទនៃអាជីវកម្មដែលធ្វើការព្យាយាមដ៏ត្រឹមត្រូវទាក់ទងនឹង ឬការផ្តល់ជូន ឬការទទួលផលិតផល ឬសេវាកម្មទៅកាន់ ឬមកពីក្រុមហ៊ុន ដៃគូ ក្រុមហ៊ុនឯកកម្មសិទ្ធិ ឬទីភ្នាក់ងារមិនស្វែងរកប្រាក់ចំណេញ ឬទីភ្នាក់ងាររដ្ឋាភិបាល។

(2) សម្រាប់គោលបំណងនៃផ្នែករងនេះ៖

(A) ~~"អ្នកម៉ៅការ"~~ *"អ្នកម៉ៅការឯករាជ្យ"* មានន័យថា រូបវន្តបុគ្គលដែលផ្តល់សេវាណាមួយជូនអាជីវកម្មដោយយោងតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។

(B) "នាយក" មានន័យថា រូបវន្តបុគ្គលដែលត្រូវបានចាត់តាំងនៅក្នុងលក្ខន្តិកៈសាជីវកម្មនោះ ឬត្រូវបានបោះឆ្នោតជ្រើសរើសដោយសាជីវករនិងរូបវន្តបុគ្គលទាំងឡាយដែលត្រូវបានចាត់តាំង បោះឆ្នោតជ្រើសរើស ឬតែងតាំងដោយឈ្មោះឬមុខងារផ្សេងទៀត ដើម្បីធ្វើជានាយក និងអ្នកស្នងរបស់ពួកគេ។

(C) "មន្ត្រី" មានន័យថា រូបវន្តបុគ្គលដែលត្រូវបានបោះឆ្នោតជ្រើសរើស ឬតែងតាំងដោយក្រុមប្រឹក្សាភិបាលដើម្បីចាត់ចែងប្រតិបត្តិការប្រចាំថ្ងៃរបស់សាជីវកម្មមួយដូចជានាយកប្រតិបត្តិ ប្រធាន លេខាធិការ ឬហិរញ្ញិក។

(D) "ម្ចាស់កម្មសិទ្ធិ" មានន័យថា រូបវន្តបុគ្គលដែលបំពេញតាមលក្ខខណ្ឌខាងក្រោម៖

(i) មានកម្មសិទ្ធិ ឬសិទ្ធិអំណាចក្នុងការបោះឆ្នោតលើសពី 50 ភាគរយនៃភាគហ៊ុនសរុបនៃថ្នាក់ណាមួយនៃមូលប័ត្របោះឆ្នោតរបស់អាជីវកម្ម។

(ii) មានការគ្រប់គ្រងនៅក្នុងរបៀបណាមួយទៅលើការបោះឆ្នោតនៃភាគច្រើននៃនាយក ឬបុគ្គលទាំងឡាយដែលប្រើប្រាស់មុខងារស្រដៀងគ្នានេះ។

(iii) មានសិទ្ធិអំណាចក្នុងការប្រើឥទ្ធិពលគ្រប់គ្រងទៅលើការចាត់ចែងរបស់ក្រុមហ៊ុន។

(3) ផ្នែករងនេះត្រូវមានប្រសិទ្ធភាពនៅថ្ងៃទី 1 ខែមករា ឆ្នាំ ~~2021។~~ *2023។*

(o) (1) ផ្នែកទី 1798.105 និង 1798.120 មិនត្រូវអនុវត្តចំពោះការប្រមូល ការដំណើរការ ការលក់ ឬការប្រកាសផ្សាយព័ត៌មានអ្នកគ្រប់គ្រងអាជីវកម្មរបស់ទីភ្នាក់ងាររាយការណ៍ឥណទានពាណិជ្ជកម្ម ដល់កម្រិតមួយដែលទីភ្នាក់ងាររាយការណ៍ឥណទានពាណិជ្ជកម្មនោះ ប្រើប្រាស់ព័ត៌មានអ្នកគ្រប់គ្រងអាជីវកម្ម តែម្យ៉ាងគត់គឺដើម្បីកំណត់អត្តសញ្ញាណទំនាក់ទំនងរបស់អ្នកប្រើប្រាស់ជាមួយនឹងអាជីវកម្ម ដែលអ្នកប្រើប្រាស់នោះមាន ឬទាក់ទងអ្នកប្រើប្រាស់តែក្នុងតួនាទីរបស់អ្នកប្រើប្រាស់ក្នុងនាមជាម្ចាស់កម្មសិទ្ធិ នាយក មន្ត្រី ឬនិយោជិកចាត់ចែងរបស់អាជីវកម្មប៉ុណ្ណោះ។

(2) សម្រាប់គោលបំណងនៃផ្នែករងនេះ៖

(A) "ព័ត៌មានអ្នកគ្រប់គ្រងអាជីវកម្ម" មានន័យថា ឈ្មោះ ឬបណ្តាឈ្មោះរបស់ម្ចាស់កម្មសិទ្ធិ ឬបណ្តាម្ចាស់កម្មសិទ្ធិ នាយក មន្ត្រី ឬនិយោជិកចាត់ចែងរបស់អាជីវកម្ម និងព័ត៌មានទំនាក់ទំនង រួមមានជាអាទិ៍ មុខងារអាជីវកម្ម សម្រាប់ម្ចាស់កម្មសិទ្ធិ ឬបណ្តាម្ចាស់កម្មសិទ្ធិ នាយក មន្ត្រី ឬនិយោជិកចាត់ចែងនោះ។

(B) "ទីភ្នាក់ងាររាយការណ៍ឥណទានពាណិជ្ជកម្ម" មានអត្ថន័យដូចបានចែងនៅក្នុងផ្នែករង (b) នៃផ្នែកទី 1785.42។

(C) "ម្ចាស់កម្មសិទ្ធិ" មានន័យថា រូបវន្តបុគ្គលដែលបំពេញតាមលក្ខខណ្ឌខាងក្រោម៖

(i) មានកម្មសិទ្ធិ ឬសិទ្ធិអំណាចក្នុងការបោះឆ្នោតលើសពី 50 ភាគរយនៃភាគហ៊ុនសរុបនៃថ្នាក់ណាមួយនៃមូលប័ត្របោះឆ្នោតរបស់អាជីវកម្ម។

(ii) មានការគ្រប់គ្រងនៅក្នុងរបៀបណាមួយទៅលើការបោះឆ្នោតនៃភាគច្រើននៃនាយក ឬបុគ្គលទាំងឡាយដែលប្រើប្រាស់មុខងារស្រដៀងគ្នានេះ។

(iii) មានសិទ្ធិអំណាចក្នុងការប្រើឥទ្ធិពលគ្រប់គ្រងទៅលើការចាត់ចែងរបស់ក្រុមហ៊ុន។

(D) "នាយក" មានន័យថា រូបវន្តបុគ្គលដែលត្រូវបានចាត់តាំងនៅក្នុងលក្ខន្តិកៈសាជីវកម្មនៃអាជីវកម្ម ក្នុងនាមជានាយក ឬត្រូវបានបោះឆ្នោតជ្រើសរើសដោយសាជីវករនិងរូបវន្តបុគ្គលទាំងឡាយដែលត្រូវបានចាត់តាំង បោះឆ្នោតជ្រើសរើស ឬតែងតាំងដោយឈ្មោះឬមុខងារផ្សេងទៀតដើម្បីធ្វើជានាយក និងអ្នកស្នងរបស់ពួកគេ។

(E) "មន្ត្រី" មានន័យថា រូបវន្តបុគ្គលដែលត្រូវបានបោះឆ្នោតជ្រើសរើស ឬតែងតាំងដោយក្រុមប្រឹក្សាភិបាលដើម្បីចាត់ចែងប្រតិបត្តិការប្រចាំថ្ងៃរបស់សាជីវកម្មមួយដូចជាអគ្គនាយកប្រតិបត្តិ ប្រធាន លេខាធិការ ឬហិរញ្ញិក។

(F) "និយោជិកផ្នែកគ្រប់គ្រង" មានន័យថា រូបវន្តបុគ្គលដែលឈ្មោះ និងព័ត៌មានទំនាក់ទំនងត្រូវបានរាយការណ៍ទៅកាន់ ឬប្រមូលដោយទីភ្នាក់ងាររាយការណ៍ឥណទានពាណិជ្ជកម្មថាជាអ្នកចាត់ចែងចម្បងនៃអាជីវកម្មមួយ និងត្រូវបានប្រើប្រាស់តែម្យ៉ាងគត់ក្នុងបរិបទនៃតួនាទីរបស់រូបវន្តបុគ្គលនោះថាជាអ្នកចាត់ចែងចម្បងនៃអាជីវកម្មនោះ។

(p) កាតព្វកិច្ចទាំងឡាយដែលដាក់ទៅលើអាជីវកម្មនៅក្នុងផ្នែកទី 1798.105, 1798.106, 1798.110 និង 1798.115 មិនត្រូវអនុវត្តទៅលើទិន្នន័យគ្រួសារឡើយ។

(q) (1) ចំណងជើងនេះមិនតម្រូវឲ្យអាជីវកម្មមួយអនុលោមតាមសំណើរបស់អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បានដើម្បីលុបចោលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ក្រោមផ្នែកទី 1798.105 ដល់កម្រិតមួយដែលសំណើអ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បានអនុវត្តចំពោះនិទ្ទេស

24

ពិន្ទុនៃការអប់រំ ឬលទ្ធផលតេស្តអប់រំរបស់សិស្សដែលអាជីវកម្មកាន់កាប់ក្នុងនាមជាទីភ្នាក់ងារអប់រំក្នុងមូលដ្ឋាន ដូចមានកំណត់នៅក្នុងផ្នែករង (d) នៃផ្នែកទី 49073.1 នៃក្រមស្តីពីការអប់រំ ដែលសិស្សនោះចុះឈ្មោះចូលរៀនបច្ចុប្បន្ន។ ប្រសិនបើអាជីវកម្មមួយមិនអនុលោមតាមសំណើដោយអនុលោមតាមផ្នែកនេះទេនោះ អាជីវកម្មត្រូវជូនដំណឹងដល់អ្នកប្រើប្រាស់ថា ខ្លួនកំពុងតែធ្វើដោយអនុលោមតាមការលើកលែងនេះ។

(2) នៅក្នុងការឆ្លើយតបទៅនឹងសំណើដោយអនុលោមតាមផ្នែកទី 1798.110 ចំណងជើងនេះមិនតម្រូវឲ្យអាជីវកម្មមួយប្រកាសផ្សាយអំពីការវាយតម្លៃស្តង់ដារអប់រំ ឬការវាយតម្លៃការអប់រំ ឬការឆ្លើយតបជាក់លាក់របស់អ្នកប្រើប្រាស់ចំពោះការវាយតម្លៃស្តង់ដារអប់រំ ឬការវាយតម្លៃការអប់រំឡើយ ប្រសិនបើការចូលប្រើប្រាស់ កាន់កាប់ ឬគ្រប់គ្រងរបស់អ្នកប្រើប្រាស់នឹងបង្កគ្រោះថ្នាក់ដល់សុពលភាព និងភាពអាចជឿទុកចិត្តបាននៃការវាយតម្លៃស្តង់ដារអប់រំ ឬការវាយតម្លៃការអប់រំនោះ។ ប្រសិនបើអាជីវកម្មមួយមិនអនុលោមតាមសំណើដោយអនុលោមតាមផ្នែកនេះទេនោះ អាជីវកម្មត្រូវជូនដំណឹងដល់អ្នកប្រើប្រាស់ថា ខ្លួនកំពុងតែធ្វើដោយអនុលោមតាមការលើកលែងនេះ។

(3) សម្រាប់គោលបំណងនៃផ្នែករងនេះ៖

(A) "ការវាយតម្លៃស្តង់ដារអប់រំ ឬការវាយតម្លៃការអប់រំ" មានន័យថា សំណួរ ឬតេស្ត ឬការវាយតម្លៃផ្សេងទៀតដែលមានលក្ខណៈស្តង់ដារ ឬមិនស្តង់ដារដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃសិស្សនៅក្នុង ឬសម្រាប់ការចូលថ្នាក់មត្តេយ្យ និងថ្នាក់ទី 1 ដល់ 12 ដោយរាប់បញ្ចូលទាំងសាលារៀន ស្ថាប័នក្រោយមធ្យមសិក្សា កម្មវិធីវិជ្ជាជីវៈ និងកម្មវិធីថ្នាក់ក្រោយឧត្តមសិក្សា ដែលទទួលស្គាល់ដោយទីភ្នាក់ងារទទួលស្គាល់ផ្លូវការ ឬអង្គការដែលទទួលស្គាល់ដោយរដ្ឋ California ឬក្រសួងអប់រំសហរដ្ឋអាមេរិក ក៏ដូចជាការពិនិត្យលិខិតបញ្ជាក់ និងអាជ្ញាប័ណ្ណដែលប្រើសម្រាប់កំណត់សមត្ថភាព និងភាពមានសិទ្ធិក្នុងការទទួលលិខិតបញ្ជាក់ ឬអាជ្ញាប័ណ្ណពីទីភ្នាក់ងាររដ្ឋាភិបាល ឬស្ថាប័នទទួលស្គាល់របស់រដ្ឋាភិបាល។

(B) "បង្កគ្រោះថ្នាក់ដល់សុពលភាព និងភាពអាចជឿទុកចិត្តបាននៃការវាយតម្លៃស្តង់ដារអប់រំ ឬការវាយតម្លៃការអប់រំ" មានន័យថា ការបញ្ចេញព័ត៌មានដែលនឹងផ្តល់ប្រយោជន៍ដល់អ្នកប្រើប្រាស់ដែលបានដាក់ជូនសំណើអ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បាន ឬទៅកាន់រូបវន្តបុគ្គលម្នាក់ផ្សេងទៀត។

(r) ផ្នែកទី 1798.105 និង 1798.120 មិនត្រូវអនុវត្តចំពោះការប្រើប្រាស់ ការប្រកាសផ្សាយ ឬការលក់របស់អាជីវកម្មនូវព័ត៌មានផ្ទាល់ខ្លួនជាក់លាក់របស់អ្នកប្រើប្រាស់ណាម្នាក់ ប្រសិនបើអ្នកប្រើប្រាស់នោះបានយល់ព្រមចំពោះការប្រើប្រាស់ ការប្រកាសផ្សាយ ឬការលក់របស់អាជីវកម្មនូវព័ត៌មាននោះ ដើម្បីបង្កើតបានជាវត្ថុរូបវន្តមួយ រួមមានជាអាទិ៍ សៀវភៅឆ្នាំសិក្សាដែលមានរូបថតរបស់អ្នកប្រើប្រាស់ ប្រសិនបើ៖

(1) អាជីវកម្មនោះបានរ៉ាប់រងចំណាយយ៉ាងច្រើនផ្អែកទៅលើការយល់ព្រមរបស់អ្នកប្រើប្រាស់។

(2) ការអនុលោមតាមសំណើរបស់អ្នកប្រើប្រាស់ក្នុងការជ្រើសរើសការមិនចូលរួមការលក់ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ឬលុបចោលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់នោះនឹងមិនសមហេតុសមផលជាលក្ខណៈពាណិជ្ជកម្មឡើយ។

(3) អាជីវកម្មអនុលោមតាមសំណើរបស់អ្នកប្រើប្រាស់នៅពេលដែលវាសមហេតុសមផលជាលក្ខណៈពាណិជ្ជកម្មក្នុងការធ្វើដូច្នោះ។

ផ្នែកទី 16. ផ្នែកទី 1798.150 នៃក្រមរដ្ឋប្បវេណី ត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.150. ~~1798.150.~~ (a) (1) អ្នកប្រើប្រាស់ណាម្នាក់ដែលព័ត៌មានផ្ទាល់ខ្លួនមិនត្រូវបានអ៊ីនគ្រីប និងមិនត្រូវបានរៀបចំសម្រាប់បោះពុម្ពដូចមានកំណត់នៅក្នុងកថាខណ្ឌរង (A) នៃកថាខណ្ឌទី (1) នៃផ្នែករង (d) នៃផ្នែកទី 1798.81.5 ឬដែលអាសយដ្ឋានអ៊ីមែលរួមផ្សំជាមួយនឹងពាក្យសម្ងាត់ ឬសំណួរ និងចម្លើយផ្នែកសន្តិសុខដែលនឹងអនុញ្ញាតការចូលដំណើរការគណនីនោះ ស្ថិតក្រោមការចូលដំណើរការ និងការផ្ទេរអំពើរចោរកម្ម ឬការប្រកាសផ្សាយដោយគ្មានការអនុញ្ញាត ដែលជាលទ្ធផលនៃការរំលោភបំពានរបស់អាជីវកម្មទៅលើកាតព្វកិច្ចក្នុងការអនុវត្ត និងរក្សានូវនីតិវិធីនិងការប្រតិបត្តិសន្តិសុខដ៏សមហេតុសមផល ដែលសមរម្យចំពោះលក្ខណៈនៃព័ត៌មាន ដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនដែលអាចបង្កើតជាវិធានការរដ្ឋប្បវេណីមួយ សម្រាប់ខាងក្រោមនេះ៖

(A) ដើម្បីរ៉ាប់រងទៅលើការខូចខាតក្នុងចំនួនទឹកប្រាក់មិនតិចជាងមួយរយដុល្លារ ($100) និងមិនច្រើនជាងប្រាំពីររយហាសិបដុល្លារ ($750) ក្នុងអ្នកប្រើប្រាស់ម្នាក់ ក្នុងឧបទ្ទវហេតុមួយ ឬការខូចខាតជាក់ស្តែង មួយណាដែលមានចំនួនទឹកប្រាក់ច្រើនជាង។

(B) ការបន្ទរបន្ថយដែលជាបញ្ជា ឬការប្រកាស។

(C) រាល់ការបន្ទរបន្ថយផ្សេងទៀតដែលតុលាការចាត់ទុកថាត្រឹមត្រូវ។

(2) នៅក្នុងការវាយតម្លៃចំនួនទឹកប្រាក់នៃការខូចខាតតាមច្បាប់ តុលាការត្រូវពិចារណាទៅលើរាល់កាលៈទេសៈពាក់ព័ន្ធមួយ ឬច្រើនដែលបង្ហាញដោយភាគីណាមួយនៃរឿងក្តី រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ លក្ខណៈនិងភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តមិនត្រឹមត្រូវ ចំនួននៃការរំលោភបំពាន ភាពមិនព្រមលះបង់នៃការប្រព្រឹត្តមិនត្រឹមត្រូវ ថេរៈវេលានៃការប្រព្រឹត្តមិនត្រឹមត្រូវដែលបានកើតឡើង ឆន្ទៈនៃការប្រព្រឹត្តមិនត្រឹមត្រូវរបស់ចុងចោទ រួមទាំងទ្រព្យ បំណុល និងតម្លៃសុទ្ធរបស់ចុងចោទ។

(b) បណ្តឹងទាំងឡាយដែលអនុលោមតាមផ្នែកនេះ អាចធ្វើឡើងដោយអ្នកប្រើប្រាស់ ប្រសិនបើ មុនពេលចាប់ផ្តើមអំពើណាមួយប្រឆាំងនឹងអាជីវកម្មសម្រាប់ការខូចខាតតាមច្បាប់ជាលក្ខណៈបុគ្គល ឬទូទាំងថ្នាក់ អ្នកប្រើប្រាស់ផ្តល់ជូនសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 30 ថ្ងៃធ្វើការដែលកំណត់នូវប្រការជាក់លាក់នៃចំណងជើងនេះ ដែលការចោទប្រកាន់របស់អ្នកប្រើប្រាស់ត្រូវបាន ឬកំពុងត្រូវបានរំលោភបំពាន។ ករណីដែលការកែខៃអាចធ្វើទៅបានប្រសិនបើក្នុងរយៈពេល 30 ថ្ងៃ អាជីវកម្មនោះពិតជាបានដោះស្រាយការរំលោភបំពានដែលបានជូនដំណឹងនិងផ្តល់ជូនអ្នកប្រើប្រាស់នូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរឆាប់រហ័សមួយ ដែលថាការរំលោភបំពាននោះត្រូវបានដោះស្រាយរួច ហើយនឹងគ្មានការរំលោភបំពានបន្ថែមកើតឡើងទៀតនោះ គ្មានការខូចខាតតាមច្បាប់ជាលក្ខណៈបុគ្គល ឬការខូចខាតតាមច្បាប់ទូទាំងថ្នាក់ អាចត្រូវបានចាប់ផ្តើមប្រឆាំងនឹងអាជីវកម្មនោះឡើយ។ *ការអនុវត្ត និងការរក្សានូវនីតិវិធី និងការប្រតិបត្តិសន្តិសុខសមហេតុសមផល ដោយអនុលោមតាមផ្នែកទី 1798.81.5 ក្រោយការបំពាន មិនបង្កើតបានជាការកែខៃមួយដែលទាក់ទងនឹងការរំលោភបំពាននោះឡើយ។* គ្មានសេចក្តីជូនដំណឹងណាមួយត្រូវបានតម្រូវមុនពេលដែលអ្នកប្រើប្រាស់ជាបុគ្គលចាប់ផ្តើមសកម្មភាពមួយ តែម្យ៉ាងគត់សម្រាប់ការខូចខាតលុយកាក់ជាក់ស្តែងដែលបានទទួលរងដោយសារតែការរំលោភបំពានដែលត្រូវបានចោទប្រកាន់ពីចំណងជើងនេះឡើយ។ ប្រសិនបើអាជីវកម្មមួយបន្តរំលោភបំពានលើចំណងជើងនេះ ដែលរំលោភបំពានលើសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរឆាប់រហ័ស ដែលផ្តល់ជូនអ្នកប្រើប្រាស់ក្រោមផ្នែកនេះ អ្នកប្រើប្រាស់អាចចាប់ផ្តើមសកម្មភាពមួយប្រឆាំងនឹងអាជីវកម្ម ដើម្បីអនុវត្តសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ហើយអាចបន្តការខូចខាតតាមច្បាប់សម្រាប់ការរំលោភបំពាននីមួយៗ

24

នៃសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរឆាប់រហ័ស ក៏ដូចជារាល់ការរំលោភបំពានណាមួយទៅលើចំណងជើងនៅក្រោយកាលបរិច្ឆេទនៃសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរនោះ។

(c) បុព្វហេតុនៃសកម្មភាពដែលបង្កើតឡើងដោយផ្នែកនេះ ត្រូវអនុវត្ត*ចំពោះ*តែរាល់ការរំលោភបំពានទាំងឡាយដូចបានកំណត់នៅក្នុងផ្នែករង (a) ហើយមិនត្រូវផ្អែកទៅលើការរំលោភបំពានទៅលើផ្នែកផ្សេងទៀតនៃចំណងជើងនេះឡើយ។ គ្មានអ្វីមួយនៅក្នុងចំណងជើងនេះត្រូវបានបកស្រាយថាបម្រើជាមូលដ្ឋានសម្រាប់សិទ្ធិឯកជននៃសកម្មភាពក្រោមច្បាប់ណាមួយផ្សេងទៀតឡើយ។ នេះមិនត្រូវបានបកស្រាយថាជាការបន្ធូរបន្ថយភាគីណាមួយពីករណីយកិច្ច ឬកាតព្វកិច្ចដែលត្រូវបានដាក់ក្រោមច្បាប់ផ្សេងទៀត ឬរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ឬរដ្ឋ California ឡើយ។

ផ្នែកទី 17. ផ្នែកទី 1798.155 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.155. ការអនុវត្តផ្នែករដ្ឋបាល

~~1798.155.~~ (a) ~~អាជីវកម្ម ឬភាគីទីបីណាមួយអាចស្វែងរកមតិយោបល់របស់អគ្គមេធាវីសម្រាប់ការណែនាំអំពីរបៀបអនុលោមតាមប្រការទាំងឡាយនៃចំណងជើងនេះ។~~

~~(b) អាជីវកម្មមួយត្រូវចាត់ទុកថារំលោភបំពានលើចំណងជើងនេះ ប្រសិនបើខ្លួនខកខានក្នុងការកែខៃរាល់ការរំលោភបំពានដែលបានចោទប្រកាន់ក្នុងរយៈពេល 30 ថ្ងៃក្រោយការជូនដំណឹងអំពីការមិនអនុលោមដែលបានចោទប្រកាន់។~~ អាជីវកម្ម អ្នកផ្ដល់សេវា *អ្នកម៉ៅការ* ឬបុគ្គលម្នាក់ផ្សេងទៀតដែលរំលោភបំពានចំណងជើងនេះ ត្រូវ~~ស្ថិតក្រោមសេចក្ដីបង្គាប់និង~~ ទទួលខុសត្រូវចំពោះ *ការពិន័យផ្នែករដ្ឋបាលមិនលើសពីពីរពាន់ប្រាំរយដុល្លារ ($2,500) សម្រាប់ការរំលោភបំពាននីមួយៗ ឬប្រាំពីរពាន់ប្រាំរយដុល្លារ ($7,500) សម្រាប់ការរំលោភបំពានដោយចេតនានិមួយៗ ឬការរំលោភបំពានដែលពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដែលអាជីវកម្ម អ្នកផ្ដល់សេវា អ្នកម៉ៅការ ឬបុគ្គលផ្សេងទៀតបានដឹងជាក់ស្ដែងថាមានអាយុក្រោម 16 ឆ្នាំ ដូចដែលបានលៃតម្រូវដោយអនុលោមតាមកថាខណ្ឌទី (5) នៃផ្នែករង (a) នៃផ្នែកទី 1798.185 នៅក្នុងបណ្ដឹងអនុវត្តរដ្ឋបាលដោយទីភ្នាក់ងារការពារឯកជនភាពរដ្ឋ California*។ ~~ទោសមញ្ញត្តិរដ្ឋប្បវេណីមិនលើសពីពីរពាន់ប្រាំរយដុល្លារ ($2,500) សម្រាប់រាល់ការរំលោភបំពាននីមួយៗ ឬប្រាំពីរពាន់ប្រាំរយដុល្លារ ($7,500) សម្រាប់ការរំលោភបំពានដោយចេតនា ដែលត្រូវវាយតម្លៃ និងដោះស្រាយនៅក្នុងបណ្ដឹងរដ្ឋប្បវេណីដែលប្ដឹងក្នុងនាមជាប្រជាពលរដ្ឋ California ដោយអគ្គមេធាវី។ ទោសមញ្ញត្តិរដ្ឋប្បវេណីដែលមានចែងនៅក្នុងផ្នែកនេះ ត្រូវវាយតម្លៃ និងដោះស្រាយទាំងស្រុងនៅក្នុងបណ្ដឹងរដ្ឋប្បវេណីដែលប្ដឹងក្នុងនាមជាប្រជាពលរដ្ឋ California ដោយអគ្គមេធាវី។~~

~~(c)~~ *(b)* នៅក្នុង~~ការពិន័យរដ្ឋបាល~~ *ទោសបញ្ញត្តិរដ្ឋប្បវេណី* ដែលត្រូវបានវាយតម្លៃសម្រាប់ការរំលោភបំពានចំណងជើងនេះ និងចំណាត់ការនៃដំណោះស្រាយណាមួយលើបណ្ដឹងដែលប្ដឹងដោយអនុលោមតាមផ្នែករង ~~(b)~~ *(a)* ត្រូវដាក់នៅក្នុងមូលនិធិឯកជនភាពអ្នកប្រើប្រាស់ ដែលបង្កើតនៅក្នុងមូលនិធិទូទៅដោយអនុលោមតាមផ្នែករង (a) នៃផ្នែកទី 1798.160 ដោយមានចេតនាទូទាត់ទាំងស្រុងរាល់ថ្លៃចំណាយដែលទទួលបន្ទុកដោយតុលាការរដ្ឋនិងអគ្គមេធាវី*និងទីភ្នាក់ងារការពារឯកជនភាពរដ្ឋ California* ទាក់ទងនឹងចំណងជើងនេះ។

ផ្នែកទី 18. ផ្នែកទី 1798.160 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.160. មូលនិធិឯកជនភាពអ្នកប្រើប្រាស់

~~1798.160.~~ (a) មូលនិធិពិសេសដែលត្រូវគេស្គាល់ថា "មូលនិធិឯកជនភាពអ្នកប្រើប្រាស់" ត្រូវបានបង្កើតនៅក្នុងមូលនិធិទូទៅនៅក្នុងរតនាគាររដ្ឋ និងអាចរកបានសម្រាប់ការបម្រុងទុកដោយអង្គនីតិបញ្ញត្តិ*សិន* ដើម្បីទូទាត់បន្ទុកចំណាយដែលទទួលរងដោយតុលាការរដ្ឋពាក់ព័ន្ធនឹងបណ្ដឹងដែលបានប្ដឹងដើម្បីអនុវត្តចំណងជើងនេះ ~~និងរាស់~~ *បន្ទុកចំណាយដែលទទួលរងដោយអគ្គមេធាវីនៅក្នុងការអនុវត្តករណីយកិច្ចរបស់អគ្គមេធាវីក្រោមចំណងជើងនេះ*និង*បន្ទាប់មកសម្រាប់គោលបំណងបង្កើតនូវមូលនិធិវិនិយោគនៅក្នុងរតនាគាររដ្ឋ ជាមួយនឹងប្រាក់ចំណូលឬការប្រាក់ណាមួយពីមូលនិធិដែលត្រូវដាក់នៅក្នុងមូលនិធិទូទៅ និងការបង្កើតប្រាក់ជំនួយដើម្បីលើកកម្ពស់ និងការពារឯកជនភាពអ្នកប្រើប្រាស់ អប់រំកុមារនៅក្នុងវិស័យឯកជនភាពតាមអនឡាញ និងផ្ដល់មូលនិធិដល់កម្មវិធីសហការជាមួយអង្គភាពអនុវត្តច្បាប់អន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងសកម្មភាពក្លែងបន្លំទាក់ទងនឹងការបំពានទិន្នន័យអ្នកប្រើប្រាស់*។

(b) មូលនិធិដែលផ្ទេរទៅកាន់មូលនិធិឯកជនភាពអ្នកប្រើប្រាស់ ត្រូវប្រើប្រាស់ទាំងស្រុងដូច *តទៅ*៖

(1) ~~ដើម្បី~~ *ដើម្បី* ទូទាត់រាល់បន្ទុកដែលទទួលរងដោយតុលាការរដ្ឋ និងអគ្គមេធាវីដែលពាក់ព័ន្ធនឹងចំណងជើងនេះ។

(2) បន្ទាប់ពីបំពេញកាតព្វកិច្ចក្រោមកថាខណ្ឌទី (1) មូលនិធិដែលនៅសេសសល់ត្រូវលៃចែកតាមឆ្នាំសារពើពន្ធនីមួយៗដូចតទៅ៖

(A) កៅសិបមួយភាគរយត្រូវវិនិយោគដោយហិរញ្ញិកនៅក្នុងទ្រព្យហិរញ្ញវត្ថុ ដោយមានគោលដៅបង្កើនជាអតិបរមានូវលទ្ធផលរយៈពេលវែងដែលស៊ីគ្នាជាមួយនឹងកម្រិតហានិភ័យដែលត្រូវប្រុងប្រយ័ត្ន។ ប្រាក់ដើមមិនត្រូវស្ថិតក្រោមការផ្ទេរ ឬលៃបម្រុងទុកឡើយ ក្នុងករណីដែលការប្រាក់និងប្រាក់ចំណូលណាមួយត្រូវផ្ទេរជាប្រចាំឆ្នាំទៅកាន់មូលនិធិទូទៅសម្រាប់ការដកទុកដោយរដ្ឋសភាសម្រាប់គោលបំណងមូលនិធិទូទៅ។

(B) ប្រាំបួនភាគរយត្រូវដាក់ឲ្យប្រើប្រាស់សម្រាប់ទីភ្នាក់ងារការពារឯកជនភាពរដ្ឋ California សម្រាប់គោលបំណងបង្កើតប្រាក់ជំនួយនៅរដ្ឋ California ដោយ 3 ភាគរយត្រូវលៃចែកទៅកាន់អ្នកទទួលជំនួយដូចតទៅ៖

(i) អង្គការមិនស្វែងរកប្រាក់ចំណេញដើម្បីលើកកម្ពស់ និងការពារឯកជនភាពអ្នកប្រើប្រាស់។

(ii) អង្គការមិនស្វែងរកប្រាក់ចំណេញ និងទីភ្នាក់ងារសាធារណៈ រួមមានជាអាទិ៍ មណ្ឌលសាលារៀន ដើម្បីអប់រំកុមារនៅក្នុងវិស័យឯកជនភាពតាមអនឡាញ។

(iii) ទីភ្នាក់ងារអនុវត្តច្បាប់រដ្ឋនិងច្បាប់មូលដ្ឋាន ដើម្បីផ្ដល់មូលនិធិដល់កម្មវិធីសហការជាមួយអង្គភាពអនុវត្តច្បាប់អន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងសកម្មភាពក្លែងបន្លំទាក់ទងនឹងការបំពានទិន្នន័យអ្នកប្រើប្រាស់។

(c) ~~មូលនិធិទាំងនេះ~~*មូលនិធិនៅក្នុងមូលនិធិឯកជនភាពអ្នកប្រើប្រាស់* មិនត្រូវ*ស្ថិត*ក្រោមការដកទុក ឬ*ផ្ទេ*រដោយអង្គនីតិបញ្ញត្តិ*សម្រាប់*គោលបំណងផ្សេងទៀតឡើយ។ ~~លើកលែងតែនាយកផ្នែកហិរញ្ញវត្ថុកំណត់ថា មូលនិធិនោះលើសលប់ក្នុងការផ្ដល់មូលនិធិដែលត្រូវការដើម្បីទូទាត់ពេញលេញទៅលើបន្ទុកចំណាយដែលទទួលរងដោយតុលាការរដ្ឋនិងអគ្គមេធាវីទាក់ទងនឹងចំណងជើងនេះ ដែលក្នុងករណីនេះ អង្គនីតិបញ្ញត្តិអាចដកទុកមូលនិធិដែលលើសនោះសម្រាប់គោលបំណងផ្សេងទៀត។~~

ផ្នែកទី 19. ផ្នែកទី 1798.175 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.175. ប្រការដែលមានទំនាស់

~~1798.175.~~ ចំណងជើងនេះមានបំណងបន្តសិទ្ធិធម្មនុញ្ញនៃឯកជនភាពនិងដើម្បីបំពេញ បន្ថែមលើច្បាប់ដែលមានស្រាប់ទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ជាអាទិ៍រួមមានជំពូក 22 (ចាប់ផ្តើមជាមួយនឹងផ្នែក 22575) នៃផ្នែក 8 នៃក្រមអាជីវកម្មនិងវិជ្ជាជីវៈ និងចំណងជើង 1.81 (ចាប់ផ្តើមជាមួយនឹងផ្នែក 1798.80)។ ប្រការនៃចំណងជើងនេះមិនកំណត់ព្រំដែនត្រឹមការប្រមូលព័ត៌មាន តាមអេឡិចត្រូនិក ឬតាម អ៊ីនធឺណិតទេ ប៉ុន្តែអនុវត្តលើការប្រមូល និងការលក់ព័ត៌មានផ្ទាល់ខ្លួនទាំងអស់ដែលបានប្រមូល ដោយអាជីវកម្ម ពីអ្នកប្រើប្រាស់។ បើអាចធ្វើបាន ច្បាប់ដែលពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់គួរត្រូវបានបកស្រាយឲ្យមានភាពស្របគ្នាជាមួយនឹងប្រការនៃចំណងជើងនេះ ប៉ុន្តែក្នុងករណីដែលមានទំនាស់រវាងច្បាប់ទាំងនេះនិងប្រការនៃចំណងជើងនេះ ប្រការនៃច្បាប់ដែលមានការការពារធំបំផុតសម្រាប់សិទ្ធិឯកជនភាព សម្រាប់អ្នកប្រើប្រាស់នឹងប្រើជាគោល។

ផ្នែក 20. ផ្នែក 1798.180 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.180. សិទ្ធិទិញមុនគេ

~~1798.180.~~ ចំណងជើងនេះគឺជាបញ្ហាកង្វល់ទូទាំងរដ្ឋ និងជំនួសនិងបង្ការរាល់វិធាន បទបញ្ញត្តិ ក្រម ទម្រង់ការ និង ច្បាប់ផ្សេងទៀតដែលបានអនុម័តដោយក្រុង ខោនធី ក្រុងនិងខោនធី សាលាក្រុង ឬទីភ្នាក់ងារក្នុងមូលដ្ឋានពាក់ព័ន្ធនឹងការប្រមូល និងការលក់ព័ត៌មានផ្ទាល់ខ្លួន របស់អ្នកប្រើប្រាស់ដោយអាជីវកម្ម។

ផ្នែក 21. ផ្នែក 1798.185 នៃ ក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.185. បទបញ្ជា

~~1798.185.~~ (a) នៅថ្ងៃ ឬមុនថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2020 អគ្គមេធាវីត្រូវអញ្ជើញឲ្យ មានការចូលរួមពីសាធារណជនទូលំទូលាយ និងអនុម័តបទបញ្ញត្តិដើម្បីបន្តកិច្ចការក្នុងគោលបំណង នៃចំណងជើងនេះ ជាអាទិ៍រួមមានតែមិនកំណត់ចំពោះផ្នែកនានាដូចខាងក្រោម៖

(1) ការធ្វើបច្ចុប្បន្នភាព *ឬការបន្ថែម* ~~តាមការចាំបាច់នូវប្រភេទមន្ថែម~~នៃព័ត៌មាន ផ្ទាល់ខ្លួនទៅលើប្រភេទដែលមានរាយនាមនៅក្នុងផ្នែករង (c) នៃផ្នែក 1798.130 និងផ្នែករង ~~(o)~~ *(v)* នៃផ្នែក 1798.140 *និងការធ្វើបច្ចុប្បន្នភាព ឬការបន្ថែមប្រភេទនៃព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ទៅក្នុងប្រភេទដែលមានរាយនាមនៅក្នុងផ្នែករង (ae) នៃផ្នែក 1798.140* ដើម្បីដោះស្រាយការផ្លាស់ប្តូរលើបច្ចេកវិទ្យា ការអនុវត្តការប្រមូលទិន្នន័យ ឧបសគ្គក្នុងការ អនុវត្ត និងកង្វល់ផ្នែកឯកជនភាព។

(2) ការធ្វើបច្ចុប្បន្នភាពតាមការចាំបាច់លើ ~~និយមន័យ~~ *បណ្តានិយមន័យ* នៃពាក្យ *"ត្រូវបានបិទបាំងអត្តសញ្ញាណ"* និងបណ្តា~~ព័ត៌មានកំណត់អត្តសញ្ញាណតែមួយគត់~~ *"ព័ត៌មានកំណត់អត្តសញ្ញាណតែមួយគត់"* ដើម្បីដោះស្រាយការផ្លាស់ប្តូរ លើបច្ចេកវិទ្យា ការប្រមូលទិន្នន័យ ឧបសគ្គក្នុងការអនុវត្ត និងកង្វល់ផ្នែកឯកជនភាព និងប្រភេទនៃ ~~ការមន្ថែម~~ *ការកែប្រែ ឬការលុប* បន្ថែមទៅលើនិយមន័យនៃវិធីសាស្ត្រដែលបាន កំណត់សម្រាប់ការដាក់បញ្ជូនសំណើដើម្បីជួយសម្រួលដល់សមត្ថភាពរបស់អ្នកប្រើប្រាស់ ក្នុងការទទួលបានព័ត៌មានពីអាជីវកម្មស្របទៅតាមផ្នែក 1798.130 ។ *អាជ្ញាធរដែលត្រូវធ្វើបច្ចុប្បន្នភាពនិយមន័យនៃពាក្យ "ត្រូវបានបិទបាំងអត្តសញ្ញាណ" មិនត្រូវអនុវត្តលើស្តង់ដារការបិទបាំងអត្តសញ្ញាណ ដែលបានចែងនៅក្នុងផ្នែក 164.514 នៃចំណងជើង 45 នៃក្រមបទបញ្ញត្តិសហព័ន្ធឡើយ ដែលព័ត៌មានទាំងនោះធ្លាប់បានហៅថា "ព័ត៌មានសុខភាពដែលត្រូវបានការពារ" ដូចមានកំណត់ន័យនៅក្នុងផ្នែក 160.103 នៃចំណងជើង 45 នៃក្រម បទបញ្ញត្តិសហព័ន្ធ។*

(3) ការបង្កើតការលើកលែងណាមួយដែលចាំបាច់ដើម្បីអនុលោមតាមច្បាប់រដ្ឋ ឬច្បាប់សហព័ន្ធ ជាអាទិ៍រួមមានតែមិនកំណត់ចំពោះការលើកលែងដែលពាក់ព័ន្ធនឹងអាថ៌កំបាំងការធ្វើជំនួញ និងសិទ្ធិនៃទ្រព្យកម្មសិទ្ធិបញ្ញានៅក្នុងរយៈពេលមួយឆ្នាំនៃការអនុម័តចំណងជើងនេះ និងនៅពេល ក្រោយតាមការចាំបាច់*ជាមួយនឹងចេតនាថាអាថ៌កំបាំងការធ្វើជំនួញមិនគួរត្រូវបានបង្ហាញក្នុងការ ឆ្លើយតបទៅនឹងសំណើរបស់អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បានឡើយ។*

(4) ការបង្កើតវិធាននិងទម្រង់ការដូចខាងក្រោម៖

(A) ដើម្បីជួយសម្រួលនិងគ្រប់គ្រងការដាក់បញ្ជូនសំណើដោយអ្នកប្រើប្រាស់ដើម្បីបញ្ឈប់ការ លក់*ឬ ការចែករំលែ*កព័ត៌មានផ្ទាល់ខ្លួនស្របតាមផ្នែក 1798.120 *និងកំណត់ព្រំដែន លើការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ស្របតាមផ្នែក 1798.121 ដើម្បីធានាថាអ្នកប្រើប្រាស់មានសមត្ថភាពដើម្បីប្រើប្រាស់ជម្រើសរបស់ពួកគេ ដោយមិនមានបន្ទុកនិងដើម្បីបង្ការអាជីវកម្មពីការចូលរួមក្នុងសកម្មភាពបំភាន់ ឬបៀតបៀន រួមមានការសងសឹកប្រឆាំងនឹង អ្នក ប្រើប្រាស់ចំពោះការប្រើប្រាស់សិទ្ធិរបស់ពួកគេខណៈពេល ដែលអនុញ្ញាតឲ្យអាជីវកម្មជូនដំណឹងដល់អ្នកប្រើប្រាស់អំពីផលវិបាកនៃការសម្រេចចិត្តរបស់ពួកគេក្នុងការជ្រើសរើសមិនចូលរួមការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ឬកំណត់ព្រំដែននៃការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ ។*

(B) ដើម្បីគ្រប់គ្រងអនុលោមភាពអាជីវកម្មជាមួយនឹងសំណើជ្រើសរើសការមិនចូលរួមរបស់អ្នកប្រើប្រាស់។

(C) សម្រាប់ការអភិវឌ្ឍនិងការប្រើប្រាស់និមិត្តសញ្ញាឬប៊ូតុងដែល ងាយស្គាល់និងដូចគ្នាដោយអាជីវកម្មទាំងអស់ដើម្បីលើកកម្ពស់ ការយល់ដឹងរបស់អ្នកប្រើប្រាស់អំពីឱកាសដើម្បីបញ្ឈប់ការលក់ ព័ត៌មានផ្ទាល់ខ្លួន។

(5) ការកែតម្រូវ~~ដែនកំណត់~~ *ដែនកំណត់នានានៃរូបីយវត្ថុ* នៅ*ខែមករារៀងរាល់ឆ្នាំ*លេខសេស *ដើម្បីឆ្លុះ*បញ្ចាំ*ងអំ*ពីសន្ទស្សន៍ *តម*្លៃ*អ*្ន*ក*ប្រើ*ប្រ*ាស់ នៅ*ក*្នុ*ង*៖ អ*នុ*ក*ថ*ា*ខ*ណ្ឌ (A) *នៃ*ក*ថ*ា*ខ*ណ្ឌ (1) *នៃ*ផ្នែ*ករ*ង ~~(c)~~ *(d)* *នៃ*ផ្នែ*ក* 1798.140 *អ*នុ*ក*ថ*ា*ខ*ណ្ឌ (A) *នៃ*ក*ថ*ា*ខ*ណ្ឌ (1) *នៃ* ផ្នែ*ករ*ង *(a) នៃ*ផ្នែ*ក 1798.150* ផ្នែ*ករ*ង *(a) នៃ*ផ្នែ*ក 1798.155* ផ្នែ*ក 1798.199.25 និ*ងផ្នែ*ករ*ង *(a) នៃ*ផ្នែ*ក 1798.199.90* ~~ក្នុ*ងខែ*ម*ករ*ានៃ*ឆ្នាំ*លេ*ខ*ស*េ*ស*ដ*ើ*ម*្ប*ីឆ*ុ*ះ*ប*ញ*ាំ*ង*អ*ំ*ព*ីស*ន*ទ*ស*្ស*ន*៍ *ត*ម*្ល*ៃ*អ*ក*ប*្រ*ើ*ប*្រ*ាស*ៃ*។

(6) បង្កើតវិធាន ទម្រង់ការ និងការលើកលែងណាមួយដែលចាំបាច់ដើម្បីធានាថាការជូនដំណឹង និងព័ត៌មានដែលអាជីវកម្មត្រូវបានតម្រូវឲ្យផ្តល់ស្របតាមចំណងជើងនេះ ត្រូវបានផ្តល់ជូនតាមរបៀបដែលងាយយល់ដល់អ្នកប្រើប្រាស់ទូទៅ អាចរកបានដោយអ្នកប្រើប្រាស់ដែលមានពិការភាព និងអាចរកបានជាភាសាដែលប្រើប្រាស់ជាចម្បងក្នុងការទំនាក់ទំនងជាមួយអ្នកប្រើប្រាស់រួមមានការបង្កើតវិធាន និងសេចក្តីណែនាំទាក់ទងនឹង *ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ* ~~ការផ្តល់ជូនការលើកទឹកចិត្ត~~ ក្នុងរយៈពេលមួយឆ្នាំក្រោយបន្ទាប់ពីការអនុម័តចំណងជើងនេះ និងតាមតម្រូវការនៅពេលក្រោយ។

(7) ការបង្កើតវិធាននិងទម្រង់ការដើម្បីបន្តបំពេញគោលបំណងនៃផ្នែក *1798.105, 1798.106,* 1798.110, និង 1798.115 និងជួយសម្រួលដល់សមត្ថភាពរបស់ ភ្នាក់ងារដែលត្រូវបានប្រគល់សិទ្ធិពីអ្នកប្រើ

ប្រាស់ដើម្បីលុបព័ត៌មានផ្ទាល់ខ្លួន កែតម្រូវព័ត៌មានផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវ ស្របតាមផ្នែក 1798.106 ឬទទួលព័ត៌មានស្របតាមផ្នែក 1798.130 ជាមួយនឹងគោលដៅនៃការកាត់បន្ថយបន្ទុករដ្ឋបាលទៅលើអ្នកប្រើប្រាស់ដោយគិតពីបច្ចេកវិទ្យាដែលអាចប្រើប្រាស់បាន កង្វល់សន្តិសុខ និងបន្ទុកមកលើអាជីវកម្មដើម្បីគ្រប់គ្រងការកំណត់របស់អាជីវកម្មថាសំណើសុំព័ត៌មានដែលបានទទួលពីអ្នកប្រើប្រាស់គឺជាសំណើរបស់អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បាន រួមមានការដោះស្រាយសំណើ ដែលបានបញ្ជូនមកតាមគណនីការពារដោយពាក្យសម្ងាត់ដែលត្រូវបានរក្សាទុកដោយ អ្នកប្រើប្រាស់ជាមួយនឹងអាជីវកម្ម ខណៈពេលដែលអ្នកប្រើប្រាស់ចូលទៅក្នុងគណនីក្នុងនាមជាសំណើអ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បាន និងការផ្តល់យន្តការសម្រាប់អ្នកប្រើប្រាស់ដែលមិនមានគណនីជាមួយអាជីវកម្មអោយស្នើសុំព័ត៌មានតាមរយៈការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវរបស់អាជីវកម្ម ទៅលើអត្តសញ្ញាណរបស់អ្នកប្រើប្រាស់ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីការអនុម័តចំណងជើងនេះ និងតាមការចាំបាច់នៅពេលក្រោយ។

(8) កំណត់ភាពញឹកញាប់ និង ក្នុងស្ថានភាពអ្វីដែលអ្នកប្រើប្រាស់អាចស្នើសុំការកែតម្រូវ ស្របតាមផ្នែក 1798.106 ដោយរួមបញ្ចូលទាំងស្តង់ដារគ្រប់គ្រងដូចខាងក្រោម៖

(A) របៀបដែលអាជីវកម្មឆ្លើយតបនឹងសំណើសុំកែតម្រូវ រួមមានការលើកលែងសម្រាប់សំណើ ដែលការឆ្លើយតបមិនអាចធ្វើទៅបាន ឬ ដែលនឹងពាក់ព័ន្ធនឹងកិច្ចប្រឹងប្រែងមិនសមាមាត្រ និងសំណើសុំកែព័ត៌មានដែលត្រឹមត្រូវ។

(B) របៀបដោះស្រាយក្តីបារម្ភពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃព័ត៌មាន។

(C) ជំហានដែលអាជីវកម្មអាចអនុវត្តដើម្បីបង្ការការក្លែងបន្លំ។

(D) ប្រសិនបើអាជីវកម្មបដិសេធសំណើសុំកែតម្រូវព័ត៌មានផ្ទាល់ខ្លួនដែលបានប្រមូលនិងដែលបានវិភាគទាក់ទងនឹងសុខភាពរបស់អ្នកប្រើប្រាស់ សិទ្ធិរបស់អ្នកប្រើប្រាស់ក្នុងការផ្តល់សេចក្តីបញ្ជាក់បន្ថែមជាលាយលក្ខណ៍អក្សរទៅលើអាជីវកម្មពាក់ព័ន្ធនឹងរបាយការណ៍ ឬ អំណះអំណាងទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួនទាំងនោះ ដែលអ្នកប្រើប្រាស់ជឿថាមិនពេញលេញ ឬមិន ត្រឹមត្រូវ។ សេចក្តីបញ្ជាក់បន្ថែមត្រូវកំណត់ត្រឹម 250 ពាក្យក្នុងមួយចំណុចដែលមិនពេញលេញ ឬមិនត្រឹមត្រូវ
ហើយត្រូវបង្ហាញឱ្យច្បាស់ជាលាយលក្ខណ៍អក្សរដែលអ្នកប្រើប្រាស់ស្នើសុំឱ្យបង្កើត សេចក្តីបញ្ជាក់បន្ថែមជាផ្នែ មួយនៃកំណត់ហេតុរបស់អ្នកប្រើប្រាស់។

(9) ការបង្កើតស្តង់ដាដើម្បីគ្រប់គ្រងការកំណត់របស់អាជីវកម្ម អនុលោមតាមអនុកថាខណ្ឌ (B) ក្នុង កថាខណ្ឌ (2) របស់ផ្នែករង (a) នៃផ្នែក 1798.130 ដែលការផ្តល់ព័ត៌មានលើសពីរយៈ ពេល 12 ខែក្នុងការឆ្លើយតបទៅសំណើរបស់អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បានគឺមិនអាចទៅរួច ឬនឹងត្រូវមានកិច្ចប្រឹងប្រែងដែលមិនសមាមាត្រ។

(10) ការចេញបទបញ្ជាដែលបន្ថែមកំណត់ន័យ និងបន្ថែមគោលបំណងអាជីវកម្មរួមមាន គោលបំណង ដែលបានទទួលដំណឹងផ្សេងទៀតដែលអាជីវកម្ម អ្នកផ្តល់សេវាកម្ម និង អ្នកម៉ៅការអាចនឹងប្រើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ស្របតាមការរំពឹងទុករបស់អ្នកប្រើប្រាស់ ហើយដែលកំណត់ន័យបន្ថែមលើគោលបំណងអាជីវកម្មដែលអ្នកផ្តល់សេវាកម្ម និងអ្នកមៅការអាចនឹង ដាក់បញ្ចូលគ្នានូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ដែលទទួលបានពីប្រភពផ្សេងគ្នា លើកលែង តែមានចែងក្នុងកថាខណ្ឌ (6) នៃផ្នែករង (e) នៃផ្នែក 1798.140។

(11) ការចេញបទបញ្ជាដែលកំណត់អត្តសញ្ញាណគោលបំណងអាជីវកម្មទាំងនោះ រួមមាន គោលបំណងដែលបានទទួលដំណឹងផ្សេងទៀតដែលអ្នកផ្តល់សេវា និងអ្នកម៉ៅការអាចនឹងប្រើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដែលបានទទួលដោយ អនុលោមតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយអាជីវកម្មសម្រាប់គោលបំណងអាជីវកម្មផ្ទាល់ខ្លួនរបស់អ្នកផ្តល់សេវាឬអ្នកម៉ៅការដែលមានគោលដៅធ្វើឱ្យឯកជនភាពរបស់អ្នកប្រើប្រាស់មានប្រសិទ្ធភាព ជាអតិបរមា។

(12) ការចេញបទបទបញ្ជាដើម្បីបន្តកំណត់ន័យបន្ថែមនូវ "ការធ្វើអន្តរកម្មដោយចេតនា," ដែលមាន គោលដៅធ្វើឱ្យឯកជនភាពរបស់អ្នកប្រើប្រាស់មានប្រសិទ្ធភាពជាអតិបរមា។

(13) ការចេញបទបញ្ជាដើម្បីកំណត់ន័យបន្ថែមពី "ទីតាំងភូមិសាស្ត្រជាក់លាក់" រួមទាំងប្រសិនបើទំហំដែលបានកំណត់មិនគ្រប់គ្រាន់ដើម្បីការពារឯកជនភាពអ្នកប្រើប្រាស់នៅក្នុងតំបន់ដែលមានប្រជាជនតិចតួច ឬនៅពេលដែលព័ត៌មានផ្ទាល់ខ្លួនត្រូវបានប្រើប្រាស់សម្រាប់គោលបំណងប្រតិបត្តិការធម្មតា រួមទាំងការចេញវិក័យបត្រផងដែរ។

(14) ការចេញបទបញ្ញត្តិដើម្បីកំណត់ពីវាក្យសព្ទ "ចំណែកជាក់លាក់នៃព័ត៌មានដែលបានទទួលពីអ្នកប្រើប្រាស់" ដែលមានគោលដៅក្នុងការបង្កើនប្រសិទ្ធភាពជាអតិបរមានូវសិទ្ធិរបស់អ្នកប្រើប្រាស់ដើម្បីចូលមើលព័ត៌មានផ្ទាល់ខ្លួនដែលពាក់ព័ន្ធ ខណៈពេលដែលការកាត់បន្ថយការចែកចាយ ព័ត៌មានជាអតិបរមា ទៅអ្នកប្រើប្រាស់ដែលមិនមានប្រយោជន៍ដល់អ្នកប្រើប្រាស់ រួមមាន ព័ត៌មានចូលប្រើប្រព័ន្ធ និងទិន្នន័យបច្ចេកទេសផ្សេងទៀត។ សម្រាប់ការបញ្ជូនព័ត៌មានផ្ទាល់ខ្លួនសម្ងាត់បំផុត បទបញ្ជាអាចនឹងតម្រូវឱ្យមានស្តង់ដារខ្ពស់ជាងនៃការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ករណីដែលទីភ្នាក់ងារត្រូវត្រួតពិនិត្យផលប៉ះពាល់នៃស្តង់ដារ ខ្ពស់ជាងទៅលើសិទ្ធិអ្នកប្រើប្រាស់ដើម្បីទទួលបានព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ក្នុងការធានាថា តម្រូវការនៃការផ្ទៀងផ្ទាត់មិនបណ្តាលឱ្យមានការបដិសេធមិនសមហេតុផលចំពោះសំណើរបស់អ្នកប្រើប្រាស់ដែលអាចផ្ទៀងផ្ទាត់បាន។

(15) ការចេញបទបញ្ជាដែលតម្រូវឱ្យអាជីវកម្មដែលការដំណើរការព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ បង្ហាញនូវហានិភ័យខ្ពស់ចំពោះឯកជនភាព ឬសុវត្ថិភាពរបស់អ្នកប្រើប្រាស់ដើម្បី៖

(A) អនុវត្តសវនកម្មសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតប្រចាំឆ្នាំ ដែលរួមមានការកំណត់វិសាលភាពនៃសវនកម្មនិងការបង្កើតដំណើរការ ដើម្បីធានាថាសវនកម្មនោះគឺហ្មត់ចត់និងឯករាជ្យ។ កត្តាដែលត្រូវពិចារណានៅក្នុងការកំណត់ថាពេលណាដែលការដំណើរការអាចនឹងបណ្តាលឱ្យមានហានិភ័យខ្ពស់ដល់សុវត្ថិភាពព័ត៌មានផ្ទាល់ខ្លួន ត្រូវរាប់បញ្ចូលនូវទំហំនិងភាពស្មុគ្រស្មាញនៃអាជីវកម្មព្រមទាំងលក្ខណៈ និងវិសាលភាពនៃសកម្មភាពដំណើការ។

(B) ដាក់ជូនទៅទីភ្នាក់ងារការពារឯកជនភាពរដ្ឋ California នូវការវាយតម្លៃហានិភ័យជាប្រចាំពាក់ព័ន្ធនឹងការដំណើរការព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ រួមទាំងថាតើដំណើរការទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួនសម្ងាត់និងការកំណត់អត្តសញ្ញាណ និងការថ្លឹងថ្លែងពីអត្ថប្រយោជន៍ដែលបានមកពីដំណើរការលើអាជីវកម្ម អ្នកប្រើប្រាស់ អ្នកពាក់ព័ន្ធផ្សេងទៀត និងសាធារណជន ប្រៀបនឹងហានិភ័យដែលអាចកើតមានចំពោះសិទ្ធិរបស់អ្នកប្រើប្រាស់ដែលជាប់ទាក់ទងនឹងការ

24

ដំណើរការនោះ ដែលមានគោលដៅក្នុងការរឹតបន្តឹង និងការហាមឃាត់ដំណើរការ ប្រសិនបើមាន ហានិភ័យចំពោះឯកជនភាពរបស់អ្នកប្រើប្រាស់ ធ្ងន់ជាងអត្ថប្រយោជន៍ដែលបានមកពីដំណើរការចំពោះអ្នកប្រើប្រាស់ អាជីវកម្ម អ្នកពាក់ព័ន្ធផ្សេងទៀត និងសាធារណជន។ មិនមានអ្វីនៅក្នុងផ្នែកនេះត្រូវតម្រូវឱ្យអាជីវកម្មបកអាក្រាត អាថ៌កំបាំងពាណិជ្ជកម្មទេ។

(16) ការចេញបទបញ្ជាក្នុងការគ្រប់គ្រងសិទ្ធិចូលមើលនិងសិទ្ធិជ្រើសរើសមិនចូលរួមដែលពាក់ព័ន្ធ នឹងការប្រើប្រាស់របស់អាជីវកម្មលើបច្ចេកវិទ្យាការសម្រេចចិត្តដោយស្វ័យប្រវត្តិ ដែលរួមមានទម្រង់ប្រវត្តិរូប និងការតម្រូវឱ្យមានការឆ្លើយតបរបស់អាជីវកម្មក្នុងការចូលមើលសំណើ ដើម្បី ដាក់បញ្ចូលព័ត៌មានដែលមានខ្លឹមសារអំពីភាពសមហេតុផលដែលជាប់ទាក់ទិនទៅនឹងដំណើរការធ្វើការសម្រេចចិត្តទាំងនោះ ក៏ដូចជាការពណ៌នាពីលទ្ធផលនៃដំណើរការពាក់ព័ន្ធនឹងអ្នកប្រើប្រាស់។

(17) ការចេញបទបញ្ជាដើម្បីកំណត់បន្ថែម ពី "ការសើបអង្កេតដែលអនុម័តដោយទីភ្នាក់ងារអនុវត្តច្បាប់" ក្នុងគោលបំណងនៃការលើកលែងនៅក្នុងកថាខណ្ឌ (2) នៃផ្នែករង (a) នៃផ្នែក 1798.145។

(18) ការចេញបទបញ្ជាដើម្បីកំណត់វិសាលភាព និងដំណើរការសម្រាប់ការប្រើប្រាស់សិទ្ធិអំណាច សវនកម្មរបស់ទីភ្នាក់ងារដើម្បីបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសបុគ្គលដើម្បី ធ្វើសវនកម្មនិងការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ពីការបង្ហាញទៅសវនករដោយមិនមាន ដីកាតុលាការ ដីកាចាប់ខ្លួន ឬ ដីការកោះហៅ។

(19) (A) ការចេញបទបញ្ជាដើម្បីកំណត់លក្ខខណ្ឌតម្រូវនិង លក្ខណៈបញ្ជាក់ផ្នែកបច្ចេកទេសសម្រាប់ការផ្តល់សញ្ញាចំណង់ចំណូលចិត្តនៃការជ្រើសរើសមិនចូលរួម ដែលត្រូវបាន បញ្ជូនដោយប្រព័ន្ធ បច្ចេកវិទ្យា ឬយន្តការដើម្បីបង្ហាញពីចេតនារបស់អ្នកប្រើប្រាស់ក្នុងការជ្រើសរើសការមិនចូលរួមការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ និង កំណត់ព្រំដែននៃការប្រើប្រាស់ ឬការបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់។ លក្ខខណ្ឌតម្រូវ និងលក្ខណៈបញ្ជាក់បច្ចេកទេសសម្រាប់ការផ្តល់សញ្ញាចំណង់ចំណូលចិត្តជ្រើសរើសមិនចូលរួម គួរត្រូវបានធ្វើបច្ចុប្បន្នភាពយូរៗម្តង ដើម្បីធ្លុះបញ្ចាំងអំពីមធ្យោបាយ ដែលអ្នកប្រើប្រាស់ធ្វើអន្តរកម្មជាមួយអាជីវកម្ម ហើយគួរតែ៖

(i) ធានាថាក្រុមហ៊ុនបង្កើតប្រព័ន្ធ ឬកម្មវិធីរុករកលើវិប ឬឧបករណ៍ដែលបញ្ជូនសញ្ញាចំណង់ចំណូលចិត្តនៃការជ្រើសរើសមិនចូលរួម មិនអាចធ្វើឲ្យអាជីវកម្មផ្សេងចាញ់ប្រៀបយ៉ាងអយុត្តិធម៌។

(ii) ធានាថាសញ្ញាចំណង់ចំណូលចិត្តនៃការជ្រើសរើសមិនចូលរួមគឺល្អសម្រាប់អ្នកប្រើប្រាស់ រៀបរាប់បានច្បាស់លាស់ និងងាយស្រួលប្រើដោយអ្នកប្រើប្រាស់ទូទៅ ហើយមិនតម្រូវ ឲ្យអ្នកប្រើប្រាស់ផ្តល់ព័ត៌មានបន្ថែមក្រៅពីអ្វីដែលចាំបាច់។

(iii) បង្ហាញយ៉ាងច្បាស់លាស់អំពីចេតនារបស់អ្នកប្រើប្រាស់ និងមិនមានកំហុសដែលរឹតត្បិត ឬ សន្មតជាមុននូវចេតនានោះ។

(iv) ធានាថាសញ្ញាចំណង់ចំណូលចិត្តនៃការជ្រើសរើសមិនចូលរួម មិនមានទំនាស់ជាមួយនឹងការកំណត់ឯកជនភាពដែលត្រូវបានប្រើប្រាស់ជាញឹកញាប់ ឬឧបករណ៍ដែលអ្នកប្រើប្រាស់ អាចនឹងប្រើប្រាស់។

(v) ផ្តល់យន្តការសម្រាប់អ្នកប្រើប្រាស់ក្នុងការយល់ព្រមតាមជម្រើសលើការលក់ព័ត៌មានផ្ទាល់ខ្លួនអ្នកប្រើប្រាស់របស់អាជីវកម្ម ឬការប្រើប្រាស់ ឬការបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ ដោយ មិនប៉ះពាល់ដល់ចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់ ពាក់ព័ន្ធនឹងអាជីវកម្ម ឬការបិទដំណើការសញ្ញាចំណង់ចំណូលចិត្តនៃការជ្រើសរើសមិនចូលរួមទាំងស្រុង។

(vi) ថ្លែងថា ក្នុងករណីដែលទំព័រ ឬការកំណត់ទិដ្ឋភាពដែល អ្នកប្រើប្រាស់ចូលមើលដើម្បីកំណត់ សញ្ញាចំណង់ចំណូលចិត្តជ្រើសរើសមិនចូលរួម អ្នកប្រើប្រាស់គួរមើលឃើញរហូតដល់ បីជម្រើស រួមមាន៖

(I) ការជ្រើសរើសមិនចូលរួមទាំងស្រុងនៅក្នុងការលក់ និងការចែកចាយព័ត៌មានផ្ទាល់ខ្លួន ដែលរួមមានការណែនាំឲ្យកំណត់ព្រំដែននៃការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ ។

(II) ជម្រើសក្នុងការ "កំណត់ព្រំដែននៃការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនសម្ងាត់។"

(III) ជម្រើសដែលមានចំណងជើង "ហាមលក់/ហាមចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់ខ្ញុំសម្រាប់ការផ្សាយ ពាណិជ្ជកម្មអាកប្បកិរិយាឆ្លងបរិបទ។"

(B) ការចេញបទបញ្ជាដើម្បីបង្កើតលក្ខខណ្ឌបញ្ជាក់បច្ចេកទេស សម្រាប់សញ្ញាចំណង់ចំណូលចិត្តជ្រើសរើសមិនចូលរួមដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ឪពុកម្តាយ ឬអាណាព្យបាល របស់អ្នកប្រើប្រាស់បញ្ជាក់ថាអ្នកប្រើប្រាស់មានអាយុក្រោម 13 ឆ្នាំឬយ៉ាងតិច 13 ឆ្នាំ និងអាយុក្រោម 16 ឆ្នាំ។

(C) ការចេញបទបញ្ជាក្នុងគោលដៅពង្រឹងឯកជនភាពរបស់អ្នកប្រើប្រាស់ ខណៈពេលកំពុង ពិចារណាផលប្រយោជន៍ប្រតិបត្តិការស្របច្បាប់របស់អាជីវកម្ម ដើម្បីគ្រប់គ្រងការប្រើប្រាស់ ឬការបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់ ថ្វីបើមានការណែនាំរបស់អ្នកប្រើប្រាស់ក្នុងការកំណត់ព្រំដែនការប្រើប្រាស់ ឬការបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នក ប្រើប្រាស់ក៏ដោយ រួមមាន៖

(i) ការកំណត់គោលបំណងបន្ថែមណាមួយដែលអាជីវកម្មអាចនឹងប្រើ ឬបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់។

(ii) ការកំណត់វិសាលភាពនៃសកម្មភាពដែលបានអនុញ្ញាតក្រោមកថាខណ្ឌ (8) នៃផ្នែករង (e) នៃផ្នែក 1798.140 ដូចបាន អនុញ្ញាតដោយផ្នែករង (a) នៃផ្នែក 1798.121 ដើម្បីធានាថា សកម្មភាពទាំងនោះមិនជាប់ពាក់ព័ន្ធនឹងការស្រាវជ្រាវ ទាក់ទងនឹងសុខភាព។

(iii) ការធានាការបំពេញមុខងារនៃប្រតិបត្តិការរបស់អាជីវកម្ម។

(iv) ការធានាថាការលើកលែងក្នុងផ្នែករង (d) នៃផ្នែក 1798.121 ចំពោះព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ ដែលអនុវត្តចំពោះព័ត៌មានដែលត្រូវបានប្រមូល ឬត្រូវបានដំណើរការដោយអចេតនា ឬ ដោយគ្មានគោលបំណងសន្និដ្ឋានលើចរិតលក្ខណៈអំពីអ្នកប្រើប្រាស់ ខណៈពេលកំពុងធានាថាអាជីវកម្មមិនប្រើប្រាស់ការលើកលែងដើម្បីគោលបំណងគេចវេសពីសិទ្ធិរបស់អ្នកប្រើប្រាស់ ក្នុងការកំណត់ការប្រើប្រាស់និងការបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់ពួកគេក្រោមផ្នែក 1798.121។

(20) ការចេញបទបញ្ជាដើម្បីគ្រប់គ្រងពីរបៀបដែលអាជីវកម្ម បានជ្រើសរើសគោរពតាមផ្នែករង (b) នៃផ្នែក 1798.135 ឆ្លើយតបទៅនឹងសញ្ញាចំណង់ចំណូលចិត្តជ្រើសរើសមិនចូលរួមហើយផ្តល់ឱ្យអ្នកប្រើប្រាស់នូវ ឱកាសយល់ព្រមនៅពេលក្រោយចំពោះការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ឬការប្រើប្រាស់ និងការបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់ របស់ ពួកគេក្នុងគោលបំណងបន្ថែមលើព័ត៌មានផ្ទាល់ខ្លួនទាំងនោះដែលត្រូវបានអនុញ្ញាតដោយផ្នែករង (a) នៃផ្នែក 1798.121។ បទបញ្ជាគួរតែ៖

(A) ខិតខំលើកកម្ពស់ការប្រកួតប្រជែងនិងជម្រើសអ្នកប្រើប្រាស់ និងមានអព្យាក្រឹត្យផ្នែកបច្ចេកវិទ្យា។

(B) ធានាថាអាជីវកម្មមិនឆ្លើយតបទៅនឹងសញ្ញាចំណង់ចំណូលការជ្រើសរើសមិនចូលរួមតាមរយៈ៖

(i) ការធ្វើឱ្យបាត់បង់តម្លៃមុខងារនៃបទពិសោធន៍របស់អ្នកប្រើប្រាស់ ដោយចេតនា។

(ii) ការគិតថ្លៃពីអ្នកប្រើប្រាស់ក្នុងការឆ្លើយតបទៅនឹងចំណង់ចំណូលចិត្ត នៃការជ្រើសរើសមិនចូលរួមរបស់អ្នកប្រើប្រាស់។

(iii) ការបង្កើតផលិតផល ឬសេវាកម្មណាមួយដែលបំពេញមុខងារ មិនបានត្រឹមត្រូវ ឬពេញលេញ សម្រាប់អ្នកប្រើប្រាស់ ធៀបនឹងអ្នកប្រើប្រាស់ដែលមិនប្រើប្រាស់សញ្ញាចំណង់ចំណូលចិត្តការជ្រើសរើសមិនចូលរួម។

(iv) ការប៉ុនប៉ងបង្ខំអ្នកប្រើប្រាសឱ្យជ្រើសរើសចូលរួមក្នុងការលក់ ឬការចែកចាយព័ត៌មានផ្ទាល់ខ្លួន របស់អ្នកប្រើប្រាស់ ឬការប្រើប្រាស់ ឬការបង្ហាញព័ត៌មានផ្ទាល់ខ្លួនសម្ងាត់របស់អ្នកប្រើប្រាស់តាមរយៈការថ្លែង ឬការបង្កប់ន័យថាការប្រើប្រាស់សញ្ញាចំណង់ចំណូលចិត្តជ្រើសរើសមិនចូលរួមនឹងមានផលប៉ះពាល់មិនល្អដល់អ្នកប្រើប្រាស់ ធៀបនឹងអ្នកប្រើប្រាស់ដែលមិនប្រើសញ្ញាចំណង់ចំណូលចិត្តជ្រើសរើសមិនចូលរួម ដែលរួមមានការថ្លែង ឬការបង្កប់ន័យថាអ្នកប្រើប្រាស់នឹងមិនអាចប្រើប្រាស់ផលិតផល ឬសេវាកម្មរបស់អាជីវកម្ម ឬថាផលិតផល ឬសេវាកម្មទាំងនោះអាចនឹងមិនបំពេញមុខងារបានត្រឹមត្រូវ ឬពេញលេញ។

(v) ការដាក់បង្ហាញការជូនដំណឹង ឬការលេចឡើងណាមួយ ក្នុងការឆ្លើយតបទៅនឹងសញ្ញាចំណង់ ចំណូលចិត្តជ្រើសរើសមិនចូលរួមរបស់អ្នកប្រើប្រាស់។

(C) ធានាថាតំណភ្ជាប់ណាមួយទៅកាន់គេហទំព័រ ឬមាតិកាគាំទ្ររបស់ខ្លួនដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់យល់ព្រមក្នុងការជ្រើសរើសចូលរួម៖

(i) មិនមែនជាផ្នែកនៃការលេចឡើង ការជូនដំណឹង បដា ឬការរចនាដែលរំលោភបំពានផ្សេងទៀត ដែលលាក់បាំងផ្នែកណាមួយនៃគេហទំព័រដែលអ្នកប្រើប្រាស់មានបំណងចូលមើលពីទិដ្ឋភាពទាំងមូល ឬដែលជ្រៀតជ្រែក ឬរារាំងក្នុងវិធីណាមួយដល់បទពិសោធន៍របស់អ្នកប្រើប្រាស់ក្នុងការចូលមើល ឬការរុករកលើទំព័រវិប ឬគេហទំព័រដែលអ្នកប្រើប្រាស់មានបំណងចង់មើល។

(ii) មិនទាមទារ ឬបង្កប់ន័យថាអ្នកប្រើប្រាស់ត្រូវតែចុចតំណភ្ជាប់ដើម្បីទទួលបានមុខងារពេញ លេញនៃផលិតផល ឬសេវាកម្មណាមួយ រួមទាំងគេហទំព័រ។

(Iii) មិនទាញយកផលប្រយោជន៍ពីល្បិចខ្មៅងងឹតណាមួយ។

(iv) អនុវត្តតែលើអាជីវកម្មដែលអ្នកប្រើប្រាស់មានបំណងធ្វើអន្តរកម្មជាមួយ។

(D) ព្យាយាមទប់ស្កាត់ការអនុវត្តបែបបង្ខំ ឬ បំភាន់ក្នុងការឆ្លើយតបទៅនឹងសញ្ញាចំណង់ចំណូលចិត្ត ការជ្រើសរើសមិនចូលរួម ប៉ុន្តែមិនគួររឹតបន្តឹងជ្រុលហួសហេតុលើអាជីវកម្មដែលព្យាយាមក្នុងចេតនាល្អដើម្បីអនុលោមតាមផ្នែក 1798.135 ទេ។

(21) ពិនិត្យមើលប្រការនៃក្រមធានារ៉ាប់រង និងបទបញ្ជាដែលមានស្រាប់ទាក់ទងនឹងឯកជនភាពអ្នកប្រើប្រាស់ លើកលែងតែប្រការដែលទាក់ទងនឹងអត្រាឬការកំណត់តម្លៃធានារ៉ាប់រង ដើម្បី កំណត់ថាតើប្រការណាមួយនៃក្រមធានារ៉ាប់រង ផ្តល់ការការពារដល់អ្នកប្រើប្រាស់ច្រើនជាងប្រការនៃចំណងជើងនេះឬទេ។ នៅពេលបញ្ចប់ការពិនិត្យមើលរួច ទីភ្នាក់ងារត្រូវអនុវត្តតាមបទបញ្ជា ដែលអនុវត្តតែប្រការដែលការពារកាន់តែខ្លាំងនៃចំណងជើងនេះចំពោះក្រុមហ៊ុនធានារ៉ាប់រង។ សម្រាប់គោលបំណងនៃភាពច្បាស់លាស់ ស្នងការធានារ៉ាប់រងត្រូវមានយុត្តាធិការលើអត្រានិងការកំណត់តម្លៃធានារ៉ាប់រង។

(22) ការធ្វើឲ្យស៊ីគ្នានូវបទបញ្ជាដែលគ្រប់គ្រងយន្តការការជ្រើសរើសមិនចូលរួម សេចក្តីជូនដំណឹង ដល់អ្នកប្រើប្រាស់ និងយន្តការប្រតិបត្តិការផ្សេងទៀតក្នុងចំណងជើងនេះដើម្បីលើកកម្ពស់ភាពច្បាស់លាស់ និងមុខងារនៃចំណងជើងនេះសម្រាប់អ្នកប្រើប្រាស់។

(b) អគ្គមេធាវីអាចនឹងអនុវត្តតាមយន្តការបន្ថែមដូចតទៅ៖

~~(1) ដើម្បីបង្កើតវិធាននិងនីតិវិធី អំពីរបៀបដំណើរការនិងអនុវត្តតាមសំណើរបស់អតិថិជនដែលអាចធ្វើឯកជ្ញាធ~~ ~~ាត~~ ~~ាបានសម្រាប់មំណែកជាក~~ ~~ាលាក~~ ~~ាន~~ ~~ៃ~~ ~~ព~~ ~~ត~~ ~~ាមានផ~~ ~~ាល~~ ~~ាខ~~ ~~ួ~~ ~~ាទ~~ ~~ាក~~ ~~ាទ~~ ~~ងនឹ~~ ~~ងគ~~ ~~ួ~~ ~~ារ~~ ~~ដ~~ ~~ើ~~ ~~ដ~~ ~~ោ~~ ~~ះ~~ ~~ស~~ ~~ាយ~~ ~~ឧ~~ ~~ប~~ ~~ស~~ ~~គ~~ ~~ក~~ ~~ុ~~ ~~ង~~ ~~ការ~~ ~~អ~~ ~~ន~~ ~~ុ~~ ~~វ~~ ~~ត~~ ~~ និ~~ ~~ងកង~~ ~~ល~~ ~~ផ~~ ~~ក~~ ~~ឯ~~ ~~ក~~ ~~ជ~~ ~~ន~~ ~~ភ~~ ~~ាព~~ ~~។~~

~~(2) តាមការ~~ចាំបាច់ដើម្បីពង្រីកគោលបំណងនៃចំណងជើងនេះ។

(c) អគ្គមេធាវីមិនត្រូវនាំយកវិធានការអនុវត្តច្បាប់ក្រោមចំណងជើងនេះ រហូតដល់រយៈពេលប្រាំមួយខែបន្ទាប់ពីការបោះពុម្ពផ្សាយនៃបទបញ្ជាចុងក្រោយដែលបានចេញ ដោយអនុលោមតាមផ្នែកនេះ ឬថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2020 ឬកាលបរិច្ឆេទណាមួយដែលឆាប់ជាង។

(d) ថ្វីបើមានផ្នែករង (a) បន្ទាត់ពេលវេលាសម្រាប់ការអនុវត្តបទបញ្ជាចុងក្រោយ ដែលត្រូវបានតម្រូវដោយក្រមច្បាប់ដែលបន្ថែមផ្នែករងនេះ ត្រូវនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2022។ ការចាប់ផ្តើមក្រោយថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2021 ឬរយៈពេលប្រាំមួយខែបន្ទាប់ពីទីភ្នាក់ងារផ្តល់សេចក្តីជូនដំណឹងទៅអគ្គមេធាវី ដែលត្រូវបានរៀបចំដើម្បីចាប់ផ្តើមការបង្កើតច្បាប់ក្រោម ចំណងជើងនេះ អាជ្ញាធរដែលបានចាត់តាំងទៅអគ្គមេធាវី ដើម្បីអនុវត្តបទបញ្ជាក្រោមផ្នែកនេះ ត្រូវប្រើប្រាស់ដោយទីភ្នាក់ងារការពារឯកជនភាពរដ្ឋ California។ ថ្វីបើមានច្បាប់ផ្សេងណាមួយ ការអនុវត្តរដ្ឋប្បវេណី និងរដ្ឋបាលរបស់ប្រការនៃច្បាប់ដែលបានបន្ថែម ឬបានធ្វើវិសោធនកម្មដោយក្រមច្បាប់នេះ មិនត្រូវចាប់ផ្តើមឡើយរហូតដល់ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2023 ហើយត្រូវអនុវត្តតែចំពោះការរំលោភបំពានដែលកើតឡើងនៅ ឬបន្ទាប់ពីកាលបរិច្ឆេទនោះ ប៉ុណ្ណោះ។ ការអនុវត្តប្រការនៃច្បាប់ដែលមានក្នុងក្រមច្បាប់ស្តីពីឯកជនភាពអ្នកប្រើប្រាស់ឆ្នាំ 2018 ប្រចាំរដ្ឋ California ដែលត្រូវបាន ធ្វើវិសោធនកម្មដោយក្រមច្បាប់នេះ ត្រូវនៅជាធរមាន និងអាចអនុវត្តបានរហូតដល់ប្រការដូចគ្នានៃក្រមនេះអាចអនុវត្តបាន។

ផ្នែក 22. ផ្នែក 1798.190 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.190. ការប្រឆាំងនឹងការគេចវេស

~~1798.190.~~ តុលាការ ឬទីភ្នាក់ងារត្រូវច្រានចោលជំហាន ឬប្រតិបត្តិការអន្តរកាលក្នុងគោលបំណងនៃការធ្វើឱ្យគោលបំណងមានប្រសិទ្ធភាពនៃចំណងជើងនេះ៖

(a) ប្រសិនបើស៊ើរ៉ានជំហាន ឬប្រតិបត្តិការគឺជាចំណែកសមាសភាគនៃប្រតិបត្តិការតែមួយដែលមានចេតនាចាប់ពីដំបូងដើម្បីធ្វើឡើងដោយមានបំណងជៀសវាងការឈានទៅដល់ នៃចំណងជើងនេះ ដែលរួមមានការបង្ហាញព័ត៌មានតាមរយៈអាជីវកម្មទៅភាគីទីបីដើម្បីជៀសវាងនិយមន័យការលក់ ឬការចែកចាយ។

(b) ប្រសិនបើជំហាន ឬប្រតិបត្តិការត្រូវបានធ្វើឡើងដើម្បីជៀសវាងនិយមន័យនៃការលក់ ឬ ការចែកចាយដោយចេតនា តាមរយៈការលុបបំបាត់ការពិចារណាផ្នែករូបិយវត្ថុ ឬវត្ថុមានតម្លៃផ្សេងទៀតណាមួយ រួមទាំងតាមរយៈការចុះកិច្ចសន្យាដែលមិនរាប់បញ្ចូលការដោះដូរ សម្រាប់ការពិចារណារូបិយវត្ថុ ឬវត្ថុមានតម្លៃផ្សេងទៀត ប៉ុន្តែជាកន្លែងដែលភាគីនឹង ទទួលបានអ្វីមានតម្លៃ ឬការប្រើប្រាស់ ~~តុលាការត្រូវច្រានចោលជំហាន ឬប្រតិបត្តិការអន្តរកាលនោះ ក្នុងគោលបំណងនៃការធ្វើឱ្យគោលបំណងមានប្រសិទ្ធភាពនៃចំណងជើងនេះ។~~

ផ្នែក 23. ផ្នែក 1798.192 នៃក្រមរដ្ឋប្បវេណីត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារ៖

1798.192. ការបោះបង់សិទ្ធិ

~~1798.192.~~ ប្រការណាមួយនៃកិច្ចសន្យា ឬកិច្ចព្រមព្រៀងប្រភេទណាមួយ*រួមមានការបោះបង់សិទ្ធិធ្វើសកម្មភាពអ្នកតំណាង* ដែលគាំទ្រដល់ការបោះបង់សិទ្ធិ ឬការកំណត់ព្រំដែនតាមវិធីណាមួយនៃសិទ្ធិ~~អ្នកប្រើប្រាស់~~ សិទ្ធិនៅក្រោមចំណងជើងនេះ*រួមមានប៉ុន្តែមិនកំណត់*ចំពោះសិទ្ធិណាមួយក្នុងការដោះស្រាយ ឬមធ្យោបាយនៃការអនុវត្ត ដែលផ្ទុយនឹងគោលនយោបាយសាធារណៈ*ត្រូវចាត់ទុកជានិរាករណ៍* និងមិនអាចអនុវត្តបាន។ ផ្នែកនេះមិនបង្ការអ្នកប្រើប្រាស់ពីការបដិសេធក្នុងការស្នើសុំព័ត៌មានពីអាជីវកម្ម បដិសេធលើ ~~ការជ្រើសរើសមិនចូលរួម~~*ក្នុ*ងការលក់*ក*ាលរបស់អាជីវកម្មនៃព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ឬការប្រគល់សិទ្ធិឲ្យអាជីវកម្មដើម្បីលក់ *ឬចែកចាយ*ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ក្រោយពីបានជ្រើសរើសមិនចូលរួម។

ផ្នែក 24. *ការបង្កើតទីភ្នាក់ងារការពារឯកជនភាពរដ្ឋ California*។

ផ្នែក 24.1. ផ្នែក 1798.199.10 ត្រូវបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.10. (a) មានការបង្កើតនៅក្នុងរដ្ឋាភិបាលនៃរដ្ឋនូវទីភ្នាក់ងារការពារឯកជនភាពរដ្ឋ California ដែលត្រូវបានផ្ទេរអំណាចរដ្ឋបាល អំណាចអាជ្ញាធរ និង អំណាចយុត្តាធិការទាំងស្រុង ក្នុងការអនុវត្ត និងពង្រឹងក្រមច្បាប់ស្តីពីឯកជនភាព អ្នកប្រើប្រាស់ឆ្នាំ 2018 ប្រចាំរដ្ឋ California។ ទីភ្នាក់ងារត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សារដែលមានសមាជិកប្រាំរូប រួមទាំងប្រធាន។ ប្រធាន និងសមាជិកក្រុមប្រឹក្សាមួយរូបត្រូវបានជ្រើសតាំងដោយអភិបាលរដ្ឋ។ អគ្គមេធាវីគណៈកម្មាធិការច្បាប់ព្រឹទ្ធសភា និងអ្នកនាំពាក្យសភាត្រូវជ្រើសតាំងសមាជិកមួយរូប រៀងៗខ្លួន។ ការជ្រើសតាំងទាំងនេះគួរតែធ្វើឡើងដោយជ្រើសយកពីពលរដ្ឋ California ដែលមានជំនាញក្នុង ផ្នែកឯកជនភាព បច្ចេកវិទ្យា និងសិទ្ធិអ្នកប្រើប្រាស់។

(b) ការតែងតាំងដំបូងក្នុងទីភ្នាក់ងារត្រូវធ្វើឡើង ក្នុងកំឡុងរយៈពេល 90 ថ្ងៃចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពរបស់ក្រមច្បាប់ដែលបន្ថែមក្នុងផ្នែកនេះ។

ផ្នែក 24.2. ផ្នែក 1798.199.15 ត្រូវបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.15. សមាជិកនៃក្រុមប្រឹក្សាទីភ្នាក់ងារត្រូវ៖

(a) មានលក្ខណៈសម្បត្តិ បទពិសោធន៍ និងជំនាញ ជាពិសេសក្នុងផ្នែកឯកជនភាព និងបច្ចេកវិទ្យា ដែលត្រូវការដើម្បីបំពេញតួនាទីរបស់ទីភ្នាក់ងារ និងប្រើប្រាស់អំណាចរបស់ខ្លួន។

(b) រក្សាការសម្ងាត់នៃព័ត៌មានដែលខ្លួនបានដឹងនៅអំឡុងពេលបំពេញកិច្ចការរបស់ខ្លួន ឬការប្រើប្រាស់អំណាចរបស់ខ្លួន លើកលែងតែការបង្ហាញព័ត៌មាននោះគឺជាការតម្រូវដោយក្រមច្បាប់កំណត់ត្រាសាធារណៈ (Public Records Act)។

(c) នៅតែមិនមានឥទ្ធិពលពីខាងក្រៅទោះដោយផ្ទាល់ ឬប្រយោលហើយមិនត្រូវស្វែងរកការណែនាំពីអ្នកផ្សេងឡើយ។

(d) ជៀសវាងពីសកម្មភាពដែលមិនត្រូវគ្នានឹងតួនាទីនិងការពាក់ព័ន្ធក្នុងមុខងារដែលមិនស៊ីគ្នា ទោះបីជាមានប្រយោជន៍ ឬគ្មានក្នុងពេលបំពេញការងារនោះ។

(e) មានសិទ្ធិចូលប្រើព័ត៌មានទាំងអស់ដែលផ្តល់ដោយទីភ្នាក់ងារជូនដល់ប្រធាន។

(f) ត្រូវបានរារាំងរយៈពេលមួយឆ្នាំ ក្រោយពេលចាកចេញពីការិយាល័យ ពីការទទួលយកការងារជាមួយអាជីវកម្មដែលស្ថិតនៅក្រោមសកម្មភាពអនុវត្តច្បាប់ ឬសកម្មភាពរដ្ឋប្បវេណីនៅក្នុងចំណងនេះ អំឡុងពេលកាន់មុខតំណែងរបស់សមាជិក ឬក្នុងរយៈពេលប្រាំឆ្នាំមុនការតែងតាំងរបស់សមាជិក។

(g) ត្រូវបានរារាំងសម្រាប់រយៈពេលពីរឆ្នាំ ក្រោយពេលចេញពីការិយាល័យ ពីការធ្វើសកម្មភាព សម្រាប់ការទូទាត់ប្រាក់ ក្នុងនាមជាភ្នាក់ងារ ឬមេធាវី ឬតំណាងឲ្យបុគ្គលណាម្នាក់ លើកលែងតែកិច្ចដែលមិនទាន់បញ្ចប់ មុនទីភ្នាក់ងារ ប្រសិនបើគោលបំណងគឺដើម្បីជះឥទ្ធិពលលើ សកម្មភាពរបស់ភ្នាក់ងារ។

ផ្នែក 24.3. ផ្នែក 1798.199.20 ត្រូវបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌដែលចែងថា៖

1798.199.20. សមាជិកនៃក្រុមប្រឹក្សាទីភ្នាក់ងារ រួមទាំងប្រធានត្រូវបម្រើការងារទៅតាមសេចក្តីត្រូវការរបស់អាជ្ញាធរតែងតាំង ប៉ុន្តែមិនត្រូវបម្រើយូរជាងប្រាំបីឆ្នាំជាប់គ្នាទេ។

ផ្នែក 24.4. ផ្នែក 1798.199.25 ត្រូវបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌដែលចែងថា៖

1798.199.25. សម្រាប់រាល់ថ្ងៃដែលខ្លួនបំពេញការងារក្នុងភារកិច្ចផ្លូវការ សមាជិកនៃក្រុមប្រឹក្សា ទីភ្នាក់ងារត្រូវទទួលបានប្រាក់កម្រៃក្នុងអត្រាមួយរយដុល្លារ ($100) ដោយកែតម្រូវកន្លះឆ្នាំម្តង ដើម្បីឆ្លុះបញ្ចាំងការប្រែប្រួលតម្លៃរស់នៅ ហើយត្រូវទូទាត់សងសម្រាប់ការចំណាយដែលកើតឡើងក្នុងពេលបំពេញភារកិច្ចផ្លូវការរបស់ពួកគេ។

ផ្នែក 24.5. ផ្នែក 1798.199.30 ត្រូវបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌដែលចែងថា៖

1798.199.30. ក្រុមប្រឹក្សាទីភ្នាក់ងារត្រូវតែងតាំងនាយកប្រតិបត្តិដែលត្រូវបំពេញកិច្ចការស្របតាមគោលនយោបាយបទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ និងច្បាប់ជាធរមាន។ ទីភ្នាក់ងារត្រូវតែងតាំង និងបញ្ចប់ភារកិច្ចមន្ត្រីក្រុមប្រឹក្សា និងបុគ្គលិកស្របទៅតាមច្បាប់មុខងារសាធារណៈជាធរមាន ហើយត្រូវដោះស្រាយការទូទាត់ប្រាក់របស់បុគ្គលិកស្របតាមតួនាទីរបស់បុគ្គលិកទាំងនោះ។ ទីភ្នាក់ងារអាចចុះកិច្ចសន្យាម៉ៅការសម្រាប់សេវាកម្មដែលមិនអាចផ្តល់ដោយបុគ្គលិករបស់ខ្លួនបាន។

ផ្នែក 24.6. ផ្នែក 1798.199.35 ត្រូវបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌដែលចែងថា៖

1798.199.35. ក្រុមប្រឹក្សាទីភ្នាក់ងារអាចផ្ទេរសិទ្ធិអំណាចទៅប្រធាន ឬនាយកប្រតិបត្តិដើម្បីបំពេញការងារក្នុងនាមជាទីភ្នាក់ងារ រវាងការប្រជុំរបស់ទីភ្នាក់ងារ លើកលែងតែទាក់ទងនឹងសេចក្តីសម្រេចនៃសកម្មភាពអនុវត្តច្បាប់ និងការបង្កើត វិធាននានា។

ផ្នែក 24.7. ផ្នែក 1798.199.40 ត្រូវបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌដែលចែងថា៖

1798.199.40. ទីភ្នាក់ងារត្រូវបំពេញមុខងារដូចខាងក្រោម៖

(a) គ្រប់គ្រង អនុវត្ត និងពង្រឹងសកម្មភាពរដ្ឋបាលនៃចំណងជើងនេះ ។

(b) នៅថ្ងៃ និងក្រោយថ្ងៃ 1 ខែកក្កដា ឆ្នាំ 2021 ឬ ក្នុងរយៈពេលប្រាំមួយខែ ក្រោយពីទីភ្នាក់ងារបានផ្តល់ដល់អគ្គមេធាវីនូវសេចក្តីជូនដំណឹងថាខ្លួនបានត្រៀមរួចរាល់ក្នុងការទទួលយក ទំនួលខុសត្រូវក្នុងការបង្កើតច្បាប់នៅក្រោមចំណងជើងនេះ អនុវត្ត ធ្វើវិសោធនកម្ម និងលុបចោលបទបញ្ជានានា ដោយអនុលោមតាមផ្នែក 1798.185 ដើម្បីអនុវត្តគោលបំណង និងប្រការនៃច្បាប់ស្តីពីសិទ្ធិឯកជនភាពរបស់អ្នកប្រើប្រាស់រដ្ឋ California ឆ្នាំ 2018 ដែលរួមមានបទបញ្ជាដែលបញ្ជាក់ពីតម្រូវការនៃការរក្សាកំណត់ត្រាសម្រាប់អាជីវកម្ម ដើម្បីធានាបានអនុលោមភាពតាមចំណងជើងនេះ។

(c) តាមរយៈការអនុវត្តនៃចំណងជើងនេះ ការពារសិទ្ធិឯកជនភាពជាមូលដ្ឋានរបស់រូបវន្តបុគ្គល ដែលទាក់ទងនឹងការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ។

(d) លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការយល់ដឹងអំពីហានិភ័យ ច្បាប់ ទំនួលខុសត្រូវ ការការពារ និងសិទ្ធិនានាទាក់ទងនឹងការប្រមូល ការប្រើប្រាស់ ការលក់ និងការបង្ហាញព័ត៌មានផ្ទាល់ខ្លួន រួមទាំងសិទ្ធិអនីតិជនដែលទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ និងដើម្បីផ្តល់របាយការណ៍សាធារណៈដែលសង្ខេបពីការវាយតម្លៃហានិភ័យដែលត្រូវតម្កល់ទុកនៅទីភ្នាក់ងារដោយអនុលោមតាមកថាខណ្ឌ (15) នៃផ្នែករង (a) នៃផ្នែក 1798.185 ខណៈពេលធានា ថាសុវត្ថិភាពទិន្នន័យមិនត្រូវបានខូចខាត។

(e) ផ្តល់ការណែនាំដល់អ្នកប្រើប្រាស់ទាក់ទងនឹងសិទ្ធិរបស់ពួកគេ នៅក្រោមចំណងជើងនេះ ។

(f) ផ្តល់ការណែនាំដល់អាជីវកម្មទាក់ទងនឹងតួនាទី និងទំនួលខុសត្រូវរបស់ពួកគេក្រោមចំណងជើងនេះ ហើយតែងតាំងប្រធានសវនករឯកជនភាពដើម្បីធ្វើសវនកម្មអាជីវកម្មដើម្បីធានា អនុលោមភាពតាមចំណងជើងនេះ ដែលស្របតាមបទបញ្ជាដែលបានអនុវត្ត អនុលោមតាមកថាខណ្ឌ (18) នៃផ្នែករង (a) នៃផ្នែក 1798.185 ។

(g) ផ្តល់ជំនួយបច្ចេកទេស និងដំបូន្មានទៅរដ្ឋសភាតាមការស្នើសុំទាក់ទងនឹងការបង្កើតច្បាប់ឯកជនភាព។

(h) ត្រួតពិនិត្យការវិវឌ្ឍន៍ពាក់ព័ន្ធនឹងការការពារព័ត៌មានផ្ទាល់ខ្លួន និងជាពិសេស ការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង និងការអនុវត្តពាណិជ្ជកម្ម។

(i) សហការជាមួយទីភ្នាក់ងារផ្សេងទៀតដែលមានយុត្តាធិការលើច្បាប់ឯកជនភាព និងជាមួយអាជ្ញាធរដំណើរការទិន្នន័យរដ្ឋ California រដ្ឋផ្សេងទៀត ដែនដី និងបណ្តាប្រទេសនានា ដើម្បីធានាបាននូវការអនុវត្តជាប្រចាំនូវការការពារឯកជនភាព។

(j) បង្កើតយន្តការដោយអនុលោមតាមបុគ្គលដែលកំពុងធ្វើជំនួញនៅរដ្ឋ California ដែលមិនបំពេញតាមនិយមន័យនៃអាជីវកម្ម ដែលមានចែងក្នុងកថាខណ្ឌ (1), (2) ឬ (3) នៃផ្នែករង (d) នៃផ្នែក 1798.140 អាចបញ្ជាក់ដោយស្ម័គ្រចិត្តថា ពួកគេអនុលោមតាមចំណងជើងនេះ ដូចមានចែងក្នុងកថាខណ្ឌទី (4) នៃផ្នែករង (d) នៃមាត្រា 1798.140 ហើយធ្វើឲ្យបញ្ជីឈ្មោះអង្គភាពទាំងនោះអាចរកបានដល់សាធារណៈជន។

(k) រៃអង្គាស ពិនិត្យឡើងវិញ និងអនុម័តពាក្យសុំជំនួយ ដល់កម្រិតមួយដែលមូលនិធិមានលទ្ធភាពប្រើប្រាស់បាន ដោយអនុលោមតាមកថាខណ្ឌទី (2) នៃផ្នែករង (b) នៃផ្នែកទី 1798.160។

(l) ធ្វើសកម្មភាពផ្សេងទៀតទាំងអស់ដែលចាំបាច់ ឬសមរម្យនៅក្នុងការអនុវត្តសិទ្ធិ អំណាច និងយុត្តាធិការរបស់ខ្លួន និងស្វែងរកការផ្លាំងផ្លែងគោលដៅនៃការពង្រឹងឯកជនភាពអ្នកប្រើប្រាស់ ដោយផ្តល់ការយកចិត្តទុកដាក់ទៅលើផលប៉ះពាល់ទៅលើអាជីវកម្ម។

ផ្នែកទី 24.8. ផ្នែកទី 1798.199.45 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.45. (a) នៅពេលមានបណ្តឹងដោយទៀងត្រង់របស់បុគ្គលណាម្នាក់ ឬដោយផ្អែកលើគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ទីភ្នាក់ងារអាចស្ទើបអង្កេតទៅលើការរំលោភបំពានដែលអាចកើតឡើងលើចំណងជើងនេះ ដែលពាក់ព័ន្ធនឹងអាជីវកម្ម អ្នកផ្តល់សេវា អ្នកម៉ៅការ ឬបុគ្គលណាម្នាក់។ ទីភ្នាក់ងារអាចសម្រេចចិត្តមិនស្ទើបអង្កេតទៅលើពាក្យបណ្តឹង ឬសម្រេចចិត្តផ្តល់ជូនអាជីវកម្មជាមួយនឹងកំឡុងពេលមួយដើម្បីកែខៃការរំលោភបំពានដែលបានចោទប្រកាន់។ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តមិនស្ទើបអង្កេត ឬផ្តល់ពេលវេលាបន្ថែមដើម្បីកែខៃ ទីភ្នាក់ងារអាចពិចារណាលើចំណុចខាងក្រោម៖

(1) កង្វះចេតនាក្នុងការរំលោភបំពានចំណងជើងនេះ។

(2) កិច្ចប្រឹងប្រែងដោយស្ម័គ្រចិត្តដែលធ្វើឡើងដោយអាជីវកម្ម អ្នកផ្តល់សេវា អ្នកម៉ៅការ ឬបុគ្គលណាម្នាក់ដើម្បីកែខៃការរំលោភបំពានដែលបានចោទប្រកាន់ មុនពេលត្រូវបានជូនដំណឹងដោយទីភ្នាក់ងារអំពីពាក្យបណ្តឹងនោះ។

(b) ទីភ្នាក់ងារត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដែលបានធ្វើពាក្យបណ្តឹងទៅលើវិធានការ ប្រសិនបើមាន ដែលទីភ្នាក់ងារបានចាត់ធ្វើ ឬមានផែនការចាត់វិធានការទៅលើពាក្យបណ្តឹងនេះ ព្រមទាំងហេតុផលសម្រាប់បណ្តឹង ឬមិនមែនបណ្តឹង។

ផ្នែកទី 24.9. ផ្នែកទី 1798.199.50 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.50. គ្មានការរកឃើញនូវមូលហេតុប្រហាក់ប្រហែលដែលត្រូវជឿជាក់ថាចំណងជើងនេះត្រូវបានរំលោភបំពាន ត្រូវបានធ្វើឡើងដោយទីភ្នាក់ងារឡើយ លើកលែងតែក្នុងរយៈពេលយ៉ាងតិច 30 ថ្ងៃមុនការពិចារណារបស់ទីភ្នាក់ងារទៅលើការរំលោភបំពានដែលបានចោទប្រកាន់ អាជីវកម្ម អ្នកផ្តល់សេវា អ្នកម៉ៅការ ឬបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានរំលោភបំពានលើចំណងជើងនេះត្រូវបានជូនដំណឹងអំពីការរំលោភបំពានដោយសេវាដំណើរការ ឬប្រៃសណីយ៍ដែលបានចុះបញ្ជីជាមួយនឹងបង្ការ៖ដៃទទួលធ្វើត្រឡប់ដែលបានស្នើសុំដែលផ្តល់ជូនជាមួយនឹងសេចក្តីសង្ខេបភ័ស្តុតាង និងទទួលបានដំណឹងអំពីសិទ្ធិរបស់ខ្លួនដែលត្រូវមានវត្តមានដោយផ្ទាល់ និងត្រូវបានតំណាងដោយក្រុមប្រឹក្សានៅក្នុងរឿងក្តីណាមួយរបស់ទីភ្នាក់ងារដែលធ្វើឡើងក្នុងគោលបំណងពិចារណាថាតើ មានមូលហេតុប្រហាក់ប្រហែលសម្រាប់ជឿជាក់ថាបុគ្គលនោះបានរំលោភបំពានលើចំណងជើងនេះដែរឬទេ។ សេចក្តីជូនដល់អ្នករំលោភបំពានដែលត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាត្រូវបានធ្វើឡើងនៅកាលបរិច្ឆេទនៃសេវា ជាកាលបរិច្ឆេទដែលបានចុះហត្ថលេខាលើការទទួលសំបុត្រដែលបានចុះបញ្ជីនេះ ឬប្រសិនបើការទទួលសំបុត្រដែលបានចុះបញ្ជីនេះ កាលបរិច្ឆេទដែលធ្វើត្រឡប់ដោយការិយាល័យប្រៃសណីយ៍។ ដំណើររឿងក្តីដែលធ្វើឡើងសម្រាប់គោលបំណងនៃការពិចារណាទៅលើមូលហេតុប្រហាក់ប្រហែលត្រូវមានលក្ខណៈឯកជន លើកលែងតែអ្នករំលោភបំពានដែលត្រូវបានចោទប្រកាន់ដាក់សំណើរជាលាយលក្ខណ៍ជាមួយទីភ្នាក់ងារថាដំណើររឿងក្តីនោះមានលក្ខណៈជាសាធារណៈ។

ផ្នែកទី 24.10. ផ្នែកទី 1798.199.55 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.55. (a) នៅពេលទីភ្នាក់ងារកំណត់ថាមានមូលហេតុប្រហាក់ប្រហែលសម្រាប់ជឿជាក់ថា ចំណងជើងនេះត្រូវបានរំលោភបំពាននោះ ទីភ្នាក់ងារត្រូវបើកសវនាការមួយដើម្បីកំណត់ថាតើការរំលោភបំពានមួយ ឬការរំលោភបំពានទាំងឡាយបានកើតឡើងដែរឬទេ។ សេចក្តីជូនដំណឹងត្រូវផ្តល់ជូន ហើយសវនាការដែលបានធ្វើឡើងដោយអនុលោមតាមច្បាប់ស្តីពីនីតិវិធីរដ្ឋបាល (ជំពូកទី 5 [លដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 11500] ភាគទី 1 ចំណែកទី 3 ចំណងជើងទី 2 ក្រមរដ្ឋាភិបាល)។ ទីភ្នាក់ងារត្រូវមានសិទ្ធិអំណាចដែលបានផ្តល់ជូនដោយជំពូកនោះ។ ប្រសិនបើទីភ្នាក់ងារកំណត់ដោយឈរលើមូលដ្ឋាននៃសវនាការដែលបានធ្វើឡើងដោយអនុលោមតាមផ្នែករងនេះ ដែលថាការរំលោភបំពានមួយ ឬការរំលោភបំពានទាំងឡាយបានកើតឡើងនោះ ទីភ្នាក់ងារត្រូវចេញដីការមួយដែលអាចតម្រូវឲ្យអ្នករំលោភបំពាននោះធ្វើដូចខាងក្រោម៖

(1) បញ្ឈប់ និងឈប់ធ្វើការរំលោភបំពានលើចំណងជើងនេះ។

24

(2) ស្ថិតក្រោមផ្នែកទី 1798.155 បង់ប្រាក់ពិន័យរដ្ឋបាលរហូតដល់ពីរពាន់ប្រាំរយដុល្លារ ($2,500) សម្រាប់ការរំលោភបំពាននីមួយៗ ឬរហូតដល់ប្រាំពីរពាន់ប្រាំរយដុល្លារ ($7,500) សម្រាប់ការរំលោភបំពានដោយចេតនានីមួយៗ និងការរំលោភបំពាននីមួយៗដែលពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ជាអនីតិជនទៅកាន់មូលនិធិឯកជនភាពអ្នកប្រើប្រាស់នៅក្នុងមូលនិធិទូទៅរបស់រដ្ឋ។ នៅពេលទីភ្នាក់ងារកំណត់ថា គ្មានការរំលោភបំពានអ្វីមួយកើតឡើងទេនោះ ទីភ្នាក់ងារត្រូវផ្សព្វផ្សាយអំពីសេចក្ដីថ្លែងការណ៍បែបនោះ។

(b) ប្រសិនបើមានបុគ្គលពីរនាក់ ឬច្រើននាក់ទទួលខុសត្រូវចំពោះរាល់ការរំលោភបំពានណាមួយ ឬការរំលោភបំពានទាំងឡាយ ពួកគេត្រូវទទួលខុសត្រូវរួមគ្នា និងច្រើនគ្នា។

ផ្នែកទី 24.11. ផ្នែកទី 1798.199.60 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.60. នៅពេលណាទីភ្នាក់ងារច្រានចោលសេចក្ដីសម្រេចរបស់ចៅក្រមច្បាប់រដ្ឋបាល ដោយអនុលោមតាមផ្នែកទី 11517 នៃក្រមរដ្ឋាភិបាល ទីភ្នាក់នោះត្រូវបញ្ជាក់មូលហេតុជាលាយលក្ខណ៍អក្សរសម្រាប់ការច្រានចោលសេចក្ដីសម្រេចនោះ។

ផ្នែកទី 24.12. ផ្នែកទី 1798.199.65 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.65. ទីភ្នាក់ងារអាចចេញដីកាកោះសាក្សី តម្រូវឲ្យមានការចូលរួម និងការផ្ដល់កសិណសាក្សីរបស់ពួកគេ គ្រប់គ្រងការស្បថ និងការបញ្ជាក់អះអាង យកភ័ស្តុតាង និងតម្រូវដោយដីកាកោះសាក្សីនូវការផលិតសៀវភៅ ឯកសារ កំណត់ត្រា ឬសម្ភារឯកសារផ្សេងទៀតចំពោះការធ្វើករណីយកិច្ចរបស់ទីភ្នាក់ងារ ឬអនុវត្តសិទ្ធិអំណាចរបស់ខ្លួនរួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ សិទ្ធិអំណាចរបស់ខ្លួនក្នុងការធ្វើសវនកម្មអនុលោមភាពរបស់អាជីវកម្មជាមួយនឹងចំណងជើងនេះ។

ផ្នែកទី 24.13. ផ្នែកទី 1798.199.70 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.70. គ្មានបណ្ដឹងរដ្ឋបាលណាមួយដែលត្រូវបានប្ដឹងដោយអនុលោមតាមចំណងជើងនេះ ដែលចោទប្រកាន់ការរំលោភបំពានទៅលើបទបញ្ញត្តិណាមួយនៃចំណងជើងនេះ ត្រូវចាប់ផ្ដើមលើសពីប្រាំឆ្នាំក្រោយបរិច្ឆេទដែលការរំលោភបំពាននោះកើតឡើង។

(a) សេវានៃសេចក្ដីជូនដំណឹងអំពីសវនការលើមូលហេតុប្រហាក់ប្រហែល ដូចដែលបានតម្រូវដោយផ្នែកទី 1798.199.50 ទៅលើបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានរំលោភបំពានចំណងជើងនេះ ត្រូវបង្កើតបានជាការចាប់ផ្ដើមនៃវិធានការរដ្ឋបាល។

(b) ប្រសិនបើបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានរំលោភបំពានចំណងជើងនេះពាក់ព័ន្ធនៅក្នុងការលាក់កំបាំងបែបក្លែងបន្លំនូវអំពើរ ឬអត្តសញ្ញាណរបស់បុគ្គលណាម្នាក់នោះ ត្រូវពន្យារពេលប្រាំឆ្នាំសម្រាប់រយៈពេលនៃការលាក់កំបាំងនោះ។ សម្រាប់គោលបំណងនៃផ្នែករងនេះ "ការលាក់កំបាំងបែបក្លែងបន្លំ" មានន័យថា បុគ្គលម្នាក់បានដឹងអំពីអង្គហេតុជាសារវ័ន្តដែលទាក់ទងនឹងករណីយកិច្ចរបស់បុគ្គលម្នាក់ដែលស្ថិតក្រោមចំណងជើងនេះ ហើយលាក់កំបាំងវាដោយចេតនានៅក្នុងការអនុវត្ត ឬលុបចោលការអនុវត្តករណីយកិច្ចទាំងនោះសម្រាប់គោលបំណងនៃការបោកប្រាស់សាធារណជននូវព័ត៌មានដែលមានសិទ្ធិក្រោមចំណងជើងនេះ។

(c) ប្រសិនបើ នៅពេលត្រូវបានបង្គាប់បញ្ជាដោយតុលាការកំពូលឲ្យផលិតឯកសារណាមួយដែលស្វែងរកដោយដីកាកោះហៅសាក្សីមួយនៅក្នុងរឿងក្ដីរដ្ឋបាលក្រោមចំណងជើងនេះ បុគ្គលដែលត្រូវបានចោទប្រកាន់ថាបានរំលោភបំពានចំណងជើងនេះខកខានមិនបានផលិតឯកសារដែលធ្លើយតបទៅនឹងដីកាត្រឹមកាលបរិច្ឆេទដែលត្រូវបានបង្គាប់ឲ្យអនុលោមតាមទេនោះ ត្រូវពន្យារពេលប្រាំឆ្នាំសម្រាប់រយៈពេលនៃការពន្យារ ដោយគិតពីកាលបរិច្ឆេទនៃការដាក់ញត្តិដើម្បីបង្ខិតបង្ខំរហូតដល់កាលបរិច្ឆេទដែលឯកសារទាំងនោះត្រូវបានផលិត។

ផ្នែកទី 24.14. ផ្នែកទី 1798.199.75 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.75. (a) បន្ថែមពីលើដំណោះស្រាយណាមួយដែលមានលទ្ធភាពអាចប្រើប្រាស់បាន ទីភ្នាក់ងារអាចដាក់បណ្ដឹងរដ្ឋប្បវេណី និងទទួលបានសាលក្រមនៅក្នុងតុលាការកំពូលសម្រាប់គោលបំណងប្រមូលប្រាក់ពិន័យរដ្ឋបាលដែលមិនទាន់បានបង់ ដែលដាក់បង្ខំឲ្យបង់ដោយអនុលោមតាមចំណងជើងនេះ ក្រោយពីផុតកំណត់ការពិនិត្យផ្នែកច្បាប់ឡើងវិញរបស់ទីភ្នាក់ងារ។ បណ្ដឹងនេះអាចត្រូវបានដាក់ជាពាក្យបណ្ដឹងតូចៗ បណ្ដឹងរដ្ឋប្បវេណីមានកម្រិត ឬគ្មានកម្រិតដែលអាស្រ័យទៅលើតម្លៃក្ដីនោះ។ យុត្តាធិការនៃបណ្ដឹងនេះ ត្រូវស្ថិតក្នុងខោនធីដែលប្រាក់ពិន័យរដ្ឋបាលត្រូវបានបង្ខំដោយទីភ្នាក់ងារនេះ។ ដើម្បីទទួលសាលក្រមនៅក្នុងរឿងក្ដីក្រោមផ្នែកនេះ បន្ទាប់ពីនីតិវិធី និងវិធាននៃភ័ស្តុតាងដូចមានអនុវត្តនៅ ក្នុងបណ្ដឹងរដ្ឋប្បវេណីធម្មតា ទីភ្នាក់ងារត្រូវបង្ហាញថា៖

(1) ប្រាក់ពិន័យរដ្ឋបាលត្រូវបានដាក់បង្ខំតាមនីតិវិធីដែលមានចែងនៅក្នុងចំណងជើងនេះ និងនីតិវិធីអនុវត្ត។

(2) ចុងចោទ ឬបណ្ដាចុងចោទនៅក្នុងបណ្ដឹងនេះត្រូវបានជូនដំណឹងដោយសេចក្ដីជូនដំណឹងជាក់ស្ដែង ឬស្ថាបនា អំពីការដាក់បង្ខំប្រាក់ពិន័យរដ្ឋបាល។

(3) តម្រូវការនូវការទូទាត់ប្រាក់ត្រូវបានធ្វើឡើងដោយទីភ្នាក់ងារ ហើយការទូទាត់ពេញលេញនៅមិនទាន់បានទទួលនៅឡើយទេ។

(b) បណ្ដឹងរដ្ឋប្បវេណីដែលប្ដឹងដោយអនុលោមតាមផ្នែករង (a) ត្រូវចាប់ផ្ដើមក្នុងរយៈពេលបួនឆ្នាំក្រោយបរិច្ឆេទដែលបានដាក់បង្ខំប្រាក់ពិន័យរដ្ឋបាល។

ផ្នែកទី 24.15. ផ្នែកទី 1798.199.80 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.80. (a) ប្រសិនបើរយៈពេលសម្រាប់ការពិនិត្យផ្នែកច្បាប់ឡើងវិញនៃដីកា ឬសេចក្ដីសម្រេចជាស្ថាពររបស់ទីភ្នាក់ងារ ឬប្រសិនបើមធ្យោបាយទាំងអស់នៃការពិនិត្យផ្នែកច្បាប់ឡើងវិញនៃដីកា ឬសេចក្ដីសម្រេចបានផុតកំណត់ ទីភ្នាក់ងារអាចដាក់ស្នើជូនក្រឡាបញ្ជីតុលាការ ដើម្បីសុំសាលក្រមប្រមូលប្រាក់ពិន័យរដ្ឋបាលដែលដាក់បង្ខំដោយដីកា ឬសេចក្ដីសម្រេច ឬដីកាដូចដែលបានកែប្រែស្របទៅតាមសេចក្ដីសម្រេចទៅលើការពិនិត្យផ្នែកច្បាប់ឡើងវិញ។

(b) ពាក្យសុំ ដែលត្រូវដាក់បញ្ចូលនូវសេចក្ដីចម្លងបញ្ជាក់នៃដីកា ឬសេចក្ដីសម្រេចមួយច្បាប់ ឬដីកាដូចដែលបានកែប្រែដោយអនុលោមតាមសេចក្ដីសម្រេចទៅលើផ្នែកច្បាប់ឡើងវិញ និងភ័ស្តុតាងនៃសេវារបស់ដីកា ឬសេចក្ដីសម្រេច បង្កើតបានជាការបង្ហាញគ្រប់គ្រាន់ដើម្បីធានានូវការចេញសាលក្រមដើម្បីប្រមូលប្រាក់ពិន័យរដ្ឋបាល។ ក្រឡាបញ្ជីតុលាការត្រូវចូលសាលក្រមជាធរមានភ្លាមៗដោយអនុលោមតាមពាក្យសុំ។

(c) ពាក្យសុំដែលបានធ្វើឡើងដោយអនុលោមតាមផ្នែកនេះ ត្រូវធ្វើឡើងដោយក្រឡាបញ្ជីតុលាការកំពូលនៅក្នុងខោនធី ដែលប្រាក់ពិន័យរដ្ឋបាលត្រូវបានដាក់បង្ខំដោយទីភ្នាក់ងារ។

(d) សាលក្រមដែលចូលជាធរមានដោយអនុលោមតាមផ្នែកនេះ មានអានុភាព និងប្រសិទ្ធិដូចគ្នា ហើយស្ថិតក្រោមបទបញ្ញត្តិទាំងអស់នៃច្បាប់ដែលទាក់ទងនឹងសាលក្រមនៅក្នុងបណ្ដឹងរដ្ឋប្បវេណី ហើយអាចត្រូវបានអនុវត្តនៅក្នុងលក្ខណៈដូចគ្នានឹងសាលក្រមផ្សេងទៀតរបស់តុលាការដែលសាលក្រមនេះត្រូវបានបញ្ចូលជាធរមាន។

24

(e) ទីភ្នាក់ងារអាចដាក់ពាក្យដោយអនុលោមតាមផ្នែកនេះក្នុងរយៈពេលតែបួនឆ្នាំប៉ុណ្ណោះ ក្រោយកាលបរិច្ឆេទដែលគ្រប់មធ្យោបាយនៃការពិនិត្យផ្នែកច្បាប់ឡើងវិញនៃដីកា និងសេចក្ដីសម្រេចបានផុតកំណត់។

(f) ដំណោះស្រាយដែលមានលទ្ធភាពប្រើប្រាស់បានក្រោមច្បាប់នេះ គឺជាការបន្ថែមពីលើដំណោះស្រាយទាំងឡាយដែលមានលទ្ធភាពប្រើប្រាស់បានក្រោមច្បាប់ណាមួយផ្សេងទៀត។

ផ្នែកទី 24.16. ផ្នែកទី 1798.199.85 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.85. រាល់សេចក្ដីសម្រេចរបស់ទីភ្នាក់ងារ ទាក់ទងនឹងពាក្យបណ្ដឹង ឬប្រាក់ពិន័យរដ្ឋបាល ត្រូវស្ថិតក្រោមការពិនិត្យផ្នែកច្បាប់ឡើងវិញនៅក្នុងបណ្ដឹងមួយដែលប្ដឹងដោយភាគីដែលជាប្រយោជន៍នៃពាក្យបណ្ដឹង ឬប្រាក់ពិន័យរដ្ឋបាល ហើយត្រូវស្ថិតក្រោមការបំពានស្ដង់ដារឆន្ទានុសិទ្ធិ។

ផ្នែកទី 24.17. ផ្នែកទី 1798.199.90 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.90. (a) រាល់អាជីវកម្ម អ្នកផ្ដល់សេវា អ្នកម៉ៅការ ឬបុគ្គលផ្សេងទៀតដែលរំលោភបំពានទៅលើចំណងជើងនេះ ត្រូវស្ថិតក្រោមអធិបញ្ជាមួយនិងទទួលខុសត្រូវចំពោះទោសបញ្ញត្តិរដ្ឋប្បវេណីមិនលើសពីរពាន់ប្រាំរយដុល្លារ ($2,500) សម្រាប់ការរំលោភបំពាននីមួយៗ ឬប្រាំពីរពាន់ប្រាំរយដុល្លារ ($7,500) សម្រាប់ការរំលោភបំពានដោយចេតនានីមួយៗ ហើយការរំលោភបំពាននីមួយៗដែលពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ជាអនីតិជន ដូចដែលបានលៃតម្រូវដោយអនុលោមតាមកថាខណ្ឌ (5) នៃផ្នែករង (a) នៃផ្នែកទី 1798.185 ដែលត្រូវវាយតម្លៃ និងស្តារឡើងវិញនៅក្នុងបណ្ដឹងរដ្ឋប្បវេណីដែលប្ដឹងក្នុងនាមជាប្រជាពលរដ្ឋ California ដោយអគ្គមេធាវី។ តុលាការអាចពិចារណាអំពីកិច្ចសហការដោយស្មោះត្រង់របស់អាជីវកម្ម អ្នកផ្ដល់សេវា អ្នកម៉ៅការ ឬបុគ្គលដទៃទៀត នៅក្នុងការកំណត់អំពីស្ថានទម្ងន់នៃទោសបញ្ញត្តិរដ្ឋប្បវេណី។

(b) រាល់ទោសបញ្ញត្តិរដ្ឋប្បវេណីដែលស្តារឡើងវិញដោយបណ្ដឹងមួយដែលប្ដឹងដោយអគ្គមេធាវីសម្រាប់ការរំលោភបំពានលើចំណងជើងនេះ និងប្រាក់ចំណូលពីដំណោះស្រាយណាមួយទៅលើបណ្ដឹងដែលបានពោលមកនេះ ត្រូវដាក់ចូលក្នុងមូលនិធិឯកជនភាពអ្នកប្រើប្រាស់ ។

(c) ក្រោយពីមានសំណើដោយអគ្គមេធាវី ទីភ្នាក់ងារត្រូវចាត់វិធានការរដ្ឋបាល ឬការស៊ើបអង្កេតណាមួយក្រោមចំណងជើងនេះ ដើម្បីអនុញ្ញាតឲ្យអគ្គមេធាវីដំណើរការជាមួយនឹងការស៊ើបអង្កេត ឬបណ្ដឹងរដ្ឋប្បវេណី ហើយមិនត្រូវបន្តវិធានការរដ្ឋបាល ឬការស៊ើបអង្កេត លើកលែងតែអគ្គមេធាវីកំណត់ជាបន្តបន្ទាប់ថាមិនបន្តការស៊ើបអង្កេត ឬបណ្ដឹងរដ្ឋប្បវេណី។ ទីភ្នាក់ងារមិនអាចកំណត់ព្រំដែននៃសិទ្ធិអំណាចរបស់អគ្គមេធាវីក្នុងការអនុវត្តចំណងជើងនេះបានឡើយ។

(d) គ្មានបណ្ដឹងរដ្ឋប្បវេណីណាមួយអាចត្រូវបានដាក់ដោយអគ្គមេធាវីក្រោមផ្នែកនេះសម្រាប់រាល់ការរំលោភបំពានណាមួយលើចំណងជើងនេះ ក្រោយពីទីភ្នាក់ងារនោះបានចេញនូវសេចក្ដីសម្រេចមួយដែលអនុលោមតាមផ្នែកទី 1798.199.85 ឬដីកាមួយដែលអនុលោមតាមផ្នែកទី 1798.199.55 ប្រឆាំងនឹងបុគ្គលនោះសម្រាប់ការរំលោភបំពានដូចគ្នានោះទេ។

(e) ផ្នែកនេះមិនត្រូវប៉ះពាល់ទៅលើសិទ្ធិឯកជននៃបណ្ដឹងដែលមានចែងនៅក្នុងផ្នែកទី 1798.150 ឡើយ។

ផ្នែកទី 24.18. ផ្នែកទី 1798.199.95 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌដែលចែងថា៖

1798.199.95. (a) មានការលៃបម្រុងពីមូលនិធិទូទៅរបស់រដ្ឋទៅកាន់ទីភ្នាក់ងារនូវចំនួនទឹកប្រាក់ប្រាំលានដុល្លារ ($5,000,000) អំឡុងឆ្នាំសារពើពន្ធលើកទីមួយ 2020–2021 ហើយចំនួនទឹកប្រាក់ដប់លានដុល្លារ ($10,000,000) ដែលត្រូវបានលៃតម្រូវសម្រាប់ការប្រែប្រួលថ្លៃចំណាយក្នុងការរស់នៅ អំឡុងឆ្នាំសារពើពន្ធនីមួយៗក្រោយមកទៀតសម្រាប់ការចំណាយដើម្បីគាំទ្រដល់ប្រតិបត្តិការនៃទីភ្នាក់ងារដែលអនុលោមតាមចំណងជើងនេះ។ ការចំណាយនៃមូលនិធិក្រោមការបម្រុងទុកនេះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរដ្ឋបាលធម្មតាឡើងវិញដែលបានផ្ដល់ជូនសម្រាប់ការបម្រុងទុករបស់រដ្ឋផ្សេងទៀត។ រដ្ឋសភាត្រូវធ្វើវិភាជន៍ចំនួនប្រាក់បន្ថែមទៅកាន់គណៈកម្មការ និងទីភ្នាក់ងារផ្សេងទៀតតាមការចាំបាច់ ដើម្បីអនុវត្តបទបញ្ញត្តិទាំងឡាយនៃចំណងជើងនេះ។

(b) ក្រសួងហិរញ្ញវត្ថុ នៅក្នុងការរៀបចំថវិការដ្ឋ និងច្បាប់ថវិកា (Budget Act) ដែលបានដាក់ជូនរដ្ឋសភា ត្រូវដាក់បញ្ចូលនូវចំណុចមួយសម្រាប់ការគាំទ្រលើចំណងជើងនេះ ដែលត្រូវបង្ហាញនូវចំណុចទាំងអស់ដូចខាងក្រោម៖

(1) ចំនួនទឹកប្រាក់ដែលត្រូវធ្វើលៃបម្រុងទៅកាន់ទីភ្នាក់ងារផ្សេងទៀតដើម្បីអនុវត្តក្រោមចំណងជើងនេះ ដែលចំនួនទឹកប្រាក់នោះត្រូវស្ថិតនៅក្នុងការបន្ថែមចំណុចគាំទ្រនៃទីភ្នាក់ងារទាំងនោះ។

(2) ចំនួនទឹកប្រាក់បន្ថែមដែលត្រូវការដើម្បីធ្វើការលៃបម្រុងដោយអង្គនីតិបញ្ញត្តិទៅកាន់ទីភ្នាក់ងារនោះ ដើម្បីអនុវត្តគោលបំណងទាំងឡាយនៃចំណងជើងនេះ ដូចមានចែងនៅក្នុងផ្នែកនេះ។

(3) សម្រាប់គោលបំណងជាព័ត៌មាន នៅក្នុងវង់ក្រចក ការលៃបម្រុងជាបន្តអំឡុងឆ្នាំសារពើពន្ធនីមួយៗចំនួនដប់លានដុល្លារ ($10,000,000) ដែលត្រូវបានលៃតម្រូវសម្រាប់ការប្រែប្រួលថ្លៃចំណាយលើការរស់នៅដែលបានធ្វើឡើងដោយអនុលោមតាមផ្នែកនេះ។

(c) អគ្គមេធាវីត្រូវផ្ដល់ការគាំទ្រផ្នែកបុគ្គលិកដល់ទីភ្នាក់ងាររហូតទាល់តែទីភ្នាក់ងារនោះជួលបុគ្គលិកផ្ទាល់ខ្លួនបាន។ អគ្គមេធាវីត្រូវទទួលបានសំណងវិញពីទីភ្នាក់ងារសម្រាប់សេវាកម្មទាំងនេះ។

ផ្នែកទី 24.19. ផ្នែកទី 1798.199.100 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌដែលមានខ្លឹមសារដូចខាងក្រោម៖

1798.199.100. ទីភ្នាក់ងារនិងតុលាការណាមួយ តាមដែលអាចអនុវត្តបាន ត្រូវពិចារណាទៅលើកិច្ចសហការដោយស្មោះត្រង់របស់អាជីវកម្ម អ្នកផ្ដល់សេវា អ្នកម៉ៅការ ឬបុគ្គលដទៃទៀតនៅក្នុងការកំណត់អំពីស្ថានទម្ងន់នៃប្រាក់ពិន័យរដ្ឋបាល ឬទោសបញ្ញត្តិរដ្ឋប្បវេណីសម្រាប់ការរំលោភបំពានលើចំណងជើងនេះ។ អាជីវកម្មមិនត្រូវតម្រូវដោយទីភ្នាក់ងារ តុលាការ ឬផ្សេងពីនេះ ដើម្បីបង់ប្រាក់ពិន័យរដ្ឋបាល និងទោសបញ្ញត្តិរដ្ឋប្បវេណីសម្រាប់ការរំលោភបំពានដូចគ្នានេះឡើយ។

ផ្នែកទី 25. វិសោធនកម្ម។

(a) ប្រការទាំងឡាយនៃច្បាប់នេះអាចត្រូវបានធ្វើវិសោធនកម្មក្រោយពីការអនុម័តរបស់វាដោយអ្នកបោះឆ្នោត ដោយលក្ខន្តិកៈដែលបានឆ្លងដោយការបោះឆ្នោតមួយដែលមានសំឡេងភាគច្រើននៃបុគ្គលិកសភានីមួយៗរបស់រដ្ឋសភា និងចុះហត្ថលេខាដោយអភិបាល ករណីដែលវិសោធនកម្មទាំងនោះស៊ីសង្វាក់គ្នា និងពង្រីកបន្ថែមគោលបំណង និងចេតនានៃច្បាប់នេះ ដូចមានចែងនៅក្នុងផ្នែកទី 3 រួមទាំងវិសោធនកម្មចំពោះការលើកលែងទាំងឡាយនៅក្នុងផ្នែកទី 1798.145 ប្រសិនបើច្បាប់ដែលការលើកលែងទាំងនេះផ្អែកលើត្រូវបានធ្វើវិសោធនកម្មដើម្បីពង្រីកបន្ថែមឯកជនភាពស៊ីសង្វាក់គ្នា និងពង្រីកបន្ថែមគោលបំណង និងចេតនានៃ

24

ច្បាប់នេះ និងវិសោធនកម្មដើម្បីដោះស្រាយសេចក្តីសម្រេចរបស់តុលាការរដ្ឋ ឬសេចក្តីសម្រេចរបស់តុលាការសហព័ន្ធថាបទបញ្ញត្តិនៃច្បាប់នេះមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ឬត្រូវបានចាត់វិធានការបង្ការដោយច្បាប់សហព័ន្ធ ករណីដែលរាល់វិសោធនកម្មបន្ថែមណាមួយលើនីតិកម្មដែលដោះស្រាយការកំណត់របស់តុលាការ ត្រូវស្ថិតក្រោមផ្នែករងនេះ។

(b) ថ្វីបើមានផ្នែកទី 1798.199.25 រដ្ឋសភាអាចអនុញ្ញាតប្រាក់សំណងបន្ថែមសម្រាប់សមាជិកនៃទីភ្នាក់ងារឯកជនភាពអ្នកប្រើប្រាស់រដ្ឋ California ប្រសិនបើខ្លួនកំណត់ថា វាចាំបាច់ត្រូវអនុវត្តមុខងាររបស់ទីភ្នាក់ងារនោះ ដោយលក្ខន្តិកៈមួយដែលត្រូវបានអនុម័តដោយការបោះឆ្នោតដែលមានសំឡេងភាគច្រើននៃសភានីមួយៗរបស់អង្គនីតិបញ្ញត្តិ និងចុះហត្ថលេខាដោយអភិបាល។

(c) ផ្នែកនេះត្រូវបានអនុវត្តចំពោះលក្ខន្តិកៈទាំងអស់ដែលត្រូវបានធ្វើវិសោធនកម្ម ឬអនុម័តឡើងវិញថាជាផ្នែកមួយនៃច្បាប់នេះ និងបទបញ្ញត្តិទាំងអស់នៃលក្ខន្តិកៈទាំងនោះ ដោយមិនគិតថាច្បាប់នេះធ្វើការផ្លាស់ប្តូរសំខាន់អ្វីមួយឡើយ។

(d) បទបញ្ញត្តិទាំងឡាយនៃច្បាប់នេះត្រូវមានប្រៀបលើនីតិកម្មដែលមានទំនាស់ណាមួយដែលបានអនុម័តក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2020។ រាល់វិសោធនកម្មចំពោះច្បាប់នេះ ឬនីតិកម្មណាមួយដែលមានទំនាស់ជាមួយនឹងប្រការនៃច្បាប់នេះ ត្រូវចាត់ទុកជាមោឃៈក្រោយការអនុម័តច្បាប់នេះដោយអ្នកបោះឆ្នោត ដោយមិនគិតពីក្រមដែលវាស្ថិតនៅក្នុងឡើយ។ នីតិកម្មត្រូវបានចាត់ទុកថា "មានទំនាស់" សម្រាប់គោលបំណងនៃផ្នែករងនេះ លើកលែងតែនីតិកម្មនេះស៊ីសង្វាក់គ្នា និងពង្រីកបន្ថែមគោលបំណង និងចេតនានៃច្បាប់នេះ ដូចមានចែងនៅក្នុងផ្នែកទី 3។

ផ្នែកទី 26. ឯករាជ្យភាពនៃប្រការ។

ប្រសិនបើប្រការណាមួយនៃវិធានការនេះ ឬផ្នែកណាមួយនៃវិធានការនេះ ឬការអនុវត្តនៃប្រការ ឬផ្នែកណាមួយទៅលើបុគ្គល ឬកាលៈទេសៈណាមួយ គឺដោយសារតែមូលហេតុណាមួយដែលចាត់ទុកថាគ្មានសុពលភាពនោះ ប្រការ ឬការអនុវត្តនៃប្រការដែលនៅសល់ មិនត្រូវរងការប៉ះពាល់ឡើយ ប៉ុន្តែត្រូវនៅតែមានអានុភាព និងប្រសិទ្ធភាពពេញលេញ ហើយសរុបមក ប្រការទាំងឡាយនៃវិធានការនេះគឺអាចកាត់ចេញពីគ្នាបាន។ ប្រសិនបើតុលាការត្រូវស្វែងរកសាលក្រមមិនអាចពិនិត្យឡើងវិញបានចុងក្រោយ ដែលការមិនរាប់បញ្ចូលនូវអង្គភាព ឬសកម្មភាពមួយ ឬច្រើនពីភាពអាចអនុវត្តបាននៃច្បាប់ធ្វើឲ្យច្បាប់នោះមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនោះ ការលើកលែងទាំងនោះគួរតែកាត់ផ្តាច់ ហើយច្បាប់នោះគួរតែធ្វើឲ្យអាចអនុវត្តបានចំពោះអង្គភាព ឬសកម្មភាពដែលពីមុនមកត្រូវបានលើកលែងពីច្បាប់នេះ។ វាគឺជាចេតនារបស់អ្នកបោះឆ្នោតដែលច្បាប់នេះនឹងត្រូវបានអនុម័តដោយមិនគិតថាតើប្រការណាមួយដែលគ្មានសុពលភាពត្រូវបានដាក់បញ្ចូល ឬការអនុវត្តដែលគ្មានសុពលភាពណាមួយត្រូវបានធ្វើឡើងដែរឬទេ។

ផ្នែកទី 27. គំនិតផ្តួចផ្តើមដែលមានទំនាស់។

(a) ក្នុងករណីដែលវិធានការនេះ និងវិធានការមួយផ្សេងទៀតដែលដោះស្រាយឯកជនភាពរបស់អ្នកប្រើប្រាស់ត្រូវមាននៅលើសន្លឹកឆ្នោតទូទាំងរដ្ឋដូចគ្នានោះ ប្រការនៃវិធានការ ឬបណ្តាវិធានការផ្សេងទៀតត្រូវចាត់ទុកថាមានទំនាស់ជាមួយនឹងវិធានការនេះ។ ក្នុងករណីដែលគំនិតផ្តួចផ្តើមនេះទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងវិធានការដែលចាត់ទុកថាមានទំនាស់ជាមួយវា ប្រការនៃគំនិតផ្តួចផ្តើមនេះនឹងត្រូវមានប្រៀបទាំងស្រុង ហើយវិធានការ ឬបណ្តាវិធានការផ្សេងទៀតត្រូវចាត់ទុកជាមោឃៈ។

(b) ប្រសិនបើវិធានការនេះត្រូវបានអនុម័តដោយអ្នកបោះឆ្នោត ប៉ុន្តែត្រូវបានជំនួសដោយច្បាប់ដោយវិធានការមានទំនាស់ផ្សេងទៀតដែលអនុម័តដោយអ្នកបោះឆ្នោតនៅពេលបោះឆ្នោតតែមួយ ហើយវិធានការសន្លឹកឆ្នោតដែលមានទំនាស់ត្រូវបានចាត់ទុកជាមោឃៈនាពេលក្រោយមកទៀតនោះ វិធានការនេះត្រូវតែស្វ័យអនុវត្ត និងទទួលបានប្រសិទ្ធភាពពេញលេញ។

ផ្នែកទី 28. សិទ្ធិប្តឹង។

ថ្វីបើមានបទបញ្ញត្តិផ្សេងទៀតនៃច្បាប់ ប្រសិនបើរដ្ឋ ឬមន្ត្រីណាម្នាក់របស់ខ្លួនខកខានមិនបានការពាររដ្ឋធម្មនុញ្ញភាពនៃច្បាប់នេះបន្ទាប់ពីការអនុម័តដោយអ្នកបោះឆ្នោត ទីភ្នាក់ងាររដ្ឋាភិបាលណាមួយផ្សេងទៀតនៃរដ្ឋនេះ ត្រូវមានសិទ្ធិអំណាចក្នុងការអន្តរាគមន៍នៅក្នុងបណ្តឹងតុលាការណាមួយដែលប្រឈមបញ្ហាដល់រដ្ឋធម្មនុញ្ញភាពនៃច្បាប់នេះ សម្រាប់គោលបំណងនៃការការពារធម្មនុញ្ញភាពរបស់វា ទោះបីជាបណ្តឹងនោះស្ថិតនៅក្នុងតុលាការជំនុំជម្រះរដ្ឋ ឬសហព័ន្ធក៏ដោយ លើបណ្តឹងឧទ្ធរណ៍ ឬលើការពិនិត្យដោយឆន្ទានុសិទ្ធិរបស់តុលាការកំពូលនៃរដ្ឋ California ឬតុលាការកំពូលនៃសហរដ្ឋអាមេរិកក៏ដោយ។ ក្រៃសេវា និងការចំណាយដែលសមរម្យនៃការការពារបណ្តឹង ត្រូវជាបន្ទុកទៅលើមូលនិធិដែលបានបម្រុងទុកសម្រាប់ក្រសួងយុត្តិធម៌ដែលត្រូវបង់យ៉ាងទៀងទាត់។

ផ្នែកទី 29. ការបកស្រាយ។

ច្បាប់នេះត្រូវបកស្រាយដោយសេរីភាពដើម្បីប្រតិបត្តិតាមគោលបំណងរបស់វា។

ផ្នែកទី 30. សេចក្តីព្រមាន។

ច្បាប់នេះមានគោលបំណងបំពេញបន្ថែមដល់ច្បាប់សហព័ន្ធ និងច្បាប់រដ្ឋតាមការអនុញ្ញាតបាន ប៉ុន្តែមិនត្រូវបានអនុវត្តឡើយ ប្រសិនបើការអនុវត្តនោះត្រូវបានចាត់វិធានការបង្ការដោយ ឬមានទំនាស់ជាមួយនឹងច្បាប់សហព័ន្ធ ឬរដ្ឋធម្មនុញ្ញនៃរដ្ឋ California ។ ប្រការទាំងឡាយនៃច្បាប់ដែលទាក់ទងនឹងកុមារអាយុក្រោម 16 ឆ្នាំ ត្រូវអនុវត្តតែទៅដល់កម្រិតមួយដែលមិនមានទំនាស់ជ ជាមួយនឹងច្បាប់ការពារឯកជនភាពតាមអនឡាញសម្រាប់កុមា (Children's Online Privacy Protection Act) របស់សហព័ន្ធប៉ុណ្ណោះ។

ផ្នែកទី 31. កាលបរិច្ឆេទចូលជាធរមាន និងប្រតិបត្តិការ។

(a) ច្បាប់នេះ ត្រូវមានប្រសិទ្ធភាពដូចដែលបានចែងនៅក្នុងផ្នែករង (a) នៃផ្នែកទី 10 នៃមាត្រា II នៃធម្មនុញ្ញរដ្ឋ California ។ លើកលែងតែមានចែងនៅក្នុងផ្នែករង (b) ប៉ុណ្ណោះ ច្បាប់នេះត្រូវមានប្រសិទ្ធភាពនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2023 និងដោយមានការលើកលែងលើសិទ្ធិក្នុងការចូលដំណើរការ ត្រូវអនុវត្តតែទៅលើព័ត៌មានផ្ទាល់ខ្លួនដែលប្រមូលដោយអាជីវកម្មមួយនៅថ្ងៃទី ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2022 ប៉ុណ្ណោះ។

(b) ផ្នែករង (m) និង (n) នៃផ្នែកទី 1798.145 ផ្នែកទី 1798.160, 1798.185 ផ្នែកទី 1798.199.10 រហូតដល់ 1798.199.40 ដោយរាប់បញ្ចូល និងផ្នែកទី 1798.199.95 ត្រូវអាចអនុវត្តបាននៅកាលបរិច្ឆេទប្រសិទ្ធភាពនៃច្បាប់នេះ។

(c) ប្រការទាំងឡាយនៃច្បាប់ឯកជនភាពអ្នកប្រើប្រាស់រដ្ឋ California ឆ្នាំ 2018 ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់នេះ ត្រូវនៅតែមានអានុភាព និងប្រសិទ្ធភាពពេញលេញ ហើយត្រូវអាចអនុវត្តបានរហូតដល់ប្រការដូចគ្នានៃច្បាប់នេះមានប្រសិទ្ធភាព និងអាចអនុវត្តបាន។

សំណើប្រជាមតិ 25

ច្បាប់នេះដែលបានស្នើដោយសេចក្តីព្រាងច្បាប់ព្រឹទ្ធសភា 10 នៃសម័យប្រជុំសាមញ្ញឆ្នាំ 2017–2018 (ជំពូកទី 244 លក្ខន្តិកៈឆ្នាំ 2018) ត្រូវបានដាក់ជូនប្រជាពលរដ្ឋថាជាការធ្វើប្រជាមតិដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃផ្នែកទី 9 នៃមាត្រា II នៃធម្មនុញ្ញរដ្ឋ California ។

សំណើច្បាប់នេះធ្វើវិសោធនកម្មទៅលើផ្នែកមួយនៃក្រមរដ្ឋាភិបាល និងបន្ថែមផ្នែកទាំងឡាយទៅលើក្រមព្រហ្មទណ្ឌ។ អាស្រ័យហេតុនេះ ប្រការជាធរមានដែលត្រូវបានស្នើសុំឲ្យលុបចោលត្រូវបានបោះពុម្ពជា ~~ប្រភេទ អក្សរឆ្លុតចោល~~ ហើយរាល់ប្រការថ្មីដែលត្រូវបានស្នើសុំឲ្យបន្ថែមត្រូវបានបោះពុម្ពជា *ប្រភេទអក្សរទ្រេត* ដើម្បីបញ្ជាក់ថាវាជាប្រការថ្មី។

សំណើច្បាប់

ផ្នែកទី 1. វាគឺជាចេតនារបស់រដ្ឋសភាដោយអនុម័តវិធានការនេះ ដើម្បីអនុញ្ញាតដល់ការឃុំឃាំងបង្ការនៃចុងចោទមុនជំនុំជម្រះ តែក្នុងលក្ខណៈមួយដែលស៊ីសង្វាក់គ្នាជាមួយនឹងរដ្ឋធម្មនុញ្ញសហរដ្ឋ ដូចដែលបានបកស្រាយដោយតុលាការកំពូលសហរដ្ឋ និងដល់កម្រិតមួយដែលត្រូវបានអនុញ្ញាតដោយធម្មនុញ្ញរដ្ឋ California ដូចដែលបានបកស្រាយដោយតុលាការត្រួតពិនិត្យនៃរដ្ឋ California ប៉ុណ្ណោះ។

ផ្នែកទី 2. ផ្នែកទី 27771 នៃក្រមរដ្ឋាភិបាលត្រូវបានធ្វើវិសោធនកម្ម ដែលចែងថា៖

27771. (a) ប្រធានមន្ត្រីគ្រប់គ្រងការដោះលែងនៅក្រៅឃុំ ដោយមានលក្ខខណ្ឌ ត្រូវអនុវត្តករណីយកិច្ច និងបញ្ឈប់កាតព្វកិច្ចទាំងឡាយដែលដាក់ទៅលើការិយាល័យដោយច្បាប់ ឬដោយដីកាតុលាការកំពូល ដែលរួមមានដូចខាងក្រោម៖

(1) ការត្រួតពិនិត្យនៅក្នុងសហគមន៍ទៅលើជនល្មើសដែលស្ថិតក្រោមដែនសមត្ថកិច្ចនៃតុលាការអនីតិជន ដោយអនុលោមតាមផ្នែកទី 602 ឬ 1766 នៃក្រមស្តីពីសុខុមាលភាព និងស្ថាប័ន។

(2) ប្រតិបត្តិការនៃសាលអនីតិជនដែលអនុលោមតាមផ្នែកទី 852 នៃក្រមស្តីពីសុខុមាលភាពនិង ស្ថាប័ន។

(3) ប្រតិបត្តិការបោះតង់របស់អនីតិជន និងវាលស្រែចិញ្ចឹមសត្វដែលបានបង្កើតឡើងក្រោមផ្នែកទី 880 នៃក្រមស្តីពីសុខុមាលភាព និងស្ថាប័ន។

(4) ការត្រួតពិនិត្យនៅក្នុងសហគមន៍ទៅលើបុគ្គលដែលស្ថិតក្រោមការដោះលែងឲ្យនៅក្រៅឃុំមានលក្ខខណ្ឌ ដែលស្ថិតក្រោមលក្ខខណ្ឌដែលដាក់បង្ខំក្រោមផ្នែកទី 1203 នៃក្រមព្រហ្មទណ្ឌ។

(5) ការត្រួតពិនិត្យនៅក្នុងសហគមន៍ទៅលើបុគ្គលដែលស្ថិតក្រោមការត្រួតពិនិត្យតាមច្បាប់ ដែលអនុលោមតាមកថាខណ្ឌរង (B) នៃកថាខណ្ឌទី (5) នៃផ្នែករង (h) នៃផ្នែកទី 1170 នៃក្រមព្រហ្មទណ្ឌ។

(6) ការត្រួតពិនិត្យនៅក្នុងសហគមន៍ទៅលើបុគ្គលដែលស្ថិតក្រោមការត្រួតពិនិត្យក្នុងសហគមន៍ក្រោយការដោះលែង ដែលអនុលោមតាមផ្នែកទី 3451 នៃក្រមព្រហ្មទណ្ឌ។

(7) រដ្ឋបាលនៃកម្មវិធីកែប្រែតាមសហគមន៍ រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ កម្មវិធីទាំងឡាយដែលអនុញ្ញាតដោយជំពូកទី 3 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 1228) នៃចំណងជើងទី 8 នៃភាគទី 2 នៃក្រមព្រហ្មទណ្ឌ។

(8) បម្រើក្នុងនាមជាប្រធាននៃភាពជាដៃគូកែលំអសហគមន៍ ដោយអនុលោមតាមផ្នែកទី 1230 នៃក្រមព្រហ្មទណ្ឌ។

(9) ផ្តល់អនុសាសន៍ជូនតុលាការ រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះ របាយការណ៍ការស៊ើបអង្កេត ~~មុនពេលកាត់ទោស~~ មុនពេលកាត់ទោសដែលអនុលោមតាមផ្នែកទី 1203.7 និង 1203.10 នៃក្រមព្រហ្មទណ្ឌ *ឬរបាយការណ៍ដែលរៀបចំដោយអនុលោមតាមផ្នែកទី 1320.15 នៃក្រមព្រហ្មទណ្ឌ*។

(b) ប្រធានមន្ត្រីគ្រប់គ្រងការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ អាចអនុវត្តករណីយកិច្ចផ្សេងៗដែលស៊ីសង្វាក់ជាមួយនឹងករណីយកិច្ចដែលមានរៀបរាប់នៅក្នុងផ្នែករង (a) ហើយអាចទទួលការតែងតាំងទៅកាន់គណៈកម្មការកែប្រែរដ្ឋ និងសហគមន៍ និងប្រមូលសោហ៊ុយប្រចាំថ្ងៃដែលអនុញ្ញាតដោយផ្នែកទី 6025.1 នៃក្រមព្រហ្មទណ្ឌ។

ផ្នែកទី 3. ផ្នែកទី 1320.6 ត្រូវបានបន្ថែមទៅលើក្រមព្រហ្មទណ្ឌ ដែលចែងថា៖

1320.6. ជំពូកនេះត្រូវនៅតែមានប្រសិទ្ធភាពរហូតដល់ត្រឹមថ្ងៃទី 1 ខែតុលា ឆ្នាំ 2019 និងរហូតដល់កាលបរិច្ឆេទនោះត្រូវលុបចោល។

ផ្នែកទី 4. ជំពូកទី 1.5 (ដែលចាប់ផ្តើមជាមួយនឹងផ្នែកទី 1320.7) ត្រូវបានបន្ថែមទៅលើចំណងជើងទី 10 នៃភាគទី 2 នៃក្រមព្រហ្មទណ្ឌ ដែលចែងថា៖

ជំពូកទី 1.5 ស្ថានភាពមើលថែរក្សាមុនពេលជំនុំជម្រះ

មាត្រា 1. និយមន័យ

1320.7. ដូចដែលបានប្រើនៅក្នុងជំពូកនេះ ពាក្យទាំងឡាយខាងក្រោមនេះមានអត្ថន័យដូចតទៅ៖

(a) "តុលាការ" ដូចដែលបានប្រើនៅក្នុងជំពូកនេះ រាប់បញ្ចូលទាំង "មន្ត្រីច្បាប់ថ្នាក់ក្រោម" ប្រសិនបើត្រូវបានអនុញ្ញាតដោយតុលាការកំពូលជាក់លាក់ ដូចដែលបានអនុញ្ញាតនៅក្នុងផ្នែកទី 22 នៃមាត្រា VI នៃធម្មនុញ្ញរដ្ឋ California និងបញ្ជាក់លម្អិតនៅក្នុងវិធានទី 10.703 នៃវិធានតុលាការរដ្ឋ California ។

(b) "ហានិភ័យខ្ពស់" មានន័យថា ជនដែលត្រូវបានចាប់ខ្លួន បន្ទាប់ពីការកំណត់នៃហានិភ័យរបស់ជននោះ ក្រោយការស៊ើបអង្កេតដោយសេវាកម្មវាយតម្លៃមុនជំនុំជម្រះ រួមទាំងការប្រើប្រាស់ឧបករណ៍វាយតម្លៃហានិភ័យដែលមានសុពលភាព ត្រូវបានចាត់ថ្នាក់ថាមានកម្រិតខ្ពស់លើហានិភ័យនៃខកខានក្នុងការបង្ហាញខ្លួននៅតុលាការតាមការតម្រូវ ឬហានិភ័យចំពោះសុវត្ថិភាពសាធារណៈដោយសារតែការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌថ្មី ខណៈពេលដែលត្រូវបានដោះលែងទៅលើបទល្មើសព្រហ្មទណ្ឌបច្ចុប្បន្ន។

(c) "ហានិភ័យទាប" មានន័យថា ជនដែលត្រូវបានចាប់ខ្លួន បន្ទាប់ពីការកំណត់នៃហានិភ័យរបស់ជននោះ ក្រោយការស៊ើបអង្កេតដោយសេវាកម្មវាយតម្លៃមុនជំនុំជម្រះ រួមទាំងការប្រើប្រាស់ឧបករណ៍វាយតម្លៃហានិភ័យដែលមានសុពលភាព ត្រូវបានចាត់ថ្នាក់ថាមានកម្រិតទាបលើហានិភ័យនៃខកខានក្នុងការបង្ហាញខ្លួននៅតុលាការតាមការតម្រូវ ឬហានិភ័យចំពោះសុវត្ថិភាពសាធារណៈដោយសារតែការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌថ្មី ខណៈពេលដែលត្រូវបានដោះលែងទៅលើបទល្មើសព្រហ្មទណ្ឌបច្ចុប្បន្ន។

(d) "ហានិភ័យមធ្យម" មានន័យថា ជនដែលត្រូវបានចាប់ខ្លួន បន្ទាប់ពីការកំណត់នៃហានិភ័យរបស់ជននោះ ក្រោយការស៊ើបអង្កេតដោយសេវាកម្មវាយតម្លៃមុនជំនុំជម្រះ រួមទាំងការប្រើប្រាស់ឧបករណ៍វាយតម្លៃហានិភ័យដែលមានសុពលភាព ត្រូវបានចាត់ថ្នាក់ថាមានកម្រិតមធ្យមលើហានិភ័យនៃខកខានក្នុងការបង្ហាញខ្លួននៅតុលាការតាមការតម្រូវ ឬហានិភ័យចំពោះសុវត្ថិភាពសាធារណៈដោយសារតែការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌថ្មី ខណៈពេលដែលត្រូវបានដោះលែងទៅលើបទល្មើសព្រហ្មទណ្ឌបច្ចុប្បន្ន។

(e) "ការដោះលែងដោយទទួលស្គាល់ខ្លួនឯង" មានន័យថា ការដោះលែងមុនជំនុំជម្រះទៅលើជនដែលត្រូវបានចាប់ខ្លួន ដែលសន្យាជាលាយលក្ខណ៍អក្សរថានឹងបង្ហាញខ្លួននៅតុលាការតាមការតម្រូវ និងដោយគ្មានការត្រួតពិនិត្យ។

(f) "ការវាយតម្លៃហានិភ័យមុនជំនុំជម្រះ" មានន័យថា ការវាយតម្លៃដែលធ្វើឡើងដោយសេវាកម្មវាយតម្លៃមុនជំនុំជម្រះ ដោយប្រើប្រាស់ឧបករណ៍វាយតម្លៃហានិភ័យដែលត្រូវបានរៀបចំឡើងដើម្បីផ្តល់ព័ត៌មាន

អំពីហានិភ័យខកខានរបស់បុគ្គលក្នុងការបង្ហាញខ្លួននៅតុលាការតាមការតម្រូវ ឬហានិភ័យចំពោះសុវត្ថិភាពសាធារណៈដោយសារតែការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌថ្មី ប្រសិនបើជននោះត្រូវបានដោះលែងមុនសាលក្រមនៃបទល្មើសព្រហ្មទណ្ឌបច្ចុប្បន្ន។

(g) "សេវាកម្មវាយតម្លៃមុនជំនុំជម្រះ" មានន័យថា អង្គភាព ផ្នែក ឬកម្មវិធីដែលទទួលបានការចាត់តាំងនូវការទទួលខុសត្រូវ ដោយអនុលោមតាមផ្នែកទី 1320.26 ដើម្បីវាយតម្លៃកម្រិតហានិភ័យនៃជនទាំងឡាយដែលជាប់ចោទពីការប្រព្រឹត្តបទឧក្រិដ្ឋ រាយការណ៍អំពីលទ្ធផលនៃការកំណត់ហានិភ័យទៅកាន់តុលាការ និងផ្តល់អនុសាសន៍សម្រាប់លក្ខខណ្ឌនៃការដោះលែងបុគ្គលដែល ការវិនិច្ឆ័យមិនទាន់សម្រេចនៃសំណុំរឿងព្រហ្មទណ្ឌរបស់ពួកគេ និងតាមការចង្អុលបង្ហាញក្រោមលក្ខន្តិកៈ ឬវិធាននៃតុលាការ អនុវត្តផ្នែកលើហានិភ័យទាក់ទងនឹងការដោះលែង និងការឃុំខ្លួន។ អង្គភាព ផ្នែក ឬកម្មវិធី តាមជម្រើសរបស់តុលាការថ្នាក់លើអាចជា និយោជិករបស់ តុលាការ ឬជាបុគ្គលិករបស់អង្គភាពសាធារណៈ ដែលចុះកិច្ចសន្យាជាមួយតុលាការសម្រាប់សេវាកម្មទាំងនោះ ដូចមានចែងនៅក្នុងផ្នែក 1320.26 ហើយអាចរួមបញ្ចូលអង្គភាព ផ្នែក ឬកម្មវិធីពីខោនធីជាប់គ្នា ឬខោនធីដែលផ្តល់សេវាកម្មជាសមាជិកនៃក្រុមទីភ្នាក់ងារប្រចាំភូមិភាគ។ ក្នុងគ្រប់កាលៈទេសៈ បុគ្គលដែលធ្វើកិច្ចការជំនួសឲ្យអង្គភាព ផ្នែក ឬកម្មវិធីត្រូវតែជា មន្ត្រីរបស់តុលាការ។ "សេវាកម្មវាយតម្លៃមុនជំនុំជម្រះ" មិនរួមបញ្ចូលការត្រួតពិនិត្យលើបុគ្គលដែលត្រូវបានដោះលែងនៅក្រោមជំពូកនេះទេ។

(h) "ហានិភ័យ" សំដៅលើភាពដែលអាចកើតឡើងដែលបុគ្គលម្នាក់នឹងមិនបង្ហាញខ្លួននៅតុលាការតាមការតម្រូវ ឬលទ្ធភាពដែលអាចកើតឡើងដែលបុគ្គលម្នាក់នឹងប្រព្រឹត្តបទល្មើសថ្មី ប្រសិនបើបុគ្គលនោះត្រូវបានដោះលែងមុនពេលកាត់សេចក្តីលើបទល្មើសព្រហ្មទណ្ឌបច្ចុប្បន្នរបស់បុគ្គលនោះ។

(i) "ពិន្ទុហានិភ័យ" សំដៅលើការវាយតម្លៃរៀបរាប់អំពីហានិភ័យរបស់បុគ្គលម្នាក់នៃការមិនបង្ហាញខ្លួននៅតុលាការតាមការតម្រូវ ឬហានិភ័យចំពោះសុវត្ថិភាពសាធារណៈ ដោយសារការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌថ្មី ប្រសិនបើ បុគ្គលនោះត្រូវបានដោះលែងមុនសេចក្តីសម្រេចរបស់ចៅក្រម លើបទល្មើសព្រហ្មទណ្ឌបច្ចុប្បន្នរបស់បុគ្គលនោះ។ លទ្ធផលនៃការធ្វើការប៉ាន់ប្រមាណជាមួយនឹងឧបករណ៍ប៉ាន់ប្រមាណហានិភ័យដែលមានសុពលភាពអាចនឹងរួមមានតម្លៃជាលេខ ឬជាពាក្យដូចជា ហានិភ័យ "ខ្ពស់" "មធ្យម" ឬ "ទាប" ។

(j) "ការដោះលែងដោយការទទួលស្គាល់ខ្លួនឯងដែលមានការត្រួតពិនិត្យ" សំដៅលើ ការដោះលែងមុនជំនុំជម្រះលើបុគ្គលដែលត្រូវបានចាប់ខ្លួនដែលសន្យាជាលាយលក្ខណ៍អក្សរប៉ុន្តែដោយមិនបានដំកល់ប្រាក់ ឬ ប័ណ្ណបំណុល សុវត្ថិភាព ថានឹងបង្ហាញខ្លួននៅតុលាការតាមការតម្រូវ និងដែល តុលាការ ឬសេវាកម្មវាយតម្លៃមុនជំនុំជម្រះបានដាក់លក្ខខណ្ឌជាក់លាក់សម្រាប់ការដោះលែង។

(k) "ឧបករណ៍ប៉ាន់ប្រមាណហានិភ័យមុនជំនុំជម្រះ" សំដៅលើ ឧបករណ៍វាយតម្លៃហានិភ័យដែលបានជ្រើសរើស និងអនុម័តដោយ តុលាការដោយ មានការពិគ្រោះយោបល់ជាមួយសេវាកម្មវាយតម្លៃមុនជំនុំជម្រះ ឬ អង្គភាពមួយទៀត ដែលផ្តល់ការប៉ាន់ប្រមាណហានិភ័យមុនកាត់សេចក្តី ពីបញ្ជីឧបករណ៍វាយតម្លៃហានិភ័យមុនជំនុំជម្រះដែលបានអនុម័ត ដែលរក្សាទុកដោយក្រុមប្រឹក្សា តុលាការ។ ឧបករណ៍វាយតម្លៃត្រូវតែបានបង្ហាញដោយការស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រថា មានភាពត្រឹមត្រូវ និងអាចទុកចិត្តបានក្នុងការប៉ាន់ប្រមាណលើហានិភ័យរបស់បុគ្គល ដែលមិនបង្ហាញខ្លួននៅតុលាការតាមការតម្រូវ ឬហានិភ័យចំពោះសុវត្ថិភាពសាធារណដោយការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌថ្មី ប្រសិនបើ បុគ្គលនោះត្រូវបាន ដោះលែងមុនពេលសម្រេចសេចក្តី លើបទល្មើសព្រហ្មទណ្ឌបច្ចុប្បន្នរបស់ខ្លួន និងកាត់បន្ថយភាពលម្អៀងឲ្យនៅអប្បបរមា។

(l) "សាក្សី" សំដៅលើបុគ្គលណាម្នាក់ដែលបានធ្វើ សក្តីយកម្ម ឬ ត្រូវបានរំពឹងថានឹងធ្វើសក្តីយកម្ម ឬដែល ដោយហេតុផលនៃការមានព័ត៌មានពាក់ព័ន្ធ ស្ថិតនៅក្រោមការហៅ ឬអាចនឹងត្រូវបានហៅឲ្យធ្វើជាសាក្សីនៅក្នុង ចំណាត់ការ ឬនីតិវិធីសម្រាប់បទល្មើសបច្ចុប្បន្ន ទោះបីជាចំណាត់ការ ឬនីតិវិធីបាន ឬ មិនទាន់បានចាប់ផ្តើមក្តី និងទោះបីជាបុគ្គលនោះជា ឬមិនមែនជាសាក្សី សម្រាប់ការការពារ ឬការកាត់ទោសក្តី។

មាត្រា 2. ការឃាត់ខ្លួន និងការដោះលែង

1320.8. ជនដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួនសម្រាប់បទមជ្ឈិម ឬ ក្រៅពីបទមជ្ឈិម ដែលបានចុះនៅក្នុងផ្នែករង (e) នៃផ្នែក 1320.10 អាចត្រូវបានឃាត់ខ្លួន និងដោះលែងដោយមិនមានការចាប់ខ្លួន ឬ ប្រសិនបើត្រូវបានចាប់ខ្លួននឹងត្រូវដោះលែងពីការឃុំដោយមិនមានការវាយតម្លៃលើហានិភ័យដោយសេវាកម្មវាយតម្លៃមុនជំនុំជម្រះក្នុងរយៈពេល 12 ម៉ោងក្រោយការឃាត់ខ្លួន។ ផ្នែកនេះត្រូវអនុវត្តលើបុគ្គលណាដែលត្រូវបានចាប់ខ្លួនពីបទមជ្ឈិមក្រៅពីបទល្មើស ទាំងនោះ ឬកត្តាដែលបានចុះនៅក្នុងផ្នែករង (e) នៃផ្នែក 1320.10 ទោះបីជាបានចាប់ខ្លួនដោយមាន ឬដោយគ្មានដីការ។

មាត្រា 3. ការស៊ើបអង្កេតលើសេវាកម្មវាយតម្លៃមុនជំនុំជម្រះ

1320.9. (a) មុនការបញ្ជូនខ្លួន ឬមុនការត្រួតពិនិត្យមុនការបញ្ជូនខ្លួន សម្រាប់ជនដែលមានលក្ខណៈសម្បត្តិសម្រាប់ការពិនិត្យ សេវាកម្មវាយតម្លៃមុនជំនុំជម្រះត្រូវ ទទួលបានរាល់ព័ត៌មានទាំងអស់ដូចខាងក្រោមពាក់ព័ន្ធនឹងបុគ្គលដែលត្រូវបានឃុំឃាំងនិមួយៗ ក្រៅពីបុគ្គលដែលត្រូវបានឃាត់ខ្លួននិងដោះលែងក្រោមផ្នែក 1320.8៖

(1) លទ្ធផលនៃការប៉ាន់ប្រមាណហានិភ័យដោយប្រើឧបករណ៍វាយតម្លៃហានិភ័យ ដែលមានសុពលភាព រួមទាំងពិន្ទុហានិភ័យ ឬកម្រិតហានិភ័យ។

(2) ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌចំពោះបុគ្គលដែលត្រូវបានចាប់ខ្លួន និងប្រវត្តិបទល្មើសរបស់បុគ្គលរួមទាំងប្រវត្តិនៃការមិនបង្ហាញខ្លួននៅតុលាការ ក្នុងរយៈពេលបីឆ្នាំកន្លងទៅរបស់បុគ្គលនោះ។

(3) ព័ត៌មានបន្ថែមណាមួយដែលអាចរកបានដោយសមហេតុផលដែលដោះស្រាយ ដោយផ្ទាល់ហានិភ័យចំពោះសុវត្ថិភាពរបស់សាធារណជន ឬហានិភ័យនៃការមិនបង្ហាញខ្លួននៅតុលាការដូចបានតម្រូវរបស់បុគ្គលដែលបានចាប់ខ្លួន។

(b) មេធាវីមណ្ឌលត្រូវបង្កើតការខិតខំប្រឹងប្រែងដែលសមហេតុផលដើម្បីទាក់ទង ជនរងគ្រោះឱ្យផ្តល់យោបល់អំពីស្ថានភាពការឃុំឃាំងរបស់បុគ្គលនោះ។

(c) មុនការពិនិត្យមើលមុនបញ្ជូនខ្លួនទៅចៅក្រម ស្របតាមផ្នែករង (a) ឬ (b) នៃផ្នែក 1320.10 ឬផ្នែក 1320.13 ឬមុនការបញ្ជូនខ្លួន សេវាកម្មវាយតម្លៃមុនជំនុំជម្រះ ត្រូវរៀបចំរបាយការណ៍ដែលមានព័ត៌មានដែលបានទទួលដោយអនុលោម ទៅតាមផ្នែករង (a) និង (b) និងអនុសាសន៍ណាមួយសម្រាប់លក្ខខណ្ឌនៃការដោះលែងបុគ្គលនោះ។ ជម្រើសសម្រាប់លក្ខខណ្ឌនៃការដោះលែងត្រូវបង្កើតដោយ ក្រុមប្រឹក្សាតុលាការ និងមានចែងក្នុងវិធានតុលាការរដ្ឋ California។ សេចក្តីចម្លងនៃរបាយការណ៍នោះត្រូវបញ្ជូនទៅតុលាការ និងក្រុមប្រឹក្សា។

(d) របាយការណ៍ដែលបានរៀបរាប់ក្នុងផ្នែករង (c) ដែលរួមមានលទ្ធផលនៃការវាយតម្លៃហានិភ័យដោយប្រើឧបករណ៍ប៉ាន់ប្រមាណហានិភ័យដែលមានសុពលភាព មិនត្រូវប្រើសម្រាប់គោលបំណងណាមួយក្រៅពីគោលបំណង ដែលបាន ចែងសម្រាប់ជំពូកនេះឡើយ។

25

មាត្រា 4. ការដោះលែងដោយសេវាកម្មវាយតម្លៃមុនជំនុំជម្រះ

1320.10. (a) សេវាកម្មវាយតម្លៃមុនជំនុំជម្រះត្រូវធ្វើការពិនិត្យមុនការបញ្ជូនខ្លួនទៅចៅក្រមអំពីអង្គហេតុ និងកាលៈទេសៈដែលពាក់ព័ន្ធនឹងការឃុំខ្លួន របស់បុគ្គលដែលត្រូវបានចាប់ខ្លួន និងត្រូវពិចារណាលើព័ត៌មានដែលមាន និងពាក់ព័ន្ធ ដែលបានផ្តល់ដោយការអនុវត្តច្បាប់ បុគ្គលដែលត្រូវបានចាប់ខ្លួន ជនរងគ្រោះណាមួយ និងការដាក់ទោស ឬការការពារ។

(b) សេវាកម្មវាយតម្លៃមុនជំនុំជម្រះ ដោយការប្រើប្រាស់ព័ត៌មានដែលបានទទួល ស្របតាមផ្នែកនេះ និងផ្នែក 1320.9 និងដោយការវាយតម្លៃបុគ្គលថាមានហានិភ័យ ទាបដល់សុវត្ថិភាពសាធារណៈ និងហានិភ័យទាបចំពោះការមិនបង្ហាញខ្លួន នៅតុលាការ ត្រូវដោះលែងបុគ្គលដែលមានហានិភ័យទាបដែលមានការទទួល ស្គាល់ខ្លួនឯង មុនពេលបញ្ជូនខ្លួនទៅចៅក្រម ដោយមិនមានការពិនិត្យដោយតុលាការ និងដោយលក្ខខណ្ឌ រឹតត្បិតតិចតួចបំផុតដែលមិនមែនជារូបិយវត្ថុ ឬការរួមបញ្ចូលគ្នានៃលក្ខខណ្ឌដែលនឹងធានាយ៉ាងសមហេតុផលនូវសុវត្ថិភាពសាធារណៈនិងការវិលត្រឡប់មកតុលាការវិញរបស់បុគ្គលនោះ។ ផ្នែករងនេះមិនអនុវត្តចំពោះបុគ្គលដែលត្រូវបានឃាត់ខ្លួន ឬត្រូវបានដោះលែងស្ថិតក្រោមផ្នែក 1320.8 ឬ បុគ្គលដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការពិចារណាការដោះលែង មុនការបញ្ជូនខ្លួនទៅចៅក្រមដូចមានចែងនៅក្នុងផ្នែករង (e) ។

(c) សេវាកម្មវាយតម្លៃមុនជំនុំជម្រះត្រូវបង្គាប់ការដោះលែង ឬការឃុំខ្លួនបុគ្គលដែលមានហានិភ័យមធ្យម អនុលោមតាមការពិនិត្យ និងស្តង់ដារដោះលែង ដូចមានចែងនៅក្នុងច្បាប់ក្នុងមូលដ្ឋាន នៃតុលាការដែលបានប្រគល់សិទ្ធិក្រោមផ្នែក 1320.11 ។ បុគ្គលដែលត្រូវបានដោះលែងស្របតាមច្បាប់ក្នុងមូលដ្ឋាននៃតុលាការ នឹងត្រូវបានដោះលែងដោយការទទួលស្គាល់ខ្លួនឯង ឬការដោះលែងដោយការទទួលស្គាល់ខ្លួនឯងក្រោមការត្រួតពិនិត្យ មុនការបញ្ជូនខ្លួនទៅចៅក្រមដោយមិនមានការពិនិត្យដោយតុលាការ និងដោយលក្ខខណ្ឌរឹតត្បិតតិចតួចបំផុត ដែលមិនមែនជារូបិយវត្ថុ ឬការរួមបញ្ចូលគ្នានៃលក្ខខណ្ឌដែលនឹងធានាយ៉ាងសមហេតុផលនូវសុវត្ថិភាពសាធារណ និងការវិលត្រឡប់មកតុលាការវិញរបស់បុគ្គលនោះ។ ផ្នែករងនេះមិនត្រូវ អនុវត្តចំពោះបុគ្គលដែលត្រូវបានឃាត់ខ្លួន និងដោះលែងក្រោមផ្នែក 1320.8 ឬ បុគ្គលដែលមិនមានលក្ខណៈសម្បត្តិទទួលបានការពិចារណាមុនពេលបញ្ជូនខ្លួនទៅចៅក្រមស្របតាមផ្នែករង (e) នៃផ្នែកនេះឡើយ។ ស្របតាមផ្នែក 1320.13 តុលាការអាចនឹងរៀបចំការត្រួតពិនិត្យមុនពេលបញ្ជូនខ្លួនទៅចៅក្រមហើយអាចនឹងធ្វើសេចក្តីសម្រេចការដោះលែង ព្រមទាំងអាចនឹងប្រគល់សិទ្ធិឲ្យមន្ត្រីតុលាការថ្នាក់ក្រោមក្នុងការរៀបចំការត្រួតពិនិត្យមុនពេលបញ្ជូនខ្លួនទៅចៅក្រម និងធ្វើសេចក្តីសម្រេចការដោះលែងដែលបានប្រគល់សិទ្ធិដោយជំពូកនេះ។

(d) បុគ្គលមិនត្រូវបានតម្រូវឲ្យបង់ប្រាក់សម្រាប់លក្ខខណ្ឌមិនមែនរូបិយវត្ថុ ឬការរួមបញ្ចូលលក្ខខណ្ឌ ដែលបានដាក់ស្របតាមផ្នែកនេះឡើយ។

(e) ទោះមានចែងក្នុងផ្នែករង (a) និង (b) ក៏ដោយ សេវាកម្មវាយតម្លៃមុនជំនុំជម្រះមិនត្រូវដោះលែង៖

(1) បុគ្គលដែលត្រូវបានវាយតម្លៃនៅក្នុងករណីបច្ចុប្បន្នដោយសេវាកម្មវាយតម្លៃបុរេជំនុំជម្រះ ដោយប្រើប្រាស់ឧបករណ៍វាយតម្លៃហានិភ័យដែលមានសុពលភាពស្របតាមផ្នែក 1320.9 ហើយត្រូវបានវាយតម្លៃថាមានហានិភ័យខ្ពស់។

(2) បុគ្គលដែលត្រូវបានចាប់ខ្លួនពីបទល្មើសដែលមានរៀបរាប់ក្នុងកថាខណ្ឌ (2) ឬ (3) នៃផ្នែករង (d) នៃផ្នែក 290 ។

(3) បុគ្គលដែលត្រូវបានចាប់ខ្លួនពីបទល្មើសមជ្ឈិមណាមួយដូចខាងក្រោម៖

(A) ការរំលោភបំពានណាមួយលើផ្នែក 273.5។

(B) ការរំលោភបំពានលើកថាខណ្ឌ (1) នៃផ្នែករង (e) នៃផ្នែក 243 ។

(C) ការរំលោភបំពានលើផ្នែក 273.6 ប្រសិនបើបុគ្គលដែលត្រូវបានឃុំខ្លួន ត្រូវបានចោទប្រកាន់ថាបានបង្ករការគំរាមកំហែងសម្លាប់ ឬបង្ករគ្រោះថ្នាក់ បានពាក់ព័ន្ធក្នុងអំពើហិង្សាលើ ឬបានចូលទៅកន្លែងរស់នៅ ឬកន្លែងធ្វើការរបស់ភាគីដែលត្រូវបានការពារ។

(D) ការរំលោភបំពានណាមួយលើផ្នែក 646.9។

(4) បុគ្គលដែលត្រូវបានចាប់ខ្លួនពីបទល្មើសព្រហ្មទណ្ឌដែលរួមមានធាតុមួយនៃបទឧក្រិដ្ឋដែលបុគ្គលនោះត្រូវបានចាប់ខ្លួនដូចជាអំពើហិង្សាលើរូបរាងកាយបុគ្គលផ្សេងទៀត ការគំរាមកំហែងដូច្នោះ ឬលទ្ធភាពដែលអាចបង្ករបួសធ្ងន់ធ្ងរលើរាងកាយ ឬបទល្មើសព្រហ្មទណ្ឌដែលបុគ្គល នោះត្រូវបានចោទប្រកាន់ ដោយបានប្រើប្រាស់អាវុធផ្ទាល់ខ្លួន ឬបានប្រើប្រាស់អាវុធ ឬកាំភ្លើងពិឃាតនៅក្នុងពេលប្រព្រឹត្តបទល្មើស ឬត្រូវបានចោទប្រកាន់ពីការបង្ករឱ្យមានរបួសធ្ងន់ធ្ងរផ្នែករាងកាយដោយផ្ទាល់ ក្នុងពេលប្រព្រឹត្តបទល្មើស។

(5) បុគ្គលដែលត្រូវបានចាប់ខ្លួនពីបទល្មើសជាលើកទីបីក្នុងរយៈពេល 10 ឆ្នាំចុងក្រោយនៃការបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹង ឬគ្រឿងញៀន ឬការរួមបញ្ចូលនៃបទល្មើស ឬសម្រាប់បទល្មើសនៃការបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹងឬគ្រឿងញៀនដែលបង្កឱ្យមានរបួសស្នាមដល់អ្នកដទៃ ឬសម្រាប់បទល្មើសនៃការបើកបរដោយមានកម្រិតជាតិអាល់កុលចាប់ពី 0.20 ដឹក្រេឡើងទៅ។

(6) បុគ្គលដែលត្រូវបានចាប់ខ្លួនពីបទរំលោភបំពានលើប្រភេទដីកាហាមឃាត់ណាមួយនៅក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។

(7) បុគ្គលដែលមានដីកាចាប់ខ្លួនកាលពីមុនចំនួនបីឡើងទៅសម្រាប់ការមិនបង្ហាញខ្លួនក្នុងរយៈពេល 12 ខែចុងក្រោយ។

(8) បុគ្គលដែល នៅពេលនៃការចាប់ខ្លួន ស្ថិតនៅក្នុងការជំនុំជម្រះដែលមិនទាន់បញ្ចប់ ឬការកាត់ទោសមិនទាន់បញ្ចប់ពីបទមជ្ឈិម ឬបទឧក្រិដ្ឋ។

(9) បុគ្គលដែលនៅពេលនៃការចាប់ខ្លួន ស្ថិតនៅក្រោមទម្រង់ណាមួយនៃការត្រួតពិនិត្យក្រោយ កាត់ទោស ក្រៅពីការដោះលែងសាកល្បងក្រៅផ្លូវការ ឬការត្រួតពិនិត្យរបស់តុលាការ។

(10) បុគ្គលដែលបានបំភិតបំភ័យ ឃាត់ឃាំង ឬគំរាមកំហែងអំពីការសងសឹកប្រឆាំងនឹងសាក្សី ឬជនរងគ្រោះនៃបទល្មើសបច្ចុប្បន្ន។

(11) បុគ្គលដែលបានរំលោភបំពានលើលក្ខខណ្ឌនៃការដោះលែងមុនជំនុំជម្រះ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។

(12) បុគ្គលដែលត្រូវបានកាត់ទោសពីបទឧក្រិដ្ឋធ្ងន់ធ្ងរដូចមានចែងនៅក្នុងផ្នែករង (c) នៃផ្នែក 1192.7 ឬបទឧក្រិដ្ឋហិង្សាដូចមានចែងក្នុងផ្នែករង (c) នៃផ្នែក 667.5 ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។

(13) បុគ្គលដែលត្រូវបានចាប់ខ្លួនដោយមិនមានដីកាពីបទឧក្រិដ្ឋធ្ងន់ធ្ងរដូចមានចែងនៅក្នុងផ្នែករង (c) នៃផ្នែក 1192.7 ឬ "បទឧក្រិដ្ឋហិង្សា" ដូចមានចែងក្នុងផ្នែករង (c) នៃផ្នែក 667.5 ។

(f) ពិនិត្យមើលស្ថានភាពឃុំខ្លួនរបស់បុគ្គលនោះ និងការដោះលែងស្របតាមផ្នែករង (b) ឬ (c) ត្រូវកើតឡើងដោយមិនចាំបាច់មានការពន្យារពេល និងមិនលើសពី 24 ម៉ោង ក្រោយការឃាត់ខ្លួនបុគ្គលនោះ។ រយៈពេល 24 ម៉ោងអាចត្រូវបានពន្យារបន្ថែមសម្រាប់មូលហេតុល្អ ប៉ុន្តែមិនត្រូវលើសពី 12 ម៉ោងឡើយ។

(g) បុគ្គលមិនត្រូវបានដោះលែងដោយការទទួលស្គាល់ខ្លួនឯងឡើយ អនុលោមតាមផ្នែករង (b) ឬ (c) រហូតដល់បុគ្គលនោះចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោះលែង ដែលយ៉ាងហោចណាស់រៀបរាប់ពីបុគ្គលនោះ នូវចំណុចទាំងអស់ដូចខាងក្រោម៖

(1) ការសន្យាថាត្រូវបង្ហាញខ្លួននៅគ្រប់ពេលនិងគ្រប់ទីកន្លែង តាមការបញ្ជាដោយតុលាការ។

(2) ការសន្យាថាមិនត្រូវចាកចេញពីរដ្ឋនេះដោយមិនមានការអនុញ្ញាតពីតុលាការ។

(3) កិច្ចព្រមព្រៀងក្នុងការបោះបង់បត្យាប័ន ប្រសិនបើបុគ្គលនោះមិនបានបង្ហាញខ្លួនតាមការចាំបាច់ និងត្រូវបានចាប់ខ្លួននៅក្រៅរដ្ឋ California ។

(4) ការទទួលស្គាល់ថាបុគ្គលនោះត្រូវបានជូនដំណឹងអំពីផលវិបាក និងការដាក់ទោសដែលអាច អនុវត្តចំពោះការរំលោភបំពានលក្ខខណ្ឌដោះលែងទាំងនេះ។

(5) ការយល់ព្រមក្នុងការគោរពតាមច្បាប់និងបទបញ្ជាទាំងអស់របស់តុលាការ។

(h) បុគ្គលដែលមិនត្រូវបានដោះលែងស្របតាមផ្នែកនេះត្រូវបានឃុំខ្លួនរហូតដល់ការបញ្ជូនខ្លួនទៅចៅក្រម លើកលែងតែតុលាការផ្តល់ការពិនិត្យមើលមុនការបញ្ជូនខ្លួនស្របតាមផ្នែក 1320.13 ។

មាត្រា 5. ការពិនិត្យមើលមុនការបញ្ជូនខ្លួនទៅចៅក្រមដោយសេវាកម្មវាយតម្លៃមុនជំនុំជម្រះ ឬតុលាការ

1320.11. (a) ដោយមានការពិគ្រោះយោបល់ជាមួយសេវាកម្មវាយតម្លៃមុនជំនុំជម្រះ និងភាគីពាក់ព័ន្ធផ្សេងទៀត តុលាការ ថ្នាក់លើត្រូវអនុវត្តតាមច្បាប់ក្នុងមូលដ្ឋានរបស់តុលាការស្របទៅនឹងច្បាប់រដ្ឋ California នៃតុលាការដែលបានអនុម័តដោយក្រុមប្រឹក្សាតុលាការ ដូចមានចែងក្នុងផ្នែករង (a) នៃផ្នែក 1320.25 ដែលកំណត់ស្តង់ដារការពិនិត្យ និងការដោះលែង សម្រាប់សេវាកម្មវាយតម្លៃមុនជំនុំជម្រះ សម្រាប់បុគ្គលដែលត្រូវបានវាយតម្លៃថាមាន ហានិភ័យមធ្យម និងមានលក្ខណៈសម្បត្តិទទួលបានការដោះលែងមុនបញ្ជូនខ្លួនទៅចៅក្រមដោយការទទួលស្គាល់ខ្លួនឯង ឬការទទួលស្គាល់ខ្លួនឯងក្រោមការត្រួតពិនិត្យ។ ច្បាប់ក្នុងមូលដ្ឋានរបស់តុលាការត្រូវផ្តល់ការដោះលែង ឬការឃុំខ្លួនចុងចោទដែលមានហានិភ័យមធ្យម គាំទ្រប្រព័ន្ធដោះលែងនិងឃុំខ្លួនមុនជំនុំជម្រះប្រកបដោយប្រសិទ្ធភាព និងសមត្ថភាព ដែលការពារសុវត្ថិភាពរបស់សាធារណជន និងគោរពតាមនីតិវិធីត្រឹមត្រូវតាមច្បាប់ដល់សិទ្ធិរបស់ចុងចោទ។ ច្បាប់ក្នុងមូលដ្ឋានត្រូវផ្តល់សេវាកម្មវាយតម្លៃមុនជំនុំជម្រះជាមួយ អាជ្ញាធរដើម្បីឃុំខ្លួន ឬដោះលែងចុងចោទដែលទទួលស្គាល់ខ្លួនឯង ឬដែលទទួលស្គាល់ខ្លួនឯងក្រោមការត្រួតពិនិត្យ ដែលត្រូវបានវាយតម្លៃថា មានហានិភ័យមធ្យមស្របតាមស្តង់ដារដែលបានចែងនៅក្នុងច្បាប់។ ច្បាប់ក្នុងមូលដ្ឋានអាចនឹងបន្តពង្រីកបញ្ជីនៃបទល្មើស និងកត្តាដែលការដោះលែងបុគ្គលមុនពេល បញ្ជូនខ្លួនទៅចៅក្រមត្រូវបានវាយតម្លៃថាជាហានិភ័យមធ្យម មិនត្រូវបានអនុញ្ញាត ប៉ុន្តែមិនត្រូវផ្តល់ការមិនរាប់បញ្ចូលការដោះលែងចុងចោទដែលមានហានិភ័យមធ្យមទាំងអស់ដោយសេវាកម្មវាយតម្លៃមុនជំនុំជម្រះឡើយ។ អាជ្ញាធរនៃច្បាប់ក្នុងមូលដ្ឋានរបស់តុលាការត្រូវបានកំណត់ព្រំដែនត្រឹមសេចក្តីសម្រេចដែលធ្វើ ឡើងស្របតាមផ្នែករង (c) នៃផ្នែក 1320.10។ ជាប្រចាំឆ្នាំ តុលាការជាន់ខ្ពស់ត្រូវពិចារណាលើផលប៉ះពាល់នៃច្បាប់ទៅលើសុវត្ថិភាពសាធារណៈ សិទ្ធិទទួលបានការត្រួតពិនិត្យរបស់ចុងចោទ និងការអនុវត្តច្បាប់កាលពីឆ្នាំមុន។

(b) ស្របតាមផ្នែករង (d) នៃវិធាន 10.613 នៃច្បាប់តុលាការរដ្ឋ California តុលាការត្រូវផ្តល់ជូន ទៅក្រុមប្រឹក្សាតុលាការនូវឯកសារចម្លងជាអេឡិចត្រូនិកនៃច្បាប់ និងការធ្វើវិសោធនកម្មលើច្បាប់ដែលបានអនុម័តស្របតាមផ្នែកនេះនៅក្នុងទម្រង់ដែលបានអនុញ្ញាតដោយក្រុមប្រឹក្សាតុលាការ។

1320.13. (a) តុលាការអាចនឹងធ្វើការពិនិត្យមើលមុនពេលបញ្ជូនខ្លួនទៅចៅក្រម ធ្វើការ សម្រេចចិត្តការដោះលែង និងអាចនឹងប្រគល់សិទ្ធិដល់មន្ត្រីតុលាការថ្នាក់ក្រោមដូចមានកំណត់នៅក្នុងវិធាន 10.703 នៃច្បាប់រដ្ឋ California ដើម្បីធ្វើការពិនិត្យមើលមុនពេលបញ្ជូនខ្លួន និងធ្វើការសម្រេចចិត្តការដោះលែងដែលអនុញ្ញាតដោយជំពូកនេះ។

(b) អាជ្ញាធរសម្រាប់ការពិនិត្យមើលមុនបញ្ជូនទៅតុលាការនិងការដោះលែង ដែលបានផ្តល់ដោយ ផ្នែកនេះ មិនត្រូវអនុវត្តលើបុគ្គលដូចខាងក្រោមទេ៖

(1) បុគ្គលដែលត្រូវបានវាយតម្លៃថាមានហានិភ័យខ្ពស់។

(2) បុគ្គលដែលត្រូវបានចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរដូចមានចែងនៅក្នុងផ្នែករង (c) នៃផ្នែក 1192.7 ឬបទឧក្រិដ្ឋហិង្សាដូចមានចែងក្នុងផ្នែករង (c) នៃផ្នែក 667.5 ។

(3) បុគ្គលដែលនៅពេលចាប់ខ្លួន ស្ថិតនៅក្នុងការជំនុំជម្រះដែលមិនទាន់បញ្ចប់ ឬការកាត់ទោសពី បទឧក្រិដ្ឋ។

(c) នៅពេលធ្វើសេចក្តីសម្រេចការដោះលែងមុនបញ្ជូនខ្លួន ឬធ្វើការឃុំខ្លួន និងលក្ខខណ្ឌនៃការបញ្ជាឲ្យដោះលែង ព័ត៌មានដែលបានទទួលក្រោមផ្នែក 1320.9 ព្រមទាំងអនុសាសន៍និង ជម្រើសលក្ខខណ្ឌនៃការដោះលែងណាមួយត្រូវបានពិចារណា ដោយផ្តល់ទម្ងន់ខ្លាំងទៅលើអនុសាសន៍ និងសេវាកម្មវាយតម្លៃមុនជំនុំជម្រះ។

(d) តុលាការត្រូវពិចារណាលើព័ត៌មានពាក់ព័ន្ធនិងព័ត៌មានដែលបានផ្តល់ដោយផ្នែកអនុវត្តច្បាប់ បុគ្គលដែលត្រូវបានចាប់ខ្លួន ជនរងគ្រោះណាម្នាក់ និងបណ្តឹងចោទប្រកាន់ ឬការការពារ មុននឹងធ្វើសេចក្តីសម្រេចដោះលែងមុនជំនុំជម្រះ ឬសេចក្តីសម្រេចឱ្យជាប់ឃុំ។

(e) (1) ប្រសិនបើតុលាការរកឃើញថា បុគ្គលនោះមានភាពសមស្របនឹងការដោះលែងមុនបញ្ជូនទៅចៅក្រម បុគ្គលដែលត្រូវបានចាប់ខ្លួននោះ ត្រូវបានដោះលែងដោយការទទួលស្គាល់ខ្លួនឯង ឬការទទួលស្គាល់ខ្លួនឯងដែលត្រូវបានត្រួតពិនិត្យរបស់បុគ្គលនោះ ដោយមានលក្ខខណ្ឌរឹតត្បិតតិចតួចបំផុតដែលមិនមែនជារូបិយវត្ថុ ឬបន្សំនៃលក្ខខណ្ឌនានាដែលនឹងធានាយ៉ាងសមហេតុផលនូវ សុវត្ថិភាពសាធារណៈ និងការបង្ហាញខ្លួនក្នុងតុលាការដូចដែលបានតម្រូវរបស់បុគ្គលដែលបានចាប់ខ្លួននោះ។

(2) បុគ្គលមិនត្រូវបានតម្រូវឲ្យបង់ប្រាក់សម្រាប់លក្ខខណ្ឌមិនមែនរូបិយវត្ថុ ឬការរួមបញ្ចូលលក្ខខណ្ឌនានាដែលបានដាក់ ស្របតាមផ្នែករងនេះឡើយ។

(f) បុគ្គលដែលត្រូវបានដោះលែងដោយការទទួលស្គាល់ខ្លួនឯង ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងការដោះលែង ដែលយ៉ាងហោចណាស់ រៀបរាប់ពីបុគ្គលនោះនូវចំណុចទាំងអស់ដូចខាងក្រោម៖

(1) ការសន្យាថាត្រូវបង្ហាញខ្លួននៅគ្រប់ពេលនិងគ្រប់ទីកន្លែង តាមការបញ្ជាដោយតុលាការ។

(2) ការសន្យាថាមិនត្រូវចាកចេញពីរដ្ឋនេះដោយមិនមានការអនុញ្ញាតពីតុលាការ។

(3) កិច្ចព្រមព្រៀងក្នុងការបោះបង់បត្យាប័ន ប្រសិនបើបុគ្គលនោះមិនបានបង្ហាញខ្លួនតាមការចាំបាច់ និងត្រូវបានចាប់ខ្លួននៅក្រៅរដ្ឋ California ។

(4) ការទទួលស្គាល់ថាបុគ្គលនោះត្រូវបានជូនដំណឹងអំពីផលវិបាក និងការដាក់ទោសដែលអាច អនុវត្តចំពោះការរំលោភបំពានលក្ខខណ្ឌដោះលែងទាំងនេះ។

(5) ការយល់ព្រមក្នុងការគោរពតាមច្បាប់និងបទបញ្ជាទាំងអស់របស់តុលាការ។

25

(g) ជម្រើសសម្រាប់លក្ខខណ្ឌនៃការដោះលែងត្រូវបង្កើតដោយក្រុមប្រឹក្សាតុលាការ និងមានចែងក្នុងវិធានតុលាការរដ្ឋ California។

(h) តុលាការអាចនឹងបដិសេធការដោះលែងបុគ្គលដែលរង់ចាំការបញ្ជូនខ្លួនទៅចៅក្រម ប្រសិនបើទំនងជាមិនមានលក្ខខណ្ឌ ឬការរួមបញ្ចូលលក្ខខណ្ឌនានានៃការត្រួតពិនិត្យមុនជំនុំជម្រះ ដែលនឹងធានាយ៉ាងសមហេតុផលដល់សុវត្ថិភាពសាធារណៈ ឬការបង្ហាញខ្លួនរបស់បុគ្គលនោះតាមការតម្រូវទេ។

(i) ត្រូវមានការសន្មត់ជាមុនថាគ្មានលក្ខខណ្ឌ ឬបណ្តុំលក្ខខណ្ឌនៃការត្រួតពិនិត្យមុនជំនុំជម្រះណា ដែលនឹងធានាយ៉ាងសមហេតុផលដល់សុវត្ថិភាពបុគ្គលផ្សេងទៀត និងសហគមន៍ ពីការរង់ចាំការបញ្ជូនខ្លួនទៅតុលាការឡើយ ប្រសិនបើការសន្មត់នោះបង្ហាញថាអនុវត្តទៅលើចំណុចណាមួយខាងក្រោម៖

(1) បទល្មើសដែលបុគ្គលត្រូវបានចាប់ខ្លួននោះមានគឺជាការប្រព្រឹត្តអំពើហិង្សាលើបុគ្គលណាម្នាក់ អំពើហិង្សាគំរាមកំហែង ឬលទ្ធភាពបង្ករបួសរាងកាយធ្ងន់ធ្ងរ ឬបទល្មើសដែលជននោះបានប្រព្រឹត្តគឺជាបទល្មើសប្រដាប់អាវុធផ្ទាល់ខ្លួន ឬប្រើប្រាស់អាវុធ ឬកាំភ្លើងពិឃាតក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបង្ករបួសរាងកាយធ្ងន់ធ្ងរនៅក្នុងការប្រព្រឹត្តបទល្មើសនោះ។

(2) នៅពេលចាប់ខ្លួន បុគ្គលនោះបានស្ថិតនៅក្នុងទម្រង់ណាមួយនៃការត្រួតពិនិត្យក្រោយការកាត់ ទោស ក្រៅពីការត្រួតពិនិត្យរបស់តុលាការ ឬការដោះលែងបណ្តោះអាសន្នក្រៅផ្លូវការ។

(3) បុគ្គលដែលត្រូវបានចាប់ខ្លួនបានបំភិតបំភ័យ ឃាត់ឃាំង ឬគំរាមកំហែងអំពីការសងសឹកប្រឆាំងនឹងសាក្សី ឬជនរងគ្រោះនៃបទល្មើសបច្ចុប្បន្ន។

(4) បច្ចុប្បន្នបុគ្គលនោះកំពុងស្ថិតនៅក្នុងការដោះលែងមុនពេលជំនុំជម្រះ ហើយបានរំលោភបំពាន លើលក្ខខណ្ឌនៃការដោះលែង។

1320.14. នៅពេលណាមួយតាមញត្តិផ្ទាល់ខ្លួន ឬនៅពេលមានការដាក់ពាក្យសុំពីបុគ្គលដែលត្រូវបានចាប់ខ្លួន ភាគីដើមចោទ ឬសេវាកម្មវាយតម្លៃមុនជំនុំជម្រះ ដើម្បីបុព្វហេតុល្អដែលបានបង្ហាញមក តុលាការអាចនឹងកែប្រែលក្ខខណ្ឌនៃការដោះលែងជាមួយការជូនដំណឹងក្នុងពេល 24 ម៉ោង លើកលែងតែពេលវេលា និងកាលៈទេសៈមិនអនុញ្ញាតការជូនដំណឹងក្នុងរយៈពេល 24 ម៉ោង។

មាត្រា 6. សេចក្តីសម្រេចការដោះលែង ឬការឃុំខ្លួននៅពេលបញ្ជូនខ្លួនទៅតុលាការ

1320.15. នៅពេល ឬមុនពេលការបញ្ជូនខ្លួនទៅចៅក្រមរបស់ចុងចោទ ការវាយតម្លៃមុនជំនុំ ជម្រះ ប្រសិនបើចុងចោទមិនត្រូវបានដោះលែងស្របតាមផ្នែក 1320.8 ទេ ត្រូវដាក់បញ្ជូនរាល់ព័ត៌មានសម្រាប់ការពិចារណដោយតុលាការដូចតទៅ៖

(a) លទ្ធផលនៃការវាយតម្លៃហានិភ័យ ដែលរួមមានពិន្ទុហានិភ័យ ឬកម្រិតហានិភ័យ ឬទាំងពីរ ដែលបានទទួលដោយការប្រើប្រាស់ឧបករណ៍វាយតម្លៃហានិភ័យដែលមានសុពលភាព។

(b) ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌចំពោះបុគ្គលដែលត្រូវបានចាប់ខ្លួន និងប្រវត្តិបទល្មើស របស់បុគ្គល រួមទាំងប្រវត្តិនៃការមិនមកបង្ហាញខ្លួននៅតុលាការ ក្នុងរយៈពេល បីឆ្នាំចុងក្រោយរបស់បុគ្គលនោះ។

(c) ព័ត៌មានបន្ថែមណាមួយដែលអាចរកបានដោយសមហេតុផលដែលដោះស្រាយដោយផ្ទាល់នូវហានិភ័យចំពោះសុវត្ថិភាពសាធារណៈឬហានិភ័យនៃការមិនមកបង្ហាញខ្លួននៅតុលាការ ដូចបានតម្រូវលើចុងចោទ។

(d) អនុសាសន៍ទៅតុលាការសម្រាប់លក្ខខណ្ឌនៃការដោះលែងដើម្បីដាក់លើចុងចោទដែលត្រូវបានដោះលែង។ ជម្រើសសម្រាប់លក្ខខណ្ឌនៃការដោះលែងត្រូវបង្កើតដោយក្រុមប្រឹក្សាតុលាការ និងមានចែងក្នុងច្បាប់តុលាការរដ្ឋ California។

1320.16. (a) ជនរងគ្រោះពីបទឧក្រិដ្ឋដែលចុងចោទត្រូវបានចាប់ខ្លួននឹងត្រូវបានជូនដំណឹងអំពីការបញ្ជូនខ្លួនទៅចៅក្រមដោយការដាក់ទោស និងប្រសិនបើមានសំណើ ត្រូវប្រាប់អំពីសវនាការផ្សេងទៀតនៅពេលដែលស្ថានភាពឃុំខ្លួនរបស់ចុងចោទនឹងត្រូវបានកំណត់។ ប្រសិនបើមានសំណើពីជនរងគ្រោះ ជនរងគ្រោះនោះនឹងត្រូវបានផ្តល់ឱកាសយ៉ាងសមហេតុផលដើម្បីឲ្យនិយាយអំពីបញ្ហា ស្ថានភាពឃុំខ្លួន របស់ចុងចោទ។

(b) អយ្យការត្រូវបង្កើតការខិតខំប្រឹងប្រែងដែលសមហេតុផលដើម្បីទាក់ទងជនរងគ្រោះឱ្យផ្តល់ យោបល់អំពីស្ថានភាព ជាប់ឃុំរបស់ចុងចោទ។

(c) ក្នុងករណីដែលជនរងគ្រោះមិនអាច ឬមិនចង់បង្ហាញខ្លួន នៅពេលការបញ្ជូនខ្លួនទៅចៅក្រម អយ្យការត្រូវបញ្ជាក់អំពីមតិរបស់ជនរងគ្រោះចំពោះស្ថានភាពឃុំខ្លួនរបស់ចុងចោទជាលាយលក្ខណ៍អក្សរទៅតុលាការ។

(d) ការបង្ហាញខ្លួន ឬការមិនបានបង្ហាញខ្លួនរបស់ជនរងគ្រោះ និងយោបល់ណាមួយដែលបានផ្តល់ ដោយជនរងគ្រោះត្រូវបានរួមបញ្ចូលនៅក្នុងកំណត់ត្រានោះ។

(e) ប្រសិនបើបានស្នើសុំដោយភាគីណាមួយ តុលាការអាចនឹងពិនិត្យមើល ហើយកែប្រែលក្ខខណ្ឌនៃការដោះលែងចុងចោទនោះនៅពេលបញ្ជូនខ្លួនទៅចៅក្រម។

1320.17. នៅពេលបញ្ជូនខ្លួនទៅចៅក្រម តុលាការត្រូវបញ្ជាឲ្យចុងចោទដែលត្រូវបានដោះលែងដោយការទទួលស្គាល់ខ្លួនឯង ឬការទទួលស្គាល់ខ្លួនឯងក្រោមការត្រួតពិនិត្យ ដោយមានលក្ខខណ្ឌរឹតត្បិតតិចតួចបំផុតដែលមិនមែនជារូបិយវត្ថុ ឬការរួមបញ្ចូលលក្ខខណ្ឌនានាដែលនឹងធានាយ៉ាងសមហេតុផលដល់សុវត្ថិភាពសាធារណៈ និងការត្រឡប់មកតុលាការវិញរបស់ចុងចោទ លើកលែងតែអយ្យការដាក់ញត្តិសម្រាប់ការឃុំខ្លួនបង្ការដោយ អនុលោមតាមផ្នែក 1320.18 ។

1320.18. (a) នៅពេលបញ្ជូនខ្លួនចុងចោទទៅចៅក្រមឬ នៅអំឡុងពេលអនុវត្តនីតិវិធីព្រហ្មទណ្ឌ អយ្យការអាចនឹងដាក់ញត្តិស្នើការឃុំខ្លួនចុងចោទដែលមិនទាន់បញ្ចប់ការជំនុំជម្រះ អាស្រ័យលើកាលៈទេសៈណាមួយដូចខាង ក្រោម៖

(1) បទល្មើសដែលបុគ្គលត្រូវបានចាប់ខ្លួននោះមានគឺជាការប្រព្រឹត្តអំពើហិង្សាលើបុគ្គលណាម្នាក់ អំពើហិង្សាគំរាមកំហែង ឬលទ្ធភាពបង្ករបួសរាងកាយធ្ងន់ធ្ងរ ឬបទល្មើសដែលជននោះបានប្រព្រឹត្តគឺជាបទល្មើសប្រដាប់អាវុធផ្ទាល់ខ្លួន ឬប្រើប្រាស់អាវុធ ឬកាំភ្លើងពិឃាតក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬជាបទល្មើសដែលបុគ្គលនោះបង្ករបួសរាងកាយធ្ងន់ធ្ងរដោយផ្ទាល់នៅក្នុងការប្រព្រឹត្តបទល្មើស។

(2) ចុងចោទ ដែលនៅពេលនៃការចាប់ខ្លួន ស្ថិតនៅក្រោមទម្រង់ណាមួយនៃការត្រួតពិនិត្យក្រោយកាត់ទោស ក្រៅពីការដោះលែងសាកល្បងក្រៅផ្លូវការ ឬការត្រួតពិនិត្យរបស់តុលាការ។

(3) នៅពេលចាប់ខ្លួន ចុងចោទបានស្ថិតក្រោមការជំនុំជម្រះដែលមិនទាន់បញ្ចប់ ឬការកាត់ទោស ដែលមិនទាន់បញ្ចប់នៃបទឧក្រិដ្ឋ។

(4) ចុងចោទបានបំភិតបំភ័យ ឬគំរាមកំហែងអំពីការសងសឹកប្រឆាំងនឹងសាក្សី ឬជនរងគ្រោះនៃបទល្មើសបច្ចុប្បន្ន។

(5) មានមូលហេតុជាច្រើនក្នុងការជឿជាក់ថា គ្មានលក្ខខណ្ឌ មិនមែនរូបិយវត្ថុ ឬការរួមបញ្ចូលលក្ខខណ្ឌនានានៃការត្រួតពិនិត្យមុនជំនុំជម្រះណាមួយ ដែលនឹងធានាដល់ការការពារយ៉ាងសមហេតុផលដល់សាធារណជន ឬជនរងគ្រោះ ឬការបង្ហាញខ្លួនរបស់ចុងចោទនៅតុលាការតាមការតម្រូវ។

(b) តុលាការត្រូវធ្វើសវនការឃុំខ្លួនបង្ការដូចមានចែងនៅក្នុងផ្នែក 1320.19 ។

(c) បន្ទាប់ពីការដាក់ញត្តិសម្រាប់ការឃុំខ្លួនបង្ការ តុលាការត្រូវធ្វើការកំណត់ពាក់ព័ន្ធនឹងការដោះ លែង ឬការឃុំខ្លួនចុងចោទដែលមិនទាន់បញ្ចប់សវនាការឃុំខ្លួនបង្ការ។ នៅពេលធ្វើសេចក្តីសម្រេចការដោះលែង ឬការឃុំខ្លួន និងលក្ខខណ្ឌនៃការបញ្ជាឲ្យដោះលែង ដែលកំពុងរង់ចាំសវនាការឃុំខ្លួនបង្ការ តុលាការនឹងពិចារណាលើព័ត៌មានដែលផ្តល់ដោយសេវាកម្មវាយតម្លៃមុនជំនុំជម្រះ ដែលរួមមានអនុសាសន៍លើលក្ខខណ្ឌនៃការដោះលែង និងត្រូវផ្តល់ទម្ងន់ខ្លាំងទៅលើអនុសាសន៍ និងការវាយតម្លៃពីសេវាកម្មវាយតម្លៃមុនជំនុំជម្រះ។

(d) ប្រសិនបើតុលាការកំណត់ថា មានលទ្ធភាពច្រើនដែលមិនមានលក្ខខណ្ឌមិនមែនរូបិយវត្ថុ ឬការ រួមបញ្ចូលគ្នានៃលក្ខខណ្ឌនៃការត្រួតពិនិត្យមុនជំនុំជម្រះណា ដែលនឹងធានាយ៉ាងសមហេតុផលពីការបង្ហាញខ្លួនរបស់ចុងចោទនៅសវនាការឃុំខ្លួនបង្ការ ឬធានាយ៉ាងសមហេតុផលពីសុវត្ថិភាពសាធារណមុនពេលសវនាការឃុំខ្លួនបង្ការ តុលាការអាចនឹងឃុំឃាំងចុងចោទដែលរង់ចាំសវនាការឃុំខ្លួនបង្ការនោះ ហើយត្រូវថ្លែងពីហេតុផលចំពោះការឃុំខ្លួននៅលើកំណត់ត្រានោះ។

(e) (1) ប្រសិនបើតុលាការសម្រេចថា មិនមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការឃុំឃាំងចុងចោទដែលរង់ចាំសវនាការឃុំខ្លួនបង្ការ តុលាការត្រូវដោះលែងចុងចោទដែលមានការទទួលស្គាល់ខ្លួនឯង ឬការទទួលស្គាល់ខ្លួនឯងដែលបានត្រួតពិនិត្យ ហើយដាក់លក្ខខណ្ឌរឹតត្បិតតិចតួចបំផុតដែលមិនមែនជារូបិយវត្ថុ ឬការរួមបញ្ចូលនៃលក្ខខណ្ឌនានានៃការដោះលែងមុនជំនុំជម្រះ ដើម្បីធានាយ៉ាងសមហេតុផលនូវសុវត្ថិភាពសារធារណៈ និងការបង្ហាញខ្លួនក្នុង តុលាការរបស់ចុងចោទដូចដែលបានតម្រូវ។

(2) បុគ្គលមិនត្រូវបានតម្រូវឲ្យបង់ប្រាក់សម្រាប់លក្ខខណ្ឌមិនមែនរូបិយវត្ថុ ឬការរួមបញ្ចូលលក្ខខណ្ឌនានាដែលបានដាក់ ស្របតាមផ្នែករងនេះឡើយ។

មាត្រា 7. សវនាការឃុំខ្លួនបង្ការ

1320.19. (a) ប្រសិនបើចុងចោទត្រូវបានដាក់ក្នុងកន្លែងឃុំឃាំង សវនាការឃុំខ្លួនបង្ការនឹងត្រូវប្រព្រឹត្តទៅក្នុងរយៈពេលបីថ្ងៃធ្វើការរបស់តុលាការយ៉ាងយូរ បន្ទាប់ពីបានដាក់ញត្តិឃុំខ្លួនបង្ការ។ ប្រសិនបើចុងចោទមិនត្រូវបានដាក់ក្នុងកន្លែងឃុំឃាំងទេ សវនាការឃុំខ្លួនបង្ការនឹងត្រូវប្រព្រឹតទៅ ក្នុងរយៈពេលបីថ្ងៃធ្វើការរបស់តុលាការយ៉ាងយូរ បន្ទាប់ពីចុងចោទត្រូវបាននាំមកដាក់ក្នុងមន្ទីរឃុំឃាំងដែលជាលទ្ធផលនៃដីកាដែលបានចេញដោយអនុលោមតាមផ្នែករង (c)។ ប្រសិនបើចុងចោទមិនស្ថិតនៅក្នុងកន្លែងឃុំឃាំង នៅពេលស្នើសុំសវនាការឃុំខ្លួនបង្ការទេ ហើយតុលាការមិនចេញដីកាដែលពាក់ព័ន្ធនឹងសំណើសម្រាប់សវនាការនោះ សវនាការឃុំខ្លួនបង្ការនឹងត្រូវប្រព្រឹត្តទៅក្នុងរយៈពេលប្រាំថ្ងៃធ្វើការរបស់តុលាការយ៉ាងយូរ នៃសំណើសម្រាប់សវនាការនេះ។ ដោយលក្ខខណ្ឌពិសេសរបស់ក្រុមប្រឹក្សា ជាមួយនឹងកិច្ចព្រមព្រៀងរបស់តុលាការ សវនាការឃុំខ្លួន បង្ការនឹងត្រូវប្រព្រឹត្តទៅរួមគ្នាជាមួយការបញ្ជូនខ្លួនទៅចៅក្រម ឬក្នុងរយៈពេលបីថ្ងៃធ្វើការរបស់តុលាការ បន្ទាប់ពីការបញ្ជូនខ្លួន។

(b) ដើម្បីបុព្វហេតុល្អ ចុងចោទ ឬអយ្យការអាចនឹងស្នើសុំការបន្តសវនការឃុំខ្លួនបង្ការ។ ប្រសិនបើសំណើសម្រាប់ការបន្តត្រូវបានផ្តល់ នោះការបន្តអាចនឹងមិនលើសពីរយៈពេលបីថ្ងៃធ្វើការ របស់តុលាការឡើយ លើកលែងតែបានកំណត់ដោយភាគី។

(c) សវនាការត្រូវតែបញ្ចប់ក្នុងពេលតែម្តង លើកលែងតែចុងចោទបោះបង់សិទ្ធិរបស់ខ្លួនដោយផ្ទាល់ ក្នុងសវនាការឃុំខ្លួនបង្ការដែលកំពុងបន្ត។ ក្រោយការដាក់ពាក្យសុំដីការួមជាមួយញ្ញត្តិសម្រាប់ការឃុំខ្លួនបង្ការ ប្រសិនបើចុងចោទនៅក្រៅមន្ទីរ ឃុំឃាំង នៅពេលសវនាការឃុំខ្លួនបង្ការត្រូវបានស្នើសុំ តុលាការអាចនឹងចេញដីការចាប់ខ្លួន ដែលតម្រូវឲ្យចុងចោទស្ថិតនៅកន្លែងឃុំឃាំង រង់ចាំការបញ្ចប់សវនាការឃុំខ្លួន បង្ការ។

(d) ចុងចោទត្រូវមានសិទ្ធិទទួលបានតំណាងពីមេធាវីនៅឯសវនាការ។ ប្រសិនបើចុងចោទមិនមានលទ្ធភាពខាងហិរញ្ញវត្ថុដើម្បីទទួលបានអ្នកតំណាងទេ ចុងចោទមានសិទ្ធិ ទទួលបានមេធាវីដែលបានចាត់តាំង។ ចុងចោទមានសិទ្ធិនិយាយនៅក្នុងសវនាការឃុំខ្លួនបង្ការ។

(e) ក្រោយការស្នើសុំរបស់ជនរងគ្រោះពីបទឧក្រិដ្ឋ ជនរងគ្រោះនោះត្រូវបានជូនដំណឹងដោយអយ្យការអំពីសវនាការឃុំខ្លួនបង្ការ។ ប្រសិនបើបានស្នើសុំ ជនរងគ្រោះត្រូវទទួលបានឱកាសសមហេតុផល ក្នុងការចូលរួមសវនាការទៅលើបញ្ហានៃស្ថានភាពជាប់ឃុំឃាំងរបស់ចុងចោទ។

(f) អយ្យការត្រូវបង្កើតការខិតខំប្រឹងប្រែងដែលសមហេតុផលដើម្បីទាក់ទងជនរងគ្រោះឱ្យផ្តល់ យោបល់អំពីស្ថានភាព ជាប់ឃុំរបស់ចុងចោទ។ ក្នុងករណីដែលជនរងគ្រោះមិនអាចឬ មិនចង់បង្ហាញខ្លួននៅសវនាការឃុំខ្លួនបង្ការ អយ្យការត្រូវដាក់បញ្ជូននូវមតិរបស់ជនរងគ្រោះ ប្រសិនបើមាន ចំពោះស្ថានភាពឃុំខ្លួនរបស់ចុងចោទជាលាយលក្ខណ៍អក្សរទៅតុលាការ និងក្រុមប្រឹក្សា។

(g) ការបង្ហាញខ្លួន ឬការមិនបានបង្ហាញខ្លួនរបស់ជនរងគ្រោះ និងយោបល់ដែលបានផ្តល់ដោយ ជនរងគ្រោះត្រូវតែរួមបញ្ចូលនៅក្នុងកំណត់ត្រានេះ។

1320.20. (a) ត្រូវមានការសន្ទ្ធត់ជាមុនដែលគ្មានលក្ខខណ្ឌ ឬការរួមបញ្ចូលគ្នានៃលក្ខខណ្ឌត្រួតពិនិត្យមុនជំនុំជម្រះដែលនឹងធានាសុវត្ថិភាពយ៉ាងសមហេតុផលដល់សាធារណៈជនប្រសិនបើតុលាការរកឃើញមូលហេតុប្រហាក់ប្រហែលដែលអាចជឿទុកចិត្តបានដូចខាងក្រោម ៖

(1) បទល្មើសព្រហ្មទណ្ឌបច្ចុប្បន្នគឺជាបទឧក្រិដ្ឋហិង្សាដូចមានចែងនៅក្នុងផ្នែករង (c) នៃផ្នែក 667.5 ឬជាបទឧក្រិដ្ឋដែលបានប្រព្រឹត្តអំពើហិង្សាលើបុគ្គលណាម្នាក់ អំពើហិង្សាគំរាមកំហែង ឬលទ្ធភាពបង្ករបួសរាងកាយធ្ងន់ធ្ងរ ឬបទល្មើសដែលចុងចោទនោះប្រដាប់ដោយអាវុធ ឬប្រើប្រាស់អាវុធ ឬកាំភ្លើងពិឃាតក្នុងការប្រព្រឹត្តបទល្មើស ឬបទល្មើសដែលខ្លួនបង្ករបួសរាងកាយធ្ងន់ធ្ងរដោយផ្ទាល់ក្នុងការប្រព្រឹត្តបទល្មើសនោះ ឬ

(2) ចុងចោទត្រូវបានវាយតម្លៃថាមាន "ហានិภัយខ្ពស់" ដល់សុវត្ថិភាពសាធារណ ឬជនរងគ្រោះ និងណាមួយដូចខាងក្រោម៖

(A) ចុងចោទត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្រិតធ្ងន់ ដូចមានកំណត់នៅក្នុងផ្នែករង (c) នៃផ្នែកទី 1192.7 ឬបទឧក្រិដ្ឋហិង្សាដូចមានកំណត់នៅក្នុងផ្នែករង (c) នៃផ្នែកទី 667.5 នៅក្នុងរយៈពេល 5 ឆ្នាំកន្លងមក។

25

(B) ចុងចោទបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌបច្ចុប្បន្នដែលរង់ចាំការកាត់ទោសពីបទល្មើសព្រហ្មទណ្ឌដូចមានចែងនៅក្នុងកថាខណ្ឌទី (1) នៃផ្នែករង (a)។

(C) ចុងចោទបានបំភិតបំភ័យ ឃាត់ឃាំង ឬគំរាមកំហែងអំពីការសងសឹកប្រឆាំងនឹងសាក្សី ឬជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌបច្ចុប្បន្ន។

(D) នៅពេលចាប់ខ្លួន ចុងចោទ ស្ថិតនៅក្រោមការត្រួតពិនិត្យក្រោយការផ្តន្ទាទោសទម្រង់ណាមួយក្រៅពីការដោះលែងសាកល្បងក្រៅផ្លូវការ ឬការត្រួតពិនិត្យដោយតុលាការ។

(b) អយ្យការត្រូវបង្កើតនៅឯសវនាការឃុំខ្លួនបង្ការថាមានមូលហេតុប្រហាក់ប្រហែលក្នុងការជឿថា ចុងចោទបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬបទល្មើសទាំងឡាយដែលបានចោទប្រកាន់ នៅពេលដែលមិនមានភស្តុតាងគ្រប់គ្រាន់ ឬប្រសិនបើចុងចោទ ពុំទាន់ត្រូវបាននាំចូលក្នុងសវនាការដើម្បីឆ្លើយតបសវនាការនាំមុខ ឬការលះបង់សិទ្ធិសវនាការនាំមុខ ហើយចុងចោទប្រឈមនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដែលបង្ហាញថា ខ្លួនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬបទល្មើសទាំងឡាយដែលបានចោទប្រកាន់។

(c) តុលាការត្រូវធ្វើសេចក្តីសម្រេចផ្ទាល់ខ្លួនទាក់ទងនឹងការឃុំខ្លួនបង្ការ រួមទាំងការកំណត់មូលហេតុប្រហាក់ប្រហែលដើម្បីជឿថា ចុងចោទបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬបទល្មើសទាំងឡាយ ដោយផ្អែកលើសេចក្តីថ្លែងការណ៍ ប្រសិនបើមាន របស់ចុងចោទ ការផ្តល់ភស្តុតាង និងទឡ្ហីករណ៍របស់មេធាវី មតិចូលរួមពីជនរងគ្រោះ ប្រសិនបើមាន និងរាល់ភស្តុតាងដែលបានបង្ហាញនៅសវនាការ។ តុលាការអាចពិចារណាអំពីពាក្យចចាមអារាមដែលអាចជឿទុកចិត្តបាននៅក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយក្រោមផ្នែកនេះ។ ចុងចោទត្រូវមានសិទ្ធិផ្តល់កសិណសាក្សីនៅឯសវនាការ។

(d) (1) នៅឯសវនាការឃុំខ្លួន តុលាការអាចបង្គាប់ឲ្យឃុំខ្លួនបង្ការចុងចោទដែលរង់ចាំការជំនុំជម្រះ ឬសវនាការផ្សេងទៀត តែក្នុងករណីដែលការឃុំខ្លួននោះត្រូវបានអនុញ្ញាតក្រោមរដ្ឋធម្មនុញ្ញសហរដ្ឋ និងក្រោមធម្មនុញ្ញរដ្ឋ California ហើយតុលាការកំណត់ដោយភស្តុតាងច្បាស់លាស់ និងគួរឲ្យទុកចិត្តថា គ្មានលក្ខខណ្ឌមិនមែនរូបិយវត្ថុ ឬការរួមបញ្ចូលគ្នានូវលក្ខខណ្ឌនៃការត្រួតពិនិត្យមុនពេលជំនុំជម្រះណា នឹងធានាយ៉ាងសមហេតុផលនូវសុវត្ថិភាពសាធារណៈ ឬការបង្ហាញខ្លួនរបស់ចុងចោទនៅតុលាការតាមការតម្រូវ។ តុលាការត្រូវបញ្ជាក់អំពីហេតុផលសម្រាប់ការចេញដីកាឃុំខ្លួនបង្ការលើកំណត់ត្រា។

(2) អត្ថបទនៃសវនាការត្រូវផ្តល់ជូនតាមសំណើរបស់ភាគីណាមួយ ក្នុងរយៈពេលពីរថ្ងៃនៅតុលាការ បន្ទាប់ពីបានធ្វើការស្នើសុំរួច។

(3) ប្រសិនបើភាគីណាមួយដាក់ដីកាបង្គាប់មួយដែលប្រឆាំងនឹងសេចក្តីសម្រេច តុលាការឧទ្ធរណ៍ត្រូវពិចារណាដីកាបង្គាប់នោះជាបន្ទាន់។

(e) (1) ប្រសិនបើតុលាការកំណត់ថា ពុំមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការឃុំខ្លួនចុងចោទទេនោះ តុលាការត្រូវដោះលែងចុងចោទដោយការទទួលស្គាល់ផ្ទាល់ខ្លួនរបស់ពួកគេ ឬការទទួលស្គាល់ផ្ទាល់ខ្លួនដែលបានត្រួតពិនិត្យ និងដាក់លក្ខខណ្ឌរឹតត្បឹតកម្រិតតិចតួចបំផុតមិនមែនរូបិយវត្ថុ ឬការរួមបញ្ចូលគ្នានូវលក្ខខណ្ឌនានានៃការត្រួតពិនិត្យមុនពេលជំនុំជម្រះ ដើម្បីធានាយ៉ាងសមហេតុផលនូវសុវត្ថិភាពសាធារណៈ ឬការបង្ហាញខ្លួនរបស់ចុងចោទនៅតុលាការតាមការតម្រូវ។

(2) បុគ្គលមិនត្រូវបានតម្រូវឲ្យបង់ប្រាក់សម្រាប់លក្ខខណ្ឌមិនមែនរូបិយវត្ថុ ឬការរួមបញ្ចូលលក្ខខណ្ឌនានាដែលបានដាក់ ស្របតាមផ្នែករងនេះឡើយ។

(f) សម្រាប់តែគោលបំណងម្យ៉ាងគត់គឺកំណត់ថាតើបុគ្គលនោះគួរត្រូវបានឃុំខ្លួន ឬបង្កើតនូវលក្ខខណ្ឌរឹតត្បឹតកម្រិតតិចតួចបំផុតមិនមែនរូបិយវត្ថុនៃការដោះលែងមុនជំនុំជម្រះដើម្បីដាក់ទៅលើ តុលាការអាចពិចារណាអំពីព័ត៌មានពាក់ព័ន្ធណាមួយ ដូចមានចែងនៅក្នុងច្បាប់តុលាការរដ្ឋ California រួមមានប៉ុន្តែមិនកំណត់ចំពោះខាងក្រោមនេះ៖

(1) លក្ខណៈ និងកាលៈទេសៈនៃបទល្មើសព្រហ្មទណ្ឌដែលបានចោទប្រកាន់។

(2) ស្ថានទម្ងន់នៃភស្តុតាងប្រឆាំងនឹងចុងចោទ លើកលែងតែថា តុលាការអាចនឹងពិចារណាអំពីភាពអាចអនុញ្ញាតបាននៃភស្តុតាងដែលស្វែងរកការដកចេញ។

(3) ការប្រព្រឹត្តពីមុនចំណងគ្រួសារ និងសហគមន៍ ប្រវត្តិបទល្មើសព្រហ្មទណ្ឌរបស់ចុងចោទ និងកំណត់ត្រាដែលពាក់ព័ន្ធនឹងការបង្ហាញខ្លួននៅតុលាការនៅក្នុងដំណើរការរឿងក្តីតុលាការ។

(4) នៅពេលដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬ ការចាប់ខ្លួនបច្ចុប្បន្ន ថាតើចុងចោទស្ថិតក្នុងការដោះលែងសាកល្បង ការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ ឬទម្រង់ណាមួយនៃការដោះលែងមានការត្រួតពិនិត្យ ដែលរង់ចាំការជំនុំជម្រះ ការកាត់ទោស បណ្តឹងឧទ្ធរណ៍ ឬការបញ្ចប់ការកាត់ទោសសម្រាប់បទល្មើសក្រោមច្បាប់សហព័ន្ធ ឬច្បាប់របស់រដ្ឋនេះ ឬរដ្ឋណាមួយផ្សេងទៀត។

(5) លក្ខណៈ និងស្ថានទម្ងន់នៃហានិភ័យចំពោះសុវត្ថិភាពរបស់បុគ្គលណាម្នាក់ផ្សេងទៀត ឬសហគមន៍ ដែលបង្ករដោយការដោះលែងចុងចោទ ប្រសិនបើអាចអនុវត្តបាន។

(6) អនុសាសន៍នៃសេវាកម្មវាយតម្លៃមុនជំនុំជម្រះដែលបានទទួលដោយប្រើឧបករណ៍វាយតម្លៃហានិភ័យដែលមានសុពលភាព។

(7) ផលប៉ះពាល់នៃការឃុំខ្លួនទៅលើទំនួលខុសត្រូវ និងចំណងទំនាក់ទំនងរវាងគ្រួសារ និងសហគមន៍ការងារ និងការចូលរួមនៅក្នុងការអប់រំរបស់ចុងចោទ។

(8) សំណើផែនការនៃការត្រួតពិនិត្យណាមួយ។

(g) ប្រសិនបើចុងចោទណាម្នាក់ ត្រូវបានដោះលែងពីការថែរក្សា បន្ទាប់ពីសវនាការឃុំខ្លួនបង្ការ នៅក្នុងឯកសារ ដែលអនុញ្ញាតការដោះលែងចុងចោទតុលាការ ត្រូវជូនដំណឹងដល់ ចុងចោទដូចខាងក្រោម៖

(1) លក្ខខណ្ឌទាំងអស់ ប្រសិនបើមាន ដែលការដោះលែងស្ថិតក្រោមក្នុងលក្ខណៈមួយដែលមានភាពច្បាស់លាស់ និងជាក់លាក់គ្រប់គ្រាន់ ដើម្បីបម្រើជាមគ្គុទ្ទេសក៍សម្រាប់ការប្រព្រឹត្តរបស់ចុងចោទ។

(2) ទោសបញ្ញត្តិសម្រាប់ និងផលវិបាកផ្សេងៗនៃការរំលោភបំពានទៅលើលក្ខខណ្ឌនៃការដោះលែង ដែលអាចរាប់បញ្ចូលទាំងការចាប់ខ្លួនចុងចោទ ឬការចេញសាលក្រមភ្លាមៗសម្រាប់ការចាប់ខ្លួនចុងចោទ។

1320.21. (a) បន្ទាប់ពីការបង្ហាញភ័ស្តុតាង អង្គហេតុ ឬការផ្លាស់ប្តូរកាលៈទេសៈឯកសារដែលទើបរកឃើញថ្មីៗ អយ្យការ ឬស្មាគ្គីអាចដាក់ញត្តិ ដើម្បីបើកសវនាការឃុំខ្លួនបង្ការឡើងវិញ ឬសម្រាប់សវនាការថ្មីមួយនៅពេលណាមួយមុនការជំនុំជម្រះ។ នៅលើញត្តិរបស់ខ្លួន តុលាការអាចនឹងបើកសវនាការឃុំខ្លួនបង្ការឡើងវិញដោយផ្អែកលើភ័ស្តុតាង អង្គហេតុ ឬការផ្លាស់ប្តូរកាលៈទេសៈឯកសារដែលទើបរកឃើញថ្មីៗ ដែលនាំទៅកាន់ការយកចិត្តទុកដាក់របស់តុលាការដោយសេវាកម្មវាយតម្លៃបុរេជំនុំជម្រះ។

(b) ញត្តិណាមួយសម្រាប់សវនាការក្រោយសវនាការឃុំខ្លួនបង្ការ ត្រូវបញ្ជាក់ភ័ស្តុតាង ឬកាលៈទេសៈដែលមិនត្រូវបានដឹងនៅពេលនៃសវនាការឃុំខ្លួនបង្ការ ឬការផ្លាស់ប្តូរកាលៈទេសៈឯកសារដែលចេញ

សាលក្រមសវនាការឃុំខ្លួនបង្ការដែលបានបើកឡើងវិញ ឬថ្មី រួមទាំងថាតើមានលក្ខខណ្ឌនៃការដោះលែងដែលនឹងធានាសុវត្ថិភាពសាធារណៈយ៉ាងសមហេតុផលនិងការបង្ហាញខ្លួនរបស់ចុងចោទនៅតុលាការតាមការតម្រូវដែរឬទេ។

(c) ក្រោយពីមានសំណើរបស់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ ជនរងគ្រោះនោះត្រូវទទួលបានសេចក្តីជូនដំណឹងដោយអយ្យការអំពីសវនាការឃុំខ្លួនបង្ការដែលបានបើកឡើងវិញនោះ។ ប្រសិនបើបានស្នើសុំ ជនរងគ្រោះត្រូវទទួលបានឱកាសសមហេតុផលក្នុងការចូលរួមសវនាការដោយផ្អែកលើបញ្ហានៃស្ថានភាពថែរក្សារបស់ចុងចោទ។

(d) តុលាការអាចនឹងផ្តល់ញត្តិដើម្បីបើកសវនាការឃុំខ្លួនបង្ការឡើងវិញ ឬសម្រាប់សវនាការថ្មីមួយដែលផ្អែកលើហេតុផលល្អមួយដែលបានបង្ហាញ។

(e) ការសម្រេចរបស់តុលាការទាក់ទងនឹងស្ថានភាពថែរក្សាចុងចោទ ត្រូវធ្វើឡើងដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃជំពូកនេះ។

1320.22. តុលាការអាចចេញសាលក្រមសម្រាប់ការចាប់ខ្លួនចុងចោទបន្ទាប់ពីការអនុវត្តដែលបង្ហាញថា ចុងចោទបានរំលោភបំពានលក្ខខណ្ឌនៃការដោះលែងដែលបង្ខំដោយតុលាការ។ នៅពេលចាប់ខ្លួនចុងចោទស្ថានភាពថែរក្សារបស់ពួកគេត្រូវពិនិត្យឡើងវិញដោយអនុលោមតាមជំពូកនេះ។

1320.23. (a) ប្រសិនបើតុលាការចេញសាលក្រមចាប់ខ្លួន ឬដីកាឲ្យនាំខ្លួននៅពេលចុងចោទខកខានមិនបង្ហាញខ្លួននៅតុលាការតាមការតម្រូវ ឬនៅពេលដែលការចោទប្រកាន់ថាចុងចោទបានរំលោភបំពានលក្ខខណ្ឌនៃការត្រួតពិនិត្យមុនជំនុំជម្រះ ឬក្រោយការផ្តន្ទាទោស តុលាការអាចបញ្ជាក់នៅលើផ្នែកខាងមុខនៃសាលក្រមថាតើនៅពេលដែលចុងចោទត្រូវបានចាប់ខ្លួនតាមសាលក្រម ចុងចោទគួរត្រូវបានកក់ទុក និងដោះលែង ឃុំខ្លួនសម្រាប់ការពិនិត្យឡើងវិញលើកដំបូង ឃុំខ្លួនដោយមិនទាន់បាននាំខ្លួនមកឆ្លើយនៅមុខតុលាការ ឬឃុំខ្លួនដោយមិនទាន់បានចូលរួមសវនាការទៅលើការរំលោភបំពានលើការត្រួតពិនិត្យ។

(b) ប្រសិនបើអយ្យការ ទីភ្នាក់ងារអនុវត្តច្បាប់ ឬទីភ្នាក់ងារត្រួតពិនិត្យ ស្នើសុំសាលក្រមមួយដែលមានស្ថានភាពថែរក្សាសម្រាប់ចុងចោទក្រៅពីការកក់ទុក និងការដោះលែង ទីភ្នាក់ងារត្រូវផ្តល់ជូនតុលាការជាមួយនឹងកត្តាទាំងឡាយដែលធ្វើយុត្តិកម្មការត្រួតពិនិត្យ ឬការឃុំខ្លួន។

(c) ការបញ្ជាក់អំពីការដោះលែងឬការឃុំខ្លួនរបស់តុលាការនៅលើសាលដីកា ត្រូវចងភ្ជាប់កាតព្វកិច្ចអនុវត្តទៅលើទីភ្នាក់ងារចាប់ខ្លួន និងកក់ទុក និងមន្ទីរថែរក្សា ប៉ុន្តែមិនចងភ្ជាប់កាតព្វកិច្ចអនុវត្តទៅលើសេចក្តីសម្រេចបន្តបន្ទាប់ណាមួយដោយតុលាការ ឬសេវាកម្មវាយតម្លៃបុរេជំនុំជម្រះឡើយ។ ទោះជាយ៉ាងណា ការបញ្ជាក់នេះ កត្តាមួយដែលអាចត្រូវបានពិចារណាដោយសេវាកម្មវាយតម្លៃបុរេជំនុំជម្រះឬតុលាការនៅពេលកំណត់ស្ថានភាពឃុំខ្លួនរបស់ជននោះនៅក្នុងដំណើរការរឿងក្តីនៅតុលាការជាបន្តបន្ទាប់។

(d) ប្រសិនបើជននោះត្រូវបានចាប់ខ្លួនពីបទមជ្ឈឹម ការកំណត់ស្ថានភាពថែរក្សារបស់ជននោះត្រូវចាប់ផ្តើមជាមួយនឹងនីតិវិធីទាំងឡាយដែលមានចែងនៅក្នុងផ្នែកទី 1320.8។ ប្រសិនបើជននោះត្រូវបានចាប់ខ្លួនពីបទឧក្រិដ្ឋ ការកំណត់ស្ថានភាពថែរក្សារបស់ជននោះត្រូវចាប់ផ្តើមជាមួយនឹងនីតិវិធីទាំងឡាយដែលមានចែងនៅក្នុងផ្នែកទី 1320.9។

មាត្រា 8. ការទទួលខុសត្រូវរដ្ឋបាលរបស់ក្រុមប្រឹក្សាតុលាការ

1320.24. (a) ក្រុមប្រឹក្សាតុលាការ ត្រូវអនុម័តវិធានៃតុលាការរដ្ឋ California និងទម្រង់ប្រែបបទ ដើម្បីធ្វើដូចខាងក្រោម៖

(1) ចេញវេជ្ជបញ្ជាការប្រើប្រាស់ត្រឹមត្រូវនូវព័ត៌មានវាយតម្លៃហានិភ័យមុនជំនុំជម្រះ ដោយតុលាការនៅពេលធ្វើការសម្រេចចិត្តអំពីការដោះលែង និងឃុំខ្លួនមុនជំនុំជម្រះ ដែលពិចារណាទៅលើសុវត្ថិភាពរបស់សាធារណជន និងជនរងគ្រោះ សិទ្ធិទទួលបានដំណើរការត្រឹមត្រូវរបស់ចុងចោទ លក្ខណៈជាក់លាក់ ឬតម្រូវការរបស់ចុងចោទ និងលទ្ធភាពប្រើប្រាស់បាននូវធនធានក្នុងមូលដ្ឋាន ដើម្បីត្រួតពិនិត្យបុគ្គលប្រកបដោយប្រសិទ្ធភាពខណៈពេលបង្កើនប្រសិទ្ធភាពជាអតិបរិមា។

(2) បរិយាយអំពី សមាសភាព នៃ "ការធ្វើឲ្យមានសុពលភាព" ដោះស្រាយភាពចាំបាច់ និងភាពញឹកញាប់នៃការធ្វើឲ្យមានសុពលភាពនៃឧបករណ៍វាយតម្លៃហានិភ័យ ទៅលើប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងដោះស្រាយការកំណត់អត្តសញ្ញាណ និងកាត់បន្ថយភាព លម្អៀងទាំងស្រុងនៅក្នុង លិខិតូបករណ៍វាយតម្លៃ។

(3) ចេញវេជ្ជបញ្ជាស្តង់ដារសម្រាប់ការពិនិត្យឡើងវិញ ការដោះលែងនិងការឃុំខ្លួនដោយសេវាកម្មវាយតម្លៃបុរេជំនុំជម្រះ និងតុលាការ ដែលត្រូវរាប់បញ្ចូលនូវស្តង់ដារមួយដែលអនុញ្ញាតការឃុំឃ្លួនមុនពេលនាំខ្លួនមកឆ្លើយនៅមុខតុលាការ ប្រសិនបើមានលទ្ធភាពជាច្រើនដែលថាគ្មានលក្ខខណ្ឌ មិនមែនជាប្រាក់ ឬការរួមបញ្ចូលគ្នានូវលក្ខខណ្ឌនៃការត្រួតពិនិត្យមុនពេលជំនុំជម្រះ នឹងធានាសុវត្ថិភាពសាធារណៈយ៉ាងសមហេតុផល ឬការបង្ហាញខ្លួនរបស់ចុងចោទនៅតុលាការតាមការតម្រូវ។

(4) ចេញវេជ្ជបញ្ជាប៉ារ៉ាម៉ែត្រនៃវិធានតុលាការក្នុងមូលដ្ឋានដែលត្រូវបានអនុញ្ញាតនៅ ក្នុងផ្នែកទី 1320.11 ដោយពិចារណាអំពីសុវត្ថិភាពនៃសាធារណជន និងជនរងគ្រោះ សិទ្ធិទទួលបានដំណើរការត្រឹមត្រូវរបស់ចុងចោទ និងលទ្ធភាពប្រើប្រាស់បាននូវធនធានក្នុងមូលដ្ឋាន ដើម្បីត្រួតពិនិត្យបុគ្គលប្រកបដោយប្រសិទ្ធភាពខណៈពេលបង្កើនប្រសិទ្ធភាពជាអតិបរិមា។

(5) ចេញវេជ្ជបញ្ជាការដាក់បង្ខំលក្ខខណ្ឌនៃការដោះលែងមុនជំនុំជម្រះ រួមទាំងការកំណត់ទុកមុននូវកម្រិត ឬប្រភេទនៃហានិភ័យ។

(b) ក្រុមប្រឹក្សាតុលាការ ត្រូវកំណត់អត្តសញ្ញាណ និងកំណត់នូវទិន្នន័យដែលត្រូវការជាអប្បបរិមាដែលត្រូវរាយការណ៍ដោយតុលាការនីមួយៗ។ តុលាការត្រូវដាក់ជូនទិន្នន័យពីរដងក្នុងមួយឆ្នាំទៅកាន់ក្រុមប្រឹក្សាតុលាការ។ ទិន្នន័យនឹងរួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ចំពោះចំនួននៃការកើតឡើងដែលក្នុងនោះបុគ្គលទាំងនោះ៖

(1) ត្រូវបានវាយតម្លៃដោយប្រើប្រាស់ឧបករណ៍វាយតម្លៃហានិភ័យ និងកម្រិតនៃហានិភ័យរបស់បុគ្គលទាំងនោះ។

(2) ត្រូវបានដោះលែងដោយផ្អែកទៅលើការសន្យាគោរពតាមតុលាការផ្ទាល់ខ្លួន ឬការសន្យាគោរពតាមតុលាការផ្ទាល់ខ្លួនដែលត្រូវបានត្រួតពិនិត្យដោយអនុលោមតាម៖

(A) ផ្នែករង (b) នៃផ្នែកទី 1320.10។

(B) ផ្នែករង (c) នៃផ្នែកទី 1320.10។

(C) ផ្នែកទី 1320.12 បែងចែកតាមកម្រិតនៃហានិភ័យ។

(D) ផ្នែកទី 1320.13 បែងចែកតាមកម្រិតនៃហានិភ័យ។

(3) ឃុំឃាំងនៅឯ៖

(A) នាំខ្លួនមកឆ្លើយនៅមុខតុលាការ បែងចែកតាមកម្រិតនៃហានិភ័យ។

(B) សវនាការឃុំខ្លួនមុនជំនុំជម្រះ បែងចែកតាមកម្រិត នៃហានិភ័យ។

(4) ការសន្យាគោរពតាមតុលាការផ្ទាល់ខ្លួនមុនជំនុំជម្រះនៅពេលដោះលែង ឬការដោះលែងតាមការសន្យាគោរពតាមតុលាការផ្ទាល់ខ្លួនមុននៅពេលត្រួតពិនិត្យ ដែល៖

25

(A) ខកខានមិនបង្ហាញខ្លួនតាមការតម្រូវឲ្យមក បង្ហាញខ្លួននៅ តុលាការ។

(B) មានការចោទប្រកាន់សម្រាប់បទល្មើសព្រហ្មទណ្ឌថ្មីមួយ។

(5) ត្រូវបានពិចារណាឲ្យដោះលែង ឬឃុំខ្លួននៅឯសវនាការឃុំខ្លួនបង្ការ។

(c) ដោយអនុលោមតាមកិច្ចសន្យាក្រោមផ្នែករង (a) នៃផ្នែកទី 1320.26 តុលាការអាចតម្រូវឲ្យអង្គភាពដែលផ្តល់សេវាកម្មវាយតម្លៃបុរេជំនុំជម្រះរាយការណ៍អំពីទិន្នន័យនៅក្នុងផ្នែកនេះជូនក្រុមប្រឹក្សាតុលាការនៅពេលវេលាសមរម្យ។

(d) មួយឆ្នាំម្តង តុលាការនីមួយៗត្រូវផ្តល់ព័ត៌មានជូនក្រុមប្រឹក្សាតុលាការដូចខាងក្រោម៖

(1) ថាតើតុលាការធ្វើការពិនិត្យឡើងវិញមុនពេលនាំខ្លួនមកឆ្លើយនៅមុខតុលាការ ដោយអនុលោមតាមផ្នែកទី 1320.13 ដែរឬទេ។

(2) តម្រូវការពេលពេលវេលាដែលបានប៉ាន់ស្មានសម្រាប់ធ្វើសេចក្តីសម្រេចចិត្តលើការដោះលែង និងឃុំខ្លួននៅឯសវនាការនាំខ្លួនមកឆ្លើយនៅមុខតុលាការ និងសវនាការឃុំខ្លួនបង្ការ។

(3) ឧបករណ៍វាយតម្លៃហានិភ័យដែលបានធ្វើសុពលកម្ម ដែលត្រូវបានប្រើប្រាស់ដោយសេវាកម្មវាយតម្លៃបុរេជំនុំជម្រះ។

(e) ក្រុមប្រឹក្សាតុលាការត្រូវធ្វើដូចខាងក្រោម៖

(1) ចងក្រង និងរក្សាទុកនូវបញ្ជីនៃឧបករណ៍វាយតម្លៃ ហានិភ័យមុនជំនុំជម្រះដែលមានសុពលភាព រួមទាំងឧបករណ៍ទាំងឡាយដែលសមស្របសម្រាប់វាយតម្លៃសម្រាប់អំពើហិង្សាក្នុងគ្រួសារ បទល្មើសផ្លូវភេទ និងបទល្មើសហិង្សាផ្សេងៗ។ ក្រុមប្រឹក្សាតុលាការត្រូវប្រឹក្សាជាមួយសេវាកម្មវាយតម្លៃបុរេជំនុំជម្រះ និងភាគីពាក់ព័ន្ធផ្សេងទៀតនៅក្នុងការចងក្រងបញ្ជីឧបករណ៍វាយតម្លៃ។

(2) ប្រមូលទិន្នន័យដូចមានបរិយាយនៅក្នុងនៅក្នុងផ្នែករង (b)។

(3) បណ្តុះបណ្តាលចៅក្រមអំពីការប្រើប្រាស់ព័ត៌មានសេវាកម្មវាយតម្លៃបុរេជំនុំជម្រះ នៅពេលធ្វើសេចក្តីសម្រេចទៅលើការដោះលែង និងការឃុំខ្លួនមុនជំនុំជម្រះ និងងំពីការដាក់បង្ខំលក្ខខណ្ឌនៃការដោះលែងមុនជំនុំជម្រះ។

(4) នៅក្នុងការប្រឹក្សាជាមួយ ប្រធានមន្ត្រីគ្រប់គ្រងការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌនៃរដ្ឋ California ជួយសម្រួលដល់តុលាការនៅក្នុងការបង្កើតកិច្ចសន្យាជាមួយអង្គភាពសាធារណៈក្នុងមូលដ្ឋាន ទាក់ទងនឹងបទបញ្ញត្តិនៃ សេវាកម្មវាយតម្លៃបុរេជំនុំជម្រះ។

(5) នៅថ្ងៃទី ឬមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2021 និងរាល់ឆ្នាំបន្តបន្ទាប់មកទៀត ត្រូវដាក់ជូននូវរបាយការណ៍មួយជូនអភិបាល និងសកម្មភាពអនុវត្តកម្មវិធីចងក្រងឯកសាររបស់រដ្ឋសភា និងផ្តល់ទិន្នន័យទៅលើលទ្ធផល និងលទ្ធផលរបស់កម្មវិធី។ របាយការណ៍ដំបូងត្រូវផ្តោតជាសំខាន់ទៅលើការអនុវត្តកម្មវិធី ហើយរបាយការណ៍បន្តបន្ទាប់ត្រូវមានទិន្នន័យដែលមានបរិយាយនៅក្នុងផ្នែករង (b)។ របាយការណ៍ដែលត្រូវដាក់ជូនដោយអនុលោមតាមកថាខណ្ឌនេះ ត្រូវដាក់ជូនដោយអនុលោមតាមផ្នែកទី 9795 នៃក្រមរដ្ឋាភិបាល។

(6) ក្នុងកិច្ចសហការជាមួយតុលាការកំពូល ត្រូវបង្កើតនូវការប៉ាន់ស្មានពេលវេលាដែលត្រូវការនៅពេលនាំខ្លួនមកឆ្លើយនៅមុខតុលាការ ដើម្បីធ្វើការកំណត់អំពីការដោះលែង ឬការឃុំខ្លួន នៅពេលដែលការកំណត់នោះត្រូវបានធ្វើឡើងជាលើកដំបូងនៅពេលនាំខ្លួនមកឆ្លើយនៅតុលាការ និងពេលវេលាដែលបានប៉ាន់ស្មានដែលត្រូវការសម្រាប់សវនាការឃុំខ្លួនបង្ការ។

(7) កោះប្រជុំគណៈអ្នកឯកទេសលើកម្មវត្ថុ និងមន្ត្រីតុលាការ ដើម្បីអនុវត្តការទទួលខុសត្រូវទាំងឡាយដែលមានបរិយាយនៅក្នុងផ្នែករង (a) នៃផ្នែកទី 1320.25 និងធ្វើឲ្យព័ត៌មាននោះមាន សម្រាប់ តុលាការ។

1320.25. (a) គណៈអ្នកឯកទេស និងមន្ត្រីតុលាការដូចមានចែងនៅក្នុងកថាខណ្ឌទី (7) នៃ ផ្នែករង (e) នៃផ្នែកទី 1320.24 ត្រូវកំណត់ទុកមុននូវកម្រិតហានិភ័យ designate "ទាប" "មធ្យម" និង "ខ្ពស់" ដោយផ្អែកលើពិន្ទុ ឬកម្រិតដែលផ្តល់ជូនដោយលិខិតុបករណ៍សម្រាប់ការប្រើប្រាស់ដោយសេវាកម្មវាយតម្លៃបុរេជំនុំជម្រះ នៅក្នុងការអនុវត្តការទទួលខុសត្រូវរបស់ពួកគេដោយអនុលោមតាមផ្នែកទី 1320.9។

(b) ប្រធានផ្នែកយុត្តិធម៌ ត្រូវចាត់តាំងបុគ្គលបួនរូបដែលមានជំនាញឯកទេសកម្មវត្ថុជាក់លាក់លើការដាក់ពិន្ទុលិខិតុបករណ៍វាយតម្លៃហានិភ័យមុនជំនុំជម្រះ និងមន្ត្រីតុលាការបីរូបដែលមានជំនាញឯកទេសផ្នែកច្បាប់ព្រហ្មទណ្ឌ ដែលក្នុងនោះមួយរូបត្រូវធ្វើជាប្រធាន ដើម្បីបម្រើការនៅលើគណៈនេះ។ យ៉ាងហោចណាស់មន្ត្រីមួយរូបក្នុងចំណោមអ្នកឯកទេស ត្រូវតែមានជំនាញឯកទេសផ្នែកហេតុប៉ះពាល់សក្តានុពលទៅលើភាពលំអៀងនៅក្នុងលិខិតុបករណ៍វាយតម្លៃហានិភ័យ បន្ថែមពីលើការដាក់ពិន្ទុការវាយតម្លៃហានិភ័យ។

1320.26. (a) តុលាការត្រូវបង្កើតសេវាកម្មវាយតម្លៃបុរេជំនុំជម្រះ។ សេវាទាំងនេះអាចត្រូវបានធ្វើឡើងដោយបុគ្គលិកតុលាការ ឬតុលាការអាចចុះកិច្ចសន្យាសម្រាប់សេវាទាំងនោះជាមួយទីភ្នាក់ងារសាធារណៈក្នុងមូលដ្ឋានដែលមានបទពិសោធន៍ពាក់ព័ន្ធ។

(b) មុនពេលតុលាការសម្រេចចិត្តមិនចុះកិច្ចសន្យាជាមួយទីភ្នាក់ងារសាធារណៈក្នុងមូលដ្ឋានដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ណាម្នាក់ តុលាការនោះត្រូវស្វែងរកឲ្យឃើញថាទីភ្នាក់ងារនោះនឹងមិនយល់ព្រមអនុវត្តមុខងារនេះជាមួយនឹងធនធានទាំងឡាយដែលមាន ឬពុំមានសមត្ថភាពក្នុងការអនុវត្តមុខងារនោះ។

(c) ប្រសិនបើគ្មានទីភ្នាក់ងារក្នុងមូលដ្ឋានដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ណាម្នាក់នឹងអនុវត្តមុខងារវាយតម្លៃមុនជំនុំជម្រះនេះសម្រាប់តុលាការកំពូលណាមួយ ហើយតុលាការនោះជ្រើសរើសមិនអនុវត្តមុខងារនេះនោះ តុលាការនោះអាចចុះកិច្ចសន្យាជាមួយទីភ្នាក់ងារសេវាកម្មវាយតម្លៃបុរេជំនុំជម្រះក្នុងស្រុកថ្មីមួយ ដែលបានបង្កើតឡើងដើម្បីអនុវត្តតួនាទីនេះជាពិសេស។

(d) សម្រាប់គោលបំណងនៃការផ្តល់សេវាកម្មវាយតម្លៃបុរេជំនុំជម្រះ តុលាការអាចនឹងមិនចុះកិច្ចសន្យាជាមួយទីភ្នាក់ងារសាធារណៈក្នុងមូលដ្ឋានដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានការទទួលខុសត្រូវចម្បងចំពោះការចាប់ខ្លួន និងការឃុំខ្លួនជាមួយនឹងអំណាចច្បាប់។

(e) សេវាកម្មវាយតម្លៃបុរេជំនុំជម្រះ ត្រូវធ្វើឡើង ដោយនិយោជិកសាធារណៈ។

(f) ថ្វីបើមានផ្នែករង (h) ក៏ដោយ តុលាការកំពូលនៃខោនធី Santa Clara អាចនឹងចុះកិច្ចសន្យាជាមួយការិយាល័យសេវាមុនជំនុំជម្រះនៃខោនធី Santa Clara ដើម្បីផ្តល់ជូនសេវាកម្មវាយតម្លៃបុរេជំនុំជម្រះ នៅក្នុងខោនធី Santa Clara ហើយការិយាល័យនោះត្រូវមានសិទ្ធិទទួលបានប្រាក់រំភាជន៍មូលនិធិដោយអនុលោមតាមផ្នែករង (c) នៃផ្នែកទី 1320.27 និងផ្នែកទី 1320.28។

(g) នៅថ្ងៃទី ឬមុនថ្ងៃទី 1 ខែកុម្ភៈ ឆ្នាំ 2019 ប្រធានចៅក្រមនៃតុលាការកំពូល និងប្រធានមន្ត្រីគ្រប់គ្រងការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌនៃខោនធីនីមួយៗ ឬនាយកនៃការិយាល័យសេវាមុនជំនុំជម្រះរបស់ខោនធី Santa Clara សម្រាប់ខោនធីនោះ ត្រូវដាក់ជូនក្រុមប្រឹក្សាតុលាការនូវលិខិតមួយច្បាប់ដែលបញ្ជាក់អះអាងអំពីចេតនារបស់ខ្លួនក្នុងការចុះកិច្ចសន្យាសម្រាប់ សេវាកម្មវាយតម្លៃបុរេជំនុំជម្រះ ដោយអនុលោមតាមផ្នែកនេះ។

(h) សម្រាប់ គោលបំណង នៃផ្នែកនេះ៖

(1) "សេវាកម្មវាយតម្លៃបុរេជំនុំជម្រះ" មិនរាប់បញ្ចូលនូវការត្រួតពិនិត្យជនល្មើសដែលត្រូវបាន ដោះលែងក្រោមជំពូកនេះឡើយ។

(2) A "ទីភ្នាក់ងារសាធារណៈ:ក្នុងមូលដ្ឋានដែលមានលក្ខណៈ:សម្បត្តិគ្រប់គ្រាន់" គឺជាទីភ្នាក់ងារដែលមានបទពិសោធន៍ទាំងអស់ដូចខាងក្រោម៖

(A) ជំនាញឯកទេសពាក់ព័ន្ធ នៅក្នុងការធ្វើការកំណត់ដោយផ្អែកលើហានិភ័យ។

(B) ការផ្តល់អនុសាសន៍ជូនតុលាការដោយ អនុលោម តាមផ្នែកទី 1203។

(C) ការត្រួតពិនិត្យជនល្មើសនៅក្នុងសហគមន៍។

(D) ការជួលមន្ត្រីសន្តិភាព។

1320.27. (a) នៅថ្ងៃទី ឬមុនថ្ងៃទី 10 ខែមករា ជារៀងរាល់ឆ្នាំ ក្រសួងហិរញ្ញវត្ថុ ក្នុងកិច្ចពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាតុលាការ និងប្រធានមន្ត្រីគ្រប់គ្រងការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌនៃរដ្ឋ California ត្រូវប៉ាន់ស្មានកម្រិតនៃការផ្តល់មូលនិធិដែលត្រូវការសម្រាប់គាំទ្រឲ្យបានគ្រប់គ្រាន់ទៅលើ សេវាវាយតម្លៃមុនជំនុំជម្រះ ដែលបានផ្តល់ជូនដោយអនុលោមតាម ជំពូកនេះ។ ការប៉ាន់ស្មានធ្វើផ្អែកទៅលើវិធីសាស្ត្រដែលបានបង្កើតឡើងដោយក្រសួងហិរញ្ញវត្ថុ ក្នុងកិច្ចពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាតុលាការនៃរដ្ឋ California ដែលនឹងដាក់បញ្ចូលចំនួនប៉ាន់ស្មាននៃចុងចោទដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ដែលទទួលការវាយតម្លៃហានិភ័យ បន្ទុកចំណាយដោយផ្ទាល់ និងដោយប្រយោលដែលពាក់ព័ន្ធ នឹងការធ្វើការវាយតម្លៃហានិភ័យ និងបន្ទុកចំណាយទាំងអស់ដែលពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចចិត្តដោះលែង និងឃុំខ្លួនដោយតុលាការ និងសេវាមុន ជំនុំជម្រះ។ ការប៉ាន់ស្មាននេះ ក៏ត្រូវឆ្លុះបញ្ចាំងផងដែរនូវបន្ទុកចំណាយដោយផ្ទាល់ និងដោយប្រយោលរបស់បុគ្គលិក ដែលចាំបាច់ដើម្បីធ្វើមុខងារនេះ។ ក្រសួងត្រូវបោះពុម្ពផ្សព្វផ្សាយការប៉ាន់ស្មានរបស់ខ្លួន ហើយបញ្ជូនវាទៅកាន់រដ្ឋសភា នៅពេលដាក់ជូនថវិការបស់អភិបាលដោយ អនុលោមតាមផ្នែកទី 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញរដ្ឋ California។

(b) នៅពេលដកទុកដោយអង្គនីតិបញ្ញត្តិ ក្រុមប្រឹក្សាតុលាការត្រូវលៃទុកមូលនិធិដល់តុលាការក្នុងមូលដ្ឋានសម្រាប់សេវាកម្មវាយតម្លៃបុរេជំនុំជម្រះ។ មូលនិធិត្រូវលៃទុកក្រោយកិច្ចពិគ្រោះយោបល់ ជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមមានជាអាទិ៍ ប្រធានប្រតិបត្តិតុលាការ តំណាងនិយោជិក និងប្រធានមន្ត្រីគ្រប់គ្រងការដោះលែងឲ្យ នៅក្រៅឃុំដោយមានលក្ខខណ្ឌ ឧនៃរដ្ឋ California។ ដូចដែលបានកំណត់ដោយក្រុមប្រឹក្សាតុលាការ ប្រាក់វិភាជន៍ត្រូវរាប់បញ្ចូលទាំងចំនួនទឹកប្រាក់មូលដ្ឋានសម្រាប់ គាំទ្រសេវាកម្មវាយតម្លៃបុរេ ជំនុំជម្រះទូទាំងរដ្ឋ និងការផ្តល់មូលនិធិបន្ថែមដោយ ផ្អែកលើលក្ខណៈ:វិនិច្ឆ័យសមរម្ម។ ក្រុមប្រឹក្សាតុលាការត្រូវពិចារណាអំពីបម្រែបម្រួលបន្ទុកចំណាយក្នុងតំបន់ មាត្រដ្ឋានទូទាត់ និងកត្តាផ្សេងទៀតនៅពេលធ្វើការសម្រេចចិត្តលើប្រាក់លៃទុកវិភាជន៍។ ការធ្វើវិភាជន៍ទូទាំងរដ្ឋនូវមូលនិធិប្រចាំឆ្នាំសម្រាប់សេវាមុនជំនុំជម្រះ ត្រូវអនុម័តដោយក្រុមប្រឹក្សាតុលាការនៅអង្គប្រជុំសាធារណៈ ហើយត្រូវបោះពុម្ពផ្សាយជាសាធាណៈ។

(c) មូលនិធិទាំងអស់សម្រាប់សេវាកម្ម វាយតម្លៃបុរេជំនុំជម្រះ ត្រូវចំណាយលើបន្ទុកចំណាយដោយផ្ទាល់ និងដោយប្រយោលទាំងស្រុងទាក់ទង នឹងការផ្តល់សេវាទាំងនោះ។ តុលាការក្នុងមូលដ្ឋានដែលចុះកិច្ចសន្យាសម្រាប់សេវាកម្មវាយតម្លៃបុរេជំនុំជម្រះ ដោយអនុលោមតាមផ្នែកទី 1320.26 ត្រូវផ្តល់មូលនិធិទាំងអស់ដែលបានទទួលតាមរយៈ ប្រាក់វិភាជន៍នេះ ដោយផ្ទាល់ទៅកាន់អង្គភាពសាធារណៈ:ជាប់កិច្ចសន្យា។

(d) អង្គភាពសាធារណៈ:ក្នុងមូលដ្ឋានដែលទទួលប្រាក់វិភាជន៍ដោយអនុលោមតាមផ្នែកនេះ ត្រូវមានចំនួនទឹកប្រាក់ដោយឡែកស្មើនឹងមូលនិធិទាំងនេះ និងបញ្ជាក់ប្រចាំឆ្នាំថា មូលនិធិដែលបានចំណាយដោយ អនុលោមតាមច្បាប់រដ្ឋ ពាក់ព័ន្ធ រួមទាំងលក្ខខណ្ឌតម្រូវនៃផ្នែកនេះ។

(e) មូលនិធិដែលបានលៃទុកដោយអនុលោមតាមផ្នែកនេះ ត្រូវបំពេញបន្ថែម ហើយមិនត្រូវជំនួសឲ្យមូលនិធិមូលដ្ឋានបច្ចុប្បន្ន ដើម្បីគាំទ្រដល់សេវាកម្មវាយតម្លៃបុរេជំនុំជម្រះឡើយ។

1320.28. (a) ត្រឹមថ្ងៃទី 10 ខែមករា ជារៀងរាល់ឆ្នាំ ក្រសួងហិរញ្ញវត្ថុ ក្នុងកិច្ចពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាតុលាការ និងប្រធានមន្ត្រីគ្រប់គ្រងការដោះលែងឲ្យនៅក្រៅឃុំ ដោយមានលក្ខខណ្ឌនៃរដ្ឋ California ត្រូវប៉ាន់ស្មាន កម្រិត នៃធនធានដែលត្រូវការដើម្បីគាំទ្រឲ្យបានគ្រប់គ្រាន់ទៅលើការផ្តល់សេវាត្រួតពិនិត្យមុនជំនុំជម្រះ ដែលផ្តល់ជូន ដោយ អនុលោមតាមជំពូកនេះ។ ការប៉ាន់ស្មាននេះ ត្រូវឆ្លុះបញ្ចាំងចំនួននៃបុគ្គលទាំងឡាយដែលកំពុងត្រូវបានត្រួតពិនិត្យ និងកម្រិតនៃការត្រួតពិនិត្យដែលត្រូវការ។ ការប៉ាន់ស្មានក៏ត្រូវឆ្លុះបញ្ចាំងនូវបន្ទុកចំណាយដោយផ្ទាល់ និងដោយប្រយោលនៃបុគ្គលិកដែលចាំបាច់សម្រាប់ផ្តល់ជូនសេវាទាំងនេះផងដែរ។ ក្រសួងត្រូវបោះពុម្ពផ្សព្វផ្សាយការប៉ាន់ស្មានរបស់ខ្លួន ហើយបញ្ជូនវាទៅកាន់រដ្ឋសភា នៅពេលដាក់ជូនថវិការបស់អភិបាលដោយអនុលោមតាមផ្នែកទី 12 នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញរដ្ឋ California។

(b) នៅពេលដកទុកដោយរដ្ឋសភា ក្រសួងហិរញ្ញវត្ថុ ត្រូវធ្វើវិភាជន៍មូលនិធិដល់ក្រសួងគ្រប់គ្រងការដោះលែងឲ្យនៅក្រៅឃុំដោយ មានលក្ខខណ្ឌក្នុងមូលដ្ឋាន សម្រាប់សេវាវាយតម្លៃមុនជំនុំជម្រះ។ សម្រាប់គោលបំណងនៃផ្នែករងនេះ ការិយាល័យសេវាមុនជំនុំជម្រះរបស់ ខោនធី Santa Clara ត្រូវមានសិទ្ធិទទួលបានមូលនិធិនៅក្នុងខោនធីនោះ។ នៅក្នុងការលៃវិភាជន៍មូលនិធិ ក្រសួងត្រូវពិចារណាអំពីបម្រែបម្រួលបន្ទុកចំណាយក្នុងតំបន់ មាត្រដ្ឋានទូទាត់ និងកត្តាផ្សេងទៀតនៅពេលធ្វើការសម្រេចចិត្តលើប្រាក់វិភាជន៍។ ការធ្វើវិភាជន៍ត្រូវរាប់បញ្ចូលនូវចំណែកមូលដ្ឋានសម្រាប់គាំទ្រដល់ការត្រួតពិនិត្យមុនជំនុំជម្រះទូទាំងរដ្ឋ និងចំនួនទឹកប្រាក់បន្ថែម យ៉ាងហោចណាស់ដោយផ្អែកទៅលើមនុស្សពេញវ័យអាយុចន្លោះ 18 ឆ្នាំ និង 50 ឆ្នាំរបស់ខោនធីនិងអត្រាចាប់ខ្លួនក្នុងមូលដ្ឋាន ។ ក្រសួងហិរញ្ញវត្ថុ ត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាតុលាការ ប្រធានមន្ត្រីគ្រប់គ្រងការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌនៃរដ្ឋ California និងភាគីពាក់ព័ន្ធសំខាន់ៗ រួមមានជាអាទិ៍ តំណាងនិយោជិក នៅពេលអនុម័តវិធីសាស្ត្រធ្វើវិភាជន៍ប្រចាំឆ្នាំ។

(c) មូលនិធិទាំងអស់សម្រាប់សេវាវាយតម្លៃមុនជំនុំជម្រះ ត្រូវចំណាយលើបន្ទុកចំណាយដោយផ្ទាល់ និងដោយប្រយោលទាំងស្រុងទាក់ទងនឹងការផ្តល់សេវាទាំងនោះ។ មូលនិធិទាំងអស់ ដែលត្រូវបានលៃទុកដើម្បីគាំទ្រសេវាមុនជំនុំជម្រះ ត្រូវលៃទុកដល់អង្គភាពក្នុងមូលដ្ឋាន ដើម្បីគាំទ្រដល់ការ ត្រួតពិនិត្យមុនជំនុំជម្រះ។

(d) អង្គភាពសាធារណៈ:ក្នុងមូលដ្ឋានដែលទទួលប្រាក់លៃបម្រុងដោយអនុលោមតាមផ្នែកនេះ ត្រូវមានទំនួលខុសត្រូវដាច់ដោយឡែកសម្រាប់មូលនិធិទាំងនេះ និងបញ្ជាក់ជារៀងរាល់ឆ្នាំថា មូលនិធិត្រូវបានចំណាយ ដោយអនុលោមតាមច្បាប់រដ្ឋដែលពាក់ព័ន្ធ ដែលរួមមានលក្ខខណ្ឌតម្រូវនៃផ្នែកនេះ។

(e) អង្គភាពសាធារណៈ:ក្នុងមូលដ្ឋាន ត្រូវមានសិទ្ធិទទួលបានមូលនិធិនេះតែនៅពេលដែលពួកគេចុះកិច្ចសន្យាជាមួយតុលាការសម្រាប់ការផ្តល់សេវាកម្មវាយតម្លៃមុនជំនុំជម្រះប៉ុណ្ណោះ។

(f) មូលនិធិដែលបានលៃទុកដោយអនុលោមតាមផ្នែកនេះត្រូវបំពេញបន្ថែម និងមិនត្រូវជំនួសឲ្យមូលនិធិមូលដ្ឋានបច្ចុប្បន្នដើម្បីគាំទ្រដល់សេវាកម្មវាយតម្លៃមុនជំនុំជម្រះឡើយ។

1320.29. ត្រឹមថ្ងៃទី 10 ខែមករាជារៀងរាល់ឆ្នាំ ក្រសួងហិរញ្ញវត្ថុ ក្នុងកិច្ចពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាតុលាការ ត្រូវប៉ាន់ស្មានកម្រិតនៃធនធានដែលត្រូវការដើម្បីគាំទ្រឲ្យបានគ្រប់គ្រាន់ទៅលើបន្ទុកការងាររបស់តុលាការក្រោមជំពូកនេះ។ ការប៉ាន់ស្មានត្រូវឆ្លុះបញ្ចាំងនូវចំនួនសំណុំរឿងដែលតុលាការកំពុងធ្វើការកំណត់លើការឃុំខ្លួននៅពេលនាំមកឆ្លើយនៅមុខតុលាការ ទំហំនៃសវនាការឃុំខ្លួនបង្ការ រយៈពេលជាមធ្យមដែលត្រូវការដើម្បីធ្វើសេចក្តីសម្រេចទាំងនេះ និងដើម្បីធ្វើសវនាការ បន្ទុកចំណាយដែលពាក់ព័ន្ធនឹងកិច្ចសន្យាសម្រាប់សេវាកម្មវាយតម្លៃមុនជំនុំជម្រះ និងកត្តាផ្សេងៗដែលទាក់ទងនឹងបន្ទុកការងាររបស់តុលាការដោយអនុលោមតាមច្បាប់នេះ។ ការប៉ាន់ស្មាននេះក៏ត្រូវឆ្លុះបញ្ចាំងបន្ទុកចំណាយដោយផ្ទាល់ និងដោយប្រយោល គិតជាមធ្យមក្នុងមួយនាទីទៅលើដំណើរការរឿងក្តីតុលាការជំនុំជម្រះផងដែរ។ ក្រសួងត្រូវបោះពុម្ពផ្សព្វផ្សាយការប៉ាន់ស្មានរបស់ខ្លួន ហើយបញ្ជូនវាទៅកាន់អង្គនីតិបញ្ញត្តិ នៅពេលដាក់ជូនថវិការបស់អភិបាលដោយអនុលោមតាមផ្នែកទី 12 នៃមាត្រា IV នៃធម្មនុញ្ញរដ្ឋ California។

1320.30. (a) នៅពេលធ្វើការលៃបម្រុងដោយអង្គនីតិបញ្ញត្តិ គណៈកម្មការរដ្ឋនិងការកែប្រែសហគមន៍ត្រូវចុះកិច្ចសន្យាជាមួយស្ថាប័នសិក្សា មជ្ឈមណ្ឌលគោលនយោបាយសាធារណៈ ឬអង្គភាពស្រាវជ្រាវផ្សេងៗសម្រាប់ការវាយតម្លៃដោយឯករាជ្យអំពីច្បាប់ដែលបានអនុម័ត ដោយផ្នែកនេះ ជាពិសេសអំពីផលប៉ះពាល់នៃច្បាប់តាមជាតិសាសន៍ ជាតិពន្ធ ភេទ និងកម្រិតប្រាក់ចំណូល។ ការវាយតម្លៃនេះត្រូវដាក់ជូនព្រឹទ្ធសភារដ្ឋលេខាធិការ និងប្រធានក្រឡាបញ្ជីនៃរដ្ឋសភាឲ្យបានមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2024។

(b) ចាប់ពីឆ្នាំសារពើពន្ធ 2019–20 មូលនិធិរដ្ឋត្រូវផ្គត់ផ្គង់ មិនមែនជំនួសមូលនិធិក្នុងមូលដ្ឋានដែលបានលៃទុកទៅកាន់សេវាត្រួតពិនិត្យវាយតម្លៃមុនជំនុំជម្រះ ឬគោលបំណងផ្សេងៗដែលទាក់ទង នឹងសកម្មភាពមុនជំនុំជម្រះ ដែលលើកលែងការឃុំខ្លួន។

1320.31. (a) វាគឺជាចេតនារបស់រដ្ឋសភាដែលថា ដល់កម្រិតមួយដែលអាចអនុវត្តបាន អាទិភាពសម្រាប់សមត្ថភាពពន្ធនាគារដែលមានលទ្ធភាពប្រើប្រាស់បាន ត្រូវតែសម្រាប់ជនល្មើសក្រោយការផ្តន្ទាទោស។

(b) អង្គនីតិបញ្ញត្តិរកឃើញ និងប្រកាសថាការអនុវត្តជំពូកនេះ នឹងត្រូវការមូលនិធិដែលចាំបាច់ដើម្បីគាំទ្រដល់សេវាវាយតម្លៃហានិភ័យមុនជំនុំជម្រះ ការត្រួតពិនិត្យមុនជំនុំជម្រះ កំណើនបន្ទុកការងាររបស់តុលាការជំនុំជម្រះ និងសកម្មភាពចាំបាច់ទូទាំងរដ្ឋដើម្បីគាំទ្រដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។ មូលនិធិទាំងនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការចំណាយរយៈពេលវែងថ្មីបំផុតរបស់រដ្ឋ ហើយនឹងត្រូវស្ថិតក្រោមការលៃបម្រុងនៅក្នុងច្បាប់ថវិកាប្រចាំឆ្នាំ។

1320.32. ដោយចាប់ផ្តើមនៅថ្ងៃទី 1 ខែតុលា ឆ្នាំ 2019 រាល់ឯកសារយោងទាំងអស់នៅក្នុងក្រមនេះទៅលើពាក្យថា "ប្រាក់ធានា" ត្រូវសំដៅទៅលើនីតិវិធីទាំងឡាយដែលមានបញ្ជាក់នៅក្នុងជំពូកនេះ។

1320.33. (a) ចុងចោទដែលត្រូវបានដោយលែងដោយមានប្រាក់ធានាមុនថ្ងៃទី 1 ខែតុលា ឆ្នាំ 2019 ត្រូវនៅតែស្ថិតក្នុងការធានាដោយអនុលោមតាមលក្ខខណ្ឌទាំងឡាយនៃ ការដោះលែងរបស់ពួកគេ។

(b) ចុងចោទស្ថិតក្នុងការឃុំឃាំងនៅថ្ងៃទី 1 ខែតុលា ឆ្នាំ 2019 ត្រូវបានពិចារណាសម្រាប់ការដោះលែងដោយអនុលោមតាមផ្នែកទី 1320.8 និងប្រសិនបើមិនត្រូវបានដោះលែងទេ ត្រូវទទួលបានការវាយតម្លៃហានិភ័យ និងត្រូវបានពិចារណាសម្រាប់ការដោះលែង និងឃុំខ្លួនដោយអនុលោមតាមជំពូកនេះ។

1320.34. ជំពូកនេះត្រូវចាប់ផ្តើមអនុវត្តនៅថ្ងៃទី 1 ខែតុលា ឆ្នាំ 2019។

ផ្នែកទី 5. ដល់កម្រិតមួយដែលអាចអនុវត្តបាន ក្រុមប្រឹក្សាតុលាការ ត្រូវសម្របសម្រួលជាមួយ ប្រធានមន្ត្រីគ្រប់គ្រងការដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌនៃរដ្ឋ California ដើម្បីផ្តល់កិច្ចប្រឹងប្រែងបណ្តុះបណ្តាល ធ្វើការបណ្តុះបណ្តាលរួម និងបើមិនដូច្នោះទេ សហការជាមុខងារចាប់ផ្តើមថ្មីដែលចាំបាច់ដើម្បីអនុវត្តច្បាប់នេះ។

ផ្នែកទី 6. ប្រសិនបើគណៈកម្មការទទួលបន្ទុកអណត្តិរដ្ឋកំណត់ថាច្បាប់នេះមានបន្ទុកចំណាយដែលកំណត់អាណត្តិដោយរដ្ឋ ការផ្តល់សំណងដល់ទីភ្នាក់ងារក្នុងមូលដ្ឋាន និងមណ្ឌលសាលារៀនសម្រាប់បន្ទុកចំណាយទាំងនោះ ត្រូវធ្វើឡើងដោយអនុលោមតាមភាគទី 7 (ដែលចាប់ផ្តើមជាមួយផ្នែកទី 17500) នៃផ្នែកទី 4 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល។

ដូចដែលបានតម្រូវដោយច្បាប់ អត្ថបទសំណើប្រជាមតិ 14 ដែលជាវិធានការប័ណ្ណកម្ម ត្រូវបានរួមបញ្ចូលនៅក្នុងមគ្គុទេសក៍ព័ត៌មានអ្នកបោះឆ្នោតផ្លូវការដែលត្រូវបានផ្ញើរទៅតាមគេហដ្ឋានអ្នកបោះឆ្នោតទាំងអស់។ អត្ថបទសំណើច្បាប់សម្រាប់សំណើប្រជាមតិ 14 ក៏អាចរកបានតាមអនឡាញផងដែរនៅ *voterguide.sos.ca.gov*។

បោះឆ្នោតដោយសុវត្ថិភាពនៅទីតាំងបោះឆ្នោតមុនពេលកំណត់

ទីតាំងបោះឆ្នោតមុនពេលកំណត់មួយ ឬច្រើននឹងអាចប្រើប្រាស់បាននៅក្នុងខោនធីជាច្រើនសម្រាប់រយៈពេល **យ៉ាងតិចបួនថ្ងៃ** ចាប់ផ្តើមនៅថ្ងៃសៅរ៍មុនការបោះឆ្នោត **ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020**។ ទីតាំងបោះឆ្នោតនឹងផ្តល់ជូនការចុះឈ្មោះអ្នកបោះឆ្នោត សន្លឹកឆ្នោតជំនួស ម៉ាស៊ីនបោះឆ្នោតសម្រាប់ជនពិការ និងជំនួយផ្នែកភាសា។

អ្នកអាចជួយរក្សាទីតាំងបោះឆ្នោតឲ្យមានសុវត្ថិភាព សម្រាប់អ្នកបោះឆ្នោតនិងបុគ្គលិកបោះឆ្នោតតាមវិធីទាំងបីនេះ ៖

1 រំលងការតម្រង់ជួរ។

អ្នកអាចប្រគល់សន្លឹកឆ្នោតដែលបានបំពេញរួច **តាមសំបុត្រ** ដោយមិនចាំបាច់បោះត្រា នៅតាម **ប្រអប់ទម្លាក់សន្លឹកឆ្នោត**សុវត្ថិភាព ឬនៅតាម **ទីតាំងបោះឆ្នោត**។ ទីតាំងបោះឆ្នោតនឹងមានជួរ ដាច់ដោយឡែក សម្រាប់អ្នកបោះឆ្នោតទម្លាក់សន្លឹកឆ្នោតដែលបាន បំពេញ រួច។

ស្វែងរកប្រអប់ទម្លាក់សន្លឹកឆ្នោតដែលនៅជិត រឺទីតាំងបោះឆ្នោតនៅ *CAEarlyVoting.sos.ca.gov*

2 បោះឆ្នោតមុនពេលកំណត់។

ប្រសិនបើអ្នកទៅទីតាំងបោះឆ្នោតដោយផ្ទាល់ **សូមទៅមុនថ្ងៃបោះឆ្នោត** ដើម្បីជួយដល់ការរក្សាគម្លាតរាងកាយ។ ទីតាំងបោះឆ្នោតមួយ ឬ ច្រើននៅក្នុងខោនធីជាច្រើននឹងបើកសម្រាប់រយៈពេល **យ៉ាងតិចបួនថ្ងៃ** ចាប់ផ្តើមនៅថ្ងៃសៅរ៍មុនថ្ងៃបោះឆ្នោត។

3 អនុវត្តតាមទម្រង់ការសុវត្ថិភាព។

ការពារសុខភាពរបស់អ្នកនិងសុខភាពរបស់អ្នកបោះឆ្នោតផ្សេងទៀត និងបុគ្គលិកបោះឆ្នោតនៅទីតាំងបោះឆ្នោតដោយការប្រុងប្រយ័ត្នដូចខាងក្រោម៖

បញ្ជីត្រួតពិនិត្យសុវត្ថិភាពទីតាំងបោះឆ្នោត

- ☑ **ពាក់ម៉ាស** នៅពេលនៅទីតាំងបោះឆ្នោត។
- ☑ **រក្សាចម្ងាយប្រវែង 2 ដៃ** ពីអ្នកដទៃ។
- ☑ **លាងដៃ** មុននិងក្រោយចូលកន្លែងបោះឆ្នោត។
- ☑ **ប្រើប្រាស់ទឹកសម្លាប់មេរោគ** ក្រោយពេលប៉ះទ្វារ ឬឧបករណ៍បោះឆ្នោត។
- ☑ **យកបិចមកតាមខ្លួន** ដើម្បីជៀសវាងការប៉ះផ្ទៃ ដែលមានការប៉ះពាល់ច្រើន។

ចង់បានព័ត៌មានបន្ថែមអំពី របៀបរក្សាសុវត្ថិភាពនៅពេលបោះឆ្នោតឬ?
អានគោលការណ៍ណែនាំរបស់មជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រង និងបង្ការជំងឺតាម *www.cdc.gov/coronavirus/2019-ncov/community/election-polling-locations.html*

អ្នកបោះឆ្នោតដែលអាចបោះឆ្នោតតាមសំបុត្រ នឹងជួយធានានូវការរក្សាគម្លាតរាងកាយសុវត្ថិភាពនៅទីតាំងបោះឆ្នោត។ ការិយាល័យបោះឆ្នោតប្រចាំខោនធីនឹងចាប់ផ្តើមបញ្ជូនសន្លឹកឆ្នោតបោះតាមសំបុត្រ ទៅអ្នកបោះឆ្នោតនៅរដ្ឋ California ចាប់ពី **ថ្ងៃទី 5 ខែតុលា ឆ្នាំ 2020** តទៅ។ សន្លឹកឆ្នោតផ្ញើរមកវិញតាមសំបុត្រត្រូវមានតែមសម្គាល់ថាផ្ញើតាមប្រៃសណីយ៍នៅត្រឹម **ថ្ងៃទី 3 ខែ វិច្ឆិកា ឆ្នាំ 2020**។ សន្លឹកឆ្នោតដែលប្រគល់មកតាមប្រអប់ទម្លាក់សន្លឹកឆ្នោតសុវត្ថិភាព ត្រូវផ្ញើមកត្រឹម **ម៉ោង 8:00 p.m. នៅថ្ងៃទី 3 ខែ វិច្ឆិកា ឆ្នាំ 2020**។

បោះឆ្នោតដោយសុវត្ថិភាពជាមួយនឹងសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នក

អ្នកបោះឆ្នោតទាំងអស់នៅរដ្ឋ California នឹងទទួលសន្លឹកឆ្នោតបោះតាមសំបុត្រសម្រាប់ការបោះឆ្នោត នៅ **ថ្ងៃទី 3 ខែ វិច្ឆិកា ឆ្នាំ 2020**។ ការិយាល័យបោះឆ្នោតខោនធីរបស់អ្នក នឹងចាប់ផ្តើមផ្ញើរសន្លឹកឆ្នោតស្រដៀងនឹងរូបថតមួយ ខាង ក្រោមចាប់ពី **ថ្ងៃទី 5 ខែតុលា ឆ្នាំ 2020 តទៅ**។



ការបោះឆ្នោតតាមសំបុត្រគឺ *សុវត្ថិភាព* និង *ងាយស្រួល*។

ក្រោយពេលគូសជម្រើសរបស់អ្នកនៅលើសន្លឹកឆ្នោតអ្នកគ្រាន់តែ៖

☑ បិទស្រោមសំបុត្ร។

ដាក់សន្លឹកឆ្នោតរបស់អ្នក ទៅខាងក្នុងស្រោមសំបុត្រពីការិយាល័យបោះឆ្នោតខោនធីរបស់អ្នក។

☑ ចុះហត្ថលេខាលើវា។

ត្រូវប្រាកដថា *ហត្ថលេខានៅលើស្រោមសំបុត្រសន្លឹកឆ្នោតរបស់អ្នកត្រូវគ្នា* ទៅនឹងហត្ថលេខា នៅលើប័ណ្ណបើកបរ California របស់អ្នក ឬ ប័ណ្ណអ៊ីឌីប្រចាំរដ្ឋរបស់អ្នកឬ ហត្ថលេខាដែលអ្នកបានផ្តល់ នៅពេលចុះឈ្មោះ។ ការិយាល័យបោះឆ្នោត ប្រចាំខោនធីរបស់អ្នកនឹង ប្រៀបធៀបហត្ថលេខាទាំងនោះ ដើម្បីការពារ សន្លឹកឆ្នោតរបស់អ្នក។

☑ ផ្ញើរវាមកវិញ។

តាមសំបុត្រ—សូមប្រាកដថាសន្លឹកឆ្នោតរបស់អ្នកត្រូវបានសម្គាល់ថាផ្ញើតាមប្រៃសណីយ៍ នៅត្រឹម **ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020**។ មិនចាំបាច់បិទតែមទេ!

ឬ

ដោយផ្ទាល់ខ្លួន—ទម្លាក់សន្លឹកឆ្នោតរបស់អ្នកនៅប្រអប់ទម្លាក់សន្លឹកឆ្នោតដោយសុវត្ថិភាព ទីកន្លែងបោះឆ្នោត មជ្ឈមណ្ឌលបោះឆ្នោត ឬ ការិយាល័យបោះឆ្នោតប្រចាំខោនធីនៅត្រឹមម៉ោង **8:00 យប់ នៅថ្ងៃទី 3 ខែ វិច្ឆិកា ឆ្នាំ 2020**។

☑ តាមដានមើលវា។

អ្នក អាច ចុះឈ្មោះ នៅតាម អាសយដ្ឋាន *wheresmyballot.sos.ca.gov* ឬ សុំការជូនដំណឹងតាមសារអក្សរ (SMS) អ៊ីម៉ែល ឬ ការហៅទូរសព្ទជាសំឡេង អំពីស្ថានភាព នៃសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នក។

អ្នកបោះឆ្នោតដែលអាចបោះឆ្នោតតាមសំបុត្រនឹងជួយធានាការរក្សាចម្ងាយរាងកាយដោយសុវត្ថិភាពនៅទីតាំងបោះឆ្នោត។ ទីតាំងបោះឆ្នោតនឹងអាចប្រើប្រាស់បាន នៅក្នុងខោនធីទាំងអស់នៅមុនថ្ងៃបោះឆ្នោត។ ទីតាំងបោះឆ្នោតនឹងផ្តល់ជូនការចុះឈ្មោះ អ្នកបោះឆ្នោត សន្លឹកឆ្នោតជំនួស ម៉ាស៊ីនបោះឆ្នោតសម្រាប់ជនពិការ និង ជំនួយផ្នែកភាសា។

តើ សន្លឹកឆ្នោត ខ្ញុំ នៅ ឯណា?

រដ្ឋលេខាធិការនៃរដ្ឋ California បច្ចុប្បន្ននេះ កំពុងផ្តល់ជូនអ្នកបោះឆ្នោតនូវមធ្យោបាយថ្មីមួយដើម្បីតាមដាន និងទទួលបានការជូនដំណឹងអំពីស្ថានភាពការបោះឆ្នោតតាម សំបុត្រ។ ឧបករណ៍ "តើសន្លឹកឆ្នោតរបស់ខ្ញុំនៅកន្លែងណា?" អាចឲ្យអ្នកបោះឆ្នោតដឹងថាតើសន្លឹកឆ្នោតរបស់ពួកគេនៅកន្លែងណា ស្ថានភាពសន្លឹកឆ្នោត និងគ្រប់ជំហានទាំងអស់។ ចុះឈ្មោះតាម *WheresMyBallot.sos.ca.gov*។

នៅពេលអ្នកចុះឈ្មោះ "តើសន្លឹកឆ្នោតរបស់ខ្ញុំនៅកន្លែងណា?" អ្នកនឹងទទួលបានបច្ចុប្បន្នភាពនានាដោយស្វ័យប្រវត្តិ នៅពេលការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក៖

- ផ្ញើសន្លឹកឆ្នោតរបស់អ្នកតាមប្រៃសណីយ៍
- ទទួលបានសន្លឹកឆ្នោតរបស់អ្នក
- រាប់សន្លឹកឆ្នោតរបស់អ្នក ឬ
- ប្រសិនបើមានបញ្ហាជាមួយសន្លឹកឆ្នោតរបស់អ្នក។

អ្នកបោះឆ្នោត ដែលចុះឈ្មោះតាម *WheresMyBallot.sos.ca.gov* អាចជ្រើសរើសទទួលបានបច្ចុប្បន្នភាពនានាដោយស្វ័យប្រវត្តិតាម៖

- អ៊ីម៉ែល
- សារជាអក្សរ (SMS)
- ការហៅទូរស័ព្ទជាសំឡេង

ការតាមដានសន្លឹកឆ្នោតរបស់អ្នក —នៅពេលសន្លឹកឆ្នោតត្រូវបានផ្ញើតាមប្រៃសណីយ៍ ទទួលបាន និងរាប់— មិនធ្លាប់ងាយស្រួលជាងនេះទៀតទេ។

WheresMyBallot.sos.ca.gov

ការបោះឆ្នោតក្នុងរដ្ឋ California

ច្បាប់បោះឆ្នោតបឋមដោយបើកចំហរសម្រាប់បេក្ខជនកំពូលពីរនាក់ តម្រូវថាបេក្ខជនទាំងអស់សម្រាប់ដំណែងក្នុងការិយាល័យតែងតាំងដោយអ្នកបោះឆ្នោតត្រូវតែចុះឈ្មោះនៅលើសន្លឹកឆ្នោតតែមួយ។ កាលពីមុនត្រូវបានគេស្គាល់ថាជាការិយាល័យបក្សព័ន្ធ ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោតរួមមានការិយាល័យច្បាប់រដ្ឋ ការិយាល័យសភាសហរដ្ឋអាមេរិកនិងការិយាល័យរដ្ឋធម្មនុញ្ញរបស់រដ្ឋ។

ទាំងនៅក្នុងការបោះឆ្នោតបឋមដោយបើកចំហ និងការបោះឆ្នោតសកល អ្នកអាចបោះឆ្នោតជ្រើសរើសបេក្ខជនណាមួយ ដោយមិនគិតពីគណបក្សអាទិភាព ដែលអ្នកបានកំណត់យកនៅ លើទម្រង់ចុះឈ្មោះបោះឆ្នោតរបស់អ្នក។ នៅក្នុងការបោះឆ្នោតបឋម បេក្ខជនពីររូបដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេ - មិនគិតពីគណបក្សអាទិភាព - នឹងបន្តទៅប្រកួតក្នុងការបោះឆ្នោតសកល។ ប្រសិនបើបេក្ខជនទទួលបានសន្លឹកឆ្នោតភាគច្រើន (យ៉ាងតិច 50 ភាគរយ + 1) ការបោះឆ្នោតសកល នៅតែត្រូវធ្វើឡើង។

ប្រព័ន្ធបោះឆ្នោតបឋមបើកចំហរបស់រដ្ឋ California មិនអនុវត្តចំពោះបេក្ខជនដែលឈរឈ្មោះជាប្រធានាធិបតីសហរដ្ឋអាមេរិក គណៈកម្មធិការកណ្តាលប្រចាំខោនធី ឬ ការិយាល័យក្នុងតំបន់ទេ។

បេក្ខជនដែលគេសរសេរបញ្ចូលឈ្មោះ ក្នុងសន្លឹកឆ្នោតសម្រាប់ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោត នៅតែអាចឈរឈ្មោះនៅក្នុងការបោះឆ្នោតបឋម។ ប៉ុន្តែ បេក្ខជនដែលគេសរសរបញ្ចូលឈ្មោះក្នុងសន្លឹកឆ្នោតអាចបន្តទៅការបោះឆ្នោតទូទៅបានតែក្នុងករណីដែលបេក្ខជននោះ ស្ថិតក្នុងចំណោមបេក្ខជនណាម្នាក់នៃបេក្ខជនពីររូបដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេក្នុងការបោះឆ្នោតបឋមនោះ។ លើសពីនេះទៀត មិនមានដំណើរការតែងតាំងឯករាជ្យសម្រាប់ការបោះឆ្នោតទូទៅទេ។

ច្បាប់រដ្ឋ California តម្រូវឱ្យបោះពុម្ពព័ត៌មានដូចខាងក្រោមនៅក្នុងមគ្គុទ្ទេសក៍នេះ។

ការិយាល័យត្រូវបានតែងតាំងដោយគណបក្ស/ការិយាល័យបក្សព័ន្ធ

គណបក្សនយោបាយអាចតែងតាំងបេក្ខជនជាផ្លូវការសម្រាប់ការិយាល័យត្រូវបានតែងតាំងដោយ គណបក្ស/ការិយាល័យបក្សព័ន្ធនៅក្នុងការបោះឆ្នោតបឋម។ បេក្ខជនដែលទទួលបានការតែងតាំងនឹងធ្វើជាតំណាងគណបក្សនោះ ជាបេក្ខជនផ្លូវការសម្រាប់ ការិយាល័យជាក់លាក់ នៅក្នុងការបោះឆ្នោតទូទៅ ហើយសន្លឹកឆ្នោតនឹងឆ្លុះបញ្ចាំងចំពោះ ការកំណត់ ជាផ្លូវការ។ អ្នកដែលទទួលបានសន្លឹកឆ្នោតច្រើនបំផុត សម្រាប់គណបក្សនីមួយនៅក្នុងការបោះឆ្នោតបឋម នឹងបន្តទៅប្រកួតក្នុងការបោះឆ្នោតសកល។ គណបក្សក៏បោះឆ្នោតជ្រើសរើសមន្ត្រីនៃគណៈកម្មធិការកណ្តាលប្រចាំខោនធី នៅក្នុងការបោះឆ្នោត បឋមផងដែរ។

អ្នកបោះឆ្នោតអាចបោះឆ្នោតបានតែ នៅក្នុងការបោះឆ្នោតបឋមនៃគណបក្សនយោបាយ ដែលខ្លួនបានបង្ហាញអាទិភាពក្រោយពេល ចុះឈ្មោះដើម្បីបោះឆ្នោតតែប៉ុណ្ណោះ។ ទោះយ៉ាងណា គណបក្សនយោបាយអាចអនុញ្ញាតឲ្យបុគ្គលម្នាក់ ដែលបានបដិសេធការបង្ហាញ អាទិភាពគណបក្សបោះឆ្នោតបាន នៅក្នុងការបោះឆ្នោតបឋមរបស់គណបក្សនោះ។

សេចក្តីថ្លែងការស្តីពីការបោះឆ្នោតជ្រើសរើសប្រធានាធិបតីសហរដ្ឋអាមេរិកអាចរកបានតាមអនឡាញនៅ *voterguide.sos.ca.gov*

ការិយាល័យដែលត្រូវតែងតាំងដោយអ្នកបោះឆ្នោត

គណបក្សនយោបាយមិនមានសិទ្ធិតែងតាំងបេក្ខជនផ្លូវការសម្រាប់ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបឋមឡើយ។ បេក្ខជនដែលត្រូវបានតែងតាំងសម្រាប់ការិយាល័យ ដែលតែងតាំងដោយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបឋម គឺជាអ្នកដែលត្រូវបានតែងតាំងរបស់ពលរដ្ថ ហើយមិនមែនជាបេក្ខជនជាផ្លូវការនៃគណបក្សណាមួយ នៅក្នុងការបោះឆ្នោតសកលនោះទេ។ បេក្ខជនសម្រាប់ការតែងតាំងទៅការិយាល័យដែលត្រូវតែងតាំង ដោយអ្នកបោះឆ្នោតត្រូវមានការបញ្ជាក់ពីគណបក្សអាទិភាព ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬកង្វះគណបក្សអាទិភាពដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់របស់ខ្លួន នៅលើសន្លឹកឆ្នោត ប៉ុន្តែការកំណត់គណបក្សអាទិភាពត្រូវតែជ្រើសរើសដោយបេក្ខជន ហើយត្រូវបានបង្ហាញសម្រាប់តែជាព័ត៌មាននៃអ្នកបោះឆ្នោតតែប៉ុណ្ណោះ។ វាមិនមានន័យថាបេក្ខជនត្រូវបានតែងតាំង ឬគាំទ្រដោយគណបក្សដែលបានកំណត់ទេ ឬថាមានទំនាក់ទំនងរវាងគណបក្ស និងបេក្ខជន ហើយគ្មានបេក្ខជនណាដែល ត្រូវបានតែងតាំងដោយអ្នកបោះឆ្នោតត្រូវបានចាត់ ទុកថាជាបេក្ខជនដែលត្រូវបានតែងតាំងជាផ្លូវការ របស់គណបក្សនយោបាយណាមួយឡើយ។ នៅក្នុងមគ្គុទេសក៍ព័ត៌មានអ្នកបោះឆ្នោតក្នុងខោនធី គណបក្សអាចចុះបញ្ជីបេក្ខជនសម្រាប់ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោត ដែលបានទទួលការយល់ព្រមជាផ្លូវការពីគណបក្ស។

អ្នកបោះឆ្នោតណាមួយអាចបោះឆ្នោតជ្រើសរើសបេក្ខជនណាមួយសម្រាប់ការិយាល័យ ដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោតប្រសិនបើពួកគេបំពេញតាមលក្ខណសម្បត្តិផ្សេងទៀត ដែលតម្រូវឱ្យបោះឆ្នោតសម្រាប់ការិយាល័យនោះ។ អ្នកទទួលសម្លេងឆ្នោតពីររូបកំពូលក្នុងការបោះឆ្នោតបឋម បន្តទៅការបោះឆ្នោតសកលសម្រាប់ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោត ថ្វីបើជាបេក្ខជនទាំងពីរបានបញ្ជាក់ពីគណបក្សអាទិភាពដូចគ្នាក៏ដោយ។ គ្មានគណបក្សណាមានសិទ្ធិឱ្យបេក្ខជនដែលកំណត់គណបក្សអាទិភាពរបស់ខ្លួនបន្តទៅការបោះឆ្នោតទូទៅបានទេ លើកលែងតែបេក្ខជនណាម្នាក់ស្ថិតក្នុងចំណោមបេក្ខជនពីររូបដែលទទួលបានសន្លឹកឆ្នោតច្រើនជាងគេនៅក្នុងការបោះឆ្នោតបឋម។

ការិយាល័យគ្មានបក្សព័ន្ធ

គណបក្សនយោបាយមិនមានសិទ្ធិតែងតាំងបេក្ខជនសម្រាប់ការិយាល័យគ្មានបក្សព័ន្ធ នៅក្នុងការបោះឆ្នោតបឋមទេ ហើយបេក្ខជននៅឯការបោះឆ្នោតបឋមមិនមែនជាបេក្ខជនជាផ្លូវការ សម្រាប់គណបក្សណាមួយសម្រាប់ការិយាល័យជាក់លាក់នៅការបោះឆ្នោតសកលទេ។ បេក្ខជនសម្រាប់ការតែងតាំងឱ្យទៅការិយាល័យ គ្មានបក្សព័ន្ធអាចមិនកំណត់គណបក្សអាទិភាព ឬខ្វះគណបក្សអាទិភាពរបស់ខ្លួន នៅលើសន្លឹកឆ្នោត។ បេក្ខជនពីររូបដែលទទួលសម្លេងឆ្នោតច្រើនជាងគេក្នុងការបោះឆ្នោតបឋមនឹងបន្តទៅការបោះឆ្នោតសកលសម្រាប់ការិយាល័យគ្មានបក្សព័ន្ធ។

អ្នកបរិច្ចាគកំពូលៗទៅលើ បេក្ខជនរដ្ថ និងវិធានការសន្លឹកឆ្នោត

នៅពេលគណៈកម្មាធិការ (មនុស្ស ឬក្រុមមនុស្ស ដែលទទួល ឬចំណាយលុយក្នុងគោលបំណងជះឥទ្ធិពលដល់អ្នកបោះឆ្នោតដើម្បីគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬវិធានការសន្លឹកឆ្នោត) គាំទ្រ ឬប្រឆាំងវិធានការសន្លឹកឆ្នោត ឬបេក្ខជន និងរៃអង្គាសប្រាក់យ៉ាងតិច $1 លានដុល្លារ គណៈកម្មាធិការត្រូវរាយការណ៍ពី អ្នកបរិច្ចាគកំពូលៗទាំង 10 របស់ខ្លួនទៅគណៈកម្មការអនុវត្តនយោបាយយុត្តិធម៌នៃរដ្ថ California (California Fair Political Practices Commission, FPPC)។ គណៈកម្មាធិការត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះកំពូលទាំង 10 នៅពេលមានការផ្លាស់ប្តូរ។

ខ្ពស់ ជាងគេ 10 $

បញ្ជីទាំងនេះអាចរកបាននៅលើគេហទំព័ររបស់ FPPC *នៅ*
http://www.fppc.ca.gov/transparency/top-contributors.html

ការចុះឈ្មោះអ្នកបោះឆ្នោត

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ អ្នកមិនចាំបាច់ចុះឈ្មោះសារជាថ្មីទេ ***លើកលែងតែ*** អ្នកប្តូរឈ្មោះ អាសយដ្ឋានផ្ទះ អាសយដ្ឋានអ៊ីមែលរបស់អ្នក ឬប្រសិនបើអ្នកចង់ ប្តូរ ឬជ្រើសរើសគណបក្សនយោបាយណាមួយ។.

អ្នកអាចចុះឈ្មោះបោះឆ្នោតតាមអនឡាញនៅ *registertovote.ca.gov* ឬ ទូរស័ព្ទទៅបណ្តាញទាន់ហេតុការណ៍អ្នកបោះឆ្នោតឥតគិតថ្លៃរបស់រដ្ឋលេខាធិការតាមលេខ (888) 345-4917 ដើម្បីឲ្យគេផ្ញើទម្រង់បែបបទមកអ្នកតាមប្រៃសណីយ៍។

ពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោតអាចរកបាននៅការិយាល័យប្រៃសណីយ៍ភាគច្រើន បណ្ណាល័យ ការិយាល័យរដ្ឋាភិបាលក្រុង និងខោនធី ការិយាល័យបោះឆ្នោតខោនធី និងការិយាល័យរដ្ឋលេខាធិការ រដ្ឋ California។

ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ

ក្នុងអំឡុងពេល 14 ថ្ងៃ មុនថ្ងៃបោះឆ្នោត និងរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោត អ្នកអាចទៅការិយាល័យមន្ត្រីបោះឆ្នោតប្រចាំខោនធីរបស់អ្នក មណ្ឌលបោះឆ្នោត ឬកន្លែងបោះឆ្នោតដើម្បីចុះឈ្មោះបោះឆ្នោតដោយមានលក្ខខណ្ឌហើយទៅបោះឆ្នោត។ ដើម្បីស្វែងយល់បន្ថែម សូមចូលទៅ *sos.ca.gov/elections/voter-registration/same-day-reg/*។

ព័ត៌មានស្តីពីឯកជនភាពការចុះឈ្មោះអ្នកបោះឆ្នោត

កម្មវិធីចុះឈ្មោះអ្នកបោះឆ្នោតជាសម្ងាត់នៅផ្ទះដោយមានសុវត្ថិភាព៖ អ្នកបោះឆ្នោតមួយចំនួនដែលកំពុងប្រឈមនឹងស្ថានភាពគំរាមកំហែងដល់អាយុជីវិត (ពោលគឺជនរងគ្រោះ និងអ្នករស់រានពីអំពើហិង្សាក្នុងគ្រួសារ ការឈ្លបចាប់ ការបៀតបៀនផ្លូវភេទ ការជួញដូរមនុស្ស ការរំលោភបំពានមនុស្សចាស់/មនុស្សពេញវ័យក្នុងបន្ទុក) អាចមានគុណសម្បត្តិគ្រាប់គ្រាន់សម្រាប់ឋានៈជាអ្នកបោះឆ្នោតសម្ងាត់ ប្រសិនបើពួកគេជាសមាជិកសកម្មនៃកម្មវិធីសុវត្ថិភាពនៅផ្ទះ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកម្មវិធីសុវត្ថិភាពនៅផ្ទះរបស់រដ្ឋលេខាធិការតាមលេខទូរស័ព្ទមិនគិតថ្លៃ (877) 322-5227 ឬចូលទៅកាន់ *sos.ca.gov/registries/safe-home/*។

ឯកជនភាពនៃព័ត៌មានអ្នកបោះឆ្នោត៖ ព័ត៌មានអំពីសំបុត្របញ្ជាក់ការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកនឹងត្រូវបានប្រើដោយមន្ត្រីបោះឆ្នោតដើម្បីផ្ញើឱ្យអ្នកនូវព័ត៌មានផ្លូវការអំពីដំណើរការបោះឆ្នោត ដូចជាទីតាំងនៃកន្លែងបោះឆ្នោត និងបញ្ជា និងបេក្ខជននានាដែលនឹងលេចឡើងលើសន្លឹកឆ្នោត។ ការប្រើប្រាស់ព័ត៌មានការចុះឈ្មោះអ្នកបោះឆ្នោតសម្រាប់ពាណិជ្ជកម្ម គឺត្រូវបានហាមឃាត់ ដោយច្បាប់ និងមានទោសកម្រិតមជ្ឈិម។ ព័ត៌មានអ្នកបោះឆ្នោតប្រហែលជាត្រូវបានផ្តល់ទៅបេក្ខជនសម្រាប់មុខតំណែង គណៈកម្មាធិការវិធានការសន្លឹកឆ្នោត ឬជនដទៃទៀតសម្រាប់ការបោះឆ្នោត សម្រាប់គោលបំណងលក្ខណៈសិក្សាស្រាវជ្រាវ សារព័ត៌មាននយោបាយ ឬរដ្ឋាភិបាល ដូចដែលត្រូវបានសម្រេចដោយរដ្ឋលេខាធិការ។ ប័ណ្ណបើកបរ លេខសន្តិសុខសង្គម ឬ ហត្ថលេខារបស់អ្នក ដូចដែលបានបង្ហាញលើប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក មិនត្រូវអាចបញ្ចេញសម្រាប់គោលបំណងទាំងនេះទេ។ ប្រសិនបើអ្នកមានសំណួរទាក់ទងនឹងការប្រើប្រាស់ព័ត៌មានអ្នកបោះឆ្នោត ឬមានបំណងចង់រាយការណ៍អំពីការប្រើប្រាស់ខុសលើព័ត៌មានទាំងនេះ ដែលគួរអោយសង្ស័យ សូមទូរស័ព្ទទៅបណ្តាញទាន់ហេតុការណ៍អ្នកបោះឆ្នោតឥតគិតថ្លៃរបស់រដ្ឋលេខាធិការតាមលេខ (888) 345-4917។

ចុះឈ្មោះទុកជាមុននៅអាយុដប់ប្រាំមួយឆ្នាំ។ បោះឆ្នោតនៅអាយុដប់ប្រាំបីឆ្នាំ។

ការចុះឈ្មោះជាមុនអាចរកបានតាមអនឡាញសម្រាប់អ្នកមានអាយុ 16 ឆ្នាំនិង 17 ឆ្នាំដែលមានសិទ្ធិនៅគេហទំព័រ *registertovote.ca.gov* ឬតាមរយៈទម្រង់បែបបទចុះឈ្មោះជាក្រដាស។ យុវជនរដ្ឋ California ដែលបានចុះឈ្មោះបោះឆ្នោតជាមុននឹងធ្វើឱ្យការចុះឈ្មោះរបស់ពួកគេសកម្មឡើងវិញ នៅពេលពួកគេមានអាយុ 18 ឆ្នាំ។

ចុះឈ្មោះជាមុន ក្នុងជំហាន 4 យ៉ាងងាយស្រួល៖

1. ចូលទៅកាន់ *registertovote.ca.gov*។
2. ចុចប៊ូតុង "ចុះឈ្មោះជាមុនដើម្បីបោះឆ្នោត"។
3. ក្លាយជាអ្នកបានចុះឈ្មោះដោយស្វ័យប្រវត្តិនៅថ្ងៃកំណើតគំរប់ 18 ឆ្នាំរបស់អ្នក។
4. ធ្វើការបោះឆ្នោតនៅថ្ងៃបោះឆ្នោត!

តើការចុះឈ្មោះជាមុនគឺជាអ្វី?

ប្រសិនបើអ្នកមានអាយុ 16 ឬ 17 ឆ្នាំ ហើយបំពេញគ្រប់លក្ខខណ្ឌសិទ្ធិអ្នកបោះឆ្នោតផ្សេងទៀត អ្នកអាចចុះឈ្មោះបោះឆ្នោតជាមុននៅ *registertovote.ca.gov*។

គ្រាន់តែបំពេញពាក្យសុំចុះឈ្មោះជាមុនតាមអនឡាញ ហើយនៅចំថ្ងៃកំណើតគំរប់ 18 ឆ្នាំរបស់អ្នក អ្នកនឹងត្រូវបានចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិ។

របៀបបោះឆ្នោតតាមសំបុត្រប្រៃសណីយ៍

តើនរណាខ្លះអាចបោះឆ្នោតតាមប្រៃសណីយ៍បាន?

អ្នកបោះឆ្នោតគ្រប់រូបដែលបានចុះឈ្មោះរួច នឹងទទួលបានសន្លឹកឆ្នោតបោះតាមប្រៃសណីយ៍មួយសន្លឹកសម្រាប់ការបោះឆ្នោតជាសាកលថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020។ មន្ត្រីបោះឆ្នោតប្រចាំខោនធី នឹងចាប់ផ្តើមផ្ញើសន្លឹកឆ្នោតតាមប្រៃសណីយ៍ទៅកាន់អ្នកបោះឆ្នោតឲ្យបានមុនថ្ងៃទី 5 ខែតុលា ឆ្នាំ 2020។ ប្រសិនបើអ្នកមិនទទួលបានសន្លឹកឆ្នោតបោះតាមប្រៃសណីយ៍របស់អ្នក ឬត្រូវការស្នើសុំការជំនួសថ្មី សូមទាក់ទងការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក។ ព័ត៌មានទំនាក់ទំនងការិយាល័យការបោះឆ្នោតខោនធី អាចរកឃើញនៅ *sos.ca.gov/elections/voting-resources/county-elections-offices*។

របៀបបញ្ជូនសន្លឹកឆ្នោតបោះឆ្នោតតាមប្រៃសណីយ៍របស់អ្នកត្រឡប់មកវិញ

បន្ទាប់ពីបានគូសជម្រើសរបស់អ្នកនៅលើសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នករួចរាល់ហើយ សូមដាក់វានៅក្នុងស្រោមសំបុត្រផ្លូវការដែលផ្តល់ជូនដោយការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក រួចបិទវាឲ្យជិត។ **ចុះហត្ថលេខា** លើស្រោមសំបុត្រនៅពេលត្រូវបានណែនាំ។ អ្នកមានជម្រើសជាច្រើនសម្រាប់បញ្ជូនសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញ។

ដើម្បីធានាសន្លឹកឆ្នោតរបស់អ្នកមកដល់តាមកាលកំណត់ សូមបញ្ជូនវាត្រឡប់មកវិញ៖

- តាមប្រៃសណីយ៍—ត្រូវតែវាយត្រាប្រៃសណីយ៍លើសំបុត្រនៅថ្ងៃទី ឬមុនថ្ងៃទី **3 ខែវិច្ឆិកា** និងបានទទួលដោយការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នកមិនឲ្យយឺតជាងថ្ងៃទី **20 ខែវិច្ឆិកា។ មិនតម្រូវឲ្យមានថ្លៃតែមប្រៃសណីយ៍ឡើយ!**
- ដោយផ្ទាល់—យកមកដាក់នៅការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក ឬនៅមណ្ឌលបោះឆ្នោត កន្លែងបោះឆ្នោត ឬទីតាំងទម្លាក់សន្លឹកឆ្នោតនៅរដ្ឋ California មុនពេលការិយាល័យបោះឆ្នោតបិទទ្វារនៅម៉ោង 8:00 យប់ នៅថ្ងៃទី 3 ខែវិច្ឆិកា។

ច្បាប់រដ្ឋផ្តល់សេរីភាពដល់អ្នកបោះឆ្នោតក្នុងការចាត់តាំងនរណាម្នាក់តាមការជ្រើសរើសរបស់ពួកគេឲ្យបញ្ជូនសន្លឹកឆ្នោតបោះឆ្នោតតាមសំបុត្ររបស់ពួកគេមកវិញ។ ទោះជាយ៉ាងណា យើងសូមណែនាំឲ្យអ្នកគ្រាន់តែចុះហត្ថលេខាលើសន្លឹកឆ្នោតដែលបានបំពេញរួចរបស់អ្នក ហើយប្រគល់ឲ្យនរណាម្នាក់ដែលអ្នកជឿទុកចិត្ត។ ហើយមិនត្រូវប្រគល់សន្លឹកឆ្នោតបោះឆ្នោតតាមសំបុត្ររបស់អ្នកទេ ប្រសិនបើអ្នកមិនទាន់បានបិទជិត និងចុះហត្ថលេខានៅលើខ្នងស្រោមសំបុត្រដែលផ្តល់ជូនដោយការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក។

ទោះបីជាអ្នកបានទទួលសន្លឹកឆ្នោតបោះតាមសំបុត្រ និងស្រោមសំបុត្ររបស់អ្នកក៏ដោយ អ្នកនៅតែអាចបោះឆ្នោតដោយផ្ទាល់នៅកន្លែងបោះឆ្នោតរបស់អ្នកនៅថ្ងៃបោះឆ្នោត។ យកសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នកមកកាន់កន្លែងបោះឆ្នោត ហើយឲ្យវាទៅបុគ្គលិកការិយាល័យបោះឆ្នោតដើម្បីដោះដូរជាមួយនឹងសន្លឹកឆ្នោតនៅកន្លែងបោះឆ្នោត។ ប្រសិនបើអ្នកមិនមានសន្លឹកឆ្នោតបោះតាមសំបុត្រ និងស្រោមសំបុត្ររបស់អ្នកទេនោះ អ្នកអាចនឹងបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្នបាន។ នេះធានាថា អ្នកនៅមិនទាន់បានបោះឆ្នោតរួចនៅឡើយទេ។

ខោនធីទាំងអស់ផ្តល់ជម្រើសដែលអាចទទួលយកបានមួយហៅថាការបោះឆ្នោតតាមសំបុត្រដែលអាចយកបានពីចម្ងាយ (RAVBM)។ RAVBM អនុញ្ញាតឲ្យអ្នកបោះឆ្នោតដែលជាជនពិការទទួលបានសន្លឹកឆ្នោតរបស់ពួកគេនៅផ្ទះ និងគូសជ្រើសរើសដោយឯករាជ្យ និងឯកជន មុនពេលផ្ញើវាត្រឡប់មកកាន់មន្ត្រីបោះឆ្នោតវិញ។ សូមទាក់ទងមន្ត្រីបោះឆ្នោតប្រចាំខោនធីរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។

លទ្ធផល នៃការ
បោះឆ្នោត សាកល

ចង់ឃើញលទ្ធផលនៃការបោះឆ្នោតជាសាកលនៅថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020 បន្ទាប់ពីការិយាល័យបោះឆ្នោតបិទទ្វារនៅម៉ោង 8:00 យប់ដែរឬទេ? ចូលទៅកាន់គេហទំព័រប្រកាសលទ្ធផលបោះឆ្នោតរបស់រដ្ឋលេខាធិការរដ្ឋ California តាម *electionresults.sos.ca.gov*។

គេហទំព័រប្រកាសលទ្ធផលការបោះឆ្នោតគឺត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់ប្រាំនាទីនៅយប់ថ្ងៃបោះឆ្នោត នៅពេលខោនធីរាយការណ៍លទ្ធផលទៅរដ្ឋលេខាធិការ។ មន្ត្រីបោះឆ្នោតប្រចាំខោនធីផ្ញើលទ្ធផលបោះឆ្នោតពាក់កណ្តាលផ្លូវការទៅកាន់គេហទំព័ររបស់រដ្ឋលេខាធិការ បន្ទាប់ពីការិយាល័យបោះឆ្នោតបិទទ្វារនៅម៉ោង 8:00 យប់ និងបន្តផ្ញើរការធ្វើបច្ចុប្បន្នភាពយ៉ាងហោចណាស់រៀងរាល់ពីរម៉ោងម្តង រហូតទាល់តែសន្លឹកឆ្នោតនៅថ្ងៃបោះឆ្នោតត្រូវបានរាប់អស់។

ចាប់ផ្តើមនៅថ្ងៃទី 5 ខែវិច្ឆិកា រហូតដល់ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2020 គេហទំព័រប្រកាសលទ្ធផលបោះឆ្នោតនឹងធ្វើបច្ចុប្បន្នភាពជារៀងរាល់ថ្ងៃនៅម៉ោង 5:00 ល្ងាច ខណៈដែលខោនធីរាប់សន្លឹកឆ្នោតដែលនៅសេសសល់។

លទ្ធផលជាផ្លូវការនៃការបោះឆ្នោតនឹងត្រូវបានប្រកាសផ្សាយនៅត្រឹមថ្ងៃទី 11 ខែធ្នូ ឆ្នាំ 2020 តាម *sos.ca.gov/elections/*។

ជំនួយសម្រាប់អ្នកបោះឆ្នោតជាជនពិការ

រដ្ឋ California ប្តេជ្ញាចិត្តធានាថា អ្នកបោះឆ្នោតគ្រប់រូបអាចបោះឆ្នោតបានប្រកបដោយឯកជនភាព និងឯករាជ្យភាព។

សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀតអំពីជំនួយ ដែលខោនធីរបស់អ្នកផ្តល់ជូនអ្នកបោះឆ្នោតជាជនពិការ សូមពិនិត្យមើលមគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតក្នុងខោនធីរបស់អ្នក ឬទាក់ទងខោនធីរបស់អ្នក។ ព័ត៌មានទំនាក់ទំនង ខោនធីគឺមានជូននៅ *sos.ca.gov/elections/voting-resources/county-elections-offices*។

ការបោះឆ្នោតនៅកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោត

ប្រសិនបើអ្នកត្រូវការជំនួយគូសសន្លឹកឆ្នោតរបស់អ្នក អ្នកអាចជ្រើសយករហូតដល់មនុស្សពីរនាក់ ដើម្បីជួយអ្នក។ បុគ្គលនេះមិនអាចជា៖

- និយោជករបស់អ្នក ឬនរណាម្នាក់ ដែលធ្វើការឱ្យនិយោជករបស់អ្នកឡើយ
- មេដឹកនាំសហជីពកម្មករបស់អ្នក ឬនរណាម្នាក់ ដែលធ្វើការឱ្យសហជីពការងាររបស់អ្នក

ការបោះឆ្នោតនៅចិញ្ចើមផ្លូវ អាចឱ្យអ្នកចតនៅជិតកន្លែងបោះឆ្នោតបំផុតតាមដែលអាចធ្វើទៅបាន។ មន្ត្រីបោះឆ្នោតនឹងយកបញ្ជីឈ្មោះឲ្យអ្នកចុះហត្ថលេខា សន្លឹកឆ្នោតមួយ និងសម្ភារៈបោះឆ្នោតឯទៀត ដែលអ្នកត្រូវការ មិនថាអ្នកនៅក្បែរគែមចំណតឬនៅក្នុងឡានក្តី។ សូមទាក់ទងមកការិយាល័យបោះឆ្នោតរបស់អ្នក ដើម្បីសាកសួរថាតើមានការផ្តល់ជូនការបោះឆ្នោតលើចិញ្ចើមផ្លូវនៅទីកន្លែងឬមជ្ឈមណ្ឌលបោះឆ្នោតរបស់អ្នកឬទេ។

គ្រប់កន្លែងបោះឆ្នោត និងមណ្ឌលបោះឆ្នោតទាំងអស់ តម្រូវឲ្យមានការបង្កលក្ខណៈងាយស្រួលសម្រាប់ ជនពិការអាចចូលទៅបោះឆ្នោតបាន ហើយនឹងមានម៉ាស៊ីនបោះឆ្នោតដែលអាចចូលប្រើបាន។

ការបោះឆ្នោតនៅផ្ទះ

ប្រព័ន្ធបោះឆ្នោតតាមសំបុត្រពីចម្ងាយ (RAVBM) ផ្តល់នូវ ជម្រើសអាចធ្វើបានសម្រាប់អ្នកបោះឆ្នោតជាជនពិការ ដើម្បីទទួលសន្លឹកឆ្នោតរបស់ខ្លួននៅឯលំនៅដ្ឋាន ហើយគូសវាដោយឯករាជ្យ និង ដោយឯកជនមុននឹងផ្ញើវាទៅមន្ត្រីផ្នែកបោះឆ្នោត។ សូមទាក់ទងមន្ត្រីបោះឆ្នោតប្រចាំខោនធីរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។

សៀវភៅមគ្គុទេសក៍ព័ត៌មានអ្នកបោះឆ្នោតបោះពុម្ពជាអក្សរធំៗ ឬជាសម្លេង

សៀវភៅមគ្គុទេសក៍នេះអាចរកបានជាទម្រង់បោះពុម្ពអក្សរធំៗ និងជាសម្លេង។ សៀវភៅមគ្គុទេសក៍នេះក៏អាចរកបានដោយមិនគិតថ្លៃជាភាសាអង់គ្លេសភាសាចិន ភាសាហិណ្ឌូ ភាសាជប៉ុន ភាសាខ្មែរ ភាសាកូរ៉េ ភាសាអេស្ប៉ាញ ភាសាតាហ្គាឡុក ភាសាថៃ និងភាសាវៀតណាមផងដែរ។

ដើម្បីស្នើសុំ៖

- សូមទូរស័ព្ទទៅបណ្តាញទាន់ហេតុការណ៍អ្នកបោះឆ្នោតដោយមិនគិតថ្លៃរបស់រដ្ឋលេខាធិការតាមលេខ (888) 345-4917
- ចូលទៅកាន់ *voterguide.sos.ca.gov*
- ទាញយកទម្រង់ជាសំលេង MP3 នៅ *voterguide.sos.ca.gov/audio/km*

កាលបរិច្ឆេទត្រូវចងចាំ!

★★★

California Secretary of State
Elections Division
1500 11th Street
Sacramento, CA 95814

NONPROFIT
U.S. POSTAGE
PAID
CALIFORNIA
SECRETARY
OF STATE

OFFICIAL ELECTION MAIL
Authorized by the U.S. Postal Service

ចោះឆ្នោតដោយសុវត្ថិភាពនៅរដ្ឋ CALIFORNIA

All California voters will receive a vote-by-mail ballot for the November 3, 2020, election. Learn more inside.
English: (800) 345-VOTE (8683) **TTY/TDD: (800) 833-8683**

អ្នកបោះឆ្នោតទាំងអស់ក្នុងរដ្ឋ California នឹងទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រសម្រាប់ការបោះឆ្នោតនៅថ្ងៃទី **3 ខែវិច្ឆិកា ឆ្នាំ 2020** ។ សម្រាប់សំណួរ ឬជំនួយអ្នកបោះឆ្នោត សូមហៅមកលេខខាងក្រោម ។
ខ្មែរ/Khmer: (888) 345-4917

Todos los votantes de California recibirán una boleta electoral de voto por correo para la elección del 3 de noviembre de 2020. Para preguntas o asistencia al votante, llame al número a continuación.
Español/Spanish: (800) 232-VOTA (8682)

모든 캘리포니아 유권자는 **2020**년 **11**월 **3**일 선거를 위한 우편 투표지 받게 됩니다. 문의 사항 또는 유권자 지원을 원하시면, 아 래 전화번호로 연락해주십시오.
한국어**/Korean: (866) 575-1558**

所有加州選民將收到用於 **2020** 年 **11** 月 **3** 日選舉的郵寄投票選票。如有疑問或需要提供選民協助，請致電下列號碼。
中文**/Chinese: (800) 339-2857**

Tatanggap ang lahat ng botante ng California ng balota para sa pagboto sa pamamagitan ng koreo para sa halalan sa Nobyembre 3, 2020. Para sa mga katanungan o tulong sa botante, mangyaring tawagan ang numero sa ibaba.
Tagalog: (800) 339-2957

कैलिफोर्निया के सभी मतदाताओं को **3 नवंबर, 2020** के चुनाव के लिए 'डाक-द्वारा-मतदान करें' मतपत्र प्राप्त होगा। प्रश्नों या मतदाता सहायता के लिए, कृपया नीचे दिए गए नंबर पर कॉल करें।
हिन्दी **/Hindi: (888) 345-2692**

ผู้ออกเสียงลงคะแนนในรัฐแคลิฟอรเนียทุกคนจะ ได้รับบัตรเลือกตั้งประเภทลงคะแนนเสียงผานทาง ไปรษณียสำหรับการเลือกตั้ งที่จะจัดขึ้นในวันที่**3** พฤศจิกายน **2020** หากมีขอสงสัยหรือตองการความชวยเหลือ โปรดโทรติดตอหมายเลขดานลาง
ภาษาไทย **/Thai: (855) 345-3933**

すべてのカリフォルニア州有権者には 2020 年 11 月 3 日選挙の郵便投票用紙が送られます。お問 い合わせまたは有権者の支援に関しては、以下 の番号までお電話ください。
日本語 **/Japanese: (800) 339-2865**

Tất cả các cử tri California đều sẽ nhận được lá phiếu bầu bằng thư cho kỳ bầu cử vào **ngày 3 tháng Mười Một, 2020.** Nếu có thắc mắc hoặc cần giúp về bầu cử, xin gọi số điện thoại dưới đây.
Việt ngữ **/Vietnamese: (800) 339-8163**

OSP 20 150162

KHMER